ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

សៀវភៅទស្សនាវដ្ដីចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

ឆ្នាំគំរប់ ១១

ខ្សែ ១, ២, ៣, រួមគ្នា

កុង្សីយសេនាបតីបានអនុញ្ញាតហើយ

សម្ដេចសង្ឃនាយកទាំងពីរគណៈយល់ព្រម

ព្រះរាជបណ្ណាល័យកម្ពុជា

BIBLIOTHEQUE ROYALE DU CAMBODGE

ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MOEURS & COUTUMES

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព. ស. ២៤៨១

គ. ស. ១៩៣៩

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

## សៀវភៅទស្សនាវដ្ដីចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

ឆ្នាំគំរប់ ១១

ខ្សែ ១, ២, ៣, រួមគ្នា

កុង្ស៊ីយសេនាបតីបានអនុញ្ញាតហើយ

សម្ដេចសង្ឃនាយកទាំងពីរគណៈយល់ព្រម

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព. ស. ២៤៨១

គ. ស. ១៩៣៩

CEDORE
No 1479

# បញ្ជីរឿង


ទំព័រ

១ — ទឹកទន្លេសាប របស់ថ្មី គិម-ហាក់ . . . . . . . . . . . . . . . . . ៥

២ — ដំណឹងផ្សេង . . . . . . . . . . . . . . . . . . . . . . . . ៣៣

៣ — ប្រជុំពាក្យកាព្យភាគទី ១ ព្រះរាជនិពន្ធព្រះបាទសម្តេចព្រះស្រីធម្មរាជា (ត
ទី ៣) . . . . . . . . . . . . . . . . . . . . . . . . . ៣៩

៤ — ជាតុរង្គបទ បទទី ៤ (តចប់) . . . . . . . . . . . . . . . . . . ៥៣

៥ — រឿងថៅកាំបិតបន្ទោះ (មានត) . . . . . . . . . . . . . . . . . . ៦៣

៦ — ទំនៀមទម្លាប់ខ្មែរ:
ពិធីថ្វាយបង្គំអារ . . . . . . . . . . . . . . . . . . . . . . ៧៩


## រូបក្រៅរឿង


រូបភិក្ខុនីឈ្មោះវេដិក៏ (ជាតិអង់គ្លេស) នៅស្រុកសាណាជី ប្រទេសឥណ្ឌា.. ១

# TABLE DES MATIÈRES

Pages.

1° — L'eau du Tonlé Sap par Kim Hak (premier roman moderne du Cambodge)........................... 5

2° — Informations diverses........................... 33

3° — Anthologie cambodgienne par Préas Bat Samdach Préas Sreythammaréachéa (suite)........................... 39

4° — Caturangapāda par Moha Krasem (suite et fin)......... 53

5° — Contes populaires cambodgiens inédits "Chau Kombet Bantos" ou le couteau miraculeux (à suivre)......... 63

6° — Mœurs et coutumes cambodgiennes :

Prosternation devant S. M. le Roi lors de la réception d'un grade de dignitaire offert par Elle.................. 79

## HORS TEXTE

Portrait de la Bhikkhuni Vajira de Sarnath........... 1



នេះរូបភិក្ខុនីឈ្មោះវជិរ៉ា នៅស្រុកសារណាថ
(ប្រទេសឥណ្ឌា)

# ប្រទេសនល្ហោ

ភិក្ខុនីឈ្មោះវេដិក៏" មានកំណើតជាជាតិអង់គ្លេសជាបុត្រីរបស់អ្នកមានត្រកូលខ្ពង់ខ្ពស់មួយ នៅប្រទេសអង់គ្លេស នាងមានសេចក្តីស្រឡាញ់ពេញចិត្តនឹងលទ្ធិពុទ្ធសាសនាពន់ពេក ។ កាលនាងនៅប្រទេសអង់គ្លេស នាងធ្វើជាសមាជិកមួយរបស់សមាគមមហាពោធិ ហើយនាងលះបង់សេចក្តីថ្កើងថ្កៃប្រកាន់ខ្លួនជាវិស័យរបស់បុថុជ្ជន ដើម្បីប្រតិបត្តិខ្លួនជាសាវិការបស់ព្រះសម្ពុទ្ធជាម្ចាស់ ហេតុដូច្នេះ បានជានាងកាត់សំពៅទៅស្រុកសីឡង់ នៅក្នុងស្រុកនេះ ចំនួនពីឆ្នាំកន្លះ ហើយនាងទៅតាំងទីលំនៅ ៗ ស្រុកសារណាថ ក្នុងឆ្នាំ ១៩៣៦ នេះ ទើបនាងបានទទួលពិធីបួស (ជានាងភិក្ខុនី) ដូចយើងមើលឃើញក្នុងរូបខាងមុខនេះ ។

នាងភិក្ខុនីនេះបានឮដំណឹងគេនិយាយពីពុទ្ធសាសនបណ្ឌិត្យ (ស្រុកយើងនេះ) ក៏ប្រឹងនឹងមកស្រុកខ្មែរ យើងមានសង្ឃឹមទុកជាមុនថា បណ្តាស្ត្រីរួមជាតិរបស់យើងនឹងចាត់ចែងទទួលដោយមេត្រីចិត្តមិនខាន ។

ពីការឧទ្ទេសរាយ

របស់ប៊ី គិម-ហាក់ លេខានុការក្រសួងប្រៃសណីយ៍

(ប៉ុស្តិ៍ខ្សែលួស) បានតែងរៀបរៀង

# អារម្ភកថា

រឿង "ទឹកទន្លេសាប" នេះកើតឡើងដោយសារចិត្តខ្ញុំទ្រុឌទ្រោមស្រពោនស្រពាន់ គិតសង្វេគដល់អក្សរសាស្ត្រខ្មែរយើងដែលពុំសូវចំរើនរុងរឿង សព្វថ្ងៃនេះអវិជ្ជាដែលមកបិទបាំងជាតិខ្មែរទាំងអស់គ្នា កាន់តែស្តើង ៗ បន្តិច ៗ ទៅហើយ ដោយគុណបំណាច់មហានគរបារាំងសែស បានដឹកនាំវិជ្ជាការទាំងឡាយមកឲ្យបណ្តារាស្ត្រ កម្ពុជរដ្ឋនេះ ។

អ្នកប្រាជ្ញដែលឈ្លាសខាងអក្សរសាស្ត្រនោះ មានតិចណាស់ ហើយគ្មានពេលឱកាសទៀតធ្វើរឿងរ៉ាវអ្វីក្រៅអំពីជួយព្រះពុទ្ធសាសនា ឲ្យបានចំរើនរុងរឿងក្នុងស្រុកប៉ុណ្ណឹង បើប្រសិនណា មានអ្នកទៀតធ្វើបានវិញក៏ពុំជាការកុបតឹនប៉ុន្មាន មកពីជាតិយើងខុសពីជាតិឥរុបទឹងជាតិអាមេរិកឆ្ងាយណាស់ ជាតិអស់នោះគេប្រឹងព្យាយាមបង្កើតរបស់ដែលមានប្រយោជន៍ដល់សាធារណជន· មានធ្វើរបស់ដែលគ្មានក្នុងលោកនេះឲ្យមានឡើងបាន ឬធ្វើរបស់ឯណា ដែលមានហើយឲ្យរឹតតែល្អប្រសើរប្រណីតទៅទៀត ពីព្រោះគេមានសេចក្តីសាមគ្គីសមគ្គា ជួយជ្រោមជ្រែងគ្នា ហើយគេបានកំចាត់បង់នូវសេចក្តីខ្ជិលទ្រមក់ពីខន្ធសន្តាន នៅប្រទេសឥរុបក្តី អាមេរិកក្តី អ្នកដែលមានភោគសម្បត្តិល្មមគ្រប់គ្រាន់ ចិញ្ចឹមជីវិតខ្លះ គេមិនសូវមកធ្វើការរាជការទេ គេទុកឲ្យអ្នកកំសត់ទុគ៌តធ្វើ គេប្រឹងដេកដើរ

អង្គុយគិតបង្កើតរបស់ផ្សេង ៗ   ឬសរសេរតែងរឿងធ្វើសៀវភៅឲ្យបាន ច្រើនមុខជាប្រយោជន៍ដល់ជាតិនឹងផែនដីគេ   ម្ល៉ោះហើយវិជ្ជាទាំងឡាយ ក៏មានការសពេញទាំងស្រុកអាចធ្វើឲ្យស្រុកអស់នោះ   មានបុណ្យានុភាព ក្លៀវក្លា សត្រូវទាំងឡាយក៏មិនហ៊ានមកពាលាប្រមាថមើលងាយបាន ៗ

ឯខ្ញុំដែលប្រឹងតែងរឿងនេះ មកពីមានសេចក្តីប្រាថ្នាពីរប្រការ :

១ បំបាត់ពាក្យរបស់អ្នកតាំងប្រទេស   ដែលចេះភាសាខ្មែរយើង បន្តិចបន្តួចថា ខ្មែរគ្មានសៀវភៅរឿងក៏អ្វីមើលស្រួលពុំបាន មានច្រើន តែសៀវភៅធម៌ ជាតកប្រវត្តិរឿងព្រះពុទ្ធកាលនៅជាពោធិសត្វនៅឡើយ ច្រើនតែងជាពាក្យកាព្យនាំឲ្យអ្នកចេះខ្មែរតិច ៗ មើលពុំយល់ ៗ

២ លើកបង្ហាញទោសដែលកើតឡើង ដោយកាមគុណាធ្វើឲ្យសត្វ លិចលង់ក្នុងវដ្តសង្សារនេះ ៗ

ខ្ញុំមានសេចក្តីសង្ឃឹមជាមុនថា លោកអ្នកដែលមើលឬស្តាប់រឿងនេះ គ្មានសេចក្តីចោទប្រកាន់ថា  ខ្ញុំធ្វើរឿងនេះ  ដើម្បីនឹងបណ្តុះបណ្តាលទូវ កតាមកិលេស របស់លោកអ្នកនោះទេ ៗ

ក្នុងអវសាននេះ   ខ្ញុំសូមថ្លែងសេចក្តីអំណរអរគុណដល់អ្នកស្រីការ ប៉ីឡែស អគ្គលេខាធិការពុទ្ធសាសនបណ្ឌិត្យ ដោយជួយយករឿងនេះទៅ កាន់ពុម្ពបាន   អ្នកស្រីនេះមានចិត្តស្រឡាញ់ជាតិសាសនាខ្មែរយើងនេះ ណាស់ ៗ

# ទឹកទន្លេសាប

## ឈុតទី ១

ចៅហេមស័យនឹងចៅសត្តា ចង់បាននាងម៉ាល៉ាជាភរិយា កាលអំពីអតីតប្រព្រឹត្តកន្លងទៅហើយ ក្នុងរាជ្យព្រះកេតុមាលាជាម្ចាស់ជីវិតលើត្បូង កាលប្រាសាទអង្គរទាំងឡាយទើបនឹងកើតឡើងថ្មីៗ ប្រកបដោយគ្រឿងចម្លាក់ចេទាដ៏ល្អវិចិត្រទឹបសុទ្ធតែមាសតាសពេញ ជាទីគួរអស្ចារ្យពន់ពេកណាស់ គួរឲ្យជាតិខេមរៈសព្វថ្ងៃនេះមានសេចក្តីសោកស្តាយនូវរបស់អស់នោះដែលបាត់បែកអស់ជាងពាក់កណ្តាលទៅហើយ គួរឲ្យមានចិត្តខំប្រឹងរៀនសូត្រឲ្យចេះដឹងដូចជាតិខ្លួនកាលជាន់នោះ ខំធ្វើដោយស្នាដៃខ្លួនឲ្យកើតប្រាសាទឯណាទីមួយឲ្យយ៉ាងល្អ ល្មមទុកជាកេរ្តិ៍ឲ្យខ្មែរជាន់ក្រោយទៀតបាន ឲ្យអ្នកតាំងប្រទេសដែលគេមកមើលនគរកម្ពុជា មានសេចក្តីស្ងើច ៗ

ក្នុងវដ្តកាលនោះ មានបុរសម្នាក់ឈ្មោះសីណាប្រពន្ធឈ្មោះបុប្ផាផាន់ មានកូនស្រីក្រមុំមួយរូបយ៉ាងល្អឈ្មោះម៉ាល៉ា ៗ នាងម៉ាល៉ា អាយុបាន ១៨ ឆ្នាំ ប្រុសកំឡោះៗ មានចិត្តស្រឡាញ់នាងនោះស្ទើរតែគ្រប់គ្នា តែមិនដឹងធ្វើដូចម្ដេចនឹងទៅជិតបាន ពីព្រោះនាងនោះប្រកបដោយលក្ខណភរិយាស្រគត់ស្រគំ មិនជាអ្នកល្ហើល្ហាចឡើយ ប៉ុន្តែនាងម៉ាល៉ាមានបុរសពីរនាក់ប្រាថ្នាចង់បានធ្វើជាភរិយា មួយនោះឈ្មោះ ហេមស័យ

មួយទៀតឈ្មោះសត្វា ចៅហៅមស័យជាកូនអ្នកកំសត់ទុគ៌ត ប៉ុន្តែមាន គំនិតមារយាទត្រឹមត្រូវ ជាអ្នកសុភាពរាបទាបគួរសមដឹងចាស់ព្រឹទ្ធាចារ្យ វិជ្ជាក៏មានបេះប្រកបការរកស៊ីចិញ្ចឹមជីវិតឪពុកម្តាយចាស់ ៗ បាន ឯចំ-ណែកចៅសត្វា ជាកូនអ្នកមានសម្បត្តិស្តុកស្តម្ភ ឪពុកងារជាព្រះសេនា-វិជ័យ មេកងទ័ពព្រះកេតុមាលា ។ ទ្រង់សព្វព្រះរាជហឫទ័យស្រឡាញ់ ព្រះសេនាវិជ័យពន់ពេកណាស់ ទ្រង់យកឲ្យទៅនៅក្នុងព្រះបរមរាជវាំង ជាមួយ ចៅសត្វា ជាកូនបានទៅរៀនសិល្បសាស្ត្រឯស្រុកកូមារបេះ ដឹងជ្រៅឆ្ងាយទូលាយ តែមានចិត្តពាលហើនគោរពកាចអាងបុណ្យទ្រព្យ សម្បត្តិឪពុកម្តាយ គ្មានគោរពខ្លាចអ្នកណាមួយសោះ ក្រៅអំពីម្ចាស់ ផែនដីនឹងព្រះរាជវង្សានុវង្ស ចៅហៅមស័យនឹងចៅសត្វា បាននិយាយ ឲ្យឪពុកម្តាយរៀងខ្លួនទៅដណ្តឹងនាងម៉ាណ៉ាមួយលើកទៅហើយ តែមាតា បិតានាងនេះមិនទាន់បានសំរេចព្រមឲ្យកូនទៅឈ្មោះណាទេ ។

## ឈុតទី ២

ចៅសីណា នាងបុប្ផាផាន់ រើសកូនប្រសា

ព្រះសុរិយាអស្តង្គតលេចអស់ពន្លឺ មេឃខ្មៅងងឹត ព្រះពាយផាត់ ពពកខ្ចាត់ខ្ចាយ មែកព្រឹក្សាទាំងឡាយបាក់បែកខ្ទេចខ្ទី បក្សាបក្សីមាន សេចក្តីរន្ធត់ហើរចាកចោលទ្រនំ មនុស្សក្នុងភូមិក៏តក់ស្លុតដោយខ្យល់

ព្យុះព្យាមា គួរឲ្យវេទនាណាស់ ទូកនាវាខ្លះនៅក្នុងសមុទ្របាក់ខ្ទេច លិចលង់វិនាសដល់ជីវិតមនុស្សដែលជិះនៅក្នុងនោះផង ។

អ្នកស្រុកនៅជិតប្រាសាទអង្គរ មានសេចក្ដីភិតភ័យនឹងព្យុះខ្យល់នេះដល់យូរបន្តិចទៅព្រះពិរុណក៏ធ្លាក់មកលើពសុធា ខ្យល់បានស្បើយ អាកាសក្លាយទៅជាត្រជាក់ស្រួល ផ្គរលាន់ឮសូរធំស្ដាប់ទៅគួរចង់យំណាស់ ។

ក្នុងវេលាដែលកើតកោលាហលនោះ ចៅសីណា និងនាងបុប្ផាជាប្រពន្ធមានចិត្តញាប់ញ័ររត់ឆ្វេឆ្វាពេញតែផ្ទះ ដល់ខ្យល់ព្យុះអស់ទៅជនទាំងពីរនាក់ត្រេកអរពន់ពេក បើកទ្វារមើលមេឃស្រែកថា អើយើងស្រួលវិញហើយ រួចក៏នាំគ្នាទៅដេកក្នុងបន្ទប់និយាយលេងជាកំសាន្តសប្បាយ ។

សីណា — ប្អូនអើយនាងស្ដាប់ចុះ សូរផ្គរលាន់ព្រាំពងញ័ររអើសពសុធា ឱ គួរសង្វេគណាស់ យើងគ្មានកូនប្រុសសោះ មានតែកូនស្រីមួយ ដូចត្រយឹពទូក ឥឡូវនេះថែមទាំងប្រុស ៗ រវដណ្ដើមគ្នាចង់បានទៀត មិនដឹងធ្វើដូចម្ដេចទេ ប្អូនអើយប្អូន កូនយើងមីនាងម៉ាលា រូបរាងកាន់តែល្អឡើង ៗ សំបុរក៏កាន់តែស្រស់មិនចាំបាច់លាបរមៀតម្សៅទេ នេះហើយបាននាំឲ្យអាហោមស័យនឹងអាសត្ថា រាស៊ីប្ដូរជីវិតដណ្ដើមគ្នា ដណ្ដឹងយកជាភរិយា រឿងនេះតាមចិត្តបង ១ ចង់រៀបចំអាពាហ៍ពិពាហ៍កូនយើង

ឲ្យឆាប់ទៅ  ទុកយូរក្រែងកើតសៅហ្មង  តែតែបែកបៀងវែងឆ្ងាយទៅទៀត  ផ្ទះណាមានកូនស្រីល្អ  ផ្ទះនោះនាំឲ្យកំឡោះមកកុះករ  ដូចជាផ្កាទាំងឡាយនាំឲ្យសត្វឃ្មុំមកបោមពេមជានិច្ច  ណាប្អូនណា ។

បុប្ផាផាន់ – ចាស  អ្នកបងមានប្រសាសន៍នេះបំផាត់ពេញចិត្តខ្ញុំណាស់  ខ្ញុំសព្វថ្ងៃធុញទ្រាន់នឹងកូនស្រីនេះដែរ  ទៅណាមកណាមិនហ៊ានខ្លាចក្រែងប្រុសៗ មកប្រមាថមើលងាយ  មេមាន់ញញាបាលកូនក៏បែបហ៊ឹងពកា  ខ្ញុំគប់គ្រងកូនស្រីខ្ញុំយ៉ាងនោះដែរ  នៃអ្នកបង  តាមចិត្តអ្នកគេថាចៅហោមស័យនេះមួយ  ចៅស្តានេះមួយ  អ្នកយកគាណា  ឯចំណែកខ្ញុំយល់ឃើញថា  ចៅហោមស័យពិតមែនតែកូនអ្នកមិនសូវប្រកបដោយយសនឹងសម្បត្តិ  តែត្រង់កិរិយាទឹងមារយាទគ្មានប្រុសណាមកស្មើបានទេក៏ជាអ្នករកស៊ីធ្វើការគ្មានឈប់ឈរ  មិនចេះដើរលេងផ្តេសផ្តាស  ចំណែកខាងចៅស្តាវិញពិតមែនជាអ្នកចេះដឹង  ឪពុកម្តាយមានបុណ្យទ្រព្យសម្បត្តិច្រើន  តែជាបុកពាក់ក្មេងក្មាងកោងកាចលើសបន្ទាត់  ញញាក់ញញ័រដូចជាសត្វពានរ  ខុសឆ្ងាយពីចៅហោមស័យណាស់ ។

សំណា – នឹមើលចុះធ្វើជាមនុស្សម៉ែនដឹងរបស់ល្អរបស់អាក្រក់មិនបង់បានថ្លៃ  បង់បានតែថោក ។  គិតតបងខុសពីប្អូនឯង  ចៅស្តាត្រកូលក៏ខ្ពស់សម្បត្តិក៏មាន  ចំណោះគេគំរប់បុណ្យ  ដល់ថ្ងៃក្រោយកដការទឹងពាត់

ឲ្យទៅឈរត្រួតត្រាខែត្រមួយមិនខាន បើប្រសិនណា បើយើងព្រមឲ្យកូនទៅចៅនេះ ច្បាស់ជាយើងបានធំធាត់ខ្ពស់មុខនឹងគេមួយគ្រានេះ ។

បុប្ផាផាន់– យីអ្នកបង ល្អអាក្រក់ ថ្លៃថោកខ្ញុំស្គាល់ណាស់ តែខ្ញុំមកគិតអាណិតកូន មិនចង់ឲ្យកូនវេទនា ឪពុកម្តាយតែងស្វែងរកសុខឲ្យកូនជានិច្ច តែតោងមើលនាយមើលអាយឲ្យស្រួលបួលផង ប្រយ័ត្នក្រែងបែរជាឲ្យទុក្ខគ្នាវិញ ធម្មជាតិជាអ្នកធំ បងអើយបង គំនិតគេច្រើនរបិញរបុញណាស់ គេអាងសម្បត្តិអាងបំណោះ គេមិនសូវយល់មុខយើងអ្នកក្រប៉ុន្មានទេ ប្រពន្ធវិញ បើគេស្រឡាញ់ផ្ដេកផ្ដិតអស់ចិត្តអស់ថ្លើមគេហើយ គេច្រើនឆាកបែរទៅរកប្ដីពីរបីទៀត ឯកិរិយាដើមនោះច្បាស់ជាជូតទឹកភ្នែកកាលយប់ពុំខានឡើយ បើអ្នកតូចជួបគ្នានេះចំជាស្រួលណាស់ មើលចុះដូចជារូបបងនឹងរូបខ្ញុំ សុខអើយសុខ ស្រួលអើយស្រួលទាំងយប់ទាំងថ្ងៃគ្មានទុក្ខអ្វីសោះ ។

សីណា – ឱពុទ្ធោអើយពុទ្ធោ នេះបានចំជាភាបតៀនទាលដូចជាសត្វពា មិនចង់បានខ្ពស់នឹងគេសោះ កូនស្រីរូបល្អយ៉ាងហ្នឹងចង់ឲ្យមានប្តីអ្នកក្រ គួរណាស់តែឲ្យគ្នាបានធ្វើជាលោកស្រីនឹងគេបានម្តង យ៉ាងតំរក់ណាស់បីឆ្នាំក៏យកដែរ មិនគួរឲ្យគ្នាទៅអ្នករកស៊ីធ្វើការរហេមរហាមសោះ ។

បុប្ផាផាន់ – យីធំអ្វីម៉្លេះ ធ្វើជាលោកស្រី ខ្ញុំសព្វថ្ងៃចង់ខ្ពស់ណាស់ ប៉ុន្តែខ្ញុំខ្លាច ក្រែងដូចគេថា ឡើងទៅដល់ពពកចុះមកដេកឯអាចម៍ជន្លេន

វិញ ដូចជារូបនាងសាវុន កូនពូកែម-មិនគួយ កាលពីដើមនាងសាវុន យកប្ដីព្រះអង្គម្ចាស់មួយ ជិះស្ទូតែរទេះឡាន ដល់បានមួយវស្សា ពោះធំប៉ុនចង្អេរ មកអង្គុយលក់ចេកអាំងនៅជ្រុងកំពង់ធ្វើក្លិះ ៗ មានសំពត់តែមួយចង្កេះ ឆ្អេះពេញខ្លួន ហើយកាលពីខែមុននេះឆ្លងទន្លេ រកតែលុយទិញខ្ទះសកំដៅខ្លួនមិនបានផង មើលតើខ្ពស់ ឬទាបអ្នកបង ៗ

ស៊ីណា — អើខ្ពស់មួយដង ទាបមួយដង ណ្ហើយកុំនិយាយច្រើនពេក ប្រយ័ត្នតិចល្បងលើកម៉ីម៉ាលាៈទៅឲ្យលោកកុងស៊ែយក្មេងម្នាក់ តិចលហៅកូនឯង នៃលោកជំទាវ... នៃគំនិតប្រុសមិនដូចស្រីទេ បើប្រុសគំនិតមិនកើត គេយកស្រីឲ្យធ្វើការពេញក្រសួងការទៅហើយ គេឲ្យស្រីត្រួតត្រាលើប្រុសវិញ មែនឬទេ ៗ

បុប្ផាវ៉ាន់ — ឱកម្មអើយកម្ម ខ្ញុំពិបាកចិត្តណាស់ពិតមែនតែប្រុសមានគំនិតញឹកញាប់ជាងស្រី តែបាមានបួនកាលគ្នាដោយសេចក្ដីលោភមកគ្របសង្កត់ម្ដង ៗ មិនខាន បើកតែព្រះសម្ពុទ្ធជាម្ចាស់ទីងព្រះអរហន្តខណាស្រីពេលបេញ ទើបអកុសលធម៌នេះ មកបៀតបៀនពុំបាន តាមបវេណីពីដើមរៀងមក ខ្មែរយើងទុកដាក់កូនស្រីត្រូវតែម្ដាយ កូនប្រុសត្រូវតែឪពុក តែវេលានេះ បើបង់ចូលចិត្តឲ្យទៅទៅសត្វា ខ្ញុំក៏មិនព្រមដាច់ខាត ខ្ញុំសុំបិត្តអ្នកបរិមង្គលផុះ ពីព្រោះតាំងតែពីយើងបានចាប់ដៃប្ដូរខ្លួយជាមួយគ្នាមិនដែលបានទាស់អង្គស្រីយនឹងគ្នាម្ដងសោះ ទើប

តែគ្រានេះហើយ ពីព្រោះខ្ញុំស្រឡាញ់កូនស្រីណាស់ សូមបងករុណាគិតប្អូនម្តងកុំខាន ។

សីណា — យើម៉ែអើយម៉ែ នេះបំផាសែនវិបាក ឯងចង់ខ្ពស់ គេចង់ទាប ឯងមិនចង់សៀបប្រៀប គេចង់តែកញ្ចះគេ មិនគួរសោះ មីនាងកូនឯអើយ នេះគឺកម្មកូនពីអតីតតាមមកដល់ នែប្អូន កូនមួយនេះ បងលែងរស់ហើយ ស្រេចតែលើប្អូនឯង ដល់ថ្ងៃអាពាហ៍ពិពាហ៍ បងមិនខ្ចីស៊ីភោជនាហារទេ បងខ្មាសគាំងពីមនុស្សប្រហែលដល់ខ្មោច កូនរូបល្អយ៉ាងហ្នឹងមិនគួរឲ្យមានប្តីអ្នកក្រសោះឡើយ ។

បុប្ផាផាន់ — ធ្វើដូចម្តេច បើបងមិនព្រមនៅរៀបចំអាពាហ៍ពិពាហ៍កូនស្រី ខ្ញុំមិនហ៊ានឃាត់ខាំងទេ ទៅតាមបុត្តបុះ ធ្វើដូចម្តេចជាអកុសលរបស់កូនយើង មានឪពុកហាក់ដូចគ្មាន នួរអាណោចអាធម្មណាស់ ណ្ហើយចាំខ្ញុំទុកក្បាលជ្រូក ផ្ញើទុំទុកឲ្យបងពិសា ដល់បាត់ខឹងត្រឡប់មកផ្ទះវិញ ។

សីណា — បងឈឺចិត្តណាស់ បង់បានអ្វីមិនបានដូចប្រាថ្នា ការនេះត្រូវតែហៅកូនស្រីយើងមកសួរចិត្តវាសិន ដល់ថ្ងៃក្រោយកុំឲ្យវាមានពាក្យបន្ទោសថាខូចខាតខ្លួន ដោយសារតែម៉ែឪទុកដាក់ឲ្យមានប្តីមិនត្រូវគនូង ។

បុប្ផាផាន់ – បាស ខ្ញុំចូលចិត្តណាស់ ថាហើយក៏ដើរម្នីម្នាចូលទៅ ក្នុងបន្ទប់កូនក្រមុំខ្លួន បក់ដៃហៅឲ្យចេញមកក្រៅ នាងម៉ាលាក៏ចេញមក អង្គុយស្រគត់ស្រគំជិតមាតាបិតា ។

ស៊ីណា – អើកូនអញឥឡូវនេះ ល្អអីល្អ សអីស រកស្រីណាឲ្យល្អ ជាងកូនអញគ្មានទេ នែកូនស្រីស្ងួនឪពុក ឪសព្វថ្ងៃនេះមានចិត្តចង់ ឲ្យកូនមានប្ដីណាស់ មានគេពីរនាក់មកដណ្ដឹង មួយឈ្មោះហោមស៊័យ មួយទៀតឈ្មោះសុគ្គា អាហោមស៊័យជាកូនអ្នកកំសត់ទុគ៌តទេ តែគំនិត ត្រឹមត្រូវ ឯអាសុគ្គាវិញ កូនអើយកូន ឪពុកម្ដាយវាមានបុណ្យស័ក្ដិ ទ្រព្យសម្បត្តិច្រើនណាស់ ចំណេះវាក៏មានច្រើនផង ប៉ុន្តែធ្វើដូចម្ដេចកូន អ្នកធំច្រើនវិលខ្លួចបន្តិច តែល្មមអធ្យាស្រ័យបាន ហើយដល់ផុតខែនេះ ទៅ ចូលខែក្រោយ ពួកការទើងតាំងឲ្យធ្វើមេទាយក ខែត្រមួយយ៉ាងធំ មើលមនុស្សទាំងពីរនាក់នេះ តើកូនចូលចិត្តយកអ្នកណា និយាយ ឲ្យដាច់ខាតឲ្យស្រេចទៅ កុំឲ្យឪពុកបំបែងចិត្តកាលទិនទំពេក ។

បុប្ផាផាន់ — នែកូនស្រីម៉ែតែមួយ ការនេះត្រូវកូនគិតឲ្យមែនទែន ក្រែងលោធ្លោះធ្លោយគំនិត បែរបន្ទោសថា ម៉ែមិនជួយគិត ឯម៉ែចង់ ឲ្យកូនបានសុខខ្ពស់មុខមាត់នឹងគេណាស់ ក្រែងតែវាសនាកូនទៅពុំដល់ ។

ម៉ាលា — ខ្ញុំសូមជំរាបលោកឪ លោកម៉ែ បុរសទាំងពីរនាក់កូនក៏ មិនដែលស្គាល់មុខសោះទេ ចិត្តកូនស្រឡាញ់តែឈ្មោះហោមស៊័យនេះទេ

ពីព្រោះគំនិតសម្បត្តិធនធានស្មើនឹងយើង ហើយគេគ្មានហ៊ានមើលងាយយើងផង សេចក្ដីសុខ-ចម្រើនទើបនឹងកើតមានឡើងមិនខាន ៗ

សីណា — ឱប្រុសអើយប្រុស នេះចំជាកូនម៉ែ មិនមែនកូនឪ ទើបគំនិតត្រូវនឹងម៉ែក៏បែបហ្នឹង កូននេះចំជាឈាមកប់ មិនមែនឈាមអណ្ដែត ចំជាកូនទាមិនមែនកូនមាន់ ច្បាស់ជាមកពីស្ថាននរក មិនមែនមកពីស្ថានទេវតាទេ ណ្ហើយតាមកម្មចុះ អញលែងស្ដីនិយាយទៀត ហើយ ឯងស៊ីក្រសៃម៉ែឯងចុះ ៗ

បុប្ផាផាន់ — អើនេះ បានចំជាកូនស្រីម៉ែ ទើបគំនិតត្រូវគ្នា បេះទុកមុខមាត់ឲ្យម្ដាយឪពុក គ្រាន់បើជាងកូនស្រីគេឯទៀត ៗ

សីណា - ទុកមុខឲ្យម៉ែចុះ ឪមិនត្រូវការទេ ៗ

បុប្ផាផាន់ - ប្រយ័ត្នក្រែងទៅរកពឹងកូន តិចទៅរកលុយកាចាយ រកប៉ាយកាពិសា ៗ

សីណា - មិនខ្វី អញស៊ូអត់ឲ្យស្ងួតដូចកន្ត្របខែប្រាំង អញពីដើមនិយាយសុទ្ធតែនាងអ្នក ឥឡូវចង់តែប្រទេចផ្កាសា អញក្ដៅក្រហាយណាស់ មានប្រពន្ធកូន បេះដូង ស្លូត ពោះវៀន ថ្លើមខុសគ្នា ឯងនិយាយថា នៅខាងលិច គេនិយាយថា នៅខាងកើត ឯងចង់ឲ្យគេមានកំណើត គេចង់តែលិចកណ្ដាលដី ៗ

បុប្ផាផាន់- ប្រយ័ត្នស៊ិត ៗ ទៅ ពិបាកកូននិមន្តលោកសូត្រធម៌ ធ្វើបុណ្យឧទ្ទិសផលជូនឲ្យ ។

សីណា - អញមិនត្រូវការទេ អញបួស ១០ វស្សាហើយ ក្បាលទំពែកប្រាសត្រងោលអស់ហើយ ធម៌អញរៀនសូត្រខ្ទេចខ្ទី មិនបាច់ឲ្យអ្នកណាសូត្រឲ្យស្តាប់ទៀតទេ បុណ្យក៏អញបានធ្វើញឹកញាប់ណាស់ដែរ អញមិនតោងការ ឲ្យអាណាធ្វើឲ្យអញទៀតទេ បើតាមចិត្តអញ ៗ ផ្តាច់ពីអាពីរនាក់នេះ មីម៉ាលាអាណាក៏អញមិនឲ្យ អញយកទៅថ្វាយស្តេចឲ្យវាបានធ្វើជាឃុនព្រះម្នាង យ៉ាងតិចត្រឹម ១ ខែក៏អញយកដែរ តែថាសេចក្តីផ្រាត់សង្សារគេនេះ មានបាបក្រាស់ណាស់ ណ្ហើយតាមយថា-កម្មាចុះ ឈប់និយាយ ។

# ឈុតទី ៣

## ការអាពាហ៍ពិពាហ៍ចៅហេមស័យនឹងម៉ាលា

ចៅហេមស័យនឹងនាងម៉ាលាមានចិត្តកួចកាន់ស្រឡាញ់គ្នារៀងខ្លួន ទឹកថា នុអាត្មាអញអើយ ពេលវេលាក៏កាន់តែជិតដល់ណាស់ទៅហើយ កាលនៅលីវនៅឡើយ មានរូបតែ ១ ខ្លួនតែប្រាំ ដល់បន្តិចទៀត រូបពីរខ្លួនដប់ ដល់មានកូនទៅទៀត រូបកាន់តែច្រើន ខ្លួនកាន់តែច្រើន នុគួរនិច្ចាសត្វក្នុងវដ្តសង្សារយើងនេះអើយ ប៉ុន្តែការនេះវៀរពុំរួច គេចពុំផុត

ដូចជាស្រមោលតែងអន្ទោលទៅតាមប្រាណ តែសត្វសកុណជាតិ ក៏គង់តែមានឈ្មោលញីដែរ ។

ដល់កំណត់ថ្ងៃមង្គលការ ញាតិសន្តានទាំងពីរខាងមកជួបជុំគ្នាផ្សំផ្គុំចៅហេមស័យនឹងនាងម៉ាលា ខានតែឪពុកខាងស្រីនៅតែកាន់ចិត្តគំនុំគុំគួន មិនព្រមមកចូលដៃកូន ប្រឹងដើរចូលទៅក្នុងវត្ត អង្គុយឱបក្បាលផង្គង់ធ្វើក្ងុំះៗ ក្រោមកុដិលោកគ្រូសង្ឃរាជ រហូតពិធីការអាពាហ៍ពិពាហ៍កូន ទើបត្រឡប់មកផ្ទះវិញ ។

នៅថ្ងៃដែលបុរសនឹងស្ត្រីពល់គ្នាបានរួបរួមប្រាណគ្នា ជាបឋមបង្អស់នោះគឺវេលាដែលរួមខ្នើយ ផ្សំដំណេក នាងម៉ាលាក៏នាំប្ដីចូលទៅកាន់បន្ទប់ខ្លួនរៀបពូកខ្នល់ខ្នើយឲ្យស្វាមីយ៉ាងល្អស្អាត ហើយនាំគ្នាប្រាសដេកនិយាយលេង ចរចារអំពីរឿងរ៉ាវផ្សេងៗ ដល់ពេលព្រះចន្ទត្រង់ កាលណោះមានមហាកុដង្គនាគពជមួយធំសម្បើមក្តៅក្រហាយ ក្នុងព្រះចិន្តាប្រឹងលូនចេញម្នីម្នាពីក្នុងព្រះធរណី ចុះមកប្រភាគលេងក្នុងមហាសមុទ្របង្អួរទឹកភ្លៀងធ្លាក់ពេញលើពសុធា ចៅហេមស័យនឹងនាងម៉ាលា ញ័រញាក់ត្រជាក់ដល់ដួងហឫទ័យ រឹងរិតតែស្នេហាគ្នាតទៅទៀត រួចហើយចៅហេមស័យលួងលោមភរិយាឲ្យដេក ដោយយប់កាន់តែជ្រៅណាស់ទៅហើយ ច្រៀងបំពេប្រពន្ធថា :

អូនអើយអូនមើលព្រះចន្ទ្រា  រះក្នុងមេឃរាត្រីថ្ងៃ
ដូចជាចិត្តបងសោមនស្សា  បានរួមដំណេកនឹងមាសថ្លៃ
ព្រះពាយព្រឹងបោកពពកបាត់  ដូចបងបានឃ្លាតពីទុក្ខភ័យ
ដោយហេតុបានខ្លួនស្ងួនថ្លៃ  មាសថ្លៃដូចប្រើមផន់រៀមក៏
អូនស្ដាប់សព្ទសូរមាន់រងាវ  ស្រែកហៅកញ្ច្រៀវពេញភូមិណា
លួមអូនគន់គូបកែវកនិដ្ឋា  គេងទៅពៅណាយប់យូរហើយ ។

នាងម៉ាលាបានស្ដាប់ពាក្យប្ដីលួងលោមឲ្យដេកដូច្នោះហើយ ក៏មានចិត្តរីករាយ ចំណេញនេត្រាទាំងសងដេកលង់លក់ទៅ ដល់ជិតភ្លឺនាងយល់និមិត្តមួយប្លែកអស្ចារ្យណាស់ យល់ហាក់ដូចជាតាចាស់ម្នាក់កាន់កាំបិតយ៉ាងមុតស្រួច មកវះយកថ្លើមប្រុះហើយដើរទៅខាងទិសនិរតីបាត់ទៅ ដល់យូរបន្តិចតាចាស់ដដែលនេះ កាន់យកនូវថ្លើម មកដាក់ឲ្យដូចដើមវិញ មានចិត្តភិតភ័យពេកណាស់ ភ្ញាក់ឡើងដាស់ស្វាមីនិយាយប្រាប់សព្វគ្រប់ប្រការ ចៅហែមស័យក្រោកអង្គុយសញ្ជឹងស្ដាប់ ពិចារណានូវសុបិននិមិត្តគិតឃើញថា នេះប្រាកដជាមានសេចក្ដីព្រាត់ប្រាសដល់អញនឹងប្រពន្ធមិនខានទេឡើយ ប៉ុន្តែយូរទៅនឹងបានជួបគ្នាវិញ បើអញនិយាយប្រាប់នាងនេះដោយត្រង់ សមជាក់នឹងសោកសៅកើតទុក្ខមិនខាន បើដូច្នេះត្រូវអញកុហកវាយកលនិយាយបង្វែរទៅវិញ ទើបបែរទៅកៀកប្រពន្ធបីថ្នមដាក់លើភ្លៅ ហើយនិយាយថា កែវអើយ និមិត្តនេះជា

មង្គលល្អណាស់ ដែលឃើញថា តាចាស់មកកាត់យកថ្មើមនោះ នោះគឺជាបញ្ហាឲ្យនាងដឹងថា កាលអ្នកឯងនៅក្រមុំនៅឡើយ រូបរាងលោមពណ៌សង់តែល្អស្អាត ចិត្តក៏គ្មានរើរកយកណាទៀត ឥឡូវនាងមានប្តីហើយ កែវអើយរូបរាងនាងក៏កាន់តែអួនថយទៅដោយនូវការផ្សេង ៗ តែត្រង់ថា ឃើញតាចាស់នោះ យកថ្មើមមកដាក់ឲ្យវិញនោះ គឺថាដល់យូរបន្តិចទៅប្អូននឹងមានរូបរាងល្អដូចពីដើមវិញ បុរសឯណា បានឃើញហើយច្បាស់ជា ....... ៗ នាងម៉ាណ៉ាដែលជាតិជាស្ត្រីស្មារតីតិចហើយជាអ្នកស្រឡាញ់នូវរូបរាងកាយផង ប្រឹងជឿជាក់នូវសំដីប្តី ទើបលាន់មាត់ថា បើប្រសិនណាដូចពាក្យបងមានប្រសាសន៍មែន ចំជាខ្ញុំបានកសាងល្អណាស់ពីអតីតមក ៗ

មាន់រងាវចុះចាកពីទ្រនំ សន្សើមធ្លាក់ជោកជាំពេញព្រះធរណី ជប់ជាប់នៅស្លឹករុក្ខជាតិទាំងឡាយ បុប្ផានានាសឹងរីកដេរដាសមានក្លិនពិដោរឈ្ងុយឈ្ងប់ក្នុងភូមិគត ព្រះចន្ទលិចទៅទិសបស្ចិមបន្តិចម្តង ៗ ព្រះសុរិយាតើនចាកពីសយនា ប្រឹងមម្នាឡើងប្រថាប់លើព្រះពជរថយាត្រាប្រទក្សិណភ្នំមេរុបញ្ចេញនូវឆព្វណ្ណរង្សីបំភ្លឺលោក អ្នកស្រុកទាំងអស់នាំគ្នាទៅរកស៊ីធ្វើការងារទីទៃ ៗ ចៅហេមស័យនឹងនាងម៉ាណ៉ា នាំប្តីប្រពន្ធដំរះរាងកាយងូតទឹក ស្លៀកពាក់គុបតែងដោយគ្រឿងមាសពេជ្រដ៏វិចិត្រ

គួរប្រតិព័ទ្ធ រួចស្រេចក៏ទៅសំពះម្ដាយឪពុកចាស់ទុំ ឲ្យជូនយកផ្កាស្លា ទៅប្រគេនលោកគ្រូចៅអធិការវត្តនគរ ។

ឪពុកម្ដាយមាមីងនាំគ្នាស្រុះស្រួលជូនកូនចៅទៅវត្ត ដើរតាមផ្លូវ ពួកអ្នកលក់ដូរនាំគ្នាមើលឈ្ងោរ គន់ប្រកាន់ចៅហេមស័យ ហើយនឹងពាងម៉ាល៉ា មានស្រីខ្លះកែះគ្នានិយាយថា ទំម៉េះបើគេបានប្ដីល្អណាស់អ៊ុយ បើប្រសិនណាប្ដីអញរូបល្អដូចគាត់នោះ ឆាប់ហើយ អញស៊ូរកចិញ្ចឹមមិនឲ្យព្រួយ ពេលថ្ងៃពិបាក ៗ ចុះ ឲ្យតែពេលយប់បានស្រួល អញធ្វើស្នេហ៍ដាក់កុំឲ្យស្រឡាញ់ស្រីណាទៀត អញស៊ូថ្នាក់ថ្នមមិនឲ្យអាក់អន់ចិត្តឡើយ ឯចំណែកពួកប្រុសវិញលាន់មាត់ថា ទំមើលនាងនោះល្អណាស់តើ យើបើប្រសិនណាបានមកធ្វើប្រពន្ធអញវិញ ច្បាស់ជាមានភ័ព្វធំ អញចាក់សោទុកកុំឲ្យប្រុសណាឃើញ ការហត់នឿយប៉ុន្មានអញលែងគិត ៗ តែផ្គាប់ចិត្តកុំឲ្យទាស់ ឱនាងនេះមិនគួរបានទៅគេសោះ ពួកតា ៗ បែរទៅបន្ទោសយាយថា យាយឯងនេះអញលែងស្និតហើយ សាច់ស្វិត ស្បែកយារ មិនជាប់មើលទេ អញមើលទៅទ្រាំមិនបានទេ ច្បាស់ជាទៅរកក្រមុំណាឲ្យមានរូបល្អដូចនាងនោះហ្ន៎ ៗ យាយឮហើយក៏ឆ្លើយតបថា អើ តាឯងឆ្អើលចាស់ហើយអ៊ុយ បើតាឯងឆ្អើល អញឆ្អើលដែរ អញទៅរកកំលោះណាឲ្យយ៉ាងល្អដូចអ្នកនោះ ហើយអញតែងខ្លួនឲ្យយ៉ាងកុំផាន នៃ ស្លៀកសុទ្ធតែផាមួង ពាក់ការវៀលកចង្ក

មុខក្រោយ ស្បែកជើងកែងខ្ពស់ បណ្ដើរគ្មាមកបង្អួតគាងឲ្យឆ្ងាយក្អួត មួយជាន់ហ្នឹង ប្រយ័ត្នកុំឲ្យអញ្ញល ក្រែងលិច ទាំងក្មេងទាំងចាស់នាំគ្នា សរសើរចៅហេមស័យនឹងនាងម៉ាល៉ា ជាអនេកបរិយាយ ។

ជនទាំងពីរនាក់ នាំឪពុកម្ដាយមាមីងចូលទៅក្នុងវត្តក្នុងពេលដែល លោកសង្ឃកំពុងឆាន់ព្រឹក លោកសង្ឃខ្លះបានឃើញរូបរាងនាងម៉ាល៉ា ប្រឹងមើលតាំងភ្លេចស្មារតី ខ្លះបោះស្លាបព្រាចោលទៅក្នុងវែងឆាន់ ប្រឹងដើរតាមមើលស្រីនោះ លោកគ្រូចៅអធិការបានឃើញញាតិញោមមក ត្រៀបត្រា ប្រឹងមីម្នាស្ទុះទៅរៀបចំទទួលដោយរាក់ទាក់ សាកសួរសុខទុក្ខគ្រប់ប្រការរួចស្រេច ទើបហៅចៅហេមស័យនឹងនាងម៉ាល៉ាឲ្យចូល
៧ ទៅជិតលោកមានពុទ្ធដីកាថា ម្នាលចៅទាំងពីរ ដែលបានជួបគ្នាជាប្ដីប្រពន្ធហើយ គោងប្រយ័ត្ន ត្រូវចេះរក្សាចិត្តគ្នាកុំឲ្យថោះធ្លោយដោយអំពើចិត្តពាល ចៅអើយប្រពន្ធគេទុកដូចដី ប្ដីគេទុកដូចមេឃ គួរគិតពាក្យនេះឲ្យមែនទែន ដីបើចង់ទៅនៅពីលើមេឃវិញ មានបានកាលណា ដូចជាស្រីដែលសន្ដានចិត្តឫស្យាចំទែងចំទាស់ចង់ត្រួតត្រាប្រុសវិញ ជាការមិនល្អមើលឡើយ គួរតែគោរពប្រតិបត្តិភស្ដាកុំឲ្យអាក់ ឯមេឃដែលបាននៅពីលើដីហើយ គួររក្សាដីឲ្យបានត្រជាក់ មានដីជាតិល្អ ដូចបុរសត្រូវរក្សាស្រីឲ្យបានសុខ ស្គាល់ត្រូវស្គាល់ខុសកុំរំលោភអាងខ្លួនធំជាងគេ ភ្លេងផ្សំគ្រួចម្រៀងដ៏ពីរោះយ៉ាងណា មិនពីរោះស្មើសំដីស្រី

នឹងបុរសដែលបេះស្រឡាញ់គ្នា តាសូមឱ្យគាថា ឱ្យបានប្រកបដោយសេចក្ដីសុខ-ចម្រើនគ្រប់ជំពូក អាយុឱ្យបានវែង មានកូនក៏ឱ្យច្រើន យ៉ាងតិចត្រឹមពីរ ១ ឆ្នាំ ចំណែកតា ៗ មើលទៅទ្រាំទ្រផ្នួសមិនបានយូរទេ បើមិនឆ្នាំនេះក៏ឆ្នាំក្រោយ បើមិនក្រោយក៏ឆ្នាំក្រោយទៀត តាសឹកហើយ តាបួសតាំងពីអាយុ ១២ ឆ្នាំ រហូតមកដល់ឥឡូវនេះ តានិយាយប៉ុណ្ណឹងចៅយល់ទេ ចៅហោមស័យនឹងនាងម៉ាណា ក៏លើកដៃសំពះថ្វាយបង្គំទទួលសាធុការពរ ហើយសើចញញឹមដោយលោកតាបំអន់លេងផង រួចហើយថ្វាយបង្គំលាលោកគ្រូទៅអធិការវិលត្រឡប់មកកាន់គេហស្ថានវិញ ។

## ឈុតទី ៤

### ចៅហោមស័យនឹងនាងម៉ាណាព្រាត់ប្រាសគ្នា

ការព្រាត់ប្រាសនិកសមិត្តរបស់គាប់ចិត្តតែងមានដល់គ្រប់រូប គ្រប់កាយ គ្មានបុគ្គលណាមួយវៀរបានឡើយ មិនតែមនុស្សយើងទេ ទាំងសត្វតិរច្ឆាននឹងរុក្ខជាតិទាំងឡាយ ក៏តង់ព្រាត់ប្រាសគ្នាដែរ តែសត្វតិរច្ឆានសោយអារម្មណ៍កើតទុក្ខតិចជាងមនុស្សយើង ។

ខ្ញុំសង្កេតគិតដល់ទឹកដែលហូរចេញពីភ្នែកសត្វលោកពល់គ្នា ក្នុងមួយទិវា ៗ មិនដឹងជាបានប៉ុន្មានទន្លេទេ ។

ដូចជាចៅហោមស័យនឹងនាងម៉ាលាបានរួមស្នានជាមួយគ្នាចំនួនមួយវស្សាប៉ុណ្ណឹង ក៏បែកពីគ្នាទីទៃរៀងខ្លួន ៗ

សម័យថ្ងៃមួយពេលព្រលប់ជាកាលកម្មរបស់ជនទាំងពីរនាក់ ចៅហោមស័យវេលានោះក្តៅក្រហាយ ហាក់ដូចជាអគ្គីមកដុតពេលពលពេញសព៌ាង្គកាយ បបួលប្រពន្ធទៅងូតទឹកទន្លេ ដើម្បីនឹងជំរះលាងខ្លួនឲ្យត្រជាក់ ពីផ្ទះទៅទន្លេឆ្ងាយចំនួន ១.០០០ ម៉ែត្រ នាងម៉ាលាត្រេកអរណាស់ ឮប្តីបបួលក៏ម្នីម្នារៀបចំគ្រឿងប្រដាប់សម្រាប់ផ្លាស់ងូតទឹករួចស្រេចកាលណា ក៏នាំគ្នាត្រសងដើរដម្រង់ទៅឯមាត់ទន្លេ ដើរតាមផ្លូវ ចៅហោមស័យស្រែកច្រៀងថា :

ម៉ាលាអូនអើយមើលរុក្ខជាតិ ដុះមរព្រោងព្រាតពេញព្រឹក្សា
ឈើខ្លះមានផ្លែខ្លះមានផ្កា ក្រអូបណាស់សាណាមាសបង
ចម្ប៉ាដូចបងចំពើបបាន រួមប្រាណសុខសាន្តនឹងនួនល្អង
ចម្បីដូចរៀមបីត្រកង នួនល្អងនាងល្អគួរពេកនា

កាលពីដើមទីនេះបងតែងមកលេងកំសាន្តសប្បាយ មានក្រមុំល្អ ៗ ចុះងូតទឹកលេងជាមួយគ្នា តែបងគ្មានប្រាថ្នាចង់បានមករួមបវេណីសោះ លាក់បាំងអ្វីប្អូន ៗ បងបានឃើញតែមួយភ្លែតប៉ុណ្ណឹង ចិត្តបងក្ខួបត្រចាញ់ស្រឡាញ់ប្អូនស្មើស្មុះទៅឲ្យបពុំគិតខ្លាចអ្នកណា ហេតុហ្នឹងបានជាបងគន្ទក់គន្ទេញ ឲ្យមាតាបិតាគាត់ដណ្តឹងយកប្អូនធ្វើជាប្រពន្ធឲ្យខាងតែបាន

ឱប្អូនអើយនាងមើលសត្វសារិកាទាំងគូទំលើដើមសីដានិយាយគ្នាផ្អៀងផ្អង មើលមកយើង ប្រហែលជាគេគិតថា មនុស្សក៏មានគូស្រករដែរ នៃសត្វសារិកាកែវអើយ ឯងទាំងពីរស្រឡាញ់គ្នាយ៉ាងណា យើងទាំងពីរក៏ស្រឡាញ់គ្នាបែបឯងដែរ នាំមើលសត្វតាបយំបេប ៗ ក្នុងសំបុក មេវាគ្រប់គ្រងថែរក្សា ចំណែកឯបាពវិញ ប្រឹងទៅនាំពស្ដុផលយកមកចិញ្ចឹម និងស្វែកឈើមកធ្វើសំបុក ត្រង់នេះយើងគង់ដឹងខ្លួន កាលណាយើងមានកូនយើងនឹងនឿយព្រួយដូចសត្វតាបដែរ ៗ

ចៅហោមស័យនឹងនាងម៉ាលា អង្គុយក្រោមដើមស្វាយធំ ១ ក្បែរមាត់ទន្លេ គន់មើលព្រះអាទិត្យលិចទៅទិសបស្ចិមបន្តិចម្ដង ៗ ចៅហោម-ស័យនឹកស្ដើតដល់អាយុសង្ខារសត្វ តែងធ្វើដំណើរទៅកាន់មរណៈមួយថ្ងៃបន្តិច ៗ ដូចជាព្រះសូរ្យានាពេលអស្ដង្គត ហើយប្រាប់ទៅប្រពន្ធឲ្យផ្លាស់សំពត់ទៅងូតទឹក នាងម៉ាលាក៏ស្លៀកក្រមាចុះទៅកាន់ទន្លេជាមួយនឹងប្ដី នាំគ្នាប្រឡែងកញ្ឆ្រោកបោកបាចសាចទឹក កើតសេចក្ដីសំរើបស្រើបក្នុងផ្លូវមេថុន ជួនកាលចៅហោមស័យ កន្ត្រាក់ក្រមាដែលរុំកាយប្រពន្ធបានហើយរត់ឡើងគោក នាងម៉ាលាធ្វើពុតជាស្រែកយំហៅប្ដី ៗ រត់ចុះមកស្លៀកដណ្ដប់ ឲ្យដូចដែលវិញ ប្រឡែងលេងបានយូរបន្តិចទៅកម្មអាក្រក់តាមមកទាន់អ្នកទាំងពីរនាក់នេះ ចៅហោមស័យនិយាយទៅប្រពន្ធថា ៈ ម្នាលប្អូន តាំងបងហែលឲ្យប្អូនមើល បងហែលបានឆ្ងាយ

ណាស់ ថាហើយក៏លោតហែលស្ទុង បណ្ដោយតាមទឹកហូរយ៉ាងខ្លាំង ដល់ត្រឡប់មកវិញ ហែលឡើងពុំរួច អស់កម្លាំង ខ្សែទឹកក៏គួចចៅហោមស័យទៅឆ្ងាយបាត់ទៅ ។

ចៅហោមស័យ ដោយអំណាចខ្លាចលិចលង់ទៅក្នុងទឹក ហើយទឹករលឹកដល់ប្រពន្ធ ប្រឹងហែលបណ្ដែតខ្លួនតាំងពីក្បាលព្រលប់រហូតដល់ភ្លឺស្វាងច្បាស់ អណ្ដែតទៅប៉ះជាប់ត្រាំងខាងចុងខទន្លេសាប ដល់ទីនោះចៅហោមស័យត្រឡប់បាត់ស្មារតីដោយសារហត់នឿយហួសកម្លាំង ។

មានស្ត្រីម្នាក់ឈ្មោះម៉ិះប្រពន្ធមេចោរ ប្ដីមិននៅក៏នាំពួកចោរទៅប្លន់ឯប្រទល់ដែនស្រុកសៀម នាងនោះនៅតែម្នាក់ឯងកណ្ដាបកណ្ដែនខ្ទបផ្កា គាប់ជួនថ្ងៃនោះនាងម៉ិះកណ្ដៀតក្អមទៅដងទឹកយកមកដណ្ដាំបាយ មើលពីលើមាត់ត្រាំងទៅឃើញមនុស្សម្នាក់ដេកស្តូក នាងនោះទម្លាក់ក្អមស្ទុះម្នីម្នាទៅលើកត្រកងបីចៅហោមស័យ យកទៅដាក់លើផ្ទះ គិតក្នុងចិត្តថា អ្នកនេះមានរូបល្អចំឡែក ល្អជាងប្ដីអញមួយរយត គួរបេតនាហេតុម្ដេចបានមកស្លាប់ដោយមាត់ទន្លេដូច្នេះ តែខ្លួននៅក្ដៅ ដង្ហើមនៅមាន គួរអញជួយសង្គ្រោះយកជីវិតគាត់នេះ នាងម៉ិះយកថ្នាំមករិតស្រឡាបចៅហោមស័យ ៗ ក៏ដឹងខ្លួនឡើងវិញ លើកដៃសំពះថា ឱអ្នកមានគុណលើខ្ញុំណាស់ ខ្ញុំគ្មានអ្វីតបគុណអ្នកឡើយ មានតែម្រាមដៃទាំង ១០ នេះឯង នាងម៉ិះស្ទុះទៅចាប់ចៅហោមស័យ កុំឲ្យសំពះ ហើយសាកសួរ

ពីហេតុដែលអណ្ដែតខ្លួនមកដល់ទីនោះ បានជឹងសត្វគ្រប់ប្រការវេលា ណា នាងមុំះក៏និយាយមិត្រប្រាយលែបខាយទៅហៅហេមស័យថា :

មុំះ – អ្នកមានប្រសាសន៍ថា មានតែម្រាមដៃ ១០ទេ តបគុណខ្ញុំ ៗ ពុំត្រូវការទេ ត្រូវការតែត្រីមួយម៉ាយកេណាស់ផង តើអ្នកកេឲ្យខ្ញុំបានឬទេ ?

ហេមស័យ– ឱនាងអើយគុណនាងធ្ងន់ណាស់ កុំថាតែរបស់ម៉ាយកេប៉ុណ្ណឹង ទោះបីដល់កាយក៏ចាប់ចិត្តខ្ញុំ ៗ ក៏គិតជូននាងឲ្យខាងតែបានលើកតែជីវិត ពីព្រោះខ្ញុំមានភរិយាមួយជាទីគាប់ចិត្តណាស់ មិនបង់ឲ្យបែកឃ្លាតឡើយ ។

មុំះ – អើអ្នកបងលាក់បាំងអ្វីខ្ញុំតាំងពីបានឃើញរូបអ្នកបងវេលាណាវិញ្ញាណសាតើខ្ញុំហាក់ដូចជាលេតលើងឈឺអស់ពីខ្លួន ភ្លេចបាយភ្លេចទឹកភ្លេចម៉ែភ្លេចឪភ្លេចទាំងប្ដីខ្ញុំថែមទៀត ប្ដីខ្ញុំទៅបាត់ចំនួនកន្លះខែហើយ បើខ្ញុំលែបអ្នកបងរួច ខ្ញុំលែបបាត់ទៅហើយ ដោយអំណាចស្រឡាញ់ ។

ហេមស័យ – យីម្ដេចដូច្នេះ ឯខ្លួនខ្ញុំវិញ បានឃើញអ្នកឯង ខ្ញុំគិតតែលើកដល់ប្រពន្ធ ដែលគ្នាកំពុងតែយំនៅផ្ទះឯណោះ ម្ដេចចិត្តអ៊ីក៏ខុសពីគ្នាឆ្ងាយណាស់ហ្ន៎ ។

មុំះ – ប្រហែលជារូបខ្ញុំមិនដល់រូបប្រពន្ធអ្នកបងហើយមើលទៅ នែអ្នកបង កាលខ្ញុំនៅពេញរូបពេញកង កាលនៅក្រមុំ ប្រុស ១១១ នាក់

ដណ្ដើមគ្នាចង់បានខ្ញុំ ៗ ពុំព្រមយក ដល់ប្ដីសព្វថ្ងៃនេះ គាត់ស្រឡាញ់ខ្ញុំហួសពេក ស៊ូបោលស្រុកឪពុកម្ដាយ លើកគ្នាឡើងទៅចាប់យកខ្ញុំពីលើផ្ទះ នាំមកលាក់បំពួនក្នុងទីរហោស្ថានស្ងាត់នេះ តាំងខ្លួនធ្វើជាមេចោរ ដើរស្វែងរកប្រាក់មកចិញ្ចឹមកុំឲ្យខ្ញុំព្រួយ តែគាត់មើលទៅប្រហែលជាបីខែទៀត បានត្រឡប់មកពីព្រៃប្រទល់ដែនសៀមវិញ ខ្ញុំនៅតែម្នាក់ឯងត្រ-មោចត្រមង់ចាំបែងចិត្តណាស់ បានឃើញអ្នកបងហាក់ដូចជាបានឃើញមុខប្ដីខ្ញុំមួយរយដងពុំស្មើ គួរអ្នកបងអាណិតជួយនៅកំដរប្អូនកុំឲ្យកំព្រាដេករងាតែឯកឯង ទំរាំប្ដីខ្ញុំមកវិញ ។

ហោមស័យ – យើប្ដីនាងធ្វើមេចោរផង ខ្ញុំខ្លាចណាស់ ក្រែងតែមកទាន់វាយសម្លាប់ខ្ញុំ មួយទៀតមានបាបក្រាស់ណាស់ ពីព្រោះនាងជាស្រីមានម្ចាស់ហួងហែង ។

ម៉ិះ – អ្នកបងខ្លាចអ្វី ណានាទៅខ្លួនខ្ញុំ ប្ដីខ្ញុំមុននឹងគាត់ត្រឡប់មកទីនេះ គាត់ប្រើឆ្កមកឲ្យដំណឹងខ្ញុំមួយថ្ងៃមុន ឯត្រង់បាបប..កុំព្រួយខ្ញុំទទួលទាំងអស់ ។

ថាតែប៉ុណ្ណោះហើយ ក៏លោស្ទុះទៅឱបថើបហោមស័យក្ដិតហើយច្រៀងល្អងលោមថា :

បងអើយមើលសត្វអំពិលអំពែក ហើរក្លៃក្លូត ៗ ក្នុងកន្ទប់
ដូចជាបុរសក្នុងពេលយប់ ប្រឹងតុបតែងខ្លួនរកស្ត្រី

រូបប្អូនយ៉ាងស្រស់ត្រកែកផ្ចិត ម្តេចរៀមមិនស្ញៀតឥតប៉ះត្តី
មាត់ពេញពោរពាសទូរចំណាំ រៀមនៅមិនខ្ជីចំពាទៀត
រៀមអើយធម្មជាតិសត្វស្រមោច តូចហោចពិតតែមានមារយាទ
ឲ្យឃើញតែស្ករប្រឹងខ្នីឃ្លាត កណ្តៀតជញ្ជូនទៅគោត្តា ។

ហោមស័យ – ប្រឹងបំពក់ពីដៃនាងម្ចិះហើយស្រែកថា មិនដែលឃើញអីចេះតាប់ប្រុស បែបនេះទេ ។

ម្ចិះ - ខ្ញុំមិនមែនចាប់យកទៅដាក់គុកទេ ខ្ញុំចាប់យកទៅដាក់លើគ្រែទេតើ ។

ហោមស័យ - យកខ្ញុំទៅដាក់លើគ្រែធ្វើអ្វី ។

ម្ចិះ – អ្នកបងក្រែងធ្លាប់មានប្រពន្ធហើយតើ ។

ហោមស័យ — មានយូរហើយ តែវាមិនដែលចាប់ខ្ញុំដាក់លើគ្រែទេ ។

ម្ចិះ – ប្រពន្ធអ្នកបងមិនឆ្លាត មិនចេះធ្វើឲ្យប្តីស្រឡាញ់ ។

ហោមស័យ – នាងអើយវាចេះណាស់ ប្រហែលចេះជាងនាងឯងផង មើលនាងគិតចាប់ទៅដាក់លើគ្រែធ្វើអ្វី ប្រាប់ឲ្យត្រង់សោះខ្ញុំសង្ស័យ ។

ម្ចិះ — ឱពុទ្ធោៗអើយ ប្រុសអីល្ងង់ម៉្លេះ រូបល្អ តែបញ្ញាគ្មាន គេចាប់ឲ្យទៅដេក គេមានឲ្យធ្វើអ្វីទៀត ។

ហេមស័យ - បើគ្រាន់តែដេកបាន តែខ្ញុំដេកលក់ នាងឯងកុំដាស់ ពីព្រោះអស់កម្លាំងណាស់ ព្រួទេ ។

ម៉ិះ - មុននឹងដេកលក់ គេត្រូវដេកលេងសិន គេមិនដែលដេកសស់ក្រស់ដូចបងថាទេ ។

ហេមស័យ — បើខ្ញុំដេកលើគ្រែ នាងឯងដេកត្រង់ណាទៅ ។

ម៉ិះ — ខ្ញុំដេកជិតអ្នកបង ។

ហេមស័យ — គ្រែមួយ ខ្ញុំមិនចេះដេកពីរនាក់ទេ បើជាមួយនឹងប្រពន្ធខ្ញុំ ទើបខ្ញុំចេះដេក ។

ម៉ិះ — យើអ្នកបង មិនគួរប្រកែកប្រកួតនឹងខ្ញុំផល់ម៉េះទេ ស្មានថាខ្ញុំមិនស្មើមុខឬម្ដេច បានជួយជីវិតឲ្យរួចពីសេចក្ដីស្លាប់ គ្រាន់តែពឹងការបន្តិចប៉ុណ្ណឹង ក៏មិនព្រម នេះបំផា . . . . . . ថាតែប៉ុណ្ណោះហើយ នាងម៉ិះធ្វើឫកជា:បោកខ្លួនទៀលលើក្ដារ ស្រែកទ្រហោយំថា:

អនិច្ចាខ្លួនអើយសែនពិបាក រូបអើយគោកយ៉ាកពេកណាស់សា
ប្ដីអើយអ្នកឆាប់វិលមកក៏ ទ្រូងអើយខ្លោចផ្សាតឹងណែនក្រៃ ។
កម្មអើយធ្វើគុណមិនបានគាប់ គុណអើយត្រឡប់ជាទោសវៃ
ទោសអើយមិនគួរបែបនេះនៃ ប្រុសអើយឃើញស្រីមិនចេតនា ។

ហេមស័យ — ដោយមានចិត្តទន់អាណិតនាងម៉ិះ ក៏ស្ទុះទៅលើកថ្នមដាក់លើភ្លៅ ហើយស្រដីទៅកាន់នាងម៉ិះថា នាងអើយកុំអន់អាក់ចិត្ត

អ៊ី បងបានជាខុសគំនិតបន្តិចទៅហើយ ដោយសារចិត្តបងចំបែងណាស់ អំពល់អំពែកដែលភ្លឺម្តងងងឹតម្តង ដូចចិត្តបងអផេង ភ័យផង អរផង មួយជាន់ហ្នឹង បងបានសងគុណនាងហើយ ភ័យ គឺក្រែងប្តីនាងមកទាន់ សមជាបងវេទនាមិនខានឡើយ ឯស្រមោចមិនត្រូវឃើញនូវស្ករហើយ ចេះតែពាំស៊ីទេ ចួនកាលគេប្រឡាក់ដោយគ្រឿងបំពុល ឲ្យស្រមោចស្លាប់ក៏មាន ចំណីពេញមាត់មិនទំពាពិតហើយ មុននឹងទំពារគាងគិតមើល តើចំណីរឹងឬទន់ មិនប្រយ័ត្នក្រែងប៉ះទៅលើចំណីរឹងបាក់ធ្មេញអស់ទៅ ។

ម៉ុះ — បងអើយចំណីរបស់ខ្ញុំទន់ត្រជាក់យ៉ាងផ្អែមជាប់អណ្តាតមួយជាតិ បើបានស៊ីហើយចង់ស៊ីទៀត ។

គង់វេលានោះព្រះពាយក៏មិនអាចនៅស្ងៀមបាន ប្រឹងចេញអំពីស្ថានវិមានមាសមកក្រៅ បណ្តាលឲ្យមានព្យុះខ្យល់ ឲ្យព្រះគង្គាមានសុទ្ធតែរលកធំបែកជាផ្កាត្រែងចំនួនកន្ទុះម៉ោងទៅ ព្រះពាយចូលទៅក្នុងវិមានវិញ ។

ចៅហោមស័យ — ក្តួចគិតនាងម៉ាលា នាងម៉ុះក្តួចគិតប្តី អ្នកទាំងពីរនាក់តែងរួមគាស្នេហាគ្នាជាប្រក្រតី នាងម៉ុះនាំចៅហោមស័យទៅប្រាប់ទីកន្លែងដែលប្តីខ្លួនកប់លាក់ទ្រព្យដែលប្លន់លួចពីគេបានមក ចៅហោមស័យ ក៏ចំណាំទុកកន្លែងអស់គ្មានភ្លេច ។ (មានតទៅទៀត)

## ដំណើរដេរ្ឈក ៗ

អំពីសិល្បកម្មជាន់ចាស់នៃប្រទេសឥណ្ឌូស៊ិន តាំងនៅក្នុងពិពិធ-ភណ្ឌស្ថានក្រុងប៉ារីស ក្នុងឆ្នាំ ១៩៣៨

ពិពិធភណ្ឌស្ថានគីមេត៍នៅក្រុងប៉ារីសនោះ កាលពីដើមមក ជាពិពិធភណ្ឌសាសនានៃចុងបូព៌ាប្រទេស ដល់មកឥឡូវនេះ មានការកែប្រែផ្លាស់ប្តូរជាថ្មីទាំងអស់ ហើយបានចាត់តាំងសិល្បកម្មសម័យចំរើន
៥ រុងរឿងរបស់បូព៌ាទិស ដើម្បីតាំងជូនដល់សាធារណជនជាតិបារាំងសែសចូលមើល ។

នៅឱកាសតាំងវត្ថុដ៏ឧឡារិកជាដំបូង ពិពិធភណ្ឌស្ថានបានបោះពុម្ពសៀវភៅបញ្ជី (កាតាឡុក) មួយនៅក្របសៀវភៅនោះ គេបានបោះរូបចម្លាក់បែបខ្មែរមួយយ៉ាងល្អ ៗ ក្នុងសៀវភៅនោះ យើងឃើញមានពាក្យអធិប្បាយពន្យល់ អំពីវិហារខ្មែរមួយ ដែលគេកសាងដោយថ្ម មានក្បាច់ចម្លាក់ដោយថ្មផង តាំងអំពីពុទ្ធសករាជ ១១៩៣ ដល់ ១៧៤៣ ។

ចំណោមវត្ថុដែលនាំពីស្រុកខ្មែរទៅតាំងនោះ ឃើញព្រះពុទ្ធរូប ១ អង្គ ព្រះវិស្ណុ ១ អង្គ ។ ឯគ្រឿងហោជាងនេះសុទ្ធតែមានឆ្លាក់ជាក្បាច់រំលេចជារឿងមហាភារតយុទ្ធ និងរឿងព្រាហ្មណ៍ ។

នៅឱកាសនោះ លោកអ្នករៀបរៀងសៀវភៅបញ្ជីនោះបានកត់សំគាល់ទុកថា ជនជាតិខ្មែរជាគ្រូគេក្នុងការបង្កើតសិល្បកម្ម មានបម្លាក់ឆ្លាក់ជាក្បាច់រំលេចទៅជារឿងជាកំរហូរហែល្អមើលណាស់ ៗ

ក្នុងចំពួកគ្រឿងសំរិទ្ធិខ្មែរដែលបានតាំងក្នុងទីនោះ ឃើញនាគពជ ១ មានពន្លឺចាំងកោងស្ទើត ចេញសម្បុរស្ពាន់ខៀវស្រងាត់ ។

✲

✲ ✲

# អំពីរូបបដិមាករនៅពិពិធភណ្ឌស្ថាន

## គីមេត៍ ក្រុងប៉ារីស

កាសែតរូបភាសាបារាំងសែសឈ្មោះ អិល្លូស្ត្រាស្យុងលេខ ៩ ខែសូយេតឆ្នាំ ១៩៣៨ ឃើញមានរូបខ្លះដែលមានប្រយោជន៍យ៉ាងច្រើនសម្រាប់ព្រះពុទ្ធសាសនា កាសែតនេះចុះថា នៅពិពិធភណ្ឌស្ថាន គីមេត៍ក្រុងប៉ារីស នោះមានរូបបដិមាករថ្មខ្មែរយ៉ាងល្អ ហើយមានរូបបដិមាករបែបគន្ធារៈជាច្រើន ដែលគេកសាងទុកមកតាំងអំពី ព.ស. ១.១៥០ ៗ នៅទីនេះគេថតយកមកតែរូប ៣ ដែលបង្ហាញឲ្យឃើញថាដៃយ៉ាងល្អក្នុងចំណោមរូបដែលមាននៅក្នុងប្រទេសគន្ធារខាងដើម ក្នុងចំណោមរូប

នោះមានព្រះពុទ្ធរូប ១ អង្គទ្រង់គង់សម្រឹងសម្រាកព្រះកាយដោយយកព្រះបាទស្តាំបត់ចូលពត់ព្រះភ្នែន ព្រះបាទឆ្វេងសំយុងទំរេតទៅឆ្វេងបន្តិច ទ្រង់ដាក់ព្រះហស្តឆ្វេងលើព្រះជានុនៃព្រះបាទខាងឆ្វេង ទ្រង់ទុនព្រះសិរបន្តិច ព្រះភក្ត្រសំឡឹងទៅព្រះធរណី ព្រះអង្សាខាងស្តាំបំហាទទេ គ្មានពាក់ចីវរ ព្រះអង្សាខាងឆ្វេងទឹងព្រះកាយទ្រង់ចីវរ មានផ្នត់អន្លាញ់ ៗ ល្អមើលណាស់ ។

មានរូបថ្មចម្លាក់មួយទៀត ធ្វើជារូបស្តេចនាគពីរ គង់នៅក្នុងអាងថ្មលេចឡើងមកត្រឹមពាក់កណ្ដាលខ្លួន បែរមុខទល់គ្នា អាងថ្មនោះមានឈូកដុះឡើងនៅចំកណ្ដាល ហើយមានព្រះពុទ្ធរូបគង់ពីរខាងលើផ្កាឈូកនោះមួយជាន់ទៀត ។

មានរូបមួយទៀត ធ្វើជារូបទេវតាមានគ្រឿងអម្ពរប្រកបដោយវត្ថា-លង្ការសឹងមើលឃើញច្បាស់ទៃងទាំងអស់ មានបរិបូណ៌គ្រប់គ្រាន់ ។

*

* *

ការតាំងពិពិធភណ្ឌ ដែលគាស់កកាយបានមកពីស្រុកគន្ធារៈ ទុកជាវត្ថុដ៏សំខាន់ បានជាមានការសែតអង់គ្លេសមានរូបច្រើនមើលឃើញ ព្រាលជាប់ដោយប្រវត្តិសាស្ត្រខាងក្បាច់រចនាបែបពុទ្ធសាសនាសុទ្ធតែជា

របស់ឯក ៗ ។ ដ្បិតគេបានប្រទះឃើញរូបភាពដែលមាននិយាយបញ្ជាក់ អំពីរឿងដែលមានក្នុងគម្ពីរពុទ្ធសាសនា (មហាយាន) ជាភាសាសំស្ក្រឹត និងភាសាចិន ។

កាសែតអង់គ្លេសនេះ មានថតជាក់ព្រះពុទ្ធរូបមានព្រះរូបសល់នៅត្រឹមពាក់កណ្ដាលព្រះអង្គ ១ អង្គ ព្រះពុទ្ធរូបអង្គនេះជាព្រះពុទ្ធរូបទ្រង់គ្រឿង មានព្រះកេសាវិលក្របួបជាទក្ខិណាវដ្ដ មានព្រះកណ្ណយាវវែង ទ្រង់ពាក់ក្រវិលពេជ្រ នៅលើចីវរមានផ្ដត់អង្កាញ់ ៗ នៅខាងមុខជិតព្រះឧរ គេបំពាក់កងប្រដាប់ពេជ្រ ១ ខាងក្រោយព្រះបិដ្ឋិ ១ នៅចុងព្រះពាហាឆ្វេង ១ ចុងព្រះពាហាស្ដាំ ១ នៅជុំវិញព្រះកណ្ឋ (ក) គេបំពាក់កងពេជ្រលៀនចេញមកលើព្រះអង្សាទាំងពីរខាង ។ ព្រះពុទ្ធរូបអង្គនេះប្រដាប់ពេជ្រនិលត្បូងដ៏មានដំឡៃជាច្រើនណាស់ ។

ព្រះពុទ្ធរូបនេះមានពណ៌ (លឿង) គេចាប់កសាងមកប្រហែលក្នុងពុទ្ធសករាជ ១.១០០ ។ ព្រះពុទ្ធរូបទ្រង់គ្រឿងបែបនេះជារបស់មានដំឡៃ រកបានដោយក្រណាស់ បង្អួលប្រាប់ឲ្យយើងយល់ថា គ្រឿងត្រៃចីវរបែបសាសនា គ្រឿងបរិក្ខារ ហើយនឹងគ្រឿងពេជ្រនិលត្បូងថ្មដ៏មានដំឡៃជាសម្បត្តិរបស់ក្សត្រ ទាំងនេះជាងចំឡាក់ជាតិគន្ធារៈឆ្លាក់តាមពាក្យដែលមានពោលទុកក្នុងគម្ពីរពុទ្ធសាសនាសព្វគ្រប់ ដែលមានសំដែងក្នុងសម័យនោះ ។

ព្រះពុទ្ធរូបបែបគន្ធារៈធ្វើដោយដីដុតមានពណ៌ល្មៀងនេះ  នៅមន្ទីរព្រះរាជបណ្ណាល័យក៏មានខ្លះដែរ  បើលោកអ្នកចង់មើលបែបភាពព្រះពុទ្ធរូបគន្ធារៈ  សូមអញ្ជើញចូលទៅឯមន្ទីរព្រះរាជបណ្ណាល័យ  បើចូលតាមទ្វារខាងកើត  ដល់ទៅខាងក្នុងសាលានឹងឃើញមានទូលេខ ១ នៅខាងស្តាំដៃ ជាគ្រឿងសំគាល់  ព្រះពុទ្ធរូបបែបគន្ធារៈ  បានដំកល់ទុកក្នុងទូនេះឯង អញ្ជើញទៅពិនិត្យមើលបានតាមប្រាថ្នា ។

*

*    *

# អំពីសេចក្តីសង្ខេបនៃបាឋកថា

## របស់លោកកុម្មង់ដង់ត៍ឡឺប្រឺតុង

កាលពីហេមន្តរដូវនោះលោកកុម្មង់ដង់ត៍ឡឺប្រឺតុង (អ្នកប្រវត្តិសាស្ត្រជាតិបារាំងម្នាក់)  បានថ្លែងបាឋកថាមួយនៅប្រទេសបារាំងសែស  អធិប្បាយអំពីដំណើររបស់លោកម៉ាកូប៉ូឡូ (Marco Polo) ជាអ្នកត្រាច់ចរគ្រាត់ធំមួយជាតិឥតាលីដែលលោកបានធ្វើដំណើរទៅកាន់ប្រទេសចិន  ខាងឧត្តរទិស  កាលពីពុទ្ធសករាជ ១៨១២ ។  ក្នុងកាលដែលលោកម៉ាកូប៉ូឡូអញ្ជើញទៅប្រទេសចិននោះ  ព្រះសង្ឃរាជ (Pape) កាតូលិកបានធ្វើ

ខ្លួនជាក់ប្រេងស័ក្តិសិទ្ធិជាគ្រឿងបណ្ណាការទៅថ្វាយព្រះមហារាជាធិរាជនៃទ្វីបអាស៊ីទ្រង់ព្រះនាមកុប្លៃខាន់ផង ។

លោកម៉ាកូប៉ូឡូអញ្ជើញចូលទៅលង្កាទ្វីប ហើយបានយកគ្រឿងបរិក្ខារព្រះសម្មាសម្ពុទ្ធជាម្ចាស់មានបាត្រជាដើម ជាបណ្ណាការទៅថ្វាយដល់ព្រះមហារាជាធិរាជកុប្លៃខាន់នោះដែរ ។ ប្រេងដែលព្រះសង្ឃរាជផ្ញើទៅនោះបានដាក់ទុកក្នុងប្រអប់ដែលមានដំឡៃ ឯព្រះសារីរិកធាតុបានប្រតិស្ឋានទុកក្នុងកោដ្ឋដែលមានដំឡៃ ។ គ្រឿងបណ្ណាការទាំងអស់នោះ ទុកជារបស់នាំឲ្យព្រះមហារាជាធិរាជកុប្លៃខាន់ ទ្រង់បានប្រកបដោយសេចក្តីសុខក្សេមក្សាន្ត ទីងនាំឲ្យកើតសេចក្តីចំរើនរុងរឿងក្នុងក្រុងប៉េកាំង (Péking) នៃមហាណាចក្រចិនផង ។

ឯលោកម៉ាកូប៉ូឡូបានទៅនៅក្រុងប៉េកាំងនោះអស់ចំនួន ២០ ឆ្នាំ ជាទីប្រឹក្សាការផ្សេងៗរបស់ព្រះមហារាជាធិរាជនោះ ។

លុះដល់បញ្ចប់បាឋកថា លោកបាឋកៈ (Conférencier) មានប្រសាសន៍ថា កិច្ចការដែលទាក់ទងគ្នាខាងសាសនារវាងទ្វីបអាស៊ីនិងទ្វីបអឺរុបក្នុងពេលនោះ ក៏ហាក់ដូចជានាំគ្នាបំភ្លេចចោលស្រឡះ ដោយមនុស្សជំនាន់នោះគេយល់ថា ការនេះមិនជាការសំខាន់អ្វីប៉ុន្មានឡើយ ។

# ប្រជុំពាក្យកាព្យ

## ភាគទី ១

ព្រះរាជនិពន្ធ ព្រះបាទសម្តេចព្រះស្រីធម្មរាជា

ព្រះរាជសម្ភារ

ព្រះចៅក្រុងកម្ពុជាធិបតី

( តទី ៣ )

ខ្ញុំប្អូនស្ងួនពេញសំឡាញ់ស្និទ្ធ　ពីដួចប្រាសព្រាត់ទៅថ្ងៃណា
រៀមទ្រាំទុក្ខម្នេញក្នុងទ័យា　ក្ដៅផ្សាគ្មានសុខពល់ក្រើ ។
ពេលដែលនិយាយចាំពចា　ពេលដែលស្នេហាចាំមេត្រី
ខ្ញុំធ្វើកម្មអ្វីដូច្នេះនៃ　មិនឲ្យហឫទ័យបានសុខសោះ ។
ទេវតាអង្គណានាំឲ្យស្នេហ៍　ទេវតាណាផ្ដែផ្ដាច់បណ្ដោះ
ធ្វើកម្មឲ្យតែខ្ញុំស្រណោះ　បំពត់ទាំងស្រស់បំពសផ្សា ។
បំណាច់កើតក្នុងព្រះសាស្នា　គួរឬទេវតាមិនអាណិត
ត្រង់ណាដែលបានពេញទ័ងចិត្ត　បំពត់ពីកាយសែនឆ្ងាយសល់ ។
ឥឡូវមិនឆ្ងាយតែត្រឹមខ្លួន　ថែមផ្លូនទាំងមិត្រភ្ជាត់គ្មានឈ្នួង
ឬអកុសលមកពីព្រេង　ឲ្យព្រេកវង្វេងក្ដុចរៀមក៏ ។
ខ្ញុំគ្រានេះអើយនឹងអស់យល់　លុះពាល់តែក្ស័យផ្ទុដីក៏
ពីមុនគ្រាន់ទឹងទន្ទឹងគិត　ក្រែងឃើញវរមិត្រដូចចិន្ដា ។
រៀមរ័ក្សតាំងចិត្តតាំងនេត្រា　ទន្ទឹងកនិដ្ឋាតែពល់ថ្ងៃ
គិតស្មានថាជាគង់សង្ស័យ　នៅចាំអាល័យដូចប្ដេជ្ញា ។
មិនដឹងជាចិត្តដូច្នេះឡើយ　អនិច្ចាកម្មអើយគួរវេទនា
ឥឡូវឃើញចិត្តកនិដ្ឋា　គ្រានេះកល្យិយា"[១]មិនអាណិត ។

---

(១) កល្យា គឺ ម. កញ្ញា, សំ. កល្យា ។

ឃ្លាតខ្លួនឆ្ងាយស្ងួនប្រែទាំងចិត្ត បានគ្រូគៀបជិតស្និទ្ធមូលមៃ
ផ្តេកផ្តិតនៃបទិត្យរាល់យប់ថ្ងៃ ភ្លេចក្តីអាល័យរៀមអសារ ។
ចិត្តអើយសព្វថ្ងៃមិនភ្លេចគិត ដល់អស់ជីវិតទៅថ្ងៃណា
ទើបបានបែរបែកក្តីស្នេហា កនិដ្ឋាភ្លេចសោះអស់សង្ស័យ ។
ស្តាយចិត្តដែលបានប្តូរប្តេជ្ញា ស្តាយគ្រាកើតទុក្ខស៊ូរទឹកក្ស័យ
ស្តាយដែលធ្លាប់ជិតធ្លាប់អាល័យ ស្តាយ ១ កាលថ្ងៃដែលប្រាស្នា ។
គាំងចិត្តគិតស្មានថាចាំពិត ដល់អស់ជីវិតដូចពាក្យថា
កាលដែលសន្មតប្តូរប្តេជ្ញា ទេវតាទ្រង់ជ្រាបទាំងអស់អើយ ។

ព្រះមែយុប្បជ្ជារតី បានទទួលព្រះរាជនិពន្ធច្បាប់នេះហើយ ក៏ថ្វាយបង្គំលាសម្តេចព្រះឧទ័យរាជាថា ចេញទៅក្រសាលបង់ សម្តេចព្រះឧទ័យក៏អនុញ្ញាតឲ្យស្តេចទៅ គ្រាដែលព្រះមែយុប្បជ្ជារតីស្តេចចេញពីក្រុងឧដុង្គទៅ ដោយព្រះទីនាំងទាក់ ស្តេចហួសមកជួបនឹងព្រះរាជសំភារ ម្ចាស់ផែនដីនៅត្រើយពោធិ៍ព្រះបាទ នោះព្រះបាទសម្តេចព្រះស្រីធម្មរាជាព្រះរាជសំភារជាម្ចាស់ផែនដី ទ្រង់នាំព្រះមែយុប្បជ្ជារតីទៅឯព្រះរាជកំងកោះឃ្លោក ។

ខាងសម្តេចព្រះឧទ័យរាជា ព្រះបិតុលា បានជ្រាបហើយ ឲ្យលើកទាហានពាទុគេស ទៅតាមចាប់ នោះព្រះរាជសំភារម្ចាស់ផែនដីត្រាស់

បង្គាប់ឲ្យលើកទាហានខ្មែរ ទាហានចិនចេញទទួលច្បាំង ខាងម្ចាស់ផែនដីខូចទាហានជាច្រើន ទ្រង់ព្រះដំរិះយល់ថា សឹកខាងបច្ចាមិត្រខ្លាំងហួសកំឡាំង ទើបស្តេចដោះព្រះអង្គចេញទៅ ដល់ទី ១ ជាទីរហោះព្រៃមានដើមគ្នាគជាច្រើន ក៏ស្តេចឡើងលើដើមគ្នាគ ឯពួកពៃរីក៏លើកទ័ពដេញព្រះអង្គប្រកិតទៅ ។

ឯព្រះបាទសម្តេចព្រះស្រីធម្មរាជា ព្រះរាជសំការម្ចាស់ផែនដី ទ្រង់ឈ្វេងដោយព្រះយោបល់យល់ថា មុខជាមិនរួចព្រះអង្គហើយ ក៏ទ្រង់ចាប់ព្រះខាន់ត្រីមុខ កាត់ត្រួយគ្នាគហើយចុះឡាយព្រះហស្តលេខាថាព្រះរាជនិពន្ធពុំទាន់ចប់សេចក្តី ខាងកងទ័ពបច្ចាមិត្រក៏លើកទៅដល់នោះព្រះរាជសំការម្ចាស់ផែនដី ទ្រង់តាំងព្រះរាជហឫទ័យដោយមានះក្សត្រិយ៍ ទ្រង់បោយព្រះហស្ត ហើយមានព្រះដំរាស់ដោយព្រះសូរសៀងយ៉ាងខ្លាំងថា :

ប៉ាក់ងអប្បលក្ខណ៍ រាបោមពាញ់អ្នក
ព្រះរាជសំការ ពីលើចុងគ្នាគ
មិនកោតបេស្តា អ្នកយកហត្ថា
ភាំងខាំងយាត់ ៗ សាធុសម្តាយ
កុំបីរាយមាយ ទឹងក្តីកាមា
នាំឲ្យវង្វេង កង់វដ្តសង្សារ

ស្លាប់ទៅកាលណា បានសោយតែទុក្ខ ៗ
ហេតុតែស្ត្រី នាំឲ្យអប្រិយ
ដូចត្រីក្នុងភក់ បើបុរសផង
បង់ខ្លួននរក កុំធ្វើរីក
ដូចខ្ញុំម្ល៉េះណា ៗ ពីព្រោះកាមេ
ស៊ូទ្រាំទាល់តែ កុំណា ក៏យដឹក
ស៊ូស្លាប់ទៅគាប់ ឲ្យជាប់ធម្មា
សូមអស់ទេព ជួយផ្ដាំវិញ្ញាណ ៗ
ទើបព្រះភូមិន្ទ នាគយន្តធិបតិន្ទ
ព្រមអធិដ្ឋាន ពីនេះទៅមុខ
ខ្ញុំសូមឲ្យបាន ជាព្រះពុទ្ធញាណ
នាំសត្វទាំងឡាយ ៗ ឲ្យអ្នកទាំងពួង
ជាទាហានហ្វូង នាំយកទៅថ្វាយ
ព្រះបិតុលា បានប្រាប់អធិប្បាយ
កុំឲ្យភ័យមាយ ទិន្នក្តីកាមេ ៗ

៣ ទៅគាស់ម៉ែយចង្អៀតចិត្តអីម៉្លេះ ជួបចូលខែទេះបេះតែផ្កា
សោកសល់ខ្វល់ចិន្តា ចង្អៀតទុកគ្មានហៅស្បើយ ៗ

ធ្លេសធ្លោវិញ្ញាណគិតកនិដ្ឋា　　អនិច្ចាវេទនាទុកម្នេអើយ
ពុំគួរបើមកដូច្នេះឡើយ　　ទេវតាអើយពុំទ្រង់មេត្តាសោះ ។
ឯមនុស្សលោកិយនៅក្នុងដែន　　សល់សែនហៅពេញឥតសប្បុរស
វិត្រង់ទេវតាដែលទ្រង់យស　　ប្រែចិត្តអស់ដូចមនុស្សដែរ ។
រឿងនេះព្រះរាជសំភារក្សត្រិយ៍　　កាលប្រាសព្រាត់អគ្គកនិដ្ឋា
ស្ដេចទ្រាំទុក្ខម្នេញពេញឧរា　　ក្ដៅផ្សាស្ទើរបង់ព្រះជន្មា ។
អនិច្ចាក្សត្រិយ៍ចមក្រុងត្រៃ　　ព្រះទ័យអាល័យរាជវនិតា
អស់ព្រះជន្មទៅទុករាល　　ឲ្យអគ្គកនិដ្ឋាទៀតឯក្រោយ ។
វេទនាគ្រានេះព្រះទ័យក្សត្រិយ៍　　ព្រួយព្រាត់ឈឺផ្សាព្រះទ័យធ្ងន់
ឥតអ្នកណាមួយជួយព្រះអង្គ　　ស្ដេចបង់ព្រះជន្មដោយសត្យា ។

ទ្រង់ព្រះរាជនិពន្ធរួចហើយ ស្ដេចទំលាក់ចុះពីលើដើមត្នោត ខាងហានពាវទុគេសថ្វាយគ្រាប់មាសត្រូវព្រះអង្គធ្លាក់ពីលើដើមត្នោត ខាងខ្មែរថាអស់ព្រះជន្មក្នុងខណៈដែលធ្លាក់ពីដើមត្នោត ដំណើងខាងតាងប្រទេសថានាំយកមកធ្វើទោសឯក្នុងក្រុង ស្ដេចគង់ក្នុងរាជសម្បត្តិ ៤ ឆ្នាំ ព្រះជន្ម ៣០ ឆ្នាំ ។

ទីនដំណរឿងនេះបន្តិចតទៅដូចមានសេចក្ដីខាងក្រោយនេះ រឿងសម្ដេចព្រះឧទ័យរាជាទីងព្រះបាទសម្ដេចព្រះស្រីធម្មរាជា ព្រះរាជសំភារ តៅពញា (តូ) ក្នុងព្រះរាជពង្សាវតារក្រុងកម្ពុជាធិបតី មិនថ្លែងសេចក្ដីឲ្យ

ច្បាស់ គ្រាន់តែនិយាយព្រលាំខ្ញី ៗ អ្នកទាំងពួងស្តាប់បានថា ព្រះបាទសម្តេចព្រះស្រីធម្មរាជាព្រះរាជសំភារ លួចយកព្រះម៉ែយុប្ផាវតី ជាព្រះជាយានៃសម្តេចព្រះឧទ័យរាជាជាព្រះបិតុលា ឯត្រង់សម្តេចព្រះឧទ័យជាព្រះរាជបិតុលាលួចយកព្រះនាងបុប្ផាវតី ជាព្រះមហេសីគ្គុន៉ាកាន់នៃព្រះបាទសម្តេចព្រះស្រីធម្មរាជាព្រះរាជសំភារ ជាម្ចាស់ផែនដីជាព្រះភាគិនៃយាធិរាជនោះ ព្រះរាជពង្សាវតារក្រុងកម្ពុជាធិបតី មិនថ្លែងសេចក្តីឲ្យច្បាស់ត្រង់ទោសសម្តេចព្រះឧទ័យរាជាជាបិតុលាលួចយកព្រះនាងបុប្ផាវតី ជាព្រះមហេសីគ្គុន៉ាកាន់ ព្រះរាជពង្សាវតារក្រុងកម្ពុជាមិនថ្លែងសេចក្តីឲ្យឃើញផង ៗ

ឯសម្តេចព្រះឧទ័យរាជាជាព្រះរាជបិតុលា ប្រព្រឹត្តមិនគប្បី លួចព្រះនាងបុប្ផាវតី ជាព្រះមហេសីគ្គុន៉ាកាន់ នៃព្រះបាទសម្តេចព្រះស្រីធម្មរាជា ព្រះរាជសំភារ ជាម្ចាស់ផែនដីនេះ ១ សម្តេចព្រះឧទ័យរាជា ។ ព្រះរាជបិតុលាកំហែងចាប់ចងក្សត្រ សឹងមានព្រះជន្មគិតជាង ១៨ ឆ្នាំនេះ ២ ។ ព្រោះតែព្រះម៉ែយុប្ផាវតី បាំព្រះទ័យស្មោះស្មានទទឹងព្រះរាជសំភារម្ចាស់ផែនដី ត្រឡប់ព្រះទ័យទៅរកម្ចាស់ផែនដី សឹងជាព្រះស្វាមីគ្គុន៉ាកាន់ ហើយសម្តេចព្រះឧទ័យរាជា ឲ្យលើកទាហានទៅចាប់ព្រះរាជ

សំភារ ជាម្ចាស់ផែនដី ទឹងព្រះនាងបុប្ផាវតី យកមកធ្វើទោសដល់ក្ស័យ ព្រះជន្មនេះ ៣ ព្រះរាជពង្សាវតារក្រុងកម្ពុជាមិនថ្លែងសេចក្ដីឲ្យច្បាស់ មិនមានថា សម្ដេចព្រះឧទ័យរាជា ជាព្រះបិតុលា មានទោសដល់តិចសោះ ដ្បិតតែជាព្រះរាជបិតុលា ធ្វើអ្វីមិនមានខុស។ តែខាងព្រះបាទស្រីធម្មរាជា ព្រះរាជសំភារ ជាម្ចាស់ផែនដីជាព្រះភាគិណេយ្យ ។

# ព្រះរាជប្រវត្តិ

## ព្រះបាទសម្ដេចព្រះស្រីធម្មរាជា ព្រះរាជសំភារ

(សេចក្ដីសង្ខេប)

ព្រះបាទសម្ដេចព្រះស្រីធម្មរាជា ព្រះរាជសំភារ ជាព្រះរាជបុត្រព្រះបាទសម្ដេចព្រះជ័យជេដ្ឋា កាលនៅជាព្រះរាជកុមារទ្រង់ព្រះនាមហៅពញា (តូ) ព្រះបរមរាជបិតា ទ្រង់ព្រះគុណនាំងអាន់ទ់នឹងព្រះនាងបុប្ផាវតី ជាព្រះរាជកនិដ្ឋា ហៅពញា (តូ) ព្រះជន្ម ២១ ឆ្នាំ បេញទ្រង់ព្រះផ្នួស

ព្រះបាទសម្ដេចព្រះជ័យជេដ្ឋា ជាព្រះបរមរាជបិតា ទ្រង់ព្រះសុវណ្ណគតទៅ សម្ដេចព្រះឧទ័យរាជា ព្រះរាជអនុជទទួលរាជការផែនដីក្រុងកម្ពុជា ខាងហៅពញា (តូ) មានសេចក្ដីទាក់ទាមនឹងកិច្ចរាជការផែនដី គង់នៅជាភិក្ខុ ក្នុងវាំងហៅពញា (តូ) ទ្រង់ព្រះផ្នួសជាភិក្ខុ សម្ដេចព្រះឧ-ទ័យរាជា ព្រះរាជបិតុលា សំរេចរាជការផែនដី យកព្រះនាងបុប្ផាវតីជាគូគ្នាអាន់ទៃហៅពញា (តូ) ធ្វើជាព្រះជាយា ឲ្យហៅថា ព្រះម៉ែយុបុប្ផាវតី ។

ហៅពញា (តូ) ទ្រង់ព្រះផ្នួស៥វស្សា ព្រមអស់សេនាបតីមន្ត្រីគ្រប់ក្រសួងអញ្ជើញហៅពញា (តូ) ឲ្យដាក់ព្រះផ្នួសឡើងសោយរាជសម្បត្តិ

ជាម្ចាស់ផែនដីក្រុងកម្ពុជាធិបតី ទ្រង់ព្រះនាមព្រះបាទសម្ដេច ព្រះស្រីធម្មរាជាព្រះរាជសំភារ ថ្លៃវិសេស សាងព្រះរាជវាំងគង់នៅកោះឃ្លោក ។

សម្ដេចព្រះឧទ័យរាជា ព្រះរាជបិតុលា ដាក់ព្រះអង្គជាឧបយោរាជ្យ គង់នៅព្រះរាជវាំងក្រុងឧដុង្គ ។

ក្រោយនោះសម្ដេចព្រះឧទ័យរាជាព្រះរាជបិតុលា ទ្រង់ព្រះឈួននោះ ព្រះបាទសម្ដេចព្រះស្រីធម្មរាជា ព្រះរាជសំភារ ម្ចាស់ផែនដី ទ្រង់ស្ដេចមកប្រចាំប់ព្យាបាលព្រះរោគនៃសម្ដេចព្រះឧទ័យរាជា ព្រះរាជបិតុលា, ខណៈនោះ សម្ដេចព្រះឧទ័យរាជា ព្រះរាជបិតុលា គ្រាស់បង្គាប់ឲ្យព្រះម៉ែយ៉ូបុប្ផាវតីរៀបគ្រឿងក្រយាស្ងោយ ថ្វាយព្រះបាទសម្ដេចព្រះស្រីធម្មរាជា ព្រះរាជសំភារសោយ ហើយសម្ដេចព្រះឧទ័យរាជា ព្រះរាជបិតុលា គ្រាស់បង្គាប់ឲ្យព្រះម៉ែយ៉ូបុប្ផាវតី ចេញមកគាល់ ព្រះបាទសម្ដេចជាម្ចាស់ផែនដី ។

ឯព្រះបាទសម្ដេចព្រះស្រីធម្មរាជាព្រះរាជសំភារ ជាម្ចាស់ផែនដី គ្រាដែលទតព្រះនេត្រឃើញព្រះនាងបុប្ផាវតី ក៏មានព្រះរាជហឫទ័យក្ដួចប្រតិព័ទ្ធដោយជាគូគុទាំងអាន់ តាំងពីនៅជាព្រះរាជកុមារមកស្រាប់ ។

ក្រោយព្រះរាជបិតុលាជាប្រឈួនហើយ ព្រះរាជសំការជាម្ចាស់ផែនដីក៏ព្រះរាជដំណើរមកគាល់សម្តេចព្រះបិតុលាជារឿយៗ សម្តេចព្រះឧទ័យរាជា ព្រះរាជបិតុលាបបួលក្រសាលចិត្ត មានសេចក្តីប្រៀបប្រាយជាពាក្យចំអកចំអន់ផ្សេងៗ មានពាក្យប្រៀបបទ ១ ជាពាក្យឃ្លោងថា

ព្រាយធ្លាជាផលស្វាយ ដំរីសាស្លាប់ជាភ័ព្វក្មួយ
ប្រពន្ធផងក្មួយជាភ័ព្វមា ៗ

សម្តេចព្រះឧទ័យរាជា ព្រះរាជបិតុលាមិនស្គាល់ព្រះអង្គថា ទ្រង់ព្រះជរា ៗ

ខាងព្រះបាទសម្តេចព្រះរាជសំការម្ចាស់ផែនដី ព្រះជន្មត្រឹម ២៩ ឆ្នាំដល់ ៣០ ឆ្នាំ កំពុងពេញព្រះដំរេក តាំងព្រះរាជហឫទ័យបំណងយកព្រះនាងបុប្ផាវតីឲ្យខានតែបាន ៗ

មានខណៈ ១ ម្ចាស់ផែនដី ស្តេចព្រះរាជដំណើរដោយក្បួនព្យុហៈទៅធ្វើពិធីនមស្សការ លើទីប្រាសាទនគរវត្ត ៗ

សម្តេចព្រះឧទ័យរាជា ព្រះរាជបិតុលានឹងព្រះមៃយុប្ផាវតី ក៏ស្តេចព្រះដំណើរព្រមនឹងម្ចាស់ផែនដី ខណៈដែលស្តេចឡើងទៅប្រាសាទ

នគរវត្តនោះ ម្ចាស់ផែនដីទ្រង់បានជួបចាប់ព្រះហត្ថា នៃព្រះមៃយ្យបុប្ផាវតី កើតសេចក្តីប្រតិព័ទ្ធទៅវិញទៅមក ក្រោយស្តេចត្រឡប់មកពីនគរវត្តវិញ តាំងមានសុភអក្សរទៅវិញទៅមក ហើយទ្រង់ព្រះនិពន្ធជាពាក្យកាព្យរឿងនិរាស រឿងស្រណោះ ដូចមានពាក្យកាព្យទាំងអំបាលនេះ ៗ

ក្សត្រីព្រះអង្គនេះ ជាស្តេចប្រាជ្ញខាងកវីនិពន្ធ បានសិក្សាព្រះត្រៃបិដក សព្វព្រះទ័យខាងកាព្យឃ្លោងបានពិនិត្យឃើញថា ជាគូបងរានឹងសម្តេចព្រះឧទ័យរាជា ព្រះរាជបិតុលាពីបុព្វមក ទើបបណ្តាលហេតុឲ្យកើតឡើងជាគូបដិព័ទ្ធដល់ប្អូនព្រះជន្មក្នុងជាតិនេះ ៗ

ចាតុរង្គបទ បទទី ៤

(ត) ចប់

របស់ព្រះមហាពិទូរ ក្រសេម គន្ថរចនបណ្ឌិត

រៀបរៀង

៧ ព្រោះហេតុនោះ បុគ្គលអ្នកបានទទួលផលជាទិដ្ឋធម្មវេទនីយហើយ ទើបគួរទីងបំពេញខ្លួនឲ្យបានទទួលផលតាមជួនផង ដោយសមគួរដល់កំលាំងអាច ៗ បើមិនអាចបំពេញទាំងអស់ តែត្រឹមសទ្ធាមួយយ៉ាង ក៏ទីងបានជាគ្រឿងកំដរចិត្តទៅដែរ ព្រោះសទ្ធាជាមិត្តរបស់មនុស្សយើង ជាទ្រព្យដ៏ប្រសើររបស់មនុស្សក្នុងលោកនេះ អាចរួបរួមទូវស្បៀងគឺកុសលទុកបាន លុះតាំងមាំហើយ ក៏ឲ្យកើតសុខក្នុងលោកនេះនឹងក្នុងលោកឯមុខ ៗ

គ ផលដ៏កំពូល គោលយ៉ាងជាន់ទាបសិន ពាក្យថា "ឯកអគ្គ" នេះជាសំដីដែលគេសរសើរបុគ្គលអ្នកដែលអាចសមតាមពួក ឬតាមដំណែងការដែលសម្បូណ៌ដោយសេចក្ដីល្អមិនខ្វះកន្ទះ ពាល់តែសេចក្ដីល្អនោះប្រាកដជាក់ស្ដែងដល់ភ្នែកអ្នកទាំងពួងនេះ រាប់ក្នុងចំពួកផលដ៏កំពូល តែជាជាន់ទាប ៗ ៗ គោលយ៉ាងខ្ពស់ អ្នកប្រាជ្ញរមែងទទួលរាប់រងទូទៅថា ព្រះពុទ្ធជាព្រះសាស្ដាឯកក្នុងលោក នេះព្រោះហេតុអ្វី? ព្រោះព្រះពុទ្ធអង្គទ្រង់សម្បូណ៌ដោយផលដ៏កំពូល គឺសេចក្ដីល្អបរិបូណ៌ពេញទី ៗ ដោយធម្មាធិដ្ឋានផលដ៏កំពូល ក៏គឺព្រះនិព្វាន ដែលអ្នកប្រាជ្ញលោកចាត់ជាបរ.មត្ថប្រយោជន៍ ៗ ព្រះនិព្វានបានឈ្មោះថា ផលដ៏កំពូល ព្រោះជាផលខ្ពស់បំផុតក្នុងព្រះពុទ្ធសាសនា គ្មានផលអ្វីក្នុងលោកនេះនឹងប្រៀបផ្ទឹមបាន

ព្រះពុទ្ធទាំងឡាយ ក៏ព្រមព្រៀងថា ព្រះនិព្វានជាកំពូល ព្រោះពេញទៅដោយបរមសុខមិនចេះសាបសូន្យ មិនចេះអស់ទៅណា ជាផលដ៏ផុតវិស័យមនុស្សបុថុជ្ជនដែលក្រាស់ដោយកិលេសនឹងឈោងទៅចាប់យកបាន ព្រះនិព្វានទើបជាធម្មជាតរំលត់បង់នូវកិលេសទាំងពួង តែផ្លូវគ្រឿងដល់ព្រះនិព្វានមែនមានទៅក្នុងពួកបុថុជ្ជនដោយពិត ។ លគិតបន្តិចមើល។ ក្នុងខណៈដែលយើងកើតជម្រែក កើតទោសៈ កើតវង្វេងងងឹតងងល់ ហើយនឹងក្នុងខណៈដែលយើងស្ងាត់អំពីកិលេសនោះ ។ សូម្បីមួយផងមួយគ្រា ផលដែលនឹងគប្បីបានក្នុងខណៈទាំងពីរនោះតើផ្សេងដូចម្តេច ? គឺផលខាងណាប្រព្រឹត្តទៅដើម្បីទុក្ខ ផលខាងណាប្រព្រឹត្តទៅដើម្បីសន្តិ-សុខ ដោយន័យនេះ សេចក្តីរំលត់កងទុក្ខទាំងពួងបានជាជាប់ខាតអ្នកប្រាជ្ញលោកពោលថា "និព្វាន" ។ ក៏ព្រះនិព្វាននោះជាបរមសុខយ៉ាងនោះពិតឬទេ ក៏សូមឱ្យគិតមើលតាមន័យដូចពោលហើយ ក៏នឹងដឹងបានដោយខ្លួនឯងថា សូម្បីតែរម្ងាប់សេចក្តីជម្រែក ឬសេចក្តីក្រោធជាដើមដែលកើតឡើងហើយ ឱ្យស្ងប់ចុះត្រឹមមួយដង មួយគ្រាប៉ុណ្ណោះក៏អាចដឹងបានថា សុខស្រួលក្នុងចិត្តទៅហើយ មិនបាច់ពោលដល់ព្រះនិព្វាន ដែលជាស្ថានរលត់កិលេសអំបាលនោះបានដាច់ជ្រះស្រឡះហើយ ព្រោះហេតុនោះព្រះនិព្វានទើបជាប្រយោជន៍របស់ខ្លួនយ៉ាង

កំពូល ដែលជាទីបំណងរបស់ពុទ្ធបរិស័ទ ។ មានរឿងថា កាលព្រះបរមសាស្តា ទ្រង់ដាក់អាយុសង្ខារនឹងស្តេចបំលត់ខន្ធចូលកាន់ព្រះនិព្វានក្នុងថ្ងៃវិសាខបុណ្ណមី គ្រានោះ ភិក្ខុទាំងឡាយដែលជាសេខបុគ្គលនាំគ្នាសង្វេគស្លុតចិត្ត មិនបានចៀសចេញពីគាល់ ប្រជុំប្រឹក្សាគ្នាជាពួក ៗ តែព្រះអត្តទត្តត្ថេរមិនបានចូលប្រជុំប្រឹក្សាផង ដោយមកគិតថា គួរយើងនឹងបំពេញព្យាយាមឲ្យសម្រេចព្រះអរហត្តឲ្យបានទាន់ក្នុងវេលាដែលព្រះបរមគ្រូនៅគង់ព្រះជន្មនៅ លុះគិតដូច្នេះហើយ ក៏ចៀសចេញទៅចំរើនសមណធម៌តែម្នាក់ឯង ភិក្ខុទាំងឡាយលើកទោសថា លោកគ្មានសេចក្តីភក្តីនឹងសម្តេចព្រះបរមគ្រូ ទើបនាំសេចក្តីនោះក្រាបទូល ព្រះអង្គត្រាស់ឲ្យហៅខ្លួនមកហើយត្រាស់សួរ លោកក៏ក្រាបទូលពីគំនិតរបស់ខ្លួនឲ្យទ្រង់ជ្រាប ទើបប្រទានសាធុការ ឲ្យភិក្ខុទាំងឡាយកាន់យកជាតួយ៉ាង រួចទ្រង់សរសើរធម្មានុធម្មប្បដិបត្តិត្រាស់ថា បុគ្គលកុំគប្បីបោះបង់ប្រយោជន៍របស់ខ្លួន ព្រោះប្រយោជន៍អ្នកដទៃ សូម្បីដ៏ច្រើនឡើយ កាលស្គាល់ប្រយោជន៍របស់ខ្លួនហើយ ក៏គួរជាខ្វល់ខ្វាយកាន់យកប្រយោជន៍របស់ខ្លួនចុះ ៗ ឧទាហរណ៍នេះលើកមកឲ្យឃើញថា ប្រយោជន៍ចំពោះខ្លួន គឺផលដ៏កំពូលសំដៅយកអ្វី នឹងជាទីត្រូវការក្នុងព្រះពុទ្ធសាសនាត្រឹមណា ; ព្រោះហេតុនោះប្រយោជន៍ចំពោះខ្លួន ទើបមានផលជា ៣ ជាន់ដូច្នេះ ៗ

៦ — នៅមានគោលបាឡី ១ យ៉ាងដែលប្រែបានសេចក្ដីថា មនុស្ស ដែលគិតឃើញតែប្រយោជន៍ខ្លួន ជាមនុស្សមិនល្អ ដូច្នេះ ហេតុនេះព្រះពុទ្ធជាម្ចាស់កាលបានសម្រេចប្រយោជន៍ចំពោះព្រះអង្គពេញទីហើយ ក៏នៅទ្រង់តាំងព្រះហឫទ័យនៅក្នុងមហាករុណា ផ្សាយទៅក្នុងពពួកសត្វ មានព្រះពុទ្ធបំណងនឹងប្រោសសត្វឲ្យសម្រេចផលដូច្នោះដែរ ទើបស្ដេចស្ដាត់ទៅទេសនាប្រោសវេនេយ្យនិករ ក្នុងនិគមជនបទនោះៗ ឲ្យបានសម្រេចទិដ្ឋធម្មិកត្ថប្រយោជន៍ សម្បរាយិកត្ថប្រយោជន៍ និងបរមត្ថ-ប្រយោជន៍ តាមឧបនិស្ស័យរបស់វេនេយ្យនិករនោះ ៗ ដរាបដល់ស្ដេចចូលខន្ធបរិនិព្វាន ព្រះអង្គទើបជាទីពឹងជាទីគោរពយ៉ាងលើសលប់របស់ពួកយើងពុទ្ធសាសនិកបរិស័ទទាំងគ្រហស្ថទាំងបព្វជិត លុះដល់សព្វថ្ងៃនេះ ។ ដោយន័យនេះ ប្រយោជន៍ចំពោះអ្នកដទៃ ក៏គឺប្រោសអ្នកដទៃតាំងដើមពីបុគ្គលម្នាក់ឡើងទៅដល់ជាតិឲ្យសម្រេចផលជាជាន់ ៗ ដូចពោលហើយ ។ ឧទាហរណ៍យ៉ាងទាប ដូចយ៉ាងចេះប្រើទ្រព្យឲ្យជាប្រ-យោជន៍ដល់អ្នកដទៃ តាមសមគួរ ដើម្បីចែកហិតសុខឲ្យដល់គេ ឬក៏ប្រកបអ្នកដទៃ ឲ្យជាអ្នកមានទ្រព្យឡើងដោយឧបាយដ៏ប្រពៃ និងការចេះប្រើឲ្យជាប្រយោជន៍ ដល់អ្នកដទៃ ទាល់តែគេមានសេចក្ដីចេះដឹងតាមដូច្នេះជាដើម និងកប់ចូលក្នុងប្រយោជន៍ចំពោះអ្នកដទៃក៏បាន សូម្បីផលតាមដូន ក៏គប្បីដឹងដោយវិធីប្រៀបធៀបដូច្នេះ ។

៣ — បើប្រសិនជាមានពាក្យទទឹងទាស់មកថា ប្រយោជន៍ចំពោះខ្លួននឹងប្រយោជន៍ចំពោះអ្នកដទៃ ២ យ៉ាងប៉ុណ្ណោះក៏ល្មមហើយ ហេតុម្តេចទើបគោងមានប្រយោជន៍ទាំងចំពោះខ្លួន ទាំងចំពោះអ្នកដទៃទៀតផង ។ សូមឆ្លើយថា បានរឿងដំណាលថា ព្រះបច្ចេកពុទ្ធកាលបានសម្រេចព្រះបច្ចេកពោធិញាណហើយ លោកថា មិនបានប្រកបអ្នកដទៃឲ្យសម្រេចប្រយោជន៍ដូច្នោះទេ ហាក់បីដូច្នេះមែន នាំឲ្យសម្រេចសន្និដ្ឋានថា ព្រះបច្ចេកពុទ្ធខ្វះប្រយោជន៍ចំពោះអ្នកដទៃ, បានតែត្រាស់ដឹងចំពោះខ្លួន, បានសម្រេចផលដ៏ជាកំពូលតែចំពោះខ្លួនប៉ុណ្ណោះ ។ ពោលចំពោះក្នុងបច្ចុប្បន្ន ដូចយ៉ាងបុគ្គលអ្នកមានទ្រព្យមានបំណោះ តែជាអ្នកកំណាញ់ មិនចេះប្រើទ្រព្យប្តូរបំណោះដែលមាននៅ ឲ្យជាប្រយោជន៍ដល់អ្នកដទៃ ដូច្នេះ ទាំងខ្លួនឯងក៏ខាតប្រយោជន៍ដែលគួរបាន ទាំងកាត់ប្រយោជន៍បុគ្គលដទៃដែលគួរបានថែមទៀត ដោយភាវៈជាពួកមនុស្សផងគ្នា ព្រោះហេតុនោះ ព្រះពុទ្ធសាសនា ទើបតាំងគោលនៃប្រយោជន៍ជា ៣ គឺ ប្រយោជន៍ទាំងចំពោះខ្លួន ទាំងចំពោះអ្នកដទៃចូល ១ ថែមទៀត ដើម្បីញ៉ាំងពុទ្ធសាសនិកជនឲ្យខ្ជាប់ខ្ជួនទៅក្នុងការបំពេញប្រយោជន៍ទាំងពីរខាងដើម ។ គឺប្រយោជន៍ទាំងចំពោះខ្លួន ទាំងចំពោះអ្នកដទៃនោះ បានដល់ការប្រកបខ្លួននឹងអ្នកដទៃឲ្យសមគួរ ទាល់តែបាន

សម្រេចផលដូចពោលហើយ ។ រីឯវិស័យមនុស្សពាលកាលដឹងថា ព្រះពុទ្ធអង្គលោកប្រសើរឡើងបំពេញប្រយោជន៍ខ្លួនមុនដូច្នេះ មិនទាន់ពិចារណាឲ្យសព្វគ្រប់ថា ព្រះពុទ្ធជាម្ចាស់មានបំណងដូចម្តេច រវល់តែកេងកាសបណ្តោះបណ្តែពេលវេលាឡើយទៅ ក្នុងទីបំផុត ប្រយោជន៍ខ្លួនក៏ខូច ប្រយោជន៍អ្នកដទៃក៏ខាតទាំងគ្នា គឺគេបណ្តោយឲ្យជីវិតដែលបានមកដោយក្រ ឲ្យជាប់របស់ទទេចាកប្រយោជន៍ទាំងពីរ ។ ព្រោះហេតុនោះ អ្នកបំណងសេចក្តីចំរើនចំពោះខ្លួន ចំពោះអ្នកដទៃ មិនគួរកាន់យកគំរូយ៉ាង ព្រោះបើចាំតែការដូច្នេះក្រែងថា ជីវិតមិនប្រព្រឹត្តទៅតាមកាលបណ្តាលមានអន្តរាយក្នុងរវាងដោយស្រួលសោត ម្តេចឡើយនឹងបានឱកាសប្រកបប្រយោជន៍ ឲ្យសម្រេចប្រយោជន៍ដូចប្រាថ្នា ព្រោះអ្នកណាក៏ដោយ នឹងសូមបណ្តោះបណ្តែវេលានៃសេចក្តីស្លាប់មិនបានជាដាច់ខាត ហេតុនោះទើបមិនគួរនឹងបណ្តោះបណ្តែដូច្នោះ ។ ចំណែកឯវិស័យបណ្ឌិត គឺអ្នកដំណើរប្រយោជន៍ដោយបញ្ញា កាលពិចារណាឃើញដូច្នោះ រមែងប្រព្រឹត្តប្រយោជន៍ដើម្បីខ្លួន ដើម្បីអ្នកដទៃទាំងពីរស្ថានតែម្តង មិនបានបន្អែបន្អង់ដូចពោលហើយ ។ សូម្បីព្រះពុទ្ធជាម្ចាស់កាលសោយព្រះជាតិជាពោធិសត្វ ប្រាកដថា ព្រះអង្គទ្រង់ធ្វើទាំងប្រយោជន៍ខ្លួន ទាំងប្រយោជន៍អ្នកដទៃឡើកបបក មានសេចក្តីក្នុងវេស្សន្តរជាតកថា

ព្រះអង្គសោយព្រះជាតិជាព្រះវេស្សន្តរ ក៏បានទ្រង់បំពេញទានបារមីជាដើម ។ គួរយ៉ាងនៃប្រយោជន៍ជាន់ទេះគង់បច្ចុប្បន្ន ដូចយ៉ាងអ្នកមានទ្រព្យ ឬអ្នកមានចំណេះដ៏ត្រូវតាមគន្លងធម៌ ទេះចាប់ចាយទ្រព្យដ៏មាននៅ ឲ្យជាប្រយោជន៍ដល់អ្នកដទៃ ខ្លួនឯងក៏បានសុខ ទាំងអ្នកដទៃក៏បានសុខផង ឬយកចំណេះវិជ្ជានោះទៅប្រកបរាជកិច្ចក៏បាន ប្រកបកិច្ចជាចំណែកខ្លួនក៏បាន ខ្លួនឯងក៏បានផលប្រយោជន៍ចិញ្ចឹមជីវិត ទាំងជាប្រយោជន៍ដល់រដ្ឋបាល ដែលមានមុខងារជាអ្នកចាត់ការគ្រប់គ្រងស្រុកទេសឲ្យជាសុខដូច្នេះជាដើម យ៉ាងនេះគួររាប់ថាបានប្រយោជន៍ទាំងចំពោះខ្លួន ទាំងចំពោះអ្នកដទៃ ដោយបរិយាយមួយយ៉ាង ៗ ប្រយោជន៍ជាន់នេះ ទើបរាប់ថាជាន់ខ្ពស់ សមគួរណាស់តែអ្នកដែលប្រាថ្នាសេចក្ដីចំរើន បំណងផល ដូចពោលមក ។ ស្វាហាប់បំពេញឲ្យកើតបានឡើង នឹងបានសម្រេចផលទាន់ភ្នែកឃើញ នឹងផលតាមជូន បើបំពេញបានពេញទីក៏នឹងអាចបានសម្រេចផលដ៏ជាកំពូលជាប្រាកដ ។

## រួមសេចក្ដីហេតុរឿង

ជីវិតជាសម្បត្តិក្នុងខ្លួន នឹងជារបស់មានតំលៃ តែតោងអាស្រ័យសមគ្គភាព ទោះបីសមគ្គភាពនោះ បើខ្វះសហករណ៍ ក៏ថយកំឡាំងចុះ ៗ ចំណែកឯសហករណ៍សោត ក៏តោងប៉ុនប៉ងប្រយោជន៍ជា

គោល កាលគុណទាំង ៤ មកប្រជុំក្នុងទីជាមួយគ្នា ព្រមសព្វគ្រប់ជាធម្មសាមគ្គី រមែងមានកំឡាំងដ៏មហិមាបរិបូណ៌ដោយសម្បត្តិខាងក្នុងខាងក្រៅ ជាទីពឹងពំនាក់ដ៏មាំមួនរបស់រាងកាយនឹងចិត្តនេះ សឹងបីដូចជាដើមឈើរួមទាំងឫសកែវ ឫសរាយល្អិត ដើម មែក ស្លឹក ខ្លឹម នឹងផ្កាផ្លែ ។ គុណ ៤ យ៉ាងមានព្រមនៅក្នុងបុគ្គលឯណា រមែងធ្វើបុគ្គលនោះ ឲ្យមានជីវិតពេញទៅដោយប្រយោជន៍ទាំងចំពោះខ្លួន ទាំងចំពោះអ្នកដទៃ គ្រប់យ៉ាងគ្រប់ប្រការហោង ។

ភក្ខុមត្ត

# រឿងហៅកាំបិតបន្ទោះ

(មានតទៅខាងមុខ)

# រឿងព្រេង – រឿងចៅកាំបិតបន្ទោះ

កាលពីដើមមានបុរសពីរនាក់ បងនឹងប្អូន ម្តាយឪពុកស្លាប់អស់ទៅ នៅតែពីរនាក់បងនឹងប្អូន ក៏បបួលបងប្អូនទៅនៅវត្ត រៀនអក្សរធម៌អាថ៌សាស្ត្រាបាឡី ក៏បុរសបងប្អូនទៅនៅនឹងលោកគ្រូសង្ឃរាជ លោកក៏តែងអាណិតមេត្តាករុណាប្រៀនប្រដៅឲ្យរៀនសូត្រ ឯក្មេងបុរសទាំងពីរនាក់នឹងមានអស់ក្មេងណារៀនឲ្យស្មើក៏គ្មាន ដល់រៀនចេះចប់ លោកគ្រូលោកបំបួសនេន ឯនេនទាំងពីរពុំមានខ្ជិលតែងតែខំរៀនសូត្របំរើគ្រូពុំមានឲ្យគ្រូអាក់អន់ព្រះទ័យពីអ្វីឡើយ ហើយនេនទាំងពីរបួសបាន ៥ ព្រះវស្សាម្នាក់ ក៏ទឹកបង់សឹក នេនទាំងពីរចូលទៅវន្ទាលាគ្រូសឹក គ្រូក៏ពុំមានឃាត់ ហើយលោកគ្រូព្រមឲ្យនេនទាំងពីរសឹក ។ រួចលោកគ្រូផ្តាំបុរសបង ឲ្យទៅនៅរកស៊ីស្រុកចិន នឹងបានធំទៅសួដក្នុងស្រុកចិន ឯបុរសប្អូនគ្រូពុំមានផ្តាំអ្វី ដ្បិតគ្រូមើលឲ្យថា បុរសប្អូននឹងបានសោយរាជ្យជាស្តេចនគរពីរ ទើបលោកគ្រូលោកផ្តាំថា ឯងទៅរកស៊ី បើនឿយណាស់កុំដេក បើយកប្រពន្ធមើលម្តាយក្មេក ចូលដំណេកកុំនិយាយនឹងប្រពន្ធ បើឯងរក្សាពាក្យទាំង ៣ ម៉ាត់នេះបានស្មើថ្លៃនគរពីរ ឯអញគ្មានអ្វីឲ្យឯងទេ ឯបុរសទាំងពីរនាក់បងប្អូនលាគ្រូដើរទៅ ឯបងគ្រូផ្តាំឲ្យទៅរកស៊ីឯស្រុកចិន ។

បុរសបងក៏ទៅរកស៊ីតាមពាក្យគ្រូផ្តាំ បានជាចៅសួធំ ឯបុរសប្អូនមិនដឹងបើនឹងរកស៊ីអ្វី ក៏ទៅនៅនឹងបងប្អូនញាតិសន្តានគេក៏អាណិត ដណ្ដឹងប្រពន្ធរៀបការធ្វើផ្ទះឲ្យនៅ ឯចៅបុរសក៏ធ្វើដូចពាក្យដែលគ្រូផ្តាំក៏នៅរកស៊ីនឹងប្រពន្ធ ជួនបានស៊ី ជួនបានអត់ រកបានស៊ីព្រឹកអត់ល្ងាច រកបានស៊ីល្ងាចអត់ព្រឹក សំពត់នឹងស្លៀកក៏គ្មាន មានតែខោកញ្ចាស់ ខោមួយពាក់កណ្តាលក្អៅ ដាច់លេចមុខលេចក្រោយ ក៏បុរសនោះតែងដើរទៅកំពង់ទឹក ក្រែងមានគេមកពីស្រុកចិន នឹងបានសួរដំណឹងគេពីបង ។

គឺជួនថ្ងៃនោះមានសំពៅគេមកពីស្រុកចិន ក៏បុរសនោះចុះទៅសួរគេថា អ្នកនាយសំពៅអើយ ក្រែងបានប្រទះខ្មែរម្នាក់ផង នៅនៅរកស៊ីស្រុកចិន ៥ ឆ្នាំនេះហើយ ឯនាយសំពៅនិយាយប្រាប់ថា ឃើញខ្មែរម្នាក់ឥឡូវគេបានជាចៅសួធំ មានភរិយាកូនស្រុកចិន គ្មានអ្នកណានឹងមានស្មើគ្មាន ៗ ឯចៅបុរសសួរទៅនាយសំពៅវិញថា អ្នកនាយសំពៅអញ្ជើញទៅវិញថ្ងៃណា ឯនាយសំពៅថា ខ្ញុំ ៣ ថ្ងៃទៀតវិលទៅវិញ ហើយចៅបុរសនិយាយនឹងនាយសំពៅថា អ្នកនាយសំពៅ បើអ្នកអញ្ជើញទៅវិញឲ្យអ្នកអាណិត ខ្ញុំសូមដោយសារទៅផង ឯនាយសំពៅក៏ព្រមឲ្យទៅ បុរសនោះក៏លានាយសំពៅមកផ្ទះវិញ ក៏បុរសនោះនិយាយនឹងប្រពន្ធថា

នាងអើយ យើងសព្វថ្ងៃនេះ ក្រពិបាកណាស់ ឥឡូវឮដំណឹងបងអញគេ ទៅនៅស្រុកចិន គេមានគេបានជាចៅសួធំក្នុងស្រុកចិន ឥឡូវបងចង់ទៅ សួរ ក្រែងបងគេអាណិតឃើញឯងក្រ គេឲ្យប្រាក់កាសចាយ សំពត់ អាវស្បៀកពាក់ខ្លះ ឯប្រពន្ធឮប្ដីស្រដីដូច្នោះ សួរថា ចុះអ្នកទៅនឹងអ្នក ណា ឯចៅបុរសជាប្ដីប្រាប់ប្រពន្ធថា បងជោយសារសំពៅគេទៅ គេ ព្រមឲ្យទៅហើយ ៣ ថ្ងៃទៀត គេចេញសំពៅទៅ ឯប្រពន្ធថា អើអ្នក ទៅក៏ទៅចុះ លុះដល់ ៣ ថ្ងៃក៏ចៅបុរសចុះទៅ នាយសំពៅគេឃើញ ចៅបុរសនោះទៅ គេក៏ហៅចុះសំពៅបើកចេញទៅ បើកសំពៅរៀងទៅ ឯចៅបុរសក៏មើលថែទាំជួយរក្សារបស់ទ្រព្យនាយសំពៅ ឯនាយសំពៅ ឃើញចៅបុរសនោះមានគំនិតមារយាទល្អក៏ស្រឡាញ់រាប់អាន អាណិត ឲ្យបាយទឹកស៊ីតែសព្វថ្ងៃរៀងទៅ ៗ ឯមេប្រពន្ធចៅបុរសនោះ ពីក្រោយ ចៅបុរសទៅស្រុកចិនលួចមានសហាយយកមកដេកយប់ ៗ ថ្ងៃឲ្យទៅវិញ ឯចៅបុរសក៏ទៅជាមួយនឹងនាយសំពៅ ។ លុះដល់ស្រុកចិនក៏ចៅបុរស នោះសួរនាយសំពៅវិលទៅស្រុកខ្មែរវិញថ្ងៃណាប្រាប់ខ្ញុំផង ឯនាយសំ-ពៅក៏ប្រាប់ទៅចៅបុរសនោះថា ខាន ៣ ថ្ងៃទៀតនឹងចេញសំពៅ ចៅ បុរសនោះឮថាដូច្នោះ ក៏ឡើងទៅសួររកបងដើរទៅដល់មាត់ទ្វារផ្ទះបង នោះ ឃើញមនុស្សនៅចាំទ្វារនោះសួរថា អ្នក នេះហើយឬ ផ្ទះលោក

ចៅស្លូខ្មែរ ឯអ្នកចាំទ្វារប្រាប់ថា នេះហើយផ្ទះលោកចៅស្លូ អ្នកចាំផ្ទះសួរទៅចៅបុរសវិញថា អ្នកឯងមកពីណា មកសួររកផ្ទះលោកចៅស្លូ ឯបុរសនោះប្រាប់ថា ខ្ញុំមកពីស្រុកខ្មែរ ឯលោកចៅស្លូនេះលោកជាបងខ្ញុំបង្កើត ឯមនុស្សដែលចាំទ្វារ មើលទៅរូបចៅបុរសនោះមិនសមជាបងប្អូននឹងលោកចៅស្លូនោះសោះ រូបក៏អាក្រក់ ស្លៀកខោពាក់កណ្ដាលភ្លៅ សំពត់គ្មានដណ្ដប់ ខោស្លៀកពាក់កណ្ដាលភ្លៅ លេចមុខលេចក្រោយ មើលទៅមិនគួរសម ជាប្អូនលោកចៅហ្វាយអញសោះ ។ អាដែលចាំទ្វារវាមិនស្ងៀម វាទៅប្រាប់នាងជាប្រពន្ធចៅស្លូនោះ ឯចៅស្លូមិននៅទៅគាល់ស្ដេច អានោះវាទៅដល់វាជំរាបថា អ្នកចៅហ្វាយស្រី មានមនុស្សកំសត់ម្នាក់មកពីស្រុកខ្មែរ រូបនោះអាក្រក់ស្លៀកសំពត់ខោពាក់កណ្ដាលភ្លៅ ទឹងគន់ទៅខោនោះដាចដាច់ លេចមុខលេចក្រោយ ហើយប្រាប់ខ្ញុំបាទថា ត្រូវជាប្អូនលោកចៅហ្វាយប្រុសបង្កើត ឥឡូវខ្ញុំបាទឲ្យនៅ ៗ មាត់ទ្វារ ។ ឯនាងជាប្រពន្ធចៅស្លូនោះនឹកខឹងថា អាដែលមនុស្សកំសត់ទុគ៌តពីណា ក៏ហ៊ានមកពោលបង្កាច់កេរ្តិ៍ថា ប្ដីអញជាបងវាបង្កើត នាងនោះខឹង ប្រើមនុស្សឲ្យទៅចាប់ចៅបុរសនោះមកដាក់ច្រវាក់ទុកនៅពេនសេះថា ចាំប្ដីមកនឹងឲ្យយកទៅសម្លាប់ ឯចៅបុរសនោះគេយកទៅដាក់ច្រវាក់ក៏នឹកថា ខុអញអើយ សង្វាតមកពីស្រុកខ្មែរដល់ស្រុកចិន ព្រោះផ្សែតតែបង ឥឡូវគេមាន គេពុំគិតករុណាតណាមដែលកើតមកពោះ

ជាមួយគ្នា គេធ្វើមាន គេហ៊ានចាប់ឯងមកដាក់ច្រវាក់គិតនឹងសម្លាប់ផង ខ្ញុំអញអើយ បើនៅស្រុកខ្មែរ រកស៊ីតាមខ្លួនក៏គ្មាននរណាហ៊ានធ្វើបាបខ្លួន ឯចៅប្រុសនោះពុំដឹងជាបងទៅគាល់ស្តេច ។ លុះចៅសួជាបងវិលមកដល់ផ្ទះប្រពន្ធក៏ប្រាប់ថា ជាបងបង្កើត តែប្អូននោះអាក្រក់ស្លៀកខោពាក់កណ្ដាលក្ដៅដាច់លេចមុខលេចក្រោយ ឥឡូវខ្ញុំឲ្យដាក់ច្រវាក់ទុកនៅរោងសេះ ចាំលោកអញ្ជើញមកឲ្យនាំទៅសម្លាប់ ។ ឯចៅសួជាបងឮហើយថា ទៅយកវាមកមើលក្រែងប្អូនបង្កើតមែន ហើយចៅសួឲ្យដោះច្រវាក់ចៅប្រុសនោះមកដល់ស្គាល់ជាប្អូនប្រាកដមែន ក៏រៀបបាយឲ្យស៊ីរួច មើលទៅប្អូនក៏ក្រស្លៀកខោពាក់កណ្ដាលក្ដៅ នឹងគិតពិតពិលមើលទៅក៏ក្រម៉្លេះ ហើយចៅសួឲ្យខោមួយស្លៀក ហើយសួរប្អូនថា ប្អូននៅនាយក្រអ្វីម៉្លេះ សព្វថ្ងៃរកស៊ីអ្វីនឹងគេ ឯចៅប្រុសជាប្អូនប្រាប់បងថា ខ្ញុំនៅនាយមិនដឹងរកស៊ីអ្វីទេ ក្រណាស់ហើយមានប្រពន្ធផង រកតែអីស៊ីគ្មាន ឯបងឮប្អូននិយាយដូច្នោះនឹកអាណិតប្អូនមិនចេញស្តី ។ ហើយសួរថា ប្អូនមកដោយសារអ្នកណា ឯចៅប្រុសជាប្អូនជំរាបថា ខ្ញុំមកនឹងនាយសំពៅគេឲ្យដោយសារមក ឯចៅសួជាបងថា ចុះគេទៅវិញថ្ងៃណា ចៅប្រុសប្អូនប្រាប់បងថា ៣ ថ្ងៃទៀតគេចេញសំពៅទៅវិញ ។ ចៅសួជាបងដឹងដូច្នោះ ក៏ស្ងៀមទៅ ឲ្យលើកបាយមកហៅចៅប្រុសជាប្អូនស៊ីជាមួយគ្នា លុះស៊ីរួចប្រាប់ប្អូនថា ប្អូននៅដេក

លេងទៅផ្ទះនេះបុះ  បងទៅលេងផ្ទះចិនសែ  ឯចៅស្លូជាបងទៅដល់ផ្ទះ ចិនសែ  ចិនសែឃើញចៅស្លូទៅដល់ក៏រៀបតោគី ថ្នាំចិន ខ្សៀ ទឹកតែ ទទួល  ហើយចៅស្លូនិយាយនឹងចិនសែថា  អ្នកចិនសែ  ខ្ញុំមករកមើល ឲ្យប្អូនខ្ញុំបន្តិច  ក៏នឹងបេះតែក្រដូចប្អូនទៅ  ឬក៏នឹងគ្រាន់បើនឹងគេឡើងដែរ ឬនៅតែក្រយ៉ាងហ្នឹងទៅ  ។  ឯចិនសែទាញសៀវភៅមកមើលសព្វ ។ ទៅ  ទាយថា  ប្អូនលោកមិនជាអ្នកក្រលំបាកទេ  ដល់ ៧ ឆ្នាំនឹង បានសោយរាជ្យ  ជាស្ដេចនគរតើ  លោកនឹងបានជាធំសំរាប់រាជការ ដោយសារប្អូន  ប៉ុន្តែឥឡូវលំបាកណាស់  ដល់វិលទៅស្រុកវិញ ពាក់កណ្ដាលផ្លូវ  នឹងបានទ្រព្យដំឡៃនគរតើជាសំរាប់ខ្លួន  តែថាឃ្លាត ទៅវិញទ្រព្យនោះ  ដល់កំណត់បានសោយរាជ្យ  នឹងបានមកជាសំរាប់ បុណ្យវិញទាំងអស់  ឯចៅស្លូបានដឹងដំណើរប្អូនដូច្នោះ  ក៏លាចិនសែ ទៅផ្ទះវិញ ។ ដល់ ៣ ថ្ងៃនាយសំពៅគេផ្ទុកសំពៅរួចអស់  ចៅប្រុស និយាយប្រាប់បងថា  អ្នកបងខ្ញុំបង់លាអ្នកបងទៅ  ដ្បិតសំពៅគេនឹង ចេញទៅថ្ងៃនេះហើយ  ។  ឯចៅស្លូជាបងយកផាឌិបមកហែកមួយត្បង ហុចឲ្យទៅចៅប្រុសជាប្អូន  ឯចៅប្រុសជាប្អូន  ក៏ទទួលយកផាឌិបមួយ ត្បងណាបង់ចុះទៅ  ដើរបណ្ដើរគិតបណ្ដើរ  នឹកតូចចិត្តស្ទើរមិនចង់ កាន់ផាឌិបនោះសោះ  ចៅប្រុសបេះតែនឹកតូចចិត្តថា  ឱបងប្អូននឹងគ្នាអត់ពី ឪពុកម្ដាយស្លាប់ចោលទៅ  នៅកំព្រាតែបងប្អូនពីរនាក់  កាលវេលាក្រ

បេះស្រឡាញ់គ្នា កប់អានគ្នា ដល់វេលាមានទាត់គ្នាចោល ធ្វើមានស្មើរមិនកប់គ្នា មាសប្រាក់ដាក់ឃ្លាំងគរគោក មិនហ៊ានយកឲ្យគ្នាមួយស៊ីង យកខ្មោចអាផាឌុបឲ្យគ្នាមួយតម្រង ១ ចៅបុរសនោះដើរទៅដល់សំពៅឡើងលើសំពៅ នាយសំពៅគេឲ្យក្ដូនឈ្មួលស្រាវយុថ្កាសាក្ដោងបើកទៅ ហើយនាយសំពៅសួរចៅបុរសនោះថា ប្អូនទៅឯលោកចៅសួ លោកឲ្យអ៊ីខ្លះ ចៅបុរសប្រាប់នាយសំពៅថា គ្មានឲ្យអីទេ ឲ្យតែផាឌុបមួយត្បូងទំនាំខោមួយ នាយសំពៅបានដឹងហើយក៏ស្ងៀមទៅ លុះបើកសំពៅទៅដល់កណ្ដាលផ្លូវយប់ងងឹតទឹងទៅពុំរួចបោះយុថ្កាដេក ឯចៅបុរសហេតុតែបុណ្យគាត់ដល់ ក៏នឹកឃើញពាក្យដែលគ្រូផ្ដាំថា នឿយកុំឲ្យដេក ឥឡូវអស់អ្នកសំពៅនេះដេកអស់ ដូច្នេះ អញកុំដេក ក៏ចៅបុរសនោះអង្គុយនៅក្បែរដងក្ដោងពុំហ៊ានដេក លុះដល់អធ្រាត្រយក្ខវ៉ាហោះមកឃើញសំពៅ វ៉ាចុះមកប៉ងទឹងស៊ីអស់មនុស្ស ហើយវ៉ាឈ្ងោកមើលទៅក្នុងសំពៅ ធ្លាក់ពុកមាត់ទៅលើចៅបុរសនោះៗ ក៏ស្រវ៉ាស្ទុះទៅចាប់ជាប់ហើយថា អាឯងស្លាប់នឹងដៃអញឥឡូវនេះហើយ យក្ខឮចៅបុរសនោះថាដូច្នោះ គិតភ័យនឹងស្ទុះទៅមិនរួច ដ្បិតចៅបុរសនោះចាប់ពុកមាត់ជាប់ ក៏យក្ខភ័យក្រែងស្លាប់ យក្ខនិយាយទៅនឹងចៅបុរសថា អ្នកបុរសអើយ បើអ្នកករុណាគខ្ញុំលែងខ្ញុំៗ នឹងតបគុណអ្នកជាខ្សែរចងឯង ដម្បងវាយឯង ឆ្នាំងផ្ទុនឯង ឯខ្សែរនឹងដម្បង បើមានបច្ចាមិត្រ

ពីណាមកប្រមាថជាទីអហង្ការ ឲ្យតែខ្សែទៅចង ជម្ពូងទៅកាយ ក៏
បច្ចាមិត្រនោះស្លាប់វិនាសអន្តរាយអស់ ឯឆ្នាំងនេះបើឃ្លានអាហារចំណី
ហើយនឹកចង់បរិភោគអាហារចំណីអ្វីប្រាប់ឆ្នាំងថា ឆ្អិនឡើងអញស៊ី ក៏
ឆ្អិនឯងឡើងបានបរិភោគមិនបាច់ដាំឡើយ ។ ចៅប្រុសនោះ បានដឹង
ដូច្នោះហើយថា បើដូច្នោះ យកខ្លួនឯងឲ្យបកស័មអញលែង ឯយក្ខក៏ហុច
អស់ប្រដាប់ទាំងនោះមកចៅប្រុស ចៅប្រុសក៏ទទួលយក លែងយក្ខៗ
ក៏ហោះទៅស្ថានលំនៅវិញ ។ លុះព្រឹកឡើងចៅប្រុសនិយាយប្រាប់
នាយសំពៅថា អ្នកនាយសំពៅយប់មិញមានយក្ខមួយមកគិតនឹងស៊ីយើង
ពល់គ្នា កុំតែបានខ្ញុំយក្ខរាយកទៅស៊ីទាំងអស់ បើអ្នកនាយសំពៅមិនជឿ
ខ្ញុំ យក្ខរាឲ្យសំណូកខ្ញុំផង មានខ្សែចងជម្ពូងកាយឯង ឆ្នាំងឆ្អិនឯង នាយ
សំពៅឮដូច្នោះហើយថា នៅឯណាប្អូន យកមកឲ្យបងមើលផង ចៅ
ប្រុសហេតុតែខ្លួនត្រង់ ក៏យករបស់ទាំងនោះមកបង្ហាញនាយសំពៅ ឯ
នាយសំពៅឃើញរបស់ទាំងនោះទើបថា របស់នេះជាទ្រព្យមានដំឡៃ
ឥតមានស្មើបណា នាម៉ឺនណាមាន ចៅប្រុសនេះក៏មានសំណាងអីខ្ពស់
ម៉្លេះ បានទ្រព្យយ៉ាងនេះ ហើយនាយសំពៅនឹកក្នុងចិត្តថា ចៅប្រុស
នេះល្ងង់ឆោតម៉្លេះ អញគិតបញ្ឆោតថា ទុករក្សាឲ្យ បើបើកសំពៅទៅ
មានគ្រោះត្រង់ណា អញនឹងបញ្ឆោតឲ្យឡើង អញបើកសំពៅចោល
អញយកទ្រព្យទាំងនេះ ។ នាយសំពៅគិតដូច្នោះហើយ និយាយថា

ប្អូនទ្រព្យរបស់ទាំងអស់នេះ ឲ្យមកបងទុកក្សាឲ្យ ដ្បិតប្អូនឯងគ្មានហិបដាក់ ឯចៅបុរសគិតថា ជានាយសំពៅគេយកទៅទុកក្សាឲ្យតាមត្រង់ មិនដឹងជាគេនឹងគិតទុច្ចរិតនឹងខ្លួននោះពុំដឹងឡើយ ហើយក៏យករបស់ទាំងនោះប្រគល់ទៅនាយសំពៅទាំងអស់ ។ ឯនាយសំពៅក៏ទទួលបើកសំពៅ ដល់ទៅចុងកោះមួយមានដើមល្វាមួយដើម ដុះនៅក្នុងទឹក ក៏សំពៅបើកទៅដល់ នាយសំពៅឲ្យចាប់ឈប់ ហើយនាយសំពៅនិយាយនឹងចៅបុរសថា ចៅបុរស បងចង់ប្រើប្អូនឲ្យឡើងបេះផ្លែល្វាស៊ី ឯចៅបុរសឮនាយសំពៅប្រើក៏ឡើងដើមល្វាបេះផ្លែ មិនដឹងជាគេនឹងចេញសំពៅទៅចោលនោះមិនដឹង ហើយនាយសំពៅចង្អុលថា ទំប្អូនឡើងទៅមែកលើ ប្អូនបេះអាចង្កោមធំនោះឲ្យបង ឯចៅបុរសក៏ឡើងទៅមែកលើ នាយសំពៅឲ្យកូនឈ្នួលច្រានសំពៅបើកទៅចោលចៅបុរស ។ ឯចៅបុរសក៏ស្រែកហៅគេ ឲ្យគេមកយកក៏គេពុំមក ចៅបុរសមកគិតថា ឱអញអើយ គេបញ្ឆោតឲ្យឡើងដើមល្វា គេចេញសំពៅទៅចោល គេគិតយករបស់ឯង ខ្លួនឯងគេចោលឲ្យស្លាប់ម្នាក់ឯងកណ្ដាលសមុទ្រ បើនឹងស្លាប់នឹងរស់ ក៏ឆ្នាំងផ្អិនឯងនោះនៅទៅក៏នឹងគ្រាន់ឲ្យផ្អិនបាយបំណីស៊ី ក្រែងមានសំពៅគេមកនឹងសុំដោយសារគេទៅ ឥឡូវបាយក៏អត់ សំពត់ដណ្ដប់ក៏គ្មានសមនឹងស្លាប់ពុំលែង ក៏បុរសនោះ នឹកអាណិតអាណាតអាត្មា ក៏យំសោកទ្រព្យកាយ ៗ

លុះយប់មានជ្រូកមួយតែងមកស៊ីផ្លែល្ហុងទុំ តែជ្រូកនោះមានកែវពាំដើរលើទឹកបាន លុះអធ្រាត្រស្ងាត់ជ្រូកនោះពាំកែវដើរលើទឹកមកទីងរើសផ្លែល្ហុងស៊ី ក៏បុរសនោះមើលទៅឃើញជ្រូកនោះ ចូលមកពីនាយដើងនោះ ញ៉ាំពាំកែវបោលលើទឹកមកដល់គល់ល្ហុង ដាក់កែវរើសផ្លែល្ហុងស៊ី បុរសនោះឃើញជ្រូកដាក់កែវនៅគល់ល្ហុង ក៏បេះផ្លែល្ហុងបោលឲ្យធ្លាយឲ្យជ្រូកតាមស៊ី នឹងគិតឆក់យកកែវជ្រូកនោះ ក៏ហេតុតែកុសលចៅបុរសនោះបុណ្យនឹងមាន ក៏ជ្រូកនោះស៊ីធ្លាយទៅពីកែវ ចៅបុរសស្ទុះចុះមកឆក់កែវជ្រូកបានរត់ចេញទៅ ក៏បុរសនោះចាំដើរទាំងយប់ ៗ លុះព្រឹកទាន់សំពៅ ស្រែកហៅថា អីអ្នកនាយសំពៅ ចាំខ្ញុំផង ឯនាយសំពៅឮមាត់បែរមើលទៅ ឃើញស្គាល់ជាចៅបុរសឲ្យមូរក្ដោងឈប់ចាំ ចៅបុរសទៅដល់ឡើងលើសំពៅនិយាយថា ឱអ្នកបងនាយសំពៅ មិនគួរគិតអាក្រក់មកបោលខ្ញុំឲ្យស្លាប់កណ្ដាលសមុទ្រ ប៉ុន្តែកុសលខ្ញុំមានកុំអីស្លាប់បង់អសារតែម្នាក់ឯង ឯនាយសំពៅឆ្លើយដោះថា ឱប្អូនអើយ បងស្មានជាប្អូនចុះមកខាងក្បាលសំពៅហើយ បងមិនមានគិតបង់បោលប្អូនទេ ហើយនាយសំពៅថា អើប្អូនបានអ្វីដើរលើទឹកបាន ចៅបុរសថា ខ្ញុំបានកែវជ្រូកបានជាខ្ញុំដើរលើទឹកបាន ៗ នាយសំពៅហេតុតែចិត្តអកតញ្ញូ ក៏ថា ប្អូនឲ្យបងបងទុកឲ្យ ឯចៅបុរសគិតឃើញថា នាយ

សំពៅនេះ ក៏គិតបញ្ឆោតអញទៀតហើយ ចៅបុរសនិយាយថា អ្នកនាយសំពៅ ឲ្យយករបស់មុនទាំងអស់មកឲ្យខ្ញុំ ៗ នឹងប្រមូលឲ្យមូល សឹមជូនទៅអ្នកវិញ ឯរបស់នេះនឹងប្រយោជន៍អីដល់ខ្ញុំ គង់តែខ្ញុំជូនអ្នកទាំងអស់ទេ នាយសំពៅឮដូច្នោះទឹកថា កាផែនចៅបុរសនេះ ក៏ជាអ្នកល្ងង់គង់តែបានមកដៃអញទាំងអស់ ក៏នាយសំពៅយកខ្សែចង់ដំបងវាយឯង ឆ្នាំងឆ្អិនឯងនឹងផាឹបមួយក្បួង នឹងខោមកឲ្យចៅបុរស ៗ ក៏ទទួលរៀបរៀបរួបសព្វគ្រប់ ក៏សំពះនាយសំពៅលាចុះដើរលើទឹកទៅ ឯនាយសំពៅក៏ទឹកស្គាយក្រោយ មិនចេញស្ដីមួយម៉ាត់ ៗ ឯចៅបុរសក៏ខំដើរដោយអំណាចកែវ ផ្លូវដើរចម្ងាយ ៧ យប់ ចៅបុរសដើរតែ ១ ថ្ងៃ ដល់ព្រលប់ដល់ផ្ទះ ៗ ក៏ចៅបុរសទៅដល់ផ្ទះស្រែកហៅប្រពន្ធថា នាងអើយនាង បើកទ្វារឲ្យបងទៅផង បងមកដល់ហើយ ឯមេប្រពន្ធជាស្រីអាក្រក់ក្បត់ចិត្តប្ដី ដេកឱបសហាយឮមាត់ប្ដីហៅឆ្លើយថា អ្នកណាហៅអី ប្ដីអញមិននៅកុំមកហៅ ៗ ចៅបុរសឮប្រពន្ធថាដូច្នោះ ទឹកថាប្រពន្ធចិត្តត្រង់នឹងខ្លួន ក៏ឆ្លើយទៅថា ទេបង:វតើនាង មេប្រពន្ធក៏ថាបើអ្នកទេឬ ខ្ញុំគិតថា ជាមនុស្សផ្ដេសផ្ដាសក៏ហៅខ្ញុំ ហើយមេនោះក៏ថាអ្នកចាំខ្ញុំអុជចន្ទះសិន តែក៏បណ្ដោះសហាយក៏សោះ ឯចៅបុរសក៏ជីកដីក្រោមមាត់ជណ្ដើរ ហើយកប់កែវនឹងខ្សែចងជម្រូងឆ្នាំងឆ្អិនឯង រួបលុប

ដើរទៅ មេនោះបណ្ដោះសហាយពួន ។ ពំអុសបន្ទះចុះមកទទួលប្ដីឡើងទៅ
លើផ្ទះរៀបចាយទឹកឲ្យប្ដីស៊ីរួច ពំនាំប្ដីចូលដេក ។ ហើយពំនិយាយសួរថា
អ្នកទៅស្រែកចិនបានអីមកខ្លះឆ្ងើញ ចៅប្រុសជាប្ដីប្រាប់ទៅប្រពន្ធថា បង
គ្មានបានអីទេ បងគេឲ្យតែខាមួយ ផាឌីបមួយត្បូង មេនោះធ្វើជាយំស្រែក
ថា មិនមែនទេ អ្នកកុហកខ្ញុំ មិនដែលនរណាទីងទៅដល់បងហើយគេ
មាន ក៏ទីងឲ្យផាឌីប ១ ត្បូងខាមួយផងណោះទេ ឯចៅប្រុសទឹកដល់ពាក្យ
គ្រូផ្ដាំថា ចូលដំណេកកុំនិយាយទីងប្រពន្ធ ក៏ចៅប្រុសនោះថា ព្រឿយ
នាងព្រឹកសឹមបងប្រាប់ ឯអាសហាយមេនោះលបស្ដាប់ក្រោមផ្ទះ ហើយ
មេនោះសួរប្ដីទៀត ចៅប្រុសនោះទឹកគិតថា ប្រពន្ធចិត្តត្រង់នឹងខ្លួន ក៏
អាណិតប្រពន្ធ នឹងចង់ប្រាប់ក្រែងខុសនឹងបណ្ដាំគ្រូ ក៏ហេងហាងចិត្ត ឯ
មេនោះទទូចតែសួរក៏ភ្លេចដោយចិត្តដែលអាណិតប្រពន្ធក៏ប្រាប់ថា គ្មាន
បានអីទេ បានតែកែវដ្រូក ១ ខ្សែបង់ឯង ដម្បងក់យឯង ឆ្នាំងថ្មិនឯង
គ្មានបានអីទេ ឯមេនោះទទូចសួរទៀត ក៏ចៅប្រុសយល់ឃើញថា យប់
នោះស្ងាត់ មិនដឹងជាសហាយមេប្រពន្ធនោះនៅក្រោមផ្ទះ ក៏ប្រាប់
ប្រពន្ធថា បងកប់ក្រោមមាត់ជណ្ដើរ ឯមេនោះដឹងថា ឃើញ្ញ បានកែវ
ដ្រូក ១ ខ្សែបង់ដម្បងក់យឯង ឆ្នាំងថ្មិនឯង ប្ដូរយើ កប់នៅក្រោមជណ្ដើរ
មុខផ្ទះ រីឯសហាយត្បូងនោះ ក៏ពមកគាស់អស់ទៅ ឯចៅប្រុសនោះនឹង

មេប្រពន្ធក៏ដេកលក់ទៅ ៗ លុះព្រឹកព្រេកឡើង ចៅបុរសនោះ ទៅរករបស់នោះបាត់អស់មនុស្សគាស់យកអស់ឃើញតែស្នាម ក៏ចៅបុរសនោះមិនចេញស្តី នឹកថា ប្រពន្ធអញមានសហាយ ក៏បុរសនោះធ្វើឃ្នាងដាក់ដណ្តីរយកខ្សែអូសទៅប្តឹងចៅក្រមសាលា ចៅក្រមសាលាទទួលដំរះរាយដណ្តីរពិចារណាសួរថា ដណ្តីរឯងទទួលបញ្ញើចៅបុរសនេះ ម្តេចក៏ឯងឲ្យមនុស្សលួចរបស់គេអស់ ឯចៅក្រមហេតុតែជាអ្នកឥតប្រាជ្ញាមិនយល់ការកាត់ជ្រៅ ៗ

(មានតទៅទៀត)

# ពិធីថ្វាយបង្គំអារ

# ពិធីថ្វាយបង្គំងារ

អ្នករាជការគ្រប់ក្រុមគ្រប់ក្រសួង កាលធ្វើរាជការទៅមានគុណបំណាច់សមគួរហើយ ព្រះករុណាជាម្ចាស់ជីវិតលើត្បូងតែងទ្រង់ព្រះមេត្តាប្រោសឲ្យមានយសសក្ដិជាមន្ត្រីមានទីហ៊ានជាដើមទៅ តាមគួរដល់គុណបំណាច់របស់អ្នកនោះ ៗ អ្នកដែលបានទទួលព្រះរាជទានយសសក្ដិជាដំបូងក្ដី ឬអ្នកដែលបានឡើងយសសក្ដិអំពីឋានន្តរមុនក្ដី កាលព្រះករុណា ៗ ទ្រង់ព្រះមេត្តាឲ្យព្រះហស្តលេខាក្នុងព្រះរាជប្រកាសហើយ ឬទ្រង់ព្រះមេត្តាប្រោសព្រះរាជទានដោយព្រះបន្ទូលពេចន៍ហើយ នោះត្រូវរៀបចំថ្វាយបង្គំទទួលងារតាមទំនៀម ៗ

ការថ្វាយបង្គំទទួលងារនោះមិនមានកំណត់ថ្ងៃខែទេ ស្រេចហើយនូវព្រះករុណា ៗ នឹងសព្វព្រះរាជហឫទ័យ ឲ្យថ្វាយបង្គំវេលាណាក៏រៀបចំថ្វាយបង្គំវេលានោះ តែក្នុងសម័យនេះច្រើនរមែងថ្វាយបង្គំក្នុងឱកាសបុណ្យចំរើនព្រះជន្មតែម្ដង ៗ

មុនដែលនឹងថ្វាយបង្គំងារម្ដង ៗ នោះ ត្រូវមុខក្រសួងតាងហ្វាងក្រុមព្រះរាជមន្ទីរធ្វើសេចក្ដីកយងារ គឺកយងារនាម និងឋានន្តរ របស់មន្ត្រីទាំងអំបាលនោះ ឡើងក្រាបបង្គំទូលព្រះករុណា ៗ ទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទជាមុនសិន ៗ ព្រះករុណា ៗ សព្វព្រះរាជហឫទ័យ

ឲ្យថ្វាយបង្គំថ្ងៃណា ក៏ត្រូវប្រាប់មកឲ្យដំណឹងដល់មន្ត្រីអំពាលនោះ ឲ្យប្រុងប្រៀបប្រដាប់តាមការ ។

## ១ — ប្រដាប់ថ្វាយបង្គំ

ក — ស្លាព្រះពារ ១ (គឺមានកន្ទោង ១ ដាក់ផ្កា មានគ្របធ្វើដោយស្លឹកចេក គេឲ្យមានកំពូលស្រួច រួបម្រម្ម ៣ រម្ហូរ ។ ទៅសៀតខ្ចាស់ ទឹងគ្របស្លាព្រះពារ មានផ្លែស្លាទុំប្រុំដោតជុំវិញ មានចំនួនតាមសក្តិ ទឹងមានផ្កាភក់ប្រក់ម្ទេះដោតទឹងកន្ទាល់ដូង ដោតរៀងកាយនៅកំពូលស្លាព្រះពារនោះមានចំនួនតាមសក្តិ ដូចគ្នាទឹងចំនួនទៀន) ដាក់លើជើងពានកែវ ឬប្រាក់-មាសក៏បាន ។

ខ — ទៀនក្រមួនឃ្មុំ ក្នុងទៀន ១ ទម្ងន់ ៣ ដំឡឹង មានចំនួនតាមសក្តិ គឺបើសក្តិ ៣ ហ៊ឺពាន់ ទៀន ៣ ។ ល ។ សក្តិ ១០ ហ៊ឺពាន់ ទៀន ១០ ។ ដូចមានពោលហើយក្នុងព្រះរាជពិធីចូលឆ្នាំថ្មី ។ ពានស្លាព្រះពារនោះមានគោករងតាមកំណត់ដូច្នេះ ពីសក្តិ ៨ ហ៊ឺពាន់ចុះមកមានគោករង ១ ជាន់ សក្តិ ៩ ហ៊ឺពាន់ឡើងទៅមានគោករង ២ ជាន់ ។ ទឹងមានប្រាក់ក្នុងម្នាក់ ៣ រៀល ៨០ សេន ។ ប្រាក់នេះត្រូវដាក់ឃ្លាំងហ្លួង ។

## ២— សំលៀកបំពាក់

មន្ត្រីអ្នកថ្វាយបង្គំ ត្រូវស្លៀកសំពត់សារបាប់ - ស្ទៀក - ហូលជារ-ផាមួងយ៉ាងឯណាមួយក៏បាន, ពាក់អាវ សារបាប់ - ខមវាប អត្តឡាត់

ផ្កាថាសយ៉ាងឯណាទីមួយក៏បាន តាមសមគួរដល់យសសក្តិ ។ ទីងពាក់អាវផាយក្រហមពីក្រៅ (និយាយតាមទំនៀមឥឡូវនេះ ទីងពាក់ស្បែកជើងខ្មៅ ស្រោមជើងខ្មៅផង) ។

## ៣— រៀបទីថ្វាយបង្គំ

ក្រមកម្រាលត្រូវរៀបក្រាលព្រំចៀមចំ នៅក្នុងព្រះទីនាំងណាមួយតាមដែលត្រូវការ ។ ក្រមមហាឡឹកត្រូវតាំងព្រះទីនាំងកៅអី សម្រាប់ព្រះករុណាគង់ តាំងតុតូច ១ ខាងស្តាំព្រះទីនាំងកៅអី ហើយអញ្ជើញគ្រឿងសម្រាប់ព្រះករុណាមកដំកល់លើតុនោះ ទីងរៀបម៉ាបិទ ១ ពីខាងមុខព្រះទីនាំង ។

ដល់វេលា មន្ត្រីអ្នកថ្វាយបង្គំអំបាលនោះ ត្រូវទៅជួបជុំនៅក្នុងព្រះបរមរាជវាំង ។ ចាងហ្វាងក្រមព្រះរាជមន្ទីរជាក្អាក់ង៉ារនាំថ្វាយបង្គំ ត្រូវនាំមន្ត្រីអំបាលនោះទៅរង់ចាំព្រះករុណា នៅទីក្រឡាព្រះតំនាល់ យកស្លាព្រះពារទៅដាក់ដំកល់លើជើងម៉ាខាងមុខព្រះទីនាំង រៀងគ្នាតាមយសសក្តិធំ-តូច មន្ត្រីទាំងនោះឈរនុបដៃជំរៀបគ្នាជាជួរគ្នាតាមយសសក្តិធំ-តូច ។

## ៤— ថ្វាយបង្គំ

ដល់វេលា ព្រះករុណាស្តេចចេញប្រថាប់នៅព្រះទីនាំងកៅអីដែលរៀបចំថ្វាយ ។ មន្ត្រីអំបាលនោះក្រាបថ្វាយបង្គំ ៣ ដង ។ លំដាប់នោះចាងហ្វាងក្រមព្រះរាជមន្ទីរក្រាបបង្គំទូលថ្វាយថា :

សូមព្រះតេជះដ៏កល់លើត្បូង សូមព្រះរាជទានក្រាបបង្គំទូលព្រះករុណា ជាម្ចាស់ជីវិតលើត្បូងស្ងួនទ្រង់ជ្រាប ក្រោមលម្អងធូលីព្រះបាទ វេលានេះជាមង្គលឫក្សដ៏ប្រសើរ ពួកមន្ត្រីអំបាលនេះដែលព្រះករុណាទ្រង់ព្រះមេត្តាប្រោសឲ្យឡើងយសសក្តិ គឺឈ្មោះ.... នេះ ទ្រង់ព្រះមេត្តាប្រោសឲ្យឡើងជា.... សក្តិ..... ហ៊ូពាន់ ដំណែងរាជការក្នុងក្រុម..... ឬក្នុងក្រសួង........ (ថាទាល់គ្រប់ឈ្មោះ) បានទទួលព្រះពរថ្ងៃ ។

ព្រះករុណា មានព្រះរាជឱង្ការដោយព្រះឱស្ឋថា ឈ្មោះនេះ ទ្រង់ព្រះមេត្តាប្រោសឲ្យធ្វើជា...... នេះ (ដរាបដល់គ្រប់ឈ្មោះតាមចំនួនដែលបានហៅក្នុងព្រះរាជមន្ទីរក្រាបបង្គំទូលជូន) ។

ចប់ហើយមន្ត្រីអំបាលនោះថ្វាយបង្គំ ៣ ដង ។ ព្រះករុណាទ្រង់ព្រះមេត្តាប្រោសបាចផ្កាព្រះរាជទានព្រះពរ នឹងព្រះបរមរាជោវាទតាមសមគួរឲ្យជាការចំរើនសួស្តីមង្គលដល់មន្ត្រីអំបាលនោះ ចប់ហើយមន្ត្រីអំបាលនោះថ្វាយបង្គំ ៣ ដងទទួលព្រះពរនឹងព្រះបរមរាជោវាទ ។

## ៥ – ទទួលព្រះរាជទានទឹកពិព្រទ្ធសច្ចា

លំដាប់នោះ ចៅក្នាក់ការលើកទឹកពិព្រទ្ធសច្ចាទៅដាក់លើជើងម៉ា ៗ មន្ត្រីអំបាលនោះលើកដៃថ្វាយបង្គំម្តងហើយ ដួសទឹកនោះមកទទួលព្រះ

រាជការម្នាក់បន្តិច ៗ ទូទៅគ្រប់គ្នា ។ ជាស្បូរបេតពិធីថ្វាយបង្គំ ។ ព្រះករុណាស្តេចត្រឡប់ចូលខាងក្នុង ។ ពួកមន្ត្រីទាំងនោះត្រឡប់ចេញទៅទីលំនៅរៀងខ្លួន ។

តែក្នុងសម័យនេះមិនបានដឹកទឹកព្រះពិភក្ត្រសច្ចា ក្នុងវេលាថ្វាយបង្គំនោះទេ លោកឲ្យរួមដឹកក្នុងវេលាបុណ្យចំរើនព្រះជន្មតែម្តង ត្រូវក្រុមវៀនហ្លួងនាំទៅស្បថឯព្រះវិហារព្រះកែវមរកត ។

និយាយតាមទំនៀមបុរាណ កាលថ្វាយបង្គំងាររហើយ មន្ត្រីអំបាលនោះត្រូវទៅទទួលព្រះរាជឱង្ការ ត្រាតាំងពីក្រុមព្រះអាល័ក្ខណ៍ ទឹងទៅគំនាប់ចៅហ្វាយនាយចៅក្រសួងរបស់ខ្លួន ហើយចេញទៅធ្វើរាជការតាមមុខក្រសួងរៀងខ្លួន ។

បើជាចៅហ្វាយស្រុក ចៅហ្វាយខេត្ត ខេត្តក្រៅនោះ វេលាទឹងចេញទៅមានព្រះរាជអាជ្ញាហ្លួងរៀបខេត្តជូនដំណើរទៅផង ។ កាលទៅដល់ខេត្តហើយ ត្រូវធ្វើពិធីបង់ដៃត្រាទឹងឡើងអ្នកតាតាមទំនៀម ។

## ៦ — បង់ដៃត្រា

វេលាទៅខេត្តរបស់ខ្លួនហើយ ត្រូវរើសរកថ្ងៃណាមួយដ៏ជាមង្គលឫក្ស ក៏ប្រជុំចៅភ្នាក់ងារព្រះពញា ទឹងបណ្តាជនញាតិមិត្រមកជាច្រើន ។ វេលាល្ងាចចំរើនបរិត្តអញ្ជើញព្រះរាជឱង្ការ ទឹងត្រាដំណែងយសសក្តិមកតាំងកណ្តាលផ្ទះឬកណ្តាលរោង ដែលចំរើនបរិត្ត ។ កាលដល់វេលា

មហាជនអំបាលនោះមកជួបជុំហើយ អ្នកសាមីខ្លួនតែងខ្លួនពេញយស ចូលទៅអង្គុយទៀបត្រាតាំង ស្ដាប់លោកចំរើនបរិត្ត ។ ព្រឹកឡើងជួបជុំអ្នកមានបណ្ដាសក្ដិនឹងចាស់ទុំហើយផ្ដើមធ្វើពិធីចងដៃត្រា មានព្រះរាជអាជ្ញាហ្លួងឬមន្ត្រីម្នាក់សូត្រថ្លែងព្រះរាជឱង្ការនោះឲ្យមហាជនដឹងទូទៅ ស្រេចហើយចាស់ទុំអ្នកមានបណ្ដាសក្ដិយកអំបោះដែលក់ទឹកអប់ចងទៅត្រានោះ ហៅថា "ចងដៃត្រា" ហើយនាំឲ្យសព្ទសាធុការពរទៃ ៗ មានដើមថា សុំឲ្យបានប្រកបស្រណុកសុខសប្បាយ ធ្វើរកការឲ្យបានចំរើនដោយលាភយសខ្ពង់ខ្ពស់តទៅ ។

ស្រេចកិច្ចនេះហើយក៏រៀបលៀងអាហារដល់មហាជនអំបាលនោះ តាមទំនៀមមានកាប់ជ្រូកឬគោ ឬទាំងជ្រូកទាំងគោធ្វើអាហារលៀងគ្នាជាអឹកធឹក ។ ទំនៀមចងដៃត្រានេះលើកលែងធ្វើហើយ នៅមានតែពិធីឡើងអ្នកតា ។

## ៧ — ឡើងអ្នកតា

ដល់វេលាល្ងាចត្រូវរៀបឡើងអ្នកតា មានគ្រឿងថ្វាយអ្នកតា មានបង្អែមចំអាបជាដើម តាមទំនៀមដូចមានពោលហើយក្នុងពិធីឡើងអ្នកតាជាកំសាន្តស្រុក ប៉ុន្តែក្នុងពិធីនេះ មានទឹកអប់ ១ ដបនិងអំបោះសម្រាប់ចងដៃមន្ត្រីនោះ ។ និងមានភ្លេងការ ១ វង់ មានមនុស្ស

ជារូបអ្នកតាម្នាក់ ៗ ដល់វេលា ក៏នាំយករបស់អំបាលនេះទៅឯរូបអ្នកតា (គឺអ្នកតាសម្រាប់ស្រុកដែលគេហៅថា អ្នកតាឃ្លាំងមឿង) រៀបចំអុជទៀនធូបថ្វាយក្រយាហារអ្នកតា ៗ លំដាប់នោះអ្នកភ្លេងក៏ប្រគំភ្លេងខ្នងខ្នុំ ទគរពជ ដើងព្រៃ កងសោយ ទំងភ្លេងផ្សេង ៗ តាមសមគួរ មានមនុស្សម្នាក់ជាអ្នកប្រៀងអញ្ជើញអ្នកតា មកចូលរូបទឹងទទួលសេពសោយក្រយាហារ ៗ លំដាប់នោះអ្នកតាក៏មកចូលរូប ១ ស្របក់ហើយពួកចាស់ទុំក៏និយាយប្តឹងអ្នកតាថា ផ្សិតមន្ត្រីឈ្មោះនេះបានទទួលព្រះរាជ·ឧង្ការត្រាតាំងមកធ្វើជាចៅហ្វាយស្រុកស្រុកនេះ ដើម្បីរក្សាប្រជាកស្ត្រក្នុងស្រុកឲ្យបានសេចក្តីសុខសប្បាយ ប្រាសលែងចោរខ្មាំងសឹកសត្រូវទាំងពួងសព្វកាល សូមអំណាចទេព្រក្សអ្នកតាមកអភិបាលរក្សាមន្ត្រីនេះឲ្យមានជ័យជំនះ កុំឲ្យចាញ់ទឹក – ដីអារក្សអ្នកតាឯណាទីមួយឡើយ ៗ លំដាប់នោះ រូបអ្នកតាយកអំបោះសជ្រលក់ទឹកផ្តិលចងដៃឲ្យចៅហ្វាយស្រុកនោះ ដើម្បីសេចក្តីសុខសួស្តីជ័យមង្គលទាំងពួង ជាស្រេចតែប៉ុណ្ណេះ ៗ

ក្រោយនោះក៏រៀបលៀងភោជនាហារគ្នាម្តងទៀតជាបង្ហើយ ៗ

ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

# បញ្ជីរឿង


| | ទំព័រ |
|---|---|
| ១ — ដំណឹងផ្សេង ៗ . . . . . . . . . . . . . . . . | ៩៧ |
| ២ — ហិតោបទេស ភាគទី ១ "ការបង្កមិត្ត" (ត) . . . . . . . . . . . . | ១០១ |
| ៣ — ព្រហ្មចរិយកថា (ត) . . . . . . . . . . . . . . . . . . . | ១១១ |
| ៤ — សុភាសិតវាចាកថា . . . . . . . . . . . . . . . . . . . . | ១៣១ |
| ៥ — រឿងចៅកាំបិតបន្ទោះ (តនិងចប់) . . . . . . . . . . . . . . . . . | ១៤៥ |
| ៦ — លទ្ធិទំនៀមទម្លាប់ "សៀងអារក្សក្នុងវេលាមានជម្ងឺ" . . . . . . . | ១៦៣ |


## រូបក្រៅរឿង


| | |
|---|---|
| រូបភិក្ខុខ្មែរ ១ អង្គ ដែលស្ត្រីជាតិហុលឡង់គេស ឈ្មោះម៉ាដាមស្មុលដែរស៍ គូរកាលពីខែ សេបតម ឆ្នាំ ១៩៣៨. . . . . . . . . . . . . . . . . . . . | ៩៣ |

# TABLE DES MATIÈRES

Pages

1° — Informations diverses .................................. 97

2° — Hitopadesa 1re partie par Moha Krasem (suite)......... 101

3° — Brahmacariyakatha par Préas Moha Ses de l'Institut Bouddhique (suite).................................. 111

4° — Subhāsitavācakāthā par le Vénérable Moha Chhoeun (suite).................................................. 131

5° — Contes populaires Cambodgiens inédits : Chau Kombet Bantos ou le couteau miraculeux (suite et fin)....... 145

6° — Mœurs et Coutumes Cambodgiens : Offrandes à faire aux mânes des ancêtres quand on est malade....... 163

## HORS TEXTE

Portrait d'un bonze Cambodgien par une Artiste Hollandaise, Mme Smulders (Septembre 1938)..................... 93



. រូបភិក្ខុ ១ អង្គជាតិខ្មែរ ដែលអ្នកស្រីជាតិហុល្លង់ដេស ឈ្មោះម៉ាដាមស្តុលដៃរស៍
គូរ កាលពីខែសេបតម ឆ្នាំ ១៩៣៨

# អំពីគំនូរស្រីជាតិហុល្លង់ដេស

កាលពីខែសេបតម ឆ្នាំ ១៩៣៨ មានស្ត្រីជាតិហុល្លង់ដេសម្នាក់ ឈ្មោះម៉ាដាម ស្តុលផែរស៍ ជាជាងគំនូរ មានថ្វីដៃល្បីនាម ធ្លាប់មកនៅភ្នំពេញ ១ ខែ បានគូររូបភិក្ខុខ្មែរ ៩ អង្គ ៗ នេះ ជូនដល់អ្នកមើលទស្សនាវដ្ដីរបស់យើង ។

នៅឱកាសដែលស្ត្រីជាងគំនូរតាំងផ្សាយគំនូរផ្សេង ៗ ជាថ្វីដៃរបស់គាត់ មានបណ្ដាជនតូច-ធំទៅទស្សនាជាច្រើន សម្ដេចចៅហ្វាវាំងវរវៀងជ័យមានសេចក្ដីសរសើរនិងសេចក្ដីពេញចិត្តនឹងគំនូរអស់នោះជាច្រើន ។

ដំណើរដំបូង ៗ

# អំពីពុទ្ធសាសនា នៅប្រទេសយីពុន

ក្រុមបរិសទ្យនេះក្មេងស្រុកយីពុន បានបោះពុម្ពសៀវភៅតូច ៗ មានរូបច្រើនមួយពួក សុទ្ធតែសរសេរជាភាសាឱរុប ដើម្បីពន្យល់ឲ្យគេដឹងស្គាល់នូវប្រទេសរបស់ខ្លួន ឲ្យកាន់តែច្រើនឡើងទៀត ។

ក្នុងពួកសៀវភៅអស់នោះ ព្រះរាជបណ្ណាល័យមានសៀវភៅដែលបោះពុម្ពផ្សាយលើកក្រោយបង្អស់ហៅថា "ពុទ្ធសាសនានៅប្រទេសយី-ពុន" មានរូបគំនូរសុទ្ធតែល្អមើលណាស់ ហើយមានរូបចម្លាក់ជាបែបរចនារបស់ពុទ្ធសាសនាប្រទេសយីពុនផង ។ ក្នុងអារម្ភកថាសៀវភៅនោះ លោកអ្នកប្រាជ្ញធំរបស់យីពុនម្នាក់ឈ្មោះស៊ុស៊ុគីពោលថា ព្រះពុទ្ធសាសនាបាននាំឲ្យចំរើនដល់ប្រទេសយីពុន មិនមែនត្រឹមតែចិត្តវិទ្យាទេ អាចនាំឲ្យចំរើនដល់បែបចម្លាក់រចនា បរមត្ថវិជ្ជា អក្សរសាស្ត្រ វិស្វកម្ម ឧកទដម្បូន្មានជាដើមទៀតផង ។ ជនជាតិយីពុនជាន់ក្រោយបានដឹងថា ត្រង់នេះគឺកន្លែងដែលគេបានឡើងរួចមកហើយក្តី ត្រង់នោះគឺស្ពានព្រែកដែលគេបានធ្វើស្ពានឆ្លងក្តី ផ្លូវដែលគេបានត្រាយជម្រះក្តី ស្រែចំការក្តី អណ្តូងទឹកក្តី ជ្រោះទឹកក្តៅដែលមានប្រយោជន៍ក្តី ដើមឈើជាដំណាំក្តី ព្រែក

ដីកក្តី ទាំងនេះដោយសារផ្ទៃជាលំអានចាស់របស់ពួកកិច្ចពុទ្ធសាសនាបាន ត្រេចត្រាត់ទៅក្នុងប្រទេសយើងសព្វអន្លើ ដើម្បីទេសនាប្រកាសធម៌-វិន័យនៃព្រះពុទ្ធសាសនា ។

ហេតុនេះហើយ ទុកជាត្រង់ណាទីមួយដល់ទៅចុងកាត់មាត់ញកក៏ដោយ អស់ពួកអ្នកដំណើរក៏នៅតែប្រទះឃើញគ្រឿងដំណែលចាស់របស់ពួកលោកពុទ្ធគ្គជាន់ដើមនោះ ហេតុនេះបានជាលោកស៊ីស៊ីតីពោលទុកក្នុងទីបំផុតថា នៅប្រទេសយើងនេះ វិជ្ជាពុទ្ធសាសនា ជាវិជ្ជាមួយដែលអ្នកដំណើរគួរចេះដឹងស្មើនឹងវិជ្ជាភូមិសាស្ត្រដែរ ដើម្បីចូលទៅលេងកំសាន្តងាយស្រួល ។

* * *

## អំពីព្រះសិទ្ធត្ថរាជកុមារ

កាលអំពីខែអាវ៉ែលមុននេះ នៅក្រុងប៉ារីស មានលេងរបាំរឿងព្រះសិទ្ធត្ថរាជកុមារ ។

ក្នុងកាសដែលគេលេងរបាំនោះគេច្រៀងជាពាក្យកាព្យ ហើយមានភ្លេងលេងអមផង ។

៥ សារពណ៌ដ៏មានថ្នាក់វិសេសទាំងឡាយ បានអធិប្បាយថា "រឿងព្រះសិទ្ធត្ថនេះ" ជារឿងសាស្តដែលគួរគោរព ប្រវត្តិរបស់ព្រះពុទ្ធព្រះនាមគោតម កាលតាំងអំពីទ្រង់ប្រសូត រហូតដល់ទ្រង់បានត្រាស់ដឹងនូវបរមត្ថធម៌ទាំងឡាយ មានទាំងរឿងកាលពួកពោធិសត្វប្រជុំគ្នានឹងរឿងសុបិននិមិត្តព្រះនាងមហាមាយា មានគំនូរយ៉ាងល្អដែលគេគួរលើកំណាត់ចំនួនម្ភៃផ្ទាំង ជាគ្រឿងលំអមានភ្លុងត្បូងត្រយ៉ាងធំស្ទាត់លេងអម មានប្រៀងមានកំកង្ទុកាសនោះ ឯគំនូរយ៉ាងល្អជាងគេគឺគំនូរកាលព្រះពុទ្ធទ្រង់ផ្ចាញ់មារ ទ្រង់គង់លើរតនបល្ល័ង្កក្រោមដើមពោធិព្រឹក្ស ។

ហិតោបទេស ភាគទី ១

*“ការបនមិត្រ”*

# ព្រះមហាពិទូរ ក្រសេម គន្ថរបនបណ្ឌិត

## ប្រែនឹងរៀបរៀង (ត)

លុះស្តេចកណ្តុរ ឃើញព្រាបជាប់លប់ក៏ឆ្ងល់ ធ្វើមុខស្ងឹងមួយស្របក់ ទើបមានស្មារតីសួរថា សំឡាញ់អើយ ហេតុម្តេចក៏បានជាដូច្នេះ ។

ចិត្រគ្រីវៈឲ្យការថា ទោសទាំងនេះដោយផលកម្មដែលធ្វើទុកក្នុងកាលមុន ព្រោះ.................. ។

៨១ កុសលកម្មក្តី អកុសលកម្មក្តីឯណា ដែលបានធ្វើដោយខ្លួនឯង កម្មនោះរមែងកើតឡើងដោយអំណាចព្រះវិធាតា ជាអ្នកលិខិតឲ្យមក ។

៨២ រោគាពាធ, សោក, សេចក្តីក្តៅក្រហាយ គ្រឿងរួបរឹត នឹងទុក្ខវេទនា អំបាលនេះជាផលកើតអំពីព្រេងជាតិគឺការប្រព្រឹត្តកន្លងច្បាប់ដោយខ្លួនឯងរបស់មនុស្ស ។

ហិរណ្យក: បានឮដូច្នេះ ក៏ស្ទុះទៅកាត់លប់បំពោះត្រង់ដែលរួបរឹត ចិត្រគ្រីវៈ តែចិត្រគ្រីវៈ ស្រែកឃាត់ថា កុំអាលសិន សំឡាញ់ សុំឲ្យកាត់ត្រង់ដែលរួបរឹតពួកបរិវាររបស់ខ្ញុំអំបាលនេះមុនចុះ ។

ហិរណ្យក: ថ្លែងថា ខ្ញុំមានកំលាំងតិច ទាំងធ្មេញសោតក៏មិនសូវជាមាំមួន ក្រែងមិនអាចនឹងកាត់លប់ដែលគ្របរួបរឹតបរិវាររបស់អ្នកឲ្យដាច់ទាំងអស់បាន ទើបសូមកាត់ចំពោះត្រង់ដែលរួបរឹតខ្លួនអ្នកសិន បើធ្មេញខ្ញុំមិនអន្តរាយ ក៏នឹងកាត់លប់ដែលរួបរឹតបរិវាររបស់អ្នកតទៅ ។

ចិត្រគ្រីវៈ អនុលោមថា "តាមចិត្តអ្នក តែទោះបីដូចម្តេច ក៏សូមឲ្យជួយបរិវារអំបាលនេះទាល់តែបាន" ។

ហិរណ្យកៈ បដិសេធថា "ការដែលយើងនឹងលះខ្លួន ដើម្បីស្ងួនប្រាក់ទុក អ្នកប្រាជ្ញស្ទាត់ជំនាញក្នុងនីតិសាស្ត្រ រមែងមិនសរសើរ ព្រោះ....... ។

៤៣ បុគ្គលគួររក្សាសម្បត្តិរបស់ខ្លួនឲ្យផុតចាកអន្តរាយ គួររក្សាភរិយារបស់ខ្លួនដោយសម្បត្តិ តែថា គួរនឹងប្រើទាំងភរិយាទាំងទ្រព្យការពារខ្លួនជានិច្ចទៅ ។

៤៤ ជីវិតរបស់មនុស្ស ជាបច្ច័យដើម្បីការតាំងនៃធម៌ (គឺសេចក្តីប្រព្រឹត្តល្អ) អត្ថៈ (គឺទ្រព្យសម្បត្តិ) កាមៈ (គឺសេចក្តីស្រមាន) មោក្ខៈ (គឺសេចក្តីផុតរួចចេញទៅ កាលជីវិតវិនាសហើយ អ្វីឡើយដែលនឹងមិនវិនាសទៅផង កាលបើរក្សាជីវិតទុក អ្វីខ្លះដែលមិនឈ្មោះថា បានរក្សាទុក ។

ចិត្រគ្រីវៈ បដិសេធថា "សំឡាញ់អើយ សេចក្តីដែលអ្នកលើកមកពោលនេះ ក៏ជាគោលរបស់នីតិពិតហើយ តែថា ខ្ញុំមិនអាចនឹងមើលអ្នកដែលអាស្រ័យខ្លួនជាទីពឹងហើយ ត្រូវសេចក្តីវិនាសបាន ដោយពេញភ្នែកទេ ហេតុនោះទើបសូមអង្វរអ្នកក្នុងខនេះ ព្រោះ..... ។

៤៥ អ្នកប្រាជ្ញរមែងលះទ្រព្យសម្បត្តិ សូម្បីទាំងជីវិតផង ដើម្បីធ្វើឧបការៈដល់អ្នកដទៃ ; កាលសេចក្តីស្លាប់ជារបស់ទៀង ក៏គួរលះជីវិត

ទៅក្នុងផ្លូវដែលល្អនោះទើបគាប់ប្រសើរ ៗ នៅមានខដែលគួរលើកឡើងថ្លែងទៀត គឺ:

៤៦ ពួកព្រាបបរិវាររបស់ខ្ញុំអំបាលនោះ ក៏មានពូជពង្ស គោត្តសម្បត្តិ នឹងកំលាំងស្មើនឹងខ្ញុំដែរ ព្រោះហេតុនោះ សូមប្រាប់ខ្ញុំឲ្យដឹងបន្តិចថា ទេសកាលអ្វីនឹងព្រោះអ្វីអេះ ដែលនាំឲ្យខ្ញុំមានដំណែងជាមេបារបស់គេ ៗ

៤៧ សេចក្តីពិត បរិវារអំបាលនេះ កាលមិនបានទទួលផលបំណាច់អ្វីអំពីខ្ញុំ ក៏នៅមិនលះបង់ចោលខ្ញុំទៅ ព្រោះហេតុនោះ សុំឲ្យជួយជីវិតពួកបរិវារនេះសិន ទោះបីខ្លួនខ្ញុំនឹងបង់ជីវិតក៏តាមចុះ ៗ

៤៨ សំឡាញ់អើយ សុំកុំអាលោះអាល័យក្នុងរូបកាយដែលប្រកបដោយមង្ស: មូត្រ លាមក នឹងខ្ទុះដែលជារបស់ចេះស្លាប់នេះឡើយ សុំឲ្យស្ងួនតែកិត្តិយសកេរ្តិ៍ឈ្មោះរបស់ខ្ញុំទុកចុះ ៗ

៤៩ បើបុគ្គលយករូបកាយដ៏មិនទៀង មកប្តូរនឹងកិត្តិយសដ៏ជារបស់ស្ថាពរ ឬនឹងយករូបកាយដ៏ពុកពេញដោយរបស់ស្មោកគ្រោក មកប្តូរនឹងកិត្តិយសដែលជារបស់បរិសុទ្ធឥតមន្ទិល ហើយបានកិត្តិយសមកសោត ត្រង់នេះតើអ្នកណាឈ្មោះថា មិនគប្បីបានអ្វី ៗ

៥០ សរីរៈនឹងកិត្តិគុណ ជារបស់មានដំឡៃឆ្ងាយគ្នាណាស់ សរីរៈអាចនឹងរលាយក្នុងមួយរំពេចក៏បាន (តែថា) កិត្តិគុណវិញស្ថិតស្ថាពរនៅរហូតដល់កល្បាវសាន ៗ

កាលហិរញ្ញកៈបានស្ដាប់ពាក្យសុភាសិតនេះហើយ ក៏រីករាយសប្បាយចិត្ត តបថា "សាធុ សំឡាញ់, សាធុ ពីរោះហើយ! អាស្រ័យសេចក្ដីអើពើក្នុងបរិហាររបស់អ្នក សូម្បីអាណាចក្រនៃត្រៃលោកនេះ ក៏សមគួរនឹងឲ្យអ្នកគ្រប់គ្រង" ថា ហើយក៏កាត់លប់ដែលរួតរឹតព្រាបអំបាលនោះដាច់អស់ ។ ស្រេចហើយហិរញ្ញកៈពោលដោយសភាពសំដែងសេចក្ដីត្រេកអរ នឹងព្រាបទាំងឡាយ (ដែលរួចពីអន្ដរាយ) ហើយបែរទៅនិយាយប្រលោមចិត្ត ចិត្រគ្រីវៈថា សំឡាញ់ចិត្រគ្រីវៈ ការដែលដាច់លប់នេះក៏ព្រោះពៀរនឹងគិតតូចចិត្តថា "ទាំងនេះព្រោះសេចក្ដីកំហុសរបស់ខ្លួន នៅមិនទាន់គួរនៅឡើយ" ព្រោះ —

៤១ ក្នុងលោក បក្សីដែលមើលឃើញមង្សាហារបានអំពីចម្ងាយទាំងរយយោជន៍ លុះគ្រាគ្រោះថ្នាក់មកដល់ សូម្បីតែខ្សែអន្ទាក់ដែលគេដាក់នៅមុខក៏មើលមិនឃើញ ។

៤២ កាលឃើញព្រះអាទិត្យព្រះចន្ទ្រ ត្រូវរាហុគ្រាស នឹងឃើញពាន់រួតរឹតដំរីសា ឃើញបណ្ឌិតធ្លាក់គោកយ៉ាក (ដូច្នេះ) ខ្ញុំបានសេចក្ដីសង្វេគថា ឱ! ពៀរនេះមានឫទ្ធិខ្លាំងណាស់ហ្ន៎ ។

៤៣ សូម្បីសត្វវិហគ្គដ៏ហើរហោចលើវេហាស៍ ក៏អាចត្រូវអន្ដរាយ មច្ឆាជាតិទាំងឡាយអាស្រ័យសមុទ្រដ៏ជ្រៅ ក៏នៅត្រូវអ្នកនេសាទចាប់លើកទៅបាន កាលព្រះអ្នកសាងមិនអើពើជ្រោះថ្លៃផងហើយ លាភនឹង

មានមកអំពីណា? ទើងមានប្រយោជន៍អ្វីក្នុងស្ថានដែលបានទៅកើត សេចក្ដីពិត ព្រះកាឡមានព្រះក (ដៃ) លូកទៅក្នុងសេចក្ដីវិនាស ទោះអ្នកណានៅឆ្ងាយដល់ណា ក៏អាចអូសយកខ្លួនមកបាន ។ កាលហិរណ្យកៈពោលសុភាសិត ទើងបដិសណ្ឋារៈសំឡាញ់ដោយឋានៈជាមិត្រភាពល្អម សមគួរហើយ ចិត្រគ្រីវៈព្រមដោយបរិវារក៏លាទៅកាន់លំនៅអាត្មា ។

៥៤ អ្នកឯណាទីមួយដែលគួរគប់ជាមិត្រ ក៏គប្បីគប់ជាមិត្រឲ្យមានចំនួនទាំង ១០០ នាក់ ចូរមើលព្រាបជាតួយ៉ាង ដែលរួចចេញអំពីលប់បាន ក៏ព្រោះសេចក្ដីជាមិត្រនឹងមូសិក (កណ្ដុរ) ។

ចំណែកឯហិរណ្យកៈ ស្រេចហើយក៏ចូលរូងអាត្មាទៅ ។ លំដាប់នោះមានក្អែក ១ ឈ្មោះលឃុបតនកៈ បានឃើញប្រព្រឹត្តហេតុនោះរហូតតាំងអំពីដើមមក ក៏នឹកអស្ចារ្យក្នុងចិត្ត ហើយស្រែកឲ្យស័ព្ទសាធុការថា "អឺ អ្នកហិរណ្យកៈ! អ្នកឯងគួរឲ្យសរសើរណាស់ ព្រោះហេតុនោះខ្ញុំបង់សូមចងស្ពានមេត្រីជាមិត្រភក្ដិនឹងអ្នកផង ។"

ហិរណ្យកៈឮដូច្នោះ ក៏អែបលាក់ខ្លួនបំពួនអាត្មានៅក្នុងរូងហើយស្រែកសួរមកថា "អ្នកឯងគឺនរណា" ក្អែកតបថា ខ្ញុំជាក្អែក ឈ្មោះលឃុបតនកៈ ។

ហិរណ្យកៈបានស្ដាប់ក៏អស់សំណើច ហើយនិយាយថា ដែលនឹងទទួលជាមិត្រមេត្រីនឹងអ្នក ហាក់ដូចជាមិនទំនង ព្រោះថា:

៥៥ ក្នុងលោកនេះ អ្នកមានប្រាជ្ញាគេធ្លាប់ចងមេត្រីនឹងគ្នា តែប្រភេទដែលមិនជាបដិបក្ខនឹងគ្នា នេះខ្លួនខ្ញុំជាអាហារ ចំណែកអ្នកជាអ្នកស៊ី (ដូច្នេះ) នឹងឲ្យកើតបីតិដល់គ្នានូវគ្នាយ៉ាងណាបាន? ។

៥៦ ការចងស្ពានមេត្រីក្នុងរវាងម្ខាងជាអាហារ ម្ខាងទៀតជាអ្នកស៊ី រមែងនាំមកនូវសេចក្ដីវិបត្តិជាដរាប ប្រើសជាប់អន្ទាក់ដែលគេដាក់ ក៏ព្រោះតែឆ្កែចចក ហើយរួចចាកអន្តរាយបានព្រោះក្អែក" ។

ក្អែកសួរថា រឿងនោះមានមកដូចម្ដេច? ។

# ហិរញ្ញកៈនិទានរឿង

## រឿងទី ៣

ក្នុងមគធប្រទេស មានព្រៃឈ្មោះ ចម្បកវតី ជាទីអាស្រ័យនៅនៃសត្វដ៏ជាសំឡាញ់នឹងគ្នាទាំងពីរ គឺប្រើសនឹងក្អែកមកជាយូរយារហើយ ប្រើសមានសេចក្ដីសប្បាយរីករាយ មានសាច់ឈាមធាត់ថ្លុល តែងពានេ-ចរទៅមកតាមអំពើចិត្តទាល់តែឆ្កែចចក ១ មកប្រទះឃើញ នឹកចង់ស៊ី ស្ទើរស្រក់ទឹកមាត់ គិតថា ធ្វើម្ដេចអេះនឹងបានប្រើសសាច់ខ្ចីនេះមកស៊ីហ្ន៎ តែះណ្ហើយចុះអញនឹងធ្វើះបាយលល្បួងរក់ឲ្យស្លាប់ចិត្តសិន គិតឃើញដូច្នេះហើយ ក៏ធ្វើតព្រាយចូលទៅរក ប្រើសពោលថា "សំឡាញ់អើយ! សូមសេចក្ដីចំរើនចូរមានដល់អ្នកចុះ" ប្រើសសួរថា "អ្នកឯងជានរណាមកពីណា? ។

ចចកតបថា "ខ្ញុំជាចចកឈ្មោះ កសុទ្រពុទ្ធិ អាស្រ័យនៅក្នុងព្រៃនេះតែម្នាក់ឯង ឥតញាតិមិត្រទេ មើលសព្វ ។ ទៅ ហាក់ដូចជាស្លាប់ទៅហើយ តែឥឡូវនេះបានមកប្រទះនឹងអ្នកដ៏ជាកិបេមិត្រ ហាក់ដូចជាត្រឡប់មានជីវិតរស់ឡើងវិញ មកកាន់លោកនេះជាថ្មីទៀត ហេតុនេះ ខ្ញុំសូមអ្នកអនុគ្រោះទទួលខ្លួនខ្ញុំទុកជាខ្ញុំផងចុះ ។

ប្រើសទទួលថា "តាមចិត្តអ្នកស្ម័គ្រចុះ" ។

(មានតទៅទៀត)

# ព្រហ្មចរិយកថា (៣)

# របស់ព្រះមហាសែស

# ព្រហ្មចរិយគាថា

មួយវិញទៀត ព្រះអរិយសាវកដឹងច្បាស់នូវអាហារ ទឹងហេតុនាំឲ្យកើតអាហារ ដឹងច្បាស់នូវសេចក្ដីរលត់នៃអាហារ ទឹងផ្លូវប្រតិបត្តិជាគ្រឿងដល់នូវសេចក្ដីរលត់នៃអាហារ ៗ ឯអាហារនោះមាន ៤ ប្រការ គឺ កវឡិង្ការាហារ(១) អាហារដែលគួរធ្វើឲ្យជាដុំមានបាយទំជាដើម ១ ផស្សាហារ(២) អាហារគឺផស្សទាំង៦មានចក្ខុសម្ផស្សជាដើម ១ មនោសញ្ចេតនាហារ(៣) អាហារគឺសេចក្ដីគិតដោយចិត្ត ១ វិញ្ញាណាហារ(៤) អាហារគឺវិញ្ញាណ ១ ៗ សេចក្ដីកើតឡើងនៃអាហារ ព្រោះសេចក្ដីកើតឡើងនៃតណ្ហា គឺថាតណ្ហាជាហេតុនាំឲ្យកើតអាហារ សេចក្ដីរលត់នៃអាហារព្រោះសេចក្ដីរលត់នៃតណ្ហា គឺថាកាលបើតណ្ហារលត់ហើយ អាហារក៏រលត់ដែរ អដ្ឋង្គិកមគ្គដ៏ប្រពៃមានពោលមកហើយខាងដើម ជាផ្លូវប្រតិបត្តិជាគ្រឿងដល់នូវសេចក្ដីរលត់នៃតណ្ហា ៗ

---

១ កវឡិង្ការាហារ សំដៅយកនូវឱជដ្ឋមករូបគឺរូបមានឱជាជាគំរប់ ៨ បានខាងបឋវី ធាតុដី ១ អាបោ ធាតុទឹក ១ តេជោ ធាតុភ្លើង ១ វាយោ ធាតុខ្យល់ ១ វណ្ណោ សម្បុរកាយ ១ គន្ធោ ក្លិនកាយ ១ រសោ រសជាតរបស់អាហារនោះ ១ ឱជា ការញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ឬ កំឡាំងកើតអំពីរសអាហារនោះ ១ ៗ ២ ផស្សាហារ សំដៅយកនូវវេទនាទាំង ៣ គឺសុខ ទុក្ខ ឧបេក្ខា ៗ ៣ មនោសញ្ចេតនាហារ គឺកុសលចេតនានឹងអកុសលចេតនាប្រព្រឹត្តទៅក្នុងភូមិទាំង ៣ គឺកាមាវចរភូមិ ១ រូបាវចរភូមិ ១ អរូបាវចរភូមិ ១ ម្យ៉ាងទៀតសំដៅយកនូវភពទាំង ៣

(ខានតទៅទំព័រ ១១៤)

មួយវិញទៀត ព្រះអរិយសាវកដឹងច្បាស់នូវកងទុក្ខ នឹងហេតុនាំឲ្យកើតកងទុក្ខ ដឹងច្បាស់នូវសេចក្ដីរលត់នៃកងទុក្ខ នឹងសេចក្ដីប្រតិបត្តិជាគ្រឿងដល់នូវសេចក្ដីរលត់នៃកងទុក្ខ ឯកងទុក្ខនោះគឺ ជាតិ សេចក្ដីកើតជាទុក្ខ ១ ជរា សេចក្ដីចាស់គ្រាំគ្រាជាទុក្ខ ១ មរណៈ សេចក្ដីស្លាប់ជាទុក្ខ ១ សោកៈ សេចក្ដីស្ដាយស្រណោះជាទុក្ខ ១ បរិទេវៈ សេចក្ដីខ្សឹកខ្សួលយំស្រែកជាទុក្ខ ១ ទុក្ខៈ សេចក្ដីឈឺកាយជាទុក្ខ ១ ទោមនស្សៈ សេចក្ដីឈឺចិត្តជាទុក្ខ ១ ឧបាយាសៈ សេចក្ដីចង្អៀត

---

ពិកាមភព ១ រូបភព ១ អរូបភព ១ ។ វិញ្ញាណាហារ គឺបដិសន្ធិវិញ្ញាណទាំង ១៩ គឺបដិ-សន្ធិវិញ្ញាណក្នុងអបាយទាំង ៤ ដោយអហេតុកអកុសលវិបាក ១ បដិសន្ធិវិញ្ញាណរបស់មនុស្ស ដែលតាំងពីក្រោមមានភ្នែកខ្វាក់ត្រចៀកថ្លង់អំពីកំណើតជាដើម ដោយអហេតុកកុសលវិបាក ១ បដិសន្ធិវិញ្ញាណរបស់មនុស្សនឹងកាមាវចរទេវតា ដែលល្ងង់ខ្លៅអាប់ឥតប្រាជ្ញាដោយសោម-នស្សកាមាវចរកុសលវិបាក ជាញាណវិប្បយុត្តសសង្ខារិក ១ អសង្ខារិក ១ បដិសន្ធិវិញ្ញាណរបស់មនុស្សនឹងកាមាវចរទេវតា ដែលមានបញ្ញាអាស្រ័យអ្នកដទៃខ្លះ កើតឡើងដោយខ្លួនឯងខ្លះ ដោយសោមនស្សកាមាវចរកុសលវិបាក ជាញាណសម្បយុត្តសសង្ខារិក ១ អសង្ខារិក ១ បដិសន្ធិវិញ្ញាណរបស់មនុស្សនឹងកាមាវចរទេវតាដែលល្ងង់ខ្លៅ តែមានសេចក្ដីព្យាយាមច្រើនមិនខ្ជិលច្រអូស ដោយឧបេក្ខាកាមាវចរកុសលវិបាក ជាញាណវិប្បយុត្តសសង្ខារិក ១ អ-សង្ខារិក ១ បដិសន្ធិវិញ្ញាណរបស់មនុស្សនឹងកាមាវចរទេវតា ដែលមានបញ្ញាអាស្រ័យនឹងសេចក្ដីព្យាយាមល្អ ដោយឧបេក្ខាកាមាវចរកុសលវិបាក ជាញាណសម្បយុត្តសសង្ខារិក ១ អសង្ខារិក ១ បដិសន្ធិវិញ្ញាណទាំង ៥ របស់រូបព្រហ្ម ដោយរូបាវចរកុសលវិបាកទាំង ៥ មានបឋមជ្ឈានវិបាកជាដើម នឹងបដិសន្ធិវិញ្ញាណទាំង ៤ របស់អរូបព្រហ្មទាំង ៤ ដោយអរូបាវចរកុសលវិបាក មានអាកាសានញ្ចាយតនជ្ឈានវិបាកជាដើម ។ ម្យ៉ាងទៀតនាំមកនូវនាមរូបក្នុងបដិសន្ធិ ។

បន្ទាល់ចិត្តជាទុក្ខ ១ អប្បិយេហិ សម្បយោគៈ សេចក្ដីជួបប្រសព្វដោយសត្វនិងសង្ខារមិនជាទីស្រឡាញ់ជាទុក្ខ ១ បិយេហិ វិប្ប-យោគៈ សេចក្ដីព្រាត់ប្រាសចាកសត្វនិងសង្ខារជាទីស្រឡាញ់ជាទុក្ខ ១ យម្បិច្ឆំ ន លភតិ ប្រាថ្នារបស់ឯណាហើយមិនបានរបស់នោះជាទុក្ខ ១ បើនិយាយដោយសង្ខេបរួម គឺឧបាទានក្ខន្ធទាំង ៥ ជាទុក្ខ ១ ។ ឯហេតុនាំឲ្យកើតកងទុក្ខនោះគឺ តណ្ហា ជាធម្មជាតិញ៉ាំងសត្វឲ្យកើតទៀត ជាធម្មជាតិប្រកបដោយសេចក្ដីត្រេកអររីករាយញ៉ាំងសត្វឲ្យត្រេកត្រអាលក្នុងភពនោះៗ ឯតណ្ហានោះមាន ៣ ប្រការ គឺ កាមតណ្ហា សេចក្ដីប្រាថ្នាប្រកបដោយកាមគុណទាំងប្រាំ ១ ភវតណ្ហា សេចក្ដីប្រាថ្នាក្នុងរូបភពនិងអរូបភព ១ វិភវតណ្ហា សេចក្ដីប្រាថ្នាប្រកបដោយឧច្ឆេទទិដ្ឋិ ១ ។ សេចក្ដីរលត់នៃតណ្ហានោះ ដោយមិនសល់គឺព្រះនិព្វាន ហៅថា សេចក្ដីរលត់នៃកងទុក្ខ ឯផ្លូវប្រតិបត្តិជាគ្រឿងដល់នូវសេចក្ដីរលត់នៃកងទុក្ខនោះ គឺអដ្ឋង្គិកមគ្គដូចបានពោលមកហើយ ។

មួយវិញទៀត ព្រះអរិយសាវកដឹងច្បាស់នូវជរាមរណ និងហេតុនាំឲ្យកើតជរាមរណ ដឹងច្បាស់នូវសេចក្ដីរលត់នៃជរាមរណ និងផ្លូវប្រតិបត្តិនាំឲ្យដល់នូវសេចក្ដីរលត់នៃជរាមរណ ឯជរាមរណគឺសេចក្ដីចាស់ស្លាប់ សេចក្ដីកើតមានឡើងនៃជរាមរណ ព្រោះសេចក្ដីកើតមានឡើងនៃជាតិ គឺថា បើជាតិមានហើយ ជរាមរណក៏មានដែរ សេចក្ដីរលត់នៃ

ជរាមរណ ព្រោះរលត់នៃជាតិ គឺថា បើជាតិរលត់ហើយ ជរាមរណក៏រលត់ដែរ អដ្ឋង្គិកមគ្គជាផ្លូវប្រតិបត្តិនាំឲ្យរលត់ជរាមរណ ។

មួយវិញទៀត ព្រះអរិយសាវកដឹងច្បាស់នូវជាតិ នឹងហេតុនាំឲ្យកើតជាតិ ដឹងច្បាស់នូវសេចក្តីរលត់នៃជាតិ នឹងផ្លូវប្រតិបត្តិនាំឲ្យរលត់នៃជាតិ ឯជាតិនោះគឺសេចក្តីកើតដោយកំណើត ៤ មានជលាពុជកំណើតជាដើម សេចក្តីកើតមានឡើងនៃជាតិ ក៏ព្រោះសេចក្តីកើតមានឡើងនៃភព គឺថា បើភពកើតមានឡើងហើយ ជាតិក៏កើតមានដែរ សេចក្តីរលត់នៃជាតិក៏ព្រោះរលត់នៃភព គឺថា បើភពរលត់ហើយ ជាតិក៏រលត់ដែរ អដ្ឋង្គិកមគ្គជាផ្លូវប្រតិបត្តិនាំឲ្យរលត់នៃជាតិ ។

មួយវិញទៀត ព្រះអរិយសាវកដឹងច្បាស់នូវភព នឹងហេតុនាំឲ្យកើតភព ដឹងច្បាស់នូវសេចក្តីរលត់នៃភព នឹងផ្លូវប្រតិបត្តិនាំឲ្យរលត់នៃភព ឯភពនោះមាន ៣ ប្រការគឺ កាមភព បានត្រង់អបាយភូមិទាំង ៤ នឹងមនុស្សលោកនឹងកាមាវចរទេវលោកទាំង ៦ ជាន់ ១ រូបភព បានត្រង់រូបព្រហ្មទាំង ១៦ ជាន់ ១ អរូបភព បានត្រង់អរូបព្រហ្មទាំង ៤ ជាន់ ១ សេចក្តីកើតមានឡើងនៃភព ក៏ព្រោះសេចក្តីកើតមានឡើងនៃឧបាទាន គឺថា បើឧបាទានកើតមានហើយ ភពក៏កើតមានដែរ សេចក្តីរលត់នៃភព ក៏ព្រោះសេចក្តីរលត់នៃឧបាទាន គឺថា បើឧបាទានរលត់ហើយ ភពក៏រលត់ដែរ អដ្ឋង្គិកមគ្គជាផ្លូវប្រតិបត្តិនាំឲ្យរលត់ភព ។

មួយវិញទៀត ព្រះអរិយសាវកដឹងច្បាស់នូវឧបាទាន ទាំងហេតុនាំឲ្យកើតនៃឧបាទាន ដឹងច្បាស់នូវសេចក្ដីរលត់នៃឧបាទាន ទាំងផ្លូវប្រតិបត្តិនាំឲ្យរលត់នៃឧបាទាន ឯឧបាទានប្រែថា សេចក្ដីប្រកាន់មាំ បាន ដល់តណ្ហាដែលមានកំឡាំងក្លា ឧបាទាននោះមាន ៤ ប្រការគឺ កាមុបាទាន សេចក្ដីប្រកាន់មាំដោយកាម ១ ទិដ្ឋុបាទាន សេចក្ដីប្រកាន់មាំដោយទិដ្ឋិ ១ សីលព្វតុបាទាន សេចក្ដីប្រកាន់មាំដោយសីលនឹងវត្តខាងក្រៅព្រះពុទ្ធសាសនា ១ អត្តវាទុបាទាន សេចក្ដីប្រកាន់មាំដោយពាក្យរបស់ខ្លួន ១ សេចក្ដីកើតមានឡើងនៃឧបាទាន ក៏ព្រោះសេចក្ដីកើតមានឡើងនៃតណ្ហា គឺថា បើតណ្ហាកើតមានហើយ ឧបាទានក៏កើតមានដែរ សេចក្ដីរលត់នៃឧបាទាន ក៏ព្រោះសេចក្ដីរលត់នៃតណ្ហា គឺថា បើតណ្ហារលត់ហើយ ឧបាទានក៏រលត់ដែរ អដ្ឋង្គិកមគ្គជាផ្លូវប្រតិបត្តិនាំឲ្យរលត់នៃឧបាទាន ។

មួយវិញទៀត ព្រះអរិយសាវកដឹងច្បាស់នូវតណ្ហា ទាំងហេតុនាំឲ្យកើតនៃតណ្ហា ដឹងច្បាស់នូវសេចក្ដីរលត់នៃតណ្ហា ទាំងផ្លូវប្រតិបត្តិនាំឲ្យរលត់នៃតណ្ហា ឯតណ្ហានោះមាន ៦ ប្រការគឺ រូបតណ្ហា សេចក្ដីប្រាថ្នាឬត្រេកអរត្រូវរូប ១ សទ្ទតណ្ហា សេចក្ដីប្រាថ្នាត្រូវសំឡេង ១ គន្ធតណ្ហា សេចក្ដីប្រាថ្នាត្រូវក្លិន ១ រសតណ្ហា សេចក្ដីប្រាថ្នាត្រូវរសអាហារ ១ ផោដ្ឋព្វតណ្ហា សេចក្ដីប្រាថ្នាត្រូវសម្ផស្ស ១

ធម្មតណ្ហា សេចក្តីប្រាថ្នានូវធម្មារម្មណ៍ ១ សេចក្តីកើតមាននៃតណ្ហា ក៏ព្រោះសេចក្តីកើតមាននៃវេទនា គឺថា បើវេទនាកើតមានហើយ តណ្ហា ក៏កើតមានដែរ សេចក្តីរលត់នៃតណ្ហា ក៏ព្រោះសេចក្តីរលត់នៃវេទនា គឺថា បើវេទនារលត់ហើយ តណ្ហាក៏រលត់ដែរ អដ្ឋង្គិកមគ្គជាផ្លូវប្រតិបត្តិ នាំឲ្យរលត់នៃតណ្ហា ។

មួយវិញទៀត ព្រះអរិយសាវកដឹងច្បាស់នូវវេទនានឹងហេតុនាំឲ្យ កើតវេទនា ដឹងច្បាស់នូវសេចក្តីរលត់នៃវេទនា នឹងផ្លូវប្រតិបត្តិនាំឲ្យ រលត់នៃវេទនា ឯវេទនានោះមាន ៦ ប្រការគឺ ចក្ខុសម្ផស្សជា វេទនា វេទនាកើតអំពីចក្ខុសម្ផស្ស គឺភ្នែកឃើញរូប ១ សោតសម្ផស្សជា វេទនា វេទនាកើតអំពីសោតសម្ផស្ស គឺត្រចៀកឮសំឡេង ១ ឃានសម្ផស្សជា វេទនា វេទនាកើតអំពីឃានសម្ផស្ស គឺច្រមុះ ធុំក្លិន ១ ជិវ្ហាសម្ផស្សជា វេទនា វេទនាកើតអំពីជិវ្ហាសម្ផស្ស គឺ អណ្តាតលិទ្ធជញ្ជាប់រសអាហារ ១ កាយសម្ផស្សជា វេទនា វេទនាកើតអំពីកាយសម្ផស្ស គឺកាយប៉ះពាល់ផោដ្ឋព្វារម្មណ៍ ១ មនោ-សម្ផស្សជា វេទនា វេទនាកើតអំពីមនោសម្ផស្ស គឺចិត្តនឹកគិត ពិចារណាធម្មារម្មណ៍ ១ សេចក្តីកើតមាននៃវេទនា ក៏ព្រោះសេចក្តីកើត មាននៃផស្ស គឺថា បើផស្សកើតមានហើយ វេទនាក៏កើតមានដែរ សេចក្តី

រលត់នៃវេទនា ក៏ព្រោះសេចក្ដីរលត់នៃផស្ស គឺថា បើផស្សរលត់ហើយ វេទនាក៏រលត់ដែរ អដ្ឋង្គិកមគ្គជាផ្លូវប្រតិបត្តិនាំឲ្យរលត់នៃវេទនា ។

មួយវិញទៀត ព្រះអរិយសាវកដ៏ដឹងច្បាស់នូវផស្ស ទីដ៏ហេតុនាំឲ្យកើតនៃផស្ស ដឹងច្បាស់នូវសេចក្ដីរលត់នៃផស្ស ទីដ៏ផ្លូវប្រតិបត្តិនាំឲ្យរលត់នៃផស្ស ឯផស្សនោះមាន ៦ ប្រការគឺ ចក្ខុសម្ផស្ស ភ្នែកឃើញរូប ១ សោតសម្ផស្ស ត្រចៀកឮសំឡេង ១ ឃានសម្ផស្ស ច្រមុះធុំក្លិន ១ ជិវ្ហាសម្ផស្ស អណ្ដាតលិទ្ធជញ្ជាប់សាកហារ ១ កាយសម្ផស្ស កាយប៉ះពាល់នៅផ្សព្វារម្មណ៍ ១ មនោសម្ផស្ស ចិត្តគិតនឹកពិចារណាធម្មារម្មណ៍ ១ សេចក្ដីកើតមាននៃផស្សៈ ក៏ព្រោះសេចក្ដីកើតមាននៃសឡាយតនៈ គឺថា បើសឡាយតនកើតមានហើយ ផស្សៈក៏កើតមានដែរ សេចក្ដីរលត់នៃផស្សៈ ក៏ព្រោះសេចក្ដីរលត់នៃសឡាយតនៈ គឺថា បើសឡាយតនរលត់ហើយ ផស្សក៏រលត់ដែរ អដ្ឋង្គិកមគ្គជាផ្លូវប្រតិបត្តិនាំឲ្យរលត់នៃផស្សៈ ។

មួយវិញទៀត ព្រះអរិយសាវកដ៏ដឹងច្បាស់នូវសឡាយតនទីដ៏ហេតុនាំឲ្យកើតនៃសឡាយតនៈ ដឹងច្បាស់នៅសេចក្ដីរលត់នៃសឡាយតនៈ ទីដ៏ផ្លូវប្រតិបត្តិនាំឲ្យរលត់នៃសឡាយតនៈ ឯសឡាយតនៈនោះបានខាងឯអាយតន៦ ប្រការគឺ ចក្ខាយតនៈ អណ្ដូង ( ជាទីកើតបុណ្យបាប ) គឺភ្នែក ១ សោតាយតនៈ អណ្ដូងគឺត្រចៀក ១ ឃានាយតនៈ

អណ្តូងគឺច្រមុះ ១ ជិវ្ហាយតនៈ អណ្តូងគឺអណ្តាត ១ កាយាយតនៈ អណ្តូងគឺកាយ ១ មនាយតនៈ អណ្តូងគឺចិត្ត ១ សេចក្តីកើតមាននៃសឡាយតនៈ ក៏ព្រោះសេចក្តីកើតមាននៃនាមរូប គឺថា បើនាមរូបកើតមានហើយ សឡាយតនៈក៏កើតមានដែរ សេចក្តីរលត់នៃសឡាយតនៈ ក៏ព្រោះសេចក្តីរលត់នៃនាមរូប គឺថា បើនាមរូបរលត់ហើយ សឡាយតនៈក៏រលត់ដែរ អដ្ឋង្គិកមគ្គជាផ្លូវប្រតិបត្តិនាំឲ្យរលត់នៃសឡាយតនៈ ។

មួយវិញទៀត ព្រះអរិយសាវកដឹងច្បាស់នូវនាមរូប និងហេតុនាំឲ្យកើតនៃនាមរូប ដឹងច្បាស់នូវសេចក្តីរលត់នៃនាមរូប និងផ្លូវប្រតិបត្តិនាំឲ្យរលត់នៃនាមរូប ឯនាមនោះបានខាងវេទនាចេតសិក សញ្ញាចេតសិក ចេតនាចេតសិក ផស្សចេតសិក និងមនសិការចេតសិក ឯរូបនោះបានខាងមហាភូតរូបទាំង ៤ និងឧបាទារូបដែលអាស្រ័យនឹងមហាភូតរូបនោះ សេចក្តីកើតមាននៃនាមរូប ក៏ព្រោះសេចក្តីកើតមាននៃវិញ្ញាណ គឺថា បើវិញ្ញាណកើតមានហើយ នាមរូបក៏កើតមានដែរ សេចក្តីរលត់នៃនាមរូប ក៏ព្រោះសេចក្តីរលត់នៃវិញ្ញាណ គឺថា បើវិញ្ញាណរលត់ហើយ នាមរូបក៏រលត់ដែរ អដ្ឋង្គិកមគ្គជាផ្លូវប្រតិបត្តិនាំឲ្យរលត់នៃនាមរូប ។

មួយវិញទៀត ព្រះអរិយសាវកដឹងច្បាស់នូវវិញ្ញាណ និងហេតុនាំឲ្យកើតនៃវិញ្ញាណ ដឹងច្បាស់នូវសេចក្តីរលត់នៃវិញ្ញាណ និងផ្លូវប្រតិបត្តិ

នាំឲ្យរលត់នៃវិញ្ញាណ ឯវិញ្ញាណនោះគឺចិត្ត វែកទៅមាន ៦ ប្រការ គឺ ចក្ខុវិញ្ញាណ ចិត្តអាស្រ័យនូវភ្នែក ១ សោតវិញ្ញាណ ចិត្តអាស្រ័យនូវត្រចៀក ១ ឃានវិញ្ញាណ ចិត្តអាស្រ័យនូវច្រមុះ ១ ជិវ្ហាវិញ្ញាណ ចិត្តអាស្រ័យនូវអណ្តាត ១ កាយវិញ្ញាណ ចិត្តអាស្រ័យនូវកាយ ១ មនោវិញ្ញាណ ចិត្តអាស្រ័យនូវមនោទ្វារ ១ សេចក្តីកើតមាននៃវិញ្ញាណ ក៏ព្រោះសេចក្តីកើតមាននៃសង្ខារ គឺថា បើសង្ខារកើតមានហើយ វិញ្ញាណក៏កើតមានដែរ សេចក្តីរលត់នៃវិញ្ញាណ ក៏ព្រោះសេចក្តីរលត់នៃសង្ខារ គឺថា បើសង្ខាររលត់ហើយ វិញ្ញាណក៏រលត់ដែរ អដ្ឋង្គិកមគ្គជាផ្លូវប្រតិបត្តិនាំឲ្យរលត់នៃវិញ្ញាណ ។

មួយវិញទៀត ព្រះអរិយសាវកដឹងច្បាស់នូវសង្ខារ ដឹងហេតុនាំឲ្យកើតនៃសង្ខារ ដឹងច្បាស់នូវសេចក្តីរលត់នៃសង្ខារ ដឹងផ្លូវប្រតិបត្តិនាំឲ្យរលត់នៃសង្ខារ ឯសង្ខារនោះមាន ៣ ប្រការគឺ កាយសង្ខារ អំពើបាបបុណ្យកើតដោយកាយ ១ វចីសង្ខារ អំពើបាបបុណ្យកើតដោយវាចា ១ ចិត្តសង្ខារ អំពើបាបបុណ្យកើតដោយចិត្ត ១ សេចក្តីកើតមាននៃសង្ខារ ក៏ព្រោះសេចក្តីកើតមាននៃអវិជ្ជា គឺថា បើអវិជ្ជាកើតមានហើយ សង្ខារក៏កើតមានដែរ សេចក្តីរលត់នៃសង្ខារ ក៏ព្រោះសេចក្តីរលត់នៃអវិជ្ជា គឺថា បើអវិជ្ជារលត់ហើយ សង្ខារក៏រលត់ដែរ អដ្ឋង្គិកមគ្គជាផ្លូវប្រតិបត្តិនាំឲ្យរលត់នៃសង្ខារ ។

មួយវិញទៀត ព្រះអរិយសាវកដឹងច្បាស់នូវអវិជ្ជា នឹងហេតុនាំឲ្យកើតនៃអវិជ្ជា ដឹងច្បាស់នូវសេចក្តីរលត់នៃអវិជ្ជា នឹងផ្លូវប្រតិបត្តិនាំឲ្យរលត់នៃអវិជ្ជា សេចក្តីមិនដឹងក្នុងកងទុក្ខ មិនដឹងក្នុងតណ្ហា ជាហេតុបណ្តាលឲ្យកើតកងទុក្ខ មិនដឹងក្នុងព្រះនិព្វានជាគ្រឿងរលត់នៃកងទុក្ខ មិនដឹងក្នុងផ្លូវប្រតិបត្តិនាំឲ្យរលត់នៃកងទុក្ខ ហៅថា អវិជ្ជា សេចក្តីកើតមាននៃអវិជ្ជា ក៏ព្រោះសេចក្តីកើតមាននៃអាសវៈ គឺថា បើអាសវៈកើតមានហើយ អវិជ្ជាក៏កើតមានដែរ សេចក្តីរលត់នៃអវិជ្ជា ក៏ព្រោះសេចក្តីរលត់នៃអាសវៈ គឺថា បើអាសវៈរលត់ហើយ អវិជ្ជាក៏រលត់ដែរ ។

មួយវិញទៀត ព្រះអរិយសាវកដឹងច្បាស់នូវអាសវៈនឹងហេតុនាំឲ្យកើតនៃអាសវៈ ដឹងច្បាស់នូវសេចក្តីរលត់នៃអាសវៈ នឹងផ្លូវប្រតិបត្តិនាំឲ្យរលត់នៃអាសវៈ ឯអាសវៈនោះមាន ៣ ប្រការគឺ កាមាសវៈ សេចក្តីត្រេកត្រអាលក្នុងកាម ១ ភវាសវៈ សេចក្តីត្រេកត្រអាលក្នុងភព ១ អវិជ្ជាសវៈ សេចក្តីមិនដឹងក្នុងអរិយសច្ច ១ សេចក្តីកើតមាននៃអាសវៈ ក៏ព្រោះសេចក្តីកើតមាននៃអវិជ្ជា គឺថា បើអវិជ្ជាកើតមានហើយ អាសវៈក៏កើតមានដែរ សេចក្តីរលត់នៃអាសវៈ ក៏ព្រោះសេចក្តីរលត់នៃអវិជ្ជា គឺថា បើអវិជ្ជារលត់ហើយ អាសវៈក៏រលត់ដែរ អដ្ឋង្គិកមគ្គជាផ្លូវប្រតិបត្តិនាំឲ្យរលត់នៃអាសវៈ ព្រះអរិយសាវកដឹងច្បាស់យ៉ាងនេះហើយ ក៏លះ

បង់នូវកាមានុស័យបាន បន្ទោបង់នូវបដិឃានុស័យបាន ដកចោលនូវទិដ្ឋិមានានុស័យបាន លះបង់អវិជ្ជាបានហើយញុំាងវិជ្ជាឲ្យកើតឡើង ធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្ននេះបាន ព្រះអរិយសាវកឈ្មោះថាតាំងនៅក្នុងសម្មាទិដ្ឋិដោយហេតុមានប្រមាណប៉ុណ្ណេះ ទិដ្ឋិរបស់ព្រះអរិយសាវកនោះ ក៏ដើរទៅត្រង់ក្នុងធម៌ ព្រះអរិយសាវកនោះ ប្រកបដោយសេចក្ដីជ្រះថ្លា មិនញាប់ញ័រក្នុងធម៌ រមែងមកកាន់ព្រះសទ្ធម្មនេះ ។

### ចប់សម្មាទិដ្ឋិសូត្រតែប៉ុណ្ណេះ ។

មួយវិញទៀត តាមទំនងសាលេយ្យកសូត្រ គម្ពីរមជ្ឈិមនិកាយ មូលបណ្ណាសក សេចក្ដីថា សម្មាទិដ្ឋិមានតែ ១០ គឺ អត្ថិ ទិន្នំ យល់ឃើញថា ទានដែលបុគ្គលឲ្យហើយ រមែងមានផលជាពិត ១ អត្ថិ យិដ្ឋំ ការបូជាធំ គឺទានធំជាសាធារណដល់ជនទាំងពួង រមែងមានផល ១ អត្ថិ ហុតំ គ្រឿងសក្ការល្មម គឺគ្រឿងសក្ការដែលគួរធ្វើដល់ភ្ញៀវ រមែងមានផល ១ អត្ថិ សុកដទុក្កដានំ កម្មានំ ផលំ វិបាកោ ផលដែលហូរមកលើសលប់ និងផលដែលហូរមកប្រហែលគ្នានឹងកម្ម របស់កម្មល្អអាក្រក់ រមែងមាន ១ អត្ថិ អយំ លោកោ លោកនេះដែលសត្វស្ថិតនៅក្នុងលោកខាងមុខគប្បីបាន ដោយអំពើកម្ម រមែងមាន ១ អត្ថិ បរោ លោកោ លោកខាងមុខ

ដែលសត្វស្ថិតនៅក្នុងលោកនេះ គប្បីបានដោយអំពើកម្ម រមែងមាន ១ អត្ថិ មាតា សេចក្តីប្រតិបត្តិល្អ ឬអាក្រក់ ក្នុងមាតា រមែងមានផលបុណ្យ ឬបាប ១ អត្ថិ បិតា សេចក្តីប្រតិបត្តិល្អ ឬអាក្រក់ក្នុងបិតា រមែងមានផលបុណ្យ ឬបាប ១ អត្ថិ សត្តា ឱបបាតិកា សត្វដែលច្យុតហើយទៅចាប់កំណើតទៀត រមែងមាន ១ អត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា សមណនិងព្រាហ្មណ៍ដែលប្រព្រឹត្តល្អ ប្រតិបត្តិល្អ រមែងមានក្នុងលោក ១ ។

អង្គនៃមគ្គទី ២ គឺសម្មាសង្កប្បនោះបានខាងវិតក្កចេតសិក មានលក្ខណត្រិះរិះល្អ គឺសេចក្តីនឿយណាយធុញទ្រាន់នឹងកាម ហើយត្រិះរិះគេចចេញចាកកាម ហៅថា នេក្ខម្មសង្កប្បៈ សេចក្តីត្រិះរិះប្រកបដោយមេត្តា ឥតមានព្យាបាទដល់សត្វដទៃ ហៅថា អព្យាបាទសង្កប្បៈ សេចក្តីត្រិះរិះប្រកបដោយករុណា ឥតមានបៀតបៀនសត្វដទៃ ហៅថា អវិហឹសាសង្កប្បៈ ។

អង្គនៃមគ្គទី ៣ គឺសម្មាវាចានោះ បានខាងវិរតិចេតសិក ដែលវៀរចាកវចីទុច្ចរិត ៤ ប្រការ គឺវចីសុចរិត ៤ ប្រការនោះឯង ។

អង្គនៃមគ្គទី ៤ គឺសម្មាកម្មន្តនោះ បានខាងវិរតិចេតសិក ដែលវៀរចាកកាយទុច្ចរិត ៣ ប្រការ គឺកាយសុចរិត ៣ ប្រការនោះឯង ។

ឯអង្គមគ្គទី ៥ គឺ សម្មាអាជីវៈនោះបានខាងវិរតិចេតសិកដែលវៀរចាកមិច្ឆាជីវៈ គឺចិញ្ចឹមជីវិតខុសឬអាក្រក់ របស់បព្វជិតនិងគ្រហស្ថទាំង-ឡាយ ឯមិច្ឆាជីវៈរបស់បព្វជិតនោះ មានច្រើនប្រការណាស់ តែក្នុងទីនេះសូមសំដែងតែមិច្ឆាជីវៈ គឺបាបធម៌ ៥ ប្រការល្មមជាតួយ៉ាង ឯបាបធម៌ ៥ ប្រការនោះ គឺ កុហនា ១ លបនា ១ នេមិត្តិកតា ១ និប្បេសិកតា ១ លាភេន លាភំ និជិគីសនតា ១ ឯកុហនានោះ គឺការកុហក ការញុំាងសត្វលោកឲ្យកោតឲ្យស្ញប់ ឲ្យជ្រះថ្លាដោយកុហនវត្ថុ ៣ ប្រការ ព្រោះប្រាថ្នាលាភសក្ការនិងសេចក្តីសរសើរ ឯកុហនវត្ថុ ៣ ប្រការនោះ មានមកក្នុងខុទ្ទកនិកាយ មហា-និទ្ទេសថា បច្ចយប្បដិសេវនសង្ខាតំ កុហនវត្ថុ រឿងកុហកពោលគឺការប្រើប្រាស់បច្ច័យទាំងបួន ១ ឥរិយាបថសង្ខាតំ កុហ-នវត្ថុ រឿងកុហកពោល គឺ ការផ្គត់ផ្គង់ប្រែងឥរិយាបថទាំងបួន ១ សាមន្តជប្បនសង្ខាតំ កុហនវត្ថុ រឿងកុហកពោល គឺការខ្សឹបខ្សៀវ ១ ។

ឯរឿងកុហកពោលគឺការប្រើប្រាស់បច្ច័យទាំង ៤ នោះ – គឺភិក្ខុមានសេចក្តីប្រាថ្នាច្រើន កាលបើមានទាយកគេនិមន្តដោយបច្ច័យទាំង ៤ គឺ ចីវរ បិណ្ឌបាត សេនាសនៈ គិលានភេសជ្ជ ក៏ត្រូវការណាស់ តែធ្វើហាក់ដូចជាមិនត្រូវការ ក៏ហាមឃាត់មិនទទួលបច្ច័យទាំងនោះ ហើយ

និយាយថា ធម្មតាសមណមិនត្រូវការនឹងចីវរមានដំឡៃច្រើនឡើយ ត្រូវការតែចីវរដ៏សមគួរនឹងប្រើប្រាស់ សមណគប្បីរើសយកតែសំពត់អាក្រក់ៗ អំពីព្រៃស្មសានក្តី អំពីគំនរសំរាមក្តី សំពត់ដែលធ្លាក់ចុះទៀបកនផ្សារក្តី មកធ្វើជាចីវរប្រើប្រាស់ សមណមិនត្រូវការនឹងបិណ្ឌបាតមានដំឡៃច្រើនឡើយ ត្រូវការតែបិណ្ឌបាតដ៏សមគួរនឹងឆាន់ សមណគប្បីចិញ្ចឹមជីវិតដោយដុំបាយដែលខ្លួនត្រេចទៅស្វែងរក សមណមិនត្រូវការនឹងសេនាសនមានដំឡៃច្រើនឡើយ ត្រូវការតែសេនាសនដ៏សមគួរនឹងនៅអាស្រ័យ សមណគួរតែនៅអាស្រ័យក្រោមម្លប់ឈើ ឬព្រៃស្មសាន ឬទីកលទំនេរ សមណមិនត្រូវការនឹងគិលានភេសជ្ជមានដំឡៃច្រើនឡើយ ត្រូវការតែគិលានភេសជ្ជ ដ៏សមគួរនឹងប្រើប្រាស់បាន សមណគប្បីធ្វើថ្នាំដោយទឹកនោមស្អុយ ឬផ្លែស្រម៉ប៉ុណ្ណោះ ថាដូច្នេះហើយ ក៏ប្រើប្រាស់តែចីវរសៅហ្មង ឆាន់តែបិណ្ឌបាតសៅហ្មង នៅអាស្រ័យតែសេនាសនសៅហ្មង ប្រើប្រាស់តែគិលានភេសជ្ជសៅហ្មងៗ

បំណែកខាយកបានដឹងយ៉ាងនេះហើយ ក៏មានសេចក្តីជ្រះថ្លាដោយគិតថា សមណនេះមានសេចក្តីប្រាថ្នាតិច ជាអ្នកសន្តោស មានសេចក្តីស្ងាត់ ជាអ្នកប្រារព្ធព្យាយាម មានពាក្យជាទីកំចាត់បង់នូវកិលេស ហើយក៏រឹតតែនិមន្តដោយបច្ច័យទាំង ៤ ៗ ភិក្ខុនោះក៏និយាយថា កុលបុត្រដែលមានសទ្ធា រមែងសោយបុណ្យជាច្រើន ដោយប្រជុំនៃវត្ថុ

ទាំង ៣ គឺសទ្ធា ១ ទេយ្យធម៌ ១ ទក្ខិណេយ្យបុគ្គល ១ បំណែកសទ្ធា អ្នកទាំងឡាយក៏មានស្រាប់ហើយ ទាំងទេយ្យធម៌ទឹងអាត្មាជាអ្នកទទួលក៏មានដែរ បើអាត្មាទឹងមិនទទួល អ្នកទាំងឡាយក៏សាបសូន្យចាកបុណ្យ អាត្មាក៏មិនជាត្រូវការដោយទេយ្យធម៌នេះប៉ុន្មានទេ តែថា ទទួលដោយសេចក្តីអនុគ្រោះដល់អ្នកទាំងឡាយ ថាដូច្នេះហើយក៏ទទួលបច្ច័យទាំង ៤ យ៉ាងច្រើន ៗ អំពើដូច្នេះរបស់ភិក្ខុនោះបានឈ្មោះថា រឿងកុហកពោលគឺការប្រើប្រាស់បច្ច័យទាំង ៤ ។

ឯរឿងកុហក ពោលគឺការផ្គត់ផ្គង់ដម្រង់ឥរិយាបថទាំង ៤ នោះ សេចក្តីថា ភិក្ខុពួក ១ ក្នុងសាសនានេះ មានសេចក្តីប្រាថ្នាច្រើន ប្រាថ្នាបង់ឲ្យគេសរសើរខ្លួន ក៏ចំប្រឹងផ្គត់ផ្គង់ដម្រង់ឥរិយាបថដើរឈរអង្គុយដេកឲ្យល្អ ធ្វើហាក់ដូចជាចូលកាន់សមាធិ អំពើដូច្នេះរបស់ភិក្ខុនោះឈ្មោះថា រឿងកុហកពោលគឺការផ្គត់ផ្គង់ដម្រង់ឥរិយាបថទាំង ៤ ។

ឯរឿងកុហកពោលគឺខ្សឹបខ្សៀវនោះ សេចក្តីថា ភិក្ខុពួក ១ ក្នុងសាសនានេះ មានសេចក្តីប្រាថ្នាច្រើន ប្រាថ្នាបង់ឲ្យគេសរសើរខ្លួន ក៏និយាយពាក្យអាស្រ័យនូវអរិយធម៌ថា ភិក្ខុឯណាប្រើប្រាស់ចីវរបែបនេះ ភិក្ខុនោះជាសមណមានសក្តិធំ ភិក្ខុឯណាប្រើប្រាស់បាត្រ ផ្តិលទឹក ធម្មក្រក សំពត់ដម្រង់ កូនសោ ស្បែកជើង វត្ថពន្ធចង្កេះ សំពត់អាយោគបែបនេះ ភិក្ខុនោះជាសមណមានសក្តិធំ ភិក្ខុឯណាមាន

ឧបជ្ឈាយ៍អាចារ្យជាដើមបែបនេះ ភិក្ខុនោះជាសមណមានសក្តិធំ ភិក្ខុឯណានៅក្នុងវិហារ អឌ្ឍយោគប្រាសាទជាដើមបែបនេះ ភិក្ខុនោះជាសមណមានសក្តិធំ ។

មួយវិញទៀត ភិក្ខុដែលមានមុខស្រទំក្រៃពេក មានមុខស្រពោនក្រៃពេក ញុំាងសត្វលោកឲ្យស្ញើចក្រៃពេក និយាយពាក្យច្រើនក្រៃពេក គេតែងនិយាយសរសើរថា "សមណនេះបាននូវវិហារសមាបត្តិដ៏ស្ងប់រម្ងាប់ ភិក្ខុនិយាយពាក្យប្រកបដោយលោកុត្តរធម៌នឹងព្រះនិព្វាន ជាពាក្យជ្រៅកំបាំងដ៏ល្អិតបែបយ៉ាងដូច្នោះ" អំពើដូច្នេះរបស់ភិក្ខុនោះ ឈ្មោះថា រឿងកុហកពោលគឺការខ្ជីបខ្ជៀវ ។

ឯលបនានោះ គឺការនិយាយពាក្យពក់ពាក់ស្រាកស្រួលនឹងគ្រហស្ថ ដោយសេចក្តីប្រាថ្នាលាភសក្ការ នឹងសេចក្តីសរសើរ ។ ភិក្ខុឃើញគ្រហស្ថដើរមកកាន់វត្តហើយនិយាយពក់ពាក់ថា ម្នាលអ្នកទាំងឡាយដ៏ចំរើន អ្នកទាំងឡាយអញ្ជើញមកដើម្បីអ្វី អញ្ជើញមកដើម្បីនិមន្តលោកឬអ្វី បើអញ្ជើញមកដើម្បីនិមន្តលោក ចូរត្រឡប់ទៅវិញចុះ ចាំអាត្មានាំលោកទៅតាមក្រោយ ៕

ម្យ៉ាងទៀត ភិក្ខុនិយាយអួតខ្លួនថា អាត្មាមានឈ្មោះដូច្នេះ ព្រះរាជាមែនជ្រះថ្លាកប់អាត្មាណាស់ ទាំងពួកមហាមាត្យឯនោះក្តី ។ ក៏ជ្រះថ្លាកប់អាត្មាណាស់ដែរ ។

ម្យ៉ាងទៀត ភិក្ខុនិយាយលើកគ្រហស្ថឲ្យខ្ពស់ថា លោកកុដុម្ពី លោកនាយសំពៅ លោកជាម្ចាស់ទាន ៗ

ម្យ៉ាងទៀត ភិក្ខុនិយាយល្បួងចងចិត្តគ្រហស្ថថា អ្នកទាំងឡាយពីដើមធ្លាប់ឲ្យទានក្នុងកាលនេះ ឥឡូវនេះហេតុអ្វីក៏មិនឲ្យទានទៀត កាលបើគ្រហស្ថនិយាយតបទៅវិញថា លោកម្ចាស់ ខ្ញុំមុខជានឹងឲ្យទានទៀតដែរ តែថា ខ្ញុំមិនទាន់មានឱកាស កាលបើគ្រហស្ថនិយាយដូច្នេះហើយ ភិក្ខុនោះក៏រឹងរឹតតែនិយាយលើកគ្រហស្ថ ចងចិត្តគ្រហស្ថថែមទៀត ៗ

ម្យ៉ាងទៀត ភិក្ខុឃើញគ្រហស្ថកាន់ដើមអំពៅដើរមក ក៏សួរថា នែឧបាសក ដើមអំពៅនេះអ្នកយកពីណាមក ៗ គ្រហស្ថឆ្លើយថា យកមកអំពីចំការលោកម្ចាស់ ៗ អំពៅក្នុងចំការនោះផ្អែមឬទេ ៗ បើចង់ដឹងផ្អែមឬមិនផ្អែម លុះតែឆាន់ទើបដឹង លោកម្ចាស់ ៗ នែឧបាសក ការនិយាយឲ្យគេប្រគេនដូច្នេះ មិនគួរដល់ភិក្ខុទេ ៗ

ម្យ៉ាងទៀត ភិក្ខុនិយាយបញ្ឆោរគ្រហស្ថថា ត្រកូលនេះរមែងស្គាល់អាត្មាច្បាស់ បើទេយ្យធម៌មានក្នុងត្រកូលនេះ ត្រកូលនេះឲ្យដល់អាត្មាមិនលែងឡើយ ៗ ការនិយាយមានសភាពដូច្នេះ បានឈ្មោះថា លបនា ៗ

សុភាសិតរពាកថា

របស់ព្រះគ្រូញាណសំវរ ញាណ-ឈឺន

(គ)

## សុភាសិតកថា

# ទោសសម្ផប្បលាប

*សេចក្ដីថា បុគ្គលឯណាពោលពាក្យឥតប្រយោជន៍ឥតផល បុគ្គលនោះឯងឈ្មោះថា អធម្មវាទី អធម្មវាទីបុគ្គលនោះឈ្មោះថា ជាអ្នកធ្វើព្រះសទ្ធម្មគឺសាសនាព្រះពុទ្ធឲ្យវិនាសទៅឆាប់ ៗ*

*ហេតុដូច្នោះ បានជាព្រះដ៏មានព្រះភាគទ្រង់សំដែងកបិលសូត្រក្នុងគម្ពីរឯកនិបាតង្គុត្តរដូច្នេះថា*

យេបិ តេ ភិក្ខវេ ភិក្ខូ អធម្មំ ធម្មោតិ ទីបេន្តិ តេបិ ភិក្ខវេ ភិក្ខូ ពហុជនាហិតាយ បដិបន្នា ពហុជនាសុខាយ ពហុនោ ជនស្ស អនត្ថាយ អហិតាយ ទុក្ខាយ ទេវមនុស្សានំ ពហុញ្ច តេ ភិក្ខវេ ភិក្ខូ អបុញ្ញំ បសវន្តិ តេបិ មំ សទ្ធម្មំ អន្តរធាបេន្តិ

*ប្រែថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាសំដែងសភាវមិនមែនធម៌ថាជាធម៌(១) (សំដែងធម៌ពិតថាមិនមែនជាធម៌វិញ) ម្នាលភិក្ខុទាំងឡាយ*

---

១ ត្រូវគ្នានឹងភេទករវត្ថុ ១៨ ប្រការគឺ ១ អធម្មំ ធម្មោតិ ទីបេតិ សំដែងសភាវដែលមិនមែនធម៌ថាជាធម៌ ២ ធម្មំ អធម្មោតិ ទីបេតិ សំដែងធម៌ថាមិនមែនជាធម៌ ៣ អវិនយំ វិនយោតិ ទីបេតិ សំដែងសភាវមិនមែនវិន័យថាជាវិន័យ ៤ វិនយំ អវិនយោតិ ទីបេតិ សំដែង

ថ្វន . . . . .

ភិក្ខុទាំងនោះឈ្មោះថា ជាអ្នកប្រតិបត្តិដើម្បីមិនឲ្យជាប្រយោជន៍នឹង សេចក្ដីសុខដល់ជនច្រើន ឈ្មោះថា ជាអ្នកប្រតិបត្តិដើម្បីមិនឲ្យជាប្រ-យោជន៍នឹងមិនបានជាគុណដល់ជនច្រើន (គ្រាន់តែជាអ្នកប្រតិបត្តិ) ដើម្បីសេចក្ដីទុក្ខដល់ទេវតានឹងមនុស្សទាំងឡាយ ម្នាលភិក្ខុទាំងឡាយ

---

វិន័យថាមិនមែនវិន័យ ៥ អភាសិតំ អលបិតំ តថាគតេន ភាសិតំ លបិតំ តថាគតេនាតិ ទីបេតិ សំដែងពាក្យដែលតថាគតមិនបានពោលមិនបានចរចា ថាតថាគតបានពោលបានចរចា ៦ ភាសិតំ លបិតំ តថាគតេន អភាសិតំ អលបិតំ តថាគតេនាតិ ទីបេតិ សំដែងពាក្យដែលតថាគតបានពោលបានចរចា ថាតថាគតមិនបានពោលមិនបានចរចា ៧ អនាចិណ្ណំ តថាគតេន អាចិណ្ណំ តថាគតេនាតិ ទីបេតិ សំដែងកិច្ចដែលតថាគតមិនបានសន្សំ ថាតថាគតបានសន្សំ ៨ អាចិណ្ណំ តថាគតេន អនាចិណ្ណំ តថាគតេនាតិ ទីបេតិ សំដែងកិច្ចដែលតថាគតបានសន្សំ ថាតថាគតមិនបានសន្សំ ៩ អប្បញ្ញត្តំ តថាគតេន បញ្ញត្តំ តថាគតេនាតិ ទីបេតិ សំដែងសិក្ខាបទដែលតថាគតមិនបានបញ្ញត្ត ថាតថាគតបានបញ្ញត្ត ១០ បញ្ញត្តំ តថាគតេន អប្បញ្ញត្តំ តថាគតេនាតិ ទីបេតិ សំដែងសិក្ខាបទដែលតថាគតបានបញ្ញត្ត ថាតថាគតមិនបានបញ្ញត្ត ១១ អនាបត្តិំ អាបត្តីតិ ទីបេតិ សំដែងអនាបត្តិ ថាជាអាបត្តិ ១២ អាបត្តិំ អនាបត្តីតិ ទីបេតិ សំដែងអាបត្តិ ថាជាអនាបត្តិ ១៣ លហុកំ អាបត្តិំ គរុកា អាបត្តីតិ ទីបេតិ សំដែងអាបត្តិស្រាលថាជាអាបត្តិធ្ងន់ ១៤ គរុកំ អាបត្តិំ លហុកា អាបត្តីតិ ទីបេតិ សំដែងអាបត្តិធ្ងន់ ថាជាអាបត្តិស្រាល ១៥ សាវសេសំ អាបត្តិំ អនវសេសា អាបត្តីតិ ទីបេតិ សំដែងអាបត្តិដែលជាសាវសេស ថាជាអាបត្តិអនវសេស ១៦ អនវសេសំ អាបត្តិំ សាវសេសា អាបត្តីតិ ទីបេតិ សំដែងអាបត្តិដែលជាអនវសេស ថាអាបត្តិជាសាវសេស ១៧ ទុដ្ឋុល្លំ អាបត្តិំ អទុដ្ឋុល្លា អាបត្តីតិ ទីបេតិ សំដែងទុដ្ឋុល្លាបត្តិ ថាជាអទុដ្ឋុល្លាបត្តិ ១៨ អទុដ្ឋុល្លំ អាបត្តិំ ទុដ្ឋុល្លា អាបត្តីតិ ទីបេតិ សំដែងអទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិ (គោសម្ពិកក្ខន្ធកមហាវគ្គ នឹងសង្ឃភេទក្ខន្ធកចុល្លវគ្គ)

ភិក្ខុនោះតែងសោយនូវទោសមានប្រមាណច្រើន (មិនតែប៉ុណ្ណោះសោត) ភិក្ខុនោះឈ្មោះថា ធ្វើព្រះសទ្ធម្មគឺសាសនារបស់តថាគតឱ្យសាបសូន្យទៅ ៗ ដូចរឿងកបិលភិក្ខុដែលនាំមកសំដែងក្នុងគម្ពីរធម្មបទនោះ ។

សេចក្ដីថា កាលក្នុងសាសនាព្រះពុទ្ធព្រះនាមកស្សប មានភិក្ខុមួយរូបឈ្មោះកបិលភិក្ខុ អ្នកចេះចាំព្រះត្រៃបិដកមានបរិវារច្រើនផង មានលាភច្រើនផង ក៏មានចិត្តស្រវឹងដោយការនៃខ្លួនជាពហុស្សុត ប្រកាន់មានះរឹងត្អឹង ព្រោះតណ្ហាគ្របសង្កត់ក៏ពោលពាក្យញាំញីបង្អាប់បង្អិន របស់គួរក្នុងធម៌វិន័យ ត្រឡប់ថា មិនគួរ របស់មិនគួរក្នុងធម៌វិន័យ ត្រឡប់ថា គួរវិញ ភិក្ខុដែលត្រឹមត្រូវក្នុងធម៌វិន័យ ពោលហាមប្រាមក៏មិនស្ដាប់ ប្រែជាជេរប្រទេចដល់ភិក្ខុទាំងនោះវិញ ដោយពាក្យផ្សេងៗ លុះច្យុតអំពីមនុស្សលោកនេះ ក៏ទៅឆេះនៅក្នុងអវីចិនរកអស់កាលដ៏យូរអង្វែងមួយពុទ្ធន្តរ សេសផលពីនោះមកកើតជាត្រីធំមាសក្នុងស្ទឹងអចិរវតី មានមាត់ស្អុយអាក្រក់ ព្រោះជេរប្រទេចភិក្ខុផងគ្នា មានសម្បុរល្អដូចមាស ព្រោះទ្រទ្រង់ព្រះត្រៃបិដកក្នុងកាលនោះ ។

ហេតុដូច្នោះ ពាក្យពោលជាសម្ផប្បលាប ដែលអ្នកប្រាជ្ញមិនរាប់ថាជាធម៌ បុគ្គលគប្បីលះបោលចេញ ពាក្យពោលជាអសម្ផប្បលាបដែលអ្នកប្រាជ្ញរាប់ថាជាធម៌ បុគ្គលគប្បីពោលចុះ ។

ចប់រឿងកបិលភិក្ខុ

អធិប្បាយអំពីទោសនៃទុព្ភាសិតវាចាក៏អស់សេចក្ដីតែត្រឹមនេះ ។

## គុណនៃសុភាសិតវាចា

លំដាប់តពីនេះទៅនឹងសំដែងគុណនៃសុភាសិតវាចាវិញ ។ គុណនៃសុភាសិតវាចានោះ ប្លែកគ្នាជាបួនយ៉ាងគឺមាន

១ ពាក្យសច្ចវាចា ជាហេតុដកចោលនូវទោសគឺមុសាវាទ

២ ពាក្យសុភាសិតវាចា ជាហេតុដកចោលនូវទោសគឺបិសុណវាចា

៣ ពាក្យបិយវាចា ជាហេតុដកចោលនូវទោសគឺផរុសវាចា

៤ ពាក្យជាធម៌ ជាហេតុដកចោលនូវទោសគឺសម្ផប្បលាប ។

## ន័យដទៃទៀតថា

១ មិនពោលពាក្យមុសាវាទ តបថាពោលពាក្យពិតគឺសច្ចវាចា

២ មិនពោលពាក្យបិសុណវាទ តបថាពោលពាក្យជាសុភាសិត

៣ មិនពោលពាក្យផរុសវាទ តបថាពោលពាក្យបិយវាចា

៤ មិនពោលពាក្យសម្ផប្បលាបៈ តបថាពោលពាក្យជាធម៌ ។

ន័យទាំងពីរនេះ មានសេចក្ដីរួមចុះជាមួយគ្នា ប្លែកតែដោយការអធិប្បាយប៉ុណ្ណោះ ។

## គុណអ្នកមិនពោលពាក្យមុសាវាទ

បុគ្គលអ្នកមិនពោលពាក្យមុសាវាទហើយ ជាគុណនៃវិសេសប្រាំបី

មរណភ័យបាន ដូចសត្វកិន្នរ[១] មួយគូញីឈ្មោល ដែលមានសេចក្តីមកក្នុងគម្ពីរតេរសនិបាត តក្ការិយជាតក ។

មានរឿងដំណាលថា ក្នុងកាលនោះមានព្រានព្រៃម្នាក់នៅក្នុងក្រុងពារាណសី ដើរទៅព្រៃហិមពាន្តដើម្បីបាញ់ម្រឹគ ព្រាននោះបានចាប់យកសត្វកិន្នរមួយគូញីឈ្មោល នាំមកថ្វាយព្រះបាទពារាណសី ។ ទ្រង់ត្រាស់សួរថា កិន្នរនេះមានគុណដូចម្តេចខ្លះ ព្រានព្រៃក្រាបទូលថា កិន្នរនេះចេះរាំផង ចេះច្រៀងផង រាំក៏ល្អមើល ច្រៀងក៏ពីរោះស្តាប់ មនុស្សយើងចេះមិនដូចឡើយ ស្តេចទ្រង់ព្រះសណ្តាប់កិត្តិគុណ[២] ដូច្នោះហើយ មានព្រះទ័យត្រេកអរទ្រង់ប្រទានទ្រព្យសម្បត្តិដល់ព្រានព្រៃមានប្រមាណច្រើន ហើយទ្រង់ត្រាស់ប្រើឲ្យកិន្នរទាំងពីរឲ្យច្រៀងរាំទឹងទត់កំសាន្តព្រះទ័យ ។

ទើបកិន្នរទាំងពីរគិតគ្នាថា កាលយើងច្រៀងក៏មិនពីរោះពីសារអ្វី កាលរាំសោតក៏មិនល្អមើលអ្វី នឹងទៅជាកំដាច្រៀងតែផ្តេសផ្តាស ទោសមុសាវាទក៏នឹងកើតមានដល់យើង ព្រោះតែពោលច្រើន ព្រោះតែធ្វើច្រើន សុទ្ធតែមិនពិត ។ កិន្នរទាំងពីរគិតដូច្នោះហើយ ក៏មិនច្រៀង

---

១ សត្វបំពួកមួយមានសណ្ឋានទ្រង់ទ្រាយដូចមនុស្សយើងដែរ ប្លែកតែមានស្លាបហោះហើរទៅតាមអាកាសបាន ហើយច្រើនមាននៅតែព្រៃភ្នំ ។ ដូចយ៉ាងព្រៃហិមពាន្តជាដើម ។

២ ពាក្យសរសើរពីគុណរបស់សត្វកិន្នរនោះ ។

មិនរាំ ស្ដេចប្រើហើយប្រើទៀត សត្វកិន្នរទាំងពីរនៅតែមិនច្រៀងមិនរាំ ទើបទ្រង់ខ្ញាល់ប្រើគេឲ្យយកទៅសម្លាប់ មេកិន្នរបានស្ដាប់ព្រះរាជឱង្ការ ដឹងថា ស្ដេចទ្រង់ខ្ញាល់ទឹងឲ្យសម្លាប់អាត្មាដូច្នោះ ក៏មកគិតថា គួរអញទឹងពោលពាក្យល្អក្នុងកាលឥឡូវនេះចុះ មេកិន្នរគិតហើយទើបសូត្រជាបទគាថាថា

សតំ សហស្សានំ ទុព្ភាសិតានំ
កលម្បិ នាគ្ឃតិ សុភាសិតស្ស
ទុព្ភាសិតំ សង្កមានោ កិលេសេ
តស្មា តុណ្ហី កឹ បុរិសោ ន ពាល្យាតិ

ប្រែថា រយពាន់គុណនៃវាចាជាទុព្ភាសិត គង់មិនដល់មួយចំណិតនៃវាចាជាសុភាសិត កាលបុគ្គលពោលពាក្យឲ្យយាងចុះកាន់គន្លងទុព្ភាសិតហើយ ទឹងបានសោយទុក្ខលំបាកទឹងសៅហ្មងមិនលែងឡើយ ៗ

ហេតុនោះបានជាកិន្នរឈ្មោលនៅស្ងៀមមិនច្រៀងមិនរាំ ព្រោះខ្លាចទុព្ភាសិត មិនមែនស្ងៀមនៅដោយការល្ងង់ខ្លៅទេ ៗ

ព្រះបាទពារាណសី ទ្រង់ព្រះសណ្ដាប់ពាក្យមេកិន្នរហើយ មានព្រះទ័យរីករាយ ក៏ទ្រង់មានព្រះរាជឱង្ការបង្គាប់ឲ្យនាំមេកិន្នរទៅលែងឯព្រៃហិមពាន្ត ទ្រង់ព្រះបង្គាប់ឲ្យយកកិន្នរឈ្មោលទៅសម្លាប់ធ្វើព្រះស្ងោយក្នុងពេលព្រឹក ៗ កិន្នរឈ្មោលបានឮហើយទឹកក្នុងចិត្តថា ចំនងជា

ស្ដេចឲ្យសម្លាប់អញដោយពិត បើដូច្នោះ គួរអញនឹងពោលពាក្យពីរោះខ្លះ ក្នុងកាលឥឡូវនេះចុះ កិន្នរឈ្មោលគិតហើយ ក៏ពោលពាក្យជាវេយ្យាករណ៍(១)ថា បណ្ដាសត្វទ្វេបាទទាំងអស់ តែងបរិភោគស្លាជាចំណី មានផ្លូវមេឃជាទីពឹងទីពំនាក់ បណ្ដាមនុស្សទាំងអស់ មានសត្វចិញ្ចឹមជាទីពឹងទីពំនាក់ ព្រោះថា មនុស្សតែងរស់នៅបាន ក៏អាស្រ័យនឹងបញ្ចគោរស(២) ចំណែកខ្លួនខ្ញុំមានព្រះអង្គជាទីពឹងទីពំនាក់ ប្រពន្ធខ្ញុំមានខ្ញុំជាទីពឹងទីពំនាក់ កាលខ្ញុំទាំងពីរនាក់មានជីវិតរស់នៅដរាបណា នឹងមិនបានលះបោលគ្នាដរាបនោះ ហេតុដូច្នោះ បើព្រះអង្គប្រាថ្នានឹងលែងមេកិន្នរឲ្យទៅឯព្រៃហិមពាន្ត ត្រូវតែព្រះអង្គឲ្យសម្លាប់ខ្ញុំឲ្យហើយជាមុនទៅ សឹមលែងមេកិន្នរឲ្យទៅជាខាងក្រោយចុះ ។

ព្រះបាទពារាណសី បានទ្រង់ស្ដាប់សំដីនៃសត្វទាំងពីរ ពីរោះដូច្នោះ ក៏ត្រឡប់ជាស្រួលព្រះទ័យ ទ្រង់ប្រើព្រានព្រៃឲ្យនាំយកកិន្នរទាំងពីរទៅលែងឯព្រៃហិមពាន្ត ហើយទ្រង់ហាមមិនឲ្យអ្នកណាមួយសម្លាប់កិន្នរទាំងពីរ ចាប់ដើមតាំងពីថ្ងៃនោះទៅ សត្វកិន្នរទាំងពីរបាន

---

១ របៀបបាឡីជាពាក្យរាយមិនមានឃ្លាមិនមានសង្កាត់ជាក្រុម ៗ គឺ ៨ អក្សរឬ ១១ អក្សរ ១២ អក្សរ ។ល។ ដូចជាគាថាទេ ដូចបាឡីធម្មចក្កប្បវត្តនសូត្រពីដើមរហូតដល់ចប់ សុទ្ធតែជាវេយ្យាករណ៍ជាពាក្យរាយទាំងអស់ ។ ២ រសទឹកដោះគោមាន ៥ យ៉ាងគឺ ខីរំ ទឹកដោះស្រស់ដែលទើបនឹងរូតមកថ្មី ១ ទធិ ទឹកដោះដែលក្លាយទៅជាទឹកដោះជូរ ១ ឃតំ ទឹកដោះដែលរងថ្លា ១ តក្កំ ទឹកដោះដែលឡើងប្រេង ១ នវនីតំ ទឹកដោះខាប់-ខាន់ ១ ។

រួចពីមរណភ័យ ព្រោះខ្លាចមុសាវាទ មិនហ៊ានពោលពាក្យទុព្ភាសិត តាំងនៅនឹងតែក្នុងពាក្យជាសុភាសិតតែម្យ៉ាង សមដូចបទគាថាថា

តស្មា មរណតោ មោត្តុំ បត្ថយន្តេន ជន្តុនា
បហាយ អលិកំ សច្ចំ ភាសិតព្វំ សុធីមតា

ប្រែថា ជនជាបណ្ឌិតអ្នកមានបញ្ញា កាលប្រាថ្នាចង់ឲ្យរួចចាកមរណភ័យនោះ គប្បីលះចោលពាក្យកុហក ហើយពោលតែពាក្យសច្ច[១] មួយផ្នែកប៉ុណ្ណោះ ។

ព្រះវង្គីសត្ថេរលោកដឹងសេចក្តីនេះពិតហើយ ទើបលោកសំដែងជាបទគាថាដកប់ចូលក្នុងសុភាសិតសូត្រដូច្នេះថា

សច្ចំ វេ អមតា វាចា ឯស ធម្មោ សនន្តនោ
សច្ចេ អត្ថេ ច ធម្មេ ច អាហុ សន្តោ បតិដ្ឋិតា

ប្រែថា វាចាសច្ចជាវាចាមិនស្លាប់ពិត វាចាសច្ចនេះជាធម៌គឺអ្នកប្រាជ្ញទាំងឡាយតែងសន្សំហើយពីមុន ៗ អ្នកប្រាជ្ញទាំងឡាយមានព្រះពុទ្ធជា

---

១ សច្ចមាន ៤ យ៉ាងគឺៈ វចីសច្ច បានដល់ពាក្យសំដីពិតពាក្យសំដីទៀង ដូចពាក្យថា បុគ្គលគប្បីនិយាយពាក្យពិតពាក្យទៀង ១ សម្មតិសច្ច បានដល់ការសន្មត ដូចជាគេសន្មតថា ជននេះជាព្រាហ្មណ៍ពិត ជននេះជាក្សត្រិយពិតជាដើម · ទិដ្ឋិសច្ច បានដល់សេចក្តីយល់ឃើញ ដូចយល់ឃើញថា នេះជារបស់ពិត ក្រៅពីនេះជារបស់ខុសទទេមិនពិតឡើយ ១ បរមត្ថសច្ច បានដល់អរិយសច្ចទាំង ៤ ប្រការមានទុក្ខអរិយសច្ចជាដើម ១ ។ (មគ្គវគ្គវណ្ណនា ធម្មបទដ្ឋកថា) ។

ដើម តែងស្ថិតនៅក្នុងសច្ចធម៌ គឺធម៌ជាប្រយោជន៍ខ្លួនផង ប្រយោជន៍អ្នកដទៃផង តាមធម្មតាមិនឃ្លៀងឃ្លាតឡើយ ។

ចប់រឿងកិន្នរ

ពាក្យដែលជាសច្ចៈ តែងនាំមកនូវប្រយោជន៍ខ្លួន និងប្រយោជន៍អ្នកដទៃនោះ បានសេចក្តីដូចរឿងអធិមុត្តកសាមណេរក្នុងគម្ពីរធម្មបទ និងរឿងមហាសុត្តសោមបណ្ឌិត ក្នុងគម្ពីរអសីតិនិបាត និងរឿងមនុស្សស្ត្រីម្នាក់ក្នុងគម្ពីរធម្មបទដែរ ។

# គុណបិយវាចា

សេចក្តីថា កាលក្នុងអតីតកាលកន្លងទៅយូរហើយ ក្នុងក្រុងពារាណសី មានសេដ្ឋីបុត្រ ៤ នាក់នាំគ្នាចេញទៅពីផ្ទះអង្គុយជុំគ្នាក្រោមដើមឈើមួយដើម ក្រឡេកឃើញព្រានម្រឹគម្នាក់ដឹកសាច់ក្នុងរទេះដឹកទៅលក់ ក៏នាំគ្នាសូមសាច់អំពីព្រាននោះ សេដ្ឋីបុត្រជាបឋមពោលសូមថា នែរ៉ៅព្រានចង្រៃ អ្នកឯងដឹកសាច់ទៅលក់ឯណា ឲ្យមកអញមួយដុំ ព្រានម្រឹគគិតថា អ្នកនេះសូមអញ គួរតែពោលពាក្យល្អ គិតហើយទើបតបថា អើសំដីរបស់អ្នកនេះដាផុសពារ មិនឆ្ងាញ់ពីសាប្រហែលដូចសាច់ពារ បើដូច្នោះ ខ្ញុំនឹងឲ្យសាច់ពារដល់អ្នក ថាហើយក៏ឲ្យសាច់ពារមួយដុំទៅ ។

សេដ្ឋីបុត្រជាគំរប់ពីរ ពោលសូមថា អើអ្នកបង អ្នកដឹកសាច់ទៅលក់ឯណា ចូរឲ្យខ្ញុំសូមមួយដុំ ព្រានម្រឹគគិតថា អើសំដីអ្នកនេះគួរសមហ៊ានហៅអាត្មាអញថាបង ហាក់ដូចជាបងប្អូនរបស់ខ្លួន សំដីនេះពីរោះប្រហែលដូចសាច់ចំឡកដ៏ឆ្ងាញ់ គិតហើយទើបតបថា អើសំដីរបស់អ្នកគួរហើយ ប្រហែលដូចសាច់ចំឡក បើដូច្នោះ ខ្ញុំនឹងឲ្យសាច់ចំឡកដល់អ្នក ថាហើយក៏ឲ្យសាច់ចំឡកមួយដុំទៅ ។

សេដ្ឋីបុត្រជាគំរប់បីពោលសូមថា បពិត្របិតាអ្នកដឹកសាច់ទៅលក់ឯណា ចូរអ្នកឲ្យសាច់ខ្ញុំមួយដុំផង ព្រានម្រឹគគិតថា សំដីដែលហៅថាបពិត្របិតាដូច្នេះ មានតែកូនហៅឪពុក ញុំាងបេះដូងនៃឪពុកឲ្យញាប់ញ័រ គិតហើយទើបតបថា អើសំដីរបស់អ្នកពីរោះហើយ ប្រហែលដូចសាច់បេះដូង បើដូច្នោះ ខ្ញុំនឹងឲ្យសាច់បេះដូងដល់អ្នក ថាហើយក៏ឲ្យសាច់បេះដូងមួយដុំទៅព្រមទាំងសាច់ឆ្ងាញ់ឯទៀតខ្លះផង ។

សេដ្ឋីបុត្រជាគំរប់ ៤ ពោលសូមថា នែសំឡាញ់ អ្នកដឹកសាច់ទៅលក់ឯណា ចូរសំឡាញ់ឯងចែកឲ្យយើងខ្លះផង ព្រានម្រឹគគិតថា មនុស្សប្រុស បើគ្មានមិត្រសំឡាញ់ក្នុងស្រុកនឹងគេហើយ ក៏ដូចជាគ្មានស្រុកទៅ ឧបមាដូចព្រៃមិនមានមនុស្សជ្រកព្ទុះទៅដូច្នោះដែរ ឥឡូវអ្នកនេះ គាត់ហៅអាត្មាអញថា សំឡាញ់ ៗ ហាក់ដូចជាស្និទ្ធស្នាលនឹងគ្នាឯកយូរហើយ គិតហើយទើបតបថា អើសំដីរបស់អ្នកដែលពោលមកនេះ

ប្រហែលដោយសម្បត្តិរបស់ខ្លួនទាំងអស់នេះ បើដូច្នោះ ខ្ញុំនឹងឲ្យសាប់ព្រមទាំងរទេះរបស់ខ្ញុំនេះទាំងអស់ដល់អ្នកជាសំឡាញ់ ថាហើយក៏បររទេះដឹកសាប់ទៅឲ្យសេដ្ឋីបុត្រជាគំរប់ ៤ នោះទៅ ។

សេដ្ឋីបុត្រនោះក៏រាប់អានស្មោះស្មើ ប្រាប់ប្រពន្ធកូនឲ្យរាប់អានស្មើទៅ ហើយហាមលែងឲ្យធ្វើអំពើបាណាតិបាតតទៅទៀត ឲ្យនៅដោយសម្បត្តិរបស់ខ្លួនដរាបដល់អស់ជីវិត សេដ្ឋីបុត្រមានលាភបានសាប់ច្រើនជាងសេដ្ឋីបុត្រឯទៀត ៗ ក៏ព្រោះគុណគឺពោលបិយវាចានោះឯង ។

ព្រះវគ្គីសត្ថារលោកដឹងសេចក្ដីនេះពិតហើយ ទើបលោកសំដែងជាបទគាថាថា

បិយវាចមេវ ភាសេយ្យ យា វាចា បដិនន្ទិតា
យំ អនាទាយ បាបានិ បរេសំ ភាសតេ បិយំ

ប្រែថា សំដីឯណាដែលគេត្រេកអររីករាយហើយ បុគ្គលគប្បីពោលសំដីជាបិយវាចានោះកុំខាន ។

មួយវិញទៀត បុគ្គលបើពោលពាក្យឯណាក្ដី កុំកាន់យកពាក្យដ៏លាមកដែលជាផរុសវាចាមិនជាទីស្រឡាញ់នោះឡើយ ត្រូវពោលតែពាក្យជាបិយវាចាដែលជាទីស្រឡាញ់នៃអ្នកទាំងឡាយ ។

ចប់រឿងសេដ្ឋីបុត្រ ៤ នាក់ ។

អធិប្បាយអំពីគុណនៃសុភាសិតវាចាអស់សេចក្ដីតែត្រឹមនេះ ។

គាថានេះនឹងអធិប្បាយក្នុងគុណរបស់អ្នកស្តាប់សុភាសិតចំពោះព្រះគ្រូវិញ ។

សេចក្តីថា ពុទ្ធភាសិតដែលព្រះពុទ្ធទ្រង់សំដែងទាំងប៉ុន្មាន អ្នកប្រាជ្ញតែងរាប់ថាជាសុភាសិតវាចាទាំងអស់ ព្រោះថា ព្រះអង្គពោលសំដៅសេចក្តីក្សេមក្សាន្តគឺព្រះនិព្វាន សំដៅសេចក្តីផុតចាកវដ្តទុក្ខ គឺព្រះនិព្វាន សំដៅសេចក្តីមិនកើតមិនចាស់ មិនឈឺមិនស្លាប់ គឺព្រះនិព្វាន ។

បានជាព្រះវង្គីសត្ថេរលោកដឹងសេចក្តីនេះពិតហើយ ទើបលោកសំដែងជាបទគាថាដូច្នេះថា

យំ ពុទ្ធោ ភាសតី វាចំ ខេមំ និព្វានបត្តិយា

ទុក្ខស្សន្តកិរិយាយ សា វេ វាចានមុត្តមា

ប្រែថា ព្រះពុទ្ធជាម្ចាស់ទ្រង់សំដែងនូវវាចាណាជាក្សេមក្សាន្ត វាចានោះហើយខ្ពស់វិសេសផុតជាងវាចាទាំងឡាយនានា ព្រោះសំដៅសេចក្តីដែលដល់នូវព្រះនិព្វាន ជាដែនធ្វើឲ្យអស់ទុក្ខទៅបាន ។

ឯអ្នកស្តាប់សុភាសិតចំពោះព្រះគ្រូហើយ បានលុះមគ្គផលដូចមានសេចក្តីតទៅនេះ

កាលទ្រង់សំដែងព្រះធម្មចក្កប្បវត្តនសូត្រ ព្រះអញ្ញាកោណ្ឌញ្ញត្ថេរនឹងព្រហ្ម ១៨ កោដិ បានក្រេបផឹកអម្រឹតរស គឺរសក្នុងព្រះនិព្វាន ។

(មានត)

# រឿងហៅកាំបិតបន្ទោះ

(តមកនឹងបប់)

ក៏បបួលគ្នាសើចទឹងផណ្តើរមិនស្តី ហើយទឹងចៅបុរសនាំបង្កើតក្តី ហើយថា ចៅបុរសឯងឆ្កួត ដីដូនដីតាអាណា គេក្តីទឹងផណ្តើរដូចចៅឯងទេ ចៅឯងទៅរកអ្នកណា គេដំរះឲ្យចុះ ។ ឯចៅបុរសនោះចងផណ្តើរអូសចូលទៅក្នុងទីវាំង ដួនស្តេចចេញបុនពេនក៏ស្តេចទតឃើញ ស្តេចឲ្យអមាត្យរត់ទៅហៅចៅបុរសនោះវាថី ចងផណ្តើរអូសហើយដាក់ឃ្នាងដូច្នោះ អមាត្យរត់ទៅហៅចៅបុរសនោះមក ស្តេចមានបន្ទូលសួរថា ចៅបុរសដំណើរដូចម្តេច ក៏បានជាដាក់ឃ្នាងផណ្តើរ ហើយចងអូសដូច្នោះ តើពីដំណើរហេតុអ្វី ចៅបុរសនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស កាលដើមឡើយ ខ្ញុំទូលបង្គំបានយករបស់ទៅដីកកប់ក្រោមផណ្តើរនេះ ផ្ញើទឹងផណ្តើរឲ្យផណ្តើររក្សាឲ្យ ផណ្តើរនេះឲ្យមនុស្សលួចយកអស់ បានជាទូលបង្គំពុំសុខចិត្តទឹងផណ្តើរ ។ ឯស្តេចមានបន្ទូលសួរចៅបុរសថា របស់អ្វីខ្លះ ចៅបុរសនោះក្រាបទូលថា ខ្សែចងដម្បងវាយឆ្នាំងឆ្អិនឯងរែវជ្រុកដើរលើទឹកបាន ស្តេចទ្រង់ជ្រាបហើយ ស្តេចឲ្យបុរសយកផណ្តើរនេះមកថ្វាយស្តេច ។ ឲ្យអមាត្យយកទុក ស្តេចទ្រង់ឈ្នះដោយព្រះប្រាជ្ញា ។ ស្តេចមានព្រះបន្ទូលថា ចៅបុរសប្រពន្ធចៅឯងមានសហាយ ចៅឯងនៅទឹងអញ ក៏ស្តេចទ្រង់ប្រទានសំពត់អាវ ឲ្យបុរសនោះស្លៀកពាក់ ឯចៅបុរសនោះ ក៏នៅគាល់បំរើស្តេចប្រមាណ ៣ ថ្ងៃ ស្តេចទ្រង់ប្រទានព្រះពស្ត្រកូសា ឲ្យចៅបុរសហើយស្តេចផ្តាំថា បើចៅ

បុរសយកសំពត់ដែលអញឲ្យនេះទៅផ្ទះ បើមានគេទៅបបួលថា ឲ្យមកមើលរបាំ ឯងកុំមក ឯងឲ្យតែសំពត់អស់ទាំងនេះទៅប្រពន្ធឯងស្លៀកពាក់មកមើលរបាំ ចៅបុរសនោះឮស្ដេចផ្ដាំស្រេច ក៏ថ្វាយបង្គំលាស្ដេចវិលទៅផ្ទះវិញ ។ ឯមេប្រពន្ធឃើញប្ដីបានសំពត់ល្អ ធ្វើឫកហាក់ដូចស្រឡាញ់ប្ដីនោះណាស់ លុះព្រឹកឡើងស្ដេចឲ្យប៉ាវគងថា ឲ្យអស់អាណាប្រជារាស្ត្រទាំងអស់ទៅមើលរបាំ ដ្បិតស្ដេចរៀបរាំឲ្យអស់រាស្ត្រមើល ឯអស់អ្នកស្រុកក៏បបួលគ្នាទៅមើលល្ខោនទ្រហឹងអឹងកង មេប្រ-ពន្ធចៅបុរសនោះក៏បបួលថា អ្នកទៅមើលរាំនឹងគេ ឯចៅបុរសថា នាងឯងទៅមើលចុះ យកសំពត់ឯណោះទៅស្លៀកមើលរាំនឹងគេចុះ មេនោះឮប្ដីឲ្យសំពត់ល្អទៅស្លៀកមើលរាំ ក៏នឹកអរក្នុងចិត្តគិតយកទៅឲ្យសហាយនោះស្លៀក ដ្បិតប្ដីមិនទៅមើលរាំ មេនោះក៏លេះលោំងបានសំពត់ចុះដើរទៅស្កាត់រកសហាយឃើញ ក៏ឲ្យសំពត់នោះទៅអាសហាយនោះស្លៀក រួចបណ្ដើរគ្នាទៅដល់ទីរាំងចូលទៅឈរមើលល្ខោនទន្ទឹមគ្នា ។ ឯស្ដេចឲ្យទាហានក្រុមរាំងដើរល្បាតមើល បើឃើញនរណាស្លៀកសំពត់ដែលស្ដេចប្រទានឲ្យចៅបុរសនោះ ស្ដេចឲ្យហៅមកទាំងប្រុសទាំងស្រី អស់ពួកទាហានក្រុមរាំងល្បាតទៅឃើញអានោះមេនោះឈររមើលរាំទន្ទឹមគ្នា ក៏ទាហានក្រុមរាំងហៅអានោះមេនោះមកថ្វាយស្ដេច ។ ទតទៅមិនមែនខ្លួនចៅបុរស ស្ដេចឲ្យទៅហៅចៅបុរសនោះមកស្ដេចសួរថា ឯណាប្រពន្ធ

ចៅបុរសឯង ចៅបុរសនោះថា នាងនេះប្រពន្ធហើយ ប្រពន្ធទូលបង្គំជាខ្ញុំហើយ ស្តេចមានបន្ទូលថា ចុះចៅប្រុសនេះឯងស្គាល់ទេ ចៅបុរសទូលស្តេចថាមិនស្គាល់ ក៏ស្តេចឲ្យកន្ទុបកញ្ចាស់មកឲ្យអាសហាយមេនោះផ្លាស់សំពត់នោះចេញ ហើយស្តេចសួរថា សំពត់នេះឯងបានមកពីណា អានោះភិតភ័យទូលស្តេចថា នាងនេះឲ្យទូលបង្គំស្លៀក ស្តេចសួរថា អាឯងលួចប្រពន្ធចៅបុរសនេះមែនឬទេ អានោះក៏ទូលស្តេចថា ទូលបង្គំលួចមែន ហើយស្តេចសួរថា របស់ដែលចៅបុរសនេះ គេកប់ក្រោមដំណេករមែនឬទេ អានោះថា ទូលបង្គំមែន ហើយស្តេចឲ្យបណ្តើរអានោះទៅយករបស់អស់ទាំងនោះមក ហើយស្តេចសួរបុរសនោះថា របស់នេះហើយឬចៅបុរស ជារបស់ឯង ឯចៅបុរសក្រាបទូលថា នេះហើយរបស់ទូលបង្គំជាខ្ញុំ ហើយស្តេចសួរថា ចៅបុរស ឯអានេះនឹងមេនោះ នឹងឲ្យធ្វើទោសយ៉ាងណា ចៅបុរសនោះទូលថា ណ្ហើយទូលបង្គំសូមទ្រង់ព្រះរាជទានទោសឲ្យ ៗ ទៅរកយកគ្នាចុះ ឯស្តេចនឹងនាហ្មឺនក៏កោតចិត្តចៅបុរសនោះ ស្តេចលែងទោសតាមពាក្យចៅបុរស ៗ ហើយចៅបុរសលើករបស់ទាំងអស់ថ្វាយទៅស្តេចទាំងអស់ ក៏ចៅបុរសទូលស្តេចថា សូមទ្រង់មេត្តាប្រោស ឯខ្សែទឹងជម្សងនេះ បើមានសត្រូវមកជាបច្ចាមិត្រ បើខ្សែឲ្យទៅចងជម្សងរាយ បច្ចាមិត្តនោះស្លាប់វិនាសអន្តរាយអស់ ឯឆ្នាំងនេះ បើទ្រង់សព្វព្រះរាជហឫទ័យនឹងអាហារបំណីអ្វី

ក៏ប្រាប់ថា ឆ្នាំងឆ្អិនឡើងឆ្អិនដូចចិត្ត តែប្រដេកនេះទៀត បើទ្រង់យាង លើទឹកនេះបាន ឯស្តេចនឹកក្នុងព្រះទ័យថា ទ្រព្យទាំងនេះជាទ្រព្យមានដំឡៃ អញនឹងឲ្យទ្រព្យអ្វីឲ្យស្មួននឹងថ្លៃរបស់ចៅបុរសម្នាន ទុកជាខ្លួនអញនឹងមហេសីបុត្រី ទាំងទ្រព្យនគរក្ដីក៏ពុំស្មើរបស់ចៅបុរសនេះផង ៗ ហើយមហាក្សត្រស្តេចមានបន្ទូលទៅនឹងចៅបុរសថា របស់អញគ្មានអ្វីនឹងតបថ្លៃទ្រព្យចៅ អញមានតែបុត្រីមួយនឹងរាជសម្បត្តិ អញលើកឲ្យតបថ្លៃទ្រព្យចៅ ឯចៅបុរសក្រាបទូលទៅវិញថា សូមទ្រង់មេត្តាប្រោសទូលបង្គំជាខ្ញុំជាមនុស្សកំសត់ ពុំប្រាថ្នារាជសម្បត្តិនឹងព្រះរាជបុត្រីល្អងធូលីព្រះបាទទេ បើទ្រង់ព្រះមេត្តាប្រោស សូមព្រះរាជទានតែកាំបិតបន្ទោះមួយ ស្តេចទ្រង់ជ្រាបគ្រប់ប្រការដូច្នោះហើយ ស្តេចមានបន្ទូលឲ្យជាងយកដែក ១០ ហាបទៅរាយដំធ្វើកាំបិតបន្ទោះមួយ ឯកាំបិតបន្ទោះនោះ យកក្ដារដាក់ត្រួត ៧ ជាន់ គ្រាន់តែអូសដាច់មិនដឹង ក៏ស្តេចឲ្យធ្វើស្រោមដាក់ ហើយស្តេចទ្រង់ប្រទានឲ្យចៅបុរសនោះ ឯចៅបុរសក៏ថ្វាយបង្គំលាស្តេចទៅ ៗ អស់នាហ្មឺនទឹងក្រស្ដក៏គេថា ចៅបុរសនេះជាមនុស្សឥតសំណាង ស្តេចឲ្យបុត្រីឲ្យរាជសម្បត្តិមិនយក ទៅយកឯកាំបិតបន្ទោះដងមួយ ហើយដោយសន្មតឲ្យហៅតែចៅកាំបិតបន្ទោះដងមួយ ៗ ឯចៅកាំបិតបន្ទោះដងមួយក៏ដើរទៅ ៗ ដល់ស្រុកនគរស្តេចមួយទៀត ក៏ទៅសុំសំណាក់នៅផ្ទះមហាសេដ្ឋី ឯសេដ្ឋីនោះមានកូន

ស្រីមួយគ្មានកូនប្រុស ក៏ឃើញចៅកាំបិតបន្ទោះដែកមួយ មកសុំសំណាក់
ផ្ទះ ក៏មានចិត្តស្រឡាញ់អាណិតឲ្យនៅសុំជាកូន ចៅកាំបិតបន្ទោះ
ដែកមួយ តាំងពីបានមហាសេដ្ឋីធ្វើឪពុកថ្ងៃណា ក៏តែងតែថែទាំដាស់
តឿនខ្ញុំកំដរឲ្យធ្វើការរកស៊ី មិនមានឲ្យមហាសេដ្ឋីព្រួយចិត្តឡើយ ឯ
មហាសេដ្ឋី ក៏មានចិត្តករុណាស្រឡាញ់ចៅកាំបិតបន្ទោះដែកមួយលើស
កូនបង្កើតពីពោះក៏ពុំស្មើ ៗ ក៏ជួនស្តេចនោះទ្រង់ចង់ពិសោធរករើស
នាហ្មឺនណា នឹងមានប្រាជ្ញាចេះរក្សាទឹកដីថ្វាយស្តេចបាន ក៏ស្តេចឲ្យ
រៀបទីព្រះថែនក្រាលពូកព្រែព្រំចៀមចំ ហើយរៀបសម្រាប់ដាក់គោជ-
នាហារចំណី បើមន្ត្រីណាត្រូវវេនឲ្យទៅស៊ីដេកចាំកំងជាដរាបរៀងទៅ
ក៏អស់នាហ្មឺនតែងតែទៅស៊ីចំណីនោះ ហើយដេកនៅទីព្រះថែននោះ
ស្តេចលបចេញមកមើលឃើញដេកពុំភ្ញាក់ ក៏ស្តេចឲ្យដាស់ឡើងចាប់យក
ទៅកាប់ទៅ តែត្រូវនាហ្មឺនណាដេកវេន នាហ្មឺននោះស្លាប់ ក៏ស្តេច
ពិសោធអស់នាហ្មឺនសម្លាប់ស្លាប់អស់ក្រែល ៗ ដល់វេនសេដ្ឋីក៏សេដ្ឋីឲ្យ
ប្រពន្ធរៀបរណ្តាប់ធ្វើបុណ្យខ្លួន ទឹកថា តែទៅដេកវេនហើយមិនដែល
អ្នកណារស់រួចមួយ ក៏អស់ប្រពន្ធកូនបងប្អូនញាតិសន្តានខ្ញុំកំដរ ក៏យំ
ទ្រហ៊ឹងអឹងកង ឯសេដ្ឋីក៏ដេកសន្ទឹកសន្ធៃអាហារចំណីក៏ពុំបរិភោគ ៗ
ចៅកាំបិតបន្ទោះដែកមួយឃើញគេយំកល់គ្នា ក៏ទៅសួរមហាសេដ្ឋីឪពុក ឯ
មហាសេដ្ឋីក៏ដេកអត់អាហារចំណី ចៅកាំបិតបន្ទោះដែកមួយឃើញឪពុក

ដេកសន្ទឹកសន្ធៃ ក៏សួរថា អ្នកអាពុកហេតុអ្វីក៏គេយំទ្រហឹងអឹងកង ហើយអ្នកអាពុកសម្រាន្តសន្ទឹកសន្ធៃ អាហារចំណីបរិភោគនេះតើមានការហេតុអ្វី បូរអ្នកអាពុកប្រាប់ឲ្យខ្ញុំបានដឹងផង ឯមហាសេដ្ឋីឮចៅកាំបិតបន្ទោះដងមួយសួរដូច្នោះ ក៏ប្រាប់កូនថា ឱកូនអើយ អាពុកបានអ្នកមកផ្ញើកូនថ្ងៃណា អាពុកគ្មានទាស់ចិត្តពីការអ្វី អាពុកនឹកថានឹងបាននៅរក្សាអ្នកនឹងទំនុកបំរុងអ្នកឲ្យរងស្នងអាពុក តឲ្យអាពុកបាននូវសេចក្តីស្លាប់វេលាល្ងាចនេះហើយ ដ្បិតស្តេចឲ្យទៅដេកចាំកាំង តែនាហ្មឺនណាទៅដេកក៏ស្លាប់ពុំលែង បើអត់ពីអាពុកទៅ កូននៅអ្នករក្សាម្តាយនឹងប្អូនស្រីផង ៗ ឯចៅកាំបិតបន្ទោះដងមួយឮអាពុកនិយាយប្រាប់ដូច្នោះ ក៏ជំរាបទៅអាពុកថា អ្នកអាពុក ក្រោកឡើងពីសាក្រយា ពីការត្រង់ដេកចាំកាំងអ្នកអាពុកកុំថប់ទុកការឲ្យខ្ញុំ សុំខ្ញុំទៅដេកឲ្យស្លាប់ជួសអ្នកអាពុក ឯមហាសេដ្ឋីថា ណ្ហើយកូន ខ្លួនអ្នកនៅក្មេង ខ្លួនអាពុកចាស់ហើយ ក៏ល្មមស្លាប់ដែរ ចៅកាំបិតបន្ទោះដងមួយជំរាបមកមហាសេដ្ឋីថា អាពុកថា អ្នកអាពុកឯងដេកចាំកាំងនេះ តែអ្នកណាទៅដេកហើយមិនដឹងកលក៏ស្លាប់ បើដឹងកលមិនស្លាប់ទេ ប៉ុន្តែនាហ្មឺនទាំងអស់ដែលស្លាប់នេះសុទ្ធតែគ្មានដឹងកល បានជាស្លាប់ ឯដឹងកលមានតែខ្ញុំទើបដឹងកលស្តេច មហាសេដ្ឋីឮចៅកាំបិតបន្ទោះនិយាយដូច្នោះ ក៏ក្រោកឡើងស៊ីបាយផឹកទឹក លុះដល់ល្ងាចចៅកាំបិតបន្ទោះដងមួយ ក៏កាន់កាំបិតបន្ទោះដងមួយ

ចុះដើរទៅដល់វាំង ក៏អស់ពួកព្រះក្រាលក៏ប្រគល់របស់ដែលរៀបបំរុង នោះឲ្យចៅកាំបិតបន្ទោះដងមួយ ចៅកាំបិតបន្ទោះដងមួយ មកនឹកគិតថា ឱស្តេចនេះទ្រង់ចង់រើសរកនាហ្មឺនណាទ្រង់មានគំនិតល្អបេះរក្សាទឹកដីបាន បានជាស្តេចនេះពិសោធយ៉ាងនេះហើយ ចៅកាំបិតបន្ទោះដងមួយពុំដេក ថយទៅអង្គុយចម្ងាយពីរព្យាមពីទីនោះ ៗ លុះអធ្រាត្រស្ងាត់ស្តេចចេញក្លែងភេទដើរមក ចៅកាំបិតបន្ទោះឃើញស្គាល់ជាស្តេចក្លែងភេទ ហើយសម្ងំពួនបំបាំងនៅសសរ ឯស្តេចយាងមកដល់បើកទតអស់ចំណីនៅដូចដែល ក៏ចៅកាំបិតបន្ទោះដងមួយស្រែកថា ពះកាប់អាចោរមកពីណាមកគិតលួចរបស់ស្តេច ៗ នោះភ្ញាក់រត់ទៅ ចៅកាំបិតបន្ទោះដេញបណ្តោយ ស្តេចនោះគេចទីងសសរចុងពេង ចៅកាំបិតបន្ទោះកាប់ផុត ៗ មិនឲ្យត្រូវ ឲ្យត្រូវតែសសរចុងព្រះរាជពេង ស្តេចគេចទៅសសរមួយ ចៅកាំបិតបន្ទោះកាប់បង្ខុស ស្តេចគេចគ្រប់តែសសរចុងព្រះរាជពេង ចៅកាំបិតបន្ទោះដងមួយក៏តាមកាប់បង្ខុសគ្រប់សសរ គ្មានខ្វះសសរមួយ ឯចៅកាំបិតបន្ទោះកាប់ទៅត្រូវសសរ ក៏មិនដឹងជាជាប់ ៗ លុះស្តេចស្រែកថា អញទេ ចៅកាំបិតបន្ទោះដងមួយឮស្តេចថាដូច្នោះក៏លែង ស្តេចក៏ចូលទៅក្នុងដំណាក់ ចៅប្រុសកាំបិតបន្ទោះ ក៏វិលមកកន្លែងដដែល ៗ លុះព្រឹកចៅកាំបិតបន្ទោះក៏ទៅផ្ទះវិញ ក៏មានខ្យល់បក់មកឯក្រោយ ចៅកាំបិតបន្ទោះទៅផ្ទះ រាល់ចុងព្រះរាជពេងនោះអស់ ដែលចៅកាំបិត

បន្ទោះដងមួយកាប់ ក៏ស្ដេចឲ្យសួរថា វេននរណាដេកចាំកំណប់មិញ
អមាត្យទូលថា ត្រូវវេនមហាសេដ្ឋី ហើយស្ដេចឲ្យទៅហៅមហាសេដ្ឋី
អមាត្យក៏តែទៅហៅមហាសេដ្ឋី ៗ អមាត្យទៅដល់ហៅថា លោក
មហាសេដ្ឋី ស្ដេចមានព្រះរាជបន្ទូលឲ្យហៅទៅជាឆាប់ ឯមហាសេដ្ឋីទៅ
ជាមួយនឹងអមាត្យនោះ ទៅកាំបិតបន្ទោះដងមួយដេកលក់ពុំដឹងជាអាពុក
ស្ដេចមកហៅ មហាសេដ្ឋីទៅជាមួយនឹងអមាត្យ ដល់ពាក់កណ្ដាលផ្លូវ
អមាត្យសួរមហា សេដ្ឋីថា លោកៗ អ្នកណាដេកចាំកំណប់មិញ មហា
សេដ្ឋីថា កូនខ្ញុំអ្នកអមាត្យ ហើយអមាត្យថា ឥឡូវសត្រូវកាប់ចុងព្រះ
កជពេង៍រលំអស់ បានជាស្ដេចឲ្យមកហៅលោកទៅ ឯមហាសេដ្ឋីឮ
អមាត្យប្រាប់ដូច្នោះហើយ មានសេចក្ដីនោះកិតភ័យនឹកថា ឱកូនអើយ
សូមខ្លួនមកដេកចាំកំណប់ជួសអាពុក នឹកថា ឲ្យបានសេចក្ដីសុខ ឥឡូវ
សត្រូវចូលកាប់ចុងព្រះកជពេង៍អស់ ក៏មហាសេដ្ឋីតែងអារម្មណ៍ខ្លួនគិត
ភ័យក្រែងស្លាប់ ៗ លុះដើរទៅដល់ទីចុងព្រះកជពេង៍ ឃើញចុងព្រះ
កជពេង៍រលំអស់ រឹងរឹតគិតភ័យជាថ្មីទៀត ក៏អមាត្យនាំមហាសេដ្ឋីទៅដល់
ស្ដេចៗទ្រង់សួរថា មហាសេដ្ឋី ត្រូវវេននរណាយប់មិញ មហាសេដ្ឋី
ក្រាបទូលថា ត្រូវវេនទូលបង្គំជាខ្ញុំ ស្ដេចមានបន្ទូលថា នរណាដេកចាំ
កំណ សេដ្ឋីទូលថា កូនទូលបង្គំជាខ្ញុំដេកចាំកំណ ហើយមានបន្ទូលថា
មហាសេដ្ឋី ខ្លួនឯងមានកូនប្រុសពីកាលណា ឯងមានតែកូនស្រីទេតើ

មហាសេដ្ឋីក្រាបទូលថា សូមទ្រង់មេត្តាប្រោស ឯកូនទូលបង្គំជាខ្ញុំនេះ កំព្រា មិនដឹងជាមកពីណា ទូលបង្គំជាខ្ញុំឃើញកំព្រា សុំជាកូន ដ្បិតគ្មានកូនប្រុស ៗ ស្តេចមានបន្ទូលថា បើដូច្នោះឲ្យទៅហៅវាមក អមាត្យក៏រត់ទៅហៅចៅកាំបិតបន្ទោះដងមួយ ឯមហាសេដ្ឋីរឹងរឹតតែភ័យទើបថា ឱកូនអើយ សមស្លាប់ជាមួយនឹងអាពុកថ្ងៃនេះប្រាកដពុំលែង អមាត្យដើរទៅហៅចៅកាំបិតបន្ទោះ លុះទៅដល់ប្រាប់ប្រពន្ធមហាសេដ្ឋីថា អ្នកស្រី ស្តេចឲ្យមកហៅកូនប្រុសអ្នក នាងជាប្រពន្ធមហាសេដ្ឋីថា ឱអ្នកអមាត្យអើយ ឥឡូវទទួលដំណេកទៅហើយ យប់មិញទៅដេកចាំរាំងអត់ងងុយពាល់ព្រឹក អមាត្យថា នែអ្នក បើទុកជាអត់ងងុយក៏ដាស់ឡើង ដ្បិតស្តេចឲ្យហៅជាប្រញាប់ ឯប្រពន្ធមហាសេដ្ឋី ប្រណីអាណិតកូនមិនហ៊ានដាស់ បញ្ជូនកូនស្រីឲ្យទៅដាស់ថា នាងឯងទៅដាស់បងឡើង ឯនាងកូនស្រីប្រកែកថា ទេម៉ែ ខ្ញុំមិនហ៊ានទៅដាស់ទេ ទើបនឹងសម្រានចៅកាំបិតបន្ទោះឮគេមាត់ក៏ភ្ញាក់ឡើងចេញទៅក្រៅ ម្តាយឃើញកូនភ្ញាក់ប្រាប់កូនថា កូន ស្តេចឲ្យមកហៅកូនទៅ ឥឡូវរាជបំរើគេអង្គុយតែចាំ ចៅកាំបិតបន្ទោះក៏លុបមុខសិតសក់ឆ្លុះកញ្ចក់ស្លៀកសំពត់រួចចុះទៅជាមួយនឹងអមាត្យ ទៅដល់ស្តេចមានបន្ទូលសួរថា ហ្នឹងហើយឬកូនឯងមហា-សេដ្ឋី ឯមហាសេដ្ឋីទូលថា សូមទ្រង់ព្រះមេត្តាប្រោសហ្នឹងហើយកូន

ទូលបង្គំជាខ្ញុំ ហើយស្តេចសួរថា ឯងប្អូនណាដេកបាំកាំងយប់មិញ
ទៅកាំបិតបន្ទោះដងមួយក្រាបទូលថា ទូលបង្គំជាខ្ញុំទទួលដំណេកយប់
មិញ ស្តេចទ្រង់ព្រះសណ្តាប់ហើយ ស្តេចបន្ទូលទៅនឹងមហាសេដ្ឋីថា
មហាសេដ្ឋី ពីទីចុងពេងអញនេះ ដែលដាច់ខួបលើអស់នេះ អញពុំមាន
ចិត្តខឹងទេ ធ្វើឡើងជាថ្មីទៀតបាន តែរើសរកមនុស្សឲ្យជួបកូនឯងនេះ
មិនបានទេ នេះហើយទើបគេហៅជាមនុស្ស ៗ ហើយស្តេចថា ទៅ
ឯងឈ្មោះអ្វី ឯទៅកាំបិតបន្ទោះដងមួយក្រាបទូលថា ទូលបង្គំឈ្មោះ
ទៅកាំបិតបន្ទោះដងមួយ ស្តេចបន្ទូលថា ទៅកាំបិតបន្ទោះ យប់មិញ
ដែលឯងដេញកាប់អញនោះតើកាប់នឹងអ្វី ទៅកាំបិតបន្ទោះដងមួយក្រាប
ទូលស្តេចថា ទូលបង្គំកាប់នឹងកាំបិតបន្ទោះ មហាក្សត្រៈទៅកាំបិត
បន្ទោះដងមួយក្រាបទូលដូច្នោះ ស្តេចបន្ទូលថា ទៅកាំបិតបន្ទោះដងមួយ
ឯងយកកាំបិតបន្ទោះឯងមកមើល បើថាឯងកាប់នឹងកាំបិតបន្ទោះនោះមែន
ទៅកាំបិតបន្ទោះដងមួយក្រាបទូលស្តេចថា សូមទ្រង់មេត្តាប្រោស បើ
ទ្រង់ចង់ជ្រាបជាកាំបិតបន្ទោះនេះមុតមិនមុត ទ្រង់ឲ្យយកក្តារមកដាក់
តំរួតឲ្យបាន ៧ ជាន់ ទូលបង្គំគ្រាន់តែអូសថ្វាយទត ស្តេចពុំជឿបង្គាប់
អាមាត្យឲ្យយកក្តារមកត្រួតតំរួតគ្នា ៧ ជាន់ ហើយស្តេចឲ្យទៅកាំបិតបន្ទោះ
ដងមួយ យកកាំបិតបន្ទោះទៅអូសស្តេចទ្រង់ទត ឯទៅកាំបិតបន្ទោះដង
មួយក៏យកកាំបិតបន្ទោះទៅអូសទទឹងរួច ស្តេចសួរថា ដាច់ហើយឬនៅ

ចៅកាំបិតបន្ទោះដងមួយក្រាបទូលថា ដាច់ហើយ ស្តេចបន្ទូលថា បើដាច់ហើយម្តេចក៏គ្មានស្នាម ចៅកាំបិតបន្ទោះដងមួយក្រាបទូលទៅទៀតថា សូមទ្រង់មេត្តាប្រោស បើទ្រង់ពុំជឿ ឲ្យមនុស្សទាញចុងដើមមើលទើបដឹងជាដាច់ឬមិនដាច់ ស្តេចឮចៅកាំបិតបន្ទោះដងមួយក្រាបទូលដូច្នោះ ស្តេចឲ្យអាមាត្យចាប់ចុងដើមទាញដាច់ចេញពីគ្នាដូចគេកាត់ ស្តេចទតទៅឃើញក្តារដាច់ពីគ្នាដូច្នោះ ស្តេចមានសេចក្តីភិតភ័យជាក្រោយ នឹកក្នុងព្រះទ័យថា យប់មិញ បើសិនជាអាដែងកាំបិតបន្ទោះដងមួយនេះ វាកាប់ត្រូវអញ សមអញស្លាប់បង់អសារឥតការគ្មានទោសណាសមសោះ ទាំងនេះទាំងនោះហេតុតែបុណ្យអញមានបានជាមិនស្លាប់ ៗ មហាក្សត្រស្តេចទតយល់ដូច្នោះហើយ ស្តេចបន្ទូលប្រាប់ទៅមហាសេដ្ឋីថា ឯកូនឯងនេះទើបហៅជាមនុស្សចេះរក្សាទឹកដីមែន ធ្វើមន្ត្រីរក្សាស្តេចបាន មន្ត្រីអញទាំងអស់ដែលសម្លាប់ទៅទាំងនោះគ្មានការណាមួយនឹងចេះដឹងឲ្យឃើញខុសត្រូវរក្សាទឹកដី រក្សាស្តេចបានទេ អប្បាលភ័កខ្ទងអញពាហានដេក ចំណីអញពាហានស៊ី នេះប៉ុន្តែចំណាំទីដំណេកអញពាហានធ្វើយ៉ាងនេះ បើសិនជាអញមិនទៅមើលទៅចិត្តការដែលទាហ៊នដែលអញសម្លាប់នេះ ពាន់នឹងហានឡើងដេកនឹងប្រពន្ធកូនអញមិនលែងឡើយ ៗ ហើយស្តេចបង្គាប់មហាសេដ្ឋីថា មហាសេដ្ឋី ឯកូនស្រីឯង ១ រៀបផ្សំផ្គុំឲ្យចៅកាំបិតបន្ទោះដងមួយយកធ្វើប្រពន្ធទៅ ឯមហាសេដ្ឋី

នឹងចៅកាំបិតបន្ទោះដងមួយ ក៏ថ្វាយបង្គំលាស្ដេចវិលមកផ្ទះវិញ ក៏មហាសេដ្ឋី ឲ្យរៀបធ្វើពេងខាន់ស្លា រៀបការចៅកាំបិតបន្ទោះដងមួយនឹងកូនស្រី ផ្សំផ្គុំឲ្យយកគ្នាជាប្ដីប្រពន្ធ ក៏មហាសេដ្ឋីឲ្យហៅអស់អ្នកមុខអ្នកការ ឧកញ៉ា ពញា ព្រះ ជំទាវ នាង ខុនណាង ញាតិសាច់ជិតខាង ដល់បានឫក្សពារពេលាល្អក៏រៀបមង្គលការ ចងដៃឲ្យជ័យសួស្ដីផ្សំចៅកាំបិតបន្ទោះដងមួយនឹងកូនស្រី យកគ្នាជាប្ដីប្រពន្ធស្រេចបរិបូណ៌ជាសុខសប្បាយទៅ ឯចៅកាំបិតបន្ទោះមានប្រពន្ធកាលណា ក៏ពុំមានខ្ជិល តែងទៅគាល់បម្រើស្ដេចតែសព្វថ្ងៃរៀងទៅ ឯស្ដេចនោះក៏កាន់តែចាស់ជរា ក៏ទឹកក្នុងព្រះចិន្ដាថា អញចាស់ជរាហើយ នឹងរកបុត្រាគ្មានមានតែបុត្រី ឥឡូវអំណើះអត់អំពីអញទៅនគរអញនឹងសូន្យ គ្មានកូនណានឹងសោយរាជ្យស្នងអញនេះបាន ឥឡូវចៅកាំបិតបន្ទោះនេះ វាមានបំណេះប្រាជ្ញាឥរិយាមានមារយាទល្អម្ល៉េះ ដូច្នេះអញនឹងផ្សំផ្គុំបុត្រីអញឲ្យទៅវា ឲ្យវាសោយរាជ្យស្នងកេរ្តិ៍ក្រោយអស់កាលណាប្រដាទុកស្ត្រនេះបាន ស្ដេចទ្រង់ទឹកក្នុងព្រះចិន្ដាតែម្ល៉ោះ ស្ដេចទ្រង់បង្គាប់ឲ្យសង់ពេនមង្គលអាពាហ៍ពិពាហ៍ ក៏ស្ដេចឲ្យហោរគន់គូរកេឫក្សពារ ស្ដេចនឹងផ្សំបុត្រីនឹងចៅកាំបិតបន្ទោះដងមួយ ដល់បានឫក្សពេលាល្អ ស្ដេចឲ្យមហាសេដ្ឋីនាំចៅកាំបិតបន្ទោះដងមួយទៅស្ដេចឲ្យរៀបមង្គលអាពាហ៍ពិពាហ៍ ចងដៃបុត្រីបុត្រាផ្សំគ្នាអភិសេកឲ្យសោយរាជសម្បត្តិជាស្ដេច ស្រេចបរិបូណ៌

វេក្សាអស់អាណាប្រជានុរាស្ត្រ អស់កាលជាសុខសប្បាយតទៅទៀត ។
ឯនាងជាកូនស្រីមហាសេដ្ឋី ក៏មហាក្សត្រស្ដេចឲ្យយកមកនៅជាមួយគ្នា
ឯមហាសេដ្ឋី ស្ដេចកាំបិតបន្ទោះឲ្យធ្វើជាអគ្គមហាសេនាធំ សំរាប់រក្សារ
វេក្សាព្រះនគរស្នងព្រះនេត្រ ឯមហាក្សត្រជាបិតាមាតាក៏ចាស់ជរាទិវង្គត
ទៅ ។ ក៏ស្ដេចកាំបិតបន្ទោះឲ្យធ្វើសាលាសន់មេរុប្រាសាទ ស្អិតស្អាង
ស្អាតរៀបបូជាព្រះសពព្រះបិតាព្រះមាតា មានទេសនាសង្គាយនាស្រេច
បរិបូណ៌ ធ្វើព្រះចេតិយដាក់ព្រះធាតុទាំងពីរ រួចការបុណ្យជាស្រេច
ស្ដេចកាំបិតបន្ទោះក៏គង់ជាសុខឥតទុក្ខគ្មានព្យាធិរោគាបៀតព្រះអង្គ
ឡើយ ។ ហើយស្ដេចនឹងចង់ទៅថ្វាយបង្គំស្ដេចដែលធ្វើកាំបិតបន្ទោះ
ប្រទានឲ្យ កាលនៅជាបុរសនៅឡើយ ហើយស្ដេចឲ្យមន្ត្រីរៀប
កេណ្ឌពលថ្មើរជើង រៀបទីនាំងគជេន្ទ្ររឿនគជសា ទីនាំងអស្សពាហន៍
មហិន្ទ្រាសុទ្ធ រៀបរួបមន្ត្រីចូលទូល ស្ដេចផ្ដាំអគ្គមហាសេនា ឲ្យមើល
ថែទាំព្រះរាជវាំង ហើយឲ្យមើលអគ្គមហេសីទាំងពីរ ។ ហើយស្ដេច
យាងឡើងទៅទីនាំងគជេន្ទ្រ បរបេញទៅ ៣ ខែស្ដេចដល់ ស្ដេចឲ្យ
អមាត្យចូលទៅទូលថា ឥឡូវស្ដេចកាំបិតបន្ទោះដងមួយ ចូលមកថ្វាយ
បង្គំគាល់ កាលពីដើមបានថ្វាយខ្សែបងជម្រះកាយឆ្នាំងផ្អិនឯងនឹងកែវ
ជ្រូកដើរលើទឹក ហើយស្ដេចធ្វើកាំបិតបន្ទោះដងមួយព្រះរាជទាន ឥឡូវ
បានសោយរាជ្យជាស្ដេចចូលមកថ្វាយបង្គំ អាមាត្យទទួលព្រះបណ្ដាំរួច

ថ្វាយបង្គំលាទៅ ដល់ចូលទៅទូលស្តេចនោះតាមព្រះមហាក្សត្រផ្តាំ ក៏ស្តេចនោះទ្រង់ជ្រាបឲ្យរៀបទទួល អមាត្យវិលទៅទូលស្តេចកាំបិតបន្ទោះវិញថា ស្តេចជាចៅនគរ ត្រេញ ស្តេចយានចូលទៅជាឆាប់ ផ្សិតទ្រង់នឹកព្រួកណាស់ ៗ ឯស្តេចកាំបិតបន្ទោះ ក៏ឲ្យរស់ពួកពលសកលយោធារៀបយានចូលទៅ ស្តេចម្ចាស់នគរឃើញស្តេចកាំបិតបន្ទោះទតទៅប្លែក ស្ទើរពុំស្គាល់ ក៏ស្តេចចុះពីបុងព្រះពជកេងមកទទួលចាប់ព្រះហស្តនាំឡើងទៅ ហើយស្តេចរៀបដប់លៀងរស់ពួកពលនាហ្មឺនមុខមន្ត្រីឲ្យស៊ីផឹកសប្បាយ ហើយក៏ស្តេចម្ចាស់នគរគិតក្នុងព្រះទ័យថា ដូចជាអញចាស់ហើយគ្មានបុត្រានឹងសោយរាជ្យស្នង ឯចៅកាំបិតបន្ទោះនេះមានបុណ្យណាស់ ឥឡូវបានសោយរាជ្យជាស្តេច អញមានបុត្រីមួយនេះមិនដឹងនឹងឲ្យទៅអ្នកណា ស្តេចទ្រង់គិតដូច្នោះស្តេចឲ្យរៀបមង្គលអាពាហ៍ពិពាហ៍រៀបផ្សំបុត្រីនឹងស្តេចកាំបិតបន្ទោះ អភិសេកឲ្យសោយរាជ្យជាស្តេច ក៏ស្តេចបង្គាប់សព្វនាហ្មឺនឲ្យធ្វើពេនរណ្តាប់អាពាហ៍ពិពាហ៍ បានពេលាស្តេចឲ្យប្រោហិត រៀបដូចព្រះបុត្រាបុត្រីផ្សំគ្នាឲ្យសោយរាជសម្បត្តិស្រេចបរិបូណ៌ ឯខ្សែចង ផ្សេងរាយ ឆ្នាំងដ្ឋិនឯង កែវជ្រូកស្តេចជាបិតាលើកប្រយកូនទាំងអស់ ឯស្តេចកាំបិតបន្ទោះ បានសោយរាជ្យនគរពីរ ទ្រង់នឹកវល់បរិភោគឯស្រុកចិន ក៏ប្រើ

បំរើឲ្យទៅយកមក ឲ្យធ្វើជាអគ្គមហាសេនាបតីស្ដីរាជការជាធំបង្អស់ ឯស្ដេចកាំបិតបន្ទោះ ក៏ថ្វាយបង្គំលាបិតាមាតា ហើយផ្ដាំបងឲ្យមើលរាជការរក្សាវាំង ក៏ស្ដេចកាំបិតបន្ទោះយាងវិលទៅនគរដើមវិញ តែងយាងទៅយាងមក រក្សាអស់អាណាប្រជារាស្ត្រពាសការជាសុខសប្បាយរៀងតទៅ ។

រឿងចៅកាំបិតបន្ទោះចប់បរិបូណ៌ ។

# សៀងអារក្សក្នុងវេលាមានជម្ងឺ

## ជំនឿអារក្ស

### ក្នុងវេលាមានជម្ងឺឈឺ

ជនជាតិខ្មែរនេះ មានទំនៀមកាន់អានបូជាទេវតាខ្មោចអារក្ស អ្នកតា បង់បត់ ជាដើម មកជាអង្វែងហើយ ការកាន់អានបែបនេះមានប្រឡាយមកតែអំពីទំនៀមទម្លាប់ក្នុងព្រហ្មញ្ញសាសនា ដែលជាសាសនាចាស់ជាងគេ ១ យ៉ាង សរឹងបញ្ញត្តិឲ្យគោរពកាន់អានទេវតា អារក្ស អ្នកតា បង់បត់ ទឹងកួត បិសាចផ្សេងៗជាច្រើនស្ទើរតែរាប់ពុំអស់ យកជាសរណទីពឹងៗ ក៏ការដែលកាន់អានបូជាផ្ទោះ ជាឲ្យគុណឬឲ្យទោសដល់អ្នកកាន់អានយ៉ាងណា នៅក្នុងផ្ទះរបស់អ្នកដែលស្ងួនគេសរណទីពឹងបែបនោះ នឹងគប្បីពិចារណាដោយខ្លួនឯងៗ

ពាក្យថាខ្មោចក្នុងទីនេះជាសាធារណនាម ត្រូវនឹងពាក្យក្នុងភាសាមគធៈថា "អមនុស្ស" ប្រែថា មិនមែនមនុស្ស បើនឹងបំណែកជាពួកចេញទៅមានច្រើនពួកជាអ្នកឫទ្ធិ មានអំណាចផ្សេងគ្នា ហៅឈ្មោះតាមដែលប្រើហៅក្នុងភាសាខ្មែរ គឺ ទេព្រក្ស អារក្ស មេបា អ្នកតា បង់បត់ ព្រាយ អាប ធ្មប់ កួត បិសាច ប្រេតគម្ពាល ៗលៗ ពួកគន្ធព្វ យក្ខ អសុរ ក្នុងបាលីលោករាប់រួមក្នុងពួកអមនុស្សគឺខ្មោចនេះដែរៗ

ខ្មោចអំបាលនោះ កាលយើងទទួលគោរពកាន់អាន យកជាគ្រូបាធ្យាយហើយ ត្រូវប្រព្រឹត្តឧទ្ទិសភានទៅតាមទម្រង់ទំនៀមទម្លាប់ចាស់

ត្រណមរបស់ខ្មោចនោះជាដរាប តែកាលណាប្រព្រឹត្តមិនដិតដល់ ខ្មោចនោះក៏ខឹងខឹង មកធ្វើឲ្យឈឺដោយខ្លួនឯង ឬប្រើខ្មោចដទៃឲ្យមកធ្វើ ក្នុងកាលនោះ ។ តែខ្មោចអារក្សខ្មោចមេបាចាស់ទុំនឹងជង់បត់ជាខ្មោចដែលមានបញ្ញាប់ទម្លាប់គ្រាន់បើ កាលបើនឹងធ្វើឲ្យឈឺ ក៏ធ្វើតែអ្នកដែលជាកូនសិស្សរបស់ខ្លួន សិងប្រព្រឹត្តកន្លងទំនៀមទម្លាប់ខ្លួន ។ ខ្មោចក្រៅពីនេះមានអ្នកតាជាដើម ជាខ្មោចសាហាវ ដើរធ្វើគេមិនរើសមុខ គឺតែឃើញចិត្តនឹងអ្នកណា ទោះបីជាកូនសិស្សក្តី មិនមែនជាកូនសិស្សក្តី ក៏អាចធ្វើអ្នកនោះឲ្យឈឺ ឲ្យស្លាប់ទៅបាន ។

ត្រណមខ្មោចនោះមានផ្សេង ៗ គ្នា គឺខ្មោចខ្លះហាមមិនឲ្យស៊ីផ្លែត្រឡាចនឹងមិនឲ្យមុចក្រោមទ្រើងត្រឡាច ខ្មោចខ្លះហាមមិនឲ្យស៊ីសាច់សត្វនេះ សត្វនោះមានអណ្តើកជាដើម ខ្មោចខ្លះហាមមិនឲ្យយកសំពត់សៀកមកទទូរក្បាល ហេតុដល់ទៅមិនឲ្យមុចក្រោមឈើ ឬខ្សែដែលហាលសំពត់សៀក នឹងមិនឲ្យមុចក្រោមផ្ទះ បើមានការដែលត្រូវមុចឲ្យយកសំពត់ក្រៅពីសំពត់សៀកទទូរក្បាលហើយមុចទៅបាន ។ រឿងត្រណមខ្មោចនេះមានច្រើនបែបច្រើនយ៉ាងផ្សេង ៗ ពីគ្នា មិនអាចនឹងរៀបរាប់ឲ្យសព្វគ្រប់បានទេ រៀបរាប់មកគ្រាន់ជាតួយ៉ាងប៉ុណ្ណោះ ។

ទំនៀមខ្មែរជាច្រើន កាលមានអ្នកណាបួយឈឺនៅលើផ្ទះហើយ បើដឹងសមុដ្ឋានរបស់រោគថា ឈឺមកពីហេតុនេះ ៗ ហើយគេក៏ចាត់ការ

ព្យាបាលទៅតាមហេតុឬតាមអាការកើតនោះទៅ ។ បើគេមិនបានសមុដ្ឋាន នៃកើតច្បាស់ទេ បានព្យាបាលព្រាវទៅ ដូច្នេះហើយ ដូច្នោះហើយ មិនដល់មិនគប គេរមែងពឹងរកគ្រូហ្មឬហោរឲ្យគន់គូរមើលឲ្យ ថាត្រូវខ្មោចអ្វីធ្វើឬក៏ឈឺដោយមានគ្រោះថ្នាក់ដូចម្ដេច ?

គ្រូហ្មឬហោរនោះ ក៏ទទួលគន់គូរមើលតាមក្បួនដែលធ្លាប់រៀនសូត្រមក ជួនកាលគេប្រើគំភ្លើងបញ្ចូលខ្មោចសួរក៏មាន ។ ក៏ឯវិធីគន់គូរមើលរបស់គ្រូហ្មឬហោរនោះមានច្រើនយ៉ាង អ្នកខ្លះសួរពីថ្ងៃ ខែ ឆ្នាំ និងចំនួនអាយុអ្នកជម្ងឺ ហើយរាប់លេខគន់គូរមើលក៏មាន អ្នកខ្លះសួរដូចគ្នា នេះហើយបើកក្បួនទំនាយក៏មាន អ្នកខ្លះសួរហើយកាប់ម្រាមដៃមើល រួចទើបទំនាយប្រាប់ថា ត្រូវនេះត្រូវនោះធ្វើតាមបែបបទដែលក្បួនបើកឱកាសឲ្យទំនាយ ។ ពួកអ្នកមើលនោះមិនដែលទាល់ម្ដងសោះ តែគេសួរហើយចេះតែមានរឿងប្រាប់គេជាដរាប គឺជួនកាលថា ត្រូវអារក្សធ្វើ ជួនកាលថា ត្រូវអ្នកតាធ្វើ ជួនកាលថា ខុសមេបាចាស់ទុំ ជួនកាលថា ខ្មោចព្រៃធ្វើ ជួនកាលថា ខុសបំណន់ ។ល។ ស្រេចហើយតែបែបបទរបស់ក្បួននោះត្រូវឲ្យទាយដូចម្ដេច ក៏ទាយដូច្នោះទៅ ជួនកាលក៏ត្រូវ ជួនកាលក៏ខុស និងយកជាកំណត់ទៀងទាត់ណាស់ពុំបាន ។

ពីនេះនឹងពណ៌នាចំពោះតែរឿងរក្សាជម្ងឺដែលត្រូវខ្មោចអារក្សធ្វើ ។ ពាក្យថា អារក្ខ ឬអារក្ស ប្រែថា រក្សារៀងមក កាលយកបកប្រែជា

ឈ្មោះប្រេតៈនេះ ត្រូវប្រែថា "ខ្មោចដែលគេរក្សារៀងមក" ហេតុដែល បានឈ្មោះដូច្នេះ មកពីមានទំនៀមទម្លាប់កប់សានខ្មោចនោះរៀងរបមក តាំងពីដូនជីតាពីព្រេងនាយមកហើយ ខ្មោចនោះក៏តែងតែតាមថែរក្សា រៀងមកដែរ ៗ តែជួនកាលគេហៅថា ខ្មោចចំបូរ គឺជាខ្មោចដែលដូរ បុគ្គលខាងមាតានិងខាងបិតាធ្លាប់កប់សានរៀងមក ៗ តែបើបំណែកខាង ស្ដេចវិញហៅថា ព្រះបំណាំ ៗ ខ្មោចអារក្សនេះសម្រាប់ជនជាតិខ្មែរមែន មានគ្រប់ត្រកូល តែបើនិយាយសម្រាប់បុគ្គលមួយ ៗ អ្នកខ្លះគេបោះ ចោលមិនកប់សានក៏មានដែរ បំណែកឯវង្សត្រកូលរបស់អ្នកនោះក៏គង់នៅ មានកប់សានជាធម្មតា ៗ

ហេតុដែលកប់សានខ្មោចអារក្សមានរឿងព្រេងនិទានថា ដំបូង អ្នកដែលមិនខ្លាចបាប បានធ្វើអកុសលកម្មផ្សេង ៗ មានសំឡាប់គេ លួចគេជាដើម វេលាស្លាប់ហើយបែងធ្លាក់ទៅសោយទុក្ខក្នុងនរកជា អង្វែងពាន់ឆ្នាំ លុះលោះពីនរកនោះមក មកកើតជាប្រេតអសុរកាយ ខ្មោច ក្មួត បិសាចផ្សេង ៗ ជាច្រើនពួកពាសពេញទាំងផែនដី តែង សោយទុក្ខវេទនាអត់អាហារស្រេកឃ្លានជានិច្ច ៗ

នៅស្រុកខ្មែរយើងនេះ មានកាលសម័យ ១ នោះ មានពួកក្មេង ឃ្វាលក្របីជាច្រើននាក់ តែងតែវេចបាយទៅស៊ីឃ្វាលក្របីតែរាល់ ៗ ថ្ងៃ វេលាស៊ីក៏ជួបជុំជប់លៀងគ្នា ស៊ីផឹកច្រៀងកំប្លែងសប្បាយតាមភាសា

កូនក្មេងពាល គ្រានោះមានពួកចោរមកក្រវែលមើលក្មេងអំបាលនោះ ក្រែងមានចាក់បាយចំណីដែលសេសសល់ពោល នឹងបានរើសស៊ី កាលទៅឃើញក្មេងលេងសប្បាយដូច្នោះ ចោរ ១ ក៏លបចូលទៅក្នុងរូបក្មេងម្នាក់ ក្មេងនោះក៏ក្រោកឡើងកំរើសរោសកំសដៃកំសជើង ដោយឥតអៀនខ្មាស មានអាការហាក់ដូចជាមនុស្សស្រវឹងស្រា ទាំងនិយាយចេញមកថា យើងសប្បាយណាស់ សុំឲ្យដប់លៀងយើងតែយ៉ាងហ្នឹងរាល់ៗថ្ងៃទៅ យើងនឹងឃ្វាលក្របី កុំឲ្យព្រួយពីរឿងបាត់ឡើយ ។ តាំងពីនោះមកក្មេងអំបាលនោះ ក៏នាំគ្នាដប់លៀងបែបនោះរៀងរាបមក ចោរទាំងអំបាលនោះ ក៏មកចូលក្មេងពួកនោះតែរាល់គ្នា ម្នាក់ម្ដងៗ ។ ចំណែកឯគោក្របី ចោរអំបាលនោះក៏រក្សាឲ្យមែន មិនមានបាត់ខ្ចាត់ទៅណា ៗ ដល់យូរទៅ ចោរទាំងនោះបែកប្រាជ្ញាដើរធ្វើអ្នកស្រុកឲ្យឈឺជាច្រើនគ្នា ដើម្បីយករបស់សំណែនបរិភោគ ហើយរាំមកចូលក្មេងឃ្វាលក្របី និយាយថា យើងចេះមើលជម្ងឺឲ្យជាក្នុងមួយរំពេច តែត្រូវរៀបដប់លៀងស្រាបាយយើង ព្រមទាំងមានក្មេងគ្រូគន្ត្រីលេងប្រគំឲ្យជាទីសប្បាយចិត្តយើង ជាងដែលដប់លៀងសព្វដងនេះ ទាំងឲ្យគេដាក់សំពត់អាវប្រាក់កាសថ្វាយជារង្វាន់ដល់រូបរបស់យើងផង នោះយើងទើបទទួលមើល ។ ពាក្យនេះមិនបាត់ស្ងាត់ បានឮជ្រួតជ្រាបទៅដល់អ្នកស្រុកច្រើនឡើងៗដោយលំដាប់ ។ ពួកអ្នកដែលមានជម្ងឺដំណឹង

ដូច្នោះ ក៏រលះរលាំងទៅអញ្ជើញពួកក្មេងអំបាលនោះ ក្មេងឯណាទីមួយមកបញ្ចាន់ជប់លៀងតាមបែបនោះ ដម្បីអំបាលនោះក៏ចេះតែជាទាំងអស់ ៗ មិនតែប៉ុណ្ណោះ ខ្មោចនោះក៏បានដើរធ្វើអ្នកធំ ៗ មានមន្ត្រី សេនាបតីទីង ស្ដេចជាទីបំផុត ។

ដល់ស្ដេចប្រឈួន ក៏ទ្រង់រក្សាព្រះកេតនោះតាមទំនៀម ដែលធ្លាប់តែព្យាបាលមក ក៏មិនបានជាសះជាដូចសព្វដង ស្ដេចទើបត្រាស់ឲ្យទៅយកក្មេងអំបាលនោះឯណាទីមួយមកជប់លៀងបញ្ចាក់តាមទំនៀមរបស់វា ព្រះកេតក៏ជាទៅមួយរំពេច ៗ គ្រានោះព្រះមហាក្សត្រត្រាស់ថា ប្រពន្ធអញឈ្មោះដំទាវមៅ ស្លាប់ទៅយូរណាស់ហើយ បើឯងអាចទៅយកមកបាន ហើយអញពិសោធមើល បើឃើញពិតមែន នោះអញទីងដឿងឯង ៗ ក្មេងនោះទូលថា សុំឲ្យរៀបជប់លៀងចុះ ទីងទៅយកមកថ្វាយបាន ៗ ស្ដេចក៏ឲ្យរៀបចំគ្រឿងជប់លៀងយ៉ាងត្រកាល មានទាំងភ្លេងប្រគំតាមទំនៀម ហើយទ្រង់ឲ្យយកសំពត់អាវទីងគ្រឿងប្រដាប់មាសពេជ្ររបស់ដំទាវមៅយកមកដាក់លាយឡំគ្នាទីងរបស់អ្នកដទៃ រួចទ្រង់ឲ្យជប់លៀង បញ្ចាន់តាមទំនៀម ខ្មោចក៏មកចូលកូនក្មេងនោះភ្លាម ចូលមកក៏តាំងតែយំគក់ទ្រូងគក់ស្មា សំដែងអាការៈសោកសោះអាល័យយ៉ាងខ្លាំង ស្ដេចធ្លាប់ក៏ត្រាស់សួរថា អ្នកដែលមកចូលនេះឈ្មោះអ្វី ខ្មោចនោះទូលថា ឈ្មោះដំទាវមៅ ៗ ស្ដេចត្រាស់ថា បើជាដំទាវមៅមែន

ស្គាល់របស់អំបាលនេះឬទេ? បើស្គាល់ឲ្យរើសរៀបដាក់ដោយចំណែកទៅមើល ៗ ខ្មោចនោះក៏រើសយកសុទ្ធតែរបស់ដំទាវម៉ៅមកដាក់ដោយឡែកផ្សេង ៗ ស្តេចទតឃើញដូច្នោះ ក៏ទ្រង់ជឿម្តងហើយ ទើបត្រាស់ឲ្យដំទាវម៉ៅទៅអញ្ជើញព្រះវរបិតារបស់ព្រះអង្គ ដែលសុគតទៅហើយមកពិសោធដូចគ្នានោះ ខ្មោចក៏ធ្វើឲ្យឃើញជាក់ស្តែង ព្រះអង្គក៏រឹតតែទ្រង់ជឿណាស់ឡើង ស្តេចក៏ត្រាស់សុំឲ្យព្រះវរបិតា នឹងដំទាវម៉ៅមកនៅថែរក្សាព្រះអង្គ ៗ ដោយហេតុនេះ ទើបមានចំបូរខ្មោចអារក្សហៅថា ដំទាវម៉ៅ ឬស្រីខ្មៅ នឹងព្រះវរ ជាប់តមកដល់សព្វថ្ងៃនេះ ៗ ចំណែកឯក្មេងឃ្វាលក្របីអំបាលនោះ ក៏ជាប់ជារូបអារក្សមើលគេរៀងរបមកដរាបលុះអស់ជីវិត កាលទៅមើលអ្នកណា ក៏យកអ្នកនោះជាកូនសិស្ស ៗ ហេតុនេះ ខ្មោចអារក្ស ឈ្មោះថា ដំទាវម៉ៅ នឹងព្រះវរ ទើបមានពាសពេញទាំងស្រុកខ្មែរ រូបណាជាន់ក៏មានឈ្មោះនេះជាធម្មតា ៗ តែមិនចំពោះមានតែពីរឈ្មោះទេ នៅមានឈ្មោះផ្សេង ៗ ទៀតច្រើនដូចយ៉ាងឈ្មោះកន្ទោងខៀវ ដំទាវគី ឬគីសាស្រែង សំពោងសក់ធំ ក្រពុំសក់ស្កាយ ជាដើម ៗ

## របៀបរណ្តាប់លៀងអារក្ស

កាលមានជម្ងឺឈឺនៅលើផ្ទះ ឲ្យគ្រូហ្មឬហោរមើលទៅថា ត្រូវខ្មោចអារក្សដែលជាចំបូរខាងម្តាយ ឬជាចំបូរខាងអាពុកធ្វើគ្តី ឬថាត្រូវ

ខ្មោចព្រៃផងទៃធ្វើ គេត្រូវរៀបលៀងអារក្ស ដើម្បីឲ្យអារក្សជួយអង្វរខ្មោចនោះឲ្យលើកលែងធ្វើក្តី អ្នកម្ចាស់ជម្ងឺត្រូវរៀបរណ្តាប់លៀងអារក្សតាមទំនៀម ក៏គេរៀបរណ្តាប់ថ្វាយខ្មោចអារក្សនេះដែរ ដូចគ្នាក៏មានផ្សេងគ្នាចេញទៅខ្លះ ដោយមានបញ្ចូលរបស់នេះរបស់នោះមកទៀតតាមសណ្តាប់របស់ខ្មោចនោះក៏មាន ៗ កន្លែងនេះ នឹងបានរៀបរៀងគ្រឿងថ្វាយ ១ យ៉ាង ទុកជាតួយ៉ាង គឺ:

បាយសី ១ គូ ស្លាធម៌ ១ គូ ជម ១ គូ ទឹកអប់ ១ គូ ៗ មានផ្កាស្រស់ផ្សេងៗ មានផ្កាចម្បាជាដើម ដោតប្រដាប់នៅបាយសី ៗ របស់អំបាលនេះឲ្យរៀបដាក់លើហ៊ឹង ឬលើគ្រែ មានទាំងគ្រឿងសំណែន គឺបំពេប ១ ចាស បង្អែម ១ ចាស នឹងមានមាន់ស្ងោរ ឬក៏ក្បាលជ្រូកស្ងោរ មានស្រា ១ ដប បាយ ១ ចាន នឹងមានពែ ១ សម្រាប់ចាប់គ្រឿងសំណែនដាក់សែនឲ្យខ្មោចព្រៃផ្សេងៗផង ៗ

កន្លែងការលៀងអារក្សនេះមានមនុស្សស្រីឬប្រុសម្នាក់ មកអង្គុយកណ្តាលចំណោមសម្រាប់ឲ្យអារក្សចូលជាន់ ដូចពោលហើយខាងដើមមនុស្ស បើប្រុស ហៅថា រូបអារក្ស បើស្រី ហៅថា រូបមេមត់ មានគ្រឿងប្រដាប់សម្រាប់រូបអារក្ស គឺគោក ១ បិទទៀនធំ ១ ខ្លះក៏បិទទៀនស្នែងក្របី ១ នឹងមានសំពត់ហូល ១ អាវព្រែ ១ កន្សែងព្រែក្រហម ១ ក្បាក់រង ១ នឹងដាវហ៊ុំ ១ ដាក់រងចំកល់ពីមុខរូបអារក្ស ៗ

មានភ្លេងខ្មែរ ១ វង់ គឺ ស្គរ ២ ទ្រ ១ ចាប៉ី ១ ប៉ីពក ១ ប៉ីអ ១ មានអ្នកភ្លេងគ្រប់ចំនួននេះ ទាំងមានអ្នកច្រៀងម្នាក់ ។

ដល់ថ្ងៃលៀងអារក្ស ប្រមូលរកទាំងឡើគេរៀបចំគ្រឿងប្រដាប់ អំបាលនេះបានសព្វគ្រប់ហើយ វេលាព្រលប់គេក៏រៀបលេងអារក្សនៅ លើផ្ទះ បើផ្ទះនោះធំទូលាយឬក៏នៅពេង. ដោយហោចទៅនៅទីវាល មុខផ្ទះក៏បាន ។ រូបអារក្សត្រូវរៀបតែងខ្លួនស្អាតបាតចូលទៅអង្គុយនៅ កណ្តាលទីដែលគេរៀបចំទុកសម្រាប់ ។ ពួកអ្នកភ្លេងក៏ផ្តើមលេងភ្លេង អ្នកច្រៀងក៏ច្រៀងអញ្ជើញខ្មោចអំបាលនោះមកចូលរូប ។ លេងភ្លេងមួយ ស្របក់ទៅទាំងមានខ្មោច ១ មកចូលរូប រូបនោះក៏ទាំងយកសំពត់ផាហ៊ុំ ខៀវមកទទូរ ពុំនោះសោតក៏យកក្រមាព្រែមកជូតក្បាល ជួនកាលយក សំពត់អាវព្រែមកស្លៀកពាក់ហើយទើបខ្មោចចូលជាន់ ជាន់ ១ ស្របក់ ទៅ អ្នកភ្លេងបង្អន់ភ្លេងវាយភ្លេងល្ហើយ ។ មានស្រីចាស់ម្នាក់ហៅតាម ភាសាខ្មោចថា ស្នំ ចូលទៅអង្គុយជិតខាងម្ខាង សំពះសួរថា អស់លោក ណាដែលអញ្ជើញមកនេះ ខ្មោចនោះក៏ប្រាប់ឈ្មោះខ្លួនថា យើងឈ្មោះ នេះមកចូល គឺបើជាព្រះវរក៏ប្រាប់ថា ព្រះវរ បើជាជំទាវមៅ ។ល។ តាមឈ្មោះរបស់ខ្លួន ៗ ស្នំទើបសួរតទៅទៀតថា ឥឡូវនេះផ្កាឈូកកូនចាប(១)

---

១ ខ្មោចអារក្សនេះមានភាសាហៅឈ្មោះរបស់ នឹងហៅមនុស្សចំពូកខ្លះផ្សេងពីមនុស្ស យើងដូចយ៉ាងកូនសិស្ស បើមនុស្សធំ ហៅថា ផ្កាឈូក បើក្មេងតូច ហៅថា កូនចាប ពេភក សង្ឃហៅថា តាបុណ្យ ផ្លែចេកហៅថា ក្រទន់បាក់ក ប្រាក់ហៅថា ក្រដាំង អ្នកសួរ យកការខ្មោចហៅថា ស្នំ ។ល។

ឈឺដូច្នេះ តើត្រូវអស់លោកណាធ្វើ ខ្មោចនោះ បើខ្លួនធ្វើក៏ឆ្លើយប្រាប់ថា យើងធ្វើ បើខ្លួនមិនធ្វើនឹងឆ្លើយថា យើងមិនបានធ្វើទេ ៗ បើថាខ្លួនធ្វើស្នំនឹងសួរគេទៅទៀតថា អ្នកនោះធ្វើទាស់ខុសពីរឿងអ្វី ទើបបានអស់លោកធ្វើ ៗ មានហេតុទាស់ខុសដូចម្ដេច ខ្មោចនោះក៏ឆ្លើយប្រាប់ទៅតាមរឿង ៗ លំដាប់នោះ ស្នំក៏និយាយអង្វរសុំឲ្យលើកលែងធ្វើទៅសុំឲ្យសះជាពីថ្ងៃនេះទៅ យើងខ្ញុំបានរៀបគ្រឿងក្រយាហារមកថ្វាយសេពសោយ បរិបូណ៌គ្រប់ហើយ សូមអញ្ជើញសេពសោយ បើមានត្រូវការអ្វីទៀតសូមឲ្យប្រាប់មកចុះនឹងបានរៀបថ្វាយ ៗ បើខ្មោចនោះថាខ្លួនមិនបានធ្វើ គឺខ្មោចឈ្មោះនេះឈ្មោះនោះជាអ្នកធ្វើ ស្នំក៏និយាយសុំឲ្យខ្មោចនោះទៅជួយនិយាយអង្វរខ្មោចអ្នកធ្វើនោះឲ្យលើកលែងធ្វើទៅគេរៀបគ្រឿងបូជាហើយ ៗ

ប៉ុណ្ណោះហើយក៏ចាប់លេងភ្លេងថ្មី ច្រៀងអញ្ជើញខ្មោចដទៃមកចូលទៀត ដូចមុន ដកបទចាប់តែអស់ខ្មោចអារក្សរបស់ខ្លួន ដែលធ្លាប់លៀងមកទាំងប៉ុន្មាន ៗ ក្នុងវេលាកំពុងបញ្ជាន់ខ្មោចនោះនឹងស្ដោះព្រួសឲ្យអ្នកជម្ងឺនឹងចងខ្សែក ខ្សែដៃ ខ្សែបង្កេះឲ្យអ្នកជម្ងឺនោះ ដើម្បីការពារមិនឲ្យខ្មោចដទៃក្រៅមកធ្វើ ៗ ប៉ុណ្ណោះសន្មតថា ចប់រឿងលៀងអារក្សហើយ ៗ

វេលាល្ងៀងអារក្សហើយ គេចាប់បាយចំណីដាក់តែឲ្យមនុស្សម្នាក់ យកទៅដាក់ក្រៅរបងផ្ទះ ជូនឲ្យខ្មោចព្រៃផ្សេងៗ សេពសោយ ។

កាលល្ងៀងដូច្នេះហើយ បើអារក្សនោះធ្វើមែន អាចនឹងជាបានដោយច្រើន វៀរតែធ្វើធ្ងន់ជ្រុលពេកទៅ នឹងដោះគំនួបរបស់ខ្លួនមិនរួច ស្លាប់ទៅក៏មានជាច្រើន ឬមានខ្មោចដទៃមានឫទ្ធិអំណាចខ្លាំងមកធ្វើខ្មោចអារក្សទប់ទល់អំណាចគេមិនបាន ដម្បីនោះស្លាប់ទៅក៏មានជាច្រើន ។

ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

# បញ្ជីរឿង


ទំព័រ

១ — អំពីជាឋកថា របស់លោកភិក្ខុ ប. វជិរញ្ញាណត្ថេរ . . . . . . . . ១៨១

២ — រឿងកាកី (ពាក្យកាព្យ) ព្រះភជនិពន្ធ (ត) . . . . . . . . ១៩៣

៣ — សុភាសិតភិជាកថា (ត) . . . . . . . . ២១៥

៤ — កងធម៌ផ្សេង ៗ . . . . . . . . . . . . . . . . . . . . . ២២៧

៥ — ព្រហ្មចរិយកថា (ត) . . . . . . . . . . . . . . . . ២៣៩

៦ សិលាចារឹកនគរវត្ត និងបទានុក្រម . . . . . . . . . . . . . . ២៥៥

៧ — រឿងព្រេង រឿងចៅតប់ប្រមល់ . . . . . . . . . . . . . . ២៧៣


## រូបក្រៅរឿង


១ — ប្រទេសលាវ-សៀម ស្រុកឡាំភូន វត្តកុកុដ រូបចេ.មទេវីចេតិយ៍ មើលពីចំហៀង
បណ្ដោយ . . . . . . . . . . . . . . . . . . . . . . . . . ១៩១

២ — ប្រទេសលាវ-សៀម ស្រុកជៀងម៉ៃ វត្តប្រសិង មើលចំហៀង . . . . . . . ២១៣

# TABLE DES MATIÈRES

Pages

1. Qu'est-ce que la Mort? Conférence faite à Paris par le Bhikkhu P. VAJIRAÑÑANATHÉRO ................ 181

2. La légende de Kaki (Poème) par S. M. Préas Bat Samdach Préas SREYTHAMMARÉACHÉA (suite).... 193

3. Subhâsitavâcakathâ par le Vénérable Moha CHHŒUN (suite).......................................... 215

4. Divers principes bouddhiques.......................... 227

5. Brahmacariyakathā par le Vénérable Moha SES (suite).. 239

6. Les inscriptions de Nagaravatta (suite)................ 255

7. Contes populaires Cambodgiens inédits :
   Un homme anxieux.............................. 273

HORS TEXTE :

I. Laos-Siamois. Lompun. Vat Kukut:
   Chamadévi, — chedi rectangulaire.................... 191

II. Laos-Siamois. Chieng-Mai :
   Vat Prasin, ensemble et détails..................... 213

អំពីធាបការជា

របស់ភិក្ខុ ប-វជិរញាណត្ថេរ

ឡាបូល ២៣ អូត ១៩៣៤ (La Baule 23 aout 1934)

# សេចក្តីស្លាប់គឺអ្វី?

យើងធ្លាប់គិតថា ជីវិតនឹងសេចក្តីស្លាប់ ទុកដូចជារបស់ពីរជាទំនើស នឹងគ្នានៅដោយឡែកពីគ្នា ។

ប៉ុន្តែពុទ្ធសាសនិកជន ដែលពិនិត្យឃើញច្បាស់នូវសេចក្តីមិនទៀងទាត់ នៃវត្ថុទាំងពួងដែលមានជុំវិញខ្លួនយើងនឹងវត្ថុទាំងពួងដែលផ្គុំប្រកបឡើងជាខ្លួនមនុស្ស មានចិត្ត មានសតិសម្បជញ្ញៈ នឹងកងកាយ ។ គេតែងពោលថា ជីវិតសត្វមិនឈប់នៅស្ងៀមទេ មានការប្រែប្រួលទៅមកជាដរាប ឥតនៅនឹងថ្កល់សោះឡើយ ស្រេចហើយតែកំរិតរបស់ហេតុនឹងផលប៉ុណ្ណោះ ។

ចិត្តកើតហើយរលត់ទៅ ហើយកើតចិត្តផ្សេងមួយទៀតគ្រប់ៗខណៈជវនចិត្ត ។ ឯជីវិតិន្ទ្រិយក៏មានអាការកើតឡើងនឹងរលត់ទៅជានិច្ចជាធម្មតា គឺជីវិតិន្ទ្រិយចាស់រលត់បាត់បង់ទៅ ជីវិតិន្ទ្រិយថ្មីក៏កើតឡើងជំនួស ក្នុងជីវិតិន្ទ្រិយនោះគ្មានដើមឬចុងទេ ទាំងការចាប់កំណើតជាដំបូងក៏មិនប្រាកដឡើយ ។

ហេតុនេះ ចិត្តយើងនឹងកងកាយយើងតែងស្លាប់ទៅបន្តិច ៗ រាល់ ៗ ថ្ងៃ ។

កាលណាមនោវិញ្ញាណធាតុទន់ខ្សោយថយកំឡាំងទៅ រាងកាយក៏ទ្រុឌទ្រោមហើយដល់នូវសេចក្ដីស្លាប់ ទើបទៅចាប់បដិសន្ធិក្នុងភពថ្មីទៀត ។

យើងនឹងឃើញថា ការចាប់កំណើតជាថ្មីមិនខុសប្លែកអ្វីអំពីកិច្ចការសព្វសារពើដែលយើងមើលឃើញនៅសព្វថ្ងៃនេះ ។

ក្រិតនៃការរាប់កេរ្ដិ៍ស្គាល់គ្នាពីជាតិមុន (បុព្វេសន្និវាស) ការអន្ទោលទៅចាប់កំណើតក្នុងត្រកូលណាមួយ, ការកើតឡើងជាថ្មីនឹងសេចក្ដីប្រព្រឹត្តទៅនៃជីវិតនេះ ស្រេចតែចេតនានឹងកម្ម (គឺស្រេចតែកំរិតនៃហេតុនឹងផល) ដែលបានធ្វើទុកមកពីជាតិមុន ។

ពុទ្ធសាសនិកជនឃើញច្បាស់ដោយខ្លួនឯង អំពីសភាពមិនទៀងទាត់ នឹងសេចក្ដីប្រែប្រួលជាធម្មតានោះ ទើបមិនមានចិត្តរំភើបនឹងសេចក្ដីស្លាប់សោះឡើយ ។ សេចក្ដីស្លាប់នោះតែងមានសេចក្ដីប្រែប្រួលជានិច្ចក្នុងសង្សារចក្រនេះ ។

មនុស្សយើងកើតឡើងនឹងវិនាសទៅ ប្រព្រឹត្តទៅតាមអំណាចចិត្តទាំងអស់ ។

ព្រះពុទ្ធសាសនាពន្យល់ផ្លូវដែលត្រូវប្រតិបត្តិតាម ដើម្បីជុសខាត់សំអាតនិស្ស័យសន្តានអាក្រក់ចេញ ហើយធ្វើចិត្តសន្តានជាន់ខ្ពស់ឲ្យចម្រើនលូតលាស់ឡើង សត្វដែលមានចិត្តបរិសុទ្ធនឹងមានជីវិតប្រកបដោយសេចក្ដីសុខគេចចៀសផុតពីសង្សារចក្រដែលមិនទៀងទាត់នេះ ព្រោះការនឿយណាយនឹងការមិនទៀងទាត់ ទើបគេស្វែងរកសេចក្ដីទៀងទាត់ គឺសន្តិបរមសុខ (ព្រះនិព្វាន) ឃើញ ។

ហេតុនេះ ទើបពុទ្ធសាសនិកជនយល់ឃើញសេចក្ដីស្លាប់ ទុកដូចជាចំណងចងភ្ជាប់នឹងជីវិតទាំងអស់ជានិច្ចជាធម្មតា ។ វត្ថុទាំងពួងដែលកើតឡើង តែងតែបាក់បែកខ្ទាត់ខ្ចាយទៅ ហើយចាប់កំណើតជាថ្មីទៀត សាងជាតិសាងភពឡើងទៀត ។ មិនត្រូវកត់សំគាល់យល់ឃើញមនុស្សជាតិ ទុកដូចជារបស់ដែលគេកសាងមួយដោយឡែកទេ មនុស្សលោកតែងតែធ្លាក់ទៅជាប់នឹងច្រវាក់ធំនៃសង្សារវដ្តទាំងអស់ ។ មានសត្វពួកខ្លះ មានរាងកាយស្ដួចស្ដើងធ្មារ ពួកខ្លះ មានបញ្ញាឆ្លាតឆ្លៀវលើសលប់ មានសត្វពួកខ្លះ មិនសូវមានប្រាជ្ញាឆ្លាតឆ្លៀវ ទាំងស្លូតស្លាប់ក៏មាន ។ សព្វសត្វទាំងអស់នោះ តែងមានពេលមួយ តោងធ្វើដំណើរទៅក្នុងសង្សារភពទាំងអស់គ្នា ។

ជំនន់នៃជីវិតសត្វទាំងអស់នោះ ដែលខំប្រឹងប្រែងចិញ្ចឹមជីវិតតែរៀងខ្លួន ទុកដូចជាមហាសមុទ្រដែលមានរលកគគ្រឹកគគ្រេង ។

ចិត្តនឹងកម្មដែលសត្វប្រព្រឹត្តរៀង ៗ មក នោះនាំឲ្យកើតកពនឹងឲ្យកើតជារូបបុរសស្ត្រីឡើងទៀត (តអំពីនោះបន្តិច) ក៏កើតមានមានះក្អេងក្អាងថា "អញមួយនឹងគេដែរ" (អហង្ការ, មមង្ការ) ។

ចូរនាំគ្នាមើលហេតុនៃសេចក្ដីស្លាប់របស់សត្វលោកទាំងអស់ មិនមែនជាហេតុសម្រាប់មនុស្សយើងប៉ុណ្ណោះទេ ។

ហេតុនៃសេចក្ដីស្លាប់មាន ៤ យ៉ាងគឺ:

១ ការអស់ទៅនៃកំឡាំងផលឬអស់ជីវិតទៅ ។

នៅទីនេះ គេប្រាថ្នានឹងពោលអំពីកំឡាំងប្រកបដោយកម្ម .នឹងកម្មជាកិរិតរបស់ហេតុនឹងផលដោយពិត ប្រៀបដូចជាគេពោលដុំថ្មមួយដុំទៅក្នុងទឹក រមែងធ្វើទឹកខូងជារង្វង់មូល ហើយបែកខ្ញែកចេញជារលកធំដំបូង ហើយរៀវជារលកតូចទាល់តែបាត់អស់ទៅ ដោយកំឡាំងទំហឹងដុំថ្មដែលពោលទៅនោះ ឯចិត្តយើងនឹងកម្មរបស់យើងក៏មានទំនងដូច្នោះដែរ ដោយអំណាចកំឡាំងកម្មនោះឯង យើងឃើញថា ជាតួហេតុនឹងផល កំឡាំងកម្មនុ៎ះឯងជប់លៀងចិត្តយើង ឲ្យអន្ទោលទៅក្នុងសង្សារវដ្ដ ។

២ ហេតុនៃសេចក្ដីស្លាប់នោះ គឺការផុតលេត់ទៅនៃរូបចាស់ (ផ្លាស់កាយថ្មី) មានសត្វពួកខ្លះ ដូចជាមេអំបៅជាសត្វមានរាងស្រួយស្ដើងស្ដួច មានជីវិតនៅបានត្រឹមមួយខណៈប៉ុណ្ណោះឆាប់ផ្លាស់ប្ដូរកើតកាយជាថ្មី ។

៣ ហេតុនៃសេចក្ដីស្លាប់ គឺការផុតរលត់ទៅនៃកំឡាំងជីវិតកង កាយពុកផុយទៅព្រមគ្នា ។

៤ ហេតុនៃសេចក្ដីស្លាប់នោះ គឺមានហេតុមួយទៀត ដែលមានកំឡាំងខ្លាំងក្លាជាងហេតុខាងលើនេះទាំងអស់ អាចបញ្ឈប់ហេតុឯទៀតឲ្យនៅទ្រឹងទាំងអស់ ហើយសម្លាប់សត្វលោកមិនថាក្មេងឬចាស់ ទុកជាកំពុងនៅក្មេងហើយកំពុងពេញរូបកាយគតកេតម្លៃនោះក៏ដោយ ។

ដំណើរនោះប្រៀបដូចរលកធំមួយនៅបាតសមុទ្របណ្ដាលឲ្យផុះផុលឡើងមកលើទឹក ហេតុនេះ បានជារលកឯទៀតៗ ដែលកើតឡើងស្រេចតែទឹកឡើងចុះ រមែងបែកខ្ចាត់ខ្ចាយអស់ទៅ ។ រលកធំនោះក៏នាំពាំយកគ្របដណ្ដប់រលកអស់នោះទៅទាំងអស់ ។

មានសេចក្ដីឧបមាមួយយ៉ាងទៀតថា: ប្រៀបដូចជា ប្រទីបប្រេងអាចរលត់ទៅបានដោយហេតុដូច្នេះ គឺ:

១ ប្រសិនបើប្រេងឆេះ-ឆេះអស់ទៅ (ភ្លើងក៏រលត់)

២ ប្រសិនបើប្រេងអស់រលីងទៅ ״

៣ ប្រសិនបើអស់ទាំងប្រេងឆេះទាំងប្រេង ״

៤ ប្រសិនបើមានហេតុដទៃទៀត ដូចជាខ្យល់បក់ជាដើមប្រទីបនោះក៏រលត់ទៅដែរ ។ ប៉ុន្តែបើមិនមានគ្រោះថ្នាក់ទេ ស្រេចតែហេតុ

នៃកម្មទឹងសេចក្តីវិនាសទៅនៃពិភពចក្រវាឡ ដែលមនុស្សក្នុងលោកត្រូវតែទទួលស្មើគ្នាទាំងអស់ ។

ឥឡូវនេះ យើងនាំគ្នាមកពិនិត្យមើលដំណើរដែលហៅថា សេចក្តីស្លាប់នេះចុះ តែងមានមកដល់យើងគ្រប់ៗខណៈ ហេតុនេះ យើងត្រូវស្គាល់ដំណើររបស់ចិត្តឲ្យជាក់ច្បាស់ជាមុនសិន ។

ចិត្តនេះប្រៀបដូចពន្លឺរស្មី (ព្រះអាទិត្យ) តែងញ័ររញ្ជួយជាធម្មតា ប៉ុន្តែចិត្តនេះមានអាការញ័ររញ្ជួយរហ័សជាងរស្មីនោះទៅទៀត ។

ហេតុនេះ ក្នុងយើងមើលឃើញ ឬកត់សំគាល់នូវរូបនិមួយបាននោះ លុះតែមានអាការរញ្ជួយញាប់ញ័រយ៉ាងខ្លាំងនៃពន្លឺរស្មីនោះ ។

ឯយើងត្រូវមានអាការរញ្ជួយ ១៧ ខណៈ ទើបអាចកត់សំគាល់នូវចិត្តនិមួយៗបាន (គឺថាចិត្តដែលកត់សំគាល់នូវរបស់ល្អអាក្រក់បាន) ។

## វិថីចិត្តគ្រប់ដួងបែកចេញជា ៣ ខណៈ

១ ខណៈដែលមានរូបប្រាកដ (ឧប្បាទខណៈ)

២ ខណៈដែលកើតឬចំរើនឡើងតាំងនៅ (ឋិតិ)

៣ ខណៈដែលរលត់ទៅ ហើយកើតចិត្តមួយទៀតតទៅ (ភង្គៈ)

សមដូចពាក្យលោកវ៉ាល្លេ ពុស្សាំង (Vallé-Poussin) ពោលទុកថា ជីវិតរបស់យើងប្រកបដោយចិត្តមួយដួង ហើយកើតចិត្តមួយដួងទៀតតៗគ្នាទៅ សឹងចេញមកអំពីចំណោមនៃដួងចិត្តទាំងអស់ ។

ដរនចិត្តស្ទុះទៅរហ័សណាស់ ចិត្តរបស់មនុស្សដែលប្រែប្រួលទៅជាដឹងល្អអាក្រក់ ទាំងមានអំណាចលើកងកាយនោះ សឹងប្រែប្រួលទៅតាមកំឡាំងធាតុក្នុងកងកាយ គេអាចពោលថា ទីបំផុតនៃចិត្ត គឺខណៈដែលចិត្តរលត់មិនមែនដូចគ្នាទាំងអស់ទេ រលត់នៅទីនេះ ហើយទៅកើតទីឯណោះ ហេតុនេះ បានជាព្រះពុទ្ធសាសនាសំដែងថា ចិត្តនេះកប់ប្រមាណមិនបានទេ គ្មាននៅនឹងសោះឡើយ តែងមានសេចក្តីប្រែប្រួលជានិច្ច ។

សេចក្តីស្លាប់នោះតែងជាប់ជំពាក់នឹងជីវិតយើង នឹងបែកចេញឲ្យដាច់ពីគ្នាមិនបានឡើយ ។ យើងអាចពិនិត្យឃើញថា មនុស្សស្លាប់ទៅក៏មិនចំឡែកអ្វីពីធម្មតាទេ បុគ្គលដែលកន្លងមកហើយតែងមានទំនងដូចគ្នាទាំងអស់ សូម្បីចិត្តនឹងកាយប្រសាទរបស់យើងតែងតែស្លាប់បន្តិចៗ ទៅរាល់ៗថ្ងៃដែរ ។

មនុស្សយើងតែងតែកើតនឹងស្លាប់ទៅរាល់ៗថ្ងៃ គ្រាន់តែប្តូរត្រង់មនុស្សពីម្សិលមិញ នឹងមនុស្សពីព្រឹកមិញ ហើយមានមនោវិញ្ញាណធាតុជាប់តគ្នា ហេតុនេះ មនុស្សកើតមកក្នុងជាតិនេះ ជាតិដែលកន្លងមកហើយ នឹងជាតិទៅមុខ រមែងមានមនោវិញ្ញាណធាតុជាប់ទាក់ទងគ្នាដែរ ប៉ុន្តែមានផលមិនដូចគ្នា ទោះទៅមុខក៏មិនដូចគ្នាទៀតដែរ ។

# អំពីភាវនាកម្ម

ពុទ្ធសាសនិកជនជាគ្រហស្ថដែលថ្វាយបង្គំព្រះ ចំរើនភាវនាកម្ម មិនមែនត្រឹមតែថែរក្សាពុទ្ធសាសនាទុកប៉ុណ្ណោះទេ គោលធម៌សំខាន់ ៗ ដូចជាមរណស្សតិ (ជាដើម) ត្រូវយល់ថា ទុកដូចជារបស់មានប្រយោជន៍បំផុតមួយ សម្រាប់ចំរើនភាវនា ការចំរើនភាវនានោះមិនមែននាំឲ្យឈឺចាប់អ្វីសោះឡើយ ។

មុនដំបូង គេត្រូវឃើញច្បាស់អំពីសេចក្តីមិនទៀងទាត់នៃរបស់ទាំងពួង គេតែងភ្ជាប់ផ្តេកផ្តិតចិត្តគំនិតនឹងសេចក្តីស្លាប់ ដូចជារបស់ដែលខ្លួនត្រូវមានជាប់នឹងខ្លួនជាធម្មតា មិនត្រូវមានចិត្តកើបញាប់ញ័រអ្វីឡើយ ។

គំនិតនេះហើយដែលនាំឲ្យយើងរួចផុតពីចំណងនៃរាគៈ និងសេចក្តីលោភ គំនិតនេះហើយដែលកំចាត់បង់នូវមានៈ ហើយផ្សាយមេត្តាចិត្តដល់សព្វសត្វដែលមានសោកមានស្លាប់ដូចគ្នា ។

ការចំរើនភាវនាបែបនេះ អាចការពារមនុស្សមិនឲ្យធ្វើអំពើអាក្រក់ទាំងពួង ដែលនាំឲ្យកើតក្នុងទុគ្គតិភព ។ មនុស្សដែលបានយល់ច្បាស់នូវអំណាចនៃតណ្ហា និងសេចក្តីមិនស្ថិតស្ថេរនៃជីវិតហើយ រមែងមិនរករឿងបង្ខូចកេរ្តិ៍ឈ្មោះរបស់អ្នកដទៃ ស្វែងរកតែសេចក្តីបរិសុទ្ធចំពោះខ្លួន និងស្គាល់ច្បាស់នូវអរិយសច្ចប៉ុណ្ណោះ ព្រោះអំពើអស់នេះហើយ ដែលមានដំឡៃដ៏ពិតប្រាកដ ។

# អំពីអ្នកជម្ងឺពេលនឹងស្លាប់

សេចក្ដីស្លាប់កំពុងដល់មកហើយ គឺជិតស្លាប់ហើយត្រូវរៀបចំធ្វើដំណើរខ្លួនឯង (រឿងនេះស្រេចតែទំនៀមអ្នកស្រុកលង្កាចុះ) ។

អ្នកដែលដេកស្លាប់ ជាអ្នកធ្លាប់មានគំនិតគិតអំពីសង្ខារទាំងអស់ដែលកើតឡើង ត្រូវតែបែកធ្លាយទៅវិញជាធម្មតា មិនមែនរលត់សូន្យឈឹង ដូចជាគេនិយាយប្រាប់យើងរឿយ ៗ នោះទេ នេះជាសំដីរបស់អ្នកដែលមិនស្គាល់ពុទ្ធសាសនាច្បាស់លាស់ប៉ុណ្ណោះ ។

កន្លែងបន្ទប់របស់អ្នកដែលដេកស្លាប់ ត្រូវតែស្ងប់ស្ងាត់ឲ្យមានមនុស្សតែបន្តិច ឬកុំឲ្យមានឡើយក៏បាន ប្រសិនបើអ្នកជម្ងឺនោះត្រូវការ គួរនិមន្តលោកសង្ឃមួយរូប ឬមានឧបាសកម្នាក់ជាអ្នកចេះមើលព្រះគម្ពីរអានឲ្យអ្នកជម្ងឺស្ដាប់ក៏បាន ។ ត្រូវឲ្យស្ងាត់កុំបីមានមាត់ពាក្យហើយប្រុងស្មារតី មិនត្រូវឲ្យមានយំសោក មិនត្រូវឲ្យមានសំឡេងអ៊ូអរ ។

ប្រសិនបើមានកម្រងផ្កា ទឹងគំនូរជាទីគាប់ចិត្តនឹងយកទៅបិទភ្ជាប់កន្លែងបន្ទប់ក៏បាន អ្នកជម្ងឺត្រូវតែប្រមូលចិត្តគំនិតឲ្យល្អ ។ អ្នកជម្ងឺនោះត្រូវតែលះបង់គ្រឿងកង្វល់ទាំងអស់ចោលចេញ ទាំងញាតិសន្ដានបងប្អូន ទ្រព្យសម្បត្តិ ឬគ្រឿងកង្វល់ឯទៀត ៗ ចោលចេញឲ្យអស់ កុំឲ្យជាប់ជំពាក់ចិត្តនឹងអ្វីឡើយ ។

បើអ្នកជម្ងឺគិតពីដំណើរជីវិត ត្រូវតែនឹករលឹកតែអំពើល្អ ៗ ដែលខ្លួនបានធ្វើមក មិនត្រូវគិតពីអំពើអាក្រក់ឡើយ ព្រោះចិត្តយើងស្ងប់ស្ងាត់ក៏មានសេចក្ដីសុខ ដល់ទៅពេលនឹងស្លាប់ ចិត្តគំនិតយើងតែងប្រកបដោយសេចក្ដីសុខ ទៅជាចិត្តប្រកបដោយសេចក្ដីបរិសុទ្ធមានអំណាច ៗ

ត្រូវយល់ថា ចិត្តក្រោយបង្អស់នោះ ទុកជារបស់សំខាន់បំផុតក្នុងជីវិត ដ្បិតគំនិតល្អនោះនឹងបណ្ដាលផលល្អឲ្យកើតឡើងបន្ទាប់អំពីមរណៈនោះ ៗ

អ្នកដែលមានជីវិតបរិសុទ្ធ ដោយមិនបានធ្វើអំពើអាក្រក់ដល់សត្វណាមួយសោះនោះ ដល់ទៅជាតិមុខ នឹងបានទទួលផលនៃកម្មល្អនឹងចិត្តល្អនោះ ៗ

ចិត្តគំនិតដែលបានអប់រំបង្ហឹតតែអំពើល្អ ៗ នោះ នឹងមានកំឡាំងមាំមួនល្អ ប្រសិនបើអ្នកជម្ងឺអាចភាវនាបាន គួរភាវនាធម៌មួយដែលជាគោលដែលខ្លួនធ្លាប់ភាវនាមកហើយ ៗ ចូរលះបង់គំនិតដែលជាបង់ដំពាក់មែកម្មកង្វល់លោកនេះចេញឲ្យអស់ឲ្យនៅសល់តែចិត្តស្ងប់ប្រកបដោយសុខ បុគ្គលនេះនឹងស្លាប់ទៅដោយស្រួល ដូចជាកូនក្មេងដែលដេកលក់ស៊ប់ដូច្នោះ ៗ

ព្រះពុទ្ធដីកាសំដែងទុកថា "មនុស្សដែលបានព្រោះសាបមេត្តាចិត្តដែលបានចំរើនផ្សាយមេត្តាចិត្ត ដេកក៏ជាសុខ ភ្ញាក់រលឹកឡើងក៏ជាសុខ រស់នៅក៏ជាសុខ ស្លាប់ទៅក៏ជាសុខទៀតដែរ" ៗ



ប្រទេសលាវ-សៀម ស្រុកឡាំភូន វត្តកុកុដិ រូបជាមទេវីចេតីយ៍
មើលពីចំហៀងបណ្តោយ

# រឿងកាកី

## ព្រះរាជនិពន្ធ ព្រះបាទសម្តេចព្រះហរិរក្សរាមាឥស្សរាធិបតី

## ព្រះបរមកោដ្ឋ

## តាមច្បាប់ព្រះអង្គម្ចាស់ក្សត្រីមាលិកា

( គទី ៣ )

៙ បទកាកគតិ — គន្ធទ្រួសរិះ ដងធាប់ពុំធ្លប់ ចាប់ពិណាដេញដំ
ប្រៀងផ្សំស្នូរសាល់ ជាពាក្យកិច្ចកល ទំនុកទុគថា ។ អ៊ុះឱព្រះពាយ
រំភើយរំភាយ ផាត់កូនគន្ធា រសេវកូនស្រី កាកីស្មូនភ្ញា បងចាំផាត់
ជា កូនប្អូនមិញទេ ។ ឱកូនកាកី មិនដូចអស់ស្រី ទីងស្រែអស់គេ
រងតែងអប់អស់ គន្ធសេរីលេប្ម៍ កាកីមាសមេ ក្រអូបអង្គឯង ។
ឱកូនកាកី ត្រកាលកលអ្វី ពិដោរល្វើយល្វែង ដិតដោយអង្គា កាល
ត្រាវៀមរែង ប្រលោមប្រលែង ព្រលឹងប្អូនគន់ ។ ឱស្ថានសិម្ពលី
ជាសុខឥតបី ឥតបើមានមុ— ន្ទិលពាល់តែបាត់ លះលាកដំបន់ ប្អូន
អើយបងគន់ បងគិតដល់ស្រី ប្រាសប្រាំពីរថ្ងៃ បាត់កូនប្អូនថ្ងៃ ថ្ងៃនេះ
ហេតុអ្វី ពិដោរកូនខ្លួន ប្អូនស្ងួនពិសី ដោយគេបេតី តនត្រូបពុំងា ។
ទើបជាប់កូនមេ កូនដិតដោយគេ ឈ្មុយឈ្ងប់មោះហិមា ឱម៉េះសម
ស្រី កាកីកល្យា-ណីនៅកំព្រា ត្រមោចម្នាក់ឯង ។ ឯគ្រុឌគ្រុឌធា
ស្តាប់គន្ធញ្ញា ប្រៀងប្រួចឥតក្រែង ក្រោធក្រម្នាក់ម្នេញ ក្នាន់ក្នាញ់
ខឹងខែង គិតថាអាដែង នេះគិតប្រៀងជា ។ ទំនុកសរសើរ ទំនង
ដំណើរ ពីកេរកេនិដ្ឋ ខឹងខំតែអត់ សង្កត់ចិត្តជា អះអត់ឲ្យរាំ ងាយ
ដឹងសេចក្តី ។ ឯគន្ធទ្រួសោត ដឹងដើមគ្រុឌក្រោធ វែងរិតចាប៉ុ ផ្សំ
សព្វស្នូរសៀង ប្រួចប្រៀងស្រដី ថាឱស្រស់ស្រី កេរការណិកា ។
ម៉េះសមនាងទឹក នាងទឹងសន្ធឹក សន្ធៃដង្វាយផ្កា បើបានបងនៅ ជួម

ពៅឲ្យជា សោះប្អូនរង៉ា រង៉ាប់ចិត្តទៅ ។ ស្ដាយអើយមកប្រាស
ព្រាត់វរមិត្រមាស ពុំបានវែបនៅ ជាក់ជួមផ្ដែកផ្ដិត ក្នុងចិត្តចង់ទៅ
ទៀតតាមថ្នមពៅ នៅស្ថានសិម្ពលី ។ គ្រុឌស្ដាប់វែងវង ក្ដួលក្ដៅ
តានតឹង ដូចគលអគ្គី ឈួលឆេះដង្ហប់ផ្សា ឧពបក្សី ហើយខំស្រដី
ទាំងទាល់ទៅថា ។ នៃអ្នកចំរៀង អ្នកឯងអ្នកច្រៀង ពីស្ថានគ្រុឌជា
យើងស្ដាប់យល់ប្លែក បំផ្លែកមោះហិមា ដ្បិតអ្នកជាតិជា ព្រាណ
ព្រួសដើរដី ។ ម្ដេចក៏ទៅដល់ ទីស្ថានមណ្ឌល មន្ទីរសិម្ពលី អ្នក
ដឹងជាស្ថាន ពិមានបក្សី ក្រុងគ្រុឌទាល់ទី ក្នុំសត្តបរិភណ្ឌ ។ ហើយ
មានជលធី ដោយជាន់គិរី ឈ្មោះសត្តសិទ- ន្តរដោយវង់វិល ព្រុំពីរឡើប
ជាន់ សមុទ្រទាំងខណ្ឌ ជេងជំឆ្ងាយ.បល់ ។ ហើយមានមច្ឆា និករក្ខា
នាគនៀកកាចកល បើឃើញមនុស្សម្នា សត្វណាធ្លាក់ដល់ សមពុំសំ-
ណល់ ទីងអស់សត្វផង ។ អំបាលគ្រុឌហោះ វែងខំផ្ទុកផ្ទោះ ថ្ពាស់
ប្តូរលែង ទើបបានទៅដល់ មណ្ឌលទិព្យគ្គង់ អ្នកឯងម្ដេចម្ដង អ្នកថាទៅ
បាន ។ ប្អូនមួយច្រៀងលេង ទំនុកល្បើកល្បែង ដោយដឹងនិទាន ប្អូនចេះ
ផ្ទុកផ្ទោះ ហិចហោះទៅបាន ប្អូនមួយអ្នកមាន មន្តសិល្បសាស្ត្រា ។ អ្នក
ថាបានទៅ យើងធ្ងល់ឆ្ងាយនៅ សន្ធិះសង្កា បើអ្នកបានរៀន របៀន
គ្រង់ណា យើងចង់ចូលជា សិស្សសូមរៀនផង ។ គន្ធនស្ដែងស្ដាប់
សើចសងព្រាយប្រាប់ ដោយជាន់ទំនង ដំណើរជាយើង មិនទើង

ពោះផ្សង បិត្តហានរំលង ដោយសារគ្រូឧដា ៗ ដែកកោមគ្រូឧទៅ ទាល់ទីលំនៅ កែវការណិកា គ្រូឧគ្រងឯយប់ យើងឈប់ទិទ្រា លុះរម្ងក- គឺត្រូវយើងគ្រង ៗ ថ្ងៃគ្រូខែតងទៅ បេញបោលលំ- នៅ យើងនៅស្នេហ៍ស្នង គ្រងគ្រូឧពុំដឹង ដំណឹងទំនង តែយើង គិតម្ហួង ខ្លាចមាតុគាមា ៗ ប្រាប់ក្មាងធ្វើក្មេង ចំអន់លេញលេង ជាពាក្យកាព្យា ពិពេះពិណពេក ស្រួលស្រែកឧតថា ឧស្រីស្រស់ កា· គីកែវបងអើយ ៗ ពីដោរក្ងិនស្ងួន ហាក់បានឃើញខ្លួន ដិត ជាក់បង្កើយ កាលបងទឹងពៅ នៃបនៅ ៗ ឡើយ ព្រលឹងបងអើយ ធ្លាប់ស្និទ្ធស្នេហា ៗ ក្រោយគ្រូឧទៅបាត់ បានបងប្រដិព័ទ្ធ ស្លាប់ស្នង គ្រូឧដា ថ្នាក់ថ្នមផ្ដេកផ្ដិត ដួញដិតឧក កេសកើយខ្នើយជា· មួយមិន ដទៃ ៗ កេ្រមក្សាន្តសាទរ សេពសុខសមពរ រួមរសមូលមេ· ត្រី ត្រែកមនោរម្យ បន្ទំសុខសៃ· យាសយូរគ្រប់ថ្ងៃ ប្រាំពីរទឹងបង ៗ ឧស្រីបងបាត់ ស្រីស្ងួនសមស្លាត់ សមស្ងួនទឹងរង ទុក្ខទល់ម្នាក់ម្នេញ កន្ទេញកន្ទង កន្ទេងគិតបង បងបាត់លង់លង់ ៗ កុំមានគ្រូឧដា បងទឹងស្ងួនភ្ញា ឲ្យអស់ជីពជន្ម ឥឡូវគ្រូឧគ្រង មូលផងសម្ពន្ធ ប្អូន អើយបងអន់ បងអួលឧក ៗ ឧបងទឹងយក មេមាសមិត្រមក ដិត ដោយអាត្មា មោះប្ដូបងដើរ ដំណើរវេហាស៍ ដោយសារគ្រូឧដា ឆានាំបងមក ៗ ឥន្ទ្ទនប្រៀងថ្វាត់ ថ្វាយបង្គំក្សត្រ ឥស្សរពន្ទុក គ្រូឧ

ស្ដាប់ឮជាក់ ហើយហាក់គេយក កាំពិសសរសើក ក្នុងអង្គទុក ៗ
អៀនទុនដាក់មុខ នឹងពាក្យទំនុក ទំនងកាព្យ យល់មែនពិតពុំ បន្យំ
បរោ គ្រឹះក្លាញ់ចិន្ដា ខឹងហើយស្ដាប់ផង ៗ ស្ដាយក្លិនក្រអូប ស្ដាយ
ទាំងកង់រូប ស្ដាយចិត្តស្នេហ៍ស្នង ស្ដាយបេះកោតការ សង្សារទំនង
ស្ដាយទាំងល្បែងល្បង បានបទលែបខាយ ៗ ស្ដាយណាស់វែងឆ្ងាញ់
គ្មានក្នុងពោះពេញ ក្រោធក្រៃក្រហាយ ក្រហល់បំផុត អុកក្នុងកាយ
ពិតពុំរសាយ ជញ្ជឹងគិតឈ្លង ៗ ខ្លួនអញទៅ គំនិតឆោតឆៅ
គេពុំកោតក្រែង គេល្បង(១)កលបាន ដូចការគេស្ដែង ហើយគេ
មកថ្លែង កាលគេស្នេហា ៗ ឲ្យអន់អៀនខ្មាស អាប់អាស្រូវកាស
នៃអ្នកនានា បំណាច់មានប្ដី សល្បសិទ្ធិសាស្ត្រា ប្រាណប្រែកាឡា
ហើរហោះផ្ទោះបាន ៗ គង់ចាញ់កលគេ ព្រោះចិត្តធ្វេសធ្វេ
ប្រមាថប្រុសប្រាណ ជាប្រុសដូចគ្នា លោកថាឲ្យមាន ចិត្តបេះរិះធ្យាន
ដូចគង់កជរថ ៗ អញបង់សំឡាញ់ គិតគាប់ទៅមិញ បានដឹង
ពីពុត ស្រីស្រាលស្រើបច្នេះ ពុំបេះអន់អត់ បំណេរការកត់
លុះអស់ជន្មា ៗ គិតស្រេចវេនតៃយ ស្រដីវែងវៃ កាន់គន្ធនថា
អើអ្នកក្បួន អ្នកមែនជាតិជា ប្រាណប្រុសប្រាជ្ញា ប្រកបពាក់ទី ៗ
ផ្សំស្បូវសមសព្ទ ពិណពីពេះគាប់ កលកាព្យពាក្យពី- ពេះរៀបទំនុក

---

១ ល្បង បញ្ឆោត អធិប្បាយថា គេបញ្ឆោតបានដោយកល ។

ដាក់ទុកសំដី ជួបជួនឥតបី ទញ់ទាល់ទំនង ៗ គ្រូឪថាហើយហោរា ព្រហ្មទត្តកជា ចរចេញទៅផ្គង ដល់ដើមដៃបាន ប្រែប្រាណដូចប៉ង ហើយហិចហោះផ្សង ដល់ដើមសិម្ពលី ៗ សេពាទ្ទបើកបាន ទ្វារស្រប ចូលឋាន យល់អង្គកាកី គ្រោងក្រៃក្តៅក្តាត់ ក្នុងចិត្តបក្សី ដូចកលអគ្គី ឈ្លូលឆេះទាក ៗ

១ បទពោលកាលក្រុងគ្រុឌជា គង់លើអាសនា ក្រលេកក្រឡេ សំឡឹង ៗ ខំអត់សង្កត់ទូវកំហឹង កំសាន្តផលខឹង កំដឹងកំដៅ ទ័យា ៗ សួរសាកដោយសព្វព័ត កាលយើងយាត្រា អំពី ពារាណសី ៗ មកនៅនាស្ថានសិម្ពលី ម្លេះពីរាត្រី ប្រាកដប្រែកប សុខសាន្ត ៗ ញុំាងយល់នរណាអាចហាន ចូលបួមប៉ៃប្រាណ មកនៃបមកនៅប្តូទេ ៗ កាកីដោះសាថាមេ នរណាឡើយគេ ពិជាញនូវជ័យចូលបាន ៗ ខ្ញុំនៅឯកឯងនាស្ថាន នេះទិរអ្នកហាន មកដិតមកដល់ ៗ មួង ៗ គ្រូឪស្តាប់កាកីសាសង គ្រោងក្រៃកន្ទង កន្ទាញរឹងក្នាញក្នុងចិត្ត ៗ ថាដើរចេះតែពាកពិត ធ្វើបែបប៉ាំងបិទ បង្វែងបង្វិលវៀះវៀង ៗ អញដឹងអស់ហើយកុំទាង ប្រាយប្រាប់ ប្រែប្រាន កុំដាងកុំចេះលាក់សម ៗ សហាយនរណាយពាកប់- បែង បែកលាកលំ- នៅរះទាល់ទៅបាត់បង់ ៗ ហើយចេះវិលវេះអួតអង្គ ថាឯងស្មោះត្រង់ ពុំដឹងពុំយល់នរណា ៗ អញសង្កាត់ច្បាក់ជួមសួនភ្ជា

ដូចកលជីក៏ ជីវិតជាមួយមូលអគ្គ ៗ ពុំគិតគេក្ដីកោះបាបបង់ បុណ្យបទ
ចិត្តបង់ ទឹងយកជាមិត្រពាទិតា ៗ មិនដឹងជាចិត្តសាធារណ៍ នៅ
សព្វថ្ងៃផងគ្នា ហើយខំទៀតមានសហាយ ៗ ឥឡូវកក់កិតកំយកាយ
ក្រែងដើមកំណាយ កំទឹកកក់នៅពុំបាន ៗ ហើយកំរិលរឹងទៅស្ថាន
នៃមឹងម្ដេចបាន ប្រក្លួតប្រកែកតអាយា ៗ នរណាឯងក្រែពីក់ គឺគន្លញ
កំលៀងនៃប្ដីហងឯង ៗ កាកីស្ដាប់ស្ដីយល់ស្ដែង កំយកិតហើយថ្លែង
ថាឃើព្រះអគ្គម្ដេចថា ៗ ឲ្យអាស្រូវគាសណាសំណា បង់ស៊ើបទៅហា
មកថាម្ដេចទឹងគន្លូន ៗ បើអ្នកណាឃើញជាក់ស្បាទ គ្នាយកមកផ្ទាន់
មកផ្ទឹមប្រទល់មុខគ្នា ៗ បើពិតគួរកាត់សិរសា កុំព្រះអគ្គថា ជាខ្ញុំពុំត្រូវ
ពុំត្រង់ ៗ ស្ថានពិមានចមបុង សិម្ពលីខ្ពស់ខ្ពង់ ជិតជើងសុមេរុ
ក្រៃក្រៃ ៗ មនុស្សណាឯងអាចជាញជ័យ ហើហោះឆ្ងងញ សត្ត
សីទន្ដរផល់ជិត ៗ ទ្វារសោតមន្តបង្គាំងគ្គិត ជាប់ជួនប្រសិទ្ធិ ប្រៈ
សើរទ្ធូរសាស្រ្ដាគម ៗ កុំថាតែមនុស្សឃោរខំ ទោះទេពឥន្ទ្រព្រហ្ម
វិជ្ជាធរ(១)អសុរី ៗ ពុំអាចវៃកាតគើង(២) ដោះដេបពន្ធ័ន សុបណ្ណ
សម្រិទ្ធិចង ៗ គន្ធ័នណាបេះហោះជម្រង ទោះចិត្តប៉ុនបង់ ទឹងមកដើរ
មកម្ដេចបាន ៗ ខ្ញុំសោតជាខ្ញុំក្សត្រក្សាន្ត ពូជពង្សសន្តាន ជាហង្ស

---

១ វិជ្ជាធរ ម. អ្នកចេះវេទមន្តផ្សេង ៗ, ពពួកទេពមួយពួក, អាកាសទេវតា, អ្នកកាន់ឬទ្រង់នូវក្ដួនសង្កត់ (ដូចឃើងញាវេទ) ដ៏វិសេស ៗ ២ គើង ម. អ្នកពោះ, ពោះ ៗ

គួរគួទឹងហង្ស ។ ម្ដេចខ្ញុំក្លួចភ្លាំងបោះបង់ ចិត្តហោកៈប៉ះកបង់ ហង្ស
ហើយទៅគប់ទឹងក្អែក ។ អាប់អគ្គពូជពង្សប្រែងប្រែក មួយគិតលែក
ប្រណីព្រះទ័យប្រោសប្រាណ ។ ព្រះស្ត្រីរួមរ័ករួមស្ថាន ពុំទាន់ប៉ុន្មាន
ទឹងហោរទឹងហោលក្ខូមិត្រ ។ សូមព្រះអង្គអត់គិតសិន កុំអាលស្ដេចជិន
ព្រះទ័យសង្ស័យអន់អាក់ ។ ធម្មតាមេត្តាស្មោះស្ត្រី កុំស្ដាប់ពាក្យអ្នក
ដទៃដន្ទេញលលួង ។ ឲ្យច្រលំវិលវល់ដោយល្បួង ពាក្យល្បែងទាំងពួង
បំភាំងបំភាត់គំនិត ។ ត្រូវស្ដាប់តាក់តែងរិត គ្នានក្នាញ់ក្នុងចិត្ត ពុំ
មានសោយក្រោធា ។ ទើបត្រាស់ដោយកាដកាចា ចាំស្ដាប់មើលរា
ស្រីពាលសារសេន់អប្រិយ ។ រាល់ចេះតិចទេស្ដាប់ស្ដី បទយើងប្រុសថ្មី
សម្រួលសម្រាលដោះខ្លួន ។ បើមិនដឹងពុតផាក់ជួន យល់ជាជឿមួន
ដោយកលដោយកិច្ចក្បួនក្បាច់ ។ អញដ៏ធំអស់ហើយកុំបាច់ ដោះសា
ឲ្យស្រេច បង្វេះបង្វែងសេចក្ដី ។ គន្ធនរាដេញតាប៉ី ប្រួចប្រៀង
ស្រដី ថាបានមកនៅៗនេះ ។ ហើយបានរួមរសម៉ោះម៉េះ ប្រាំពីរ
ថ្ងៃនេះ ហើយពានេចរចាកចេញ ។ រាល់ប្រៀងផ្ដោះមុខហើយដេញ
ពិណពោលជន្ទេញ ជន្ទអញខ្មាសមនុស្ស ។ អាប់យសអប្រិយ
ណាស់ណា ស្មើរទឹងមុជផែ្ដកក្រលា ប្រែបពីឲ្យស្លាប់ជាម្ដង ។ ខ្មាស
ពាក្យរាល់ប្រៀងផ្ដោះផ្ដង ចំអន់លេញលង ដោយកលអំពើពាក្យពាល ។
គិតស្មានជាស្មោះស្និទ្ធស្នាល ពុំដឹងស្រែបស្រាល មានប្រុសចេះលាក់

សំដី ៗ ស្មានហង្សតែងស្រង់ស្រះស្រី ហង្សអ៊ូអប្រិយ មកផឹក
ឯទឹកថ្លុកល្អក់ ៗ រូបល្អចិត្តក៏អាក្រក់ ស្អុយក្រៃលាមក ក្រអូបតែក្លិន
អសារ ៗ ចិត្តខៅដូចផលធីងារ ហូរហួសហៀរហោ ពុំរើសពុំរក
ព្រៃកណា ៗ ទៃមឹងអញនាំយាត្រា វិលវឹងនគរ ក្នុងនាគត្រីនេះ
ឯង ៗ កាកីប្រណម្យទូលថ្លែង សូមទានស្ដេចឈ្នះ មេត្តាករុណា
សិទព៌ ៗ ម្ដេចជឿដោយពាក្យគេថា ដោយកលប្រាជ្ញា បញ្ចុក
បញ្ឆោតឲ្យបង់ ៗ បើនាដក្លូវទេចិត្តបង់ ប្រៀងថាព្រះអង្គ មានតែក្នុង
ព្រះឧទក ៗ ហ្មោះតើទឹងវះកាយា ដោយពាក្យគេថា ប្អូនទ្រង់ចិន្ដា
រំពឹង ៗ ស្ដេចស្ដាប់តែម្ខាងហើយទឹង ខ្ញុំវិញលស់ស្រឹង កំដឹងកំដៅក្រ-
ហាយ ៗ ខ្ញុំសូមពិសោធខ្លួនថ្វាយ បើមែនមិនស្ដាយ ជីវិតសូវស្លាប់
ទៅជា ៗ ទើងវិលវឹងនគរ សូវក្ស័យជន្មា នៅនាព្រះបាទព្រះបង ៗ
គ្រូឧស្ដាប់ពាក្យពើធ្មើយស្នង រឹងទឹងកន្ទង ក៏ញ៉ាំរន្ធត់អង្គឯង ៗ
កក្ដាក្រហមទុំទែង ចក្ខុដាលដែង រហានលោហិតស្រក់ស្រោច ៗ
ផ្សព្វផ្សាឧកខ្លាំងខ្ទោប ហាក់ទឹងរបោប របេះប្រមាត់សាច់ស្អួត ៗ
ថានៃមហោរប្រើនប្រួត អញឯងមិនធ្លួត ទឹងពាក្យនៃមេមាយា ៗ
បើអញរួមរ័កស្នេហា ទឹងមេលុះអ- នាគតគេជៀលបំហុត ៗ ថា
អញជាស្ដេចក្រុងគ្រុឧ ជាអ្នកពាលពុត អង្គុយជឿពាក្យមាយា ៗ
ពាផិតទុកចិត្តថាជា ឈ្មោកក្នុកស្នេហា ល្មើលួងវង្វេងខ្វៅខ្វោះ ៗ ថា

ស្រេចគ្រុឌពាហៀរហោះ មួយដំពាស់ដៃព្រោះ ដូចដល់ពារាណសី ។
ហើយដាក់នៃអគ្គកាគី នៅព្រះលានទី ព្រះបាទព្រហ្មទត្តចមទៅ ។
ហើយថានៃហង់កាលនៅ ទឹងអញនោះគួរ ដ្បិតប្រុសតែម្នាក់អញ
ឯង ។ ពុំស្គាល់ពុំស្កប់ចិត្តល្បែង ឥឡូវហង់ឯង ប្រឡែងនឹងប្រុសឲ្យ
ស្កប់ ។ ច្រើនហើយលេងចុះកុំឈប់ ទាំងថ្ងៃទាំងយប់ កុំឲ្យស្ងប់សង្វាត
ស្រាកស្រាន្ត ។ តែពីនេះទៅទៀត កុំឲ្យអញបាន ប្រសព្វដូច្នេះ
ទៀតឡើយ ។ ជាស្រេចហិចហោះព្រងើរ អាចផ្លាស់ទូងត្រើយ
ទៅដល់នៃដើមសិម្ពលី ។

នេះបទកាកតា — តិ ក្រោយគ្រុឌា វិលវិលទៅទី លុះព្រះសុរិយោ
មគ្គាវង្ស ព្រះបាទចក្រី ព្រហ្មទត្តកជា ។ ស្តេចតើនជំរះ សោយ
ព្រះស្ងួនជ្រះ លាបលាយគន្ធា ស្រួចទ្រង់អស់ ព្រះពស្ត្រកូសា ព្រះ
ទម្រង់ទ័នថ្វា ស្តេចបរមេញថ្មី ។ បើកព្រះកៅតា ឈៀងព្រះនេត្រា
យល់អគ្គកាគី អគ្គុយនាស្ថាន ព្រះលានចក្រី ស្តេចមានសេចក្តី
ក្រោធក្រៃសែនសល់ ។ អន់អាក់អួលខ្ញុំ ព្រពោលឈ្លួលចោរ អស់
អគ្គរបល គឺមោះខំអត់ សង្កត់ទប់ទល់ ចង់ជ្រាបកិច្ចកល ដំណើរ
ដើមដាន ។ ព្រះទស្សរិទ្ធិគន់ ត្រាស់ទ្រង់ចំអន់ ចំអកទៅក្ថាន ជាក់
កាគី ស្រស់ស្រីបង់បាន ទៅនៅនាស្ថាន ស្ងួតសោយសេពសុខ ។
បង់តែងទទ្ទឹង មើលផ្លូវព្រលឹង ដេកស្ទើរមិនលក់ ទាំងថ្ងៃទាំងយប់

សញ្ញប់ដាំទុក ឥឡូវឃើញមុខ ថ្ងៃថ្មើមបងមក ៗ ដល់ព្រះលានហើយ
នៅថ្វីព្រងើយ អង្គុយជ្រប់ជ្រក អញ្ចាញប្អូនស្ងួន ខ្ញុំមខ្ញុនពន្លក លី
លាឡើងមក ប្រាសាទសួស្តី ៗ បងអរពេកពិត ខបខៃ(១) ទឹងចិត្ត
ព្រលឹងកែវថ្លៃ បំណាច់បំរុង តែងជូនថ្មើមពី- តូចទាល់តែនី· ពស
រៀមបាត់ទៅ ៗ រៀមរែងដំកើង ដំកល់លើកឡើង ជាឯកឥតគូ
សុំសិទ្ធឆ្វេងស្តាំ ចាំបំរើនៅ ដរាបគាល់ហ្វៅ សព្វទិនទិវ ៗ ពុំដឹង
គិតប្រែ ប្រាសប្រែបចិត្តស្នេហ៍ ទៅទីគ្រង បេញបោលលះលាក
ប្រាសាទបរិការ លបទៅនៅនា ពិមានសម្ពលី ៗ ស្នេហ៍ស្នាលនឹង
ត្រុឌ បានតែកំណត់ ប្រាំពីរកត្រី ក្រលៃក្រលាប់ ប្រែតាប់ប្រដី-
ក្ខពន្លមេត្រី ទឹងអគ្គីទន្ទឹញ ៗ ប្រុសមួយហើយទៀត មួយហើយ
មួយទៀត ថែមជូនបីគ្រប់ គ្រាន់ស្កប់ចិត្តហើយ ឬនៅពុំស្កប់ ឬបង់ឲ្យ
សព្វ ដល់ប្អូនប្រាំត្រួត ៗ ហៅថ្វើគំទាប់ មុខគ្មួរឲ្យរាប់ គានអង្គអស្គួត
ដោយដាក់ដំកើង លើកឡើងជម្រួត សរប្រែបជាឆ្កួត ជាឆ្មើមនគរ ៗ
ចិត្តហៅដូចេះ ជម្ពូទីបនេះ គ្មានសោះទោះបរ រកផ្ទាប់ពុំដូច ពីតូច
ពាល់មរណ៍ ក្រណាស់ចេះអរ យកទុកម្តបបាន ៗ កាលនោះគាក៏
លុតលើកអញ្ជលី វរនូតក្យក្រកហ្វន្ត ទៀងទើបវិញទូល ទំនួលដោះ
ប្រាណ ថាបពិត្រគ្មាន ដូចខ្ញុំម្ចាស់វៀ្ឈយ ។ មោះចិត្តខ្ញុំម្ចាស់

---

១ ខបខៃ ពាក្យសៀម ប្រែថា អរគុណ គាប់ចិត្ត ។

នេះពិត ៗ ណាស់ ស្រឡាញ់ឥតស្បើយ មិនមានល្ហេសល្ហៃ ទៅមេ
ម្ចាស់អើយ សូមព្រះត្រាណត្រើយ ទ្រង់ព្រះចិន្តា ៗ ឲ្យទុកក្នុងចិត្ត
ប្រាកដមែនពិត មិនមានមុសា កុំតាមពាក្យញុះ ឲ្យលុះបរណា ព្រោះ
បង់បាតា ព្រះអង្គក្សត្រក្សាន្ត ៗ កាលកើតកលិយុគ ងងឹតកាលនោះ
ក្រុងគ្រុឌតិរច្ឆាន ហោះហើរចូលដល់ មណ្ឌលទីស្ថាន ខ្ញុំម្ចាស់សោត
បាន ស្រែករកភូបាល ៗ ពុំឃើញព្រះបាទ ព្រះបង់សង្វាត តាម
ទៅឡើយកាល ពេលនោះសុបណ្ណ លោកលន់ពន់ពាល ពាពត្រ-
អាល ហើរហោះរហោស ៗ ខ្ញុំម្ចាស់ពុំគិត ពុំចូលចាប់ចិត្ត ស្នេហ៍
នឹងគ្រុឌា តែក្ដិចខ្វារខ្ញុំ ជេរទាំងដៀលថា ឲ្យលែងចោលនា កណ្ដាល
នទី ៗ ឲ្យធ្លាក់ចុះក្នុង សមុទ្រលិចលង់ ក្សិណក្ស័យជីវី ដ្បិតឃ្លាតហោះ
បង់ នឹងអង្គចក្រី គ្រុឌរាជបក្សី ពុំលែងពុំស្លាប់ ៗ ខ្វង់ខ្វាំតែហោះ
ហៀរហើរផ្តេកផ្តោះ ដល់ស្ថានធុតឆាប់ ខ្ញុំម្ចាស់សោយសោក អាមោក្ខ
ស្ទើរស្លាប់ ទឹកភ្នែកជ្រៀបជ្រប់ ជាលដូចលោហិត ៗ ពុំមានចិត្តប្រែ
ឃ្លាតឃ្លៀងវែងវែរ ពីព្រះបតិត្រ ស្រឡាញ់សុបណ្ណ ដល់ប៉ុនចំណិត
សក់សូមពិនិត្យ ដោយព្រះប្រាជ្ញា ៗ ទាល់តែគ្រុឌជ មានឫទ្ធិ
អំណាច កំហែងស្នេហា ខ្ញុំនៅសោគជាស្រី បេះអ៊ីទឹក ពិនរូបឲ្យជា
ចាំជួបក្សត្រក្សាន្ត ៗ សង្រេងជាទុក្ខ សង្រែងអាអុក ពិតពុំស្រាកស្រាន្ត
បើគ្រុឌមកទៀប នឹងហៀបធ្វើបាន ឲ្យក្ស័យព្រោះមាន បិតុគិតក្សត្រា ៗ

ក្រែងបានជួបវិញ បើពុំជួបមិញ សូមក្ស័យជន្មា ទូលទៅចេះតើ
មានបើនរណា នឹងឃើញដឿថា ចិត្តទៅទៀងត្រង់ ៗ ប៉ុន្តែសព្វថ្ងៃ
អន្ទរទេពត្រៃ ព្រឹកល្ងាចពុំបង់ សូមឲ្យគ្រុឌណាយ នឹងកាយពុំចង់
ស្នេហាជូនអង្គ មកព្រះបពិត្រ ៗ លុះប្រាំពីរថ្ងៃ គន្ធនរាងវៃ ទៅ
ដល់ស្ថានស្ថិត ប្រាប់ថាព្រះអង្គ ទ្រាំទ្រង់ទុក្ខក្តាត់ ខ្ញុំម្ចាស់ស្មុគចិត្ត
ស្មើក្ស័យជន្មា ៗ ញាប់ញ័រក្នុងចិត្ត ងងឹតមុខមាត់ ធ្វេសធ្វេចិន្តា
សន្ទប់ពុំដឹង ដំណឹងអាត្មា អ្នកគន្ធញា លបល្បួចប្រលែង ៗ ពុំដឹង
ខ្លួនសោះ គាត់ធ្វើចេះចោះ នេះតឹកម្មឯង គឺមោះក្នុងចិត្ត ពុំគិតបង់
ល្បែង ខ្ញុំម្ចាស់ទូលថ្លែង ពិតពុំមុសា ៗ ព្រះបាទព្រហ្មទត្ត រាជា
ចមក្សត្រ ស្តែងស្តាប់វាចា គាក៏ខ្ញួញខ្ញួល ឲ្យច្បូលចិន្តា ក្តៅក្នុងឧរ
ដូចភ្លើងប្រល័យ ៗ បើករសន្ធក៏រ ដោយអាជ្ញាក្លា ព្រះសូរខ្លាំង
ក្រៃ ត្រាស់ថាហ៏ស្តាប់ វាចាប់វៀះវៃ ករក្តួតដោះដៃ ដោះដោយ
មាយា ៗ អញជាចមក្សត្រ ឥស្សរាស្ត្ររដ្ឋ គ្រប់គ្រងនគរ ខ្សត់
អ្វីខ្មោចស្រី បំណើកគា ស្រីអញមានជា រយាប់សេសសល់ ៗ
វិខ្វនមេមួយ កុំបីមព្រួយ ដោះសារិលវល់ នឹងយកមេទុក ជូន
ស្រុកអំពល់ ទឹងព្រឹងដឹងដល់ ប្រទេសនានា ៗ បើគេដឹងរឿង ដឹង
វារក្សនកេរ្តិ៍ គេនឹងនិន្ទា រមាយាមេ សមតែជាកនា ពោងពាយ
ឲ្យវា អណ្តែតទឹកទៅ ៗ ទើបសមគំនិត មេបារបើកចិត្ត បេះក្នុង

បេះក្រៅ ត្រាស់ស្រេចក្សត្រក្សាន្ត បើកបន្ទូលហៅ អមាត្យចូលទៅ
ហើយផ្តែផ្តាំថា ៗ ឲ្យយកកាកី ដាក់ពោនពាយទ្វី ដូចដោយចិន្តា
អមាត្យទទួល បន្ទូលក្សត្រា ចុះចេញមីម្មា នាំនាងកាកី ៗ ទៅ
ដល់កំពង់ ស្រេចទើបដាក់អង្គ នៅពោនពាយទ្វី បណ្តែតប្រានទៅ
លឿនស្មោះចេញពី កំពង់នទី(១) ដូចព្រះអាជ្ញា ៗ ស្រេចទើបអមាត្យ
នាំគ្នាខ្ចីឃ្លាត វិលវិញយាត្រា ចូលទូលមហាក្សត្រ ព្រហ្មទត្តជា
ស្តេចស្តាប់ហើយថា សមមុខវាឯង ៗ

១ បទព្រហ្មគីតកាល ទឹងដំណាលបរោបែន ពីកាកីកណ្តែង
សាត់កណ្តាលសាគរ ៗ រលកបោកប្រានឆ្ងាយ សាត់ពោនពាយ
ដោយវាតា នាងភាំងភិតភ័យ លឿនសទ្ទិមសន្ទោចលន់ ៗ តែអង្គ
តែឯងឯក សែនសង្វេគចិត្តឆ្អែតឆ្អន់ ខ្សឹកខ្សួលអាលអួលអន់ ថប់ធុញ
ចិត្តគិតកណ្តែង ៗ នាងសោយសោកសែនសល់ ដោរដន់ដលនេត្រ
ល្ហាបល្ហែង ខ្ទត់ថប់អង្គឯង ប្រែបែរមុខមកមើលស្រុក ៗ ទឹកស្តាយ
សព្វសារសើរ ទូញបណ្តើរដោយទំនង ខ្ជាប់នៅស្រុកហោង សោយ
សម្បត្តិសម្បូណ៌បុណ្យ ៗ ជាធំលើសលែងស្រី ស្នំនារីតែឯងប៉ុន
ថ្កើងកេរ្តិ៍ថ្កើងយសលន់ ព្រួរព្រាយសព្វទិសទី ៗ អង្គអញឯងជាឯក
អភិសេកជាមហេសី រូបពន់ប្រវេណី ជាតិជាបមស្នំតាំងឡាយ ៗ

---

១ នទី ឬ. សំ. ស្ទឹង ឬទន្លេ ។ បុរាណច្រើនប្រើជា នាទី ។

ទុស្ដាយត្បូងត្រទ្រឹ ក្ដួងមហាវិចំរៀងកាយ រាំកំសាន្តកាយ ឥត
ឯទុក្ខទោសបៀតបាន ៗ ទុស្ដាយខែនសែនយស ល្អទុកាសសុខ
សម្រាន ស្ដាយស្រស់ស្រស់ទុទ្យាន តែងត្រសាលឥតឯឃ្លាត ៗ ស្ដាយ
បុណ្យបាននៅប្រាង្គណ៍ ប្រាសាទស្អាងប្រសើរស្អាត ទុកមម្លួឲ្យឃ្លាត
ព្រាត់ប្រាសមកនៅពោងពាយ ៗ តែខ្លួនអញឯកឯង អង្គកណ្ដែង
កណ្ដោចឆ្ងាយ កណ្ដាលទឹកទូលាយ ឥតអ្នកណាជាពីរអង្គ ៗ
មើលឆ្វេងបាត់ត្រើយសោះ មើលស្ដាំនោះងងឹតសូង មើលក្រោយរែង
លង្វើ មើលទៅមុខលង្វោបលង់ ៗ ឃើញតែទឹកទឹងមេឃ ខ្យល់
បោកបែកទឹកដោរជន់ រលកបោកពោកពន់ ពេកពុំស្ងប់ពុំស្ងាត់ឡើយ ៗ
មានទាំងហ្វូងមច្ឆា ហែបហែលហាមកបង្កើយ ពន្ទៀករោតឡើងហើយ
ខ្លួចខ្ទេកបែប្រែឆ្ងាយ ៗ សីងតែធាត់ធំ ៗ រូបរាំហែលលលាយ
លលេញដេញពោងពាយ ហែបត្របាក់បរិគោក្ដា ៗ នាងរែងកិតភ័យ
គាំង ស្ទុតស្ទាំងកាំងអស់អង្គា អង្គុយគន់មច្ឆា គាំងតែទុក្ខតែខ្ញុំយំ ៗ
ថាទុតិនេះទៅ ប្រាសលំនៅប្រាសអ្នកស្នំ ប្រាសព្រះរៀមឧត្ដម អង្គ
អនាថនៅកុំដឹង ៗ ឥឡូវនេះទឹងភ្ញា គេអ្នកណាជាទីពឹង ពំនាក់នៅ
អាទឹង គ្រាន់ប្រាស្រ័យជាក្ដូកាយ ៗ នាងគន់នាងគិតគ្រប់ រែងថែម
ថប់ឥតសោយ ទុកស្ទូះស្ទើរក្ស្លាយ នាងនទៀលនទាសទៅ ៗ លុះភ្ញាក់
មានស្មារតី ខ្ញុញទៀតពីក្សត្របមទៅ ហើយនាងនាជខ្ញុញទៅ ព្រះ

ឥសីសិទ្ធិព្រឹទ្ធា ៗ ថានុកាលអញកើត យកកំណើតក្នុងបុប្ផា គឺដើម
ការណិកា រសក្រអូបក្រអៃបហ្វង់ ៗ ព្រះគុណព្រះតាបស សោត
សប្បុរសយោត្រាត្រង់ យកខ្ញុំទៅក្រញូក្រុង ផ្គង់រក្សាសព្វពគ្រី ៗ
សន្ធតនាមចំពោះ តាមផ្កានោះឈ្មោះកាកី សម័យមួយចក្រី ស្តេច
ស្វែងស្ងួះទៅនមស្សការ ៗ ឥសីសួរដើមអាទិ៍ ជ្រាបវង្សជាតិទើប
អាចារ្យ លើកខ្ញុំកែវកុមារ ឲ្យព្រះបាទព្រះបង់បាន ៗ នានាំខ្ញុំដួច
ដល់ ព្រះមណ្ឌលមន្ទីរស្ថាន ទើបព្រះមហាក្សត្រក្សាន្ត អភិសេកជា
មហេសី ៗ នុស្តេចឡើយពុំគិត ពុំគាណាំតង់កប្រណី អាសូរខ្ញុំប្អូន
ស្រី ដ្បិតឥសីផ្តាំប្តេជ្ញ ៗ ទោះទោសខ្ញុំគ្គាំគ្គង់ គួរព្រះបង់ជូនប្អូនពា
ទៅឯឥសីតា ឬក្សត្រាទឹងឲ្យក្ស័យ គួរស្តេចទឹងសម្លាប់ ឲ្យខ្ញុំ
ស្លាប់នៅក្រុងកែ្រ ម្ចាស់អើយប្អូនមហាភ័យ ភិតរង់ស្ងាំងស្ងូទពន
ពេក ៗ នុយប់យូរទៅហើយ ម្ចាស់ប្អូនអើយប្អូនវិវេក រមិលមើល
ឃើញមេឃ យល់ចន្ទ្រាគាកពយ ៗ ព្រះចន្ទ្របរគ្រប់ះ ចែង
ស្រលះភ្លឺព្រោងព្រាយ ពពកសាត់លលាយ លលេលើមេឃាខណ្ឌ ៗ
ព្រះចន្ទ្រដូចព្រះបង់ គាពផង់ពយណាស់ណាន់ ដូចស្រីស្នំគាប់គាន់
គង់គាល់ហៀវនៅប្របគ្រីតី ៗ នុប្អូនធ្លាប់រង់នៅ នឹងព្រះចៅជាមហេសី
គឺកម្មកាយប្អូនស្រី នានាំនៃបទឹងគ្រុឃា ៗ កម្មស្តេចនាំប្រសព្វ នឹង
គន្លង់ទៀតពីគ្រា ទាំងនេះហេតុវេរា នឹងនិពសរៀមទៀតទៅ ៗ

ដូច្នេះតើទឹងថា អ្នកឯណាឯងឲ្យក្ដៅ គឺកម្មកាយនិត្យនៅ តែងអន្ទោល
តាមដោយដាន ៗ គ្រប់រូបគ្រប់នាមា ដូចឆាយាតែងតាមប្រាណ
ពុំដែលចាកចៀសបាន ទឹងវេកពៀកកម្មកាយ ៗ ខ្ញុំខុសប្តូទឹងខំ គិត
ផ្សេងៗឲ្យសប្បាយ តាមតែទេពតាំងឡាយ ជួយចម្រងចំរើនផង ៗ
កុំដឹងខ្លួនមានកម្ម ទឹងនាំនាំគ្រានេះម្តង កម្មក្រាស់ក្រៃកន្ទង លើស
លែងកម្មគេតាំងឡាយ ៗ ឲកម្មនេះកម្មពៀរ ជាតិទៀតកើតកម្មកាយ
កម្មក្រាស់អ៊ីទាល់ឡាយ គួរទឹងណាយទឹងទឹកបង់ ៗ មោះប្តីកម្មពីព្រេង
ឲ្យវង្វេងចិត្តកិសរង់ ពុំឲ្យអញគាប់គង់ ទឹងព្រះរៀមព្រះពជា ៗ
ឲព្រាប់រួមផ្ដឹមផ្ដុំ ទំពួបខ្ទុំមណ្ឌលា ប្រាកដប្រកបជា ចមព្រះមហាព្រះ
មហេសី ៗ ស្រណោះកាលធ្លាប់នៅ ទឹងព្រះចៅចមចក្រី នៃបទិត្យដិត
ប្រក្រតី គ្មានកៀសកោះកាយ ៗ មួយកាលនៅនាទី សួគ៌សិម្ពលី
សែនសប្បាយ គន្ធទង្វើលែបខាយ ឲ្យអន្ទកយរូបដល់ម៉្វេះ ៗ មក
ផង់ទុក្ខវេទនា ឲ្យឈឺផ្សាផ្សប់ដូច្នេះ ទ្រូង អឺយហាក់ទឹងប្រេះ ព្រោះ
បំណោះចំណាង់ឯង ៗ សមបាបពីបុព្វេ ឲ្យវៀចវេរៀះបង្វេង ឲ្យចេញ
ចាកចំបែង ប្រាសប្រាសាទប្រសើរសុខ ៗ ពីថ្ងៃនេះទៅហើយ ឲ
ខ្ញុំអើយតាំងតែទុក្ខ កប់ថ្ងៃតទៅមុខ សមទឹងក្សិណក្ស័យអសារ ៗ
បើស្លាប់នៅផែនដី បានឥសីសិលាចារ្យ ទឹងជួយជូនព្យាបាល ទឹង
នានាំទៅកុដី ៗ មកស្លាប់ម្តេចក្នុងទឹក ជ្រៅតន្ទឹកជាបំណាំ ត្រីផងរក

ទឹងស៊ី លេបប៉ីបេះប៉ោចបង់ ៗ ឆ្កួនអើយកំព្រា នៃអ្នកណាទឹង ស្រោចស្រង់ កើតមកតែឯកអង្គ កណ្ដែងកណ្ដាលគង្គា ៗ មាន ញាតិកាទឹងពឹង មានទុក្ខទឹងរិះរេក្យា ស្រោចស្រង់ពីគង្គា ទៅបំពួន បំពាក់បាន ៗ សង្ឃឹមព្រះដីកា អ្នកនៅនាព្រៃស្មសាន ឥតអ្នកនាំ ពណិជ៍មាន ពីនេះទៅឲ្យបានដល់ ៗ ឆ្ងាយផែនដីទី តែភ័រងអំពល់ អំពើអង្គអកុសល មានតែទុក្ខតែខ្ញាយំ ៗ ណាខ្លាចអស់ត្រីផង ហែល ត្រសងសឹងធំ ៗ រលកលោតប៉ុនភ្នំ ផ្ទុំបណ្ដែតបណ្ដោយខ្យល់ ៗ មុខគួរ ឲ្យអនិច្ចា រងវេទនាសោកសែនសល់ ទន្លឹងណាទឹងដល់ មានតែទល់តែ ទុក្ខនៅ ៗ រងទុក្ខរងខ្ញូទន់ អង្គឥតស្រទន់ឥតស្រាកក្ដៅ សន្ទឹកសន្ធៃ នៅ សូន្យលន្ទង់លន្ទោចក្ដាត់ ៗ សង្រេងសង្រែង ទុក្ខកន្ទង់កន្ទេង បិត្ត វែងផ្អូនវែងផ្អែតផ្អិត វែងអាណិតអនាថប្រាណ ៗ ទល់ទុក្ខ លើពោងពាយ អណ្ដែតឆ្ងាយពីត្រើយត្រាណ ក្នុងមហាសមុទ្រមាន តែរលករលាមខ្យល់ ៗ បក់បោកលោតប៉ប្លង ប៉ប្លឹមក្នុងទឹកវិលវល់ កណ្ដែងកណ្ដាលផល លុះគំរប់សត្តទិវ ៗ រលកបោកពោងពាយ បែក ខ្ទាត់ខ្ទាយចេញពីគ្នា លិចលង់នាងក្នុងមហា សមុទ្រមិញក្ស័យជីវ៍ ៗ ស្រីស្រីណាគាប់ កុំត្រងត្រាប់កែវកាកី គំនិតក្បត់ចិត្តប្ដី ពោលស្វាមី សេពសហាយ ៗ កំពុងពេញស្នេហា ចិត្តកិរិយាទឹកទីរណាយ រជិត ទៀតទាំងឆាយ ព្រោះតាប់ចិត្តចង់សម្ពន្ធ ៗ គួរកាន់ច្បាប់ធម្មា តាម

គាថាប្រសើរលន់ ទុកឲ្យនរជាតិជន ជាប្រសិទ្ធិប្រសើរក្រៃ ៗ គួររៀនរកខឹមសារ ព្រះអាចារ្យថែងកែខៃ ជាបុណ្យបានខ្លួនថ្លៃ ពិតពំនឹងពំនាក់កាយ ៗ កុំធ្វើដូចស្ត្រី កែវកាកីកេរ្តិ៍និរណាយ និរទេសអង្គអន្តរាយ រូបកណ្ដែងកណ្ដោចលន់ ៗ ព្រោះតែពីគំនិត បើកបោរចិត្តស្រាលសរសេន់ ទាល់តែអង្គឯងអ- ន្តរាយរូបរងទុក្ខពេកក្តាត់ ៗ ទីបាបនោះឯងមកផ្ត- ន្ទាទាន់ហាន់ដល់ដូចចិត្ត កំណាចព្រោះគំនិត ត្រិះត្រឹមត្រេកត្រង់ត្រអាល ៗ មករងវេទនា តែឯកាឯកោកាល ណោះនៅនាកណ្ដាល មហាសមុទ្រទល់ទុក្ខា ៗ ស្លាប់ទៅនៅនរក រងទោសទុក្ខតាមវេក លុះដល់មកសាសនា ព្រះពុទ្ធយើងនេះបានត្រាស់ ៗ ទើបបន្ទូលទេសនា ជាគាថាដុំជាតក់ច្បាស់ ជាកាកីនោះផ្លាស់ ជាតិជានាងចិញ្ចាជាក់ ៗ វិនាយនាងកូវេន សិល្បសាស្ត្រក្មេនសិទ្ធិស័ក្តិ បរវិលវេងផងអគ្គ- សាវកគឺមោគ្គល្លាន ៗ ឯអង្គព្រះព្រហ្មទត្ត វិលវិងថ្លាត់មិញមកបាន ជាអគ្គសាវកញ្ញាណ គឺអង្គព្រះសារីបុត្រ ៗ ឯគ្រុឌពជបក្សា គឺព្រះសម្មាសម្ពុទ្ធ ត្រាស់ទ្រង់បុណ្យបរិសុទ្ធ តែងទេសន៍ទូន្មានសព្វសត្វ ៗ ឲ្យលុះដោយមគ្គផល បរិបូណ៌ដល់ព្រះអរហត្ត សេពសោយសុខសម្បត្តិ និញ្វានពន់[១]ពីវេក ៗ ដំណើរនាងកាកី ប្រែសេចក្តីសៀមភាសា ជាពាក្យខ្មែរកាព្យ សូមបេរឿងចប់ម្ល៉េះហោង ៗ

---

១ ពន់ ក្នុងទីនេះប្រែថា រួច ឬ ផុត ។



ប្រទេសលាវ-សៀម ស្រុកឆៀងហ្មៃ វត្តប្រិស៊ីង មើលចំហៀងខាងមុខ

# សុភាសិតវាចាកថា

# របស់ព្រះគ្រូញាណសំវរ ញាណ-ឈឹន

## (គ)

កាលទ្រង់សំដែងអនត្តលក្ខណសូត្រ បញ្ចវគ្គិយភិក្ខុទាំង ៥ រូប បានដំកល់នៅក្នុងទីជាព្រះអរហន្ត ។

ថ្ងៃជាខាងក្រោយទៀត បុរស ៥៥ នាក់ មានយសកុលបុត្រជាដើម បានលុះព្រះអរហត្តផល ក៏ព្រោះបានស្តាប់ទេសនានេះ ។

កាលទ្រង់សំដែងអាទិត្តបរិយាយសូត្រ ក្នុងគយាសីសប្រទេស[១] ជដិលមួយពាន់នាក់ បានលុះព្រះអរហត្តផល ។

កាលទ្រង់សំដែងតិរោកុឌ្ឌសូត្រ ពួកជន ៨ ហ្មឺន ៤ ពាន់នាក់ បានក្រេបផឹកអម្រឹតរស គឺរសក្នុងព្រះនិញ្វាន ។

កាលទ្រង់សំដែងខទិរង្គារជាតក សត្វ ៨ ហ្មឺន ៤ ពាន់ បានក្រេបផឹកអម្រឹតរស គឺរសក្នុងព្រះនិញ្វាន ។

កាលទ្រង់សំដែងបាកយនសូត្រ សត្វ ១៤ កោដិ បានក្រេបផឹកអម្រឹតរស គឺរសក្នុងព្រះនិញ្វាន ។

កាលទ្រង់សំដែងព្រះអភិធម្ម សត្វ ៨០ កោដិ បានក្រេបផឹកអម្រឹតរស គឺរសក្នុងព្រះនិញ្វាន ។

កាលទ្រង់សំដែងសក្កបញ្ហសូត្រ ទេវតា ៨ ហ្មឺន បានក្រេបផឹកអម្រឹតរស គឺរសក្នុងព្រះនិញ្វាន ។

---

១ ជាឈ្មោះស្រុកមួយដម្បន់ បែកខាងតិណ្ឌៀ ក្នុងពុទ្ធសម័យ ។

នៅមានច្រើនជាងនេះ ដោយសែនកោដិ លើសកំឡាំងបញ្ញានឹងកប់សត្វទាំងនោះបាន ។

✓ គុណអ្នកស្ដាប់សុភាសិតចំពោះព្រះភក្ត្រចប់ ។

## គុណអ្នកស្ដាប់សុភាសិតជាសាធារណៈ

សេចក្ដីថា កិរិយាស្ដាប់ធម៌ទេសនាទាំងអស់ក្ដី ស្ដាប់ចំរៀងដែលប្រកបដោយធម៌ក្ដី ក៏រាប់ថា ស្ដាប់សុភាសិតទាំងអស់នោះ សមដូចមាននិទានថា កាលព្រះសម្ពុទ្ធជាម្ចាស់ទ្រង់បរិនិព្វានហើយ មានភិក្ខុ ៦០ រូបក្នុងសីហលទ្វីប ជាអ្នករៀនវិបស្សនា បានឮចំរៀងមនុស្សស្រីម្នាក់អ្នករក្សាស្រែក្នុងស្រុកលង្កា ច្រៀងប្រកបដោយសំវេជនីយធម៌ ៤ មាត់ គឺៈ កើត, ចាស់, ឈឺ, ស្លាប់ ភិក្ខុទាំងនោះកាន់យកមកពិចារណាជាអារម្មណ៍ ក៏លុះព្រះអរហត្តផលក្នុងពេលនោះ ។

មានភិក្ខុមួយរូបទៀត ឈ្មោះតិស្សៈ ជាអ្នករៀនវិបស្សនាដែរ បានឮចំរៀងមនុស្សស្រីម្នាក់ បុះកាប់ផ្កាឈូកក្នុងស្រះច្រៀងដោយទំនុកថា ផ្កាឈូកអើយរីកស្រស់តែពេលព្រឹក ល្ងឹកបើពេលល្ងាចស្វិតស្រពោនវិញ ដោយកំដៅព្រះអាទិត្យ មានឧបមាយ៉ាងណា មនុស្សសត្វទាំងឡាយអើយ តែងស្វិតស្រពោនជ្រួញជ្រីវទន់ទោរទៅដោយកំឡាំងជរាញាំញីគ្របសង្កត់ ក៏មានឧបមេយ្យដូចផ្កាឈូកនោះដែរ ។

តិស្សភិក្ខុកាន់យកមកពិចារណាជាអារម្មណ៍ ក៏បានលុះព្រះអរហត្ត-ផលក្នុងពេលនោះ ។

មានរឿងមួយទៀតថា កាលក្នុងបវេត្នោះពុទ្ធកាលមានបុរសម្នាក់នាំកូនប្រុសរបស់ខ្លួន ៧ នាក់ដើរមកពីព្រៃ លុះដើរមកដល់ស្រុកបានឮចំ-រៀងមនុស្សស្រីម្នាក់កំពុងស្រែកអង្គុះច្រៀងដោយពិទុកថា សរីរាង្គកាយយើងនេះ គឺអំណាចផ្ញាំញីឲ្យស្អិតស្រោបដែញដើរទៅ ពណ៌សម្បុរស្បែកដែលអាស្រ័យសរីរាង្គកាយ យើងនេះសោត ក៏បែកធ្លាយទៅដោយកំឡាំងមរណៈ សរីរាង្គកាយយើងនេះ តែងប្រចាំដោយគ្រឿងចង្អៀតចង្អល់នៃមូត្រគឺសេចក្តីស្លាប់ ជាសម្បុកនៃពាធផ្សេង ជាកន្លែងសម្រាប់ដាក់របស់ស្មោកគ្រោកផ្សេង ៗ ជាភាជន៍សម្រាប់ដាក់លាមករបស់មិនស្អាត សរីរាង្គកាយនេះប្រហែលដោយកំណាត់ឈើ ។

បុរសជាបិតាព្រមទាំងកូនទាំង ៧ នាក់ បានកាន់យកមកពិចារណាជាអារម្មណ៍ ក៏បានសម្រេចពោធិញ្ញាណជាព្រះបច្ចេកពុទ្ធទាំងអស់គ្នាគ្រានោះឯង ។

និទានទាំងពីររឿងដែលនាំមកនេះ អ្នកប្រាជ្ញរាប់ថា ជារឿងនោះជាសុភាសិតវាចាដោយពិត ។

គុណអ្នកស្តាប់សុភាសិតសភាធារណកថា ។

សុភាសិតសូត្រដ៏ប្រកបដោយលក្ខណ ៤ផង ៥ផង ដូចសំដែងមកដោយសង្ខេបនេះ បានឈ្មោះថាមង្គល ព្រោះនាំមកនូវសេចក្ដីសុខក្នុងលោកទាំងពីរ គឺលោកិយនិងលោកុត្តរៈ ។

បានជាព្រះសម្មាសម្ពុទ្ធទ្រង់មានព្រះពុទ្ធដីកាដូនទៀតថា ឥមេហិ ខោ ភិក្ខវេ ចតូហិ អង្គេហិ សមន្នាគតា វាចា សុភាសិ-តា ហោតិ ដូច្នេះជាដើម សេចក្ដីប្រែដូចមានមកខាងដើមរួចហើយ ។

សំដែងមកក្នុងមង្គលជាគំរប់ ១០ អស់សេចក្ដីតែប៉ុណ្ណេះ ។

លំដាប់តពីនេះនឹងរៀបរៀងក្នុងតិរច្ឆានកថា ដែលជាពាក្យគឺអ្នកប្រាជ្ញទាំងឡាយមានព្រះពុទ្ធជាដើម តែងតិះដៀលថា ជាពាក្យមិនពីរោះមិនជាទីនាំមកនូវសម្បត្តិសួគ៌និងសម្បត្តិនិព្វាន តាមន័យដូចមានក្នុងគម្ពីរទេសកង្គុត្តរព្រមទាំងអដ្ឋកថា និងពាក្យកែណៈមានក្នុងទុព្ភាសិត-វណ្ណនាប៉ែកខាងវិន័យ និងពាក្យដែលមានក្នុងគម្ពីរធម្មបទដ្ឋកថា ដូច្នេះជាដើមថា:

អ្នកជាចោរ អ្នកជាជនពាល អ្នកជាមនុស្សវង្វេង អ្នកជាឧដ្ឋ អ្នកជាគោ អ្នកជាលា អ្នកជាសត្វនរក អ្នកជាសត្វតិរច្ឆាន អ្នកមិនមានសេចក្ដីសុខ អ្នកមានតែសេចក្ដីទុក្ខ បើភិក្ខុពោលឡកឡឿយ បំអកបំអន់ដេរប្រទេចគេដោយពាក្យទាំង ១០ ម៉ាត់នេះ នឹងត្រូវអាបត្តិទុព្ភាសិត

កល់ៗ ម៉ាត់ បើសាមណេរនឹងត្រូវទណ្ឌកម្ម បើគ្រហស្ថនឹងត្រូវទោស ក្នុងវចីកម្មមិនលែងឡើយ ។

ប៉ុន្តែក្នុងទីនេះ មានបំណងនឹងអធិប្បាយនូវតិរច្ឆានកថា ២៦ ម៉ាត់ ដែលមានក្នុងគម្ពីរទេសកន្តគា ព្រមទាំងអដ្ឋកថា ដូចមានសេចក្តីតទៅនេះ:

១ រាជកថា និយាយអំពីស្តេចថា មានអានុភាពធំយ៉ាងនេះៗ ឬនិយាយថា ស្តេចឯណោះមានរូបល្អគួរជាទីគាប់ចិត្តរមិលមើល ដូច្នេះជាដើម (ដោយដំរេក មិនគួរ បើនិយាយថា ស្តេចអង្គនោះមានបុណ្យគួរជាទីអស្ចារ្យ ហើយមានសទ្ធាជ្រះថ្លា ឬនិយាយថា សូម្បីមានបុណ្យដល់ម្លោះគង់ធន់ទ្រាំនឹងមច្ចុរាជមិនបាន ដូច្នេះទើបគួរ) ។

២ ចោរកថា និយាយអំពីមូលទេវចោរ មេឃមាលចោរថា មានអានុភាពធំយ៉ាងនេះៗ ជាដើម ។

៣ មហាមត្តកថា និយាយអំពីមហាមាត្យខ្លាំងពូកែជាដើម ។

៤ សេនាកថា និយាយអំពីពលសេនា ឬនិយាយអំពីកងទ័ពជើងគោកមានអង្គ ៤ គឺ: ដំរី, សេះ, រថ, ពលថ្មើរជើង ជាដើម ។

៥ ភយកថា និយាយអំពីភ័យ (អាសន្នគួរខ្លាច) ជាដើម ។

៦ យុទ្ធកថា និយាយអំពីចម្បាំងការគេ ដោយពាក្យថា ជនឈ្មោះឯណោះ គឺជនឯណោះសម្លាប់ហើយ ជាដើម ។

៧ អន្នកថំ និយាយអំពីបាយ ។

៨ បានកថំ និយាយអំពីទឹកថា ខ្ញុំស៊ីបាយផឹកទឹកមានសម្បុរយ៉ាងនេះ មានរសយ៉ាងនេះ ឬថា ទឹកប្រៃ សាបជាដើម ។

៩ វត្ថកថំ និយាយអំពីសំពត់ ។

១០ សយនកថំ និយាយអំពីទីដំណេក ។

១១ មាលាកថំ និយាយអំពីកម្រងផ្កា ។

១២ គន្ធកថំ និយាយអំពីគ្រឿងក្រអូប ។

(បើនិយាយថា ខ្ញុំបានថ្វាយ បាយ ទឹក សំពត់ ដំណេក កម្រងផ្កា គ្រឿងក្រអូប ដល់អ្នកមានសីល ឬដល់ចេតិយដូច្នេះ ទើបគួរ ។

១៣ ញាតិកថំ និយាយអំពីញាតិថា ញាតិរបស់យើងក្លៀវក្លា ឬថា ញាតិរបស់យើងតែងត្រេចទៅដោយ យានជំនិះដ៏វិចិត្រយ៉ាងនេះ ។ ដោយជម្រែក មិនគួរ បើនិយាយថា ញាតិរបស់យើងតែងធ្វើកម្មជាប្រយោជន៍ ឥឡូវលោកធ្វើកាលកិរិយាស្លាប់ទៅហើយ ដូច្នេះ ទើបគួរ ។

១៤ យានកថំ និយាយអំពីយានជំនិះថា ខ្ញុំតែងត្រេចទៅដោយយានជំនិះយ៉ាងនេះៗ ជាដើម បើនិយាយពាក្យដូច្នេះដោយជំរេក មិនគួរ បើនិយាយថា ពីមុនខ្ញុំបានថ្វាយស្បែកជើងយ៉ាងនេះដល់សង្ឃដូច្នេះជាដើម ទើបគួរ ។

១៥ គាមកថំ និយាយអំពីអ្នកស្រុក ដូចពាក្យថា អ្នកស្រុកឯណោះជាអ្នកក្លៀវក្លាដោយអំណាចមានលំនៅស្ដុកស្ដម្ភ មានបាយបរិភោគងាយ អ្នកស្រុកឯណោះមិនក្លៀវក្លា ដោយអំណាចមានលំនៅមិនស្ដុកស្ដម្ភ មានបាយស៊ីក៏ក្រ ពោលដូច្នេះជាដើមដោយដម្រេក មិនគួរ បើពោលថា អ្នកស្រុកឯណោះធ្វើកម្មជាប្រយោជន៍ មានសទ្ធាថា ឥឡូវធ្វើកាលកិរិយាស្លាប់ទៅហើយ ដូច្នេះ ទើបគួរ ។

១៦ និគមកថំ និយាយអំពីអ្នកនិគម ស្រុកដែលមានពួកអ្នកជំនួញដើរគោកច្រើន ។

១៧ នគរកថំ និយាយអំពីក្រុង (ទីប្រជុំមនុស្សបរិបូណ៌) ។

១៨ ជនបទកថំ និយាយអំពីអ្នកជនបទ ប្រទេសជាប់ដោយមនុស្សជាតិដេរដាស ឬប្រទេសជាផ្លូវដើរចេញចូលរបស់ជន ពាក្យទាំង ៣ មាត់ គឺនិគមកថំ នគរកថំ និងជនបទកថំ មានអធិប្បាយដូចគាមកថំដែរ ។

១៩ ឥត្ថីកថំ និយាយអំពីស្រីថា មានរូបល្អ ទ្រង់ទ្រាយល្អជាដើម ដោយដម្រេក មិនគួរ បើនិយាយថា ស្រីមានសទ្ធាជ្រះថ្លា ឥឡូវធ្វើកាលកិរិយាស្លាប់ទៅហើយ ដូច្នេះ ទើបគួរ ។

២០ សូរកថំ និយាយអំពីយោធាឈ្មោះនន្ទមិត្តដ៏ក្លៀវក្លា ដូច្នេះជាដើម ដោយសេចក្ដីដំរេក មិនគួរ បើនិយាយថា យោធានោះៗ មាន

សេចក្ដីជ្រះថ្លា ឥឡូវធ្វើកាលកិរិយាស្លាប់ទៅហើយ ដូច្នេះ ទើបគួរ ឬនិយាយអំពីទឹកស្រវឹងច្រើនប្រការដោយដំរេក មិនគួរ បើនិយាយដោយអំណាចទោសគួរខ្លាច គួរកើតចាល ទើបគួរ ។

៦១ វិសិខាកថំ និយាយអំពីច្រកតូចច្រកធំ ដូចពាក្យថា ច្រកឯណោះមានមនុស្សក្រៀវក្រា ដោយអំណាចមានទីលំនៅស្ដុកស្ដម្ភ មនុស្សក្នុងច្រកឯណោះ មិនក្រៀវក្រា ព្រោះមានទីលំនៅមិនស្ដុកស្ដម្ភ ពោលដូច្នេះដោយដំរេក មិនគួរ បើពោលថា មនុស្សក្នុងច្រកឯណោះៗ មានសទ្ធាជ្រះថ្លា ឥឡូវធ្វើកាលកិរិយាស្លាប់ទៅហើយ ដូច្នេះ ទើបគួរ ។

៦២ កុម្ភទាសីកថំ និយាយអំពីខ្ញុំស្រីអ្នកដងទឹក ដោយពាក្យថា ស្រីនេះឈ្លាសក្នុងការរាំនិងច្រៀង គួរជាទីមើលគួរជាទីស្ដាប់ ពោលដូច្នេះជាដើម ដោយដំរេក មិនគួរ បើពោលថា ទាសីនោះមានសទ្ធាដូច្នេះ ទើបគួរ ។

៦៣ បុព្វេបេតកថំ និយាយអំពីញាតិដែលធ្វើកាលកិរិយាទៅកាន់បរលោកហើយ សេចក្ដីអធិប្បាយដូចក្នុងញាតិកថាដែរ ។

៦៤ នានត្តកថំ និយាយពាក្យផ្សេងៗ ដែលលើសសល់ចាកវិមុត្តិ គឺពាក្យផ្ដេសផ្ដាសមិនជាប្រយោជន៍ ។

៦៥ លោកក្ខាយិកំ និយាយពាក្យរៀបរាប់នូវការយកគតិរបស់លោក គឺគំនិតពុះរបស់សត្វ ដូចពាក្យថា អ្នកណាបង្កើតលោក អ្នកឯណោះនិម្មិត

លោក ក្អែកសព្រោះមានផ្អឹងស កុកក្រហម[១] ព្រោះមានឈាមក្រហម ដូច្នេះជាដើម ។

២៦ សមុទ្ទក្ខាយិកំ និយាយអំពីសមុទ្រ ដូចពាក្យថា សមុទ្រជ្រៅយ៉ាងណា ដូច្នេះជាដើម ។

ពាក្យទាំង ២៦ យ៉ាងនេះជាតិរច្ឆានកថា គ្រហស្ថនិងបព្វជិតមិនត្រូវពោលឡើយ ។

កាលបើគ្រហស្ថនិងបព្វជិតទាំងឡាយ បានវៀរចាកតិរច្ឆានកថាទាំងនេះរួចហើយ ត្រូវខំព្យាយាមពោលនូវកថាវត្ថុ ១០ យ៉ាងចុះ ព្រោះកថាវត្ថុទាំង ១០ យ៉ាងនេះ ជាទីសប្បាយរបស់ព្រហ្មចារីបុគ្គល ហើយជាពាក្យរាប់ចូលក្នុងសុភាសិតសូត្រផង ។

ឯកថាវត្ថុទាំង ១០ យ៉ាងនោះគឺៈ អប្បិច្ឆកថា និយាយនូវពាក្យដែលនាំមកនូវគុណគឺសេចក្តីមិនប្រាថ្នា ប្រការ ១ សន្តុដ្ឋីកថា និយាយនូវពាក្យនាំឲ្យកើតសេចក្តីសន្តោស[២] ប្រការ ១ បវិវេក[៣]កថា និយាយនូវពាក្យដែលដល់នូវសេចក្តីវិវេក (ការស្ងាត់) មានកាយវិវេកជាដើម

---

១ ក្នុងអដ្ឋកថាវិន័យខ្លះថាកុកខ្មៅ ឯក្នុងទីនេះថា កុកក្រហមវិញ ។ (មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយទសកនិបាត) ។ ២ មាន ៣ យ៉ាងគឺ យថាលាភសន្តោស ត្រេកអរតាមគួរក្នុងបច្ច័យ ៤ ដែលស្វែងរកបានមក ១ យថាសារុប្បសន្តោស ត្រេកអរក្នុងបច្ច័យ ៤ ដ៏សមរម្យដល់ខ្លួន ១ យថាពលសន្តោស ត្រេកអរក្នុងបច្ច័យ ៤ តាមគួរដល់កំឡាំង ១ សន្តោស

ផង . . . . .

ប្រការ ១ អសំសគ្គកថា និយាយសរសើរនូវសេចក្ដីប្រតិបត្តិដែលមិនច្រឡំដោយពួកដោយគណប្រការ ១ វិរិយារម្ភកថា និយាយនូវវិធីដែលផ្ដើមនូវសេចក្ដីព្យាយាមប្រការ ១ សីលកថា និយាយអំពីសីលប្រការ ១ សមាធិកថា និយាយអំពីសមាធិប្រការ ១ បញ្ញាកថា និយាយអំពីវិបស្សនាបញ្ញាប្រការ ១ វិមុត្តិកថា និយាយអំពីអរហត្តផលវិមុត្តិប្រការ ១ វិមុត្តិញាណទស្សនកថា និយាយអំពីបច្ចវេក្ខណញាណប្រការ ១ ។

រួមជាកថាវត្ថុ ១០ ប្រការ កថាវត្ថុទាំង ១០ ប្រការនេះឯងហើយ ដែលហៅថា សប្បាយកថា រាប់ថាជាសុភាសិត ។

សុភាសិតដែលរៀបរៀងមកក្នុងទីនេះ ខ្ញុំបានដកស្រង់យកអំពីគម្ពីរមង្គលត្ថទីបនីអដ្ឋកថាមង្គលសូត្រ និងគម្ពីរអង្គុត្តរនិកាយទសកនិបាត ព្រមទាំងគម្ពីរធម្មបទដ្ឋកថាខុទ្ទកនិកាយ និងគម្ពីរព្រះវិសុទ្ធិមគ្គ ជាសេចក្ដីសង្ខេបត្រឹមនេះ មិនបានជាសេចក្ដីពិស្ដារទេ ក៏សន្មតថាចប់សុភាសិតកថាតែប៉ុណ្ណេះ ។

កាលបើចប់ហើយ សូមឱ្យរាយសេចក្ដីសុខសេចក្ដីចំរើនគ្រប់ប្រការដល់អស់លោក - អ្នកដែលបានមើលបានស្ដាប់សព្វកាលតទៅហោង ។

---

ទាំង ៣ ប្រការនេះចែកចេញជាប្រភេទមាន ១២ ប្រការ ដោយអំណាចបច្ច័យទាំង ៤ គឺ ចីវរប្បច្ច័យ បិណ្ឌបាតប្បច្ច័យ សេនាសនប្បច្ច័យ គិលានភេសជ្ជប្បច្ច័យ មានពិស្ដារក្នុងសន្តុដ្ឋីកថា ទីបនី បើជាគ្រហស្ថវិញ គួរសន្ដោសតែក្នុងភរិយារបស់ខ្លួន តាមសមគួរ ។ ៣ វិវេក ៣ យ៉ាងគឺ ១ កាយវិវេក ស្ងាត់កាយគឺចូលទៅនៅក្នុងទីស្ងាត់ ២ ចិត្តវិវេក ស្ងាត់ចិត្តចាកនីវរណ៍ ៣ ឧបធិវិវេក ស្ងាត់ចាកឧបធិកិលេស ។

## គាថជម៉ផ្សេង ៗ

### អាយុរបស់មនុស្ស ១០ ភាគ

១០ ឆ្នាំទី ១ មន្ទទសក: ១០ ឆ្នាំនៃសេចក្តីឯតអគតិតាំងតែ ១ ដល់ ១០ ឈប់រាប់ថា ជាកូនក្មេងតូចកំពុងតែរពឹស ៗ

១០ ឆ្នាំទី២ ខិឌ្ឌាទសក:១០ ឆ្នាំនៃសេចក្តីកំពុងតែចូលចិត្តលេងតាំងតែអាយុ ១០ ដល់ ២០ ឆ្នាំ ពេញទៅដោយសេចក្តីគាប់ចិត្តក្នុងការលេង ៗ

១០ ឆ្នាំទី ៣ វណ្ណទសក: ១០ ឆ្នាំនៃពណ៌សម្បុរ តាំងតែអាយុ ២០ ដល់ ៣០ ឆ្នាំ រូបឆោមក៏ពេញបរិបូណ៌ពេញទី ៗ

១០ ឆ្នាំទី ៤ ពលទសក: ១០ ឆ្នាំនៃកំលាំង តាំងតែអាយុ ៣០ ឆ្នាំដល់ ៤០ ឆ្នាំ កំលាំងនឹងសេចក្តីរឹងប៉ឹងឡើងដល់កំណត់ទីបំផុត ៗ

១០ ឆ្នាំទី ៥ បញ្ញាទសក: ១០ ឆ្នាំនៃបញ្ញា តាំងតែអាយុ ៤០ ដល់ ៥០ ឆ្នាំ បញ្ញាចំរើនពេញទី ទោះបីល្ងង់ខ្លៅក៏កើតសតិបញ្ញា បើសតិបញ្ញាមានតិចក៏កំណត់នៃវយ:នេះ ៗ

១០ ឆ្នាំទី ៦ ហានិទសក: ១០ ឆ្នាំនៃសេចក្តីសាបសូន្យ តាំងតែអាយុ ៥០ ដល់ ៦០ ឆ្នាំ សេចក្តីស្រឡាញ់នៃការលេងពណ៌សម្បុរបញ្ញាកំលាំងក៏ទោរទន់បន្តិចម្តង ៗ ក្នុងវយ:នេះ ៗ

១០ ឆ្នាំទី ៧ បក្ការទសក: ១០ ឆ្នាំនៃសេចក្តីទ្រុឌទ្រោម តាំងតែអាយុ ៦០ ដល់ ៧០ ឆ្នាំ ខ្នងកោងទៅដោយលំដាប់ ៗ

១០ ឆ្នាំទី ៨ វង្កទសក: ១០ ឆ្នាំនៃសេចក្ដីជ្រុលជ្រក តាំងតែអាយុ ៧០ ដល់ ៨០ ឆ្នាំ ខ្លួនកោងគមបង្អោនចុះដូចបន្ទោលនង្គ័ល ។

១០ ឆ្នាំទី ៩ មោមូហទសក: ឬ មូឡ្ហទសក: ១០ ឆ្នាំនៃសេចក្ដីវង្វេង តាំងតែអាយុ ៦០ ដល់ ៩០ ឆ្នាំ របស់ដែលសំគាល់ចាំទុករមែកម ៗ

១០ ឆ្នាំទី ១០ សយទសក: ១០ ឆ្នាំនៃការដេក តាំងតែអាយុ ៩០ ដល់ ១០០ ឆ្នាំ ជាអាយុដែលដម្រង់ជីវិតនៅដោយឥរិយាបថដេក ៗ

(វិសុទ្ធិមគ្គ)

## ធនញ្ជយោវាទ

(ឱវាទរបស់ធនញ្ជយសេដ្ឋីប្រដៅនាងវិសាខា) ១០

១ អន្តោអគ្គិ ពហិ ន នីហាតព្វោ ភ្លើងខាងក្នុងកុំឲ្យនាំចេញទៅក្រៅ

២ ពហិអគ្គិ អន្តោ ន បវេសេតព្វោ ភ្លើងខាងក្រៅកុំនាំចូលក្នុង

៣ ទទន្តស្សេវ ទាតព្វំ គួរឲ្យដល់បុគ្គលដែលគួរឲ្យ ·

៤ អទទន្តស្ស ន ទាតព្វំ កុំឲ្យដល់បុគ្គលដែលមិនគួរឲ្យ

៥ ទទន្តស្សាបិ អទទន្តស្សាបិ ទាតព្វំ គេឲ្យឬមិនឲ្យក៏ត្រូវតែឲ្យ

៦ សុខំ និសីទិតព្វំ គួរអង្គុយឲ្យជាសុខ

៧ សុខំ ភុញ្ជិតព្វំ ហូបស៊ីឲ្យជាសុខ

៨ សុខំ និបជ្ជិតព្វំ គួរដេកឲ្យជាសុខ

៩ អគ្គិ បរិចរិតព្វោ គប្បីបូជាភ្លើង

១០ អន្តោទេវតា នមស្សិតព្វា គប្បីនមស្ការទេវតាក្នុងផ្ទះ ។

អធិប្បាយ — ១ គឺកុំឲ្យនាំទោសខាងក្នុងផ្ទះចេញទៅក្រៅ ២ កុំឲ្យនាំពាក្យទិទ្យាក្រៅផ្ទះមកក្នុងផ្ទះ ៣ អ្នកណាឲ្យរបស់ដល់យើង ទើបឲ្យគេវិញ ឬអ្នកណាខ្ចីអ្វីហើយទឹងសងវិញ ទើបឲ្យខ្ចី ៤ អ្នកណាមិនឲ្យអ្វីសោះឡើយ ក៏មិនត្រូវឲ្យអ្វីគេ ៥ ញាតិបំណែកខាងប្តីឬខាងប្រពន្ធក៏តាម ដែលក្រីក្រមកសូមពឹងគេមានអ្វីស្នងគុណ ឬមិនមានក៏តាម គួរជួយសង្គ្រោះគេ ៦ ម្តាយរបស់ប្តីឪពុករបស់ប្តី ឬប្តីឈរធ្វើការ កូនប្រសាមិនត្រូវអង្គុយស្ងៀម កាលគេឈរ ទើបយើងឈរចង ៧ មិនត្រូវបរិភោគមុនឪពុកក្មេកម្តាយក្មេកឬស្វាមី រកឲ្យគេទទួលទានស្រេចហើយ ទើបបរិភោគខាងក្រោយ ៨ ភ្ញាក់មុន ដេកជាក្រោយ ចាត់ចែងបដិបត្តិឲ្យគេលក់មុនហើយ ទើបដេក ៩ ឲ្យកោតក្រែងឪពុកក្មេកម្តាយក្មេកឬស្វាមីដូចជាគំនរភ្លើងឬពស់ពិស ១០ ឲ្យគោរពឪពុកក្មេកម្តាយក្មេកឬស្វាមីដូចជាគោរពទេវតា ។

(វិសាខាវត្ថុ ធ. ១)

## សីលសិក្ខាបទទី ២ មានអានិសង្ស ១១ ។

១ មហទ្ធនត្តា មានទ្រព្យច្រើន ២ បហុតធនធញ្ញតា មានរបស់របរ និងអាហារបរិបូណ៌ ៣ អនន្តភោគតា កេរភោគទ្រព្យបានរកទីបំផុតគ្មាន ៤ អនុប្បន្នភោគុប្បត្តិតា ភោគទ្រព្យដែលមិនទាន់បានក៏បាន ៥ ឧប្បន្នភោគថាវរតា ភោគទ្រព្យដែលបានហើយក៏ខ្ជាប់ខ្ជួន ៦ ឥច្ឆិតានំ ភោគានំ ខិប្បប្បដិលាភិតា កេរបស់ដែលប្រាថ្នាបានរហ័ស ៧ អសាធារណភោគតា សម្បត្តិមិនខ្វាត់ខ្វាយដោយពាលភ័យ ចោរភ័យ ឧទកភ័យ អគ្គិភ័យ ឬញាតិឧបោក ៨ អសាធារណធនប្បដិលាភិតា កេទ្រព្យបានដោយមិនត្រូវចែក ៩ លោកុត្តរធនប្បដិលាភិតា បានលោកុត្តរទ្រព្យ ១០ នត្ថិ ភាវស្ស អជាននតា អសវនតា មិនធ្លាប់ដឹងមិនធ្លាប់បានឮពាក្យថា គ្មាន ១១ សុខវិហារិតា នៅទីឯណាក៏ជាសុខ ៗ

(បរមត្ថជោតិកា)

## សេចក្ដីបំណងក្នុងការរក្សាវិន័យមាន ១៣

• ១ វិនយោ សំវត្តាយ ប្រព្រឹត្តវិន័យ ដើម្បីការសង្រួម ។
២ សំវរោ អវិប្បដិសារត្ថាយ សង្រួម ដើម្បីត្រូវការមិនឲ្យក្ដៅក្រហាយ ។
៣ អវិប្បដិសារោ បាមោជ្ជត្ថាយ មិនក្ដៅក្រហាយ ដើម្បីឲ្យបាន

សេចក្ដីរីករាយចិត្ត ។ ៤ បាមោជ្ជំ បីតត្ថាយ មានសេចក្ដីរីករាយចិត្ត ដើម្បីឲ្យកើតបីតិ (ឆ្អែតចិត្ត) ។ ៥ បីតិ បស្សទ្ធត្ថាយ មានបីតិ ដើម្បីត្រូវការបស្សទ្ធិ (សេចក្ដីស្ងប់) ។ ៦ បស្សទ្ធិ សុខត្ថាយ មានបស្សទ្ធិ ដើម្បីឲ្យកើតសុខ ។ ៧ សុខំ សមាធត្ថាយ មានសេចក្ដីសុខ ដើម្បីឲ្យកើតសមាធិ ។ ៨ សមាធិ យថាភូតញាណទស្សនត្ថាយ មានសមាធិ ដើម្បីសេចក្ដីឃើញញាណតាមសេចក្ដីពិត ។ ៩ យថាភូតញាណទស្សនំ និព្វិទត្ថាយ មានសេចក្ដីឃើញដោយញាណតាមសេចក្ដីពិត ដើម្បីនិព្វិទា (សេចក្ដីធុញទ្រាន់) ។ ១០ និព្វិទា វិគត្ថាយ មាននិព្វិទា ដើម្បីនឹងឲ្យអស់សេចក្ដីស្រឡាញ់ ។ ១១ វិរាគោ វិមុត្តត្ថាយ អស់សេចក្ដីស្រឡាញ់ ដើម្បីត្រូវការវិមុត្តិញាណទស្សនៈ ។ ១២ វិមុត្តិ វិមុត្តិញាណទស្សនត្ថាយ បានវិមុត្តិ ដើម្បីត្រូវការវិមុត្តិញាណទស្សនៈ ។ ១៣ វិមុត្តិញាណទស្សនំ អនុបាទាបរិនិព្វានត្ថាយ មានវិមុត្តិញាណទស្សនៈ ដើម្បីត្រូវការបរិនិព្វានដោយមិនមានចំណែកសល់ ។

(វិសុទ្ធិមគ្គសីលនិទ្ទេស)

## សីលសិក្ខាបទទី ៤ មានអានិសង្ស ១៤

១ វិប្បសន្និន្ទ្រិយតា មានឥន្ទ្រិយទាំង ៥ ដ៏ជ្រះថ្លា ២ វិស្សជ្ជមធុរតា-ណិតា មានវាចាពីរោះក្បោះក្បាយ ៣ សមសំគស្សុខន្ទា បានគ្នាញស្ញើ

ដិតបរិសុទ្ធ ៤ នាតិថូលតា មិនធាត់ពេក ៥ នាតិកិសតា មិនស្គមពេក ៦ នាតិរស្សតា មិនទាបពេក ៧ នាតិទីឃតា មិនខ្ពស់ពេក ៨ សុខសម្ផស្សតា បានតែសម្ផស្សដ៏ជាសុខ ៩ ឧប្បលគន្ធមុខតា មាត់ក្រអូបដូចផ្កាឈូក ១០ សុស្សូសកបរិជ្ជនតា មានបរិវារជនសុទ្ធតែអ្នកឧស្សាហ៍ ១១ អភេទ្យវចនតា មានពាក្យគួរជឿបាន ១២ មុទុលោហិតតនុជិវ្ហតា អណ្តាតស្តើងក្រហមទន់ដូចត្របកឈូក ១៣ អនុទ្ធតា ចិត្តមិនសាត់អណ្តែត ១៤ អបគតមម្មនតា មិនជេរមនុស្សគេលេង ៗ

(បរមត្ថជោតិកា)

## សិល្បសាស្ត្រ ១៨ ប្រការ

១ សុតិ សេចក្តីចេះសព្ទ ២ សម្មតិ ការចូលចិត្តរៀន ៣ សង្ខ្យា (ឬ) ការរាប់ ៤ យោគយន្ត្រៈ សិក្សា ៥ នីតិ នីតិសាស្ត្រ ៦ វិសេសិកា វិជ្ជាជំនួញ ៧ គន្ធព្វា វិជ្ជារបាំ ៨ គណិកា (ឬ) វិជ្ជាកំឡាំងកាយ ៩ ធនុព្វេធា (ឬ) វិជ្ជាបាញ់ធ្នូ ១០ បុរាណា បុរាណគតិ ១១ តិកិច្ឆា វិជ្ជាពេទ្យ ១២ ឥតិហាសា (ឬ) ពាក្យបុរាណ ១៣ ជោតិ (ជ្យោតិ) តារាសាស្ត្រ ១៤ មាយា (ឬ) វិជ័យសង្គ្រាម ១៥ កេតុ

វិជ្ជានិយាយ ១៦ មន្ត្រា (ឬ) វិជ្ជាមន្ត ១៧ សទ្ទា វេយ្យាករណ៍ ១៨ ពុទ្ធវចនៈ វិជ្ជាចេះដឹងពុទ្ធវចនៈ ។

(ធម្មនីតិសិប្បកថា)

## ពុទ្ធនិវាសនៈ ស្ថានដែលស្តេចគង់ចាំវស្សា ១៨ កន្លែង

វស្សាទី ១ ស្តេចចាំវស្សានៅព្រៃឥសិបតនមិគទាយវ័ន នគរពារា-ណសី វស្សាទី ២ ទី ៣ ទី ៤ ស្តេចគង់ចាំវស្សានៅក្នុងវេឡុវ័នារាម នគររាជគហៈ វស្សាទី ៥ ស្តេចគង់ចាំវស្សាក្នុងកូដាគារសាលាព្រៃមហាវ័ន នគរវេសាលី វស្សាទី ៦ ស្តេចគង់ចាំវស្សាក្នុងមកុឡបព៌ត មគធៈប្រទេស វស្សាទី ៧ ស្តេចគង់ចាំវស្សាក្នុងស្ថានតាវត្តិង្ស គង់បណ្ឌុកម្ពលសិលា-សនៈ ត្រាស់ប្រទានព្រះសត្តបករណាភិធម្ម ៧ គម្ពីរ ប្រោសព្រះពុទ្ធមាតា វស្សាទី ៨ ស្តេចគង់ចាំវស្សាក្នុងភេសកឡាវ័ន (ព្រៃសម្បុរល្វែង) ខែត្រ ភគ្គាជជនបទ វស្សាទី ៩ ស្តេចគង់ចាំវស្សាក្នុងព្រៃបាលិលេយ្យវ័ន វស្សាទី ១០ ទី ១១ ស្តេចគង់ចាំវស្សាក្នុងព្រៃជិតភូមិព្រាហ្មណ៍ឈ្មោះ សាលេយ្យគ្រាម វស្សាទី ១២ ស្តេចគង់ចាំវស្សានៅក្រោមដើមស្តៅ ដែលនឡេរុយក្ខរក្ស (នឡេរុបុចិមណ្ឌមូលេ) វស្សាទី ១៣ ស្តេចគង់ចាំ វស្សាក្នុងភ្នំបាលិលេយ្យកៈបព៌ត វស្សាទី ១៤ ស្តេចគង់ចាំវស្សាក្នុង ជេតវ័នមហាវិហារ នគរសាវត្ថី វស្សាទី ១៥ ស្តេចគង់ចាំវស្សានៅ

និគ្រោធារាម នគរកបិលវត្ថុ ដើម្បីប្រោសព្រះញាតិ វស្សាទី ១៦ ស្តេចគង់ចាំវស្សាក្នុងនគរអាឡាវី ដើម្បីទ្រង់ប្រោសអាឡវកយក្ស វស្សាទី ១៧ ទី ១៨ ទី ១៩ ស្តេចគង់ចាំវស្សាវេឡុវនារាម នគររាជគហៈ វស្សាទី ២០ ដល់ ២៩ ស្តេចគង់ចាំវស្សាក្នុងជេតវនមហាវិហារ នគរសាវត្ថី វស្សាទី ៣០ ដល់ ៣៥ ស្តេចគង់ចាំវស្សានៅក្នុងបុព្វារាម វស្សាទី ៣៦ ដល់ ៤៤ ស្តេចគង់ចាំវស្សានៅក្នុងជេតវនមហាវិហារ នគរសាវត្ថី វស្សាទី ៤៥ ស្តេចគង់ចាំវស្សាក្នុងស្រុកវេឡុវគ្រាម ។

(រូបរឿងពីគម្ពីរផ្សេង ៗ)

## សីលសិក្ខាបទទី ៣ មានអានិសង្ស ២០ ។

១ វិគតបច្ចត្ថិកតា មិនមានសឹកសត្រូវ ២ សព្វជនស្ស បិយតា ជាទីស្រឡាញ់នៃជនទូទៅ ៣ អន្នប្បានវត្ថសយនាទីនិ បដិលាភតា រកបាយទឹកគ្រឿងស្លៀកដណ្តប់ទីនៅបានងាយ ៤ សុខសយនតា ដេកលក់ក៏ជាសុខ ៥ សុខប្បដិពុជ្ឈនតា ភ្ញាក់ឡើងក៏ជាសុខ ៦ អបាយកយបរិមុត្តតា ផុតភ័យក្នុងអបាយ ៧ អកត្ថុតា មិនត្រូវកើតជាស្រី ឬខ្ទើយ ៨ អកោធនតា មិនក្រោធងាយ ៩ សក្កច្ចការិតា ធ្វើអ្វីធ្វើដោយរៀបរយ ១០ បច្ចក្ខការិតា ធ្វើអ្វីធ្វើដោយប្រាកដ ១១ អបត្ថិតក្កណ្ណតា កមិនសំយុងចុះ ១២ អនោហាបុតា មុខមិនក្រញ៉ុប (គឺមានអំណាច)

១៣ អញ្ញមញ្ញប្បិយតា មានតែគៀនជាទីស្រឡាញ់ ១៤ បរិបុណ្ណិន្ទ្រិ-យតា មានឥន្ទ្រិយ ៥ បរិបូណ៌ ១៥ បរិបុណ្ណលក្ខណតា មានលក្ខណៈបរិបូណ៌ ១៦ និរាសង្កតា មិនមានអ្នកណារង្កៀស ១៧ អប្បោស្សុក្កតា ខ្វល់ខ្វាយតិច ១៨ សុខវិហារិតា នៅក្នុងទីណាក៏ជាសុខ ១៩ អកុ-តោភយតា មិនមានភ័យមកពីទីណា ៗ ២០ បិយវិប្បយោគាភាវតា មិនសូវមានព្រាត់ប្រាសរបស់ដែលជាទីស្រឡាញ់ ។

(បរមត្ថជោតិកា)

## សីលសិក្ខាបទទី ១ មានអានិសង្ស ២៣

១ អង្គប្បច្ចង្គសម្បន្នតា បរិបូណ៌ដោយអវយវតូចធំ (កន្លែងកាយមិនវិការ) ២ អារោហបរិណាហសម្បត្តិ (ប្រកបដោយកំពស់និងសមទ្រង់) ៣ ជវសម្បត្តិ សំបូណ៌ដោយរហ័ស ៤ សុប្បតិដ្ឋិតបាទតា ជាអ្នកមានជើងប្រតិស្ឋានចុះដ៏ល្អ ៥ ចារុតា ជាអ្នកដ៏ថ្លារុងរឿង ៦ សុចិតា ជាមនុស្សស្អាត ៧ មុទុតា ជាអ្នកទន់ភ្លន់ ៨ សុខិតា ជាមនុស្សមានសេចក្ដីសុខ ៩ សូរតា ជាមនុស្សក្លៀវក្លា ១០ មហព្ពលតា ជាមនុស្សមានកំឡាំងច្រើន ១១ វិសដ្ឋវចនតា មានវាចាក្បោះក្បាយពីរោះ ១២ អភេជ្ជបរិសតា មានបរិសទ្យមិនព្រាត់ប្រាសពីខ្លួន ១៣ អច្ឆម្ភិតា ជាមនុស្សមិនតក់ស្លុតខ្លាច ១៤ អប្បធំសិកតា [illegible] សត្រូវប្រទុស្តរាយ

មិនបាន ១៥ បរូបក្កមេន អមរណតា មិនស្លាប់ដោយសេចក្តីព្យាយាមរបស់អ្នកដទៃ ១៦ អនន្តបរិវារតា មានបរិវារគេទីបំផុតមិនបាន ១៧ សុរូបតា រូបល្អ ១៨ សុសណ្ឋានតា ទ្រង់ទ្រាយល្អ ១៩ អប្បាពាធតា ឈឺតិច ២០ អសោកិតា មិនមានសេចក្តីទុក្ខចិត្ត ២១ លោកបិយតា ជាទីស្រឡាញ់របស់លោក ២២ បិយេហិ មនាបេហិ សទ្ធិំ អវិប្បយោគតា មិនបានព្រាត់ប្រាសចាកសត្វនិងសង្ខារ ដែលជាទីស្រឡាញ់និងគាប់ចិត្ត ២៣ ទីឃាយុកតា មានអាយុវែង ។

(បរមត្ថជោតិកា)

## សីលសិក្ខាបទទី ៥ មានអានិសង្ស ៣៥

១ កិច្ចករណីយេសុ ខិប្បំ បដិវិជាននតា ដឹងកិច្ចការ អតីត អនាគត បច្ចុប្បន្នបានរហ័ស ២ សទា ឧបដ្ឋិតសតិតា មានសតិដំកល់ខ្ជាប់គ្រប់កាល ៣ អនុម្មត្តកតា មិនមែនជាមនុស្សឆ្កួត ៤ ញាណវន្តតា មានសេចក្តីដឹងច្រើន ៥ អនេឡតា មិនញាប់ញ័រ ៦ អជឡតា មិនស្ទស្ទើរ ៧ អមូគតា មិនគ ៨ អមទតា មិនស្រវឹង ៩ អប្បមត្តតា មិនប្រមាទ ១០ អសម្មោហតា មិនវង្វេង ១១ អច្ឆម្ភិតតា មិនតក់ស្លុតខ្លាច ១២ អសារម្ភិតា មិនមានសេចក្តីរំខាន ១៣ អនិស្សុកិតា មិន

មានអ្នកណាប្រស្សា ១៤ អប្បោស្សុក្កតា មានសេចក្តីខ្វល់ខ្វាយតិច ១៥ សុខិតតា មានតែសេចក្តីសុខ ១៦ អកិសម្ភតតា មានតែមនុស្ស គប់អានកោតក្រែង ១៧ សច្ចវាទិតា និយាយតែពាក្យសត្យ ១៨ អបិសុណតា មិននិយាយពាក្យស៊កសៀតគេ មិនមានគេនិយាយស៊កសៀត ១៩ អផរុសតា មិននិយាយពាក្យគ្រោតគ្រើមដល់អ្នកណា គ្មានអ្នកណានិយាយពាក្យគ្រោតគ្រើមផង ២០ អសម្ផប្បលាបវាទិតា មិននិយាយលេងពាក្យឥតប្រយោជន៍ ២១ រត្តិន្ទិវមតន្ទិតតា មិនខ្ជិលច្រអូសទាំងយប់ថ្ងៃ ២២ អកតញ្ញុតា មានសេចក្តីកតញ្ញូ ២៣ កតវេទិតា មានសេចក្តីកតវេទី ២៤ អមច្ឆរិតា មិនកំណាញ់ ២៥ ចាគវន្តតា ដឹងការចែកចាយ ២៦ សីលវន្តតា មានសីលបរិសុទ្ធ ២៧ ឧជុកតា ពិតត្រង់ ២៨ អក្កោធនតា មិនក្រោធនឹងអ្នកណា ២៩ ហិរិមនតា មានចិត្តខ្មាសដល់បាប ៣០ ឧត្តប្បិតា ខ្លាចក្រែងបាប ៣១ ឧជុទិដ្ឋិតា មានសេចក្តីឃើញត្រូវ ៣២ មហាបញ្ញតា មានបញ្ញាច្រើន ៣៣ មេធាវិតា ជាអ្នកប្រាជ្ញ ៣៤ បណ្ឌិតា ជាបណ្ឌិតមានញាណគតិ ៣៥ អត្ថានត្ថកុសលតា ឆ្លាតដឹងរបស់ដែលជាប្រយោជន៍ នឹងរបស់ដែលមិនមែនជាប្រយោជន៍ ជាទោស ។

(បរមត្ថជោតិកា)

# ព្រហ្មចរិយកថា

# របស់ព្រះមហាសៃស

# (ត)

ឯនេមិត្តិកតា នោះគឺការធ្វើនិមិត្តកម្មឯណានិមួយ គឺការបញ្ចិតបញ្ចៀងដោយកាយខ្លះ ដោយវាចាខ្លះ ជាឧបាយញ៉ាំងបច្ច័យឲ្យកើតឡើងដល់ខ្លួន ដូចយ៉ាងភិក្ខុដើរទៅឃើញកូនក្មេងគង្វាលគោ ក៏សួរថា គោទាំងអំបាលនេះ ជាគោដែលមានទឹកដោះស្រស់ ឬជាគោដែលមានទឹកដោះជូរ កូនក្មេងឆ្លើយថា គោដែលមានទឹកដោះស្រស់លោកម្ចាស់ ភិក្ខុនិយាយថា មិនមែនជាគោដែលមានទឹកដោះស្រស់ទេ បើជាគោដែលមានទឹកដោះស្រស់ពិតមែន ភិក្ខុបានឆាន់ទឹកដោះស្រស់ហើយ ភិក្ខុនិយាយបំភ្លឺ ចាក់រុក គ្រាតែកូនក្មេងទាំងនោះនាំរឿងទៅប្រាប់មាតាបិតា គ្រាតែមាតាបិតាឲ្យទឹកដោះស្រស់ដល់ភិក្ខុ ។

ម្យ៉ាងទៀត រឿងកុលុបកភិក្ខុ អ្នកប្រាជ្ញគប្បីសំដែងក្នុងនេមិត្តិកតានិទ្ទេសនេះឯង បានឮថា កុលុបកភិក្ខុនោះ មានប្រាថ្នានឹងឆាន់ភោជនាហារ ហើយក៏ចូលទៅអង្គុយក្នុងផ្ទះ ១ ។ ស្រីជាមេផ្ទះបានឃើញភិក្ខុនោះ ក៏គ្មានប្រាថ្នានឹងឲ្យវត្ថុអ្វីសោះ និយាយថា ខ្ញុំគ្មានអង្ករទេ ។ ហើយក៏ដើរទៅកាន់ផ្ទះជិតខាង ធ្វើហាក់ដូចជាទៅរកអង្ករ ។ ភិក្ខុក៏ចូលទៅក្នុងល្វែងផ្ទះគយគន់មើលទៅ ឃើញដើមអំពៅនៅក្បែរជ្រុងសន្ទះទ្វារ ឃើញស្ករអំពៅនៅក្នុងភាជន ឃើញត្រីងៀតនៅក្នុងកញ្ជើ ឃើញអង្ករនៅក្នុងពាង ឃើញទឹកដោះជូរនៅក្នុងឆ្នាំង ឃើញហើយក៏ចេញមកអង្គុយធ្វើព្រងើយ ។ ស្រីជាមេផ្ទះត្រឡប់មកវិញនិយាយថា ខ្ញុំរកអង្ករ

មិនបានទេ ៗ ភិក្ខុនោះនិយាយថា នែឧបាសិកា ថ្ងៃនេះប្រហែលជា មិនបានបង្ហាប់អ្វីនាន់ទេ ព្រោះថា អំពីល្ងាចមិញ អាត្មាឃើញសុបិននិមិត្តមិនស្រួល ៗ ស្រីជាមេផ្ទះសួរថា លោកម្ចាស់ឃើញសុបិននិមិត្តដូចម្តេច ភិក្ខុឆ្លើយថា អាត្មាយល់សប្តិឃើញពស់ ១ ប្រហែលគ្នានឹងដើមអំពៅដែលនាងប្អូនទុកនៅក្បែរជ្រុងសន្ទះទ្វារ ហើយអាត្មាគយគន់មើលកន្ទុយនឹងពេលពស់នោះ ក៏បានឯដុំថ្មប្រហែលគ្នានឹងដុំស្ករអំពៅដែលនាងទុកក្នុងភាជន៍ លុះបានដុំថ្មនោះពេលពស់នោះទៅ ពស់នោះក៏បើកពពារឡើង ពពារនោះប្រហែលគ្នានឹងត្រឡៀតដែលនាងទុកក្នុងកញ្ជើ ពស់នោះក៏មានត្បូងថ្មនឹងទាំដុំថ្មនោះ ហាមាត់ឡើងក៏ឃើញធ្មេញប្រហែលគ្នានឹងអង្ករដែលនៅក្នុងរាង លំដាប់នោះ ពស់នោះក៏ក្រោធខឹងឡើងទៀត ព្រួសពិសចេញអំពីមាត់ ទឹកពិសនោះប្រហែលគ្នានឹងទឹកដោះថ្លាដែលនាងដាក់ក្នុងឆ្នាំង ៗ ស្រីជាមេផ្ទះនោះក៏គិតថា អាត្មាអញមិនអាចនឹងបញ្ឆោតសមណត្រកោលនេះបានឡើយ ហើយក៏យកដើមអំពៅមកប្រគេន រួចចំអិនបាយប្រគេនជាមួយនឹងទឹកដោះថ្លានឹងស្ករអំពៅនឹងត្រឡៀត ៗ អំពើដូច្នេះជាដើមបានឈ្មោះថា នេមិត្តិកតា ៗ

ឯនិប្បេសិកតានោះ សេចក្តីថា ការដេរគ្រហស្ថដោយអក្កោសវត្ថុទាំង ១០ ការនិយាយមើលងាយគ្រហស្ថ ការត្មះតិះដៀលគ្រហស្ថថា អាមនុស្សមិនមានសទ្ធា អាមនុស្សមិនជ្រះថ្លាជាដើម និយាយចំអក

ច្រកឡើយឲ្យគ្រហស្ថ និយាយបំអកបំអន់ទឹងគ្រហស្ថថា មនុស្សឯណា ហុចសំដីឲ្យដល់អ្នកបួសថា គ្មាន ៗ ដូច្នេះជាទិដ្ឋិ អ្នកទាំងឡាយហៅមនុស្សនេះថា មិនមែនជាពាយកដូចម្តេចបាន ៗ

មួយវិញទៀត ការនិយាយដើមដៀលគ្រហស្ថ នាំពាក្យអំពីផ្ទះមួយទៅផ្ទះមួយ អំពីស្រុកមួយទៅស្រុកមួយ អំពីជនបទមួយទៅជនបទមួយ និយាយពាក្យផ្អែមពីរោះក្នុងទីចំពោះមុខ និយាយដើមអាក្រក់ក្នុងទីកំបាំងមុខ ៗ អំពើដូច្នេះជាដើមបានឈ្មោះថា និប្បេសិកតា ៗ

ឯលាភេន លាភំ និជិគីសនតា នោះគឺការនាំលាភដែលខ្លួនបានអំពីត្រកូលឯនេះ ទៅឲ្យត្រកូលឯនោះ នាំអំពីត្រកូលឯនោះ ទៅឲ្យត្រកូលឯនោះទៀត ដោយសេចក្តីប្រាថ្នាលាភសក្ការទីងសេចក្តីសរសើរ ៗ ការចិញ្ចឹមជីវិតរបស់បព្វជិតដោយបាបធម៌ទាំង ៥ ជាដើមដូច្នេះហៅថា មិច្ឆាជីវ វៀរចាកមិច្ឆាជីវនោះ ហៅថា សម្មាអាជីវ ៗ

ការចិញ្ចឹមជីវិតខុសរបស់គ្រហស្ថ ដោយជំនួញទាំង ៥ ជាដើមហៅថា មិច្ឆាជីវ ឯជំនួញទាំង ៥ នោះគឺ សត្ថវណិជ្ជា ជំនួញសស្ត្រាវុធ ១ សត្តវណិជ្ជា ជំនួញមនុស្ស ១ មំសវណិជ្ជា ជំនួញសត្វដែលគេពិឃាតយកសាច់ ១ មជ្ជវណិជ្ជា ជំនួញទឹកស្រវឹង ១ វិសវណិជ្ជា ជំនួញថ្នាំពិសពុល ១ ការចិញ្ចឹមជីវិតដោយ

ដំនួញទាំង ៥ ជាដើម ដូច្នេះ ហៅថា មិច្ឆាជីវរបស់គ្រហស្ថ វៀរចាកមិច្ឆាជីវនោះ ហៅថា សម្មាអាជីវៈ ។

អង្គនៃមគ្គទី ៦ គឺ សម្មាវាយាមៈនោះ បានខាងសម្មប្បធានទាំង ៤ គឺព្យាយាមបិទអកុសលដែលមិនទាន់កើតឡើងក្នុងសន្តាន កុំឲ្យកើតឡើងបាន ១ ព្យាយាមលះបោលអកុសលដែលកើតឡើងស្រាប់ហើយ ១ ព្យាយាមបណ្តុះបណ្តាលកុសលដែលមិនទាន់កើតឡើង ឲ្យដុះដាលឡើង ១ ព្យាយាមញ៉ាំងកុសលដែលកើតឡើងស្រាប់ហើយ ឲ្យរឹងរិតតែចំរើនច្រើនឡើង ១ ។

អង្គនៃមគ្គទី ៧ គឺសម្មាសតិនោះ បានខាងសតិបដ្ឋានទាំង ៤ គឺ កាយានុបស្សនាសតិបដ្ឋាន ការដំកល់សតិក្នុងការពិចារណាកាយ ១ វេទនានុបស្សនាសតិបដ្ឋាន ការដំកល់សតិក្នុងការពិចារណាវេទនា ១ ចិត្តានុបស្សនាសតិបដ្ឋាន ការដំកល់សតិក្នុងការពិចារណាចិត្ត១ ធម្មានុបស្សនាសតិបដ្ឋាន ការដំកល់សតិក្នុងការពិចារណាធម៌ ១ ឯកាយានុបស្សនាសតិបដ្ឋាននោះ សង្គ្រោះដោយបព្វៈ ៦ គឺ អានាបានបព្វ ១ ឥរិយាបថបព្វ ១ សម្បជញ្ញបព្វ ១ បដិក្កូលមនសិការបព្វ ១ ធាតុមនសិការបព្វ ១ នវសីវថិកាបព្វ ១ ។

ឯអានាបានបព្វនោះ សេចក្តីថា ភិក្ខុពិចារណាកាយគឺខ្យល់ដកដង្ហើមចេញចូល កាលបើដកដង្ហើមចេញចូលវែងឬខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញចូលវែងឬខ្លីជាដើម ត្រាតែឃើញច្បាស់ថា កាយគឺខ្យល់ដកដង្ហើមចេញចូលនេះជារបស់កើតឡើងនឹងវិនាសទៅជាធម្មតា ។

ឯឥរិយាបថបព្វនោះ សេចក្តីថា ភិក្ខុពិចារណាកាយគឺឥរិយាបថទាំង ៤ គឺដេកដើរឈរអង្គុយ កាលបើកំពុងដេកដើរឈរឬអង្គុយ ក៏ដឹងច្បាស់ថា អាត្មាអញដេកដើរឈរ ឬអង្គុយ ត្រាតែឃើញច្បាស់ថា កាយគឺឥរិយាបថទាំង ៤ នេះជារបស់កើតឡើងនឹងវិនាសទៅជាធម្មតា ។

ឯសម្បជញ្ញបព្វនោះ សេចក្តីថា ភិក្ខុធ្វើនូវសេចក្តីដឹងខ្លួនក្នុងកិច្ចទាំងពួងគឺដើរឈានទៅមុខ ឈានថយក្រោយ ការក្រឡេកមើលទៅ ក្រឡេកមើលមក ការបត់ជើងដៃចូល លាជើងដៃចេញ ការប្រើប្រាស់បាត្រចីវរ ការបរិភោគអាហារ ការផឹកទឹក ការដើរឈរអង្គុយដេកលក់ ភ្ញាក់រឭក ការនិយាយ ការស្ងៀមមិននិយាយ ត្រាតែឃើញច្បាស់ថា កាយគឺកិច្ចទាំងពួងនេះជារបស់កើតឡើងនឹងវិនាសទៅជាធម្មតា ។

ឯបដិក្កូលមនសិការបព្វនោះ សេចក្តីថា ភិក្ខុពិចារណាឃើញច្បាស់ក្នុងកាយគឺអាការទាំង ៣២ មានសក់ជាដើម ត្រាតែឃើញច្បាស់ថា កាយគឺអាការទាំង៣២នេះជារបស់គួរខ្ពើមរអើម ជារបស់កើតឡើងនឹងវិនាសទៅជាធម្មតា ។

ឯធាតុមនសិការបព្វនោះ សេចក្តីថា ភិក្ខុពិចារណាឃើញច្បាស់ក្នុងកាយគឺធាតុទាំង ៤ គឺដី ទឹក ភ្លើង ខ្យល់ ត្រាតែឃើញច្បាស់ថា ជារបស់កើតឡើងទំនងនោះទៅជាធម្មតា ។

ឯនវសីវថិកាបព្វនោះ សេចក្តីថា ភិក្ខុពិចារណាឃើញច្បាស់ក្នុងកាយគឺសាកខ្មោចដែលគេយកទៅបោលក្នុងទីប៉ាឆា មាន ៩ ប្រការគឺសាកខ្មោចដែលស្លាប់បាន១ថ្ងៃក្តី ២ថ្ងៃក្តី ៣ថ្ងៃក្តី ក៏ហើមឡើងមានសម្បុរខៀវមានទឹកខ្ទុះហូរចេញ ១ គឺសាកខ្មោចដែលសត្វមានក្អែកត្មាតជាដើមទំពាចឹកស៊ីជាអាហារ ១ សាកខ្មោចដែលនៅមានកង្អឹង នៅមានតាំងសាច់ឈាម មានតាំងសរសៃជាប់នៅ ១ សាកខ្មោចដែលនៅមានកង្អឹង តែគ្មានសាច់ មានតែឈាមប្រឡាក់មានសរសៃជាប់នៅ ១ សាកខ្មោចដែលនៅតែកង្អឹងគ្មានសាច់និងឈាម តែមានសរសៃជាប់នៅ ១ សាកខ្មោចដែលមានតែឆ្អឹងខ្ចាត់ខ្ចាយពាត់ពាយ គ្មានសរសៃទាក់ចងគឺឆ្អឹងដៃនៅទីទៃ ឆ្អឹងជើងនៅទីទៃជាដើម ១ គឺសាកខ្មោចដែលនៅតែឆ្អឹងមានសម្បុរសដូចជាសម្បុរស័ង្ខ ១ សាកខ្មោចដែលនៅតែឆ្អឹងជាគំនរកន្លងហួស ១ ឆ្នាំ ១ សាកខ្មោចដែលនៅតែឆ្អឹងពុកផុយជាកំទេច ៗ ១ ត្រូវជា៩ប្រការ ភិក្ខុពិចារណាកាយគឺសាកខ្មោចទាំង៩ប្រការនេះ ប្រៀបធៀបនឹងកាយរបស់ខ្លួនថាកាយរបស់អាត្មាអញក៏ដូចជាសាកខ្មោចនោះដែរ ត្រាតែឃើញច្បាស់ថា ជារបស់កើតឡើងទំនងនោះទៅជាធម្មតា ។

ឯវេទនានុបស្សនាសតិបដ្ឋាននោះ សេចក្ដីថា ភិក្ខុពិចារណាឃើញក្នុងកងវេទនា កាលបើសោយវេទនាជាសុខ ក៏ដឹងច្បាស់ថា អាត្មាអញសោយវេទនាជាសុខ កាលបើសោយវេទនាជាទុក្ខ ក៏ដឹងច្បាស់ថា អាត្មាអញសោយវេទនាជាទុក្ខ កាលបើសោយវេទនាមិនមែនទុក្ខមិនមែនសុខ គឺជាឧបេក្ខា ក៏ដឹងច្បាស់ថា អាត្មាអញសោយវេទនាមិនមែនទុក្ខមិនមែនសុខដូច្នេះជាដើម ត្រាតែឃើញថា ជារបស់កើតឡើងនឹងវិនាសទៅជាធម្មតា ។

ឯចិត្តានុបស្សនាសតិបដ្ឋាននោះ សេចក្ដីថា ភិក្ខុពិចារណាឃើញច្បាស់ក្នុងចិត្ត កាលបើចិត្តនៅប្រកបដោយរាគ ទោស មោហ ក៏ដឹងច្បាស់ថា ចិត្តនៅប្រកបដោយ រាគ ទោស មោហ កាលបើចិត្តប្រាសចាក រាគ ទោស មោហ ហើយ ក៏ដឹងច្បាស់ថា ចិត្តប្រាសចាក រាគ ទោស មោហ ហើយ ដូច្នេះជាដើម ត្រាតែឃើញច្បាស់ថា ជារបស់កើតឡើងនឹងវិនាសទៅជាធម្មតា ។

ឯធម្មានុបស្សនាសតិបដ្ឋាននោះ សង្គ្រោះដោយបព្វៈ ៥ គឺ នីវរណបព្វ ១ ខន្ធបព្វ ១ អាយតនបព្វ ១ ពោជ្ឈង្គបព្វ ១ សច្ចបព្វ ១ ។

ឯនីវរណបព្វនោះ សេចក្ដីថា ភិក្ខុពិចារណាឃើញច្បាស់ក្នុងធម៌ គឺនីវរណទាំង ៥ គឺ កាមច្ឆន្ទ សេចក្ដីប្រាថ្នា សេចក្ដីស្រឡាញ់ពេញចិត្តក្នុងបញ្ចកាមគុណ ១ ព្យាបាទៈ សេចក្ដីព្យាបាទគុំញ៉ាំងប្រយោជន៍

ទីងសេចក្តីសុខរបស់អ្នកដទៃឲ្យវិនាស ១ ថីនមិទ្ធ សេចក្តីទ្រលច្រអូស ១ ឧទ្ធច្ចកុក្កុច្ច សេចក្តីរាយមាយ សេចក្តីក្តៅក្រហាយក្រង្វៀស ១ វិចិកិច្ឆា សេចក្តីសង្ស័យក្នុងកុសលធម៌ ១ កាលបើកាមច្ឆន្ទមានទៅក្នុងសន្តាន ក៏ដឹងច្បាស់ថា កាមច្ឆន្ទមាននៅក្នុងសន្តានអាត្មាអញ ដូច្នេះជាដើម ត្រាតែឃើញច្បាស់ថា ជារបស់កើតឡើងទឹងវិនាសទៅជាធម្មតា ។

ឯខន្ធបព្វនោះ សេចក្តីថា ភិក្ខុពិចារណាឃើញច្បាស់ក្នុងធម៌ គឺឧបាទានក្ខន្ធ ទាំង ៥ គឺ រូបូបាទានក្ខន្ធ ១ វេទនូបាទានក្ខន្ធ ១ សញ្ញូបាទានក្ខន្ធ ១ សង្ខារូបាទានក្ខន្ធ ១ វិញ្ញាណូបាទានក្ខន្ធ ១ ពិចារណាឃើញថា រូបដូច្នេះ សេចក្តីកើតឡើងនៃរូបដូច្នេះ សេចក្តីរលត់ទៅនៃរូបដូច្នេះ យ៉ាងនេះជាដើម ត្រាតែឃើញច្បាស់ថា ជារបស់កើតឡើងទឹងវិនាសទៅជាធម្មតា ។

ឯអាយតនបព្វនោះ សេចក្តីថា ភិក្ខុពិចារណាឃើញច្បាស់ក្នុងធម៌ គឺអាយតនទាំង ១២ គឺ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ៦ នេះ ហៅថា អាយតនខាងក្នុង រូប សំឡេង ក្លិន រស សម្ផស្ស ធម្មារម្មណ៍ ៦ នេះ ហៅថា អាយតនខាងក្រៅ ។ ភិក្ខុដឹងច្បាស់នូវភ្នែកនិងរូប ដឹងច្បាស់នូវសំយោជនធម៌ ដែលកើតឡើង ព្រោះអាស្រ័យភ្នែកនឹងរូប នោះដូច្នេះជាដើម ត្រាតែឃើញច្បាស់ថា ជារបស់កើតឡើងទឹងវិនាសទៅជាធម្មតា ។

ឯពោជ្ឈង្គបព្វនោះ សេចក្ដីថា ភិក្ខុពិចារណាឃើញច្បាស់ក្នុងធម៌គឺពោជ្ឈង្គទាំង ៧ គឺ សតិសម្ពោជ្ឈង្គ ធម៌ជាហេតុនៃបុគ្គលជាអ្នកត្រាស់ដឹងនូវអរិយសច្ច គឺសតិ ១ ធម្មវិចយសម្ពោជ្ឈង្គ ធម៌ជាហេតុនៃបុគ្គលជាអ្នកត្រាស់ដឹងនូវអរិយសច្ច គឺបញ្ញា ១ វីរិយសម្ពោ-ជ្ឈង្គ ធម៌ជាហេតុនៃបុគ្គលជាអ្នកត្រាស់ដឹងនូវអរិយសច្ច គឺព្យាយាម ១ បីតិសម្ពោជ្ឈង្គ ធម៌ជាហេតុនៃបុគ្គលជាអ្នកត្រាស់ដឹងនូវអរិយសច្ច គឺបីតិ ១ បស្សទ្ធិសម្ពោជ្ឈង្គ ធម៌ជាហេតុនៃបុគ្គលជាអ្នកត្រាស់ដឹងនូវអរិយសច្ច គឺបស្សទ្ធិ ១ សមាធិសម្ពោជ្ឈង្គ ធម៌ជាហេតុនៃបុគ្គលជាអ្នកត្រាស់ដឹងនូវអរិយសច្ច គឺសមាធិ ១ ឧបេក្ខាសម្ពោជ្ឈង្គ ធម៌ជាហេតុនៃបុគ្គលជាអ្នកត្រាស់ដឹងនូវអរិយសច្ច គឺឧបេក្ខា ១ កាលបើសតិសម្ពោជ្ឈង្គមាននៅក្នុងសន្ដាន ក៏ដឹងច្បាស់ថា សតិសម្ពោជ្ឈង្គ មាននៅក្នុងសន្ដានអាត្មាអញដូច្នេះជាដើម ត្រាតែឃើញច្បាស់ថា ជារបស់កើតឡើងនឹងវិនាសទៅជាធម្មតា ។

ឯសច្ចបព្វនោះ សេចក្ដីថា ភិក្ខុពិចារណាឃើញច្បាស់ក្នុងធម៌គឺអរិយសច្ចទាំង ៤ គឺដឹងតាមពិតថា នេះជាទុក្ខ នេះជាតណ្ហានាំឲ្យកើតទុក្ខ នេះជាព្រះនិព្វានជាគ្រឿងរលត់នៃទុក្ខ នេះជាផ្លូវប្រតិបត្តិដំណើរទៅកាន់ព្រះនិព្វានជាគ្រឿងរលត់នៃទុក្ខដូច្នេះជាដើម ត្រាតែឃើញច្បាស់

ថា ជារបស់កើតឡើងនឹងវិនាសទៅជាធម្មតា ។ សតិប្បដ្ឋានទាំង ៤ ដូចជូនសំដែងមកដោយសង្ខេបនេះ ហៅថា សម្មាសតិ ។

អង្គនៃមគ្គទី ៨ គឺសម្មាសមាធិនោះបានខាងឈានទាំង ៤ គឺ បឋមជ្ឈាន ១ ទុតិយជ្ឈាន ១ តតិយជ្ឈាន ១ ចតុត្ថជ្ឈាន ១ ។ បឋមជ្ឈានបានដល់ចិត្តដែលជារូបាវចរកុសល ជាចិត្តស្ងាត់ចាកកាម ស្ងាត់ចាកអកុសលធម៌ គឺនីវរណៈទាំង ៥ បានខាងអភិជ្ឈា សេចក្តីលោភ សេចក្តីចង់បាន ឬកាមឆន្ទ សេចក្តីប្រាថ្នាក្នុងកាម ១ ព្យាបាទ សេចក្តីគុំគួនធ្វើប្រយោជន៍នឹងសេចក្តីសុខរបស់អ្នកដទៃឲ្យវិនាស ១ ថីនមិទ្ធ សេចក្តីច្រអូសចិត្តច្រអូសកាយគឺសេចក្តីខ្ជិល ១ ឧទ្ធច្ចកុក្កុច្ច សេចក្តីពាយមាយក្តៅក្រហាយចិត្ត ១ វិចិកិច្ឆា សេចក្តីសង្ស័យ ១ ហើយប្រកបដោយធម៌ ៥ គឺវិតក្ក ១ វិចារ ១ បីតិ ១ សុខ ១ ឯកគ្គតា ១ ។

ឯវិតក្កៈ គឺសម្មាសង្កប្បៈ សេចក្តីត្រិះរិះដោយប្រពៃ មានលក្ខណៈលើកចិត្តដាក់ក្នុងអារម្មណ៍ នឹងជាសត្រូវដល់ថីនមិទ្ធផង ។

ឯវិចារៈ គឺការពិចារណាត្រួតត្រាអារម្មណ៍ មានលក្ខណផុសខាត់អារម្មណ៍ឲ្យភ្លឺថ្លា នឹងជាសត្រូវដល់វិចិកិច្ឆាផង ។

ឯបីតិ គឺសេចក្តីត្រេកអរ មានលក្ខណញុំាងកាយនឹងចិត្តឲ្យពេញឬឆ្អែតនឹងជាសត្រូវដល់ព្យាបាទផង ។

ឯសុខ គឺសេចក្ដីសប្បាយចិត្ត មានលក្ខណៈធ្វើចិត្តឲ្យឆ្ងាញ់ពីសា ក្នុងអារម្មណ៍ ដែលប្រាសចាកកាម ទើងជាសត្រូវដល់ឧទ្ធច្ចកុក្កុច្ចផង ។

ឯ ឯកគ្គតា គឺសមាធិ មានលក្ខណៈមិនរាយមាយឃ្លេងឃ្លោងទៅ តាមអារម្មណ៍ ទើងជាសត្រូវដល់កាមឆន្ទផង ។

ឯទុតិយជ្ឈាន បានដល់ចិត្តជារូបាវចរកុសលដែលខ្ទង់ផុតអំពីវិតក្ក នឹងវិចារ ហើយប្រកបដោយធម៌ ៣ គឺ បីតិ ១ សុខ ១ ឯកគ្គតា ១ ។

ឯតតិយជ្ឈាន បានដល់ចិត្តជារូបាវចរកុសល ដែលខ្ទង់ផុតអំពីបីតិ ហើយប្រកបដោយធម៌ ២ គឺសុខ ១ ឯកគ្គតា ១ ។

ឯចតុត្ថជ្ឈាន បានដល់ចិត្តជារូបាវចរកុសល ដែលខ្ទង់ផុតអំពីសុខ ហើយប្រកបដោយធម៌ ២ គឺឧបេក្ខា ១ ឯកគ្គតា ១ ។

មួយវិញទៀត តាមន័យដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់សំដែងក្នុង ឈានវិភង្គ ក្នុងអភិធម្ម ថា ពាក្យដែលហៅថា បឋមជ្ឈាន គឺជា ឈ្មោះរបស់ធម៌ ៥ ប្រការគឺ វិតក្ក ១ វិចារ ១ បីតិ ១ សុខ ១ ចិត្តស្ស ឯកគ្គតា ១ ឬថា រូបធម៌ទាំង៥នេះឲ្យឈ្មោះថា បឋមជ្ឈានដូច្នេះវិញក៏ បាន ។

ពាក្យថា ទុតិយជ្ឈានជាឈ្មោះរបស់ធម៌ ៤ ប្រការ គឺ សម្បុ- សាទោ សេចក្ដីជ្រះថ្លា គឺសទ្ធា ១ បីតិ ១ សុខ ១ ចិត្តស្ស

ឯកគ្គតា ១ ឬថា ប្រមូលធម៌ទាំង ៤ នេះចូលជាពាក្យមួយ ហៅថា ទុតិយជ្ឈានដូច្នេះវិញក៏បាន ។

ពាក្យថា តតិយជ្ឈាន ជាឈ្មោះរបស់ធម៌ ៤ ប្រការ គឺ ឧបេក្ខា ១ សតិ ១ សម្បជញ្ញ សេចក្តីដឹងខ្លួនដោយល្អ ១ សុខ ១ ចិត្តស្ស ឯកគ្គតា ១ ឬថា ប្រមូលធម៌ទាំង ៤ នេះបងជាពាក្យមួយហៅថា តតិយជ្ឈានដូច្នេះវិញក៏បាន ។

ពាក្យថា ចតុត្ថជ្ឈាន គឺជាឈ្មោះរបស់ធម៌ ៣ ប្រការ គឺ ឧបេក្ខា ១ សតិ ១ ចិត្តស្ស ឯកគ្គតា ១ ឬថា ប្រមូលធម៌ទាំង ៣ នេះបញ្ចូលជាពាក្យមួយហៅថា ចតុត្ថជ្ឈានដូច្នេះវិញក៏បាន ។

អរិយមគ្គដូចបានសំដែងមកនេះ ចាត់ជាព្រហ្មចរិយទី ៩ ហៅថា អរិយមគ្គព្រហ្មចរិយ ។

ព្រហ្មចរិយទី ១០ គឺសាសន (ពាក្យប្រដៅ) នោះមានមកក្នុង មហាបរិនិព្វានសូត្រ គម្ពីរទីឃនិកាយ មហាវគ្គ មានសេចក្តីថា គ្រាកាលដែលព្រះដ៏មានព្រះភាគជិតចូលបរិនិព្វាន ក្រុងមារចូលមកអារាធនាព្រះអង្គថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះអង្គបរិនិព្វានទៅ ព្រោះកាលពីដើមព្រះអង្គបានមានព្រះបន្ទូលនឹងខ្ញុំថា ម្នាលមារ តថាគតមិនទាន់បរិនិព្វានទេ ព្រោះថា ព្រហ្មចរិយរបស់តថាគតមិនទាន់សម្រេច

មិនទាន់បែករីកផ្សាយទៅសព្វទិស គេមិនទាន់ដឹងស្គាល់ច្រើនគ្នា ទេវតានឹងមនុស្សដែលជាវិញ្ញូជាតិ មិនទាន់សំដែងបានដោយប្រពៃ ក៏ឥឡូវនេះព្រហ្មចរិយធម៌របស់ព្រះអង្គក៏សម្រេចហើយ បែករីកផ្សាយទៅសព្វទិសហើយ គេដឹងស្គាល់ច្រើនគ្នាហើយ ទេវតានឹងមនុស្សដែលជាវិញ្ញូជាតិសំដែងបានដោយប្រពៃហើយ ហេតុនេះសូមព្រះអង្គបរិនិព្វានទៅ ។ ព្រះអង្គមានព្រះបន្ទូលថា ម្នាលមារ អ្នកកុំព្រួយអ្វីមិនយូរទេ នៅតែ ៣ ខែទៀត តថាគតបរិនិព្វានហើយ ។ ពាក្យថា ព្រហ្មចរិយក្នុងទីនេះសំដៅយកសាសនាតាំងមូល សង្គ្រោះដោយសិក្ខាទាំង ៣ គឺ អធិសីលសិក្ខា បានខាងបាតិមោក្ខសំវរសីល ១ អធិចិត្តសិក្ខា បានខាងសមាបត្តិ ៨ ដែលជាទីតាំងនៃវិបស្សនា ១ អធិបញ្ញាសិក្ខា បានខាងវិបស្សនាញាណជាគ្រឿងកំណត់នូវព្រះត្រៃលក្ខណ៍ ១ ។ ព្រោះហេតុនោះ បានជាអដ្ឋកថាចារ្យ អាងពុទ្ធភាសិតនេះហើយបានដាសំដែងថា សាសនាតាំងមូលជាព្រហ្មចរិយមួយដែរ ។

ម្យ៉ាងទៀត សាសនានោះ គឺព្រះបរិយត្តិធម៌ជាធម៌សំរាប់រៀនសូត្រឲ្យស្គាល់ខុសត្រូវល្អអាក្រក់បុណ្យបាប នឹងផ្លូវប្រតិបត្តិដំណើរទៅកាន់ព្រះនិព្វានជាទីបំផុត ឯព្រះបរិយត្តិធម៌នោះចាត់ជាភាសិតមាន ៤ គឺ

ពុទ្ធភាសិត ១ សាវកភាសិត ១ ឥសិភាសិត ១ ទេវតា-ភាសិត ១ ។

ឯពុទ្ធភាសិតនោះ បានខាងវិន័យបិដកទាំងអស់ អភិធម្មបិដកទាំងអស់ ទីឃ ធម្មបទ ចរិយាបិដក ឧទាន ឥតិវុត្តក ជាតក សុត្តនិបាត វិមានវត្ថុ បេតវត្ថុទីឃសូត្រទាំងឡាយ មានព្រហ្មជាលសូត្រជាដើម ។

(មានត)

# សិលាចារិកនគរវត្ត

និង

# បទានុក្រម

(១) . . . . . . . . . . ៥៨ អ្នកសតខេអាសុជ្ញប្រាំបួនរោជ្ជ

(២) . . . . . . . . . . អកហ្វងមនោឌុទេនមានបិត(សា) ទ្ធាំ

(៣) . . . . . . . . . . ព្រះប្រាក ៗ ស្វរៀបហោយទេបអា

(៤) . . . . . . . . . ព្រះសឃ៏តទ្រែងបិត្តុបរិសុទ្ធសិលមោក

(៥) . . . . . . . . . មានអ្នកព្រះគ្រូ បល័ត ទ្ធអកញាណ

(៦) នអ្នកមហាបសិកាទ្ធអ្នកឪខ្សែជេតទ្ធអ្នកស្វស

(៧) . . . . . តសសឃ៏ទាំងនេះ ស្បេតជាព្រះជានអក (៨) ហ្វងមនោឌុទេនមានបិតសទ្ធារយោកទាសិទា (៩) សខ្ញុំម ស្រីខ្ញុំមប្រុសបួនអ្នកឈ្មោះអាព្រហ្ម ១ មេតាង (១០) មេឪមា ១ មេឈាវ ១ ទាំង ៤ នែះ ប្រោសឲយជាសំម រាប (១១) ព្រះនគរតន្ត្រីប្រាសនែះហោងទោះបិអ្នកឯតាមួយ (១២) និងមោករំលោងអ៊ំពីព្រះនគរតន្ត្រិប្រាសនែះ ទោវព្រះពុទ្ធ (១៣) អំបាលខ្សេបកុំបីប្រោសអ្នកនោះលេយ បពិត្រព្រះ ស្រី (១៤) វត្តត្រៃយតេជ្ជះកុសលផលបុន្យអកម្ហងមនោឪទេ (១៥)ន ជ្វនទោតព្រះញាត្តបិត្តរជោងកុំលុងសបួសត្ថា (១៦)

ន នុសត្វដោង្គលឡឿគោព្វតបិតុរាបាយភូម តោ (១៧) យ៉

លេហៀបតល់អក្ខុតិជ្ជព្រិហ្មតោយក្រោមរ៉ូបតល (១៨) អរិបិ

តោយខាង៉ូបតលទសសំហាល្យប្រក្រារាទ្យនែះ (១៩) សូម

ផលានិសង្សនែអកហ្វងមតោឪទេនមានកត្តញ្ញូ ក (២០) ត្តូវ

ទិទ្វី ជូនកុសលផលបុន្យនែះបំរេនអ្នកដោង្គ (២១) អំប៉ាល

នែះ ទោះបិអ្នកដោង្គអំបាលនែះរង្វេងទោលឡ្វង (២២)

ព្វតបិតុរាបាយភូមគុះ តេជ្ជះផលានិសង្សនែះ ស៊ូលិតោះ

(២៣) ឱយរ៉ូបលែងភៃបិតុរាបាយទោពន្ធរាយព្វតត្រិពិធសំ

(២៤) ប្បត្តសំបូណ៌រឹង ទោះបិអ្នកដោង្គ..បាលនែះបានស្មោះ

ភ្លោះ (២៥) ទោស្មោយទិព្វសម្បត្តសំបូណ៌ហោយ តោតេជះ

ផលានិ (២៦) ស ង្សបុន្យ នែះសូមទោបំរេន្យទិព្យសម្បត្តិ

សំបូណ៌ពិពទ្ធិមូ (២៧) យ . . លុះបានបួលតបទមោក

មហោនគរនិញានជា (២៨) ស្ពានបង់តិសហោង បូពិត្រ

ព្រះត្រៃរត្នត្រៃ ទោះយោបិ (២៩) យ អកហ្វងមតោឪទេន្នែះ

បោះលាងបញ្ចខន្ធអំពិជា (៣០) តនែះទោរស្មុំឱយបានស្មោះ

ភ្លោះទោស្មោយទិព (៣១) សម្បត្តសំបូណ៌បានបួលប

មោកមហាតិញ៉ាន (៣២) នតជាស្នានបងឥសហោង បូពិត្រ
ស៊ុំមធុត ៗ រោះសា (៣៣) ធុសនិពាណនេះរោះព្រះមហា
សត្រុដ្ឋពុទ្ធកំម្រតែង (៣៤) យេងស្តេចបន្ទូលហោង ៗ

លេខ ២៣

29 (B)

(១) ស្កមស្បស្តស្វស្បតិស្រិសទ្វាតីរេក ១៥៦១ ស័កឋោះ
អ្នកខ្ស (២) ត្រីខែហផលគុណ ៧ រោជអង្គារពាំ ឥស្បផំនុមអ្នក
មហាស័យរាជ (៣) ព្រះធម្មខិត្តិមហាបូពិត្រ នុអ្នកសម្តេចប្រញា
ន នុអ្នកឱតុល (៤) ធម នូអ្នកមបេរមឆ្នៀជេត នូអ្នកសម្តេចសូ
មេត្តបញ្ញាបូពិត្រ (៥) នូឥស្បបេរានូបេរដោងស្បៀងគិជាសាកស្បិ
ពេជញ្ញាណគាងក្អែ (៦) ហ្វោឱ ហ្វោព្រិហ្ម ហ្វោប្រាប្ស មេទ្វាន មេ
ស្នូហរិ ឥសអ្នកទំងអំម្បា (៧) លនេះ ម្នាបិត្រសាំទ្វាសាងព្រះ
ពុទ្ធធវ្រ ប្សមាសអង្គ ១ ប្រាកអង្គ (៨) ៣ ទុង ១ ស្វវេហ្វ
ហេយអ្នកទំង ៦ នេះ ម្នាមេត្តាករុណាព្រោ (៩) មជាមួយ
ហេយមោកប័ម្បស្បជ្បឱនេះ ឲយប្រែបជាពាំណា (១០) ស្រម

ជ្រិះស្រលះហឥតកម្ទីងលេយ  វិឯហមេកែវផែះយោក (១១) ជ្បូឱ្វផែះជាកូនកេតក្នុងឱទរ  ដូបព្រោប្រាប្ប មេទ្វាន (១២) ឯងពោង ៕ វិសាក្យៀយឯហគ្រិហស្សសោត្រ  ម្ចាព្រះឮប្តរាជ (១៣) ១ អកហ្សងប្លែសវិង្សា ១ ព្រះមតិ្សរាជា ១ ព្រះសរេន្ទ ព្រោ ១ (១៤) ឮព្រោស្មុត ១ ព្រោប្រាប្ប ១ ព្រោតិន្ទ ១ ព្រោ ប័ន្ទ ១ ព្រោនុង ១ (១៥) នូព្រោទាង ១ ព្រោឱរ ព្រោអន មេ ព្រះ ១ វ្សិតស្សអ្នកទ័ង (១៦) អំម្បាលផែះបេហស្រិត្សិពិពា ទូជ្សឱរផែះយោកជាខ្ញុំម (១៧) លេយ ឱយព្រះត្រាស្សអំម្បាល វ៉ៃប្រក្តិ កំម្មឱយព្រោ (១៨) ស្សអ្នកលេយ  មួយសោតបេ ហកំម្រែតែងនបង្គប្ប (១៩) . . . . លេយឱយរត្នាះហទ័ងអនន បក្រាវាលផែះកុំឱ (២០) យបញ្សឈេហព្រឹក្សាតទ៉ៃយលេយេ ឱយបេញតែហអ្ន (២១) កតរេយ៉ាតោះសព្វៗជាតក្នុងេតហោង

nº 30 (B)

(១) សព្វមស្ត ១៥៦៥  សកមមែនាក្សត្រប្រិពិលរោប្ច ភទ្រិប (២) តពារស្មុ១ ឥសជុំនុំក្រិកាយ្សំសយ័ងផោងប្រែន

(៣) មោកជុំនុំម្បៀមាហនូកូណាមូយនូអារត្រ (៤) នែះតោយព្រះពុទ្ធីកាអ្នកព្រះធម្មមិវិត្តីម្ហា (៥) សយ៌រាជបុពិត្រព្រះអង្គឡូវ្រូបជាព្រៃយស្រលាះ (៦) ឥតកំម្ទឹងល្បេរ្លេងៗ មោកលុះឥសព្រះជំនទោរ (៧) នោះមានជុំនុំកំម្រែតែងសយ៌ងក្រិកាយ៉ុគ្របហ (៨) វាលដោងស្បៀងមានបិត្របិតិសោមទសព្រោមត្តូ (៩) បបន្ទាមព្រះអង្គហោង ម្បៀមាហនូកូនិងអារត្រ (១០) នែះឡូវ្រូបជាព្រៃយស្រលាះឥតកុំម្ទិងល្បេ (១១) មានជុំនុំអ្នកយេងអ្នកសំម្តេចប្រេញានបុពិត្រ (១២) នូអ្នកពរាជសិលាបាយ៉ុម្ហាសយ៌រាជបុពិត្រ អ្នក (១៣) វីនៃយធរបុពិត្រ នូអ្នកព្រះសយ៌រាជាម្ហាសង្ឃរាជ (១៤) បូពិត្រ នូអ្នកសំម្តេចព្រះធម្មិសរិកជាតបុពិត្រ (១៥) នូអ្នកម្ហាបេរបរិទក្ខិនបុពិត្រ នូអ្នកសំម្តេច (១៦) សូមេតបុពិត្រ នូឥសសំម្តេចព្រះគ្រូបេរានូបេរសំ (១៧) ម្មោរដោងប្រេន ॥ វៀឥសសិសព្រះអង្គសោតមានអ្នក (១៨) កម្ហាបេមណ្ឌិជេតបុពិត្រ ឡូអ្នកសំម្តេចបរិទក្ខិន (១៩) បុពិត្រ នូអ្នកសំម្តេចព្រះវរជេតបុពិត្រ នូអ្នកកេ (២០) វិនូអ្នកស១ នូអ្នកនៃ នូអ្នកធមណ្ឌី នូអ្នកធមសុត (២១) នូអ្នក

ស្នួនបញ្ជា នូវតិសសំម្លេរតូបទ្នំផោងប្រេន ស៊ី (២២) ងជាសិទ្ធិ វិញ្ញា (ណ) វិងគ្រហាវាសសោតម្នាអ្នកព្រះម្នោ (២៣) រិព្រះ អង្គ នូអ្នកព្រះម្ហាស្នូត នូព្រះសង្ឃករ្សិ តសក្រម (២៤) កាយ្សិ ប្រេន វិងញាតអ្នកសោតម្នាតាយសនូព្រះម (២៥) ណ្ដិរជា នូ ព្រះស្រេនៈបៅរ នូបណ្ឌិតតិន នូហោសាមន្ត្រី (២៦) នូព្រះបៅរ បក្រិយ មៀកែន ហោនោក នូព្រះតន្ត្រីប (២៧) ក្រិយ ហោស្នូរ ងស្រីយៈសោតម្នានាងនុងនាងអ្នំក្រិ (២៨) កាយ្សិអម្ប្បាលនែះ ស៊ឹងជាសិខិវិញ្ញាណត្បង (២៩) តិសសប្ដូគ្គ័យហោង ॥ នូវ្រូ ក្រិកាយ្សិញាតង (៣០) នាពិពាតស្រីត្បយោកម្សេមានូក្លូណវា នែះជាខ្ញុំអា (៣១) ត្នាល្បេ ឲ្យអ្នកនោះទោរកេតព្វតបញ្ជូនន្តរិក ទ្វំប្រាមកុំត្រា (៣២) លតោះរង្គោះព្យួនរកនោះល្បេ វិរន្ធះទ្វំអ ននកុំម្បិបញ្ញ (៣៣) ឈេហាងខែតល្បេ ឲ្យបញ្ញតែអ្នកនោះ សប្បូ ៗ ជាតកំម្នេត (៣៤) វិតសក្រិកាយ្សិអំម្ប្បាលនែះស៊ឹងជា សិខិវិញ្ញានត្បង ប្រ្សោ (៣៥) បិជាមាន្តិងវិញឲ្យអ្នកនោះប្ញង ហោរយជាតកុំម្នេតនូ (៣៦) វ្រញាតនាមួយត្បិងគេបៈពិពាត កេត្រាជាខ្ញុំ ប្រ្សហអ្នកន (៣៧) មួយគ្បិជួយអាស្នូរកុនហៀឲ្យ

អ្នកឥសអំម្បាលនោះ (៣៨) ព្រោងព្រាយពន្ទាទៅរស្វគ្គ សម្បាតសប្បៗ ផាតកុំម្ទេ (៣៩) តហោង ॥ ០ ॥ ម្ចាអ្នក សំម្តេចកម្ឡោបាម្និសសិររំម (៤០) លោមសកម្ចាអ្នកម្ហាបេរជេត វង្សាបុពិត្រ ॥

no 31 (B)

(១) សព្ទម្នសត្មមង្គលពហុលបេស្តាជ្យោតិ្យរេក (២) ១៥៨៤ ស័កន័កខ្យត្រឆ្នាំមខាលអដ្ឋមិរោជ្ជបុសថ្ងៃ (៣) ព្រះហាសសម្តិ យព្យារសារណា ឥសជុំនុំម្ចាសយ៍រាជ្ជពា (៤) រាជ្ជសោមង្គល សិលាបុពិត្រ នោអ្នកយេងអ្នកសំ (៥) ម្តែចបរិវវ៌ទូបុពិត្រនោ អ្នកសំម្តែចឪទៃយបញ្ញា (៦) បុពិត្រ នោអ្នកសំម្តេចសត្តាវិរ បុពិត្រ នោអ្នកសំ (៧) ម្តេចគាថាបារម្មិយបុពិត្រ នោឥស សំម្តេចព្រះគ្រូ (៨) បេររាគោបេរសម្ទេរដោង គាឯគ្រហសសោត នោ (៩) មានអ្នកព្រះឥន្ទស្បេង ១ អ្នកព្រះស្សូរព្រះអង្គ ១ អ្នក (១០) ព្រះឪភេយរាជ្ជ ១ អ្នកអៃរ ១ អ្នកគូ ១ អ្នកគុង ១ (១២) អ្នកព្រិហ្ម ១ ឥសអ្នក៍អំម្បាលនេះសិងតិ្យផាសុក្តិ (១៣) វិញ្ញាណ ឯអ្នកម្ចាសយ៍រាជព្រះរាជសិលាបាយ្យបុពិត្រ

(១៤) ព្រះអង្គអានុបធម្មទោហៀរនោះនោមានហោពោ មេ (១៥)
អំម្មគិជាផ្គណហៀរហោព្រិហ្ម មេបែញ ហោលុក្ខ មេស្វូស (១៦)
ហោធុន ហោរស មេពោ ហោព្រិហ្មសោត មេមោក្ខ ហោ (១៧)
ព្រិហ្មនៃ មេឱ មេបូល មេនោរ៍ សិងគិជាក្ខយតមានបិ (១៨)
ត្តុសិងតសារទ្វាសម្មោសរអនុក្ខុលមូលព្រមអនមោទ (១៩)
នាជាកុសលម្ប្យអន្ទេហានិងម្ចាស់យ៉ាជព្រះអង្គអា (២០) នុប
ធម្មទោនោះ ឥសអ្នកទំអម្ប្យាលនោះមោកប្រោស (២១)
មេឯប មេមោក្ខ ម្តាយនិងកូននេះឱយរ្រូបជាព្រៃ (២២) ជ្រោះ
សលាះហៀរម្បូនីសោតឲ្យយ. . . . ព្រះអង្គម្ចាស់យ៉ (២៣)
រាជ្ជអានុបធម្មនោះហោង នរូបោងធ្វណាកូណាក្ខយឥនា ៗ
(២៤) ម្ប្យ. មោកពិពាតមាត្រ្តាស្រតីហាមេឯបមេមោកនេះជា
(២៥) ខ្ញុំមល្បៀឱយពិនៃតោយប្បាប្បុហោង ហៀរមានតែអំ
(២៦) ម្ប្យាលនោះល្បៀឱយរគ្នាះទំងអនន្តបក្រ្កពាលកុំម្បិឱយ
(២៧) ប៉ញ្ញឈេហាតទៃក្រៃលែងល្បៀ ឱយប៉ញ្ញតែអ្នកនោះស
(២៨) ប្ប្យ ៗ ជាតកំនេតហោង មានតែអំម្ប្យាលនោះល្បៀ រ៍
(២៩) ព្រះទំអំម្ប្យាលខ្សែបកំម្ប្យិត្រាប្រោសអ្នកនោះតលម្តោ

(ង) (៣០) លេយហោង កាលនាបេស្សភាពតោយនោធម៌ សោត (៣១) ឱយអ្នកនោះបានសម្បាតនិរញ្ញាសប ៗ ផាត កុំនេតហៅ (៣២) បារិកនេះអ្នកម្ចាបេរបញ្ញាវិនៃហោះ ។

nº 31 (ខ)

(១) សព្វមុសស្តុស្វស្តិគ្រីភីមង្គលពហូលបេស្តាជៃយាតីរ (២) ក ១៥៨៥ អ្នកឧប្រត្តិឆ្នាំបិះខែហេកាតិកពេញបណ៌ (៣) ថ្ងៃ យពុទ្ធវារសណ្ហា ឥសជុំនុំកុំរវត្រែងសយ៍ផោង (៤) ត្បូទកាល នាងហ្មេមមោកគិតនឹងសាងកុសលផលប្បុន (៥) ពេនាះឱយ លោកសាងព្រះពុទ្ធអង្គមាស ៤ ព្រះពុទ្ធរូ (៦) ប្បអង់ប្រាក ៤ នូ ទងអប្បភិធ្នុ១ផ្តាន ១ គឺជាទ័ភាយខ្សែ (៧) ព្រះពុទ្ធកុំរតែងយេងគឺ ជាស្សុរេបហ្មេមោកអាវាទនាឡឹម (៨) ននូឥសយ៍ផងទំហ្លាយ ៣០ មោកស្សត្រម្មននូលេនាព្រះពាន (៩) នាកាលព្រឹក រាប្បបាទ្ធនោះមោកទូលព្រះពុទ្ធតីកាឥស្សស្រម្ម (១០) តែបអា រិសយ៍ផងទ័ហ្លាបអាទីនាមានទុំមនេត្វគឺជាតេមវ៍ (១១) នយស៍ តែបមហាសយ៍ភាជសុមង្គលសីលាចោរយ៉ាមហាសយ៍ភាជបូពិត (១២) នូអ្នកសំតែបព្រះបរវិទូនូអ្នកសំតែបឱ្យខៃប្រញ នូអ្នកសំ

(១៣) តែបបរិធំម្នា នូអ្នកសំតែបអារីវង្សា នូអ្នកសំតែបព្រះរាជ
កិរ្សិ (១៤) នូអ្នកសំតែបមហាបាលី នូអ្នកឱតុលញ្ញាណនូអ្នក
បញ្ញាភិណ (១៥) នូសំតែបបេរភានូបេរដោងសិងត្នូម៉ីងតឹងផង
នាកាលនាង (១៦) ហៀមមោករត្តាប្បូឆ្លោងព្រះនូលេនាព្រះ
ពានតោះនាងហៀមមោក (១៧) ស្រិត្យហ៊ា ព្រះសានាយុក គិ
ជាថ្ដីយកសមានជុំមឃ្យូទូរុណតោះមោក (១៨) ស្រិត្យផ្ដាម
ទ្វាហៀមគិជាប្រពន្ធហ៊ាជ្យែឡែនេះ មានគុនសប្បូរស្សប្រែនឱយ
(២០) បូស្សបជាព្រៃយស្រលាះអ៊្យិតកុំតឹងលេ នាប្រាកលឹង
១០ នេះឱយជ្បៃ (២១) ឡហោង ឯផ្ដុំណាមានជ្យលើក ជ្យ
ងូណ ឯកូនមានជ្យព្រម្នា ទ្វា (២២) សិតព្រមលមម្យូន្លេហាតិ
[ ង ] ម្ដាយអាពុកហោង ម្យូឃ្មិសោតអ្នកតជា (២៣) សទ្ធិវិញ
ណាមានព្រះធិកយោហ៊ា នូជ្យសុក្ខ នូជ្យធូរ នូជ្យនុង នូរ (២៤) ហារី
នូ ជ្យភឹម នូហោរសោក នូអ្នកសីន នូហោរសោម នូជ្យអាម្នា (២៥)
នូហោរស្សេះ នូហោកូយ នូហៅមុរ ហៅអ្យែរ នូជ្យឱង នូជ្យបន (២៦)
ឯស្រីយសោតមានអ្នកទ្វាមោក នូទ្វាតយ នូទ្វាឱក នូទ្វាមាហា
(២៧) នូនាងចិប្បូ ទ្វាលារ នូនាងឱន នូទ្វាឯម នូនាងប្បុសទ្វា

ផាត ត្វានុង (២៨) វែតល្បអ្នកទងអឹម្បាលនែះ តរឹងតជា សទ្ធីវិញណាប្រតីសោម្មស្ប (២៩) ស្មុគ្គតាសាធរសឹងតព្រម លម្មផាម្បូអន្លេនឹងព្រះសាតាយុក ត្វត្វារ (៣០) ហ្យូមនែះ ហោង ហាប្រឹហមាឥបងផ្ទុឥក្វូទហៅឯៗក្តិ ហាប្រឹហ (៣១) មោកពិពាតមាត្រាហាជ្យូនៀនែះហាដាខ្ញុំមល្បេ ព្រះពុទ្ធ (៣២) ត្រាស្បូឈ្លតកន្លោងទៅហ្យេក្តិព្រះពុទ្ធតានឹងត្រាស្បូងភ្លេ (៣៣) កមោកក្តិកុំម្បិយប្រោស្បអ្នកតោះលេ ហ្យេវាក្វាះទងអា (៣៤) គនបាក្រ្កាវិលបញ្ញមហាប្រត្តពីក្តិ បញ្ញរេលព្រឹក្សាក្តិ កុំម្បិ (៣៥) បញ្ញលេ បញ្ញតែអ្នកតរ៉ហាបំម្មរោស្បនោះហោង (៣៦) បារីកនែះសំតែបព្រះរាជ្យកិរីសាង់បោះប្វៃយពុទ្ធ (៣៧ នែះហោង ॥

លេខ ២២

№ 28 (B)

(១) អ្នកសតខេអាសុជ្ឈ *សំ. ខ. នក្សត្រ ខែអស្សុជ ។*

(៧) ស្យតជាព្រះជាទ *ខ. សំ. សិតជាប្រធាន គឺ សុទ្ធ ជាប្រធាន ។*

(១៦) ទុសត្វផ្ដោងលស្បៀតោពូតបិតុរាបាយភូម *ខ. សំ. ទូវ សត្វផងដល់ទីនៅឰដបតុកបាយភូមិ ។*

(២៧) បូលត- បទមោកមហាគគរតិញ្ញាន *សំ- ចូលដ៏-បទ មោក្សមហានគរនិពាន ។ ម.... បទមោក្ខមហានគរនិព្វាន ។*

លេខ ២៣

№ 29 (B)

(១) ស្ដុមស្បស្ដ ស្វស្បតិស្រិសទ្ធាតិរេក *សំ. សុកមស្តុ ស្វស្តិស្រីសទ្ធាតិរេក ។*

(៩) បម្បុសជ្បុឪ *ខ. បំបួសដីឪ ។*

(១២) ព្រះឰប្តរាជ *(ភាស) ព្រះឰបណ្ណរាជ ។*

(១៣) អកហ្បុងប្បែសរង្សា *(ភាស) អកបុរិធិបេសវង្សា ។*

(៤៣) ព្រះមន្ទិរាជា (ឆ្នារ) ព្រះមុន្ទីកជា ។

(១៣) ព្រះសរេន្ទ (ឆ្នារ) ព្រះស្រែនទៅ ។

លេខ ៦៦

No 30 (B)

(១) នាក្សត្រប្រិពិលរោបូភទ្រីបតពារសុខ សំ. ១. នក្សត្រ ប្រាំពីរពេច កទ្រិបទ ពារសុក្រ ។ ពារសុក្រ=ថ្ងៃសុក្រ) ។

(៦) រ្ម ង ៗ មោកលុះតិសព្រះជន់ ១. រៀន ១ មកលុះអស់ ព្រះជន្ម ។ ដែលត្រូវគួរជាសរសេរថា រៀន, សរសេររ្មន មើលថា រឿន គឺស្រៈ េ- នឹង -្យ ជា េ-ៀ , ស្រះ េ- នឹង ឺ ជា េ-ឿ ។

(៩) មៀមាហន្តភ្និងអារត្រ ១. មេមាំ នូវកូន . និងកាកត់ ឬ អារ័តន ។

(២៣) ព្រះម្ហោរិព្រះអង្គ (ឆ្នារ) ព្រះមន្ទព្រះអង្គ ឬព្រះមៈនា ព្រះអង្គ ។

(២៥) ព្រះមណ្ឌិរជា (ឆ្នារ) ព្រះមណីកជា ឬព្រះមុនីកជា ។

(២៩) ត្បងតិសសប្ជត្តិយ ១. ដៀនអស់សេបក្តិ គឺដីនអស់ សេចក្តី ។

(៣២) រិត្នាះទំអនន កំម្បិបញឈេហងទែតល្បេ *១. រទ្រុះទាំង អនទ្ទ កុំបីបាញ់ឈើងទៀតឡើយ ។*

(៣៥) ប្អេហបាជាមាត្ដិងវិញ *១. បើថាជា មិនដឹងវិញ ។*

(៣៥) ប្លិងបារយជាតកុំម្មេត *១. ជូនហារយ (៥០០) ជាតិ កំណើត ។*

(៣៦) ន្វ្រញាតនាមួយត្យិង *ខរូ ញាតិណាមួយដឹង ។*

(៣៧) ប្អេហអ្នកន មួយគ្យិជួយអាស្សូរកុន *១. បើអ្នកណាមួយ គឺជួយអាសូរកូន ។*

(៣៩) ម្នាអ្នកសំម្ដេបកង្ហោបាម្មិសសិរ *(ឈ្មោះ) មានអ្នកសម្ដេច កហាបារមីសរសេរ ។*

(៤០) សសិររំលោមសក់ *១. សរសេររំលំសក់ គឺសរសេរព្រាន ហើយទើបយកទៅផ្ដិត ឬគូរតាមទូរផែនថ្ម រួចទើបឆ្លាក់តាមនោះជាក្រោយ តែក្នុងច្បាប់បូរាណមាត្រា ៥៤២ មានពាក្យថា សំបុត្រគាំ រំលំសក់ ក្នុងទីនេះបានសេចក្ដីថា ធ្វើសំបុត្របួម ។*

*លេខ ៤៥*

nº 31 (B)

(៩) ព្រះតិន្សៀង *(ការ) ព្រះឥន្ទ្រសេង្ហ (ម. ឥន្ទ្រសិង្ហ ? )*

(១០) ព្រះឱភោយរាជ (ឆា:) ព្រះអភ័យរាជ ។

(១៤) អានុបធម្មទោហៀ្យ ម. ១. អនិច្ចធម្ម-ទៅហើយ ។

(១៨) សម្មោសរអនុកូល ម. សមោសរ អនុកូល ។ សមោ-សរ ប្រែថា ស្រុះស្រួល- ប្រដុំពុះ- ព្រមព្រៀង ។ អនុកូល ប្រែថា ប្រព្រឹត្តតាម- បណ្តោយតាម - អនុវត្តតាម ។

(២៣) គ្រូបោងផ្ទិណា ១. នរបង់ប្អូន = គោះបង់ប្អូន ។

(២៦) វត្ថះទ័អគត្ថបក្រុពាល ១. សំ. វត្ថុះទាំងអនន្តបក្រពាឡ ។

(៣០) កាលនាបេស្យភាព ១. កាលនាបើសូភាព ។

(៣១) សំម្បាតនិរញ្ញាសបៈៗ ជាតកុំនេតហៅ សំ. ១. សម្បត្តិទ័ព្វានសព្វ ។ ជាតិកំណើតៈហាន ។

លេខ ២៦
№ 31 (B)

(៦) ន្ទូទងអប្បភិធ្ម ១. ម. ទូទន់-អភិធម្ម គឺទន់-ធម្មធជ: ឬធម្មិធ្វជ: ដូចមានអធិប្បាយមកហើយ ខាងដើម ។

(៦) គឺជាទ័វាយ ១. គឺជាដង្វាយ ។

(៨) ស្បូត្រមន្ទូលេនាព្រះពាន សំ. ១. សូត្រមន្ត នៅលើនាព្រះពាន់ ។ ពាក្យថា ព្រះពាន់ ជាឈ្មោះថ្នាក់ ១ នៅទីប្រាសាទនគរវត្ត គឺកន្លែងដែលហារីកអក្សរអំបុាលនេះ ។

(៩) ព្រឹកកាប្បាទុ ១. *ព្រឹកកប់បាត្រ ។*

(១០) មានទុំមនេត្យគឺជាតេម ១. *មានទំនើប គឺជាដើម ។*

(១៧) ព្រះសាតាយុក-គិជាធ្ដិយកស ម. ១. *ព្រះវេស្សានាយក-គឺជាប្ដីកាល . . . ។*

(១៧) ជុំមឃ្យីទូរុណា ១. ម. *ជម្ពូទូរុណ ។ ពាក្យថាទូរុណ មកពីពាក្យមគធៈថា ទារុណ ប្រែថា ខ្លាំង-អាក្រក់-ខ្លោចផ្សា- គឺ ឈឺធ្ងន់ ។*

(២២) ព្រមលម្បធ្លោបា ១. *ព្រមល្មមមួយអន្ទើ ។*

(២៣) ព្រះធិកយោបា (*ឆាវ*) *ព្រះធិកយោធា = ព្រះអធិកយោធា ។*

(២៨) ប្រិតីសោម្មស្ស សំ. *ប្រីតិ សោមនស្ស (ម. បីតិ សោមនស្ស) ។*

(២៩) ស្មុគ្គតាសាធរ ស. ម. *សមុគ្គតាសាទរ = សាទរ ឡើងដោយព្រមព្រៀងគ្នា ។*

(៣៤) បញ្ញមហាប្រត្តពិក្តិ ១. សំ. *បាញ់-មហាប្រថពីក្ដី ។*

(៣៥) អ្នកតីរហាបំម្មពោស្ស ១. *អ្នកដ៏រើបម្រាស ។*

# រឿងព្រេងខ្មែរ

## ១ — រឿងចៅតប់ប្រមល់

ដើមឡើយមានបុរសពីរនាក់បានធ្វើកងការកុសលជាមួយគ្នា លុះបុរសទាំងពីររំលាងខ្លួនទៅ បុរសម្នាក់បានទៅចាប់ជាតិកើតជាព្រះឥន្ទ្រាធិរាជ បុរសម្នាក់ទៀតទៅចាប់ជាតិកើតជាបុរសកំសត់មានប្រពន្ធក្រលំបាកណាស់ រកស៊ីនេសាទដាក់លបយកត្រីជាអម្រែស់អម្រែចិញ្ចឹមជីវិត ។ គ្រានោះ ព្រះឥន្ទ្រាធិរាជបានបើកព្រះនេត្រទិព្វ ទតមកឃើញបុរសនោះវេទនាលំបាកដូច្នោះ មានសេចក្ដីអាសូរករុណា លុះដល់យប់ព្រះឥន្ទ្របានយកមាស ៣ ដុំទៅដាក់ក្នុងលបរបស់បុរសនោះ លុះព្រឹកឡើងបុរសនោះទៅលើកលបនោះមើលឃើញមាសនោះមិនស្គាល់មាសទៅជាថាថ្មវិញ ក៏ចោលទៅក្នុងទឹកហើយបានដាក់លបនោះទៅក្នុងទឹកវិញ បុរសបានមកលើកលបទៀតគំរប់ ៣ ដង ព្រះឥន្ទ្របានយកមាសនោះដាក់ក្នុងលបនោះដូចមុនទៀត បុរសឃើញដូច្នោះហើយទឹកខឹងក៏បានចងមាសទាំង ៣ ដុំនោះពុនយកទៅធ្វើជាថ្មចង្ក្រានដាំបាយ ប្រពន្ធបុរសនោះក៏មិនស្គាល់មាសក៏បានយកមាសនោះទៅធ្វើជាថ្មចង្ក្រានតាមពាក្យបុរសជាប្ដីនោះ ។

ក្រោយនោះមានព្រះរាជអាជ្ញាមកកត់ទារពន្ធព្រះរាជធានី មើលទៅឃើញមាសដែលបុរសនោះធ្វើជាថ្មចង្ក្រាន នោះព្រះរាជអាជ្ញាបាននិយាយ

នឹងបុរសនោះឲ្យយកមាស ៣ ដុំបង់ជាពន្ធដែលបុរសនោះជំពាក់រាជការ បុរសនោះនឹកអរណាស់ ដោយខ្លួនទ័លក្រ ហើយព្រះរាជអាជ្ញាយកថ្មបង្ក្រានដូច្នោះក៏ព្រមតាម បានប្រគល់ថ្មទាំង ៣ ដុំនោះទៅឲ្យព្រះរាជអាជ្ញា លុះព្រះរាជអាជ្ញាបានដុំមាសពីបុរសនោះហើយ បានយកមាស ១ ដុំទៅថ្វាយព្រះមហាក្សត្រិយ៍នោះ ស្ដេចបានសាកសួរពីហេតុដែលបានមាសនោះ ព្រះរាជអាជ្ញាទូលស្ដេចតាមដំណើរ ស្ដេចបានជ្រាបថា បានមាសពីបុរសនោះដូច្នោះ ស្ដេចឲ្យហៅបុរសនោះ ៗ ទៅដល់ហើយ ស្ដេចសាកសួរទៀត បុរសនោះទូលស្ដេចថា មាសរបស់ខ្លួន ៣ ដុំដែលជូនមកព្រះរាជអាជ្ញានោះ ស្ដេចបានទារយកមាសពីព្រះរាជអាជ្ញាពីរដុំនោះទៅទៀត ស្ដេចបានបង្គាប់ឲ្យបុរសនោះរកមាសយកមកថ្វាយស្ដេចថែមទៀត បុរសនោះទូលស្ដេចថា រកមាសនោះពុំបានទេ ស្ដេចឲ្យយកបុរសនោះទៅឃុំដាក់គុកទុក ព្រឹក ៗ ឡើងនាយជំរួតដែលជាអ្នករក្សានោះប្រើឲ្យធ្វើការជេរស្ដីបុរសនោះ ឮដល់ស្ដេច ៗ បានសួរបុរសនោះពីហេតុធ្វើការឲ្យមានទីទាស់ចិត្តនាយជំរួតនោះ បុរសនោះទូលទៅស្ដេចថា ទូលព្រះបង្គំទតប់ប្រមល់ក្នុងខ្លួនខ្លាំងណាស់ ស្ដេចក៏មានបន្ទូលថា បើដូច្នោះឲ្យឯងះទៅរកសត្វតប់ប្រមល់មកឲ្យអញ បើឯងរកពុំបានទេ អញនឹងឲ្យពិឃាតឯងក្នុងគុកនេះ បុរសនោះឮដូច្នោះហើយក៏ភ័យស្លុតក្នុងខ្លួនថា មុខជាស្លាប់ក្នុងគុកនេះហើយ មិនដឹងជាទៅរកសត្វតប់ប្រមល់ឯណាទេ

តែមិនហ៊ានប្រកែកដោយខ្លាចអំណាចស្ដេចក៏ក្រាបបង្គំលាស្ដេចដើរចេញទៅ បំណងក្នុងចិត្តបុរសនោះគិតដើរឲ្យដល់ស្លាប់ក្នុងព្រៃ លុះដើរចូលព្រៃឆ្ងាយទូលាយទៅ ៗ ព្រះឥន្ទ្រាបានបើកព្រះនេត្រទិព្វទតមកឃើញបុរសនោះដើរក្នុងព្រៃ មានសេចក្ដីវេទនាលំបាកដូច្នោះ ក៏បានជ្រាបដោយប្រាជ្ញាទិព្វឈ្វេងយល់គ្រប់ប្រការ ព្រះឥន្ទ្រាបាននិម្មិតជាអាស្រម ១ នៅពីខាងមុខបុរសដែលទៅ ហើយព្រះឥន្ទ្រាបានក្រឡាខ្លួនធ្វើជាព្រះមហាឥសី បុរសនោះមើលមើលទៅឃើញអាស្រមដូច្នោះហើយ បុរសនោះមានចិត្តត្រេកអរក៏ដើរចូលទៅក្នុងអាស្រមនោះ ឃើញឥសីក៏ថ្វាយបង្គំ ទើបឥសីសួរបុរសនោះថា ចៅមានហេតុអ្វី ៗ បុរសនោះទូលឥសីតាមដំណើរដែលស្ដេចឲ្យរកសត្វគប់ប្រមល់ យកទៅថ្វាយនោះ ឥសីថា ចៅកុំព្រួយ រួចឥសីបានយកបំពង់ពកមកហើយលោកបានសែកនូវមន្តវិជ្ជាសិល្បសាស្ត្រកើតជាខ្លា រាជសីហ៍ សិង្ហ គោ ដំរី ពស់ រមាស សឹងជាសត្វសាហាវទាំងអស់ ហើយឥសីសែកជប់បង្រួញសត្វទាំងនោះច្រកក្នុងបំពង់ពកនោះ ហើយបានប្រគល់បំពង់ពកនោះឲ្យទៅបុរសរួចផ្ដាំថា ឲ្យយកទៅថ្វាយស្ដេច ប៉ុន្តែមុននឹងបើកឆ្នុកនោះឲ្យស្ដេចប្រមូលព្រះរាជវង្សានុវង្សឲ្យជុំហើយបិទទ្វារវាំងឲ្យជិត សឹមបើកឆ្នុកមើល ព្រោះសត្វនោះរត់រហ័សណាស់ ៗ

លុះបុរសនោះបានទទួលបណ្ដាំឥសីស្រេចហើយ ក៏នាំយកសត្វនោះទៅ លុះបានដល់ទៅស្ដេចហើយ បុរសនោះទូលតាមដំណើរ ស្ដេចក៏បានឲ្យប្រមូលព្រះរាជវង្សានុវង្សជួបជុំហើយ ស្ដេចចាត់ឲ្យបិទទ្វារវាំងកំពែងស្រេច ស្ដេចឲ្យអាមាត្យបើកគ្រុកបំពង់ពកនោះ សត្វរាជសីហ៍ ខ្លា ដំរី សិង្ហ គោ ពស់ចេញពីក្នុងបំពង់ពកនោះ ក៏ខាំស៊ីស្ដេចនឹងព្រះរាជវង្សានុវង្សនោះមរណភាពអស់ទៅ ។

ក្រោយនោះ ពួកអ្នកនគរបានឃើញបុរសនោះមានរិទ្ធិអានុភាព ដូច្នោះក៏រៀបអភិសេកបុរសនោះអញ្ជើញឡើងសោយរាជសម្បត្តិ ជាព្រះមហាក្សត្រិយ៍ក្នុងព្រះនគរនោះតទៅ ។

ឯសត្វទាំងឡាយក៏លាស្ដេចបុរសនោះចូលទៅនៅព្រៃ តែថា បើស្ដេចមានភ័យ ប្រការអ្វី នឹកដល់សត្វទាំងនោះៗ នឹងមកជួយយកអាសាជាដរាប ។

រឿងនេះចប់តែប៉ុណ្ណោះ ។

## រឿងជីប៉ាងតាងតី

ក្នុងសម័យនោះគឺខែរដូវស្រូវទុំ តាប៉ាងក៏ទៅដេកចាំស្រូវរក់ទាំងយប់ថ្ងៃ មានទាំងតាប៉ុមួយទៅផង វេលាថ្ងៃឡើងមើលថែទាំស្រូវ ដល់ពេលយប់ទំនេរតាំងដេញតាប៉ុហើយប្រែកប្រៀនផង លុះកល់យប់ទៅ

មានខ្មោចស្រីក្រមុំម្នាក់ពួសរូបដំនៀនសៀនតាប៉ិតកេះពេកណាស់ ក៏ដើរទៅស្ដាប់ ទៅអង្គុយអាំងភ្លើងក្រោមខ្ទមអាប៉ាង យូរបន្តិចទៅអាប៉ាងក្រឡេកទៅក្រោមខ្ទម ឃើញខ្មោចដែលដំណែងខ្លួននោះអង្គុយអាំងភ្លើង អាប៉ាងសួរទៅថា អាណាអង្គុយក្រោមខ្ទមនោះ មេខ្មោចនោះថា ខ្ញុំ ហើយអាប៉ាងថា ប្រហែលជាខ្មោចទេ មេខ្មោចនោះឆ្លើយថា ខ្មោចថាមិនខ្មោច អាប៉ាងសួរទៅទៀតថា ហាងឯងឈ្មោះអ្វី មករកអ្វី មេខ្មោចឆ្លើយទៅវិញថា ខ្ញុំឈ្មោះ តី ខ្ញុំមកស្ដាប់តាប៉ី អាប៉ាងថា ឡើងមក បើមកស្ដាប់តាប៉ី ខ្មោចនោះក៏ឡើងទៅអង្គុយជិតអាប៉ាង ក៏ស្រឡាញ់គ្នាយកគ្នាជាប្ដីប្រពន្ធទៅ លុះដល់រួចស្រេច មេខ្មោចនោះសួរទៅអាប៉ាងថា ឥឡូវរួចស្រេចហើយ តើឯងព្រមយកអញឬទេ បើឯងមិនយកអញៗនឹងកាប់យកឯង អាប៉ាងថា អញព្រមយក ប៉ុន្តែចាំអញដឹកស្រាយកទៅទុកសិន លុះអាប៉ាងដឹកស្រាយកទៅទុករួចហើយ ក៏ត្រឡប់មកយកមេកន្ទីនោះវិញ មេកន្ទីក៏នាំអាប៉ាងទៅសំពះដំរាបសួរពួកបងប្អូនខ្មោចទាំងប៉ុន្មាន រួចក៏នៅជាមួយគ្នាដូចធម្មតា ។

ប្រហែលជាងមួយខែ ពួកខ្មោចទាំងប៉ុន្មានមកបបួលគ្នាព្រមទាំងអាប៉ាងឲ្យទៅរកបាញ់សត្វមកធ្វើជាអាហារ អាប៉ាងក៏ទៅជាមួយនឹងពួកខ្មោចនោះ លុះទៅដល់កណ្ដាលព្រៃដើបត្រថុក ពួកខ្មោចទាំងពួងថា ដើមឈើទាលហើយបានប្រទះនឹងសត្វកង្កែបមួយ ខ្មោចទាំងនោះស្រែកថា

ប្រយ័ត្នវ៉ៃយកនយើង ដំរីធំណាស់ទៅហើយ ៗ អាប៉ាងពូកែស្រែកថា ដំរីនោះក៏ប្រឹងគេមើលមិនឃើញដំរីនោះសោះ ឃើញតែសត្វកង្កែប លោតមកត្រង់មុខអាប៉ាង ៗ ក៏ចាប់សត្វនោះដាក់ក្នុងថង់សំពត់បាត់ទៅ ហើយពួកខ្មោចអស់នោះចេះតែស្រែកថា ប្រយ័ត្នវ៉ៃដំរីស្ដាមួយធំណាស់ ហើយស្រែកសួរទៅអាប៉ាងថា វ៉ៃអាប៉ាងឃើញដំរីឬទេ អាប៉ាង ស្រែកថាមិនឃើញទេ ខ្មោចប៉ុន្មានក៏នាំគ្នាដើរមកដល់ជិតអាប៉ាងហើយ ថា ទៅអាប៉ាង ទៅផ្ទះ យើងរកសត្វមិនបានទេ អាប៉ាងថា អញបាន កង្កែបមួយ ខ្មោចទាំងនោះសួរទៅអាប៉ាងថា យ៉ាងដូចម្ដេច អាប៉ាង សត្វកង្កែប ឯងចែកយើងពល់គ្នាយកធ្វើស៊ីផង អាប៉ាងក៏ដកកង្កែបពីថង់ ហើយបង្ហាញទៅពួកខ្មោចនោះ ខ្មោចអស់នោះឃើញ ក៏នាំគ្នារត់ព្រាង ព្រាត់អស់ទៅ ហើយមានពាក្យថា ប្ដីមកក្ដីឲ្យនៅមិនបានទេ ព្រោះ វាពូកែណាស់ វាហ៊ានចាប់ដំរីយកទៅដាក់ក្នុងថង់វា បើដូច្នេះយើងត្រូវ ឲ្យអាប៉ាងនេះនៅមិនបានទេ ឲ្យវាទៅវិញទៅ អាប៉ាងក៏បានរួចខ្លួន ហើយត្រឡប់ទៅផ្ទះវិញទៅ ៗ

ចប់រឿងអាប៉ាងតែប៉ុណ្ណោះ

## រឿងគ្រូហោរម្នាក់នឹងតាចាស់ដូនចាស់

មានហោរម្នាក់ជាអ្នកទាយគន់គូរមើលពូកែចុះណាស់ នៅស្រុកជាមួយនឹងតាចាស់យាយចាស់ មានកាល ១ ថ្ងៃតាចាស់ដូនចាស់គាត់នាំគ្នា

ទាំងពីរនាក់ៈទៅរកនេសាទត្រីដោយបង់បួរនៅក្បែរភូមិគាត់ៗ សម័យនោះ គាត់រកបានត្រីរ៉ស់ ១ ហើយនឹងទន្សាយលង់ទឹក ១ ដល់ល្ងាចគាត់ត្រឡប់មកផ្ទះវិញ គាត់យកទន្សាយគ្របនឹងអង្រុតទុកនៅក្នុងកណ្ដាលសួនច្បារគាត់ ១ នៅមុខផ្ទះ ត្រីរ៉ស់គាត់ដាក់ក្នុងទ្រុងប្រស់ក្នុងស្រះនៅកណ្ដាលសួនច្បារគាត់ក្បែរកន្លែងដាក់ទុកទន្សាយ ដល់ព្រឹកឡើងតាចាស់យាយចាស់គិតគ្នាថាយើងទៅរកគ្រូហោរទាយមើលថា ព្រឹកនេះយើងបានម្ហូបអ្វីស៊ី បើគ្រូហោរនោះទាយត្រូវសុំជឿថា ពូកែមែន ព្រោះយើងពីម្សិលមិញចាប់បានត្រីរ៉ស់ ១ ទន្សាយ ១ បម្រុងទុកនឹងធ្វើម្ហូបអាហារស៊ីព្រឹកនេះ ដល់ព្រមព្រៀងគ្នាស្រេចហើយក៏ដើរទៅបានដល់ទៅមុខផ្ទះគ្រូនោះ តាចាស់ក៏ស្រែកសួរទៅម្ចាស់ផ្ទះ អើអ្នកអើយ លោកគ្រូគាត់នៅៗហ្នឹងឬ ម្ចាស់ផ្ទះក៏ប្រាប់មកតាចាស់ជូនចាស់វិញថា គាត់នៅនេះទេ មានការអ្វីតា-យាយ-អញ្ជើញចូលមក តាចាស់យាយចាស់នាំគ្នាចូលទៅបន្តិចគ្រូហោរសួរដណ្ដឹងមកតាចាស់វិញ ចុះអញ្ជើញមកនេះមានការអ្វី តាចាស់យាយចាស់ក៏ដំពបទៅគ្រូនោះវិញថា ខ្ញុំមកនេះមានការបន្តិចសូមលោកគ្រូមេត្តាករុណាចុះ គ្រូហោរសួរទៅវិញថា ចុះមានការអ្វី ចូរនិទានមកចុះ ថាឱលោកគ្រូអើយ យើងខ្ញុំទាំងពីរនាក់នេះអត់ម្ហូបអាហារទំទួលទានចំនួន ២-៣ ថ្ងៃនេះហើយ តើក្នុងព្រឹកនេះនឹងបានអ្វីទទួលទានខ្លះឬទេ គ្រូហោរតាំងចាប់ក្ដារឈ្នូនឡើងវាយលេខអត្ថៈមើលឲ្យតា

យាយ មើលរួចស្រេចក៏ជំរាបតាយាយវិញថា ក្នុងពេលព្រឹកនេះតាយាយឯងមុខជាពិសាប្រហុកក្នុងពាងហើយ តាយាយឮគ្រូហោរថាដូច្នោះ ក៏នឹកក្នុងចិត្តថា គ្រូគ្មានពូកែទេ ទាយផ្ដេសផ្ដាសសោះ យើងកុំជឿ គិតតែប៉ុណ្ណោះក៏នាំគ្នាលាគ្រូហោរមកផ្ទះវិញ ហើយយាយចាស់ក៏ប្រើតាឲ្យទៅចាប់យកត្រីពីក្នុងទ្រុង មកដល់ពូកយកត្រីមកក្រៅពបង្អាស់រួចទៅ តាក៏ស្ទុះទៅយកអង្រុតដែលត្របទន្សាយមកដេញរុតត្រី ឯទន្សាយនៅក្នុងអង្រុតនោះក៏ផ្អើលរត់បាត់ទៅ ។ យាយមើលពីលើមកឃើញទន្សាយរត់បាត់ទៅចូលក្នុងព្រៃក៏ស្រែកហៅតា ៗ ទន្សាយរួចទៅហើយ តាគាត់ប្រាប់ទៅវិញថា យាយអើយត្រីពបង្អាស់រួចពីដៃអញទៅហើយ យាយក៏បន្ទោសតាថា តាឯងសមតែស៊ីប្រហុកក្នុងពាងដូចគេទាយពីព្រឹកហ្នឹងឯង តាឮយាយថាដូច្នោះក៏គិតឃើញថាគ្រូនេះទាយជុតមែន ដល់ពេលបាយព្រឹកតាចាស់ជូនចាស់ក៏នាំគ្នាស៊ីប្រហុកដូចហោរទាយឲ្យពិតមែន ទើបតាចាស់ជូនចាស់នោះជឿថា គ្រូហោរចេះដឹងត្រឹមត្រូវតាមក្បួនដំរាប្រាកដ ៗ

ចប់រឿងគ្រូហោរម្នាក់នឹងតាចាស់ជូនចាស់តែប៉ុណ្ណោះ ។

ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

សៀវភៅទស្សនាវដ្ដីចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

ឆ្នាំគំរប់ ១១

ខ្សែ ៤, ៥, ៦, រួមគ្នា

កុង្សីយសេនាបតីបានអនុញ្ញាតហើយ
សម្ដេចសង្ឃនាយកទាំងពីរគណៈយល់ព្រម

ភ្នំពេញ
ការផ្សាយរបស់ព្រះរាជបណ្ណាល័យ
ព.ស. ២៤៨២
គ.ស. ១៩៣៩

# បញ្ជីរឿង

ទំព័រ

១ — ដំណឹងផ្សេងៗ . . . . . . . . . . . . . . . . . . . . . ៣

២ — សិលាចារឹកនគរវត្ត និងបទានុក្រម . . . . . . . . . . . . . ១១

៣ — ប្រជុំពាក្យពាក្យភាគទី ២ (តទី ៤) . . . . . . . . . . . . . ៤៣

៤ — ព្រហ្មចរិយកថារបស់ព្រះមហាលេស (តនឹងចប់) . . . . . . . . ៥៥

៥ — រឿងព្រេង — គ្រូនិងសិស្ស . . . . . . . . . . . . . . . . ៧១

៦ — លទ្ធិទំនៀមទម្លាប់ខ្មែរ ពិធីលើកកសី . . . . . . . . . . . . ៨៧

## រូបក្រៅរឿង

ប្រទេសលាវវៀងចន្ទន៍ វត្តថាខែក . . . . . . . . . . . . . . . . . ១

# TABLE DES MATIÈRES


| | Pages. |
|---|---|
| 1. Informations diverses | 3 |
| 2. Les inscriptions de Nokor-Vat (suite) | 11 |
| 3. Recueil des Poèmes du roi Préas Bat Samdach Préas THAMMARÉACHÊA, 2e partie. (suite) | 43 |
| 4. Brahmacariyakathâ par Vénérable Préas Maha SÈS (suite). | 55 |
| 5. Contes populaires cambodgiens inédits: Conte du Kroû et de son Sœus (le maître et son élève) | 71 |
| 6. Mœurs et coutumes cambodgiennes: Cérémonie pour rehausser sa gloire | 77 |

HORS TEXTE:

| | |
|---|---|
| Vientiane: Pagode de Thakhek | 1 |



ប្រទេសលាវវៀងចន្ទន៍ វត្តបាខែក

ដំណឹងផ្សេងៗ

# អំពីសៀវភៅពុទ្ធសាសនា

# ជាភាសាអង់គ្លេស

មានអ្នកប្រាជ្ញធំជាតិអង់គ្លេសម្នាក់ឈ្មោះលោក ឯ. ជ. ថូម៉ាស បានបោះពុម្ពសៀវភៅពុទ្ធសាសនាមួយផ្សាយឲ្យឈ្មោះថា «ពុទ្ធវចនៈនៃពុទ្ធសាសនា ក្នុងបឋមពោធិកាល ( *Saintes écritures du Bouddhisme de la première période* ) ។ លោកបានប្រមូលគម្ពីរភាសាបាលី ហើយប្រែចេញជាភាសាអង់គ្លេស មានរឿងពុទ្ធប្រវត្តិ; ការប្រតិបត្តិតាមលទ្ធិបព្វជិត នឹងលទ្ធិគ្រហស្ថ, ឧបាយស្វែងរកមោក្ខធម៌, អំពីវិន័យ, អំពីកម្ម, អំពីហេតុផលនៃសំសារវដ្ត (បច្ចយាការ?) នឹងការចាត់របៀបកសាងអាវាសសម្រាប់សង្ឃ ។

ដោយការសិក្សាគម្ពីរពុទ្ធវចនៈជាភាសាសំស្ក្រឹត នឹងសេចក្តីប្រែក្នុងគម្ពីរនោះ លោក ឯ. ជ. ថូម៉ាស អាចយល់ដំណើរសេចក្តីក្នុងគម្ពីរបាលីខ្លះ ដែលគេយល់ឃើញលទ្ធិផ្សេងៗគ្នា ដោយផ្លូវគំនិត ក្នុងផែនដីឥណ្ឌា សម័យនោះ ។

*

* *

LE FRANÇ

# អំពីការសិក្សាសម្រាប់បណ្ដាជន
# នៅប្រទេសឥណ្ឌៀ

យើងបានដំណឹងថា នៅប្រទេសឥណ្ឌៀទើបបង្កើតសមាគមមួយហៅថា « សមាគមឥណ្ឌៀ ដើម្បីជួយជ្រោមជ្រែងការសិក្សារបស់បណ្ដាជន » មានគោលសំខាន់ៗ ដូច្នេះ គឺ:

១) ដើម្បីកំចាត់បណ្ដាក្រស្ដៃដែលល្ងង់ខ្លៅឲ្យអស់ពីអំពីប្រទេសឥណ្ឌៀ ។

២) ដើម្បីជួយជ្រោមជ្រែងប្រជាជនជាតិឥណ្ឌៀឲ្យទៅជាប្រជាជនល្អឡើង ។

៣) ដើម្បីនាំគ្នាប្រឹងប្រែងស្វែងរកឧបាយ វិធីធ្វើឲ្យចំរើនចរិយាទឹងចំណេះវិជ្ជារបស់បណ្ដាជនប្រុសស្រី ដែលនៅក្នុងវ័យក្មេងកុមារ តែរកកន្លែងរៀនសូត្រពុំបាន ។

អ្នកមុខអ្នកការធំៗ ជាតិឥណ្ឌៀទឹងជាតិអង់គ្លេស រួមរួមគ្នាធ្វើការដ៏ប្រសើរនេះ ។

*

*  *

# អំពីពុទ្ធសាសនានៅស្រុកទីបេត៍

ព្រះរាជបណ្ណាល័យ បានទទួលកាសែតរាយការរបស់ក្រុមសមាគមភូមិសាស្ត្រ នៅប្រទេសអង់គ្លេស កាលពីខែដេសម្ប៊ឆ្នាំ ១៩៣៧ នោះ មានរូបថតពណ៌ផ្សេង ៗ អំពីប្រទេសទីបេត៍ ៗ នេះជាប្រទេសកាន់ពុទ្ធសាសនាប៉ែកខាងមហាយាន តាំងនៅទិសខាងជើង ធៀងខាងកើតនៃស្រុកឥណ្ឌា ក្នុងកាសែតនោះនិយាយថា មានវត្តមួយមានចំនួនលោកសង្ឃដល់ទៅ ៥.៥០០ រូប វិហារនោះមានកំពូលជាមាស (?) ឯក្បាច់របនាវត្តនោះសំដែងឲ្យឃើញសេចក្ដីអស្ចារ្យគួរស្ញប់ដែលគេកសាងឡើងនៅលើកំពូលភ្នំខ្ពស់ដាច់ស្រយាល ដែលមាននៅក្នុងលោកនេះ ។ ឃើញមានកុដិមួយដំកល់ព្រះពុទ្ធទ្រង់ធ្វើសមាធិនៅត្រង់កណ្ដាលបឹងមួយ ។

ក្នុងក្រុងឡាស្សា (នៃប្រទេស) នោះមានទីសំរាប់ដើរកំសាលមួយ ដែលពុទ្ធសាសនិកតែងដើរទៅមកជាច្រើនក្នុង ១ ថ្ងៃ ៗ មានដុំថ្មជាច្រើនដែលនៅក្បែរថ្នល់នោះ គេឆ្លាក់ជាដំណាងព្រះពុទ្ធធ្វើអាការផ្សេង ៗ ពីគ្នា (ព្រះពុទ្ធធ្វើមុទ្រាច្រើនអង្គផ្សេង ៗ គ្នា) ហើយមានពួកឧបាសកក្រាបថ្វាយបង្គំសុំពរជ័យមង្គល ។

ក្នុងពពួករូបមានពណ៌ផ្សេង ៗ នោះ ឃើញមានរូបលោកចៅអធិការវត្តពាក់ស្បង់ចីវរ (ពាក់អាវកាសាវ៍?) ក្រាស់មានពណ៌លឿង ហើយ

នៅខាងក្រោយវិហារនោះ មានកំណាត់ថ្មមួយដ៏ក្រាស់ពណ៌ក្រហមដណ្ដាប់គ្របមួយជាន់ទៀត ដ្បិតនៅស្រុកទីបេតនោះរងាណាស់ ៗ នៅឱកាសបុណ្យឆ្នាំថ្មីពួកលោកសង្ឃតែងប្រើងកំនៅក្នុងវត្ត មានរូប ១ ទៀត ឃើញមានលោកសង្ឃឈរជម្រៀបគ្នាជុំក្រយ៉ែងធំសម្បើម នៅខាងមុខមណ្ឌបមាសមានក្បាច់ចម្លាក់ ៗ តាមដោយពិត ទីអស់នោះសុទ្ធតែជាភ្នំខ្ពស់ ៗ មានតែទឹកសន្សើមសក្បុះ ៗ

*

* *

## អំពីសសរថ្មបុរាណ

តាមកាសែតទេះភ្លើងស្រុកឥណ្ឌា ចុះខែសូយេតឆ្នាំ ១៩៣៨ ដែលព្រះរាជបណ្ណាល័យបានទទួលនោះ ឃើញមានរូបថតជាច្រើនដែលមានប្រយោជន៍ដល់អ្នកកាន់ពុទ្ធសាសនា ៗ

ក្នុងចំណោមរូបនោះ ឃើញមានរូបសសររបស់ព្រះបាទធម្មាសោកមួយ កំពស់ ៣៦ ជើង (១ជើង ៣០ សង់ទីម៉ែត្រ) ធ្វើដោយថ្មដា មានចារឹកពាក្យប្រកាសផង ៗ ពីដើមមកមានរូបគោមួយទំនៅខាងលើ ប៉ុន្តែឥឡូវបាក់បង់ទៅហើយ សសរនេះនៅក្នុងស្រុក "អាឡាហាប័ត" ស្រុកឥណ្ឌា ៗ

* 

* *

# អំពីមហាវិទ្យាល័យបុរាណ

ក្នុងកាសែតដដែលនោះ មានសេចក្ដីដំណាលអំពីសាលាមហាវិទ្យាល័យជាន់ចាស់នៅស្រុកឥណ្ឌា ហើយមានរូបចេតិយយ៉ាងល្អមួយនៅវត្តនាឡន្ទមហាវិហារ កន្លែងនេះជាទីតាំងមហាវិទ្យាល័យ ពុទ្ធសាសនាប៉ែកខាងមហាយានជាយូរអង្វែងណាស់មកហើយ ជាទីមួយយ៉ាងសំខាន់សម្រាប់ជាទីប្រជុំរៀនសូត្រ មិនមែនត្រឹមតែរៀនសូត្រចំណេះ ពុទ្ធ-សាសនាប៉ែកខាងមហាយានប៉ុណ្ណោះទេ គឺជាទីសម្រាប់សិក្សាគម្ពីរវេទរបស់ពួកឥណ្ឌូ ( ព្រាហ្មណ៍ ) ទៀតផង ។

លុះកាលតមកមានពួកខ្មាំងសត្រូវ ចូលទៅកាយបំផ្លាញកន្លែងអស់នោះឲ្យខូចទៅ ។ តមកក្រោយទៀត ត្រឡប់តាំងឡើងជាមហាវិទ្យាល័យពុទ្ធសាសនាប៉ែកខាងមហាយាន មានសេចក្ដីរុងរឿងឡើងវិញម្ដងទៀត ។ តមកប្រមាណ ១.០០០ ឆ្នាំទីនោះ នៅជាទីរៀនសូត្រពុទ្ធសាសនាដដែល ប៉ុន្តែគ្រាក្រោយមកទៀត មានគ្រោះថ្នាក់ដោយស្នាដៃពួកមហា-ហ្ម័តធ្វើបំផ្លាញឲ្យបាក់បែកខូចខាតទៅអស់ ។ ដល់មកឥឡូវនេះដែលគេបានដឹងថា ទីនោះជាទីប្រជុំសិក្សាចំណេះពុទ្ធសាសនាមួយយ៉ាងធំដោយសារពួកពុទ្ធសាសនិកជនជាតិចិន ធ្វើដំណើរទៅនមស្ការនឹងពួកទីបេត៍ដែលបានកត់ត្រាទុកមកថា ទីនុ៎ះជាទីប្រជុំរួមចំណេះវិជ្ជាខាងព្រះពុទ្ធ-សាសនា ហើយច្រើនស្តុកទៅដោយអនុស្សាវរីយ៍ (ចេតិយ) ។ ចំ-

ណែកឯពួកអ្នកធ្វើការខាងបុរាណវត្ថុក៏បានប្រទះឃើញមានព្រះពុទ្ធរូបនិងរូបព្រះពោធិសត្វជាចំនួនច្រើន ។ មួយវិញទៀត នៅមហាវិទ្យាល័យសាសនានោះ ពួកសិស្សត្រូវសិក្សាជាវេលា ១២ ឆ្នាំហើយត្រូវចេះភាសាសំស្ក្រឹតផង ។ សិស្សដែលមានទោសធ្ងន់ជាបំផុត ត្រូវបណ្ដេញចេញពីសាលាមហាវិទ្យាល័យ ។

មហាវិទ្យាល័យមួយនេះហើយ ដែលជាទីសិក្សារបស់នានាជាតិ បណ្ដាពួកសិស្សនិងគ្រូ ដែលសំណាក់នៅក្នុងសាលានោះសឹងមានសេចក្ដីសុខក្សេមក្សាន្ត ហើយខំប្រឹងប្រែងរៀនសូត្រចំណេះវិជ្ជាខាងព្រះពុទ្ធដីកាឲ្យចេះដឹងកាន់តែជ្រាលជ្រៅឡើងទៅប៉ុណ្ណោះ ។

## អំពីឧមង្គ (ផ្នូរ) របស់ខុងជឺ

កាលនៅថ្ងៃ ៤ ខែយ៉ាំងវីយេរ ឆ្នាំនេះ កងទ័ពយីពុនបានវាយយកបានក្រុងគួហ្វូ ខែត្រសានទុង (ស្រុកចិន) ។

ក្រុងគួហ្វូនេះជាទីគោរពសក្ការបូជារបស់បណ្ដារាស្ត្រចិនទាំងមូល ពីព្រោះខុងជឺដែលជាអ្នកប្រាជ្ញចិនបានមកចាប់កំណើត ហើយធ្វើដំណើរចាកលោកនេះទៅវិញនៅក្នុងទីនោះដែរ ។

មួយវិញទៀត ពិតមែនតែស្រុកចិនមានចម្បាំងនិងបះបោរច្រើនលើកច្រើនគ្រា តែត្រង់ឧមង្គដែលបញ្ចុះសពខុងជឺនិងវិហារមួយដែលគេ

សាងឧទ្ទិសចំពោះមហាអ្នកប្រាជ្ញនេះ (ជិត) ចំនួន ២៥០០ ឆ្នាំមកហើយ នៅក្នុងក្រុងគូហ្វូ គេប្រឹងថែទាំមិនឲ្យខូចខាតបន្តិចសោះ ។

ពួកញាតិរបស់ខុងជឺមាននៅក្នុងក្រុងនេះជាប់រហូតមកដល់សព្វថ្ងៃនេះ ព្រះចៅយើពុនបានតាក់ព្រះរាជបំរើមួយក្រុម ឲ្យទៅទូលសួរក្សត្រាចិនមួយអង្គព្រះនាម "គង់តេចែង" ដែលជាប់ជាញាតិសាលោហិតនឹងខុងជឺ ៧៥ ដំណមកហើយ តើព្រមទទួលសិរីរាជសម្បត្តិជាមហាក្សត្រាផែនដីចិនឬទេ ក្សត្រានោះទ្រង់ប្រកែកពុំព្រមទទួលហើយមានបន្ទូលថា តាំងពីខុងជឺអនិច្ចកម្មទៅ វង្សានុវង្សនេះមិនដែលស្វែងរករាជអំណាចឡើយ ។

ព្រះរាជបណ្ណាល័យ មានអំណរសូមជំរាបជូនដំណឹងដល់មិត្តានុមិត្ត ដ្បិតទើបនឹងបានទទួលរូបថតយ៉ាងល្អ ៗ សំរាប់ចុះធ្វើជាកុន រូបថតទាំងឡាយនេះ នឹងប្រគល់ឲ្យរថយន្ត ដែលដឹកសៀវភៅព្រះរាជបណ្ណាល័យ មួយវិញទៀត ក្នុងពួករឿងរូបថតកុនទាំងឡាយនេះមានមួយរឿងចុះអំពីរឿងអ្នកប្រាជ្ញ ខុងជឺកាលរស់នៅឡើយ ហេតុនេះមិនត្រឹមតែបណ្តាជនជាតិខ្មែរយើងដែលនៅក្នុងក្រុងភ្នំពេញនេះទេ ទាំងអ្នកដែលនៅខេត្តក្រៅក៏នឹងបានមើលហើយនឹងដឹងរឿងរ៉ាវដ៏មានប្រយោជន៍អំពីប្រវត្តិខុងជឺដែលជាអ្នកប្រាជ្ញធំមួយនៅក្នុងអាស៊ីយ៉ាទិកយើងនេះ អ្នកប្រាជ្ញនេះកើតក្រោយព្រះពុទ្ធជាម្ចាស់និព្វានទៅចំនួន ៦៤ ឆ្នាំ ។

# សិលាចារិកនគរវត្ត

និង

# បទានុក្រម

លេខ ៣១

№ 34 (A)

№ 34

(១) បុពិត្រ [នេះគឺ] ពោះត្រីពិត្រសុប្ឫរិត្តសារទ្វាមហារិ បុលអតុ (២) ល្បអត្តិរេកឯតរកតាប្រាមោជោតិបង្កុបរត្នរិនពិន្ធ (៣) អាបិន្តនិត្រយ្យបិត្តិមាតោជព្យៃពោជសុគណ្ឋរបរិរ (៤) សរសោមន៍ស្បាភិលង្កិតរិកសិសោតរបរបទុំមាភា (៥) មបោអត្តិ សៃក្រៃសមៃសុមហុត្តិមហោតំមសមន្ធអា (៦) សទាំរិកបិត្ររិធ សុប្ឫរិត្តវាប្លា សត្យអាទិស្ថាណប្រែ (៧) និជាននៃសំតែបព្រះបរិ ទូបុពិត្រក្រាបឋ្វាយបង្គម (៨) ប្រនំទូលល្អងធូលិព្រះគ្រីរបាទ យុគ្គលវិមលត្រៃនែសំ (៩) តែបព្រះសិសាក្យាមុណិត្រៃគោតំមប វម្មបុពិត្រក៍ម្រតៃ (១០) ឯយើង ស្តែបប្តើងនូអជ្ញតូរិរសតមុគ្គល អំពលនូលា (១១) យលក្ខក្កុងបក្ក អនគ្ឃអនាបំពិពាំរសបារ ព្រះអង្គ (១២) ជាពុំនាក់ត្រៃយត្រានពោហានសំពោរត្នរង ឪតុងស (១៣) ម៉ារនាំ នូអាបនាំមសត្វផោងឆ្លោងលែងរិត្ត សង្ឫារស្មៃ (១៤) ប្រភាលមហានុព្វស្រែមុទពោលមុនអ៉ក៍លេស្ស សួង (១៥) ព៌ន្ធហោរយភព្វជាតិកន្តាលសាណ្ហានៃសំតែបព្រះបរ

(១៦) វិទ្ធខំមអំប៉សក្រែងបាទធ្វើនូវអំពើហអកុសលអំពល (១៧) នូប៉តុតិស័យ្យោជាទ្វារទិដ្ឋិទ្រិសតមសន្លូបតុទសបេត្ត (១៨) សេិកិ វញ្ញកន្លូប្របកាយស្មេិតព្ទតសង្ហារបីអ្យិតខ្លិមអា (១៩) សារ ជារាព្យាធឆោងសិងតប្បេិតប្បេណ តែទេីបសំ (២០) តបព្រះបរទ្ធិមោគគិតជញ្ចិងរម្មិងអាតិត្តអនិ (២១) បាអាយុខៃយ្យាកាំម្មខៃគាតិតសជន្មាពិត្តិទោបរ (២២) លាកគាប្រិទ្ធបញ្ចញបា្លយសំពោអ្យតងពុំទាក ក្រៃលែង (២៣) តែសំតែបព្រះត្រិរត្នតត្រៃបរំមបុពិត្រ ។ លុតលសព្ទាមស្តុ (២៤) មុង្គលជ្យោតិ៍រេក ១៦០៦ សក្កជូតនក្សត្រ ៩ រោជ (២៥) កាត្តេិកពុទ្ធពារសាណ្នាក្យិជាស្រែតែសំតែបព្រះបរវី (២៦) ទ្ធមាតបិតតំម្លាសាទ្វាបាបតេិមអំមក្យិ ១៦ ឆ្នាំមលុ្ងប (២៧) រិល័រ៉ុយលតលតលូតែះព្រះជនបាន ៥៧ ហេ្យ ព្រះ (២៨) អង្គវែងកាតស្រលៃញសាទ្ធាំអោកគន្លត្រាតសសំអ្ពាងសា (២៩) ពរ៉ាអំម្តេកុសលផលបុតអំមព្យិមុតមោកលុ្ងបតល (៣០) តលូតែះព្រះអង្គសាង់ព្រះមាសព្រះប្រាកអង្គ ១០០ នូ (៣១) ព្រះឆ្លាកប្អិយ ៣៥ អង្គ

នុព្រះអន្តរជាប្លង់អំមព្យ (៣២) មុនមោកអង្គ ១០០ នូព្រះ
សីហឿងអង្គ ១ ឥសសំ

No. 34 (2)

(១) នាងព្រះអង្គទុំអម្បាលនោះបានជា ២៣៥ ហើយមោក
ទ្រង់សា (២) ទ្វាតាម្មនូព្រះត្រៃរត្នមហាពោធី ៣០ តេម្ន ហើយ
ព្រះអង្គសាងព្រះ (៣) ចេតិយ៍ខ្សែបសំរែបសាងព្រះពុទ្ធព្រះធម្ម
ព្រះសឃ័ផ្លូងនូកបើ (៤) ណាឲយជាទាន ៥ តោង ជិកអន្លង់ជីក
ស្រោះជុំរះផ្លូវសង្ឃស្តា (៥) នឱយទាន ៥ តោង ព្រះអង្គឲ្យទាន
ភ្លើងឱយទានទឹកឱយទា ៦) នសំពត្តឱយភោជនាហារត្រៃកាល
ពីសា ឱយទានកន្ទេលអាស (៧) នា ឱយទានគ្រឿងបាយគ្រឿង
ទឹកគ្រឿងស្លាម្ល កាត់ត្រៃចីវរ (៨) ឱយទានកាត់ទងកាតពិតាន
សាងកំពីព្យហ្វាយព្រះមហាស្រែរ (៩) ត្នត្រៃបរំម្មបុពិត្រទុំបីខ្ញុំ សង្ឃ
សាលា ៥ បញ្ចាំមឱយជាទាន (១០) ហើយព្រះអង្គមានមេត្រី
កុណ្ណាអាស្សូរឥសមេបាបោងផ្ទណក្ខ (១១) ណាហើ តៅញាតអំ
ម្បាលសង្ខាតមោកខ្ញីប្របែរត្តព្រះអង្គ (១២) ឥសទុំហ្វាយជា

ជញ្ជាំង ៧ ហើយព្រះអង្គមិលមើលយលជាទំម (១៣) ងុនពនប្រ
ហ្មានតសញ្ញាតសន្តានទុំអំម្បាលនោះព្រះអង្គ (១៤) ស្មោះត្រោះ
ទ្រុងសាទ្ទាលើកឪយជាទានតសញ្ញាតសន្តានទុំជញ្ជាំ (១៥) ង
៧ នោះស្រែបហោង បុពិត្រនែះគឺសំហ្មាងសំតែបព្រះបរវី (១៦)
ទុ្យ តល្បូវព្រះអង្គសូមកើតសព្វ ៗ ជាតសូមទ័ន្ធពុទ្ធបាទបាំបំម្រើ
(១៧ ហាឪយតសសែប្តក្តិ ខ្ញុំមសូមមានទ្រាំព្វធនកែរវត្ថុគុណ
មាស (១៨) មុណីត្វបជោតិកសេស្ថិមុះហីមាអ្បិតថ្មីមបាន ខ្ញុំម
សូមកុណ្ហា (១៩) សត្វសូមបិត្រកាំតអំពោយទានស្មោះសាពន
ប្រមានត្វបព្រះរេ (២០) សន្តរហោង ខ្ញុំមសូមត្វបគេមេបិត្រអតគេ
ហអ៊្សិតំងហ្មោំង សូ (២១) មបីត្រខ្ញុំមល្អហាកគ្លោំងជាសំលែញ
ទុំប្រុសទុំគ្រីយ ទោះទោស (២២) អ្នកទិងស្លាបទុលទុក្ខខ្លាប
អ្សិតប្រាទិសូមតោះរំដោះក្តីជីវីតបា (២៣) ឥរស្សរប្បាជិវិត ខ្ញុំម
សូមផ្ទិរត្វបអំម្បរព្រះប្រាជ្ញា ខ្ញុំមសូមរោង (២៤) ជារណាជិវិត
ឈត្វព្នំាកគ្រុះ បុពិត្រព្រះមហាស្រិរត្នត្រៃបរម្មបុ (២៥) ពិត្រ
ខ្ញុំមសូ្បបំពេញពោធិសំភ្ភារបារម្មីអំពីនែះទៅវ៉ិបរ៉ាលទ៌ា (២៦)
លអនាគតកាល លុះតលពោធិសត្វ ១០ ព្រះអង្គបំពេញពោធិ

សំ (២៧) ម្ការបាម្មី បានត្រាសប្រជ្ញាសាព្វេជ្ញតាញាណជា ព្រះពុទ្ធបរប្ឫរប្ឫល (២៨) និញានជាសុរ្យេបហ្យើ ឯក្រោយនោះ ឯងអញ្ញខ្ញុំមសូមឱ្យបាន (២៩) ត្រាស់ប្រជ្ញាសាព្វេជ្ញតាញាណ ជាព្រះពុទ្ធបំបាត់ទាំមសត្វផោង (៣០) ត្វបកន្លោងព្រះពុទ្ធអំព្យ បុរានរឿងមោកនោះឯងហោង (៣១) បុពិត្រព្រះមហាស្រីរត្ន ត្រៃយបរម្មបុពិត្រ អញ្ញខ្ញុំមឈ្មោះសំ (៣២) តែបព្រះបរិទ្ធបុ ពិត្រប្រាប្នាត្វប្វេះ សូមឱ្យបរប្ឫរប្រាកដ្ឋកំនត្រ (៣៣) កុំម្បីមាន ឃ្លាតឃ្លាល្បេ បុពិត្រសូមធុត ៗ ត្វបសប្តាអាទិស្ថានផែះហោង

លេខ ៣៤

Nº 35 (A)

(១) សព្ទមស្តុស្វស្តិស្រីយសព្ទមង្គលពហុលបេស្តាជ្យោតិរេ (២) ក ១៦០៩ នក្សត្រឆ្នាម្មហោះខែមាគ្គ ៧ រោជថ្ងៃយ (៣) ២ ពារសារណា មគ្គិតិសជំនុម្មអ្នកសំម្ដេចមហាសយ៉កាម្ម បុ (៤) ពិត្រទូអ្នកសំតែបព្រះបរិបញ្ញាបុពិត្រនុអ្នកទារបុពិត្រ ទូ (៥) អ្នកត្រៃយ ឯគ្រីហាសសោតមានបោបាងនុព្រះស្បៃ គាង (៦) វត្ន នុះបោបនទ៉ាអោរ ទូនាងតានគាងនៃរជ្យិតុជ្យមិម្ម តិស

អ្ន (៧) កទុំអំម្បលនែះស្យិងតជាសាក្យុយសុក្ខិវិញ្ញាណនៃនាង
បែន (៨) មានបិត្រកាត្តិម្លាសាទ្ធាំមោកលែង (ខ្ញុំ) ១ឱ្យរ័បជា
ព្រៃប្រាម្បិ (៩) ទិសតតប្បិបីរពោលល្បៀ នែះគីរោះត្រិពិត្រ
សុប្ចរិត្តសាទ្ធាម (១០) ហោរិបុលអតុលអត្ថរេកឯក្កាភត្តាប្រមេ
ជោតិបង្កុជ្ឈសុប្ចរិ (១១) តវិគពិន្ទអាជិនត្រិណិបិតិមានោជបភិ
ពោបសុគណ្ឋបរិរ ស (១២) រម្ភស្សាភិលុក្ខិតវិក្សិសោន្តរ បវិរប
ទំមាភា មហោអត្តិសែត្រៃសុមៃសុមហុ (១៣) ត្តិមហោតម្ម សម
អសយាំរិក វាចាសិត្យាអទ្ធិស្នាណរាប្រណិធាណនៃ (១៤) ឆាង
បែនក្រាប្បប្ញ្យបង្គមប្រែនមទូលល្អងធូលីព្រះស្រិយវិបា (១៥)
ទយុគ្គុលវិមុលភិបិនត្រៃយ នៃសំតៃបព្រះសិសាក្យាមណិព្រះ
(១៦) ស្រិយគោតំមព្រះកំម្រតែងយេង ស្តេចប្តិងនូអដ្ឋតរវិរសិទ្ធ
មុង្គលអម្ត (១៧) លនោលាយលាក្ខុកូងបកអក៍កអនារពិពារ
សហារអ៍បនាម្មសត្វ (១៨) ដោងឆ្លោងលែងវិពរសង្សារស្មើ
ហប្រវាលមហោនុព្វស្រមុទ្ធ ពោល (១៩) មុនគិកិលេសទំពាន្ត
ហារយភុព្វជាតិកន្តាលសាណ្ឋាន្សៃវា (២០) ឯបែនមាន
បិត្រកាតតំម្លាសាទ្ធាំបាបតើមអំពិប្រាម្បូទ (២១) ត្តុបឆ្នាំមបាម

តោយនូសម្មាងអំពើកុសលផលប្បុន្យអំពិមុនគោ (២២) លុះតល
ឆ្នាំជាសេសើប្ប សេ ហ្បេ មោកគន្ធាត្រាសំម្មាងសាង (២៣)
ព្រះពុទ្ធរូបមាសអង្គ ២ ព្រះប្រាក ១២ ព្រះអង្គព្រះសំរឹទ្ធអង្គ១
ព្រះ (២៤) សិលាអង្គ ១ ព្រះទេព្វចាររូអង្គ ១ ព្រះបទ្មអង្គ ១
កាតទុង ៩ (២៥) ផ្កាន ៣ ក្លស ១ សាងភ្នំពានូ
ព្យរតោង ភ្នំ ៥ ព្យរតោង បំបូសក្ក (២៦) ន ៩ តោង
សាងកាម្ពុ ៥ ផ្លុងត្រៃបិរ ៥ វិពរប្តូន ៤០ សាង (២៧)
ភ្យរគ្នាខ្ញុំប្ញូបុជាសំតែបព្រះស្រីរត្នត្រៃមតោងនែះហោង (២៨)
អម្ពើកុសលផលបុន្យអ្នកនាងបែនទុំអំម្បាលនែះហោង អាហិរ
(២៩) អញខ្ញុំប នមាមិ ស្រែបប្ញូបង្គមប្រនិមសិរសាតាក
លើប្បុង ទិនេ ៗ សព្វ (៣០) ៗ ថ្ងៃយ កាលំ ឰតកាល
ហោង។ ឱកាសូបុពិត្រហ្បេហេតុគេកតេ (៣១) ដះត៍ពោះ
នៃអំម្ពើកុសលផលបុន្យខ្ញុំទុំអម្បាលនែះធិព្វសម្បត្តិ (៣២) ប៉ុរប
គ្នាំ បុពិត្រហ្បេសូមខ្ញុំបានស្មោ្យសំម្បាតទុំបិប្រាកាយនោះ អ្យ
គឺ (៣៣) សំម្បាតមហាចក្កពត្តរាជមានរិទ្ធិអំនាចរាជទ្រុងគ្គ
ទស្សពិត្ត (៣៤) រាជធម្មិទុំ ១០ គោរោព្វ ព្រៃតទានតិងសិល

នោះសព្វ ៗ ជាតកុំម្រិត (៣៥) ហាង ម្យគីសម្បាតទេវតានៅទា ស្វគ៌ាយប្រសេដ្ឋថ្លាថ្លៃក្រៃ (៣៦) យលែងទេវតាអោងទុំប្លាយ ម្យសម្បាតនិញ៉ាណតជាស្ថាណា (៣៧) ប្រិមព្រៃសនិវាស្ស លែងជាតជារាម៉នោះទៀងប្រាកុត (៣៨) ហាង " សង្ក្រារ ត្តោ ទោះយោបិខុំមនិងអត្មោល (៣៩) មាកយោនយោកកំ នេតកេិតព្វតភ្យភុព្វ (៤០) មន្តុលអំម្ពុលគូវិត្តសង្ក្រារនា ៗ ក្តិ ម (៤១) ពោបញាំ ស្វមខ្ញុំមមានប្រាជ្ញាថ្លាថ្លៃ (៤២) វៃយមោះ ហិមាដ្លបព្រះមហានា (៤៣) គ្គសេនហោង បុរបន្លាំ បុពិត្រ (៤៤) ហ្សេស្វមយេងខ្ញុំបានលុះសំ (៤៥( រិទ្ធិត្លូបក្តិប្រាជ្ញាបិត (៤៦) បិត្តាស្សេខ្ញុំហោង

លេខ ៣៣

No 36 (B)

(១) សត្តមស្តុស្វស្តិគ្រៀសត្តមុង្គលពហុលបេស្តាជ្យោតិអេក (២) ១៦ ១២ ស៊ួកមមីន្តក្សត្រ ១៤ កើតខែហាបែត ( ៣ ) ថ្ងៃយសៅ ពារសាណ្ហិ មន្តិឥសជុំនម្មសម្ដេចព្រះ (៤) សុមុង្គលមហាសយំ រាជបុពិត្រ នុសម្ដេចព្រះអរជេ (៥) ដ្ឋសិត្តាមពោសយ៉ាវាជបុពិត្រ

នុសម្តេចអរិយប្រិញា (៦) នុព្រះមហាថេរម្ចីសុធម្ម នុព្រះមហាថេរ បរខាន្តិ (៧) ព្រះអរិយបទុម ព្រះបញ្ញាពិទូរ នុព្រះបរបាឡ នុអ្នក (៨) ផ្ទរនុអ្នកទ្រូងនុអ្នកល្បិ ឯគ្រសោតមានព្រះសុភាធិ (៩) ព្ទ តាសួសនុអ្នកព្រះស្ទាសម្បាតនុជ្យតើកនុអ្នកជ្យនុ (១០) អ្នក អគ្គហ្នឹនត្យ ឯគ៏សោតមានតូនតានតុតាកោរិតា (១១) បុកតា គាំតាបែនតាក្រៀតាបែនតាផាត ឥលអ្នកទុំអំម្បា (១២) ល នោះមោកជាសាក្ខស្បពេជញ្ញាណនៀអ្នកអ្នតនុអក (១៣) ហ្មេនជ្យមតាតាន្ទូមានបិត្រថ្លាសាទ្ចាមោកសាងព្រះ (១៤) មាសអង្គ ១ ទងហ៊ូអង្គ ១ ប្រាកអង្គ ២ ឯស្នាខានសោត (១៥) តំលិង ១០ ហើយលែងមេបុសនែះឡូវបជាស្រែបុឡប្រិ (១៦) ម្បិទិសឥតបិបិរពោលល្បេ ហាបេហាបោងដ្ណាកូន (១៧) កួយ ឯនាម្បមោកវិាតមាត្រាមេបុសនែះហ្សើព្រះត្រា (១៨) សអំ ម្បាលខ្សាបកុំបីប្រោសអ្នកនោះល្បេហ្សើឡវា (១៩) ឆ្ទះទូអាន ឥបកក្រពាលបែញក្បាលអ្នកនោះសព្វ (២០) ។ ជាតកំ ណេតហោង ។

លេខ ៣៧

nº 37 (A)

(១) នេះគឺពោះសុបូរិតវិត្តដំរិតជាន្នាធ្យាស្រែនៃឧកញ៉ា (២) ឃ្មុំរាជ្ជនរិទ្ធជាតិរីរងអងអគ្គមហាសេនាធិប្បី (៣) តិយេន្ត្រ វន្ទាភិរក្ខបក្ខសិទ្ធិធរាធរ ព្រះមហានគរបាលិអភៃគី (៤) រីបារា ក្រិពហុឯកមុន្ត្រីយ៍ តជាង្គិបំទារទេិព្វសុពារមានបិត្រ (៥) ទ្វាំព្យរ នោះគឺត្រអន្ទិបាក្រាបលាព្រះបាទ្ទអ្នកជាអំបស្បរ (៦) ហ្សត្រាស្ស ប្រែហមោកដោងឲ្យសាងត្រីស្សរគាងឃ្វាយថ្វា (៧) យទៅ ព្រះត្រៃរត្នតត្រៃទ្វំបី មានបិត្រនោះឱ្ន្សាទ្វារត្តាបឲ្យសង (៨) ឃាយនាសង្ហាលាបំម្រែបរាសស្រែបហ្សៃទេិបស្មាទាន នា កាលស (៩) ង្ឃាយនានោះនិមន្តព្រះសង ១៦ អង្គ គឺមហា សង្ឃរាជទាំ ១៦ អង្គ (១០) ត្តសំតែបភិកបេរសិនេរដោង ប្រេន ឯប្រិតាបសំនាងសាងព្រះ (១១) មាស្សទំមួនត់លិង ៤ នោះអង ១ ព្រះសិហិងអង ១ សាងតសសុត្រាទសជាត្រ (១២) ព្រះអភិធម្ម ប្របិម្មព្រះធម្មបក្ខដោង តសព្រះពន្ធន្ធបោង ផ្ទុណកូនកូយ៍ (១៣) ដោរិញ្ញាត្តសោតបុះព្រះតំបារ ១១ អង្គ

ហៅសិង្ហរន្ទាប្បត្រៀងថ្លឹងឲយ (១៤) ទាន ឯព្រគេទស្មាទាន សង្ឃាយតាសោតត្រៃបិរប្រិខាគសំរាបម្សៀម្យ (១៥) ១៦ បាទន្ទស្លោក ១៦ គ្រែងស្លាភ្លកសំរាប្បមេម្យ ១៦ ប្រត្ត១៦ កុំម្បឹត្ត (១៦) កោរ ១៦ កុំម្បឹត្តវឹវែយ ១៦ តែកភ្លើង ១៦ តៃកបារ ១៦ ជើងអង្ការ (១៧) ១៦ កាំម្ពីយ ១៦ បត្តាត្តុំ ១៦ ឫទ្ធសត្រា ១៦ ខ្សែប្រាស្ស ១៦ ថង់ស្លា ១ (១៨) ៦ ប្ញប្ប ១៦ ត្បៀងទ្ធំ ១៦ ត្បៀងតួប ១៦ អង្សរ្ស ១៦ បន្លាក (១៩) ១៦ អន្លង់ ១៦ គ្រង ១៦ ខ្សែស្ត្លៀង ១៦ គ្រុប្បតិសទ្ធំសយ៉ទ្រែងស (២០) ង្ហាយគាគីត្តតិសទ្ធំទំម្មែប ស្មាទាណដាប្រាកជំញឹង ៤ តាកាល (២១) លើកត្រីស្ទួរគាង ឃ្វាយ ឯសក្រាជ ១៦១៨ សក័ព្ទត្រខែផលគុណ (២២) ស្ងួតព្រះទិព្វមុន្ត្រធម្មបកមហាសុមែយថ្ងៃ ៣ គលថ្ងៃព្រះហស្សត្បៀ (២៣) ៩ កើត្រលើកហ្លើង ទៅគលថ្ងៃសុក្រ ១០ កើត្រតោះ លើកគ្នាំហ្លើង (២៤) ពាំសំរៀប ឯប្រវែងត្រីស្ទួរតោះសោភ ១៥ ហត្ថឯដំរោវទន្ទ្យសោត (២៥) ហត្ថ ៤ ឯស្លាបគាងឃ្វាយ តើមហត្ថ ៦ កន្តាលហត្ថ ៥ ឯចុងតោះហត្ថ (២៦) ៤ តេជះ

ខ្ញុំសាងជូនទៅឱយឥសអ្នកតមានគុណ ខ្ញុំសូមឱ្យបានទាណ (២៧) ព្រះសីអារ្យមៃត្រីបានបួសសំនាកញុំនាកព្រះសាស្នា ឱ្យបានព្រះពុទ្ធទំនាយ (២៨) នាកន្លងព្រះអង្គប្រាជ្ញាម្តេចមីញ ខ្ញុំសូមប្រាជ្ញាឱ្យបានដូចព្រះអង្គហោង នា (២៩) លែងជាត នែះទៀតលខ្ញុំកើតហ្មើងវិញ ខ្ញុំសូមឱ្យបានបេះសើល្បជុំបធុត រោប្ប៉្យ (៣០) ប្រកដ្ឋតូបព្រះឥស្សូរហោង នាជាត្តនែះខ្ញុំប្រាស និងផ្ទិណានិងកូណាខ្ញុំ (៣១) ទ្វិ ២ ហោងសូមសព្វជាតណោង កំម្សិមានឃ្លាតតលតែបហ្សេ ឥសត្រកូល (៣២) វង្សា ផ្សើរនោព្រះ សាស្នាកំម្សិឃ្លាតល្បេហោង "០" ទោះខុស្សលុសអ (៣៣) ក្សរសូមព្រះអង្គជួយបំពេញនោងហោង "០" បុះវ្វិបខែភុទ្រ (៣៤) បុត ៩ រោជប្ញែ ២ ជាសួរេបហោង "០"

លេខ ៣៨

No 38 (A)

(១) សព្វម្មស្តុស្ស្តីគ្រិសព្វមង្គលពហុលបេស្នាជយ្យោតី (២) អ្នក ១៦២០ គ្នក្សត្រិសក្កខាល ១ រោជខែពីសាខ្យប្រែអាទិត្យ ពារសាណា មុ (៣) ទ្គឥសជុំឝុមសំតែបព្រះសុមង្គលម្ចាសយ៉ា

រាជបុត្រ នូវសំតែបព្រះរាជ (៤) លិលាបាយ្យំម្ចាស់យ៉រាជបុត្រ
នូវសំតែបព្រះបញ្ញាពិទូរម្ចាស់បរាជបុត (៥) ត្រ នូវសំតែបព្រះ
ជេដ្ឋសត្តាបុត្រ នូវសំតែបព្រះគាថាបាម្មឹបុត្រ នូ (៦) សំតែប
ព្រះបញ្ញាវីនៃបុត្រ នូវសំតែបព្រះអរិង្សាបុត្រ នូវសំតែប (៧)
ព្រះស្មណការីនៃបុត្រ នូវសំតែបព្រះព្រហ្មរគ្គបុត្រ នូវសំតែបព្រះ
អរឱទៃប្បុ (៨) ពីត្រ នូវសំតែបព្រះឱទៃបញ្ញាបុត្រ នូវសំតែបព្រះ
ត្រៃបាឡី ឯគ្រហ៍សសោ (៩) តមានអ្នកហៅពញាសេនាធិពូ
តី្យ នូវអ្នកហៅពញាជោប្រអង្គ នូវជ្បត្រើកនា (១០) ងនៀវតូជ្យតុក
នាងតត្តជ្បឥន្ទនាងឌ្បនូព្រះធឹកសេនានាងគុងតូតូន (១១) គាំម្ម
នូតូនជ្រាំនូនាងឱង នូនាងអៅវតូជ្យគ្រីហៅតូនបែនឯងនូនាង
ទ្វើន ឥស (១២) អ្នកទាំអម្បាល្មែះស្បងផាសក្តិវិញាណនៃ្យ
នាងប៉ែននូនាងអៅវមាគបីត្រតំ (១៣) លាសាទ្វាំប្រោសខ្ញុំ
គ្រឹម្បូឈ្មោះម្បេឈ្មាងនេះឲ្យរក្សាព្រះគ្រឹវត្តត្រៃជាស្រលាះ (១៤)
ឥត្បូបីរកាលល្បេ ក្រែងខ្លាបមានបោងផ្ទូណាក្លូនក្នុយឯនា ម្ហោក
ស្រ (១៥) តី្យម្បេឈ្មាងនេះបាំផាខ្ញុំល្បេ ព្រះពុទ្ធត្រាស្បូអម្បាល
ខ្សែបកុំត្រាប្រោស្ប (១៦) អ្នកនោះល្បើ ហ្បើឲ្យរត្នះទាំអានន្ទ

បក្ខក្រវាលបាញក្បាលអ្នកនោ (១៧) (១៨) ៖ សព្វ ៗ ជាត
កំណើតហោង ◡, ◦ នេះព្រៃគេនព្រះសុមង្គលហោង

លេខ ៣៦

N° 10 (A)

(១) នែះសំម្តេចជោគ្តិទេវាមហាសយ៉េវាជបុពិត្រមាន (២) បិត្រប្តាសាទ្ធាំនាំអ្នកព្រះពុទ្ធ ២ អង្គអង្គ ១ ស្បូងទុម្ពុន (៣) មហាប្ញទ្ធាំ ២ អង្គស្មើហគ្នាម្មកគំកលព្រះ (៤) មហោនគរទ្វាំរគ្ទាំ ៤ វាយជើតសំមរ (៥) ភ្លងឯគ្គងទ្ធំមមេក្កុនគ្គោងទ្ធុប ៣ ពាត (៦) គ្គោង ១៦ ឆេង ២ សំម្រាប ស្រល្បែ ២ សំពោរ ២ សុត្រាហិប្ប (៧) ១ ពានប្រាកទ៉្មុន ១៤ ពានទ្ធង្ដែង ១ ក្អម សម្រិ (៨ ទ្ធ ១ ប្តិលប្រាក ២ ហ៊ាស ១ ពពឹល ១ តំកលទុក មហោន (៩) គរព្រះអង្គឯនាមានសទ្ធាំរក្សាព្រះពុទ្ធនែះ (១០) គសក្រេងសំម្រាប្បនែះឱ្យរក្សាឱ្យម្ហូលនិងអ្ន (១១) កព្រះពុទ្ធនែះ ឱ្យបំម្រេបាតល់ ៥០០០ បសា ហ៊ាប្បេឺ (១២) អ្នកឯនា ១ មោក ស្រតឹ្យឃ្មុកវិញអំពី្យ (១៣) អ្នកព្រះពុទ្ធទ្ធាំ ២ អង្គនែះបំប្ញែក វិញឱ្យជា (១៤) ស្អាន ២ កន្លោងនិងព្រះពុត្បឹ្យកានែះល្បេ កុំឱ្យ

(១៥) អ្នកព្រះពុទ្ធអំប្បាលត្រាសទៅហេប្យក្តិអ្នកព្រះពុទ្ធ (១៦) និងត្រាសមោកឯភ្នែកនែះក្តី កុំត្រា (ស) ឲ្យបានរ (១៧) ព្រាសអ្នកនោះលេយ ឲ្យរន្ធះទ្វ័មសែនបញ្ញត្រូវអ្ន (១៨) កបម្បែកនោះហោង ឋាបើតសញ្ញាតភោរឯ (១៩) នាជួយអនមោទនាជួយភាក្យានិងប្រាំងដាសង (២០) តំណ្ហាឯក្រៀវទោហោង ឲ្យឥសញ្ញាតនោះបាន (២១) យលនាកាលបានត្រសធម្មទ្វំប្រាំប្យហ្មើនបួនពាន្ន (២២) ឲ្យប្រកោប្បត្តបអំប្បូរអ្នកព្រះពុទ្ធអំព្វិយមួនទោះ (២៣) បោង ឯកូនបោនែះសិងអាទ្ធិស្នានទុកស្មើហកូនបរ (២៤) ង្កឹតបោបង្កើត បើញាតឯនាបំម្បែកឋាជាខ្ញុំមផ្ញើឲ្យមា (២៥) នទុកឯក្រៀវ ឲ្យញាត្តនោះត្រូវបុត្តាសាព្រះពុទ្ធតីកា(២៦) ទុកឯក្រៀវនែះឯងបោង ឋាបើញាតឯនា(២៧) ជួយអាស្វរតុំរហោតុំរ្វងជួយរាក្យាព្រះសស្នាអ្នកព្រះ (២៨) ពុទ្ធឲ្យអ្នកនោះបានទ័ននាកាលត្រសធម្មប្រប្យហ្មើនបួ (២៩) នពាននោះកុំឲ្យញាតនោះខ្វាតខ្វាហលេយះហោង

លេខ ៤៧

№ 2 (B)

(១) សព្ទមស្បុតមុង្គលាជ្យែាតិរេក ១៥៩៣ ឥក្សត្រ (២) ឆ្នាំមក្សរខែបហអាសាធថ្ងៃយសោរប្រាំបីយកើត (៣) ពារ សព្វសព្វមហោរត្តឹងមហោឡ្ឋពេបូភ្ជុលអំពីព្រះ (៤) ព្រះពុទ្ធ ហ្សទៃថ្លាំថ្លៃយ នែយអ្នកសំតែបព្រះមុនីយកុ (៥) សលបុពីត្រ ព្រះអង្គមោកសំពះព្រះអង្គរត្រ (៦) ទេះព្រះឥន្ទ្រាធិរាជ្ជលោកឲ្យ ព្រះពីសស្មោរកម្មបុះ (៧) មោកសាងទុក្ខជាកំប្អូនលោកដោង ឯក្រោយ (៨) នោះហ្បេព្រះអង្គមោកគិត្តអន្ទ៊ពាំហាថាំខ្វណនែះ (៩) មោកអំពីយវត្រអន្លងតោកនាយនោះ យោលស (១០) ងខារនែះពុំទៀងលេយ មោកអាភ្ទុតានីមន្ទុម (១១) ហាសយិ រាជព្រះរាជ្ជសុមុង្គលសីលាបាយ៉្យបុពីត្រ (១២) ឆ្វតសសងដោង ទុំហ្លួ ៥៥ មោកទ្រង់ប៉ាំ (១៣) ងស្រូលព្រះអង្គន្វល្មើហព្រះ ពន្ធនោះបហាយប្រ (១៤) បៃយវត្តល្មើកឡជាស្នាំទានោះ ប្រាកជញ្ជីង (១៥) ១ តំលឹង ៧ ស្លឹង ៥ ស្បង ១៣ ជីពរ ២០ ជាសុរេប (១៦) ន្វប្រាកាយ៉្យអំម្បាលនែះហោង

លេខ ២៨

No 32 (B)

(១) សព្ទមស្តុមង្គលជយ្យាតិរេក ១៦០៥ សកកុរនខ្សត្រ ខែចែត្រ (២) ៧ រោជអាទិត្យពារសាណ្ហាំមន្គិឥសជុំទាំងហេិម មានចិត្តប្លា (៣) សាទ្ធាំប្រោសអាសិងនៅជាព្រៃស្រលះអ្សុត ពោលបិរស្យេ កាស្នោះ (៤) ស្រោតមានសំតែបព្រះរាជសមង្គល មហាសឃ៉ារាជបពិត្រ (៥) ទូសំតែបព្រះរាជសិសាចាយ៉្យមហា សឃ៉ារាជបុពិត្រ ទូសំតេប (៦) ព្រះមហាបទុំមហាសឃ៉ារាជបូពិត្រ ទូសំតេបព្រះធម្មស (៧) ត្លាបុពិត្រ ទូឥសភិក្ខុបេរសំម្នេរដោង ប្រណាស្យិងជាស (៨) ក្ខិវិញ្ញាណ ឯគ្រុហាសសោតមាននាង មានបោលិកនាងបុស (៩) ទូព្រះវង្សាគាយ្យុកនាងម៉ាន្ទូព្រះ រាមសេន្ហានាងជ្រាំបោ (១០) ទ្យនាងភរិ ឥសអ្នកទុំអម្ប្យាលនែះ ស្យិងជាសក្យិពើជ្វាណមានចិត្តប្លាសាទ្ធាំជួយ (១១) ជ្រោម អ្នមោទ្ធនានឹងនាងហេិមប្រោសអាសិងនៅជាស្រលះហោង ហា ប៊ុំមានអ្នកឯណា ៗ (១២) ម្យស្រតីយោកអាសិងនែះជាទុំះស្យេ ឡ្យ ព្រះពុទ្ធអម្បាលខ្សែបកុំម្បីប្រោសអ្នកនោះហោង

*លេខ ៤៩*

No 32 bis (B)

(១) សព្ទមស្បុត្សូស្តីស្រីសព្ទមង្គលពហុលបេស្តាជ្យោ តីរេក្ខ ១០៦៨ ស័ក្ខប្ត (២) ហ ខែបែតថ្ងៃយសុក្ខម្យរោជ ព្រះមន្ត្រីសង្គ្រាមនូនាងញាមានបិត្រកត្តំម្រាតសា (៣) ទ្វា ម្ហក្ខសាងព្រះសាធ ៩ នូព្រះជិនរូប ១៧ ព្រះអង្គ តាមតើមព្រះស្រី វត្ថុមហាពោធិជាស្ម (៤) ណាព្ញនាក្ខព្រះសាស្នា ហោពញា ម្ហាគេត ១ មុតស្បៀ ១ ទូតិសញ្ញត្តិកាបោងផ្តិណាក្ខណ (៥) ក្ខយសិងមក់ជួយជាកុសលអនុមោទនាព្រហ្មល្មមជាម្យ នឹងព្រះ មន្ត្រីសង្គ្រា (៦) ម នោវត្តព្រះអង្គមហាសឃរាជ្ជព្រះរាជសិលា បាយ៉ោបាន្ទឱប្បសំម្បត្ត (៧) ជាភិក្ខុ បំម្រើណរទៅមាតាបីតា នូផ្ទើយក្រោម្មសូមឲ្យបានទាំនព្រះប្អូង — (៨) ក្ករាជ្ជព្រះសិអារ ម្បៀត្បៀពោធិសត្វ សូមផុត្តបំហុត — ត្រ — ន៍រូប្ចតលគិរ (៩) ញានហោ (ង) ឯតំម្ទបប្រាក់ជាស្នាហាទានតម្លឹង ៣ ឯព្រ មន្ត្រី សង្គ្រាមនោះ (១០) នូស្រុកស្រប្ញុ ខ្មេរពាន់ព្រៃយក្របាស់ប្រាទ្វី និពានុសម្បបយោ (១១) ហោន្តុ

លេខ ៣០

Nº 33 (A)

(១) សព្វមស្តុស្សស្តីយស្រីសព្វមង្គលពហុលបេស្តាដៀ្យ (២) តិរេក ១៦០៦ សក្កជូតនក្សត្រ ១ រោជកាត្តិ (៣) ក ថ្ងៃអង្គារពារសារណា មន្តិតសជុំនុំមហាសយ៉រាជ (៤) ព្រះរាជសុមង្គលបុពិត្រ មហាសយ៉រាជព្រះរាជសិលាបាយ្យុំ (៥) ពិត្រ សំតែចព្រះស្សូរបញ្ញាបុពិត្រ សំតែចព្រះមរវីនៃបុពិត្រ (៦) សំតែចព្រះជេដ្ឋសិទ្ធាន្ត សំតែចព្រះជេដ្ឋស័ត្តា សំតែចព្រះ (៧) បរវិទូ សំតែចព្រះបញ្ញាវីនៃ ព្រះបញ្ញាពិទូរ ព្រះមហាបេរស្ម (៨) ណាកីរ អ្នកបវរពោធិ ឯគ្រហស្ថសោតមានហៅពញ្ញារាម្ម (៩) ជា ព្រះមន្ត្រីធូបេស ព្រះជិតខ្សត្រិ ព្រះមនោអនិជិត្រ នាងទាន(១០)ឯសរហៅមំមហៅនួតនាងជ្រីនាងសុកនាងខែមេស៊្យកតិស (១១) អ្នកទុំអំម្បាលតែះសីងជាសាក្សីសក្ខីវិញ្ញាណនាងគន្ធមា (១២) នបិត្រសាទ្ធាសាងព្រះពុទ្ធរូបមាសអង្គ ១ ប្រាកអង្គ ១ សំណាហអង្គ (១៣) ៣ ទង ១ ពិតាន ១ កំព្យ៉ ៥ តិសប្រាកស្មាទានជញ្ជីង ១ ទូរនឹងស្បូ (១៤) ឯ ២០ គ្រឿងបាយ

សំម្រាប ៣ គ្រឿងទិកសម្រ៉ាប ៣ កន្ទេលខ្នើយ (១៥) សំម្រ៉ាប ២ គ្រឿងស្លាសម្រ៉ាប ១ កុំម្សិតប្អូបពិន្លាគតើង ឥស គ្រឿង (១៦) តែកសឹងជាទានទុំអំម្បាលនេះបំម្រើនទៅព្រះ រាជាធិរា (១៧) ជតជាស្វាមីខ្ញុំឲយខ្ញុំ ៥ អ្នករ៉ូប អ្នកសី ១ អ្នកមោក ១ (១៨) មេរត្ន ១ មេកែវ ១ មេប៉ុក ១ ឥសទុំនេះសឹងរ៉ូបស្រលាះ ៨ (១៩) ទុំសអ្សិតបីបីរពោល ល្បើ ទោះយោប្បិមានបោងផ្គណាក្ខណ (២០) ពៅធោពារ ញាតិកាងនាម្យមោកពិពាធមាត្រាហាជាខ្ញុំ (២១) ល្បើ ព្រះ ត្រាស់អំម្បាល់ខ្សែបកំម្បីឲយប្រោសអ្នកនោះបា (២២) ឥល្បើ ហើយឱយរិត្មាះទុំអានន្តបក្រពាលបែញក្បាល (២៣) នែ អ្នកនោះសព្ទ ៗ ជាតកុំនេតហោង បើហាចៅក្រ (២៤) មឯ នាម្យបង្គាបឱយសោតឱយរិត្មាះបែញត្លួហ្មោះហោង

*លេខ ២៧*

*No 2 (B)*

(៣) សព្វិសព្វមហោរតឹង មហោឡា ពេប្ភូល

*សំ. ម. សតិសតិមហោរត្តិ-មហោឡារ-ពេចកូល ។ សតិសតិមហោរត្តិ = សព្វថ្ងៃសព្វយប់ ឬកល់ថ្ងៃកល់យប់ ។ មហោឡារ = ធំទូឡារ ធំធំក្រៃ ។*

*ពេចកូល ប្រហែលជា "ពេញកូល" គឺពេញពោរឡើង...ឬកើតពេញ... ។ ចូរមើលពាក្យថា កុល ។*

(៧) ទុក្ខជាកំប្លូនលោកផោង *ខ. ទុកជាក្បូនលោកផង ។*

(៩) វិត្រអន្លងតគោក *ខ. វត្ត អន្ទង់តគោក ឬវត្តអន្ទង់តាគោក ។*

(១៣) ទ្រងបាំងស្លូលព្រះអង្គប្លើហាព្រះពន្ធ *ម. ខ. ទ្រង់បង្ក្រុកូលព្រះអង្គនៅលើព្រះពាន់ ។*

(១៤) បបាយប្របៃយ *ខ. សំ. ចាយប្រត្យ័យ ។ ម. បច្ច័យ ។*

(១៥) ជីពរ *ម. ចីពរ, មកពី ចីវរ ។*

*លេខ ២៨*

*No 32 (B)*

(៣) អ្សូតពោលបិរល្សៀ *ខ. ម. ឥតពោល-បិរ-ឡើយ ។*

ចិរ ប្រែថា បោរាណ-អស់កាលដ៏យូរ ៗ ឥតពោលចិរទៀយនេះបាន សេចក្ដីថា យូរទៅក៏ឥតមានគោលតក់យកមកវិញដែរ. ៗ

(៧) សម្មើរផោងប្រេណា ម. ១. សាមណេរ-ផងច្រើន ៗ

លេខ ២៩

Nº 32 bis (B)

(២—៣) បិត្រកត្ដម្រាតសាទ្ធាមូក្ខសាងព្រះសាធ សំ. ១. បិត្តកាត់ផម្ទាសទ្ធា មកសាងព្រះសាទ ៗ

(៥) អនុមោទីនាព្រហ្មលួប ម. ១. អនុមោទនាព្រមលួម ៗ

(៦—៧) បាន្នឱប្បសំម្បត្ត ជាភ៏ក្ខ ១. ម. បានឧបសម្ប័ទជាភិក្ខុ ៗ

(១០) នូស្រុកស្រៀប់ខ្មែរញ៉ាន ១. នៅស្រុកស្រហ៊ុ-ខ្មែរពាន់ ៗ

(១០—១១) និពានុសម្បបយោ ហោត្ដុ ម. និព្វានស្ស បច្ចយោ ហោតុ ៗ ប្រែថា សូមជាបច្ច័យដល់ព្រះនិព្វាន ៗ

លេខ ៣០

Nº 33 (A)

(៨) ចៅពញ្ញារាមជោ (ភរ) ចៅពញ្ញាពមរោជា ៗ

(៩) ព្រះមន្ត្រីធូបេស (ភរ) ព្រះមន្ត្រីធិបេសរ៍ ៗ

(៩) ព្រះមនោអតិជិត (អាន) ព្រះមនោអនុជិត ឬព្រះមនោឥន្ទុជិត ។

(១៣) ទូរនិងស្បង ឰ. ទូស៍និងស្បង់ ។ សំពត់សសម្រាប់បន្សុកូលហៅថា ទូស៍ មកពីពាក្យ មគធថា "ទុស្ស" ។

(១៥) បុប ពិឡាគ តេង ឰ. បប-ពន្លាក-ដឹង ។

លេខ ៣១

*Nº 34 ( A )*

*Nº 34/1*

(១ — ៦) បពិត្រ នេះគឺ ពោះ ត្រីពិធសុបរិត សទ្ធា មហាវិបុល្យ អតុល្យ អតិរេក ឯកគ្គតា ប្រាមោជ ជោតិបង្គជវត្តរេណុវពិន្ទ អបិន្ទនិយ៖ បីតិមានោជ ពៃរោចន៍ សុគន្ធបវរ សរសោមនស្សាភិលង្កិត វិកសិត សោត្តរបរមបទុមាភា មហាអតិស័យក្រៃសម័យសុមហុត្តមហោត្តម សមន្ត អសំខារិកបិត្តវិធសុបរិត វិបាសត្យាអធិស្ឋាន ។

(៩) សំតែបព្រះសិសាក្យាមុណី ឰ. សំ. សម្ដេចព្រះត្រៃសាក្យមុនី ។

(១០) ស្ដេចច្រើកងនូអដ្ឋុត្តរវិរសតមុង្គល ១. ម. ស្ដេចច្កើន នូវអដ្ឋុត្តរវិសេសមង្គល ។ មង្គលដ៏ប្រសើរ ១០៨ ។

(១១) ឈាយលក្ខកងចក្ក អនគ្ឃអនាថិពិពារ៍សហារ ១. សំ. ឈាយល័ក្ខណ៍កង់ច័ក្រ អនគ្ឃ អនាថ ពិពណ៌សំហារ ។ អនគ្ឃ អនាថ ក្នុងទីនេះប្រែមិនបានសេចក្ដី ប្រហែលសរសេរខុស ព្រោះឃើញក្នុងទីដទៃសរសេរជា អន័ក អនាថ ក៏មាន ។

ពិពណ៌ = មានគុណគឺបណ្ឌិតគប្បីពណ៌នាដោយវិសេស, គឺជារបស់អស្ចារ្យ-ប្លែក ចំឡែក, ត្រកាល ។

សំហារ ប្រែថា នាំព្រម, បណ្ដុំចិត្ត, បណ្ដាលចិត្ត ដូចពាក្យថា ទេពសង្ហារ ប្រែថា ទេវតាបណ្ដាលចិត្ត ។

(១៣) សម៉ារនោ៉ សំ. សមានាប្រែថា ទីរួមនៅនៃទុក្ខ គឺវដ្ដ-សង្សារ ។

(១៤) ប្រភិលមហានុត្តស្រមុទ ១. សំ. ប្រភល-មហានពសមុទ្រ ។ ប្រភល ទីដាច់សន្ធឹង-លង្វឹមលង្វោប-ល្វឹងល្វើយ ។

(១៥) ស្នងពន្ធ៌ហារយ (សៀម) សងពាន់ហារយ គឺ ពីរពាន់ប្រាំរយ ។

(១៥) ភព្វជាតិកន្ទាល ម. ភព ជាតិ កន្ទារ ។

(១៧) បតុតិស័យ្យោជា ទ្វារទ៍ដ្ឋិទ្រិស្តុមសន្ទូបតុទសបេត្តសេិកិ សំ. បតុតឹសយោធា? ទ្វាសដ្ឋីទ្រិស្តិមស? ទ្វូវបតុទសបេតសិក ។ ម. បតុតឹសយោធា ទ្វាសដ្ឋីទិដ្ឋិមស ទ្វូវបតុទសបេតសិក ។ មស នេះ ប្រហែលជាសរសេរខុស ដោយប្រមាណមើលប្រហែលជាមិស ដែលប្រែថា ប្រឡំ-លាយឡំ,ឬក៏មិសដែលប្រែថា របស់ខ្មៅ-គ្រឿងខ្មៅ ឬក៏ មិថ្យាដូចមានពោលហើយខាងដើម ។

(២១) អាយុខ្ញែយ្យកាំម្មុខ្ញែនានិតសជន្មាពិត្តិ ម. សំ· អាយុខ័យ កម្មខ័យនាទីឯអស់ជន្មពិធី ។

(២៥) កាត្តេិកពុទ្ធពារ, សាណ្ណារ ភ្សិជាស្រែ សំ. ១. កត្តិក ពុធពារ, សារណា ពីអធ្យាស្រ័យ ឬ ពី អជ្ឈាស័យ ។

(២៧) វ្ដ៍បរិលរ៉ាបាលតលតិល្វូទែះ ១. រូបកល់រប៉ាល ដល់ឥល្វូវនេះ ។ រប៉ាល គឺលំដាប់ ដូចពាក្យថារប៉ាលក្សត្រ ។

(៣១) ព្រះអន្តរយាប្បណ្ណាង ពាក្យនេះជាព្រះរ៉ើ គិតមិនយល់ ។ ប្រហែលជា ព្រះអន្តរធានបង់ ទេដឹង ។

(៣២) ព្រះសីហៀង ម. ព្រះសីហិង្គ ។ ជាឈ្មោះព្រះពុទ្ធរូប ១ យ៉ាង វែបុដើមមកពីលង្កាទ្វីប ។

№ 34 2

(៣) ទ្វ កបិណ ម. ទ្វារកបិន ។

(៤) សង្ឃស្ថាន ខ. សង់ស្ថាន ។

(១៧) រត្នត្នណមាសមុណី ម. ខ. រតន មាស មណី ។ រតនក្នុងទីនេះឲ្យមើលថា ពត់-តន់ ។ ដែលសរសេរជារត្នគុណនេះលើស ពីគេ គឺ គុណ ពាក្យនេះជាដូច្នេះឯង កុំឲ្យអ្នកមើលគិតសង្ស័យជាសព្វ អ្វីផ្សេងឡើយ ។

(២០) អ្យិតឯហ៉្មោង ខ. ឥតឯហ្មង ។

លេខ ៣៦

*N. 35 (A)*

(១៥) យុគ្គលវិមុលភិបិនត្រៃយ សំ. យុគលវិមល អបិន្ទ្រិយ ។

(២៤) ព្រះសិលា ម. គឺព្រះស្ពានអំពីថ្ម ។

(២៤) ព្រះទេពហារូ ម. ព្រះទេពតារូ គឺព្រះដែលស្ពានអំពី ដើមទេពតារូ ដែលអ្នកខ្លះហៅថា ទេពពិរូ ។

(៣២) ធិព្វសម្បត្តិ បុរិបុណ្ណំ សំ. ទិព្វសម្បត្តិ បរិបុណ្ណ័ម៍ ឬបរិបុណ្ណំ ។

(៣៧) ជាតជារាម៉ែរ ម. ជាតិ ជរា មរណ៍ ។

(៣៨) សង្សារវត្ត ម. សំសារវត្ត ប្រែថា អវត្តលះទៅ ។

(៤១) មហាបញ្ញា សំ. មហាបញ្ញ័ម៍ ឬ មហាបញ្ញាំ ។

លេខ ៣៣

*№ 36 (B)*

(៨) ឯគ្រីសសោតមានព្រះសុភាធិពូតា សួស ១.

(ន័រ) ឯគ្រីហស្ថសោតមានព្រះសុភាធិបតី សួស្តី ។

(១៩) រាន្ទុះទ្វអានឧបកក្រពាលបែញក្បាល ១. សំ.

រន្ទះទាំងអនន្តបក្រពាឡ បាញ់ក្បាល ។

លេខ ៣៤

*№ 37 (A)*

(១ – ៤) អេះគឺ រូ សុចរិតវិរិផរិតដារណាឆ្យាស្រ័យ នៃឲកញ្ញា យមរាជ នរិន្ទ្រជាតិវរវង្សអង្គឧត្តមហាសេនាធិបតិន្ទ្រារដ្ឋាភិរក្ខបក្រសិទ្ធិធរាធរ ព្រះមហាឧតរប៉ាលអភ័យតិរប៉ាក្រមពាហុ ឯកមន្ត្រី ដ៏ជាប្ដីចមទាវ ទិព្យសុពណ៌ ។ ន័រយមរាជសម័យនេះសរសេរជាយោមរាជ តែប្រើបែបបូរាណនោះត្រូវជាង ។

(៨) សង្ហាលាបំម្រេបរាសស្រែបហ្យេ ខ. សង់សាលា បម្រើបម្រាស់ស្រេចហើយ ៗ

(១១) សុត្រាទសជាត្រ សំ. សាស្ត្រាទសជាតិ ៗ

(១២) ព្រះអត្តិធម្ម ប្រឋម្ម ព្រះធម្មបក្ខដោង ម. (ឈ្មោះ) ព្រះអភិធម្ម ប្រថម (គឺបឋមសម្ពោធិ ឬបឋមត្រាស់) ព្រះធម្មចក្កជង ៗ

(១៣) បុះព្រះតំបារ ខ. បុះព្រះដំបារ គឺ បុះកន្ទផែនមាស ៗ

(១៤) គ្រែងស្លាភ្លក ខ. គ្រឿងស្លាក្លក? បើពុំដូច្នោះទេ គឺជា កញ្ច្រែងស្លា ១ យ៉ាងគេធ្វើដោយក្លក ហៅថា គ្រែង ទេដឹង ៗ

(១៧) រិតសត្រា រិតសាស្ត្រា គឺស្លឹករិតដែលចារសាស្ត្រា ៗ

(១៨) ប៊ូប្ប-តៀងទ្ធំ-តៀងតូប-អង្វស្ប-បន្លាក ខ. បប-ដីងធំ-ដីងតូច-អង្រ្ទស-ពន្លាក ៗ

(១៩) គ្រង — ខ្សើស្ទៀង ខ. គង-ខ្សែស្ទៀង ឬគ្រឿង ខ្សែស្ទៀង ៗ

(២០) គីត្តតិសទ្ធំទិម្មេប-ស្មាទាណ ខ. ម. គិតអស់ទាំង បំណាច់-សមាទាន ៗ

(២៨) ជំពោរទន្សា ខ. ជម្រៅទន្សា ។ ពន្លួញដែលសម្រាប់បញ្ចូលទៅក្នុងដំណាប់ហៅថា ទន្សា ។ ម្យ៉ាងទៀត ឈើដែលគេបោះជាគោលឲ្យទឹង ក៏ហៅថា ទន្សា ដូចពាក្យថា ទន្សាបេតិយ គឺគេយកឈើមកបោះហើយទើបផ្ចាន់ខ្សាប់មកចាក់គរឡើងជាបេតិយ ។ ម្យ៉ាង របស់ដែលជាគោលសំខាន់បាននឹងអំពើបុណ្យបាបដែលសត្វធ្វើហើយ ជាអ្នកនាំសត្វបដិសន្ធិ អំពើបុណ្យបាបនេះក៏ហៅថា ទន្សាដែរ ដូនក្នុងពាក្យសុភាសិតថា បុក្យជាតា មិនក្រែណាទឹងទន្សាកំណើត ។ តែដូនណាគេហៅថា អន្សា ។

(២៩) សើល្បធុប សំ. សិល្បធប៍ ។ តាមទម្លាប់សរសេរជាសិល្បធុប ។

លេខ ៣៨

No 38 (A)

(៩) ហៅពញាសេនាធិព្ទត្បីនូវអ្នកហៅពញាដោប្រអង្គ

(ងារ) ហៅពញាសេនាធិបតី នូវអ្នកហៅពញាគេដោព្រះអង្គ ។

លេខ ៣៦

Nº 10 (A)

(៦) ពាតគ្រោង ខ. ពាទ្យគង ។

(៦) សំពោរ ខ. សម្ភោរ ។

(៦) សុត្រាហិប្ប សំ. ខ. សាស្ត្រាហិប ។

(១១) តល ៥០០០ បសា ខ. ម. ដល់ ៥.០០០ ពស្សា

ឬ ដល់ ៥.០០០ វស្សា ។

(១៩) ប្រាងជាសង ? ( គិតមិនយល់សេចក្តី )

(២៦) បុឌ្ឍាសាព្រះពុទ្ធតីកា ខ. ម. បណ្តាស្សាព្រះពុទ្ធដីកា ។

(២៧) តុំរេហាតុំរ្វង ខ. ដំរែដម្រង់ ។

(២៨) បានទ្វ័នឆាកាលត្រសធម្មិប្រិប្យីហ្មើនបួនពាន

ខ. បានទាន់នាកាលត្រាស់ធម៌ប្រាំបីហ្មឺនបួនពាន់ ។

(២៩) ខ្លាតខ្លាហលេយ ខ. ឃ្លាតឃ្លាឡើយ ។

# ប្រជុំពាក្យកាព្យ

## ភាគទី ១

ព្រះរាជនិពន្ធ ព្រះបាទសម្ដេចព្រះស្រីធម្មរាជា

ព្រះរាជសម្ភារ

ព្រះចៅក្រុងកម្ពុជាធិបតី

គទី ៤

## ច្បាប់ព្រះរាជសម្ភារ

ហៃសាធុជនផង　　នេះគឺចំណាំ
បទបាឡីថា　　គម្ពីរសេធម៌
អាណាក្រិតិកា　　គួរគប្បីមហា
ជនផងត្រងត្រាប់ ៗ　　ធម៌នេះដំបូន្មាន
រួមរក្សាប្រាណ　　ឲ្យបានក្តីគាប់
ដល់លោកបរលោក　　ហៅរស់ពុំស្លាប់
ធម៌នេះជាច្បាប់　　ក្តីគាប់បរិយាយ ៗ
កុំទុកចិត្តបរទេស　　កុំទុកចិត្តអក៍នេស
កុំទុកចិត្តអភិប្រាយ　　ប្រើសុំវែងខ្ពស់ (១)
រំពឹងឲ្យឆ្ងាយ　　ស្តាប់ពាក្យបរិយាយ
បណ្តាំមេដី ៗ　　កុំជឿងដោយខ្យល់
កុំឧនពាក្យពល់　　កុំខ្វល់ដោយស្រី
កុំកាន់ពិសយន៍　　គប់ទឹងស្ត្រី
សមណជនដី　　កុំឲ្យក្តីត្រូវ ៗ
កុំនៅញ៉ងឈ្មោះ　　កុំស្តាប់អាស្រូពេះ
កុំស្តាប់គាស្រូវ　　កុំ[illegible]ពោនស្មុន

---

១ ច្បាប់ខ្លះថា ប្រើធំ ... ក៏មាន ។

កុំស្កាត់ច្រកផ្លូវ កុំធ្វើស្រែស្រូវ
នៅផ្លូវដំរី ៗ ផ្អែមពីរប្រការ
ចំណោរនៅដាល កុំអាលឲ្យធី
ផ្អែមមួយពាក្យពាល រែងកលរកក្តី
ផ្អែមមួយពាក្យស្រី ស្រដីមាយា ៗ
ពាក្យគ្រូរែងរឹង ស្រារែងស្រវឹង
ពុំដែលពីសា ពាក្យពិតរែងស្លូង
ពុំពីរោះថា បណ្តាំមេបា
រែងថាពុំគាប់ ៗ ទៅរែងស្អប់បេះ
ខ្សត់ឥតចំណេះ ស្អប់អ្នកមានទ្រព្យ
ស្រីស្រាលប្រចណ្ឌ រែងស្អប់ខ្ញុំគាប់
ពាលពិតឥតច្បាប់ រែងស្អប់ប្រដៅ ៗ
ចង់បុណ្យបានបាប បើងចង់លាភ
រែងបាត់ធនទៅ មានះបាត់មិត្រ
ឥតអ្នកជារៅ ក្រេវក្រោធយោរយៅ
រមែងបាត់អង្គ ៗ ស្លូងគាប់បានយស
ចង់ស្លូងរបស់ ប្រើបេះផ្គត់ផ្គង់
ចង់ធំកុំអួត ដើមមានពូជពង្ស

បង់ឲ្យខ្លួនត្រង់ ប្រើផ្គាប់អ្នកមុខ ៗ
ខ្លែងហើរផ្ចិតខ្យល់ នាយផ្កើងផ្ចិតពល
ក្រោយឲ្យសុខ ទ្រព្យគង់ផ្ចិតស្រី
បេះសំបៃទុក មានផ្ទះស្រណុក
ផ្ចិតកិរិយា ៗ បាត់យសផ្ចិតខ្ជិល
បាត់ញាណទានសីល ផ្ចិតសេពសុភ
ប្រមាទបាត់បុណ្យ ខឹងបាត់ប្រាជ្ញា
លេញលេងដៀលថា បាត់កិរិយាគាប់ ៗ
អត់ធុនឥតទោស ធ្វើចិត្តសន្តោស
បង្កើតជាទ្រព្យ មេត្រីជាញាតិ
ក្រោយដល់ស្លាប់ ចៀសក្ដីពុំគាប់
ជាគន្ធពិដោរ ៗ ទឹកបាក់ទៅទាប
បុណ្យបាត់ផ្ចិតបាប លាភបាត់ផ្ចិតឃោរ
ទឹកថ្លាផ្ចិតលេក ពុំយល់ស្រមោល
ទោសកើតផ្ចិតពោល ល្មមមាត់ឈ្លានពាន ៗ
ខ្លៅវែងស្អប់ប្រាជ្ញ នាអ្នកខ្លួនខ្លាច
វែងធ្វើជាហ៊ាន ខ្សត់ខ្សោយស៊ិតទ្រុត
វែងធ្វើជាមាន អ្នកឥតសន្តាន

វែងមើលគេឆាយ ៗ　　ទាហានជើងដូចសឹក
ធ្វើស្រែដូចទឹក　　ត្រែកពលដូចចាយ
សិស្សប្រាជ្ញដូចគ្រូ　　ដេរពោលដំរាយ
ពលជាដូចនាយ　　ហ៊ឹកហ៊ឺនខះខំ ៗ
រៀនក្តីគួរគិត　　បាស់ឥតប្រព្រឹត្ត
ទូវប្រែប្រចខ្ញុំ　　អ្នកជា ៗ កាប
តូចប្រែជាធំ　　ពង្សព្រូជឧត្តម
ប្រចខ្ញុំជាកស្រ្ត ៗ　　ឃើញសេះជាលា
ក្មានជាទា　　ពពាយជាទាស
សំណជាប្រាក់　　ស្ពាន់ធ្លាក់ជាមាស
បន្ទាយជាជាស　　កប្បាសជាគរ ៗ
ហេតុនេះគួរគិត　　គួររិះរកហឹត
ដឹងរសេគន្ធ　　ពីដោរអេសុដោរ
ពីសាសាទរ　　ហឹតៈហើយគប្បីប-
រិភោក្តាក្តិត ៗ　　ល្អឹកត្រូពីពាក្យ
សាកសួររកសាប់　　សន្តានព្រេងព្រឹទ្ធ
រករិះកលល្បើ　　សុចរិតទុច្ចរិត

ហើយហោងគួរគិត ឲ្យដឹងខ្ពស់ទាប ៗ
ដូចខ្វាក់ចាំងស្បែក មួយដូចទំពែក
ចង់សុំប្រែងលាប ដូចថ្ងង់ក្ដាប់ប្រៀង
ទះដៃព្រាក ៗ ដូចខ្វិនអាបឡាប
ចង់បងក្បិនតែ ៗ ពុតញ្ញាយមានបី
មួយដូចដំរី សាហាវឥតបទ
អាចផ្សះផ្សាំងបាន កន្ទេរកាន់កត់
ដាលដេញគោតគត់ ៦ ហត្ថហោង ៗ
មួយចង់ឈ្នានីះ ចិត្តចង់ចចេស
ពុំដោយគន្លង ពាក្យពោលអ្នកធំ
ប្រឡំសួរសេង ពុំគិតក្ដីហ្មង
ចងចេរអន្ដរាយ ៗ មួយស្រីពេស្យា
បំពេញព្រហ្មចា- វីរុសអកិច្ចាយ
អំពើទាំងបី ហៅពិសពុតញ្ញាយ
សាធុសម្ដាយ បៀសកុំបីគ្រាប់ ៗ
ប្រាជ្ញពុំស្មើពុត បំរើលំឧត
ពុំស្មើក្ដីគាប់ មានគុណពុំស្មើ

| | |
|---|---|
| អ្នកមានបុណ្យក័ព្ទ | ស្វែងរៀនគេច្បាប់ |
| ពុំស្មើចិត្តជា ៗ | ស័ក្តិពុំស្មើយស |
| អ្នកមានរបស់ | ពុំស្មើសក្តា . |
| សូវបង់ធនធាន | កុំខុសអាជ្ញា |
| សូវមានកេតា | កុំឲ្យគ្នាមើលងាយ ៗ |
| សូវសុំកុំយក | គ្នាស្មើកុំកេ |
| ដូចបាវទឹងនាយ | ខុសគាប់សូវអត់ |
| កុំឲ្យព្រឆ្ងាយ | ក្តីសុខមទាំងឡាយ |
| កុំចាយសូវស័ព្ទ ៗ | ធម៌នេះដំបូន្មាន |
| រួមគេក្របប្រាណ | ឲ្យបានក្តីគាប់ |
| សូវបង់ធនធាន | កុំឲ្យខ្លួនស្លាប់ |
| សូវស្លាប់គួរគាប់ | សេធម៌កុំបីបង់ ៗ |
| បន្ទិបមេបា | អំបូរលោកថា |
| ទូកតាមកំពង់ | សំពៅតាមខ្យល់ |
| បង្គុតដំរង់ | មេឈើមតែងត្រង់ |
| ត្រីវិសែជាមុខ ៗ | ដូចចិត្តបិជា |
| ដូចមានគតិយា | ទៅផ្ទះស្រែណុក |
| ដូចក្ដូនទទួល | យកពាក្យគ្រាពុក |

ដូចខ្ញុំឲ្យមុខ អម្ចាស់ប្រើហៅ ។
បន្តិចមេបា អំបូរលោកថា
ព្រេងព្រឹទ្ធប្រដៅ ទើងធីប្រើរក
ទើងស្វែងប្រើទៅ ទើងស្នេហ៍ប្រើហៅ
មិត្រមកជាមិត្រ ។ ពាក្យខុសកុំស្តាប់
ក្តីខុសកុំត្រាប់ អ្នកកាចកុំប្តិត
ល្ងង់កុំស្រដី ខ្សត់កុំទុកចិត្ត
ពាលោកុំប្តិត ជាមិត្រមេត្រី ។
ប្រើថ្លឹងឲ្យស្មើ ទោះបីទឹងប្រើ
ប្រើអ្នកបេះក្តី កុំយកពាក្យស្មោក
ផ្ដឹមទឹងគម្ពីរ កុំយកពាក្យដី
ផ្ដឹមទូវពាក្យពាល ។ មើលក្នុកជញ្ជីង
កុងចិត្តឲ្យដឹង ណាធ្ងន់ណាស្រាល
កុំយកមណីរ័តន៍ មាសមានជាកាល
ចិត្តកុំបណ្តាល ទូវបង់សីលធម៌ ។
ប្រើដឹងគុណហាប ប្រើដឹងខ្ពស់ទាប
មានក្នុកយល់ល្អ ទោះដឹងទឹកមាស

ពុំបោរនៅថ្ង | ទោះដឹងនៅដឹស
ពុំបោរសំបុត្រ ៗ | ផ្ញើស្រែមើលស្មៅ
សន្តានមើលផៅ | បំរើមើលពុត
ទោះដឹងពុតជា | ពុំបោរពុតត្បុត
ដឹងចិត្តបរិសុទ្ធ | ពុំបោរគេរិយា ៗ
ទេពីមើលក្រិត្យ | ក្សត្រាមើលបុទ្ធ៍
ទាហានមើលចេស្ដា | ជាងមើលអំពើ
អំពីហត្ថា | ទោះយកករិយា
មើលនាលំនៅ ៗ | អាសាក្ដីបី
បណ្ដាំមេជី | ព្រេងព្រឹទ្ធប្រជា
អង្គសេសុទ្ធ | ចំអិនឲ្យនៅ
ពីសីហើយខ្លៅ | ប្រាជ្ញឥតមារយាទ ៗ
អ្នកបួសឥតក្រិត្យ | បាស់ឥតប្រព្រឹត្ត
ខ្សត់ច្រើនប្រមាទ | គរិយាជុយផាយ
បាយក់យត់តខ្លាត | គលពាលសុទ្ធសាត
ប្រដៅក្របាន ៗ | ជុះក្អើងមានបី

អំពើពុតស្រី　ទឹងត់តប្រមាណ
កូនកាចចចេស　ពុំដោយដំបូន្មាន
ខ្ញុំកាចកៀសប្រាណ　ពុំឲ្យម្ចាស់ប្រើ ។
ហោកប្រើគូរ　កូមប្រើមូល
ស្ទង់ទឹកប្រើស្មើ　បន្ទាត់ប្រើត្រង់
ពលផ្គង់គប្បីប្រើ　ពុំហើយគប្បីធ្វើ
កុំលែងគប្បីភ្លា ។　ក្ដីកោតមានបី
កោតមួយពួកស្រី　ស្រដីមាយា
កោតមួយពាក្យពិស　អាស្រូវដៅថា
កោតមួយពាក្យពា-　ឈោឈោកខ្វេជន ។
ពិសពស់នានា　កុយខ្លាយខ្ដា
កាលគត់ស្ដាប់មន្ត　ត្រង់ពិសពាក្យពាល
ពេលកលពុំស្រន្ត　សូម្បីអស់ជន្ម
ក្រមន្តបោសបាន ។　ហេតុនោះគួរគិត
គួររិះរកហឹត　ថ្នាំពិសឲ្យស្រាន្ត
ដ៏លោកនេះគួរ　រកអ្នកទ្រង់ញាណ

| | |
|---|---|
| សេពសាងសីលទាន | ជាថ្នាំលោកិយ ៗ |
| រីថ្នាំបរលោក | ជៀសចាកទុក្ខសោក |
| បង់បញ្ចឥន្ទ្រិយ | គប្បីផឹកសត្តតិង្ស- |
| ពោធិបក្ខិយ | អាចនាំដល់ត្រៃ- |
| ពិធសម្បត្តិសារ ៗ | ពិដោរផ្កាបី |
| ពិដោរមេត្រី | ស្វសីហោចារ |
| ពិដោរបរិសុទ្ធ | កុសលសម្ភារ |
| ពិដោរនេះផល | ដល់សួគ៌ពុំស្បើយ ៗ |
| ពិដោរផ្កាបី | ក្រៃលែងគ្លិនក្ដី |
| ឥតឯល្ហែល្ហើយ | ដោយខ្យល់ប្រាសខ្យល់ |
| ទៅត្រើយឆ្លងត្រើយ | ពិដោរពុំស្បើយ |
| ហៅសេគន្ធា ៗ | ពិសាផ្លែប្រាំ |
| ពិសាសេពធម៌ | ពិសាសត្យា |
| ពិសាសីលទាន | ទ្រើសទ្រង់ករុណា |
| ពិសាសេក- | ចាបេញមជ្ឈូរ ៗ |

ពិសាផ្លែប្រាំ　　គិតជានាយនាំ
ឥន្ទ្រិយទៅចូល　　ត្រិពិធសម្បត្តិ
ទិព្វរតនអនុកូល　　បំណោរទៅចូល
មោក្ខមាគ៌ាល័យ ។　　នេះជាច្បាប់ធម៌
ប្រសើរមហាគាប់　　ឧត្តមពេកក្រៃ
ត្រូវអ្នកណាបាន　　ប្រាជ្ញាឈ្លាសវៃ
អាចដឹងដោយន័យ　　រសធម៌គាថា ។
គួរបេះគួរចាំ　　គួរតាមបណ្តាំ
ទូលទុកសិរសា　　ធម៌នេះស្មើក្សីរ
អម្រឹតផាក　　សម្តេចកតវា
សាធុប្រាសប្រាណ ។　　អ្នកណាបានស្តាប់
អ្នកណាបានត្រាប់　　អ្នកណាបានធ្យាន
រសធម៌នេះគាប់　　ជាច្បាប់ខ្មាន
អ្នកនោះស្មើបាន　　ដល់និព្វានហោង ។

# ព្រហ្មចរិយកថា

# របស់ព្រះមហាសែស

(តនឹងចប់)

ឯសាវកភាសិត បានខាងធម៌ដែលសាវកកប់បញ្ចូលក្នុងបរិសទ្យ ទាំង ៤ បានសំដែងមានអនង្គណសូត្រ សម្មាទិដ្ឋិសូត្រ អនុមានសូត្រ ចុល្លវេទល្លសូត្រ មហាវេទល្លសូត្រ ជាដើម ។

ឯឥសិភាសិត បានខាងធម៌ដែលពាហិរបរិព្វាជក គឺអ្នកបួសខាងក្រៅបានសំដែង មានបរិព្វាជកវគ្គទាំងអស់ជាដើម ។

ឯទេវតាភាសិត បានខាងធម៌ដែលទេវតាបានសំដែង គឺធម៌មាននៅក្នុង ទេវតាសំយុត្ត ទេវបុត្តសំយុត្ត មារសំយុត្ត ព្រហ្មសំយុត្ត និងសក្កសំយុត្ត ជាដើម ។

តអំពីនេះទៅនឹងជ្រើសរើសយកគាថាផ្សេងៗ មកសំដែងដើម្បីញុំាងសាធុជនឲ្យជ្រាបក្នុងភាសិតទាំង ៤ នោះ ។

សេចក្តីថា មានទេវតា ១ ចុះមកពោលគាថានេះក្នុងសំណាក់ព្រះដ៏មានព្រះភាគថា

នន្ទតិ បុត្តេហិ បុត្តិមា
គោមិកោ គោហិ តថេវ នន្ទតិ
ឧបធី ហិ នរស្ស នន្ទនា
ន ហិ សោ នន្ទតិ យោ និរូបធិ ។

(ប្រែថា) អ្នកមានកូនច្រើនរមែងត្រេកអរនឹងកូនទាំងឡាយ អ្នកមានគោច្រើនរមែងត្រេកអរនឹងគោទាំងឡាយដូចគ្នា ឧបធិគឺកាមគុណទាំង ៥ ជាទីត្រេកអរនៃជន ជនឯណាគ្មានឧបធិ ជននោះមិនត្រេកអរឡើយ ។

(គាថានេះ ជាទេវតាភាសិត)

ព្រះដ៏មានព្រះភាគទ្រង់ភាសិតថា

សោចតិ បុត្តេហិ បុត្តិមា
គោមិកោ គោហិ តថេវ សោចតិ
ឧបធី ហិ នរស្ស សោចនា
ន ហិ សោ សោចតិ យោ និរូបធិ ។

អ្នកមានកូនច្រើនរមែងសោយសោកនឹងកូនទាំងឡាយ អ្នកមានគោច្រើនរមែងសោយសោកនឹងគោទាំងឡាយដូចគ្នា ឧបធិជាទីសោយសោកនៃជន ជនឯណាគ្មានឧបធិ ជននោះមិនសោយសោកឡើយ ។

(គាថានេះជាពុទ្ធភាសិត)

មានទេវតា ១ ចុះមកពោលគាថានេះ ក្នុងសំណាក់ព្រះដ៏មានព្រះភាគថា

នត្ថិ បុត្តសមំ បេមំ   នត្ថិ គោសមិតំ ធនំ

នត្ថិ សុរិយសមា អាភា   សមុទ្ទបរមា សរា ។

(ប្រែថា) សេចក្ដីស្រឡាញ់អ្វី មិនស្មើនឹងសេចក្ដីស្រឡាញ់កូនឡើយ ទ្រព្យអ្វីមិនស្មើនឹងទ្រព្យគឺគោឡើយ ពន្លឺអ្វីមិនស្មើនឹងពន្លឺព្រះអាទិត្យឡើយ ស្រះទាំងឡាយមានសមុទ្រជាយ៉ាងក្រៃលែង គឺថាសមុទ្រដ៏ឧត្តមធំទូលាយជាងស្រះទាំងឡាយ ។

(នេះជាទេវតាភាសិត)

ព្រះដ៏មានព្រះភាគទ្រង់ភាសិតថា

នត្ថិ អត្តសមំ បេមំ   នត្ថិ ធញ្ញសមំ ធនំ

នត្ថិ បញ្ញាសមា អាភា   វុដ្ឋិ វេ បរមា សរា ។

(ប្រែថា) សេចក្ដីស្រឡាញ់អ្វីមិនស្មើនឹងសេចក្ដីស្រឡាញ់ខ្លួន ទ្រព្យអ្វីមិនស្មើនឹងទ្រព្យគឺស្រូវ ពន្លឺអ្វីមិនស្មើនឹងពន្លឺគឺបញ្ញា ស្រះទាំងឡាយមានភ្លៀងជាយ៉ាងក្រៃលែង គឺថាភ្លៀងដ៏ឧត្តមជាងស្រះទាំងឡាយ ។

(នេះជាពុទ្ធភាសិត)

មានទេវតា ១ ចុះមកពោលគាថានេះ ក្នុងសំណាក់ព្រះដ៏មានព្រះភាគថា

ខត្តិយោ ទិបទំ សេដ្ឋោ ពលិពទ្ទោ ចតុប្បទំ
កោមារី សេដ្ឋា ភរិយានំ យោ ច បុត្តាន បុព្វជោ ។

(ប្រែថា) ក្សត្រប្រសើរវិសេសជាងសត្វមានជើងពីរ សត្វគោប្រ-សើរវិសេសជាងសត្វមានជើង ៤ ភរិយាដែលមកអំពីក្មេងប្រសើរវិសេសជាងភរិយាទាំងឡាយ កូនឯណាកើតមុនគេ កូននោះប្រសើរជាងកូនទាំងឡាយ ។

(នេះជាទេវតាភាសិត)

ព្រះដ៏មានព្រះភាគទ្រង់ភាសិតថា

សម្ពុទ្ធោ ទិបទំ សេដ្ឋោ អាជានីយោ ចតុប្បទំ
សុស្សូសា សេដ្ឋា ភរិយានំ យោ ច បុត្តានមស្សវោ ។

(ប្រែថា) ព្រះសម្ពុទ្ធប្រសើរវិសេសជាងសត្វមានជើងពីរ សត្វអា-ជានេយ្យប្រសើរវិសេសជាងសត្វមានជើង៤ ភរិយាដែលស្តាប់បង្គាប់ស្វាមីប្រសើរវិសេសជាងភរិយាទាំងឡាយ កូនឯណាដែលស្តាប់បង្គាប់មាតា-បិតា កូននោះប្រសើរជាងកូនទាំងឡាយ ។

(នេះពុទ្ធភាសិត)

មានទេវតា ១ ពុះបកពោលគាថានេះក្នុងសំណាក់ព្រះដ៏មានព្រះភាគថា

និទ្ទា តន្ទី វិជម្ភិតា អរតី ភត្តសម្មទោ
ឯតេន នប្បកាសេតិ អរិយមគ្គោ ឥធ បាណិនំ ។

(ប្រែថា) សេចក្តីលក់ សេចក្តីខ្ជិលច្រអូស សេចក្តីមិតពត់កាយ សេចក្តីអផ្សុកទើងសេចក្តីស្រវឹងបាយ. រមែងមាននៅក្នុងសន្តាននៃសត្វ អរិយមគ្គរមែងមិនរុងរឿង មិនប្រាកដដល់សត្វទាំងឡាយ ក្នុងលោកនេះ ក៏ព្រោះធម៌មានសេចក្តីលក់ជាដើមនេះឯង ។

(នេះជាទេវតាភាសិត)

ព្រះដ៏មានព្រះភាគទ្រង់ភាសិតថា

និទ្ទំ តន្ទឹ វិជម្ភិតំ អរតឹ ភត្តសម្មទំ
វីរិយេន នំ បណាមេត្វា អរិយមគ្គោ វិសុជ្ឈតិ ។

(ប្រែថា) អរិយមគ្គតែងបណ្តេញនូវកិលេសជាតិនោះ ៗ គឺសេចក្តីលក់ ១ សេចក្តីខ្ជិលច្រអូស ១ សេចក្តីមិតពត់កាយ ១ សេចក្តីអផ្សុក ១ សេចក្តីស្រវឹងបាយ ១ ហើយបរិសុទ្ធបាន ដោយសេចក្តីព្យាយាម ។

(នេះជាពុទ្ធភាសិត)

មានទេវតា ១ ចុះមកក្រាបទូលសួរព្រះអង្គថា

កតិ លោកស្មឹ បជ្ជោតា យេហិ លោកោ បកាសតិ
ភគវន្តំ បុដ្ឋុមាគម្ម កថំ ជានេមុ តំ មយំ ។

(ប្រែថា) លោករមែងភ្លឺប្រាកដដោយពន្លឺឯណា ពន្លឺនោះមានប៉ុន្មានក្នុងលោក ខ្ញុំមកដើម្បីសួរព្រះអង្គ ដូចម្តេចទើបដឹងរឿងនោះបាន ។

(នេះជាទេវតាភាសិត)

ព្រះអង្គទ្រង់ភាសិតថា

ចត្តារោ លោកេ បជ្ជោតា បញ្ចមេត្ថ ន វិជ្ជតិ
ទិវា តបតិ អាទិច្ចោ រត្តិមាភាតិ ចន្ទិមា
អថ អគ្គិ ទិវា រត្តឹ តត្ថ តត្ថ បភាសតិ
សម្ពុទ្ធោ តបតំ សេដ្ឋោ ឯសា អាភា អនុត្តរា ។

(ប្រែថា) ពន្លឺមាន ៤ ក្នុងលោក ពន្លឺជាគំរប់ ៥ មិនមានក្នុងលោកនេះឡើយ ព្រះអាទិត្យភ្លឺក្នុងវេលាថ្ងៃ ព្រះចន្ទ្រភ្លឺក្នុងវេលាយប់ ចំណែកភ្លើងភ្លឺទាំងយប់ទាំងថ្ងៃ ក្នុងទីនោះៗ ព្រះសម្ពុទ្ធប្រសើរវិសេសជាងពន្លឺទាំង ៣ នោះ នេះជាពន្លឺដ៏ប្រសើរ ។

(នេះជាពុទ្ធភាសិត)

មានទេវតា ១ ចុះមកក្រាបទូលសួរព្រះអង្គថា

ចតុចក្កំ នវទ្វារំ បុណ្ណំ លោភេន សំយុតំ
បង្កជាតំ មហាវីរ កថំ យាត្រា ភវិស្សតិ ។

(ប្រែថា) បពិត្រព្រះអង្គមានព្យាយាមធំ សរីរៈនេះមានចក្កបួន គឺឥរិយាបថទាំងបួន មានទ្វារ ៩ ពេញដោយអសុចិប្រកបព្រមដោយលោភគឺតណ្ហា កើតអំពីភក់គឺកិលេស នឹងចេញទៅឲ្យផុតអំពីសរីរៈនេះដូចម្ដេចបាន ។

ព្រះអង្គទ្រង់ភាសិតថា

ឆេត្វា នទ្ធឹ វរត្តញ្ច ឥច្ឆាលោភញ្ច បាបកំ
សមូលំ តណ្ហំ អព្ពុយ្ហ ឯវំ យាត្រា ករិស្សតិ ។

(ប្រែថា) បុគ្គលកាត់នូវខ្សែចំណងនឹងខ្សែព្រ័ត្រ គឺការចងពៀរ កាត់នូវឥច្ឆាលោភដ៏លាមក ហើយដកនូវតណ្ហាព្រមទាំងឫសចោលចេញ នឹងចេញទៅឲ្យផុតអំពីសរីរៈនេះ ដោយប្រការដូច្នេះបាន ។

(នេះជាពុទ្ធភាសិត)

មានទេវតា ១ ចុះមកក្រាបទូលសួរព្រះអង្គថា

ឯណិជង្ឃំ កិសំ វីរំ អប្បាហារំ អលោលុបំ
សីហំវេកចរំ នាគំ កាមេសុ អនបេក្ខិនំ
ឧបសង្កម្ម បុច្ឆាម កថំ ទុក្ខា បមុច្ចតិ ។

(ប្រែថា) ខ្ញុំចូលមកក្រាបទូលសួរព្រះអង្គ ដែលមានស្នងព្រះបាទមូលល្អដូចជាស្នងជើងសត្វម្រឹគទ្រាយ មានព្រះកាយស្គមល្មមល្អ មាន

ព្យាយាម មានអាហារតិច មិនមានសេចក្ដីលោភ ត្រេចទៅតែ ១ ព្រះអង្គឯងដូចជាសត្វសីហទីងដំរីដ៏ប្រសើរ មិនមានសេចក្ដីប្រាថ្នាក្នុងកាមទាំងឡាយ ព្រះបុគ្គលរួចចាកទុក្ខបាន ដោយប្រការដូចម្ដេចទៅ ។

ព្រះអង្គទ្រង់ភាសិតថា

បញ្ច កាមគុណា លោកេ មនោឆដ្ឋា បវេទិតា
ឯត្ថ ឆន្ទំ វិរាជេត្វា ឯវំ ទុក្ខា បមុច្ចតិ ។

(ប្រែថា) កាមគុណទាំង ៥ មានចិត្តជាគំរប់ ៦ អ្នកប្រាជ្ញបានសំ-ដែងហើយក្នុងលោក បុគ្គលលះបង់នូវសេចក្ដីប្រាថ្នា ក្នុងកាមគុណនឹងចិត្តនេះហើយ រមែងរួចចាកទុក្ខបានដោយប្រការដូច្នេះ ។

(នេះជាពុទ្ធភាសិត)

មានទេវតា ១ ចុះមកក្រាបទូលសួរព្រះអង្គថា

កោសំ ទិវា ច រត្តោ ច សទា បុញ្ញំ បវឌ្ឍតិ
ធម្មដ្ឋា សីលសម្បន្នា កេ ជនា សគ្គគាមិនោ ។

(ប្រែថា) បុណ្យតែងចំរើនសព្វ ៗ កាលទាំងយប់ទាំងថ្ងៃ ដល់បុគ្គលណាខ្លះ ជនដែលតាំងនៅក្នុងធម៌បរិបូណ៌ដោយសីល ទៅកាន់ស្ថានសួគ៌បានឬទេ ។

(នេះជាទេវតាភាសិត)

ព្រះអង្គទ្រង់ភាសិតថា

អារាមរោបា វនរោបា យេ ជនា សេតុការកា
បបញ្ច ឧទបានញ្ច យេ ទទន្តិ ឧបស្សយំ
តេសំ ទិវា ច រត្តោ ច សទា បុញ្ញំ បវឌ្ឍតិ
ធម្មដ្ឋា សីលសម្បន្នា តេ ជនា សគ្គគាមិនោ ។

(ប្រែថា) ជនឯណាជាអ្នកដាំច្បារ គឺឈើដែលមានផ្កាផ្លែជាប្រយោជន៍ ជាអ្នកថែទាំដើមឈើដែលដុះឡើងខ្លួនឯងក្នុងព្រៃ ជាអ្នកសាងស្ពាន មួយវិញទៀត ជនឯណា ឲ្យនូវទឹក ឲ្យនូវរោងសម្រាប់ផឹកទឹកមានស្រះទឹងអណ្តូងជាដើម ទឹងទីលំនៅ បុណ្យតែងចំរើនសព្វ ៗ កាលទាំងយប់ទាំងថ្ងៃដល់ជននោះ ៗ ជនដែលតាំងនៅក្នុងធម៌បរិបូណ៌ដោយសីលនោះ រមែងទៅកាន់ស្ថានសួគ៌បាន ។

(នេះជាពុទ្ធភាសិត)

សម័យមួយ ព្រះមហាអានន្ទនិមន្តទៅបិណ្ឌបាតក្នុងនគរសាវត្ថីជាមួយនឹងវង្គីសភិក្ខុ ។ ឯវង្គីសភិក្ខុ ក៏កើតមានសេចក្តីផ្សុកឡើងមានរាគគ្របសង្កត់ចិត្ត ។ វង្គីសភិក្ខុក៏ពោលគាថានេះនឹងព្រះមហាអានន្ទថា

កាមរាគេន ឌយ្ហាមិ ចិត្តំ មេ បរិឌយ្ហតិ
សាធុ និព្វាបនំ ព្រូហិ អនុកម្បាយ គោតម ។

(ប្រែថា) ឥឡូវនេះខ្ញុំក្តៅក្រហាយដោយកាមរាគ ចិត្តរបស់ខ្ញុំ ត្រូវកាមរាគដុតពេលឲ្យក្តៅក្រហាយ បពិត្រអានន្ទជាគោតមគោត្រ សូមលោកប្រាប់ឧបាយជាគ្រឿងរំលត់នូវកាមរាគដោយសេចក្តីអនុគ្រោះ ។

ព្រះមហាអានន្ទពោលទូន្មានថា

សញ្ញាយ វិបរិយេសា ចិត្តន្តេ បរិឌយ្ហតិ
និមិត្តំ បរិវជ្ជេហិ សុភំ រាគូបសញ្ហិតំ
សង្ខារេ បរតោ បស្ស ទុក្ខតោ មា ច អត្តតោ
និព្វាបេហិ មហារាគំ មា ឌយ្ហិត្ថោ បុនប្បុនំ
អសុភាយ ចិត្តំ ភាវេហិ ឯកគ្គំ សុសមាហិតំ
សតិ កាយគតា ត្យត្ថុ និព្វិទាពហុលោ ភវ
អនិមិត្តញ្ច ភាវេហិ មានានុសយមុជ្ជហ
តតោ មានាភិសមយា ឧបសន្តោ ចរិស្សសិ ។

(ប្រែថា) ចិត្តរបស់លោកក្តៅក្រហាយ ព្រោះវិបល្លាសនៃសញ្ញា ចូរលោកលះបង់នូវនិមិត្តជាល្អ ដែលអាស្រ័យនូវរាគ ចូរលោកពិចារណានូវសង្ខារ ដោយថាជារបស់អ្នកដទៃ គឺថាជារបស់មិនទៀង ដោយថាជាទុក្ខ កុំពិចារណាដោយថាជារបស់ខ្លួនឡើយ ចូរលោករំលត់នូវរាគធំចេញ កុំក្តៅក្រហាយញយ ៗ ឡើយ ចូរចំរើនចិត្តដើម្បីអសុភចិត្តនោះក៏មានអារម្មណ៍តែមួយ តាំងនៅខ្ជាប់ខ្ជួនដោយប្រពៃ សតិ

របស់លោកចូរតាំងនៅក្នុងកាយ ចូរលោកធ្វើខ្លួនឲ្យជាបុគ្គលមានសេចក្ដីនឿយណាយច្រើន ចូរចំរើននូវវិបស្សនា ដែលរកនិមិត្តគ្មាន ចូរលះបង់នូវអនុស័យគឺមានះ លោកនឹងបានជាបុគ្គលមានចិត្តស្ងប់រម្ងាប់ ព្រោះបានត្រាស់ដឹងដោយការឃើញ នឹងលះបង់នូវមានះ ក្នុងកាលជាខាងក្រោយមិនខានឡើយ ។

(នេះជាសាវកភាសិត)

ក្នុងកាលដ៏កន្លងទៅហើយ ព្រះបរមពោធិសត្វបួសជាតាបសឥសីនៅក្នុងប្រទេសព្រៃហិមពាន្ត មានកូនប្រុស ១ បួសជាតាបសនៅជាមួយដែរ ៗ តាបសជាកូននោះ មានសេចក្ដីអផ្សុកប្រាថ្នានឹងចេញអំពីព្រៃទៅនៅក្នុងស្រុក ហើយក៏លាពោធិសត្វជាបិតាទៅ ។ ព្រះពោធិសត្វក៏ទូន្មានតាបសជាកូនថា

យស្ស កាយេន វាចាយ មនសា នត្ថិ ទុក្កដំ
ឱរសីវ បតិដ្ឋាយ តំ ភជេយ្យ ឥតោ គតោ ។

(ប្រែថា) បុគ្គលឯណាគ្មានអំពើអាក្រក់ដោយកាយវាចាចិត្ត កូនឯងទៅអំពីព្រៃនេះ ចូរទៅដំកល់ខ្លួនទុកដូចជាកូនកើតចេញអំពីទ្រូង ហើយសេពគប់នឹងបុគ្គលនោះចុះ ។

យោ ច ធម្មេន ចរតិ ចរន្តោបិ ន មញ្ញតិ
វិសុទ្ធការី សប្បញ្ញោ តំ ភជេយ្យ ឥតោ គតោ ។

មួយវិញទៀត បុគ្គលឯណាប្រព្រឹត្តតាមធម៌ កាលដែលប្រព្រឹត្តដូច្នោះ ក៏មិនមើលងាយគេឡើយ កូនឯងទៅអំពីព្រៃនេះទៅ ចូរសេពគប់នឹងបុគ្គលនោះចុះ ព្រោះបុគ្គលនោះ ជាអ្នកធ្វើនូវកុសលកម្មបថដ៏បរិសុទ្ធ ជាអ្នកមានបញ្ញា ។

(នេះជាគិសីកាសិត)

កាសិតទាំង ៤ ដូចបានសំដែងមកដោយសង្ខេបនេះ ជាសាសនាពាក្យប្រដៅ ៗ ដូចបានសំដែងមកនេះ ចាត់ជាព្រហ្មចរិយទី ១០ ហៅថាសាសនព្រហ្មចរិយ ។

ចប់ព្រហ្មចរិយកថា តែប៉ុណ្ណោះ ។

# រឿងព្រេង-គ្រូនិងសិស្ស

និយាយរឿងមួយ មានភិក្ខុសង្ឃ ១ អង្គគង់នៅវត្ត ១ មានកូនសិស្សតែម្នាក់ឈ្មោះអាផ្ញូញ អាផ្ញូញនោះខិលណាស់ គ្រូនោះល្ងង់ឆោតច្រើន ឯឧបាសកឧបាសិកា គ្មានអ្នកណាគប់អានយកចង្ហាន់ស្លាបារីទៅប្រគេនលោកនោះឡើយ ឬនិមន្តមកឆាន់ឯផ្ទះដល់ម្ដងក៏គ្មាន លោកនោះក្រលំបាកពន់ពេក ។

តែលោកនោះមានដំរី ១ លោកពិចារណាថា សព្វថ្ងៃនេះគ្មានឧបាសកគេប្រគេនវត្ថុអ្វីឆាន់សោះ បើដូច្នោះគួរតែអញទិញវត្ថុផ្សេង ៗ យកមកទុកឆាន់កុំឲ្យលំបាក គិតដូច្នោះហើយក៏ប្រាប់កូនសិស្សថា អាផ្ញូញឯងចាប់ដំរីមកហើយឯងទៅផ្សារនឹងអញទិញវត្ថុផ្សេង ៗ យកមកទុកឆាន់ កូនសិស្សក៏ទៅចាប់ដំរីបានមក នោះគ្រូនិងសិស្សក៏ឡើងជិះដំរីបរទៅផ្សារ លុះដល់គ្រូប្រាប់កូនសិស្សថា ឯងទិញវត្ថុអ្វីដែលទុកយូរបានមិនខូច អាផ្ញូញជាកូនសិស្សក៏ទិញអំបិល ១ បុងប្រកការុងស្រេប គ្រូឃើញសួរថា អាឯងហេតុម្ដេចក៏មិនទិញត្រីឆ្អើរត្រីងៀត ក៏ទិញឯអំបិលវិញ កូនសិស្សទូលគ្រូថា អំបិលទុកយូរបានមិនខូច បានជាខ្ញុំព្រះករុណាទិញ គ្រូឆោតល្ងង់ណាស់ក៏ស្ងៀម ។

ទើបគ្រូឡើងបរដំរីត្រឡប់មកវិញ សិស្សរែកអំបិលដើរពីក្រោយ ដល់ពាក់កណ្ដាលផ្លូវគ្រូមើលទៅសិស្សហើយ ឮសូរដងរែកដូចជាស្រួល

ក៏សួរសិស្សថា អាផ្អូញអញមើលទៅអាឯងរែកអំបិលដូចជាស្រួលឬយ៉ាង
ណា សិស្សទូលគ្រូថា ខ្ញុំព្រះករុណារែកនេះស្រួលណាស់ហើយស្រាល
ផង លោកនោះក៏ប្រាប់សិស្សថា ឯងជិះដំរីវិញចុះ អញរែកអំបិលដើរពី
ក្រោយហើយចុះពីលើដំរីមក កូនសិស្សក៏ឡើងជិះដំរី នោះលោកប្រាប់ថា
ឯងបរដំរីទៅចាំអញនៅម្លប់ឈើឯមុខ សិស្សក៏បរដំរីទៅដល់ម្លប់ឈើ
ក៏មិនឈប់ចាំគ្រូបរហូតទៅដល់វត្ត ។

ចំណែកគ្រូ ក៏រែកអំបិលដើរតាមក្រោយដោយធ្ងន់ណាស់ រែក
ហើយឈប់ ៗ ហើយរែកមើលទៅសិស្សមិនឃើញ លោកនោះគិតថា
អញរែកអំបិលនេះមិនរួចទេ ណ្ហើយចុះ អញលាក់ទុកនៅទីនេះសិន ថ្ងៃ
ក្រោយសឹមនាំសិស្សមកយក គិតហើយក៏យកអំបិលទៅលាក់ក្នុងព្រៃ
លោកនោះគិតថា ទីនេះបើប្រសិនណាមានគេដើរមកត្រង់ គង់តែនឹង
ឃើញគេយកអស់មិនខាន គួរតែរកទីឯណាដែលកំបាំងភ្នែកអ្នកទាំងពួង
គិតឃើញតែក្នុងទឹកគេមើលមិនឃើញ ហើយក៏យកអំបិលទាំងពីរការុង
ទៅលាក់ទុកក្នុងទឹករួចដើរទៅ លុះដល់វត្តសួរសិស្សថា ហេតុម្ដេចក៏អា
✓ ឯងមិនចាំអញ សិស្សនោះទូលថា ខ្ញុំព្រះករុណាបរដំរីមកប្រឹងចាំលោក
គ្រូប្រាកដ តែដំរីវាមិនព្រមចាំ អង្វរវាដូចម្ដេចក៏មិនព្រមវាប្រឹងដើរ
ដល់វត្តទើបវាឈប់ នោះសិស្សសួរគ្រូថា អំបិលលោកគ្រូទុកឯណា គ្រូ
ប្រាប់ថា អញលាក់ទុកនៅទីឯណោះអញកាប់ដើមឈូកដោតជាសំគាល់

លុះព្រឹកឡើងនាំកូនសិស្សទៅយកអំបិលវិញ លុះដល់ប្រាប់សិស្សថា អញលាក់ក្នុងទឹកត្រពាំងនេះ សិស្សលាន់មាត់ថា ឱប៉ៃអើយរលាយអស់ហើយ ។ អាផ្ជួញជាសិស្សក៏ចុះទៅយកអំបិលលើកការុងទាំងពីរឡើង រលាយអស់គ្មានសល់ ចំណែកដែលចងមាត់ការុងដាច់អស់ ឃើញឯត្រីកញ្ចុះមួយនៅក្នុងការុងនោះ សិស្សទូលថា លោកគ្រូមានត្រីកញ្ចុះ ១ នៅក្នុងការុងវាស៊ីអំបិលអស់ទៅហើយ ។ យកត្រីនឹងការុងមកប្រគេនគ្រូមើល លោកនោះឃើញត្រីខឹងណាស់ក៏ទះកំផ្លៀងត្រីមុតដៃនឹងធ្នងជាប់ពិសត្រីក៏ចាប់ពើតឈឺពន់ពេកហើយថា ឯងចាប់ត្រីដកធ្នងជាឆាប់ដ្បិតវាឈឺអញណាស់ សិស្សក៏ចាប់ដកទាញស្ទើរតែមិនរួច លុះដករួចឈាមហូរជាខ្លាំង ពិសរឹតតែឈឺខ្លាំងឡើង រួចនាំកូនសិស្សទៅវត្តវិញយកទាំងការុងនឹងត្រីកញ្ចុះទៅផង លុះដល់វត្តប្រាប់សិស្សថា អាផ្ជួញឯងដាំបាយ ១ ឆ្នាំងត្រីកញ្ចុះនេះអាំងឲ្យឆ្អិនជាឆាប់អញនឹងឆាន់ ពិសត្រីរឹតតែចាប់ពើតឈឺមិនបាត់ លោកនោះក៏សិងលក់ទៅ ។

ឯអាផ្ជួញក៏ដាំបាយអាំងត្រីឆ្អិនហើយបរិភោគអស់ ទុកតែបាយមួយពំនូតនឹងឆ្អឹងត្រីក្នុងចានមានគ្របតែគ្របមិនឲ្យជិត លុះលោកគ្រូនោះភ្ញាក់ឡើងប្រាប់សិស្សថា ឯងយកបាយនឹងត្រីមកឆាន់ អាផ្ជួញក៏ធ្វើកិរិយាដូចជាចូលទៅយកមកប្រគេនគ្រូ ក៏ចេញមកវិញទូលថា បាយនឹងត្រីរុយវាស៊ីអស់ទៅហើយ នៅសល់តែបាយមួយពំនូតនឹងឆ្អឹងត្រី លោកនោះក៏

ជឿតែសង្ស័យដោយឆោតល្ងង់ ទើបគ្រូឲ្យរំពាត់ផ្តៅ ១ មកសិស្សថា ឯងវាយរុយកុំឲ្យវានៅលើគុជ អាផ្ញជាសិស្សក៏វាយរុយមិនឈប់ នោះរុយមួយវាទំចុងច្រមុះគ្រូ ៗ ប្រាប់ថា រុយវាទំច្រមុះអញ ឯងវាយឲ្យងាប់ កូនសិស្សក៏វាយតាមពាក្យគ្រូ វាយទៅៗមិនត្រូវរុយត្រូវឯច្រមុះគ្រូបែកឈាមហូរខ្លាយ សិស្សភ័យណាស់រត់ទៅផ្ទះនិយាយប្រាប់អាពុកម្តាយតាមរឿង អាពុកម្តាយប្រាប់កូនឲ្យបកវត្តវិញប្រែកកមិនព្រមមក លោកនោះទៅតាមក៏មិនបានមកដោយខ្លាចគ្រូវាយ ៗ

ថ្ងៃក្រោយគ្រូតាំងពិធីសូត្រមន្តអាគមស្នេហ៍បន្ទន់ចិត្តសិស្សឲ្យមកអា-ផ្ញជាកូនសិស្សបានដឹងថាគ្រូតាំងពិធីមន្តអាគមស្នេហ៍ដូច្នោះហើយក៏បកវត្តវិញ ដើម្បីឲ្យគ្រូជឿថា ស្នេហ៍ពូកែ លុះដល់វត្តដើរលបចូលទៅឃើញគ្រូអង្គុយកំពុងតែសូត្រមន្តអាគមស្នេហ៍ក៏សួរថា លោកគ្រូធ្វើអ្វី គ្រូកុហកប្រាប់ថា អញសូត្រមន្តអាគមបំបាំងខ្លួនពីព្រោះអញទើបតែនឹងរៀនពីគេ ហើយលោកនោះគិតថា ស្នេហ៍អញពូកែមែន បានជាសិស្សអញវាមក លុះព្រឹក ឡើងសិស្សដាំបាយធ្វើម្ហូបស្រេចទូលគ្រូថា បង្ហាន់ឆ្អិនហើយ លោកនោះថា បើដូច្នោះឯងលើកមកអញនឹងឆាន់ អាផ្ញក៏លើកមកប្រគេនធ្វើជាមើលមិនឃើញដាក់ថាសទៅលើក្បាលគ្រូ ៗ ស្រែកថា អាផ្ញហេតុម្តេចក៏ដាក់ថាសលើក្បាលអញ សិស្សទូលថា ខ្ញុំព្រះករុ-ណាមើលមិនឃើញ លោកនោះក៏ងាកចេញ អាផ្ញក៏ដាក់ថាសលើ

ក្បាលគ្រូទៀត លោកនោះថា អាឯងដាក់ថាសលើក្បាលអញទៀត ហើយ សិស្សថា ខ្ញុំព្រះករុណាសុំទោសព្រោះមើលមិនឃើញ លោកនោះគិតក្នុងចិត្តថា អញរៀនស្នេហ៍ៗពូកែប្រាកដ ដល់ឲ្យវាញកុហកថា តាំងពិធីមន្តអាគមបំបាំងខ្លួនវិញក៏ពូកែគេមើលមិនឃើញប្រាកដមែន គួរទន្ទេញឲ្យចាំកុំឲ្យភ្លេច ។

ឯអាផ្ញួញជាសិស្សក៏ប្រគេនចង្ហាន់គ្រូៗឆាន់រួចស្រេចសិស្សលើកមកបរិភោគតាមការ ។

ថ្ងៃក្រោយមានឧបាសកគេនិមន្តលោកទៅឆាន់ឯផ្ទះ នោះអាផ្ញួញទូលថា បើលោកគ្រូនិមន្តទៅឆាន់ឯផ្ទះគេកុំស្លៀកស្បង់ពាក់ចាស់ខ្លួនឥតអំពើ ឃុំតែចីវរបានហើយគេមើលមិនឃើញទេ ដ្បិតលោកគ្រូបេះមន្តអាគមបំបាំងខ្លួនពូកែណាស់ អ្នកណានឹងមើលឃើញ គ្រូក៏ជឿតាមពាក្យកូនសិស្ស ។

លុះព្រឹកឡើងលោកនោះប្រាប់សិស្សថា ឯងតាមអញទៅឆាន់ឯផ្ទះឧបាសករួចឃុំចីវរតែស្បង់មិនស្លៀក ដោយគិតថាចីវរឃុំហើយ ១ មន្តអាគមអញក៏ពូកែណាស់ផង នរណានឹងមើលកេ្តិខ្មាសឃើញ រួចនាំកូនសិស្សទៅ ។

លុះដល់ឧបាសកនិមន្តឡើងទៅលើផ្ទះហើយគេលើកចង្ហាន់មកដើម្បីប្រគេនឆាន់ លោកនោះដោយមិនបានស្លៀកស្បង់អង្គុយមិនស្រួល

ឆាកឆ្វេងឆាកស្តាំក៏មិនស្រួលលេចក្តីខ្មាសនៅកណ្តាលពល ឧបាសកគេឃើញដូច្នោះនាំគ្នាសើចហោហាន់ លោកនោះពុំទាន់បានតាំងបង្អង់មានចិត្តខ្មាសគេណាស់ក៏បុះពីផ្ទះគ្រូឡប់មកដល់វត្តវិញហើយដេរបន្ទោសសិស្សថា អាឯងមិនឲ្យអញស្លៀកស្បង់ឥឡូវអញខ្មាសគេណាស់ អា-ផ្ញើជាសិស្សទូលថា លោកគ្រូកុំខ្វល់នឹងខ្ញុំព្រះករុណា រឿងនេះប្រហែលជាខុសត្រណម គ្រូសួរថា ឯងឃើញអញធ្វើខុសត្រណមដូចម្តេច នោះអាផ្ញើសួរថា កាលលោកគ្រូនិមន្តទៅឆាន់នៅផ្ទះឧបាសកនិមន្តទៅផ្លូវខាងណា គ្រូប្រាប់ថា អញកាលទៅចេញផ្លូវខាងកើត សិស្សថា ឱច្បាស់ជាលោកគ្រូខុសត្រណមមែនហើយ ថ្ងៃមុនលោកគ្រូប្រាប់ខ្ញុំព្រះករុណាថា បើរៀនមន្តអាគមទាំងពួងត្រូវឲ្យតមស៊ីផ្លែស្ពឺ សូម្បីតែមុបក្រោមដើមក៏មិនបានពិសាបមន្តអាគម ឥឡូវលោកគ្រូមុបក្រោមដើមស្ពឺបានជាខុសត្រណមសាបមន្តអាគមអស់ ហេតុនេះបានជាគេឃើញក្តីខ្មាសលោកគ្រូ គ្រូបានស្តាប់ដូច្នោះហើយថា ឱអាផ្ញើរឿងតមនោះអញភ្លេចបានជាយ៉ាងនេះ ឯងថានោះពិតប្រាកដមែន លោកនោះដោយភោតល្ងង់ក៏ជឿជាក់ឥតសង្ស័យ ឯអាផ្ញើជាសិស្សនៅបំរើគ្រូសុខសប្បាយតរៀងទៅ ។

រឿងគ្រូនឹងសិស្ស

ចប់តែប៉ុណ្ណេះ ។

ឧកញ៉ាប្រាជ្ញាធិបតីចាងហ្វាង ( យ៉េង ) តែង

# ពិធីលើកភាសី

# ពិធីលើករាសី

ពេលាដែលរាសីរបស់គេធ្លាក់អាប់ មានតែសេចក្តីមិនស្រួលកើតឡើងញយ ៗ ទឹងធ្វើអ្វីច្រើនតែមិនសម្រេចក្តីប្រាថ្នា ឬកាលទឹងធ្វើការដែលសំខាន់ ៗ នោះចង់ឲ្យសម្រេចទុតឆាប់ទៅជួបបំណងក្តី ឬប្រាថ្នាទឹងឲ្យឡើងយសសក្តិធំជាងប្រក្រតីនោះទៅក្តី ពួកអ្នកដែលជឿក្បួនខ្នាតនេះ គេតែងរៀបចំធ្វើពិធីលើករាសីរបស់ខ្លួន ឲ្យរុងរឿងភ្លឺថ្លាឡើង ៗ ក៏តែការដែលធ្វើដូច្នោះនឹងយកជាពិតប្រាកដណាស់ពុំបាន ជួនកាលក៏ឃើញឲ្យផលមុតមែន ជួនកាលក៏សូន្យឈឹងទៅ តែនិស្ស័យមនុស្សយើងទេតើ កាលមានបំណងដូចម្តេចហើយនឹងធ្វើខ្លួនឯងទៅតែម្តងមិនកើត ក៏គោងការរកនេះរកនោះមកជួយ ក្រែងលោសមប្រកបក៏នាំគ្នាធ្វើត ៗ មកទាល់តែជាប់ជាទំនៀម ត្រង់ពិតឬមិនពិតនោះទុកមួយអន្លើសិន ៗ

ក៏ឯរបៀបធ្វើនោះមានរបៀបផ្សេង ៗ ពីគ្នាតាមគតិរបស់អាចារ្យ អ្នកជាដើមការនាំឲ្យធ្វើ តែក៏មិនខុសឆ្ងាយពីគ្នាប៉ុន្មាន លើសខ្វះគ្នាត្រឹម ១ មុខ ២ មុខ ប៉ុណ្ណោះ កាលនឹងប្រមូលបែបអំបាលនោះមកសំដែងក្នុងទីនេះឲ្យអស់ដើងតែម្តង ក៏ឃើញថា យឺតយូរណាស់ ឬថា ផុតវិស័យនឹងប្រមូលមកក៏បាន ៗ ហេតុនោះ ទើបសូមនាំយកបែប ១ មកសំដែងទុកជាតួយ៉ាងតែល្មមសមគួរ ដូច្នេះ:

ឲ្យធ្វើបាយសីធំ ១ កំពស់ដំហារអ្នកសាម៉ីខ្លួន បាយសីប៉ាក់ឆាម ១ គូ, ស្លាធ័រ ១ គូ, ទឹកអប់ ១ គូ, ទៀន ៥, ធូប ៥, ផ្កា ៥, លាជ ៥, ថ្វាយជាពុទ្ធបូជា ។ ទឹងរៀបគ្រឿងសំណែន នឹងកែកយព្រំក្រៃ ១. កន្ទោង ៥ ដាក់បាយម្ហូបចំណីតាមទំនៀម, ចត្រត្រៃ ៥, ទឹងរូបសួងខ្លួន ១, ដាក់ក្នុងកែពនោះ(១) ទឹងរៀបស្លាធ័រ ៨ ទឹកអប់ឲ្យរៀបដាក់អមខាងខ្លួនអ្នកសាម៉ីម្ខាងបួន ៗ ។

ឲ្យរៀបសែនហើយ និមន្តលោកចំរើនបរិត្តលើកពសីទៅតាមទំនៀម ដែលធ្លាប់ស្រូត្រៀងមក ដូចគ្នានឹងពិធីសូត្រមន្តរំដោះគ្រោះ ៗ

ចប់អស់សេចក្តីតែប៉ុណ្ណេះ ។

---

១ ដូចកាលគេធ្វើពែមឈ្មួស ១ ទៀតដែរ ដូចពោលហើយក្នុងរឿងបណ្តោះគ្រោះ ។

# បញ្ជីរឿង


១ — ដំណឹងផ្សេងៗ . . . . . . . . . . . . . . . . . . . . . . . ៨៧

២ — រឿងគុទ្ធប្រវត្តិរៀបរៀងតាមលំដាប់ ន មោ. ក ១. . . . . . . . . . . ៩៣

៣ — ប្រជុំពាក្យកាព្យ ភាគទី ២ (តទី ៥). . . . . . . . . . . . . . . . ១០៣

៤ — វិយប្បកាសិនី (តនឹងចប់). . . . . . . . . . . . . . . . ១១៩

៥ — កុសលកម្មបថ ១០ (ពាក្យកាព្យ) របស់អាចារ្យ ហ.ឈា . . . . . . ១៣៧

៦ — រឿងព្រេង — បុរសពីរនាក់ . . . . . . . . . . . . . . . . . . . ១៤៧


## រូបក្រៅរឿង


ប្រទេសលាវ - ស្រុកវៀងចន្ទ្រ វត្តអិនប៉ែង រូបហោត្រៃ . . . . . . . . ៨៥

# TABLE DES MATIÈRES


Pages

1. Informations diverses .......... 87

2. La vie du BOUDDHA Poème alphabétique .......... 93

3. Recueil de Poèmes; 2e partie par Préas Bat Samdach Préas SREYTHAMMARÉACHÉA (suite) .......... 103

4. Vayappakâsini par Achar HIM (suite et fin) .......... 119

5. Kusalakaminapatha par Achar H. CHHÉA .......... 137

6. Contes populaires cambodgiens inédits:

L'aventure de deux hommes .......... 147

HORS TEXTE:

LAOS: VIENTIANE, Vat IN-PÊNG, la Bibliothèque .......... 85



ប្រទេសលាវ-ស្រុកវៀងចន្ទ្រ វត្តអិនប៉ែង រូបហោត្រៃ

ដំណឹងផ្សេង ៗ

# អំពីសារប្រយោជន៍នៃសៀវភៅ

នៅឱកាសដែលព្រះរាជានឹងសម្ដេចព្រះរាជជននីនៃប្រទេសអង់គ្លេស ស្ដេចមកប្រពាតមហានគរបារាំងសែស ៗ ក្រុងប៉ារីសបានទទួលព្រះចៅក្រុងអង់គ្លេសដោយគ្រឿងបណ្ណាការសុទ្ធតែមានដំឡៃថ្លៃថ្លា ហើយបានថ្វាយសៀវភៅភាសាបារាំងសែស ដែលមានប្រយោជន៍ជាអនេកដល់ព្រះរាជកុមារីជាព្រះរាជបុត្រី គឺសៀវភៅនិទានមានរូបប្រកប, ពង្សាវតារ, វិទ្យាសាស្ត្រ, មគ្គុទ្ទេស ប៉ារីស (*guides sur Paris*) សៀវភៅរូប, ឃ្លាំងកាព្យជាដើម សុទ្ធសឹងបោះពុម្ពដោយក្រដាសយ៉ាងល្អ ៗ ហើយមានពាក្យឧទ្ទិសរបស់អ្នកតែងអស់នោះគ្រប់រូប ៗ សៀវភៅអស់នេះហើយ ដែលចុះឲ្យឃើញគំនិតនឹងប្រាជ្ញានៃមហានគរបារាំងសែស ៗ ដំណើរនេះសំដែងឲ្យយើងយល់ថា សៀវភៅអស់នោះទុកជារបស់ដែលមានសារប្រយោជន៍ដ៏សំខាន់ ក្នុងជីវិតជនជាតិឱរុបក្នុងសម័យបច្ចុប្បន្ននេះ សៀវភៅអស់នេះទុកស្មើមាសពេជ្រដែលមានដំឡៃ ហើយជារបស់គួរថ្វាយដល់ព្រះរាជកុមារីនៃប្រទេសដ៏សំខាន់បំផុតមួយក្នុងលោកនេះ ៗ

យើងមានសង្ឃឹមទុកថា មិនយូរប៉ុន្មានទេ នៅស្រុកខ្មែរយើងនេះ លោកអ្នកកល់គ្នាគង់នឹងមានសេចក្ដីយល់ច្បាស់អំពីសារប្រយោជន៍ នៃ

សៀវភៅ ដែលជារបស់ជួយបំភ្លឺសតិបញ្ញារបស់ប្រជាជន ក្នុងស្រុកយើងនេះតាមទំនងនោះដែរ ។

## អំពីសភាពរុក្ខជាតិ

មានអ្នកតែងសៀវភៅម្នាក់ឈ្មោះ លោកអេហេរេគូស *(Ehé recusl)* តាំងអំពី ៦០ ឆ្នាំមកហើយ លោកនេះបានស្លាប់ទៅចំនួន ៣០ ឆ្នាំមកហើយ ប៉ុន្តែកេរ្តិ៍ឈ្មោះសៀវភៅលោកមិនទាន់ស្លាប់ទៅផងទេ ដ្បិតសៀវភៅរបស់លោកមានប្រយោជន៍ជាអនេកដល់មកសព្វថ្ងៃនេះ ព្រោះមានសេចក្តីពន្យល់អំពីសេចក្តីពិតដ៏ទៀងទាត់ ។

សៀវភៅនេះមិនបានពន្យល់អំពីពាក្យសាស្រ្តដូចជាឈ្មោះខាងលើនេះទេ គឺជាសៀវភៅនិយាយអំពីចរិយាដ៏ល្អនឹងបរមត្ថវិជ្ជាជាន់ខ្ពស់ ទុកស្មើរុក្ខជាតិដែលលូតលាស់បំរើនឡើងនៅស្រុកបារាំង ។

មានអ្នកប្រាជ្ញធំម្នាក់ទៀតនៅស្រុកបារាំងមានសេចក្តីសរសើរគុណសៀវភៅរបស់លោកអេហេរេគូសណាស់បានបញ្ចេញពាក្យថា "អ្នកដែលមិនបានជួបនឹងលោកអេហេរេគូសនេះ ទុកជាមនុស្សឥតភ័ព្វសំណាងមួយជាតិ" ។

ឯសត្វលោកដែលកើតមកក្នុងលោកមិនទាន់ពុទ្ធកាល ឬទាន់ដំ-បូន្មានព្រះពុទ្ធ ក៏ទុកជាមនុស្សឥតភ័ព្វសំណាង ឃ្លាតចាកប្រយោជន៍

ដែលខ្លួនត្រូវបានទទួលក្នុងបច្ចុប្បន្ននេះដែរ ។ ការប្រៀបធៀបសេចក្ដីបែបនេះ នាំឲ្យយើងឃើញដំឡៃដ៏ធំអស្ចារ្យរបស់លោកអ្នកតែងសៀវភៅនោះ

សេចក្ដីឧបមារបស់អ្នកប្រាជ្ញឧរុបនោះ យើងជាពុទ្ធសាសនិកជនមិនបាច់យល់ស្របតាមយោបល់នេះទេ ដ្បិតយើងយល់ច្បាស់ជឿជាក់ថា ព្រះពុទ្ធជាម្ចាស់នោះព្រះអង្គបរិសុទ្ធស្អាតចាកគ្រឿងសៅហ្មងគ្រប់ប្រការ មានព្រះខន្ធសន្តានស្អាតហ្មត់ចត់មិនប្រឡាក់ដោយកិលេសតណ្ហាទាំងពួងឡើយ ទ្រង់ជាសព្វញ្ញូត្រាស់ដឹងញេយ្យធម៌ទាំងពួងដោយព្រះអង្គឯង មានដំឡៃក្រៃលែងលើសសត្វលោកទាំងត្រៃភព ដោយធម្មចរិយា ដោយបំណេះវិជ្ជា ដោយសេចក្ដីប្រព្រឹត្តបរិសុទ្ធគ្រប់ប្រការ ។

ការដែលអ្នកប្រាជ្ញឧរុបនាំយកលោកអេហោវេគ្រុសមកប្រៀបផ្ទឹមនឹងព្រះពុទ្ធជាម្ចាស់នេះ ដោយគេយល់ថា ព្រះពុទ្ធជាអ្នកប្រាជ្ញមួយ ដូចជាអ្នកប្រាជ្ញស្រុកឧរុបដែរ ឯយើងរាល់គ្នាជាពុទ្ធសាសនិកជនមិនបាច់យល់ស្របតាមយោបល់របស់គេឡើយ យើងមិនបាច់គិតវែងឆ្ងាយទេ តែត្រឹមប៉ុណ្ណេះបានហើយ គឺអនុសាសនីរបស់ព្រះពុទ្ធគង់មកដល់ ២.៥០០ ឆ្នាំហើយ ឯអនុសាសនីរបស់អ្នកប្រាជ្ញនោះទើបមានអាយុបាន ៦០ ឆ្នាំប៉ុណ្ណោះ ។ អនុសាសនីព្រះពុទ្ធផ្សាយចេញទៅស្ទើរពេញលោក មានចំនួនពុទ្ធបរិសទ្យរាប់ដោយកោដិលាន ។ ឯអនុសាសនីអ្នកប្រាជ្ញនោះមិន

ប្រាកដស្តែងក្នុងលោក ដូចជាសាសនាទាំងឡាយទៀយ បើមានដំរៀខុសគ្នាឆ្ងាយដូច្នេះតើគួរនាំមកប្រៀបធៀបគ្នាដែរឬអ្វី ?

# អំពីការសិក្សានៅស្រុកចិន

## ក្នុងខណៈដែលមានចម្បាំង

នៅស្រុកចិននោះ មានខែត្រមួយជាខាងជើងស្រុកឆេនសី ពួកចិនបានសាងសាលាបង្រៀនជាច្រើនសម្រាប់រៀនសូត្រ ហើយពួកសិស្សនៅក្នុងរូងថ្មដែលគេវាត់បែងជីកឡើងដោយខ្លួនឯងនៅក្បែរជើងភ្នំ ៗ

នៅទីនោះមានសាលាបង្រៀនបែបថេនា, សាលាបង្រៀនបទល្ខោន និងមន្ទីរពេទ្យ ៗ ឯចំនួនសិស្សស្រីមានច្រើនជាងសិស្សប្រុស ៗ ហើយពួកស្រី ៗ អស់នេះនៅក្នុងកន្លែងដូចជាក្មេងប្រុស ៗ ដែរ ៗ

មន្ទីរពេទ្យនោះ មានអ្នកជម្ងឺចូលមកដេកថែរក្សាជម្ងឺចំនួន ៥០០ នាក់ រាល់ ៗ ថ្ងៃ ហើយជីករូងថ្មក្នុងភ្នំនៅដូចគ្នាដែរ ៗ

នៅសាលាអស់នោះ ដល់ពេលរៀនគេចេញទៅរៀនកណ្ដាលវាល មានកេងពុម្ពសម្រាប់បោះពុម្ពសៀវភៅឃើញមានតែពួកស្រី ៗ ធ្វើការងារក្នុងកេងពុម្ព ហើយមានកាសែតដែលបោះផ្សាយចេញដោយគ្រឿងរ៉ោដោយដៃផង ៗ

មានពួកចិនដែលមកអំពីទិសខាងត្បូងស្រុកចិន , អំពីទ្វីបអាមេរិក មកនៅក្នុងស្រុកចិនត្រង់បំណែកនោះ មានចំនួនតាំងពាន់ដើម្បីសិក្សារៀនសូត្រទឹងធ្វើការបម្រើប្រទេសរបស់ខ្លួន ។ បានចំនួនសំបុត្រសុំចូលរៀនដល់ទៅ ៥០.០០០ ច្បាប់ កំពុងរង់ចាំសេចក្តីអនុញ្ញាត ដើម្បីឲ្យបានធ្វើជានិស្សិត ( សិស្ស ) ក្នុងមហាវិទ្យាល័យដ៏ចំឡែកនេះ សូម្បីមនុស្សអស់នោះជាមនុស្សសម័យថ្មីមកហើយក៏ដោយ (ប៉ុន្តែការបង្រៀនក្នុងសាលានោះមិនមែនធ្វើឲ្យកាន់តែថ្មីឡើងទៀតទេ ) គឺជាកន្លែងសិក្សាធ្វើឲ្យមនុស្សវិលត្រឡប់ទៅរកសម័យបុរាណវិញ កាលពីសម័យមនុស្សដីករូងថ្មចូលជ្រកអាស្រ័យនៅតាមរអាងភ្នំហ្នឹងឯង ។

( នេះហើយដែលហៅថា សំសារចក្រមានទំនងដូចជាកាំគ្រាបកាំដួងនៃកង់រទេះ កង់របស់សំសារវដ្ត តែងបង្វិលសត្វឲ្យវិលវល់ក្រឡាប់ផ្កាប់ផ្ងារជាធម្មតា នៅក្នុងមហាសមុទ្រពោលគឺសំសារវដ្តៈនេះ ឥតមានអាការទ្រឹងនៅឬឈប់សម្រាកដល់មួយស្របក់សោះឡើយ ) ។

# រឿងពុទ្ធប្រវត្តិ

## រៀបរៀងតាមលំដាប់អក្សរ " ឥតោ, ក១ "

### រតនត្តយប្បណាមគាថា

យុត្តោ ចាគាទិគុណេហិ ពុទ្ធំ លោកស្ស ជាយតំ
សទ្ធម្មញ្ច សុនិម្មលំ សង្ឃតំ នមាមិហំ ។

## បទនមស្សការពាក្យ ៧

នាមខ្ញុំព្រួ "យ" ដាក់ស្រៈ "ុ" ខ្យល់ "ត" នៅមុខតម្រួតពីរ.
ស្រុកស្រែកំណើតកើតនៅទី ចារឹខណ្ឌពួកខេត្តសៀមរាប ។
ឯនាមបិតាអក្សរ "ម" ស្រៈ "អា" ខ្យល់ "ស" ល្អសុភាព
លោកបានដូះយល់ផ្លូវបុណ្យបាប ស្គាល់កិច្ចខ្ពស់ទាបល្អិតសុខុម ។
ខ្ញុំម្ចាស់សូមថ្លែងបែងកាព្យ សំដែងពណ៌នាដោយនិយម.
រឿងពុទ្ធប្រវត្តិល្អិតឧត្តម តែងតាមលំនាំបប់មត្រាស់ ។
ព្រមទាំងរៀបរៀងតួអក្ខរ ទុកជាដើមឃ្លាដើមឃ្លោងល្បះ
តាំងពី "ឥតោ" ដល់ "ភាំអះ" ពណ៌នាត្រូវរៈកាត់ខ្លី ៗ ។
រួចថ្លែង "គា១" ដល់ "ឡអំ" កាលមាតុលបញ្ចាំងព្រះជិនស្រី
ព្រះអង្គទ្រង់ឈ្នះដោយធម៌ ស្តេចមារបរាជ័យចាញ់ចេស្តា ។

ហេតុដល់អគ្គព្រះលោកនាថ ទ្រង់មានអាពាធក្នុងកាយា
ទ្រង់ផ្ទំលើថ្មខែនសិលា ផ្ដាំផ្ញើសាសនានឹងបរិស័ទ្យ ។
មានព្រះអានន្ទជាដើមអារ៍ ឲ្យខំសង្វាតឃ្នាតប្រតិបត្តិ
កុំបីប្រមាទត្រូវប្រយ័ត្ន ព្យាយាមដុសខាត់ប្រាជ្ញាញាណ ។
លុះទ្រង់ត្រាស់ផ្ដាំស្រេចកាលណា ទើបពិចារណានូវអគ្គឈាន
រំលត់សង្ខារឧបាទាន យាងចូលនិព្វានស្ថានសុខា ។

ឆ. នឹកដល់គុណព្រះបរមគត ព្រះអង្គជាម្ចាស់លើសលោកា
ជាទីជ្រកកោនមនុស្សទេវតា តែងពឹងដោយសារបុណ្យបារមី ។
មោ. មានមនោនឹកមមៃ ដល់ព្រះធម៌ថ្លៃព្រះជិនស្រី
ជាទីស្រោចស្រង់ជនប្រុសស្រី ឲ្យផុតភពបីអស់ទុក្ខា
ញុ. សូមពណ៌នាគុណព្រះសង្ឃ លើកករកំបង់នមស្សការ
ចំពោះព្រះសង្ឃទ្រង់សិក្ខា លះកាត់តណ្ហានឹងមានះ ។
ទ្វា. ធៀបដូចគុណឧបជ្ឈាយាចារ្យ ប្រដៅធម៌អាចិការជ្រៅកក់
ប្រាប់កិច្ចខុសត្រូវផ្លូវត្រៃលក្ខណ៍ ខ្ញុំសូមគារវៈដោយចិត្តស្មោះ ។
យ. យោងដល់គុណលោកមាតា ជាគុណអស្ចារ្យប្រសើរខ្ពស់
នឹងគុណបិតាឥតហ្មងមោះ, សង្គ្រោះជាគុណដ៏ឧត្តម ។
សិ. សូមសិរីជ័យតេជះ ដែលខ្ញុំសំពះថ្វាយបង្គំ
សូមកំចាត់បង់សត្រូវធំ អន្តរាយកុំបីកើតមាន ។

ឈ្វំ. ជួនចួនចប់នមស្សការ ប្រាំពីរអក្ខរដើមនិទាន
គេទៅថ្លែងរឿងព្រះទ្រង់ញាណ តាមបែបលំអានពុទ្ធប្រវត្តិ ។

## ថ្លែងរឿងពុទ្ធប្រវត្តិកាលព្រះអង្គចុះចាកភពតុសិត

អ. ថ្លែងកាលអង្គព្រះទ្រង់ជោគ អន្ទោលទៅមកក្នុងលោកា
អញ្ជើញចុះចាកស្ថានតុសិតា ហើយចូលកាន់មហាឧរេត្ន ។
នៃនាងមាយាជាមហេសី សុទ្ធោទនធិបតីបរមក្សត្រិយ៍
ជាស្តេចទ្រង់សោយរាជសម្បត្តិ ក្នុងបុរីរដ្ឋកបិលពស្តុ ។
អា. កាលស្តេចសាបសាងបារមី ប្រសូតចាកផ្ទៃតាមចន្លោះ
បំប្លែកជាងសព្វសត្វទាំងអស់ ហាក់ដូចទ្រង់ចុះចាកសយនា ។
ឥ. ទាំងព្រះឥន្ទឥតអត់បាន ចុះចាកសួគ៌ស្ថានមកមីមា
ព្រមទាំងពពួកទេពកញ្ញា មកជួយរក្សាមហាបុរស ។
ឦ. អង្គព្រះពង្សពោធិសត្វ ទ្រង់សោយសម្បត្តិកបិលពស្តុ
ជាមួយពិម្ពាស្រីល្អស្រស់ ព្រះទ័យស្មើស្មោះឥតទោសា ។
ឧ. ក្សត្រិយ៍ឧត្តមបរមនាថ ជាសក្យជាតិដ៏ថ្លៃថ្លា
ព្រះជន្មបាន ២៩ វស្សា យាងទតព្រឹក្សាឧទ្យានមង្គល ។
ឩ. ទ្រង់ទតឃើញរូបជរា នឹងមនុស្សព្យាធាឈឺទុព្វល
មនុស្សស្លាប់បព្វជិតសក្តិសិទ្ធសល់ ដែលទេពពន្យល់ដល់ក្សត្រា ។

៤. រីងរែងរីតគិតសង្វេគ　　ព្រះច័យបែរបែកបាកកាមា
　　ទឹកភ្នកបង់លះបោលវង្វា　　បេញសាំងបញ្ជាបំពេញព្រឹត្តិ ។

៤. រូបស្រួសកន់បន្ទាន់ណាស់　　យាងចូលហើសកាន់រាំងស្ទុះ
　　ដល់ហើយទ្រង់ផ្ទុំតឹងគិត　　ផាបដល់ជិតអគ្រាត្រស្វាត់ ។

៧. លាន់រាចាហាហៅឆន្ន　　អនាគតក៏ណាំឲ្យឡើងប្ញាត់
　　បង្គាប់ឲ្យរៀបគ្រឿងសេះរ័ត្ន　　ទ្រង់ទឹងលះកាត់បេញបញ្ជា ។

៧. លុះរៀបស្រេចស្តេចឡើងគង់　　សេះស្ទុះបេញស្ទងបាកកាក
　　ពេលនោះដឹងដល់ព្រះឥន្ទ្រា　　ចុះបាកស្ទួតាមកងាប់កែ ។

៩. អស់ពពួកទេពនិកាយ　　នាំគ្នាប្រញាប់ហោះប្រៀប្រៃ
　　ខ្វះកាន់ភ្ញីផ្កាកាន់ទង់ជ័យ　　ជួយហែក្សត្រិយ៍ថ្ងៃមិត្រៀបត្រា ។

៧. ច្រើនតាន់តាប់ពេញអាកាស　　ហោះមិនដែលសពាសរមយា
　　ព្រមទាំងមហាព្រហ្មឈ្មោះឃដិការ　　ក៏កាន់បរិក្ខារចុះមកថ្វាយ ។

៨. លុះដល់ស្ទឹងអនោមា　　មានទឹកកើតថ្លាគួរសប្បាយ
　　ជាទីព្រៃព្រឹក្សាទឹកឆ្ងាយ　　ទើបស្តេចទ្រង់ជាយចុះមកឃ្មី ។

៨. ស្រេចទើបស្តេចត្រាស់ហៅឆន្ន　　ឲ្យនាំមកកាន់កពុំរី
　　ជាមួយកណ្ឌស្សអាជានេយ្យ　　ត៏យកសេចក្តីទូលបិតា ។

៩. ព្រះបរមទ្រង់ព្រះខ័ន　　ប្រតិកាន់ក្បេស្មកាត់ព្រះកេសា
　　លុះកាត់រួចស្រេចហើយគាពពកា　　ហើយទ្រង់បញ្ជូនប្តូរផាស្រមណ៍ ។

អំ. ទ្រង់អំណរត្រេកអរពេក  គន់គេទបពូជិតយ៉ាងរម្យទម
ទើបទ្រង់ឧហាតសង្វាតខំ  ប្រព្រឹត្តយ៉ាងសមទឹងព្រហ្មចារ្យ ។
អាំ. អាចព្យាយាមយ៉ាងតឹងរ៉ឹង  សង្វាតឃ្មាតប្រឹងខំឧស្សាហ៍
ទ្រង់ផ្តើមធ្វើទុក្ករកិរិយា  ប្រាំមួយវស្សាទើបសម្រេច ។
អះ. ត្រាស់ក្រោមម្លប់ពោធិព្រឹក្ស  ស្មារតីទ្រង់ទឹករំពឹងកិច្ច
កប់ខ្យល់ចេញ-ចូលមិនមានដាច់  ទាល់បានសម្រេចពោធិញាណ ។

ថ្លែងរឿងពុទ្ធប្រវត្តិតាមលំដាប់អក្សរ “នមោ” ពីត្រឹមប្រសូតរហូតបានត្រាស់ ។

ចប់តែប៉ុណ្ណោះ

ថ្លែងរឿងពុទ្ធប្រវត្តិពីត្រឹមបានត្រាស់
ដល់ចូលនិព្វានតាមលំដាប់អក្សរ “ក ១”

## វគ្គទី ១

ក. ថ្លែងកាលអង្គព្រះគោតម  ទ្រង់ផ្ចាញ់ស្តេចមារចិត្តសាម៉ាវ
លើកពលយោធាច្រើនសែនលាន  ចិត្តទ្រស្តិ៍ក្លាហានចូលតតាំង ។
១. ខំខ្វល់ខ្វាយប្រញាយញឹក  លាន់ឮសន្ធឹកពន្ធឹកខ្ទាំង
ពលខ្លះកាន់ដាវខ្មៅចិត្តខ្ទាំង  ខ្មីឃ្មាតចូលច្បាំងតាំងប្រឡង ។
គ. ខ្លះគ្រឹកពន្ទឹកពេក  សូរសព្ទសំរែកគ្រឹកកង
ពលខ្លះហោះខ្ទាំងលីដំបង  ស្ទុះចូលប៉ុនប៉ងទឹងពាធា ។

ឃ. ឃើញព្រះអង្គគង់ឯកឯង ឥតមានកោតក្រែងដល់ក្រុងមារ
ទ្រង់អាងបារមី ១០ ប្រការ ជាពលបរិវារជួយជ្រោមជ្រែង ៗ
ង. ងងឹតអន្ធការ កាលពេញមេឃាអ័ព្ទបែកផ្សែង
តែទ្រង់អង់អាចឥតស្ញប់ស្ញែង ស្ដេចមារក៏ក្រែងខ្លាចបារមី ៗ

វគ្គទី ២

ច. កាលចុះចាញ់បុណ្យប្រេស្ដា ក្រួញក្រាបវន្ទាដោយសិរសី
ពលមារក៏បបខ្ញប់ខ្លាចជ័យ ដាក់ទ័ពបរាជ័យរត់ខ្ចាយខ្ចាត់ ៗ
ឆ. តពីនោះព្រះទ្រង់ញាណ ត្រាស់ដឹងនិព្វានស្ថានស្ងប់ស្ងាត់
កិលេសតណ្ហាទ្រង់កាប់កាត់ កំចាយកំចាត់ចាកសន្ដាន ៗ
ជ. ជួយសង្គ្រោះសត្តនិករ ទ្រង់សំដែងធម៌ប្រោសសព្វស្ថាន
ប្រឹតប្រៀនប្រដៅតាមលំអាន ដឹកនាំឲ្យបានស្ថានសុខា ៗ
ឈ. ឈានចាប់ដើមពីសហម្បតី ព្រហ្មាធិបតីលើសលោកា
ចុះមកបង្គំអារាធនា ឲ្យត្រាស់ទេសនាប្រដៅសត្វ ៗ
ញ. ព្រះទ្រង់ញាណមានមេត្តា ទទួលពាក្យមហាព្រហ្មថ្វាត់
រួចទ្រង់យាត្រាត្រេចយាងកាត់ ទៅកាន់ព្រៃស្ងាត់ឈ្មោះមិគទាយ៍ ៗ

វគ្គទី ៣

ដ. ទ្រង់ដាស់តឿនពួកឥសី គឺបញ្ចវគ្គិយ ៥អង្គ
ឲ្យប្រុងចាំស្ដាប់ព្រះធម្ម ទ្រង់និងទេសនាព្រះធម្មចក្រ ៗ

ឋ. គឺព្រះធម៌ជាបឋម ដូចកង់ចក្រធំយ៉ាងឯកអគ្គ
ជាធម៌ប្រព្រឹត្តទៅតាមថ្នាក់ ប្រកាសសច្ចៈ ៤ ប្រការ ។
ឌ. ក្នុងមណ្ឌលសាសនៈវង្ស ជាធម៌ត្រង់ត្រចះថ្លា
ជាទីលះបង់ទូរទុក្ខា ជាផ្លូវយាត្រាទៅនិព្វាន ។
ឍ. ឲ្យវឡ្យនាការបេះដូង ដុសខាត់សំរឹងប្រាជ្ញាញាណ
ដុតបង់កិលេសដោយអគ្គិឈាន ចូលកាន់និព្វានស្ថានស្ងប់ស្ងាត់ ។
ណ. លុះចប់ធម៌ស្រេចកាលណា មនុស្សនឹងទេព្តាច្រើនពេកក្តាត់
បានលុះមគ្គផលដល់អរហត្ត ត្រាស់ដឹងបរមត្ថធម៌ជ្រៅល្អិត ។

## វគ្គទី ៤

ត. តាំងពីនោះព្រះសាស្តា តែងទំទេសនាច្រើនពេកពិត
ប្រើតប្រៀនប្រោសសត្វឲ្យប្រព្រឹត្ត តាមដោយកំរឹតពាក្យបណ្តាំ ។
ថ. ព្រះលោកនាថជាតិសពេជ្ញ បំពេញពុទ្ធកិច្ចគ្រប់ទាំង ៥
ប្រឹងប្រែងប្រោសសត្វអស់ច្រើនឆ្នាំ គ្រប់ ៤៥ ព្រះវស្សា ។
ទ. ទើបទ្រង់យាងកាត់ដំរង់ ទៅកាន់ទីក្រុងកុសិនារា
ទ្រង់ផ្ទុំលើថ្មទែនសិលា នៃមល្លក្សត្រាក្រោមរាំងភ្នំ ។
ធ. ទ្រង់ប្រឈួនធ្ងន់ក្នុងកាយ សាវ័កទាំងឡាយហោមជិតជុំ
សោកាអាល័យព្រះបរម ក្សឹកក្សួលអួលដំក្នុងក ។

ឈ. ព្រះអានន្ទអនុជថ្លៃ សរសើរសំរៃស្រីរៃក្រខ្វាបផ្កា
យំត្អូញរៀបរាប់គុណអស្ចារ្យ ស្ដាយព្រះសាស្ដាជាម្ចាស់ថ្លៃ ។

វគ្គទី ៥

ញ. ព្រោះធ្លាប់បានស្ដាប់ទេសនា នៃព្រះគត់កាល់យប់ថ្ងៃ
តំរូវប្រែប្រាសព្រះបរមត្រៃ ទ្រង់កាត់កាល័យចូលនិព្វាន
ដ. ផុតវិស័យបានគាប់ព្រះអង្គ ព្រោះទ្រង់លះបង់ឧបាទាន
ព្រះទ័យផូរផង់ជូនព្រះញាណ យាងចូលនិព្វានថ្ងៃនេះហើយ ។
ឋ. ព្រះទសពលយល់អានន្ទ យំសោកសូនអន់ឥតមានស្បើយ
ទើបទ្រង់ត្រាស់ថាអានន្ទអើយ ចូរបោះសះស្បើយតាក់ទុក្ខា ។
ឌ. ព្រោះក្នុងភពគ្រប់មនុស្សសត្វ តែងមានវិបត្តិជាធម្មតា
សេចក្ដីព្រាត់ប្រាសសត្វសង្ខារ នេះជាធម្មតាក្នុងលោកិយ ។
ឍ. មានតែស្ថាននិព្វានមួយ ទើបផុតទុក្ខព្រួយបាបអប្រិយ
ចូរបាប្រឹងប្រែងប្រុងស្មារតី តាំងខ្ជាប់កុំបីធ្វេសគំនិត ។

សេសវគ្គ

ណ. ចូរអ្នកយកធម៌ជាយាន ជាគ្រូទ្ធានប្រដៅចិត្ត
តថាគតនេះនិព្វានពិត តាមដោយកំរិតសន្ធាក ។

រ. រីព្រះធម៌ល្អបរិសុទ្ធ ដែលតថាគតបានទេសនា
បានថ្លែងសំដែងច្រើនឧឡារ នេះជាសាស្ដាអ្នកពល់ប្រាណ ។
ល. លុះអំណើះទៅថ្ងៃក្រោយ ចូរអ្នកកុំធ្លោយក្នុងសន្ដាន
នាំគ្នាប្រតិបត្តិតាមលំអាន ធ្វើខ្លួនឲ្យក្សាន្តចាកទុក្ខា ។
វ. ព្រះភគវជាលោកនាថ ទ្រង់ឲ្យគុណគេច្រើនប្រការ
ប្រកាសផ្ដាំផ្ញើព្រះសាសនា ទុកជាសាស្ដាស្នងព្រះអង្គ ។
ស. គ្រាន់សង្គ្រោះដល់មនុស្សសត្វ ជាផ្លូវប្រតិបត្តិដ៏ត្រូវត្រង់
ជាគ្រឿងធ្វើចិត្តឲ្យផូរផង់ ដើម្បីលះបង់ភវតណ្ហា ។
ហ. ព្រះអរហំជាបរមគត ត្រាស់ផ្ដាំសព្វគ្រប់ស្រេចកាលណា
ទើបទ្រង់បញ្ឈប់ព្រះជា ផ្ចង់ព្រះចិន្តាចាកអារម្មណ៍ ។
ឡ. លុះវេលាទៀបនឹងព្រឹក ស្គរសព្ទសន្ធឹកសត្វយាសយំ
នឹងសព្ទទំនួញទួញយោបំ ទូគិមគួរឲ្យព្រឺពេមា ។
អ. ព្រះអរហំតាំងព្រះញាណ បំពោះអង្គឈានបានអប្បនា
រួចចូលនិរោធស្ងប់សង្ខារ យាងចូលកាន់មហានិព្វានហោង ។

ចប់តែប៉ុណ្ណោះ

សរសេរ មាស-យុត្ត

កូនសិស្សសាលាបាលីជាន់ខ្ពស់ថ្នាក់ទី ១

# ប្រជុំពាក្យកាព្យ

## ភាគទី ២

## ជារបស់ផ្សេងវោហារគ្នា

(តទី ៥)

ពាក្យនាំ

ខ្ញុំប្រារព្ធឃើញថាពាក្យកាព្យបុរាណពួកដែលតែងយ៉ាងជា គួរគប្បីរក្សាសំនួនទុក ខ្ញុំមានបំណងនឹងបោះពុម្ពមកជាយូរហើយ ដូចបានពណ៌នាក្នុងពាក្យនាំប្រជុំពាក្យកាព្យភាគទី ១ មករួចហើយ ។

អំពីពាក្យកាព្យរបស់ស្ដេចទាំងប៉ុន្មានព្រះអង្គ សឹងខ្ញុំនាំមកបោះពុម្ពក្នុងទីប្រជុំពាក្យកាព្យទី ២ នេះដោយយល់ឃើញថា ត្រូវទុកសំនួនឲ្យពួកខ្មែរជាន់ក្រោយដឹងថា ស្ដេចខ្មែរ មានស្ដេចដែលចេះតែងរឿងតែងកាព្យនោះខ្លះដែរ មិនមែនដូចពាក្យមនុស្សខ្លះនិយាយថា ស្ដេចខ្មែរ មិនដែលតែងរឿងអ្វីសោះ ថាស្ដេចខ្មែររើសយកតែរបស់ក្រស្ដ ថាមកជារបស់ខ្លួនធ្វើ ។

អំពីក្សត្រិយ៍ខ្មែរបុរាណជាមានព្រះប្រីជាដូចម្ដេចខ្លះ ខ្ញុំមិនហ៊ានអាងអួតជាប្រាកដ តែជាន់ក្រោយត្រឹមព្រះបរមរាជាព្រះជៃយចេស្ដា មកដល់កាលឥឡូវនេះខ្ញុំដឹងច្បាស់ថា ព្រះជៃយចេស្ដាទ្រង់តែងច្បាប់សំរាប់ព្រះនគរដូចមានព្រះកេរ្តិ៍ទុកដល់សព្វថ្ងៃនេះ ។

ព្រះបាទសម្ដេចព្រះស្រីធម្មរាជាព្រះរាជសម្ភារ, (ចៅពញាតូ) ជាស្ដេចប្រាជ្ញខាងសាស្ត្របាឡី-កាព្យឃ្លោង ។

ព្រះបាទសម្ដេចព្រះនារាយណ៍រាជា (ព្រះអង្គតន់) ក៏ជាប្រាជ្ញខាងពាក្យកាព្យឃ្លោង ខ្ញុំរាជការប្រុសស្រីក៏ចេះកាព្យឃ្លោងជាច្រើន ។

ព្រះបាទសម្ដេចព្រះហរិរក្សរាមាក៏ជាស្ដេចប្រាជ្ញខាងតែងរឿងដូចមានរឿងទុកមកដល់កាលឥឡូវនេះ ។

ពួកព្រះរាជបុត្រព្រះបាទសម្ដេចព្រះនរោត្តម ក៏មានស្ដេចចេះតែងពាក្យកាព្យជាច្រើន, ស្ដេចព្រះរាជបុត្រជាន់តូច ៗ មានព្រះអង្គកេតសោភ (កេសរា) ១ ព្រះអង្គក្រៃសរស្រីវង្ស ១ ជាស្ដេចប្រាជ្ញខាងតែងកាព្យ ។

១ ឱសំឡាញ់អញព្រួកដេកមិនលក់
សែនជាទុក្ខមុខជាទៀបហៀបមរណា
ព្រាំព្រួកទឹកលេងហូរនេត្រា
សូមទេពជួយជីវិតគិតប្រណី ។
ធ្វើម្ដេចគេលួចបានប្រាណថ្លៃរមិត្រ
មាសមកផ្ដិតម៉ែត្រមកផ្ដួលមូលមេត្រី
ពោះគេកាប់ស្ទាប់បង់ទៅសូវបានស្រី
ប្ដូរជីវិតផ្ដាច់ជីក៏មិនស្ដាយឡើយ ។

ព្រះរាជនិពន្ធ ព្រះករុណាព្រះបាទសម្ដេចព្រះហរិរក្សរាមាព្រះអង្គ (ដួង) ជាសេចក្ដីយ៉ាវ៉ែ ឲ្យទៅនាងកេនឡុង ។

៙ សាពទុសារផ្ដាអ្នក
ពេញស្ម័គ្រស្មោះស្មើត្រ្យយទ័យា
ដូចដួងនៃនេត្រទាំងទ្វហ:
វនិតាកុំរេកសន្ធិះគិត
អាសូរកុំឲ្យរៀមវិយោគ
សែនសោយសោករកគូមិត្រ
ផ្ដុំក្រៀមត្រៀមអង្គផ្សិតវរមិត្រ
មិនជិតដួបចូលមូលទ័យា

៙ សែនស្ដាយកាយកាលឃើញធោមយន៍
មិនគួរលះបង់ឲ្យឯកា
ទ្រូងទ្រាំផ្សាជាំពល់វេលា
គ្មានស្រាន្តចិន្តាមួម៉ងសៅ

៙ ពីកាលដែលប្អូនចូលទៅបាត់
សែនស្វាត់ស្រមៃហាក់ថ្ងៃហៅ
បែរកក្រមើលផុតមិនឃើញពៅ
ឱរះក្ដៅឥតក្ដួលរំដួលអង្គ ៗ

៙ នានាគេដឹងអស់សាយសព្វ
អារម្មណ៍ថ្មីគ្រប់ណាធោមយន៍

អញ្ជើញអណ្ដូជាកុំរង់
មកគន់ខាងបងសោះអាល័យ ៗ
◎ បើអ្នកមិនប្រោសព្រមប្រតិព័ទ្ធ
ពោលសត្វឲ្យលង់នគាល័យ
រៀមរ៉ែកសូមស្លាប់ទឹងអ្នកថ្លៃ
មិនប្រែដោះដៃកុំសង្កា ៗ
◎ ពាក្យដែលប្រាយប្រាប់ស្រីវល័ក្សណ៍
ដៀងជាក់ពិតពុំមានមុសា
ថាអ៊ីខន្តីដូចវាចា
កន្សាអាណិតចិត្តខ្វះអើយ ៗ
◎ កាខ្លង់ជាបងអ្នកជ្រើមក
ចូរគិតគិរះកេកុំស្ងៀមនៅ
អាសូរដេដ្ឋាដែលម៉ង់សៅ
កុំពៅជាម្ដេចណាថ្លៃអើយ ៗ

ព្រះអង្គម្ចាស់យុគន្ធរ

◎ អនិច្ចាចិត្តអើយសែនចំបែង
ថ្វាថ្លែងក្រាបទូលព្រះនោមស្នួទ្ធ
គ្រានេះប្រថុយជន្មជីវិត

មិនគិតក្រែងមនុស្សគេនិន្ទា ។
៙ បើមិនយល់ជាព្រះទ័យស្នេហ៍
ប្អូនមិនគិតគ្នេរជ្រើកាយោ
ព្រោះជឿហរិវង្សទ្រង់មេត្តា
បានជាកនិដ្ឋាប្រថុយប្រាណ ។
៙ បើទ្រង់បានជ្រាបសព្វអក្សរ
សូមលាយព្រះករតបប្រទាន
ឲ្យបានអណុដដង់ដើមដាន
ដោយពិតពណ៌ដ៏មានពីព្រះទ័យ ។

ស្ដេចក្សត្រី ល. អ. ៩.

៙ នេះសារពសូរវង្សពង្សត្រៃប័ក្រ
ទ្រង់បានស្ដាប់សព្វពចាស្រីណុគ្គលក្សណ៍
គិតព្យួកទឹករលែកហេតុស្នោះស្នែ
ទុកអាក់ក្រក្ដួលអួលទ័យា ។
៙ សែនមនោចោមេញពេញចាំងប្រាណ
ព្រោះយោវមាណនៅរង្វៀសក្ដិកន្ធា
ហាក់ដូចរៀមគ្មានសុចរិតពិតសត្យា
ទុកាលណាទើបឃើញត្រង់ដូចអង្គបង ។

៙ គិតសព្វថ្ងៃក្រវែងគិតរឿងមិត្រមូល
បុណ្យមិនបានជួបជិតចូលមូលដូចប៉ង
គ្រានេះប្អូនអ្នកត្រិះរិះការមើលលង
ដ្បិតបំណងទាន់គ្រាក្រក្រំចរពៅ
៙ កុំសង្ស័យថ្ងៃទិម្មុលមង្គលសក៏ត
រៀមមិនឃ្លាតឃ្លាមេត្រីស្រីឆោមឆ្ងៅ
លុះគ្រាក្ស័យប្រល័យជីពទើបចាកទៅ
កុំសោកសៅក្ដៅចរពណា ណុជអើយ ។

ព្រះអង្គម្ចាស់ក្សត្រា យុគន្ធរ
តបព្រះអង្គម្ចាស់ក្សត្រី ល. អ. ន.

ពាក្យកាព្យនេះមើលចាំមាត់មកជាអន្លែងឆ្នាំហើយ នាំយកមកបោះពុម្ព ដើម្បីរក្សាសំនួនទុក ។

ព្រះអង្គណាជាម្ចាស់របស់ ឃើញថាមានសេចក្ដីលើសលស់ខុសដូចម្ដេច សូមអភ័យដល់ខ្ញុំផងចុះ ។

៙ គឺអំបើតកើតអំពីផលរើត
បៀតតែក្ដិតដ្បិតតែខ្លួនប្រកួនមាណ់
មិនជាតខ្វង់មិនបង់ឃ្លាតពីចរពន
ស្នូត៏ប្រាកានស្នានប្រកបតែប្របអឹង ។

៙ ពេកទន់លន់នេត្រឆ្មាសង្កែន
សុតស្រវៃនសែនស្រយាកតាកលំបឹង
លំបិតពាកលំបាកចាំតាំតែតឹង
ខេចដូចម្ដឹងខឹងដូចម្ដាមិនបាថាន ៗ

ព្រះអង្គម្ចាស់ក្រៃសរស្សូវង្ស

៙ លុះបានឃើញលាយក់ទអូនដល់
បងអរសែនសល់គ្នានអ៊ូស្ទើ
ទទួលមើលសត្វគ្រប់ដំណើរ
ជាអូនកែរជ្រើជីវិតផង ៗ

៙ ព្រលឹងអើយសូមត្រួយកុំព្រួយចិត្ត
រៀមនឹងស្នេហ៍ស្និទ្ធពិតជាម្ដង
នឹងថ្នមឲ្យផុតស្ត្រីផង
ទួនល្អងជាឯកប្រយូរវង្ស ៗ

៙ បើប្អូនមេត្តាឱកពិត
ជីវិតសូមជ្រើលើធោមយង់
ខុសគាប់ម្ដេចម្ដាចូរកិសរង់
មេត្តាឲ្យគង់ជាមេត្រី ៗ

រ. ណ. រ.

៙ អង្គអញជាតិជាក់ជាត្រកូល
កំពស់កំពូលកម្ពុជា
បុត្រព្រះហរិរក្សរាជពាមា
ស្តេចជាឥស្សរអស់ក្រស្តផង ៗ
៙ ព្រះរៀមនៃអញព្រះបមកព
ស្តេចគ្រប់គ្រងក្រុងឡើងជាថ្មី
នាមនរោត្តមបក្រី
ស្តេចនាំសារស្រីទឹងសេនា ៗ
មកគង់នៅកាំងចតុមុខ
ភូមិស្រុកក្តំពេញរដ្ឋសីមា
ជាសុខនិរភ័យឥតទុក្ខា
ដោយតេជក្សត្រាទ្រើសទ្រង់បុទ្ធី ។

ពាក្យកាព្យបទនេះ ព្រះអង្គម្ចាស់ច័ន្ទវង្សទ្រង់ព្រះនិពន្ធជាពាក្យនាំក្នុងរឿងផុតពនចាំបានតែប៉ុណ្ណេះ ៗ

សិននាំយកមកបោះពុម្ព ដើម្បីរក្សាសំនួនទុក ៗ

ម៉ោងប្រាំបួនជួនព្រឹកទៅដល់
នសមមិត្រស្និតនៅស្ថានបានសុខស្កល់
ប្អុំពល់ខ្វល់អំពីនិពសគ្គា

បុប្ផាលក់ស្កលីទៅហើយស្បើយចិត្តទឹក ។

៙ វើរពូកទឹកលែកខ្ញុំបេក្ខា

គិតសង្ស័យម៉ែថាខ្ញុំពុំមេត្តា

ចិត្តអាល័យរែងមៃមមាញឹក

គិតរពូកទឹកមិនភ្លេចរាល់វេលា ។

ពាក្យកាព្យបទនេះជាបានការរបស់

ឧកញ៉ាសុន្ទរាភិហារ (ម៉ុក)

៙ ក្ដីសារថាព្រះចមម្កុដភព

ព្រះនាមទេព្វរតនប្រក់តសរ

សូមចងមេត្រីស្រីបវរ

បើមេត្តាបងអរដល់អស់ជន្ម ។

៙ សព្វថ្ងៃចក្រពង្សបំរុងលោក

សែនវិយោគសោយសោកទុក្ខពេកពន់

តាំងតែពីស្នេហ៍ដួងសៅរគន្ធ

មិនដែលហៅអន់ចិត្តត្រង់ណា ។

៙ បើមិនដឹងការថ្នបថ្ងៃនេះ

សមឥភាប្រេះព្រោះកន្យា

មរណំភ្លេចទាំងធ្វើភជការ

ក្រស្តពីនរណា ៗ តែខ្ញុំ ៗ

៙ ព្រះអណុផលុយុនមេសាលា

ទ្រង់តែងសោកតាមព្រះទ័យ

សូមជួមយូអែវកែប្រែពៃ

អាណិតក្រតៃប៉ូណាថ្មីមអើយ ៗ៖៚—

ព្រះអង្គម្ចាស់នពរ័ត្ន

ក្នុងពាក្យកាព្យនេះតាំងអង្គជាចមមកុដកពហើយថាជាបំរុងលោក ៗ ពាក្យនេះមើលចាំមាត់មកយូរអង្វែងឆ្នាំមកហើយ បើអ្នកឯណាមើលឃើញនឹងថាឃ្លាតខុសពីពាក្យដើម សុំអភ័យដល់ខ្ញុំផង សុំកុំឲ្យត្រះតិះដៀលឡើយ ៗ

៙ សាកសារៀមសូមសួរចិត្ត

ឲ្យអ្នកអាណិតពីចិន្តា

និយាយផ្ដផ្ដាច់សំរេចការ

ជានឹងស្នេហារៀមឬទេ ៗ

៙ ប្អូនមួយសូមចិត្តជៀតបងក្រ

រូបមិនសូវល្អដូចអស់គេ

បានជាមាសមិត្រម៉ិនស្និទ្ធស្នេហ៍

ច្រាប់បងឲ្យថៃសោះថប់ពេក ៗ

៙ រៀមរកតាំងចិត្តមិត្រមេត្រី
ព្រោះតែអ្នកថ្លៃទ្រូងស្ទើរបែក
អាល័យរឭកនឹកពន់ពេក
រលង់ទឹកភ្នែកកល់កត្រី ។

៙ ទ្រូងជាំក្រំចិត្តបែកពីរបី
ដោយចិត្តស្រឡាញ់ជាប់និស្ស័យ
បងទ្រាំព្រួយចិត្តមកយូរថ្ងៃ
ចាំស្តាប់សេចក្តីវិល័យល័ក្ខណ៍ ។

## មិនស្គាល់ឈ្មោះ

៙ ទឹងថ្ងៃងរិតក្តុកក្នុងប្រាណា
ទូរសេឆ្ងាយស្ពានឲ្យតែព្រួយ
សព្វថ្ងៃពុំវៃទឹងថ្ងៃមួយ
សែនព្រួយទ្រូងទ្រាំក្រំស្ទើរបែក ។

៙ ពេលដើរក៏ដើរទាំងវេទនា
ពេលទឹងនិទ្រាគិតវិវេក
ពេលសោកទ្រាំស៊ីទាំងទឹកភ្នែក
ពេលត្រេកសើចលេងទាំងខ្លោចផ្សា ។

៙ ប្រះខ្លួនដេកទៅនៅផ្ទឹង

រំពៃរំពឹងលើស័យនា
ក្រំក្រៀមឈឹងស្ងៀមពុំបរបា
ទុក្ខអើយឧបមាប្រៀបពុំបាន ។
◎ វៀវតែដេកលក់បាត់ស្មារតី
ភ្លេចថ្ងៃដោយសារបាត់វិញ្ញាណ
បើដឹងស្មារតីឡើងថ្មារម៉ាណា
រំខានទឹកថ្ងៃទាំងប្មារណោះ ។

ឆាយ១ទឹមក្រុមហាត់ឡើក

◎ នុសែនស្រណោះចម្ប៉ាខែក
ក្លិនជាប់ចម្លែកជាងអស់ផ្កា
ប្រសិនបានមកសៀតកាលណា
សមក្លិនចម្ប៉ាបូលជាប់ប្រាណ ។
◎ កម្ពុអើយដើមផ្កាក៏ឆ្ងាយយេសល់
ទស្សនាមិនយល់ពេញរំខាន
ធ្វើម្ដេចទើបទៅជួបផ្កាបាន
ផ្កានៅក្នុងស្ថានគេគេហ្ស ។
◎ ខ្វល់អើយសែនខ្វល់អំពាលគិត
ព្រោះបាននៃបជិតដួងបុប្ផា

ទ្រូងក្រំផ្សាជាំរាល់វេលា
ក្នុងទ្រូងអួលផ្សាមិនមានក្សាន្ត ៗ
៙ ប្រសិនផ្កានេះជាកុសល
នៅក្នុងមណ្ឌលឆ្ងាយប៉ុន្មាន
សូមទេពអមរិន្ទ្រឥន្ទ្រសួគ៌ស្ថាន
ជួយខ្ញុំឲ្យបានផ្កាសៀតអើយ ៗ

មិនស្គាល់ឈ្មោះ

# វយប្បការសិដី

# របស់អាចារ្យ ហ៊ឹម

( តចប់ )

## ៤៦ សង្វេគ

សង្វេគ មានសង្វេគវេទនាក្នុងកងសង្ខារឲ្យឃើញច្បាស់ថា សង្ខារប្រកបដោយត្រៃលក្ខណ៍ដូចបានពណ៌នារួចមកហើយ គប្បីរំពឹគនូវវ័យឲ្យឃើញប្រាកដថា វ័យរបស់យើងអស់២ទៅហើយនៅតែ១ទេ ១នេះសោតដឹងជាស្មើដោយភាគដើមឬមិនស្មើ ព្រោះធ្លាប់ឃើញបុគ្គលដទៃដែលមានដំណើរដើរទៅមុនៗ នោះខ្លះទៅក្នុងបឋមវ័យ ខ្លះទៅក្នុងមជ្ឈិម-វ័យ ខ្លះចូលក្នុងបច្ឆិមវ័យដែរ ប៉ុន្តែគ្រាន់តែចូលមិនគ្រប់ភាគដើមក៏មានច្រើនណាស់ បុគ្គលដែលដល់កំណត់អាយុក្ស័យឬលើសបន្តិចបន្តួចនោះមានតិចណាស់ បុគ្គលដទៃក៏ដូចខ្លួនយើងៗក៏ដូចបុគ្គលដទៃដែរ មិនគន្លងឡើយ ឥឡូវនេះខ្លួនយើងនៅក្នុងវ័យខាងចុងបំផុតហើយ បើធៀបនឹងដំណើរព្រះអាទិត្យថា រសៀលទាបប្រប្រះព្រៀបនឹងអស្តង្គតលិចហើយ ពុំនោះសោតខ្លួនយើងជាអ្នកអង្គុយបេប្រហោងក្បែរប្រឆាំងមាត់នៃមច្ចុរាជ ឬដូចសត្វកង្កែបប្រហោងនៅទៀបមាត់ច្រាំង ងាយណាស់នឹងលោតចុះទៅក្នុងទឹក នឹងប្រហែសធ្វេសមិនបានឡើយ ។

## ៤៧ តេ សុចរិតា

តេ សុចរិតា សេចក្តីប្រព្រឹត្តសុចរិត ៣ ប្រការនោះគឺ កាយសុចរិតមានប្រភេទ ៣ វចីសុចរិតមានប្រភេទ ៤ មនោសុចរិតមានប្រភេទ ៣

ដែលជា សុចរិត ៣ ប្រការដូច្នេះ តែបើរួបរួមទៅជាសុចរិត ១០ ប្រការឬ កុសលកម្មបថ ១០ នោះដដែល កុសលកម្មបថមិនបាច់ដំណាលទៀតទេ ព្រោះបានសំដែងក្នុងទេព្យប្រសើរឯនោះរួចហើយ ខ្លួនយើងចាសហើយ ប្រឹងប្រយ័ត្នកុំឲ្យមានអំពើទុច្ចរិតឲ្យសោះ ខ្វល់ខ្វាយតែក្នុងអំពើសុចរិតឲ្យ បានល្អគ្រប់ផ្លូវកុំបីធ្វេសប្រហែសឡើយ ។

## ៤៨ សង្វេគកថា

សរីរកាយរបស់យើងនេះប្រជុំព្រមដោយអាការ ៣២ ប្រការ ពេញពាសដោយសាកអសុភ មិនមែនជាទេវតានិម្មិត មិនមែនជាព្រហ្មនិម្មិត មិនមែនហើយដោយមាស មិនមែនហើយដោយកែវ · មិនមែនហើយដោយខ្លឹមចន្ទន៍ក្រហម មិនមែនកើតក្នុងផ្ទៃនៃផ្កាឈូកសឈូកក្រហមនឹងផ្កាព្រលឹតទាំងឡាយ ពោរពេញទៅដោយមូត្រលាមកស្មោកគ្រោក អាក្រក់មិនមែនជាទឹកអម្រឹត ម្យ៉ាងទៀត កំណើតដែលកើតអាស្រ័យមាតាបិតាជាកំណើតកើតក្នុងអសុភ មានកិរិយាប្រែប្រួលលុបលាងគក់ច្របាច់បែកធ្លាយនឹងខ្ចាត់ខ្ចាយជាធម្មតា ចំរើនដ័យដំទះកើតឡើងពីតណ្ហា មានសេចក្ដីសោកខ្សឹកខ្សួលជាវត្ថុ ជាលំនៅនៃរោគទាំងពួង ជាទីនៅរបស់ត្រកូលនៃសត្វដង្កូវទាំងឡាយ កាន់យកនូវកម្មករណ៍ជាប្រក្រតី ខាងក្នុងស្អុយតែងហូរចេញមកខាងក្រៅជានិច្ច សរីរកាយនេះមានប្រក្រតីបម្រះទ-

ទៀត ក្នុងគន្លងចក្រនៃសត្វលោក ប្រព្រឹត្តទៅកាន់ទីបំផុតគឺសេចក្តីស្លាប់ ជាទីបំផុត សរីរកាយនេះប្រកបដោយឆ្អឹងសរសៃ ប៉ុកប៉ាន់ទៅដោយសាច់ ហើយទឹងស្បែកគ្របដណ្តប់ ខាងក្នុងពេញទៅដោយពោះវៀនតូចពោះវៀនធំ ថ្លើមសួតបេះដូងក្រពះប្លោកនោមទឹកសម្បារទឹកញើសទឹកប្រមាត់ខ្លាញ់ពរជាដើម សរីរកាយនេះមានគ្រឿងអសោចិ៍ស្អុយឆ្អេះឆ្អាបអាក្រក់ វត្ថុទាំងនេះប្រសិនបើបារគកាយយកចេញមកខាងក្រៅដាក់ដោយដុំ ៗ ក្រែងតែកាន់ដំបងព្រនង់ដេញបក្សីក្អែកទីងត្មាតទើបបាន បើដល់អស់អាយុទៅដួលដេកស្តូកស្តឹងលើផែនដី តែហួសខួបទៅហើយ ហើមប៉ោងឡើងមានពណ៌ខៀវអេស្មុកអសោចិ៍តែងហូរចេញតាមទ្វារទាំង៩ ញាតិសាច់សាលោហិតរមែង យកទៅបោះបង់ចោលក្នុងព្រៃស្មសាន ឥតមានអាឡោះអាល័យឡើយ មនុស្សពាលដែលត្រេកត្រអាលចំពោះសរីរកាយនេះ ដល់កៀកឧបចើបប្រឡែងក៏ព្រោះតណ្ហា គឺសេចក្តីបំណង់ដែលកើតអំពីកាយគន ១២ នោះឯង សរីរកាយនេះលុះតែព្រះពុទ្ធឬសាវករបស់ព្រះពុទ្ធទើបបានដឹងច្បាស់ថា ជាគ្រឿងស្មោកគ្រោកស្អុយអាក្រក់តែប្រយោជន៍មិនគប្បីត្រេកត្រអាល គប្បីតែខ្ពើមរអើមធុញទ្រាន់សង្វេគនឿយណាយក្នុងសរីរកាយនេះជានិច្ចកាលទៅ ។

# ៤៩ សុភាសិតសុត្ត

កាលបើលោកសន្និវាស គឺភ្លើងមានរាគជាដើម ឆេះរុងរឿងអស់កាលជានិច្ចហើយ តើនឹងសើចដូចម្ដេចបាន នឹងត្រេកអរដូចម្ដេចបាន (អ្នក) នាងទាំងឡាយគឺងងឹតគ្របសង្កត់ហើយ ម្ដេចឡើយក៏មិនស្វែងរកប្រទីបជាគ្រឿងបំភ្លឺ ។

សេចក្ដីឋិតយូរ (ក្ដី) សេចក្ដីមាំមួន (ក្ដី) តែងមិនមានដល់អត្តភាពណា អ្នក (នាង) ចូរមើលចុះ អត្តភាពនោះមានវិចិត្រគឺកម្មធ្វើហើយ ជាកាយពាសពេញទៅដោយដំបៅ ដែលឆ្អឹងបីរយកំណាត់សង់ចូលគ្នាឡើង ហើយជាកាយក្ដៅក្រហាយគឺឈឺជានិច្ច ដែលជនច្រើនគ្នាប្រាថ្នាហើយ ។

រូបនេះគ្រាំគ្រាអស់ហើយ ជាទីសំណាក់នៃរោគ (ទាំងពួង) ជារបស់ពុកផុយរលួយ ពន្លឹកកាយនៃខ្លួនជារបស់ស្អុយ តែងបែកធ្លាយទៅ (ជាធម្មតា) ព្រោះថាជីវិតរបស់សត្វ មានសេចក្ដីស្លាប់ជាទីបំផុត ។

ឆ្អឹងទាំងឡាយឯណា មានសម្បុរដូចសម្បុរនៃសត្វព្រាប ដូចផ្លែឃ្លោកដែលគេចោលហើយក្នុងរដូវសរទកាល សេចក្ដីត្រេកអរដូចម្ដេចបាន ព្រោះតែឃើញនូវឆ្អឹងទាំងឡាយនោះ ។

សេចក្ដីគ្រាំគ្រាក្ដី សេចក្ដីស្លាប់ក្ដី សេចក្ដីប្រកាន់ខ្លួនក្ដី សេចក្ដីលុបគុណក្ដី ប្រជុំចុះហើយក្នុងសរីរណា សរីរនោះគឺកុសលាកុសល-

កម្មធ្វើហើយឲ្យទៅជានគររបស់ឆ្អឹងទាំងឡាយ ដ៏បូកបាច់ហើយដោយសាច់និងឈាម ។

រាជរថទាំងឡាយ ដែលជាងធ្វើវិចិត្រហើយដោយល្អស្អាត គង់តែចាស់គ្រាំគ្រាទៅបានពិត មិនត្រឹមតែរាជរថប៉ុណ្ណោះ សូម្បីសរីរក៏គង់ចូលទៅជិតដល់នូវសេចក្តីគ្រាំគ្រាដូចគ្នា មានតែធម៌របស់សប្បុរសទាំងឡាយ ទើបមិនចូលទៅជិតដល់នូវសេចក្តីគ្រាំគ្រាបាន ឯលោកសប្បុរសទាំងឡាយ តែងពោលនូវពាក្យដោយសប្បុរសទាំងឡាយតែប៉ុណ្ណោះ ។

ជនពាលទាំងឡាយ មិនប្រព្រឹត្តនូវព្រហ្មចរិយធម៌ មិនបានទ្រព្យធនក្នុងកាលនៃខ្លួននៅក្មេង តែងជ្រប់នៅដូចសត្វក្រៀលចាស់ទាំងឡាយ កាលជ្រប់នៅលើភក់ដែលមានត្រីអស់ហើយ ។

ជនពាលទាំងឡាយ មិនប្រព្រឹត្តនូវព្រហ្មចរិយធម៌ មិនបានទ្រព្យធនក្នុងកាលនៃខ្លួននៅក្មេង កាលសោកស្តាយអំពើដែលខ្លួនធ្វើអំពីមុនទាំងឡាយ រមែងដេកនៅដូចកូនសរទាំងឡាយ ដែលអស់ស្រឡះហើយចាកបន្ទោះ ។

ឥឡូវនេះខ្លួនអ្នកដូចស្លឹកឈើទុំហើយ មួយទៀត ឯបុរសរបស់យមរាជទាំងឡាយ មានប្រាកដដល់អ្នកហើយ ខ្លួនអ្នកតាំងនៅហើយក្នុងប្រធាននៃសេចក្តីស្លាប់សាបសូន្យ សូម្បីស្បៀងអាហារគឺកុសលសោត ក៏មិនមានដល់អ្នកឡើយ ។

អ្នកឯងចូរធ្វើកិច្ចរបស់ខ្លួន ចូរធ្វើព្យាយាមឲ្យឆាប់ ចូរធ្វើជាអ្នកប្រាជ្ញទៅ បើអ្នកធ្វើយ៉ាងនេះហើយ អ្នកនឹងកំចាត់បង់មន្ទិលបាន មិនមានទីវណ្ណៈ ពោលគឺកិលេសហើយ គង់នឹងដល់នូវទីជាអរិយបុគ្គលដ៏ជាទិព្វមិនខានឡើយ ។

បុគ្គលពិចារណាឃើញច្បាស់ដោយបញ្ញាថា សង្ខារទាំងឡាយទាំងពួងមិនទៀងដូច្នេះក្នុងកាលណាហើយ គង់នឿយណាយចំពោះសេចក្ដីទុក្ខ ក្នុងកាលណោះមិនខាន នេះជាផ្លូវប្រព្រឹត្តទៅដើម្បីសេចក្ដីហ្មត់ចត់ ។

បុគ្គលពិចារណាឃើញច្បាស់ដោយបញ្ញាថា សង្ខារទាំងឡាយទាំងពួងនាំមកនូវសេចក្ដីទុក្ខក្នុងកាលណាហើយ គង់នឿយណាយចំពោះសេចក្ដីទុក្ខ ក្នុងកាលណោះមិនខាន នេះជាផ្លូវប្រព្រឹត្តទៅដើម្បីសេចក្ដីហ្មត់ចត់ ។

បុគ្គលពិចារណាឃើញច្បាស់ដោយបញ្ញាថា សង្ខារទាំងឡាយទាំងពួងមិនមែនជារបស់ខ្លួនដូច្នេះក្នុងកាលណាហើយ គង់នឿយណាយចំពោះសេចក្ដីទុក្ខ ក្នុងកាលណោះមិនខាន នេះជាផ្លូវប្រព្រឹត្តទៅដើម្បីសេចក្ដីហ្មត់ចត់ ។

ធម៌ដែលឈ្មោះថាអនិច្ចតាធម៌ គឺសភាពប្រែប្រួលមិនទៀងទាត់ អនិច្ចតាធម៌នេះមិនមែនជាធម៌សម្រាប់អ្នកស្រុកតែមួយ ៗ ទេ មិនមែនជា

ធម៌សម្រាប់អ្នកនិគមតែមួយ ៗ ទេ ឬនឹងថាជាធម៌សម្រាប់ត្រកូលតែមួយ ៗ ក៏មិនមែនទេ   អនិច្ចតាធម៌នេះជាធម៌សម្រាប់មនុស្សព្រមទាំងទេវតាមារព្រហ្មទាំងអស់គ្រប់រូប ៗ

ធម៌ដែលឈ្មោះថាទុក្ខតាធម៌ គឺសភាពជាទុក្ខ ទុក្ខតាធម៌នេះ មិនមែនជាធម៌សម្រាប់អ្នកស្រុកតែមួយ ៗ ទេ មិនមែនជាធម៌សម្រាប់អ្នកនិគមតែមួយ ៗ ទេ ឬនឹងថាជាធម៌សម្រាប់ត្រកូលតែមួយ ៗ ក៏មិនមែនទេ ទុក្ខតាធម៌នេះជាធម៌សម្រាប់មនុស្ស ព្រមទាំងទេវតាមារព្រហ្មទាំងអស់គ្រប់រូប ៗ

ធម៌ដែលឈ្មោះថាអនត្តាធម៌ គឺសភាពមិនមែនជារបស់ខ្លួន អនត្តាធម៌នេះ មិនមែនជាធម៌សម្រាប់អ្នកស្រុកតែមួយ ៗ ទេ មិនមែនជាធម៌សម្រាប់អ្នកនិគមតែមួយ ៗ ទេ ឬនឹងថាជាធម៌សម្រាប់ត្រកូលតែមួយ ៗ ក៏មិនមែនទេ   អនត្តាធម៌នេះជាធម៌សម្រាប់មនុស្សព្រមទាំងទេវតាមារព្រហ្មទាំងអស់គ្រប់រូប ៗ

គង្វាលគោកៀងគោទាំងឡាយដោយអាជ្ញា គឺដម្បងនឹងរំពាត់យ៉ាងណាមិញ ជរាគឺសេចក្តីគ្រាំគ្រា នឹងមច្ចុរាជគឺសេចក្តីស្លាប់ ក៏កៀងទៅនូវអាយុរបស់សត្វទាំងឡាយយ៉ាងនោះឯង ៗ

អាយុនឹងភ្លើងធាតុនឹងវិញ្ញាណ   លះបង់នូវរាងកាយនេះកាលណាហើយ រាងកាយនេះជាសភាពគួរអ្នកផងបោះបង់ចោល តែងតែដេកស្តូក

ស្ទឹងលើផែនដីក្នុងកាលណោះឯងដូចជាអគ្គិភ័យឆេះបក្សីកណ្ដាលឈើ ដែលគេ បោះបង់ចោល ។

សេចក្ដីសោកកើតមានព្រោះសេចក្ដីស្រឡាញ់ សេចក្ដីភិតភ័យ កើតមានព្រោះសេចក្ដីស្រឡាញ់ កាលបើបុគ្គលរួចស្រឡះចាកសេចក្ដី ស្រឡាញ់ហើយ សេចក្ដីសោកក៏មិនមាន សេចក្ដីភិតភ័យនឹងមានមក ពីណា ។

អាយុរបស់សត្វទាំងឡាយ រស់នៅតិចតួចពេកណាស់ គឺជាកតែង នាំចូលទៅរកសេចក្ដីស្លាប់ កាលសត្វឯណាដែលត្រូវជកនាំទៅហើយ នឹងរកអ្នកជាទីពាត់ទាំងកំឡាំងកំឡាំង នឹងជាទីពឹងពួនគោនថ្ងៃពុំមិនមានឡើយ ។ កាលបើសាធុជនបានសំឡឹងឃើញភ័យក្នុងសេចក្ដីស្លាប់នេះហើយ គួរ តែសំឡឹងរំពឹងយកសេចក្ដីស្ងប់រម្ងាប់ គឺព្រះនិព្វានហើយលះបង់នូវអាមិស គ្រឿងបញ្ចោតចិត្ត ក្នុងលោកចោលចេញឲ្យបានកុំខានឡើយ ។

កាលទាំងឡាយតែងកន្លងផុតទៅ ពគ្គិទាំងឡាយតែងធ្លងហួស ទៅ ជំនាន់វ័យទាំងឡាយតែងលះបង់ជាលំដាប់ទៅ កាលបើសាធុជន បានសំឡឹងឃើញភ័យ ក្នុងសេចក្ដីស្លាប់នេះហើយ គួរតែសំឡឹងរំពឹងយក សេចក្ដីស្ងប់រម្ងាប់ គឺព្រះនិព្វានហើយលះបង់នូវអាមិសគ្រឿងបញ្ចោតចិត្ត ក្នុងលោកចោលចេញឲ្យបានកុំខានឡើយ ។

## ៥០ សតិប្បដ្ឋាន ៤

១ ពិចារណាឃើញរឿយ ៗ នូវកាយក្នុងកាយហើយ ប្រុងតាំងស្មារតី ៗ

២ ពិចារណាឃើញរឿយ ៗ នូវវេទនាក្នុងវេទនាទាំងឡាយហើយ ប្រុងតាំងស្មារតី ៗ

៣ ពិចារណាឃើញរឿយ ៗ នូវចិត្តក្នុងចិត្តហើយ ប្រុងតាំងស្មារតី ៗ

៤ ពិចារណាឃើញរឿយ ៗ នូវធម៌ក្នុងធម៌ទាំងឡាយហើយ ប្រុងតាំងស្មារតី ៗ

## ៥១ កាយេ កាយានុបស្សនាសតិបដ្ឋានំ

ពិចារណាឃើញរឿយ ៗ នូវកាយក្នុងកាយថា (មិនទៀង មានទុក្ខ[1] មិនជារបស់ខ្លួនហើយផ្ចង់ស្មារតីចំពោះថា កាយនេះគ្រាន់តែជាកាយ មិនមែនសត្វមិនមែនបុគ្គល មិនមែនស្ត្រីនឹងបុរសជាដើម) ល្មមតែកំណត់ដើម្បីឲ្យចម្រើនប្រាជ្ញា ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះផង មានចិត្តមិនបានអាស្រ័យនៅដោយតណ្ហានឹងទិដ្ឋិ[2] ប្រព្រឹត្តនៅផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ៗ (ឃើញដូច្នេះហើយ) ប្រព្រឹត្ត

---

១ មិនទៀង ជាទុក្ខមិនមែនរបស់ខ្លួន នេះគ្មានក្នុងសតិបដ្ឋានទេ តែធម៌នេះជាធម៌ពេញចិត្តរបស់ខ្ញុំ សូមបញ្ចូលជាធម៌ពិចារណា ។ ២ តណ្ហា សេចក្ដីចំណង់កើតអំពីអាយតន ១២ ទិដ្ឋិសេចក្ដីយល់ឃើញខុស ១០ យ៉ាង ។

ទៅ មានព្យាយាមជាគ្រឿងដុតកំដៅនូវកិលេស ប្រកបដោយប្រាជ្ញាដឹងសព្វ មានស្មារតីជាគ្រឿងកំណត់បណ្ដេញបង់នូវអភិជ្ឈា[១] និងទោមនស្សក្នុងលោក ។

## ៥២ វេទនាសុ វេទនានុបស្សនាសតិបដ្ឋានំ

ពិចារណាឃើញរឿយ ៗ នូវវេទនាក្នុងវេទនាទាំងឡាយថា (មិនទៀងមានទុក្ខមិនមែនជារបស់ខ្លួនហើយ) ផ្ចង់ស្មារតីចំពោះថា (វេទនានេះគ្រាន់តែជាវេទនា មិនមែនសត្វមិនមែនបុគ្គល មិនមែនស្ត្រីនិងបុរសជាដើម) ល្មមតែកំណត់ដើម្បីឲ្យចម្រើនប្រាជ្ញា ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះផង មានចិត្តមិនបានអាស្រ័យទៅដោយតណ្ហា និងទិដ្ឋិប្រព្រឹត្តទៅផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។ (ឃើញដូច្នេះហើយ) ប្រព្រឹត្តទៅ មានព្យាយាមជាគ្រឿងដុតកំដៅនូវកិលេស ប្រកបដោយប្រាជ្ញាដឹងសព្វមានស្មារតីជាគ្រឿងកំណត់បណ្ដេញបង់ នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។

## ៥៣ ចិត្តេ ចិត្តានុបស្សនាសតិបដ្ឋានំ

ពិចារណាឃើញរឿយ ៗ នូវចិត្តក្នុងចិត្តថា (មិនទៀង មានទុក្ខមិនមែនជារបស់ខ្លួនហើយ) ផ្ចង់ស្មារតីចំពោះថា (ចិត្តនោះគ្រាន់តែជាចិត្ត មិន

១ អភិជ្ឈា លោភបង្អោនយកទ្រព្យអ្នកដទៃ ទោមនស្ស សេចក្ដីអាក់អន់ចិត្ត ។

មែនសត្វមិនមែនបុគ្គលមិនមែនស្ត្រីនិងបុរសជាដើម ) លុះតែកំណត់ដើម្បីឲ្យចំរើនប្រាជ្ញា ដើម្បីឲ្យចំរើនស្មារតីប៉ុណ្ណោះផង មានចិត្តមិនបានអាស្រ័យនៅដោយតណ្ហា និងទិដ្ឋិប្រព្រឹត្តទៅផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។ (ឃើញដូច្នេះហើយ) មានព្យាយាមជាគ្រឿងដុតកំដៅនូវកិលេស ប្រកបដោយប្រាជ្ញាដឹងសព្វ មានស្មារតីជាគ្រឿងកំណត់បណ្ដេញបង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក ។

## ៥៤ ធម្មេសុ ធម្មានុបស្សនាសតិបដ្ឋានំ

ពិចារណាឃើញរឿយ ៗ នូវធម៌ក្នុងធម៌ទាំងឡាយថា (មិនទៀង មានទុក្ខមិនមែនជារបស់ខ្លួនហើយ) ផ្ចង់ស្មារតីចំពោះថា ធម៌នេះគ្រាន់តែជាធម៌ មិនមែនសត្វមិនមែនបុគ្គល មិនមែនស្ត្រីនិងបុរសជាដើម) លុះតែកំណត់ដើម្បីឲ្យចំរើនប្រាជ្ញា ដើម្បីឲ្យចំរើនស្មារតីប៉ុណ្ណោះផង មិនបានអាស្រ័យនៅដោយតណ្ហា និងទិដ្ឋិប្រព្រឹត្តទៅផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។ (ឃើញដូច្នេះហើយ) ប្រព្រឹត្តទៅ មានព្យាយាមជាគ្រឿងដុតកំដៅនូវកិលេស ប្រកបដោយប្រាជ្ញាដឹងសព្វ មានស្មារតីជាគ្រឿងកំណត់បណ្ដេញបង់ នូវអភិជ្ឈា និងទោមនស្សក្នុងលោក ។

## ៥៥ សតិបដ្ឋានវិធី

ផ្លូវគឺសតិបដ្ឋានទាំងឡាយ ៤ នេះ ជាផ្លូវមួយតែមួយប្រព្រឹត្តទៅ ដើម្បីសេចក្ដីស្អាតវិសេសដល់សត្វទាំងឡាយ ដើម្បីកន្លងបង់នូវសោក និងខ្សឹកខ្សួលរំជួលចិត្តទាំងឡាយ ដើម្បីដល់នូវអរិយមគ្គ ជាធម៌សម្រាប់ស្រោចស្រង់សត្វ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន (ជាស្ថានក្សេមផុតលោក) ។

## ៥៦ សារូបកថា និដ្ឋិតា

ធម៌អាថ៌ដែលខ្ញុំរៀបរាប់ឲ្យសមរម្យនឹងវ័យ ៣ ប្រការនេះ មិនមែនមានតែប៉ុណ្ណេះទេ នៅមានច្រើនជាអនេកទៅទៀត មិនឈ្នះនឹងយកមកថ្លែងឲ្យអស់ឡើយ ព្រោះគ្មានពេល សំដែងមកប៉ុណ្ណេះគ្រាន់តែជាប្រដាប់ប្រាជ្ញារបស់លោកអ្នកសិក្សា ពណ៌នាមកនេះមិនបានជាចប់សព្វគ្រប់ទេ តែសន្មតជាចប់ដោយសង្ខេបតែប៉ុណ្ណេះហោង ។ ៚—

កំណត់សាងព្រះត្រៃបិដកបាលីនឹងសេចក្ដីប្រែតាំងពីព្រះពុទ្ធសករាជកន្លងទៅពីរពាន់បួនរយចិតសិបពីរឆ្នាំក្នុងថ្ងៃព្រហស្បតិ៍បីកើត ខែបុស្ស ឆ្នាំមមី ទោស័កគឺថ្ងៃពីរហ្សាំងវីយេរឆ្នាំមួយពាន់ប្រាំបួនរយសាមសិប ចប់ព្រះវិនយបិដកក្នុងព្រះពុទ្ធសករាជកន្លងទៅពីរពាន់បួនរយចិតសិបប្រាំបី ក្នុងថ្ងៃអង្គារប្រាំបីកើតខែមិគសិរឆ្នាំកុរសប្តស័ក គឺថ្ងៃបីឌេសម ឆ្នាំមួយពាន់ប្រាំបួនរយសាមសិបប្រាំ ក្នុងព្រះរាជបណ្ណាល័យកម្ពុជា៖ ។

ខ្ញុំចូលមកធ្វើការជំនួយពិនិត្យបាលីព្រះត្រៃបិដក ក្នុងព្រះរាជបណ្ណាល័យកម្ពុជា ក្រុងភ្នំពេញ តាំងពីថ្ងៃ ១ ខែយូអាំងឆ្នាំ ១៩៣០ ដោយអំណាចសម្ដេចចក្រីលោកបង្គាប់ឲ្យចូលធ្វើក្នុងពេលដែលត្រឡប់មកអំពីដើរត្រួតត្រាការសិក្សាដល់ថ្ងៃ ៤ អ៊ូតឆ្នាំ ១៩៣១ នោះព្រះតេជព្រះគុណលោកគ្រូព្រះសិរីសម្មតិវង្សអធិបតីក្រុមជំនុំ ប្ដឹងទៅរាជការសូមឲ្យធ្វើជំនួយការផងដែល ដោយបៀវត្សអាំងស្ប៉ិកទ័រ ដល់ថ្ងៃ ១ អ៊ូតឆ្នាំ ១៩៣៣ រាជការជាធំថាក្រប្រាក់ បញ្ឈប់បៀវត្សអាំងស្ប៉ិកទ័រខ្ញុំធ្វើការនេះ៦ខែឥតមាន បៀវត្ស លុះដល់ថ្ងៃ១ យ៉ាំងវិយេរឆ្នាំ ១៩៣៤ នោះលោកអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យលោកប្ដឹងទៅរាជការជាធំសូមឲ្យមានអារេតេតាំងខ្ញុំស៊ីបជាក្រមជំនុំព្រះត្រៃបិដកក្នុងក្រុមពុទ្ធសាសនបណ្ឌិត្យរហូតមក ៗ ដែលខ្ញុំជំណាលមកប៉ុណ្ណេះដោយសេចក្ដីប៉ុនប៉ងនឹងប្រកាសឧប្បត្តិហេតុ ដែលចាប់ផ្ដើមកសាងព្រះត្រៃបិដកបាលីនឹងសេចក្ដីប្រែ ទុកខាងចុងនៃធម៌អាថ៌នេះ កំណត់ដែលតាំងសាងមកដល់ចប់ព្រះវិនយបិដក ដូចមានក្នុងតារាងខាងលើនេះហើយនឹងសេច-

ក្តីយ" ក្នុងសិក្ខាបទក្ខន្ធក ទំងបរិវារ ក្នុងផ្នែកព្រះវិន័យបិដកទាំងស្រុង ដូចមានខាងក្រោមនេះ ។

# ព្រះវិន័យបិដក

១ មហាវគ្គ បឋមភាគ វេរញ្ជកណ្ឌ សេចក្តីដំណាលរឿងវេរញ្ជព្រាហ្មណ៍ នឹងបារាជិកកណ្ឌ កណ្ឌសំដែងអំពីបារាជិក ៤ ។

២ មហាវគ្គ ទុតិយភាគ តេរសកណ្ឌ កណ្ឌសំដែងអំពីសង្ឃាទិសេស ១៣ នឹងអនិយតកណ្ឌ កណ្ឌសំដែងអំពីអនិយត ២ ។

៣ មហាវគ្គ តតិយភាគ និស្សគ្គិយកណ្ឌ កណ្ឌសំដែងអំពីនិស្សគ្គិយ ៣០ នឹងបាចិត្តិយកណ្ឌ កណ្ឌសំដែងអំពីបាចិត្តិយ ១៥ សិក្ខាបទ ។

៤ មហាវគ្គ ចតុត្ថភាគ បាចិត្តិយកណ្ឌ កណ្ឌសំដែងអំពីបាចិត្តិយ បាដិទេសនីយកណ្ឌ កណ្ឌសំដែងអំពីបាដិទេសនីយ ៤ សេខិយកណ្ឌ កណ្ឌសំដែងអំពីសេខិយ ៧៥ នឹងអធិករណសមថកណ្ឌ កណ្ឌសំដែងអំពីអធិករណសមថ ៧ (ចប់បាតិមោក្ខ) ។

៥ ភិក្ខុនីវគ្គ បញ្ចមភាគ សំដែងអំពីសិក្ខាបទភិក្ខុនី បារាជិក ៨ សង្ឃាទិសេស ១៧ និស្សគ្គិយ ៣០ បាចិត្តិយ ១៦៦ បាដិទេសនីយ ៨ សេខិយ ៧៥ អធិករណសមថ ៧ ជា ៣១១ ) ។

៦ មហាវគ្គ បឋមភាគ មហាខន្ធក សំដែងអំពីបព្វជ្ជា នឹងឧបសម្បទាជាដើម ឧបោសថក្ខន្ធក សំដែងអំពីឧបោសថ នឹងវិធីសម្មតិសីមាជាដើម ។

៧ មហាវគ្គ ទុតិយភាគ វស្សូបនាយិកក្ខន្ធក សំដែងអំពីចូលវស្សា នឹងសត្តាហកិច្ចជាដើម បវារណាខន្ធក សំដែងអំពីបវារណាជាដើម ចម្មក្ខន្ធក សំដែងអំពីសមណបរិក្ខារជាដើម នឹងភេសជ្ជក្ខន្ធក សំដែងអំពីត្រេកអរក្នុងចតុប្បច្ច័យដែលកើតអំពីរូបិយជាដើម ។

៨ មហាវគ្គ តតិយភាគ កឋិនក្ខន្ធក-សំដែងអំពីក្រាលគ្រង់អនុមោទនាកឋិនជាដើម ចីវរក្ខន្ធក សំដែងអំពីទឹកជ្រលក់ ៦ យ៉ាងជាដើម ចម្បេយ្យក្ខន្ធក សំដែងអំពីសង្ឃកម្មជាដើម នឹងកោសម្ពិកក្ខន្ធក សំដែងអំពីទាស់ទែងគ្នាជាដើម ។

៩ ចុល្លវគ្គ បឋមភាគ កម្មក្ខន្ធក សំដែងអំពីតជ្ជនីយកម្មជាដើម បរិវាសិកក្ខន្ធក សំដែងអំពីគរុកាបត្តិត្រូវធ្វើបរិវាសកម្មជាដើម សមុច្ចយក្ខន្ធក សំដែងអំពីបរិវាសកម្ម ៣ យ៉ាង នឹងអព្ភានកម្មជាដើម ។

១០ ចុល្លវគ្គ ទុតិយភាគ សមថក្ខន្ធក សំដែងអំពីអធិករណ៍ ៤ យ៉ាង មានវិវាទាធិករណ៍ជាដើម ខុទ្ទកវត្ថុក្ខន្ធក សំដែងអំពីសមណសារុប្បជាដើម សេនាសនក្ខន្ធក សំដែងអំពីសាមគ្គីនៃសង្ឃ នឹងគរុភណ្ឌរបស់សង្ឃជាដើម ។

១១ ចុល្លវគ្គ តតិយភាគ សង្ឃភេទក្ខន្ធក សំដែងអំពីសាមគ្គីនៃសង្ឃជាដើម វត្តក្ខន្ធក សំដែងអំពីអាគន្តុកវត្តជាដើម បាតិមោក្ខឋបនក្ខន្ធក សំដែងអំពីអច្ឆរិយព្ភូតធម៌ ៨ យ៉ាងជាដើម ភិក្ខុនីខន្ធក សំដែងអំពីឧប-សម្បទានៃភិក្ខុនី មានគរុធម៌ ៨ ប្រការជាដើម បញ្ចសតិកក្ខន្ធក សំដែងអំពីបរិនិព្វានហើយត្រឹម ៣ ខែធ្វើបឋមសង្គាយនា ទ៏ងសត្តសតិកក្ខន្ធក សំដែងអំពីរឿងធ្វើទុតិយសង្គាយនា វត្ថុ ១០ យ៉ាងជាដើម ។

១២ បរិវារ បឋមភាគ មហាវិភង្គ សោឡសមហាវារ ភិក្ខុនីវិភង្គ សោឡសមហាវារសមុដ្ឋានសីសសង្ខេប កតិបុច្ឆាវារ ទ៏ងវីសតិវារ ។

១៣ បរិវារ ទុតិយភាគ ខន្ធបុច្ឆា ឯកុត្តរិក ឧបោសថាទិបុច្ឆា-វិសជ្ជនា អត្ថវសបករណ គាថាសង្គណិក ទ៏ងអធិករណភេទជាដើម ។

ចប់ ព្រះវិន័យបិដក ១៣ សៀវភៅ ។

# កុសលកម្មបថ ១០

សង្ខេប

អាចារ្យ ហ. ឈា ក្រុមជំនុំព្រះត្រៃបិដក

ក្នុងក្រសួងពុទ្ធសាសនបណ្ឌិត្យនៅព្រះរាជបណ្ណាល័យ

ក្រុងភ្នំពេញ

បានតែងជាពាក្យកាព្យ

បទព្រហ្មគិត

គរុសលក្ខបជ ១០

សង្ខេប

# តែងជាពាក្យកាព្យ

## បទព្រហ្មគីត

៧ ខ្ញុំសូមលើកហត្ថា ទូនសិរសាថ្វាយបង្គំ
រំលឹកដល់ប្រជុំ គុណព្រះស្រីរត្នៈត្រ័យ ។
ជាកែវវិសេសឯក ល្អចំឡែកផុតវិស័យ
ត្បូងពេជ្រកែវចរណៃ ថ្លៃយ៉ាងណាផ្ទឹមពុំបាន ។
ព្រះត្រៃរត្នវិសុទ្ធ ខ្ពស់បំផុតក្នុងភពឋាន
កម្រនឹងរកបាន ក្រៅតែត្រស្ថានពុទ្ធកាល ។
ពួកមនុស្សនឹងទេវតា តែងប្រាថ្នាស្វែងត្រអាល
រកកែវថ្លៃត្រកាល ទុកជាទីពឹងក្នុងប្រាណ ។
ដោយអំណាចប្រណម្យ ត្រៃឧត្តមថ្លៃថ្កើងថ្កាន
គ្រោះថ្នាក់ទាំងប៉ុន្មាន កុំបីបានក្តីយាយី ។
ដល់ខ្លួនខ្ញុំអ្នកតែង កាព្យកិច្ចថ្លែងដោយភក្ដី
ភាសិតព្រះមុនី តាមវិធីពុទ្ធសាស្នា ។
ហៃសប្បុរសទាំងឡាយ ចូរប្រុងកាយផ្ទង់សោតា
ខាត់ចិត្តឲ្យក្ដីថ្លា ស្ដាប់អត្ថាធិប្បាយថ្លែង ។

អំពីកម្មៈបថ
ព្រះពុទ្ធទ្រង់សំដែង
ជាកាយៈកម្មបី
ឯមនោកម្មលោកពាត់
រួមត្រូវជា ១០ គត់
ចែកជាកុសលបាន
ប៉ែកខាងអកុសល
ចំនួនដប់ៗ ម្ខាង

និងពោលតាមបរិយាយ

កុសលទុកដម្រូវ
ដែលមានចិត្តសទ្ធា
ស្ម័គ្រក្នុងច្បាប់គ្រហស្ថ
ទី ១ គឺបាណា
សត្វតូចជាលំដាប់
ទី ២ អទិន្នា
ទ្រព្យគេទោះតូចធំ
ទី ៣ វៀរប្រព្រឹត្ត
លបលួចរួមសង្វាស

ដប់ប្រាកដដោយជាក់ស្ដែង
ញែកចែកតាមថ្នាក់សង្កាត់ ។
ជាវចីកម្មបួនមាត់
ជាពាក្យអត្ថមានបីបាន ។
បូរកំណត់កត់ក្នុងប្រាណ
តាមលំអានមាន ១០ យ៉ាង ។
ដប់វៀងកល់ជាតឹកតាង
ដូចតួយ៉ាងមានតទៅ ។
បកប្រែស្រាយអំពីផ្លូវ
ដល់ពួកជនជាសប្បុរស ។
គ្មានរញ្ញកទទឹងទាស់
ព្រះទ្រង់យសសំដែងប្រាប់ ។
លោកហាមថាកុំសំឡាប់
ដាបដល់សត្វធំៗ ។
លួចទ្រព្យាគួរតែកុំ
ត្រូវវៀរលែងកុំផ្ដេសផ្ដាស ។
ទុច្ចរិតបិត្តឡេះឡាស
សេពមេថុនទឹងករិយា ។

បុត្រានឹងបុត្រី ទាំងស្វាមីជននានា
សព្វស្រសលោកតែងលា លះលែងគ្រើមួយជីវិត ។
ចប់កាយកម្មបី ដោយសេចក្ដីវិសុទ្ធិត
អស់លោកអ្នកស្ម័គ្រចិត្ត ចូរប្រព្រឹត្តឲ្យត្រឹមត្រូវ ។
ឯវចីកម្មបួន មានចំនួនដូចតទៅ
រៀងលេខតាំងទុកនៅ ជាលំដាប់តាមទីស្ថាន ។
ទី ១ វៀរមុសា ពោលកថាថាស្មាន ។
កុតករបង្វែងដាន យកមិនបានជាការពិត ។
ទី ២ វៀរវាចា បិសុណា បំបែកមិត្ត
ញុះញង់ជនឆ្ងាយជិត ឲ្យវិបរិតកើតជំលោះ ។
ទី ៣ វៀរវាចា ផរុសា ពោលទ្រគោះ
ប្រទេចជេរកេរឈ្មោះ ដៀលពូជពង្សម៉ែឪគ្នា ។
ទី ៤ វៀរសំដី ពាក្យអប្រិយស្ដីខ្ជា
ឡេះឡោះរកគ្នីគ្នា តុកកំប្លែងលេងក៏រ៉ៃ ។
ចូលក្នុងពាក្យតិរច្ឆាន មានប្រមាណសាមសិបពីរ
ពិស្ដារក្នុងគម្ពីរ ប្រាប់សេចក្ដីស្អាតជ្រៅជ្រះ ។
វចីកម្មទាំងបួន គ្រប់ចំនួនមិនលើសខ្វះ
បញ្ចប់ចុះស្រឡះ ទឹងពោលផ្លាស់សេចក្ដីប្លែក ។

ឯមនោកម្មទាំងបី ជាសេចក្ដីដោយឡែក
ព្រះពុទ្ធសំដែងបែក តាមបំណែកចិត្តខុសគ្នា ។
ទី ១ កុំរំពឹង គិតសំឡឹងក្នុងទ្រព្យា
របស់ជនឯទា បង្អោនមកដើម្បីខ្លួន ។
ទី ២ អព្យាបាទ កុំអាឃាតចងគុំគួន
គំនិតចិត្តល្អមាំមួន មិនបំផ្លាញសន្ធារសត្វ ។
ទី ៣ យល់ឃើញត្រូវ ចុះក្នុងផ្លូវធម៌បរមត្ថ
មិនខុសមិនវិបត្តិ ពាក្យសច្ចៈធម៌ប្អូនយ៉ាង ។
ឬមួយយល់ឃើញថា ចិត្តជ្រះថ្លាចង់កសាង ។
កុសលអ្វីម៉្យាង ៗ មានផលគាប់ដោយទៀងទាត់ ។
មនោកម្មទាំងបី ចប់សេចក្ដីជាកំណត់
សង្ខេបតាមបែបបទ ដោយសង្ខេបតែប៉ុណ្ណោះ ។
សប្បុរសទាំងប្រុសស្រី គួរគប្បីរៀនឲ្យចេះ
ឲ្យចូលចិត្តទុកព្រះ រិះដឹងឲ្យស្គាល់ផល ។
ហើយខំកាន់ប្រព្រឹត្ត សុចរិតក្នុងកុសល
ទាំង ១០ ទុកជាថ្នល់ ដើរទៅកាន់សួគ៌និព្វាន ។
ទើបបានអានិសង្ស ដែលគួរគ្រែព្រះទ្រង់ញាណ
សំដែងប្រាប់ថាមាន ប្រាំប្រការពិតប្រាកដ ។

អានិសង្សទី ១ ថា
រក្សាកម្មៈបថ
អ្នកនោះផុតក់ចា
នឹងរួចផុតស្រឡះ
គឺគ្មានក្តៅក្រហាយ
ធ្វើខ្លួនឲ្យក្សេមក្សាន្ត
អានិសង្សទី ២ ថា
ទាំង ១០ ដោយប្រពៃ
ព្រោះលោកពិចារណា
អ្នកប្រាជ្ញលោកតែងដើរ
អានិសង្សគំរប់បី
ខ្ពង់ខ្ពស់កសីមុខ
អានិសង្សគំរប់បួន
ក្រហល់ខ្វល់ក្នុងកាយ
គឺមានស្មារតីរឹង
តាំងក្នុងគុណដ៏មាំ
អានិសង្សទី ៥ ថា
យល់ឃើញថាចាស់ក្មេង

អ្នកឯណាចិត្តម៉ត់ចត់
ឲ្យគត់មត់មិនឲ្យខ្វះ ។
ខ្លួនស្តីថាពោលដៀលគ្នះ
ខ្លួនដៀលខ្លួនឯងពុំបាន ។
ស្រណោះស្តាយក្រោយក្នុងប្រាណ
សុខសម្រានឥតកិតភ័យ ។
អ្នកឯណាកាន់វិន័យ
វិញ្ញូជនតែងសរសើរ ។
ដោយបញ្ញាតាមដំណើរ
ឆ្លងទៅរកកន្លែងសុខ ។
ផ្សាយសិរីល្បីសព្វស្រុក
ព្ទកេរ្តិ៍ឈ្មោះពីរោះឆ្ងាយ ។
ស្លាប់ដឹងខ្លួនមិនក្រហាយ
ពោលភយមាយកាន់ប្រឡំ ។
ចិត្តនឹងដឹងក្នុងអារម្មណ៍
ពេលទៀបស្លាប់មិនវង្វេង ។
ព្រះសាស្តាស្តេចទ្រង់ឈ្វេង
ណា មានចិត្តស្អាតបរិសុទ្ធ ។

ស្រឡាញ់ថៃកេរ្យា កាន់សាស្នាព្រះសម្ពុទ្ធ
អ្នកនោះនឹងបានផុត ពីទុក្ខភ័យក្នុងអាត្មា ។
លែងស្គាល់ស្ថាននរក ស្គាល់តែសុខក្នុងមនុស្សា
សុខដល់ស្ថានទេព្តា ឆកាមាតាំងប្រាំមួយ ។
រុងរឿងថ្កើងអស្ចារ្យ សោយអាហារទិព្វមិនព្រួយ
ព្រោះផលកុសលជួយ ស្ទួយឲ្យឡើងជាទេវតា ។
សម្បត្តិទិព្វតាំង ១០ ជាកំណប់នៃបណ្ដា
ប្រុសស្រីដែលសិក្សា រៀនទន្ទេញកម្មបថ ។
ប៉ែកខាងអកុសល នឹងកុសលឲ្យប្រាកដ
ប្រតិបត្តិមិនឲ្យឃ្លាត ដាច់ធុះធ្លាយសៅហ្មងឡើយ ។
ទៀងតែនឹងបានដល់ សុខថ្កើងថ្កល់សម្រានស្បើយ
សម្បត្តិទិព្វនេះហើយ ជាកំរៃផលកសាង ។
សន្សំធម៌សុចរិត ទុកក្នុងចិត្តជាគ្រឿងអាង
ទុច្ចរិតទាំង ៣ យ៉ាង ត្រូវកុំសាងឲ្យមានសោះ ។
អ្នកប្រាជ្ញពីបុរាណ លោកមិនបានស្ដាយស្រណោះ
ព្រះទ័យខំលោតផ្លោះ ឲ្យផុតបាតអកុសល ។
តាំង ១០ ចេញស្រឡះ ហើយខំស្វះស្វែងកុសល
តាំង ១០ ទុកជាផល សម្រាប់សោយសុខពល់ជាតិ ។

ដូច្នេះជនទាំងឡាយ　　គួរតាំងកាយកុំឲ្យឃ្លាត
អំពីពុទ្ធោវាទ　　ដែលទ្រង់ប្រោសប្រទានទុក ។
ផលសត្វក្នុងសាស្នា　　ឲ្យសិក្សាមិនរើសមុខ
សត្វណាប្រាថ្នាសុខ　　តែងបានដោយបុណ្យសម្បត្តិ ។
ក្នុងស្ថានមនុស្សទេវតា　　ថ្កើងថ្លៃថ្លាចាកវិបត្តិ
ជួបសោយបរមត្ថ　　សុខសម្បត្តិក្នុងនិព្វាន ។
និរាសអំពីជាតិ　　ជរាព្យាធិទុក្ខគ្មាន
មរណៈទុក្ខមិនហ៊ាន　　តាមផ្ដន្ទាបៀតបៀនឡើយ ។
ឯកម្មជាកុសល　　តែងឲ្យផលសុខឥតស្បើយ
កុំច្រល់ណាជនអើយ　　ចូរសិក្សាឲ្យស្ទាត់ជុះ ។
ពោលតែខាងកុសល　　អកុសលគង់ក្ដីទុះ
បើពោលថែមចម្រុះ　　នាំឲ្យស្រុះសាំសេចក្ដី ។
ប៉ែកខាងអកុសល　　ត្រូវសំគាល់ថាអប្រិយ
អាក្រក់មិនគប្បី　　ដែលប្រុសស្រីប្រព្រឹត្តធ្វើ ។
តាំងតែពីបុរាណ　　អនិន្ទាសព្វអន្ទើ
ជួបគ្រប់អំពើ　　ធ្វើទាំង ១០ ឥតសល់មួយ ។

ឯបាបទាំង ១០ នេះ ឲ្យផលឆេះផុយល្ហួយ
នាំសត្វឲ្យកើតព្រួយ ក្តៅខ្លោចផ្សាក្នុងអបាយ ។
សោយទុក្ខគ្រប់ប្រការ ជួនអស្ចារ្យអន្លង់ឆ្ងាយ
កម្មបាននៃប្រកាយ ឲ្យក្លាយជាមនុស្សប្រុសស្រី ។
ទសកម្មៈបថា ទិដ្ឋិតាសង្ខេបខ្ចី
បញ្ចប់អស់សេចក្តី ដោយវេលានេះឯងហោង ។

អាចារ្យហ៊ុន-ឈា
ក្រុមជំនុំព្រះត្រៃបិដក ក្នុងពុទ្ធសាសនបណ្ឌិត្យ
នៅព្រះរាជបណ្ណាល័យ ក្រុងភ្នំពេញ

ព.ស. ២៤៨១

# រឿងព្រេង — បុរសពីរនាក់

និយាយរឿង ១ មានបុរសពីរនាក់នាំគ្នាដើរទៅផ្លូវឆ្ងាយដល់ព្រៃដួន យប់ងងឹតដើរទៅមិនរួចបបួលគ្នាដេកក្នុងព្រៃ ឯបុរសពីរនាក់នោះដណ្ដើមគ្នាដេកកណ្ដាល់ ប៉ុន្តែមិនដឹងគិតធ្វើដូចម្តេចនឹងបានដេកកណ្ដាល អ្នកទាំងពីរគិតព្រមគ្នាថា បើដូច្នោះ យើងដេកយកជើងទល់គ្នាទើបស្រួល បុរសទាំងពីរនាក់ក៏ដេកយកជើងទល់គ្នាដណ្ដប់សំពត់ដិតលក់ទៅ ។

លុះយប់ជ្រៅមានសត្វខ្លាដើរមកបានឃើញមនុស្សពីរនាក់ដេក ក៏មើលមិនស្គាល់ជាសត្វអ្វី ខ្លាឆ្ងល់ណាស់ដ្បិតមិនដែលឃើញ ក៏បបួលអស់សត្វឯទៀតច្រើនមកជួយមើលឲ្យស្គាល់ច្បាស់ប្រាកដ សត្វទាំងនោះក៏នាំគ្នាមកមើលគ្មានសត្វណាមួយដឹងស្គាល់សោះ ទើបសត្វទាំងអម្បាលនោះប្រឹក្សាគ្នាថា សត្វនៅក្នុងព្រៃនេះប៉ុន្មានមកមើលអស់ហើយនៅសល់តែសត្វទន្សាយពុំបានមក មួយទៀត ឮល្បីថា សត្វទន្សាយជាអ្នកមានប្រាជ្ញាចេះនិយាយក្បួនច្បាប់ទំលាប់ ចេះកលមាយាចេះចាំទំនិមទំនៀមច្រើន បើដូច្នេះ យើងប្រើបងដំរីឲ្យទៅអញ្ជើញបងទន្សាយមកឲ្យមើលទើបស្គាល់សត្វនេះ ឯទន្សាយនោះបើមានគេណាទៅពឹងការអ្វី ៗ កាន់ខ្លួនណាស់ សត្វទាំងនោះប្រឹក្សាគ្នាព្រមហើយ ក៏ឲ្យដំរីទៅអញ្ជើញទន្សាយ ដំរីក៏ទៅឃើញទន្សាយអង្គុយនៅលើក្បាលដំបូក ទន្សាយឃើញដំរីដើរយេកយោកមកក៏សួរថា បងដំរីមកមានការអ្វីបានជាដើររលះរលាំងម្ល៉េះ

ដំរីប្រាប់ថា បងទន្សាយអើយ ឥឡូវមានសត្វម្នាក់នានាណា ស្គាល់សោះ ឥឡូវសត្វទាំងអស់ឲ្យខ្ញុំមកអញ្ជើញបងទៅមើល បើបងទៅមើលទើប ស្គាល់ប្រាកដ ទន្សាយសួរថា សត្វនោះដូចម្តេចតូចឬធំវែងឬខ្លី ដំរីនោះ ប្រាប់ថា សត្វនោះធំប៉ុនដើមត្នោតកណ្តាលហើយវែងប្រមាណ ៨ ហត្ថ ទន្សាយថា បើដូច្នោះ បងដំរីកុំព្រួយខ្ញុំព្រមទៅមើលឲ្យស្គាល់សត្វនោះ ប៉ុន្តែឲ្យជិះលើក្បាលបងឯង ដំរីក៏ឱនក្បាលឲ្យទន្សាយជិះរួចដើរទៅ ទន្សាយក៏ធ្វើពាក្យសំដីជាក្អេងក្អាង លុះដល់ហើយទន្សាយចុះពីក្បាលដំរី យកស្លឹកឈើដែលមានស្នាមដង្កូវរ៉ាស៊ីដូចជាអក្សរ កាន់លើកឡើងធ្វើជា សំបុត្រថា អស់បងប្អូនស្តាប់ខ្ញុំផ្សិតខ្ញុំជាបំរើព្រះឥន្ទ្រ ។ លោកប្រើឲ្យនាំ សំបុត្រមក ហើយទន្សាយឡើងលើដំបូកធ្វើជាមើលសំបុត្រថា សត្វនេះ ព្រះឥន្ទ្រលោកប្រើមក ឈ្មោះសត្វយោគីយោគា ឲ្យមកយកទាំងអស់ គ្នា ទាំងពេញទាំងឯង សត្វទាំងនោះបានស្តាប់ទន្សាយមើលសំបុត្រព្រះ ឥន្ទ្រថា ឲ្យមកយកទាំងអស់គ្នាភ័យណាស់ក៏ស្ទុះបោលជាន់គ្នាស្រែករំពង ព្រៃ សត្វខ្លះបាក់ជើងស្លាប់នៅទីនោះច្រើន ឯបុរសទាំងពីរនាក់បានដឹង ថា សត្វទាំងនោះផ្អើលភ្ញាក់តែជាន់គ្នាស្លាប់ដូច្នោះហើយក្រោកឡើងលើក ដៃសំពះទន្សាយថា អ្នកទន្សាយមានគុណនឹងយើងច្រើន បើប្រសិន

ណា មិនបានអ្នកទន្សាយមកធ្វើកលឧបាយប្រាជ្ញជួយយើងទេ សត្វខ្លានឹងខាំយើងស៊ីជាអាហារមិនខាន អ្នកទន្សាយនេះមានបញ្ញា ល្មមធ្វើជាសុភាបាន ហើយបុរសទាំងពីរនាក់មើលទៅឃើញអស់សត្វជាន់គ្នាស្លាប់ពាសពេញព្រៃក៏បបួលគ្នាអារយកសាច់រែកត្រឡប់មកផ្ទះវិញ ។

រឿងបុរសពីរនាក់ចប់តែប៉ុណ្ណោះ ។

ឧកញ៉ាប្រាជ្ញាធិបតីហាងហ្វាង ( យិន ) តែង ។

# បញ្ជីរឿង


១ — ដំណឹងផ្សេង ៗ . . . . . . . . . . . . . . . . . . . . . ១៥៧

២ — ព្រះមហាវិហារពុទ្ធគយា . . . . . . . . . . . . . . . . . . . ១៦៣

៣ — ប្រជុំពាក្យកាព្យ ភាគទី ៣ (តទី ៤) . . . . . . . . . . . . . . . ១៨១

៤ — ហិតោបទេស ភាគទី ១ . . . . . . . . . . . . . . . . . . . ១៩៧

៥ — រឿងព្រេង — រឿងបុរសផ្កាប់ត្រឡោក . . . . . . . . . . . . . . . ២០៧

៦ — លទ្ធិទំនៀមទម្លាប់ខ្មែរ — ពិធីសូត្របន្តូលដោះគ្រោះ . . . . . . . . . ២១៥


## រូបក្រៅរឿង


ប្រទេសលាវ-សៀម ស្រុកឈៀងហ្មៃ វត្តឈៀងទង រូបគ្រែទេសនា . . . . ១៥៥

# TABLE DES MATIÈRES

Pages

I- Informations diverses ....................I57

2- Le Préas Maha Vihara BODDHIGAYA par Maha Krasém........ I63

3- Recueil de poèmes, 3e partie, par Préas Bat Samdach Préas Thammaréachéa(suite)I8I

4- Hitopadesa Ire partie (suite)...........I97

5- Contes populaires cambodgiens inédits :

L'homme à la noix de coco renversée (Boros phkab Tralôk)............207

6- Moeurs & coutumes cambodgiennes :

Formules pour écarter les malheurs......2I5

HORS TEXTE :

Laos-Siamois - Chieng-Mai - Vat Xieng-Khong - Chaire à prêcher ....... I55



ប្រទេសលាវ-សៀម ស្រុកជៀងហ្មៃ វត្តជៀងខង រូបគ្រែទេសនា ។

# សុភាសិតនេះគួរទន្ទេញភាវនាទុក

“ យើងមិនត្រូវសោយទុក្ខទោមនស្ស នឹងពាក្យអាក្រក់ដែលគេនិយាយពីយើង មានតែសេចក្ដីល្អដែលគេមិននិយាយពីយើង បើចិត្តយើងល្អស្រាប់ហើយ ពាក្យផរុសវាទដែលលោកទាំងមូលពោលពីយើង ក៏ពុំអាចធ្វើសន្ដានចិត្តយើងឲ្យល្អអាក្រក់បានឡើយ ឬធ្វើកុសលធម៌ទាំងឡាយដែលយើងបានធ្វើហើយឲ្យវិនាសទៅវិញពុំបានឡើយ” ។

ជំណាំងដេរូង ។

# អំពីបុណ្យតាំងពិពិធភណ្ឌគ្រប់ប្រទេស នៅក្រុងប៉ារីស ក្នុងឆ្នាំ១៩៣៧

សព្វថ្ងៃនៅសល់តែសេចក្ដីរំឭកនឹកដល់បុណ្យមហាឧឡារិកនេះដែលជនជាតិខ្មែរយើងខ្លះបានទៅឃើញនឹងគេដែរ ។

ក្នុងឱកាសនោះមានអ្នកប្រាជ្ញបារាំងសែសម្នាក់អធិប្បាយអំពីសេចក្ដីប្រាថ្នាដែលបង្កើតឲ្យមានបុណ្យតាំងវត្ថុទាំងឡាយឡើង មានបុណ្យដែលធ្វើនៅក្រុងប៉ារីស កាលពីឆ្នាំ ១៩៣៧ជាដើម អ្នកប្រាជ្ញនោះនិយាយថា បុណ្យអស់នោះ គឺមហាសន្និបាតនៃពួកអ្នកស្រុកទាំងអស់ក្នុងលោកនាំគ្នា

យកបំណោះវិជ្ជាការមកប្រៀបផ្ទឹមគ្នា ៗ ឯសេចក្ដីប្រឹងប្រែងព្យាយាមទាំងនេះ មិនគ្រាន់តែបង់តាញ់ឈ្នះគ្នាប៉ុណ្ណោះទេ គឺចង់ជួយគ្នាទៅវិញទៅមកទៀតផង មហាជនដែលបានទៅឃើញពិធីបុណ្យនោះហើយទើបដឹងថា ក្រៅអំពីវត្ថុដែលកើតឡើងដោយកំឡាំងចិត្ត នឹងកំឡាំងកាយមនុស្សក្នុងលោកយើងនេះមានសេចក្ដីព្រមព្រៀងគ្នាគិតការមួយយ៉ាងធំ ដែលនាំឲ្យមនុស្សទាំងអស់រួបរួមគ្នាបានមិនថាប្រទេសណា ៗ ទេ តែមិនមែនថាស្រុកទាំងអស់គោងប្រព្រឹត្តដូចគ្នានោះក៏ទេ ពីព្រោះស្រុកនីមួយ ៗ ធ្វើឬគិតការអ្វី ៗ ទៅតាមវិជ្ជាការរបស់ខ្លួន តែជានគរទាំងអស់មានសេចក្ដីប្រាថ្នាចំពោះតែសេចក្ដីសុខក្សេមក្សាន្តមួយមុខ ហេតុនេះហើយបានជានៅលើផ្ទាំងសារមន្ទីររចនាបែបសម័យថ្មីមួយ គេមានសរសេរសេចក្ដីទុកថា "មនុស្សទាំងអស់ដែលនៅក្នុងលោកនេះមានចិត្តគិតមែបង់ធ្វើឲ្យប្រទេសទាំងអស់បានសេចក្ដីសុខក្សេមក្សាន្តដោយការរួបរួមគំនិតគ្នា" ហើយនៅក្នុងបន្ទប់មួយទៀត គេមើលឃើញសេចក្ដីមួយថា សិល្បសាស្ត្រទាំងឡាយនឹងទៅជារបស់សាធារណៈមរដកសំរាប់លោកទាំងមូល ទុកជាមានដំឡៃយ៉ាងណាក៏ដោយ សិល្បសាស្ត្រទាំងនោះលែងចែកដាច់មុខជារបស់សម្រាប់ក្រុមមួយ ៗ ទៀតហើយ" ។

# អំពីបុណ្យតាំងពិពិធភណ្ឌ នៅក្រុងប៉ារីស

កាលពីឆ្នាំ ១៩៣៧ មានបុណ្យតាំងពិពិធភណ្ឌ នៅក្រុងប៉ារីស គេទើបនឹងបានបោះពុម្ពសៀវភៅមួយឈ្មោះ "សេចក្ដីប្រតិទិតរបស់មនុស្ស-លោក" ដើម្បីជាទីរលឹកដល់បុណ្យនោះ ។

នៅទំព័រមុនបង្អស់ មានរៀបរាប់ឈ្មោះអ្នកប្រាជ្ញធំៗនៅក្នុងលោកនេះដែលមានគំនិតប្រហែលៗគ្នា គំនិតអស់នោះពិតមែនតែកើតឡើងក្នុងវេលាខុសគ្នា នឹងមានបែបផ្សេងៗគ្នា តែបានសេចក្ដីតែមួយយ៉ាងគឺ "អ្នកនគរទាំងអស់គ្នាបេះរៀនរាប់អានស្គាល់គ្នាបេះកោតខ្លាច-ស្រឡាញ់គ្នាទៅវិញទៅមក នេះជាហេតុនាំមិនឲ្យកើតសឹកសង្គ្រាមតទៅទៀតឡើយ" ។

មានជនជាតិអាមេរិកាំងមួយនាក់ កាល ព. ស. ២២០០ បានអធិប្បាយថា "ខ្ញុំយល់ថា វេលានេះគួរប្រជុំពួកបណ្ឌិតនឹងពួកអ្នកមានគំនិតល្អគ្រប់ប្រទេសតាំងបង្កើតជាក្រុមមួយហៅថា "សប្បុរិសក្រុម" ។

កាល ព. ស. ២៣៧០ មានអ្នកប្រាជ្ញជាតិអាល្លឺម៉ង់មួយនាក់បានអធិប្បាយថា "គួរឲ្យមនុស្សក្រោមលោកបេះស្គាល់រាប់អានគ្នាទៅវិញទៅមក ក្នុងខណៈនោះសេចក្ដីស្អប់ខ្ពើមគ្នាទៅវិញទៅមកនឹងត្រឡប់ទៅជាមានសាមគ្គីសមគ្គគ្នាទៅវិញ" ។

សេចក្ដីរិះគិតអស់នេះមិនស្មើគំនិតព្រះសម្មាសម្ពុទ្ធ ដែលបានសំដែងក្នុងគម្ពីរធម្មបទជាគាថា ថា "ស្អប់មិនដែលចាញ់ស្អប់ ស្អប់ចាញ់តែស្រឡាញ់" ។

មានជាតិអង់គ្លេសម្នាក់ កាលពុទ្ធសករាជ ២៣០០ បាននិយាយថា "គួរបង្កើតសមាគមមួយ ដោយប្រមូលពួកនិកាយគ្រប់ប្រទេសទាំងអស់ ដើម្បីនឹងតាក់តែងបង្កើតច្បាប់ទំលាប់ សម្រាប់លោកជាប្រមួយឡើង ។

នៅក្នុងសៀវភៅនេះ មានកន្លែងមួយនិយាយពីសេចក្ដីចម្រើនដែលកើតឡើងដោយពួកយុវកុមារទាំងឡាយ គ្រប់ជាតិគ្រប់ប្រទេសបេះប្រមូលគ្នា ទាំងនិយាយពីការធ្វើដំណើរទៅកាន់ស្រុកដទៃ នាំឲ្យកើតសតិបញ្ញាច្រើនឡើង គេបានទាំងទាញយកពាក្យអ្នកប្រាជ្ញបារាំងសែសម្នាក់ឈ្មោះ "ម៉ុងតែញ" កើតកាល ព. ស. ២២០០ មកពោលថា ការដើរទៅមើលប្រទេសក្រៅជាប្រយោជន៍នាំឲ្យយើងដឹងកិរិយាមារយាទនិងរបៀបប្រទេសអស់នោះ នាំឲ្យយើងចេះរៀបចំចិត្តគំនិតយើងដើម្បីប្រព្រឹត្តទៅកាន់ជនដទៃ ។

ហេតុនេះបានជានៅប្រទេសអឺរ៉ុបមានយុវសាលាច្រើនពេញពាស យើងសង្ឃឹមថា នៅស្រុកខ្មែរយើងគង់តែនឹងមានយុវសាលានេះបរិបូណ៌ដូចប្រទេសអឺរ៉ុបដែរ ។

យើងសព្វថ្ងៃបានស្គាល់ប្រទេសជាច្រើន ព្រមទាំងបណ្ដាក្សត្រនឹងគំនិតរបស់បណ្ដាក្សត្រនៅក្នុងប្រទេសអស់នោះ ដោយយើងបានស្ដាប់ជាសម៉ាស៊ីនច្រៀង បានមើលកុន មើលសៀវភៅ បានស្ដាប់ដំណឹងនានាតាមខ្សែលួសវិទ្យុ តាមរបៀបភ្លេង គំនូរនឹងអក្សរសាស្ត្រនាំឲ្យយើងចេះយល់ឃើញដូចលោកមហាចិន្តកវីនៃប្រទេសឥណ្ឌាឈ្មោះរពិន្ទ្រនាថតាគោរ ដែលនៅរស់សព្វថ្ងៃនេះថា "គ្មានរបងអ្វីខាំងមិនឲ្យស្រុកបូព៌ាប្រទេសនឹងបច្ឆិមប្រទេសមិនឲ្យទៅកាន់គ្នាទៅវិញទៅមកទេ" ។

ពាក្យដែលព្រះពុទ្ធទ្រង់បានសំដែងចំនួន ២៥០០ ឆ្នាំ មកហើយនៅតែថ្មីរហូតមកដល់សព្វថ្ងៃនេះ សេចក្ដីត្រិះរិះរបស់ព្រះអង្គពុំមានចាស់ទៅឡើយ ពីព្រោះពាក្យប្រដៅក្នុងសាសនាព្រះអង្គទាំងប៉ុន្មានសុទ្ធតែជាពាក្យពិតហើយស្ថិតស្ថេរចិរកាលផង សំរាប់ឲ្យសត្វលោកក្នុងវដ្ដសង្សារនេះប្រព្រឹត្តតាមគ្រប់ពេលគ្រប់វេលាបាន ។

ព្រះមហាវិហារពុទ្ធគយា

ព្រះមហាពិទូរ ក្រសេម គន្ធរបនបណ្ឌិត

ប្រែនិងរៀបរៀង

# ព្រះមហាវិហារពុទ្ធគយាក្នុងឥណ្ឌា

(ប្រែចេញពីសៀវភៅពុទ្ធសាសនាសៀមភាគទី ២ ខែវិច្ឆិកម ២៤៨១

ដែលប្រែចេញពីទស្សនាវដ្ដីមហាពោធិ ១ ត មកទៀត)

បណ្ដាសាសនាធំ ៗ ក្នុងលោកនេះ មាន៤ សាសនាផងគ្នាគឺសាសនាព្រាហ្មណ៍, សាសនាពុទ្ធ, សាសនាគ្រិស្ត, សាសនាមហាម៉ុត ៗ សាសនាព្រាហ្មណ៍ និងសាសនាពុទ្ធ ជាសាសនារបស់ជនជាតិអារ្យ៉ន, ចំណែកឯសាសនាគ្រិស្តនិងសាសនាមហាម៉ុត ជាសាសនារបស់ជនជាតិសេមីតិក (Semelic) ទីកំណើតរបស់សាសនាព្រាហ្មណ៍និងសាសនាពុទ្ធ នោះនៅក្នុងប្រទេសឥណ្ឌា, ទីកំណើតរបស់សាសនាគ្រិស្តនិងសាសនាមហាម៉ុតនៅត្រើយខាងលិចរបស់ទ្វីបអាស៊ី ៗ

សាសនាព្រាហ្មណ៍នោះ ចំណែកចេញជាពីរនិកាយ គឺនិកាយ «សៃវៈ» គប់អានព្រះសិវៈ, និងនិកាយ «វិស្ណុ» គប់អានព្រះវិស្ណុ, ពារាណសី ឬដែលហៅក្នុងកាលឥឡូវនេះថា «បេនណារេស» នោះជាស្ថានទីដ៏សក្ដិសិទ្ធិ៍ សម្រាប់ពួកឥណ្ឌូនិកាយសៃវៈ, របស់ពួកនិកាយវិស្ណុ នោះនៅស្រុក «មធុរ» ឬបរិណ្ដាវ៉ន សឹងនៅក្នុងប្រទេសឥណ្ឌាប៉ែកខាងត្បូង ៗ ពួកឥណ្ឌាដោយច្រើន តែងនាំគ្នាទៅថ្វាយបិណ្ឌៈ និងធ្វើបុណ្យទាននៅស្រុកគយា ៗ ពួកមហាម៉ុតក៏នាំគ្នាដើរផ្លូវព្រះពាចបសគ្គផ្សេងៗ ក្នុងទន្លេខ្សាច់ ទៅនមស្ការនៅស្រុក «មេកៈ» ដែលជាស្រុក

កំណើតរបស់ព្រះមហាម៉ុត ។ ពួកគ្រិស្តងនាំគ្នាទៅនមស្សការឯស្រុក «យេរុសាលេម» ដែលជាស្រុកកំណើតយេស៊ូគ្រិស្ត សឹងជាទីគោរពបូជារបស់គេ ។

ចំណែកឯពុទ្ធសាសនិកជន ក៏មានបូជនីយស្ថាន ៤ តំបន់ ដែលទាក់ទាមដោយរឿងពុទ្ធប្រវត្តិ គឺ ១ ទីប្រសូត ២ ទីត្រាស់ដឹង ៣ ទីសំដែងព្រះធម្មចក្រ ៤ ទីពុទ្ធបរិនិព្វាន ។ ទីប្រសូតនោះក៏គឺសួនលុម្ពិនី សិងនៅក្នុងប្រទេសនេប៉ាល់ជិតជួរភ្នំហិមពាន្ត, ទីត្រាស់ដឹងក៏គឺពុទ្ធគយា, ទីសំដែងព្រះធម្មចក្រដល់បញ្ចវគ្គិយទាំង ៥ ក៏គឺព្រៃឥសិបតនមិគទាយវ័ន ដែលហៅថា សារនាថ ក្នុងកាលឥឡូវនេះ, និងទីដែលព្រះអង្គបរិនិព្វាន គឺកុសិនារា សិងនៅជិតស្រុកគោរក្ខបុរៈ សម្រាប់នមស្សការបូជាតាមទំនៀម ។

កាលគ្រាព្រះអង្គគង់នៅ បានត្រាស់នឹងសាវកទាំងឡាយទាំងបព្វជិតទាំងគ្រហស្ថថា អ្នកដែលមានចិត្តកាន់ជ្រះសទ្ធា ទៅនមស្សការបូជនីយស្ថានដ៏សក្តិសិទ្ធិទាំង ៤ អន្លើនេះ ពិតាណោ ឲ្យកើតធម្មសង្វេគហើយ ក្រោយដែលស្លាប់ទៅនឹងបានទៅកើតក្នុងសុគតិ [១] ។ បូជនីយស្ថានអំបាលនេះ គេបានស្រាវជ្រាវរកឃើញជាការពិតប្រាកដអស់ហើយ អ្នកប្រាថ្នានឹងនមស្សការអាចនឹងទៅនមស្សការបានដោយងាយ ។

ដើមព្រះស្រីមហាពោធិព្រឹក្ស ជាស្ថានទីដែលព្រះអង្គត្រាស់ដឹង

---

១ មើលមហាបរិនិព្វានសូត្រ ។

ចាត់ជាស្ថាននៃសក្តិសិទ្ធិ៍ សំខាន់ សម្រាប់ពុទ្ធបរិស័ទទាំងឡាយនឹងនមស្សការបូជា ៖ រាប់វេលាតាំងអំពី ២៤០០ ឆ្នាំដែលកន្លងមក មានពួកពុទ្ធមាមកៈពល់ៗ មណ្ឌលនៃលោក បាននាំគ្នាដើរផ្លូវទៅនមស្សការជាញយៗ ពុំដែលដាច់ ។ ក្នុងរជ្ជសម័យនៃព្រះបាទធម្មាសោករាជ ព្រះមហាពោធិព្រឹក្សនេះបានត្រូវផ្សាំយកទៅដាំ នៅក្រុងអនុរាធបុរៈក្នុងលង្កាទ្វីប ដោយសេចក្តីចាត់ចែងរបស់ព្រះភិក្ខុនី សង្ឃមិត្តា ដែលជាព្រះរាជធីតារបស់ព្រះអង្គនឹងជាអ្នកដែលបានតាំងភិក្ខុនីសង្ឃ ទុកនៅលង្កាទ្វីបកាលប្រមាណ ២២២២ ឆ្នាំដែលហើយមក ។ ព្រះបាទធម្មាសោករាជបានទ្រង់សាងចម្រឹងថ្មជុំវិញព្រះវិហារនោះ ជាអនុស្សាវរីយគ្រឿងសំគាល់នៃសេចក្តីរលឹក ក្នុងកាលដែលស្តេចបានយាងទៅនមស្សការដើមព្រះមហាពោធិព្រឹក្ស ដែលនាយហៀវតស្ស័ងកត់ក្នុងសៀវភៅ "ប្រវត្តិសាស្ត្រការកសាងរបស់ពួកឥណ្ឌា" ទំព័រ ៨៦ គេបានសរសេរទុកថា "ជាថាវរវត្ថុ ដែលមានចម្លាក់ក្បាច់របនាសឹងជាស្នាដៃចាស់បំផុតក្នុងប្រទេសឥណ្ឌា" ។ អ្នកដំណើរចិនឈ្មោះ "ហ្វូនឆាង" បានបរិយាយរឿងទុកយ៉ាងច្បាស់លាស់ ក្នុងសៀវភៅរាយការដើរផ្លូវរបស់គេ អំពីសភាពនឹងហេតុការផ្សេងៗ ដែលគេបានឃើញនៅពុទ្ធគយា , ទាំងបានសរសេរសរសើរដល់លំអរបស់ព្រះវិហារកាលសម័យ ១២០០ ឆ្នាំដែលហើយមកផង (៦៨០A.C.) ព្រះរាជាក្រុងភូមាបានទ្រង់ជួសជុល

ព្រះវិហារនោះក្នុងឆ្នាំ គ.ស. ១២០០ ខាងក្រោយដែលព្រះពុទ្ធសាសនាក្នុងមណ្ឌលពិហារ បានត្រូវរំលាយបំផ្លាញបង់ ដោយស្នាដៃស្តេចរបស់ពួកមហាម៉ុត នាយពក្ទិយារខិលយ៉ក្នុងឆ្នាំ គ.ស. ១២០០ អ្នកសរសេរដើម ទ្រង់ទ្រាយសេចក្តីបេះដូង មានសេចក្តីយល់ឃើញថា "សេចក្តីអប្បុនទព្រះពុទ្ធសាសនាក្នុងប្រទេសឥណ្ឌានោះ ដោយហេតុត្រូវរុករានទន្ទ្រានដីកំណាច របស់ពួកមហាម៉ុត ។ ដរ.កិជន បានសរសេរក្នុងសៀវភៅ "សិក្សាសាសនាក្នុងប្រទេសបូណា" ទុកថា "ការរុករានរបស់ពួកមហាម៉ុតចូលទៅប្រទេសឥណ្ឌាក្នុងសតវត្សរ៍ទី ១១ គ្រានោះពេញទៅដោយការចំបាំងកាប់សម្លាប់គ្នាឥតល្ហែក ហើយក្នុងវេលាព្រមគ្នានោះសង្គ្រាមដើម្បីសាសនាយ៉ាងក្រពុលមុខក៏ផ្សាយទូទៅក្នុងដែនឥណ្ឌាភាគខាងលើ ។ ព្រះពុទ្ធ-សាសនាទើបរៀវពេយចុះ ។ ការជួសជុលព្រះវិហារក្នុងគ្រាក្រោយ ដោយព្រះបាទមិនដនបានបញ្ជូនជាងរបស់ព្រះអង្គទៅត្រួតត្រាមើលការជួសជុល តែដោយហេតុការសុគតរបស់ព្រះអង្គដោយបច្ចុប្បន្នទាន់ហន់ នឹងការខូចព្រះរាជាណាចក្រទាំងអស់ដល់អង់គ្លេសក្នុងឆ្នាំ គ.ស. ១៨៨៥ សេចក្តីប៉ុនប៉ងដែលនឹងគិតជួសជុលព្រះវិហារ ក៏ត្រូវសូន្យទៅផង ។ តែមកដល់ក្នុងឆ្នាំ គ.ស. ១៨[illegible] រាជការអង់គ្លេសក៏បានជួសជុលឡើងជាថ្មីម្តងទៀត ដូចមានប្រាកដដែលយើងឃើញក្នុងកាលសព្វថ្ងៃនេះ ។

ក្នុងចុងឆ្នាំ គ.ស. ១៨៩០ ស៊ើរគ្រៀសាន់គោលឡិកទ័រ នៃស្រុកគយា បានឃើញសភាពដ៏ទ្រុឌទ្រោមប្រាសចាកអ្នកយកចិត្តទុកដាក់មើលថែទាំ ទើបបានប្តឹងទៅកងការអង់គ្លេស សូមបង្ហោនព្រះវិហារនោះឲ្យនៅក្នុងស្តេចមើលថែទាំរបស់ក្រុមដួសផុលបុកណាវត្ត ក្នុងប្រទេសឥណ្ឌា ហេតុការទាំងនេះ បានកើតឡើងក្នុងដើមឆ្នាំ គ.ស.១៨៩១ ។

ក្នុងខែយាំងវីយេរ គ.ស. ១៨៩១ លោកអនាគារិកធម្មបាលបានដើរផ្លូវទៅនមស្សការស្ថានទីដ៏សក្តិសិទ្ធិនេះ កាលលោកឃើញសភាពបាក់បែកនៃព្រះវិហារក៏កើតសេចក្តីសង្វេគស្លុតចិត្តជាច្រើនលោកបានសម្រេចក្នុងចិត្តថា នឹងនៅក្នុងទីនោះ ដើម្បីនឹងរក្សាថែទាំព្រះវិហារហើយនឹងដឹកនាំភិក្ខុក្នុងប្រទេសផ្សេង ៗ មកនៅផងក្នុងឆ្នាំ គ.ស. ១៨៧៣ ស្តេចភូមាបានបញ្ជូនពេជ្រទីលបិត្តាទៅថ្វាយជាគ្រឿងសក្ការបូជាព្រះស្រីមហាពោធិព្រឹក្ស ព្រមដោយរបស់ដ៏មានដំឡៃជាច្រើនយ៉ាង ទៅប្រទានជាឆ្នាន់ដល់មហន្ត ដែលមាននាមថា "ហេមនារាយណា សិរៈ" ផង, ព្រះអង្គបានធ្វើសេចក្តីព្រមព្រៀងចុះសម្រុងនឹងពួកមហន្តថា "ត្រូវអនុញ្ញាតឲ្យភិក្ខុសង្ឃក្នុងពុទ្ធសាសនាទៅនៅប្រចាំក្នុងទីពុទ្ធគយា បានជានិច្ច ក្រោយដែលបានធ្វើសេចក្តីចុះសម្រុងគ្នាហើយ ភូមាបានសាងមន្ទីរយ៉ាងជាទីទុកដាក់គ្រឿងសក្ការបូជាដ៏មានដំឡៃ ដែលស្តេចភូមាថ្វាយព្រះស្រីមហាពោធិព្រឹក្ស និងសាងវត្តជាទីសម្រាប់ភិក្ខុសង្ឃអាស្រ័យនៅផង ។

តែទាំងខាងកងការទាំងខាងពួកមហន្ត មិនបានយកចិត្តទុកមើលថែទាំព្រះវិហារនោះឡើយ ទាល់តែដល់គ្រាសាន់ បានប្តឹងទៅដល់កងការ ៗ ពួកភិក្ខុលង្កាបានអាស្រ័យក្នុងវត្តភូមា (នៅពុទ្ធគយា) ដែលភូមាសាងឡើងនោះ គ្រាដំបូងតាំងពីខែសូយែត គ.ស. ១៨៩១ ដល់ខែហ្វេវ្រីយេ គ.ស. ១៨៩៣ លើកទីពីរ តាំងពីខែហ្វេវ្រីយេ គ.ស. ១៨៩៥ ដល់ខែហ្វេវ្រីយេ គ.ស.១៩១ ដ៏ជាខែដែលពួកភិក្ខុអំបាលនោះ ត្រូវបង្គាប់ឲ្យចេញចាកបរិវេណស្ថានទីពុទ្ធគយា ដោយសារដីការបស់សាលាជាន់ខ្ពស់នៃស្រុកបង្កាល ៗ

ពួកពុទ្ធសាសនិកជន ដែលអាស្រ័យពុទ្ធគយាក្នុងវេលានោះមិនដែលធ្វើសេចក្តីក្តៅក្រហាយដល់អ្នកឯណាទីមួយឡើយ ក្នុងឆ្នាំ គ.ស. ១៩០២ យីពុនម្នាក់ឈ្មោះឧកាកុរៈ ព្រមដោយស្វាមី វិវេកានន្ទទីងនាងនិវេទិត បានដើរផ្សារទៅមើលស្ថានទីពុទ្ធគយា ហើយបានធ្វើការប្រជុំទីងពួកមហន្ត និយាយអំពីលំនៀងទីងតាំងសាលាសមាគមតំណួ-យីពុន ឡើងនៅពុទ្ធគយា. រដ្ឋបាលបានលុបដងដំណឹងនោះភ្លាម, ហេតុនោះក្នុងឆ្នាំ គ.ស. ១៩០៦ ក្រមការស្រុកប័តនា ទើបមានបង្គាប់ទៅពួកមហន្ត ឲ្យនាំសេចក្តីឡើងប្តឹងអំពីពុទ្ធសមាគមនៅពុទ្ធគយា (សមាគមដែលលោកធម្មបាលបានសាងឡើង) ដើម្បីទីងបានដេញពុទ្ធសាសនិកជនឲ្យឃ្លាតឆ្ងាយចេញអំពីស្ថានដ៏សក្តិសិទ្ធិឲ្យអស់ទៅ សេចក្តី

ពិត រឿងនេះ មិនមែនជាហេតុដែលរដ្ឋបាលនឹងគប្បីសន្ទិះសង្ស័យឡើយ តែដូចជូនវេលានោះរដ្ឋបាលឥណ្ឌៀសង្ស័យក្នុងសេចក្ដីយកចិត្តទុកដាក់ក្នុងការរំគាយនយោបាយរបស់ពួកយីពុនដែលនៅក្នុងឥណ្ឌៀដោយច្រើន ហេតុនោះកាលបានឮដំណឹងយីពុននឹងបើកសមាគមឥណ្ឌៀ - យីពុនរែក ទិទីនៅពុទ្ធគយាផងហើយ ក៏រិតតែធ្វើឲ្យរដ្ឋបាលសង្ស័យ ព្រួយបារម្ភណាស់ឡើង ទើបមិនអាចនឹងទ្រាំមើលការដែលយីពុនធ្វើតទៅទៀតបាន ក្នុងទីបំផុតក៏គឺពួកមហន្ដបានត្រូវបង្ខំចិត្តឲ្យចាប់រឿងប្ដឹងគ៉ា ដល់សាលាជំនុំ ដោយសេចក្ដីបំណងនឹងបរពួកពុទ្ធបរិស័ទ ឲ្យចេញចាកពុទ្ធគយាទាល់តែអស់ សេចក្ដីបានដំណើរទៅតាំងអំពីឆ្នាំ គ.ស. ១៩០៧ រហូតដល់ខែហ្វេវ្រិយេរ គ.ស. ១៩១០ ផលក្នុងទីបំផុតពុទ្ធសមាគមរបស់លោកធម្មបាលក៏តោងចាលចាញ់ ហើយនឹងត្រូវចេញចាកទីត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធនៃខ្លួន ដោយសេចក្ដីទើសទាល់ព្រោះហេតុការនៃស្រុកទេស តាំងអំពីនោះមក គ្មានពុទ្ធសាសនិកជនរូបណានឹងទៅសំណាក់អាស្រ័យនៅ ៗ ពុទ្ធគយាបានឋិតថេរឡើយ ។

ក្រោយអំពីសង្គ្រាមសាសនាកើតឡើង ទីសក្ដិសិទ្ធិ គឺយេរុសាលេមបានធ្លាក់ទៅក្នុងកណ្ដាប់ដៃពួកមហាម៉ាត់ ទោះបីដូច្នោះ ពួកគ្រិស្ដាំងពល់ ៗ និកាយ ក៏នូវបានអនុញ្ញាតឲ្យអាស្រ័យនៅ ៗ ទីយេរុសាលេមទាំងមានអំណាចសាងវត្តវិហារបានតាមលទ្ធិរបស់ខ្លួន ដោយមិនមាន

ទើសទែងអ្វីឡើយអំពីពួកមហាម៉ាត់, តែការមើលថែទាំទីនោះធ្លាក់ទៅក្នុងកណ្ដាប់ដៃគួរគី ដើម្បីនឹងជៀសចាកការឈ្លោះវិវាទ ដែលអាចនឹងកើតមានឡើងនោះ រដ្ឋាភិបាលមហាម៉ាត់ក៏សំដែងទឹកចិត្តអើពើដល់គណៈគ្រីស្ដាំង ដោយអនុញ្ញាតឲ្យនៅនឹងសាងវត្តវិហារបានតាមគាប់ចិត្ត ចំណែកឯពួកគ្រីស្ដាំងក៏មានចិត្តសន្ដោសតាមនោះ ហើយនឹងពេញចិត្តក្នុងការអើពើនោះពន់ប្រមាណ រដ្ឋាភិបាលមុស្លីមឲ្យអំណាចដ៏គាប់តាមគន្លងធម៌ដល់ពួកគ្រីស្ដាំង ទោះបីទីយេរុសាលេមធ្លាក់ទៅក្នុងកណ្ដាប់ដៃគេក៏ដោយ គេនៅអើពើដល់ម្ល៉េះ តែរដ្ឋាភិបាលអង់គ្លេស បដិសេធការធ្វើដំណោះដល់ពួកពុទ្ធសាសនិកជនក្នុងឥណ្ឌា ប្រហែលជារដ្ឋាភិបាលអង់គ្លេសមានក្ដីបារម្ភទៅថា ពួកយីពុននឹងកាន់យកពុទ្ធគយា ទុកជាទីផ្សាយការស្រុកទេសរបស់ខ្លួនក្នុងឥណ្ឌា, ដើម្បីការពារខ្លួន ឲ្យផុតចាកការស្រុកទេសដ៏ស្មុកស្មាញដូចពោលមកនេះ រដ្ឋាភិបាលអង់គ្លេសទើបគិតថា ការដែលនឹងបិទទ្វារមិនឲ្យពួកយីពុនទៅធ្វើអុកឡុកនៅទីពុទ្ធគយាពេញជាស្រួល ហើយក៏បិទមែនតាមដែលគិតនោះ ។

ការដែលរដ្ឋាភិបាលអង់គ្លេសធ្វើដូច្នេះ មិនបានឲ្យសេចក្ដីយុត្តិធម៌ដល់បណ្ដាប្រជារាស្ត្ររបស់ខ្លួនដែលរាប់អានព្រះពុទ្ធសាសនាឡើយ ដ្បិតក្នុងប្រទេសភូមា អារក័ន ចិត្តកុង និងស៊ិកកិម មានអ្នកស្រុកដែលរាប់អាន

ព្រះពុទ្ធសាសនាប្រមាណ ១២ លាននាក់ ក្នុងលង្កាមានប្រមាណ ២ លាន
នាក់អំពាលនេះសុទ្ធតែជាពស្ត្ររបស់អាណាចក្រអង់គ្លេសដោយត្រង់ ។

សង្គ្រាមលោកដែលហើយមកនោះ បានធ្វើឲ្យការស្រុកទេសរបស់
លោកប្រែប្រួលទៅជាច្រើន សេចក្ដីខ្លាចការរុករានរបស់អាល្លឺម៉ង់ក៏ថយ
ទៅ យេរុសាលេមក៏ត្រឡប់បានមកនៅក្នុងអំណាចរបស់ពួកគ្រិស្តាំងត៍
ដូចដើម ពួកយីពូនអ្នកដែលត្រូវសង្ស័យមកអំពីមុន ក៏ត្រឡប់ក្លាយជា
មិត្តនឹងពួកអង់គ្លេស ហើយបានអំណាចអំពីអង់គ្លេសឲ្យជាអ្នកមើល
ថែទាំមហាសមុទ្រឥណ្ឌា សេចក្ដីឧបការជួយជ្រោមជ្រែងផ្សេងៗ ដែល
ពួកយីពូនសំដែងឲ្យប្រាកដដល់អង់គ្លេសក្នុងកាលសង្គ្រាមលោកនោះ
ធ្វើឲ្យពួកអង់គ្លេសឃើញចិត្តនឹងអំណរគុណបុណ្យយីពូនជាច្រើន ។

យេរុសាលេមដែលបាត់ទៅយូរណាស់ហើយ ក៏ត្រឡប់មកនៅក្នុង
ដៃពួកគ្រិស្តាំងត៍តាមដើមវិញ មេកះក៏នៅក្នុងអំណាចរបស់មហាម៉ាត់
បេនណារេស (ពារាណសី) ទីងពុទ្ធគយាក៏នៅក្នុងសេចក្ដីគ្រប់គ្រងរបស់
ពួកសែវៈ នឹងពួកវិស្ណុ ។ ចំឡែកតែពុទ្ធគយារបស់យើងប៉ុណ្ណោះដែលនៅ
ក្នុងកណ្ដាប់ដៃរបស់ពួកអ្នកតាំងសាសនា សឹងត្រូវគេបោះបង់ចោល ដោយ
ឥតអ្នកណាយកចិត្តទុកដាក់មើលថែទាំ កំពុងតែត្រូវពួកបរិវារនៃសែវៈ ម-
ហន្តធ្វើឲ្យថោកទាបកិត្តិយសម្ដេចពួកយើងក៏ព្រមឲ្យគេធ្វើផ្ដេសផ្ដាសយ៉ាង
ព្រៃផ្សៃដូច្នេះ , ពួកមហាម៉ាត់គេសុខចិត្តឲ្យពួកគ្រិស្តាំងត៍សាងវត្តវិហារ

ទីងអាស្រ័យនៅក្នុងស្រុកយេរូសាលេម តាមសេចក្ដីគាប់ចិត្តរបស់ខ្លួន តែបែរមកមើលខាងពួកយើង ឲ្យកើតសេចក្ដីស្លុតចិត្តជាបំផុតដែលមិនបាន ទទួលសេចក្ដីមេត្តាករុណា និងសេចក្ដីយុត្តិធម៌ដូចគេ ។

ពួកសាសនិកជននៅទីនោះមានចំនួនតិច ទើបជាហេតុឲ្យខ្សោយជាធម្មតា ហេតុនោះទើបថាមុខងារនៃរដ្ឋបាល ដែលនឹងគប្បីពិនិត្យមើលឲ្យដឹងថា គេអំពាលនោះជាត្រូវអ្នកឯណានីមួយកំហែងបៀតបៀនឬទេ? បើជាមិនហៅថាត្រូវកំហែងដោយត្រង់ ៗហើយតើនឹងហៅថាអ្វីទៅវិញ ដែលបណ្ដាសាសនិកជនមិនបានទទួលអនុញ្ញាតឲ្យសំណាក់អាស្រ័យនៅទីពុទ្ធ-គយាសិងជាបូជនីយស្ថានដ៏សក្ដិសិទ្ធិរបស់គេ? ។

រឿងរ៉ាវផ្សេង ៗ នៃព្រះវិហារដ៏មានមកដោយលំដាប់ដរាបដល់សព្វថ្ងៃនេះ រមែងធ្វើឲ្យពុទ្ធគយាទៅជាស្ថានដ៏សំខាន់នៃត្រៃលោក សម្រាប់ពួកពុទ្ធបរិស័ទទូទៅក្នុងលោក ព្រះពុទ្ធមេត្តេយ្យ ដែលជាអ្នកដំណពុទ្ធវង្សនៃព្រះគោតមនឹងស្ដេចមកត្រាស់ដឹងនៅទីពុទ្ធគយាទៀតដែរ ពុទ្ធសាស-និកជនទាំងឡាយជឿថា ព្រះពុទ្ធគ្រប់ ៗ អង្គក្នុងអតីតកាល និងព្រះពុទ្ធគោតមរបស់យើងក្នុងបច្ចុប្បន្ននោះ សុទ្ធតែទ្រង់មកត្រាស់នៅទីពុទ្ធគយាទាំងអស់ ហេតុនោះពុទ្ធគយាទើបជាស្ថានដ៏សក្ដិសិទ្ធិរបស់ពុទ្ធបរិស័ទទាំងឡាយនៅគ្រប់តទិវត្តកាល ។

ដើមព្រះមហាពោធិដែលត្រូវផ្សាំអំពីដើមនៅពុទ្ធគយា ហើយនាំយកទៅដាំនៅអនុរាធបុរៈក្នុងកោះលង្កានោះ នៅល្អបរិបូណ៌ដរាបដល់សព្វថ្ងៃនេះ មានមនុស្សទៅនមស្សការយ៉ាងពោរពេស :នោះត្រឹមតែមែកដែលបំបែកទៅ ក៏នៅមានមនុស្សសំដែងសេចក្តីគោរពដល់ម៉្លេះទៅហើយ បើប្រែះលើដើម ៗ នោះ សេចក្តីគោរពគប់អានរបស់គេគង់នឹងទ្វេឡើងប៉ុន្មានទៅ ខ្ញុំមិនបាច់អធិប្បាយ លោកអ្នកទាំងឡាយគង់ជ្រាបបានជាប្រាកដ ; ព្រះបាទសិរិមេឃាវាម ជាព្រះរាជានៃកោះលង្កា បានទ្រង់សាងសង្ឃារាម ១ ខ្នងទុកនៅពុទ្ធគយា សឹងប្រាកដថា គង់នៅរុងរឿងឋិតថេរដរាបមកដល់វេលាដែលអ្នកចារិក (អ្នកដំណើរ) ចិនម្នាក់បានដើរទៅដល់ស្ថានដ៏សក្តិសិទ្ធិនោះ ព្រះពុទ្ធឃោសាចារ្យដែលយើងអាចឲ្យឈ្មោះបានថា ជាអ្នកជ្រោមជ្រួយព្រះពុទ្ធសាសនាឡើងក្នុងសម័យកណ្ដាល ក៏បានដើរផ្លូវទៅលង្កាអំពីពុទ្ធគយានោះឯង ។

ពួកឥណ្ឌូមហន្តអាចអាងថាទីដីត្រង់ដែលសាងព្រះវិហារនោះ ជារបស់គេ ឯពុទ្ធសាសនិកជន ដែលមានចំនួនទាំង ៤៧៥ លាននាក់ក្នុងលោកនេះ ហេតុម្តេចទើបមិនបានទទួលមរតក ដែលផ្ទេរមកអំពីបុព្វបុរសរបស់ខ្លួន កាលមុននោះយេរុសាលេមបានធ្លាក់ទៅនៅក្នុងកណ្ដាប់ដៃពួកមហាម៉ាត់ តែវេលានេះ ពួកអង់គ្លេសបានដណ្តើមយកមកវិញ ហើយតទៅយើងមិនគោងសង្ស័យថា ពួកអង់គ្លេសនឹងបណ្ដោយឲ្យ

យេរូសាឡេមឲ្យធ្លាក់ទៅក្នុងកណ្ដាប់ដៃពួកមហាម៉ាត់ទៀត ពុទ្ធគយាជាស្ថានដ៏សក្តិសិទ្ធិសម្រាប់ពុទ្ធសាសនិកជននៅក្រៃលែងនោះទាំង ៣ គាត់ទៅទៀត បើនិយាយតាមផ្លូវយុត្តិធម៌ និងផ្លូវមេត្តាករុណាដ៏ស្មោះហើយ ពុទ្ធគយាសមគួរត្រឡប់បានមកជារបស់ពុទ្ធសាសនិកជន ដែលជាម្ចាស់ដើមវិញដោយពិតប្រាកដ បិតាប៉ុណ្ណោះដែលអាចដឹងបន្ទុកសេចក្ដីស្រឡាញ់របស់ខ្លួនដែលមានដល់បុត្រ បុត្រប៉ុណ្ណោះដែលអាចដឹងបន្ទុកសេចក្ដីស្រឡាញ់របស់ខ្លួនដែលមានដល់បិតា, ម្ដាយបិញ្ចឹមមិនអាចដឹងបន្ទុក ឬសំដែងសេចក្ដីស្រឡាញ់ស្មោះរបស់ខ្លួនដូចយ៉ាងមាតាបង្កើតបានឡើយ ពួកមហន្តដែលជានិកាយសៃវៈនឹងជាសិស្សរបស់សង្ករាចារ្យមើលទៅមិនមានថ្ងៃដែលនឹងស្រឡាញ់ពុទ្ធសាសនាត្រាំទៅក្នុងដួងចិត្តរបស់គេទេ កាលមហាសង្គ្រាមលោកដែលហើយមក ពុទ្ធសាសនិកជនរហូតដល់ជាតិទីបេត៍នៅខាងអង់គ្លេសនាំគ្នាជួយជ្រោមជ្រែងរដ្ឋបាល ទាំងមនុស្សទាំងទ្រព្យសម្បត្តិប្រាក់កាសយ៉ាងពេញបន្ទុក ពួកយីពុនក៏បានក្លាយមកជាមិត្តនឹងអង់គ្លេស ជាការយុត្តិធម៌ហើយ បើព្រះវិហារពុទ្ធគយាត្រឡប់បានមកជាកម្មសិទ្ធិរបស់ពុទ្ធសាសនិកជនវិញ ហើយនៅក្រោមសេចក្ដីមើលថែទាំរបស់អង់គ្លេស ។

ភ្នំអាដាមពា៎កក្នុងកោះលង្កា ដែលប្រជាជនរាប់អានថាសក្ដិសិទ្ធិនោះនៅក្នុងសេចក្ដីគ្រប់គ្រងថែទាំរបស់ភិក្ខុសង្ឃក្នុងព្រះពុទ្ធសាសនា ទាំង

ពួកឥណ្ឌូ ទាំងពួកមហាម៉ាត់ បានទទួលសេចក្ដីបដិសណ្ឋារៈយ៉ាងស្មើភាគ អំពីព្រះភិក្ខុសង្ឃអំបាលនោះ, នៅវត្តព្រះបទុមកែវ (នៅលង្កា) មានមហាជនមិនរើសជាតិសាសនា អាចចូលទៅនមស្សការបាន ដោយប្រាសចាកអន្តរាយឯណាទីមួយឡើយ, ពុទ្ធសាសនិកជន ស្រឡាញ់សាន្តិភាព ទើងមានសេចក្ដីអត់ធ្មត់ជានិច្ច ទោះបីត្រូវគេកំហែងសង្កត់សង្កិនក៏ដោយ រវាងវេលា ២.៤០០ ឆ្នាំព្រះពុទ្ធសាសនាមួយប៉ុណ្ណោះ ដែលបានផ្សាយទូទៅ គ្រប់ច្រកល្ហកក្នុងលោកដោយប្រាសចាកឈាមស្រក់ សូម្បីមួយដំណក់ឡើយ សាសនាព្រះពុទ្ធជាសាសនាដែលពេញទៅដោយសេចក្ដីមេត្តាករុណា សមគួរហើយឬ ដែលវិហារដ៏សក្ដិសិទ្ធិរបស់ព្រះពុទ្ធអង្គដែលជាអ្នកលះបង់យ៉ាងធំ ហើយបានបំពេញទុក្ករកិរិយាយ៉ាងលំបាកក្រក្រីជាបំផុត អស់វេលា ៦ ឆ្នាំ ដោយសេចក្ដីប្រាថ្នាដ៏ខ្លាំងក្លាដើម្បីយកយោងព្រះអង្គ ទើងស្រោចស្រង់សត្វលោកឲ្យផុតអំពីសង្សារវដ្ដ ដាក់ដល់ត្រើយគឺព្រះនិព្វាន ត្រឡប់មកត្រូវពួកសិស្សដ៏ឥតប្រាជ្ញារបស់ឥណ្ឌូមហាទ្ត ធ្វើឲ្យអប្បឫនពសី? ព្រះធម៌ជាច្បាប់គ្រប់គ្រងលោកនេះ ពួកមហាទ្តមិនបានគិតទេ ទើងមិនថាជាសេចក្ដីសុចរិតយុត្តិធម៌ទើងល្អប៉ុន្មានទេ ដែលពុទ្ធគយាត្រូវធ្លាក់មកនៅក្នុងកម្មសិទ្ធិរបស់ម្ចាស់ដើមវិញតាមគន្លងធម៌, មរតកបិតាត្រូវធ្លាក់ទៅជារបស់កូនប្រុស ហេតុនោះ ទើបមិនមានបញ្ហាអ្វីឡើយដែលពុទ្ធគយាទើងគួរធ្លាក់ទៅជារបស់

ពុទ្ធសាសនិកជន យើងយល់ថា បើពួកមហាន្តព្រមក្នុងរឿងនេះហើយ ពុទ្ធសាសនិកជនទាំងឡាយនឹងតបស្នងសងគុណគេវិញ ឲ្យយ៉ាងពេញចិត្តតែម្តង ទាំងរដ្ឋបាលអង់គ្លេសក៏មិនគួរនឹងភ្លេចសំដែងសេចក្តីមេត្រីដល់ពុទ្ធសាសនិកជន ដោយអំពើដូច្នេះឡើយ កាលនឹងប្រមូលសេចក្តីស្លូតត្រង់ ដោយយុត្តិធម៌កំពុងឈានចូលមកហើយ យើងទាំងឡាយកំពុងទន្ទេញដោយសេចក្តីគោរពយ៉ាងខ្ពស់ថា "ពុទ្ធគយានឹងធ្លាក់មកជាសម្បត្តិរបស់យើងក្នុងមិនយូរនោះឯង សមាគមមហាពោធិក្នុងឥណ្ឌា
✓ បានព្យាយាមធ្វើការងារមកហើយកប់វេលាជាច្រើនឆ្នាំ ដោយសេចក្តីបំណងដែលនឹងចូលទៅកាន់យកកម្មសិទ្ធិរបស់ព្រះវិហារត្រឡប់មកវិញឲ្យបាន, ប្រាក់ជាច្រើនបានចាត់ចាយទៅក្នុងការងារនេះ ហើយកំពុងតែចាត់តថែមទៀតរឿយៗ មកដរាបដល់សព្វថ្ងៃនេះ ៗ

# ប្រជុំពាក្យកាព្យ

## ភាគទី ២

## ជារបស់ផ្សេងអោហារគ្នា

(តទី ៦)

៙ អនិច្ចាចិត្តអើយអីដល់ម្ល៉េះ
ដូច្នេះជីវិតឃើញជាក្ស័យ
ព្រោះជឿតសង្ខារសែនសង្ស័យ
កែវថ្លៃចូរស្ដាប់បងថ្លៃទុក្ខ ។
៙ ឮផ្គរហើយថែមទាំងភ្លៀងធំ
ខកក្រៀមក្រំសមសៀតចុក
ព្រោះស្មានដោយខ្លួនមិនជួនមុខ
កើតទុក្ខកុំអ្វីប្រៀបពុំបាន ។
៙ នេះគឺជាកម្មផងខ្លួនហើយ
កែវអើយដូចក្នុំសង្កត់ប្រាណ
ទ្រូងទ្រាំផ្សាជាំមិនស្រាកស្រាន្ត
មិនមានល្ហែល្ហើយក្តីខ្វល់ខ្វាយ ។
៙ គាកព្រោងប្រុះធ្លុះរហាស់
អស់ទាំងមនុស្សម្នាសុខក្នុងកាយ
ព្រាត់គ្នាជួបគ្នាគេសប្បាយ
តែប្រាណឯកាយឯកោនៅ ។
៙ កំព្រាវេទនាសែនរំខាន
ហើយថែមទាំងមានសេចក្តីក្តៅ

ម៉ោងប្រាំមួយចិត្តព្រួយព្រោះទឹកទៅ
ឱហ្វរណេះនៅប្អូនទៅឯណា ។
៙ ចិត្តទឹកព្រោកមិនមានក្អែប
ចង់ដឹងកលកិច្ចពីស្ងួនក្ដា
ទឹករៀមប្អូនស្ងៀមប្អូនបរបា
ប្អូនមួយមានគ្នាទីងសាសង ។
៙ អនិច្ចាខ្លួនបងដូចសមុទ្រ
មៀងមើលងងឹតមិនយល់ត្រើយ
ព្រាត់មួយឆ្នាំជួបមួយថ្ងៃព្រាត់វិញហើយ
ម៉េះសមកន្ត្រើយបងអសារ . . . . . . .
. . . . . . . . . . . . . . . . .
. . . . . . . . . . . . . . . . .

ស៊ីមនោមៃ (ប៉ៃន)

ពាក្យកាព្យបទនេះមានច្រើនទៅទៀត ចាំបានតែប៉ុណ្ណេះ នាំយកមកបោះពុម្ពដើម្បីរក្សាសំនួនទុក ។

៙ ផ្កាអើយ ៗ ផ្កាផ្កាបុប្ផាព្រៃ
រីកប៉ៃប្រែប្អូកប៉ប្រិមញញឹមស្រស់
ជូនព្រះពាយពាយពាក់មកស្រណោះ

មិនដឹងសោះគិតម្តេចម្តាប្រែផល់ ៗ

៙ ជួបជួនអរុណរៀងរពីបុព្វៃ

ក្នុងមាល័យមាលាលាតក៏ទាបសល់

ជូនដំនោរទៅព្រះពាយរំភាយរល់

សែនស្រងល់សល់ស្រងាត់បាត់ស្មារតី ៗ

៙ ផ្កលអើយ ៗ ផ្កលផ្កាបុប្ផាព្រឹក្ស

ចិត្តរឭកនឹករលេញមិនចេញស្តី

អត់សង្កត់ទៅជាខ្វល់បែកពីរបី

នឹងស្រដីក្រែងពុំបានដូចប្រាថ្នា ៗ

៙ តែងរឭកនឹករលែកដេកមិនលក់

សែនវិតក្កអផ្សុកប៉ុកក្នុងឧរា

នេត្រលង់ប្រែងរឭកនឹកផ្កលផ្កា

នឹងថ្លែងថាឲ្យបានសុខនឹងទុក្ខខ្វល់ ៗ

មិនស្គាល់ឈ្មោះ ៗ

៙ សារលិខិតនឹកខឹងចិត្តលិខិតសារ

ចិន្តាស្មានហើយមិនបានដូចចិន្តា

មួម៉ងសៅក្តៅឧរាសែនមួម៉ង

សោកសែនទ្វីស៊ីទឹកនេត្រដោយសែនសោក ៗ

៙ បងឃ្លាតប្អូនទួទវិយោគដោយឃ្លាតបង
កន្លងឆ្នាំគ្រងចាំកាយឆ្ងាយកន្លង
ចិត្តគិតទួទល្អងគ្មានល្អៀងទៀងទឹកចិត្ត
សព្វថ្ងៃក្តុលអួលក្តៅចិត្តសៅសព្វថ្ងៃ ៗ

៙ គិតអាល័យថ្ងៃគ្មានភ្លេចអាល័យគិត
ស្និទ្ធស្នាលស្នេហ៍ព្រួយប្រាណប្រែក្តីស្នេហ៍ស្និទ្ធ
ក្រាំកាយឆ្ងាយខ្វល់កលក្រាំកាយ
សារសៀមថ្ងៃងមកឲ្យជ្រាបក្នុងសៀងសារ ៗ

៙ ឆោមឆាយឆើតកើតមេត្តាណាឆោមឆាយ
ណាយទឹកសេចក្តីព្រួកគ្មានទឹកណាយ
សញ្ញាស័ត្យប្រយ័ត្នកាយស្តាយសញ្ញា
គិតដូចស្មានបើពុំបានស្មានដូចគិត ៗ

៙ អសារសោះសូន្យគំនិតសោះអសារ
វាស្នាតិចបុណ្យក៏តូចតាមវាស្នា
ឃ្លាតបើទុកទៅជាតិមុខកុំឲ្យឃ្លាត
ខ្ញុំបំណងសាងផ្សងដូចបំណងខ្ញុំ ៗ

៙ ជាតិក្រោយទៅទៀតសូមសុំជួបសព្វជាតិ
ទៀតបងស្មានអ្នកក៏ស្មោះនឹងបងទៀត

វាចាសុំកុំឲ្យឃ្លាតពីវាចា
លុះដល់ព្រះអរហត្តកាត់បានលុះ ។
๏ ករុណាមិត្រឲ្យចិត្តនៅករុណា
មេត្តាសោះអស់ស្រឡាញ់នៅមេត្តា
រៀមរ័កស្នោះស្ម័គ្រចូរអ្នកស្ម័គ្ររៀមវ៉
ថ្លែងវាចាប្រាថ្នាសុំបានដូចថ្លែង ។
๏ លិខិតសារលេខាសានមធុរស
មធុរឿងរៀមរ័កអ្នកស្ម័គ្រស្នោះ
សូមឲ្យអនុគ្រោះកុំក្រោធា
កុំក្រោធក្រនួនខ្លួនរៀមឥតទីពឹង ។
๏ ឥតទីពាក់ពំនឹងនៅកំព្រា
កំព្រាប្រាណពុំមានញាតិមិត្រជាគ្នា
ជាកងទុក្ខវេទនាជាចិទ្ត្រៃយ
ជាប់ចិត្តត្រេកកាលក្រឡេកជួបនេត្រ ។
๏ ជួបនេត្រនឹកស្នោះស្ម័គ្រឥតឧបមៃយ
ឧបមាកាលថ្ងៃចាកចោលថ្ងៃ
មកបាត់ដួងវិល័យពីឧរា
ឧរៀមមករងទុក្ខ ៗ ពីព្រេង ។

◎ ទុក្ខពីព្រោះខ្លួនឯងឥតក់ស្មា
ព្រោះតែស្នេហ៍ឲ្យប្រែជាទុក្ខា
ទុក្ខអើយចំផ្ញើសារជូនមកដល់
មកដោយសេចក្តីគិតមានអាល័យ ៗ

◎ ដែលអាឡោះនឹកថ្ងៃសោកសែនសល់
ហើយសែនណែនទ្រូងខ្ញុំទ្រាំទុក្ខទល់
ទ្រាំទុក្ខទៀបដាច់ខ្យល់ខ្លាត់ពីកាយ
ពីកើតមករៀមមិនដែលទុកជួបចឹង ៗ

◎ ទុក្ខជួបចុះសមទឹងទ្រូងប្រេះខ្លាយ
ទ្រូងបែកខ្លាត់បាត់ដួងចេញពីកាយ
ទុកក្រំផ្សាជាំពុំមានសោយ
ទឹកនេត្រស្រោចស្រប់កាយមិនស្រាកស្រាន្ត ៗ

### ទុក្ខំ អនិច្ចំ អនត្តា

កកើតប្រាពោសទុក្ខទំ
ទុក្ខពាល់អស់កាលជាតិជាន់ជុំ
ទុក្ខធំក្រមទឹងល្ហែល្ហើយ ៗ

៙ កាយអើយគួរគិតឲ្យឆ្អិនឆ្អៅ
មនោមកនៅថ្វីព្រងើយ
គួរកាត់ពលវដ្តតែរកត្រើយ
នៅនេះណាឡើយនឹងស្បើយទុក្ខ ។
៙ គួរស្វែងអរហំតាំងនិពេធ
លះលោភក្រេវក្រោធមនោទុក
ភ្នែកបិទបុងចិត្តគិតរកសុខ
ភូមិកពនៃនរកគ្មានសុខសោះ ។
៙ អំបាលព្រះធម៌សំពប់លោក
បង្កើតកាល្បមកភ្លើងឆេះអស់
មិនមានទីណាសល់បន្ទោះ
នឹងភ្លើងឆេះនោះគ្មានសោះឡើយ ។
៙ សោឡសសួគ៌សុខតែបុណ្យបាន
កុសលដែលបានសាងជាត្រើយ
ទ្រទ្រង់បំរុងគ្រាន់ល្ហែល្ហើយ
កុសលអស់ហើយកើតទុក្ខគ្រប់ ។
៙ ដូចកលទិពនឹងពក្រើ
បាត់ស្មើព្លៃងងឹតឈ្លប់

ជាទីអនិច្ចំក្នុងត្រៃភព
កប់ជាតិគំរប់ជាធម្មតា ។

◎ អនិច្ចំទាំងឋានសួគ៌សោឡស
គង់វិនាសចុះចាកសួគ៌ា
អនិច្ចំពុំទៀងទាំងទេវតា
គួរឲ្យវេទនាពល់រូបកាយ ។

◎ គួរគិតឲ្យឃើញព្រះអនិច្ចំ
គួរតាំងចិត្តខ្ជាប់កុំពាយមាយ
គួរគិតបៀសចាកផ្លូវអបាយ
អស់យើងទាំងឡាយគួរអនិច្ចំ ។

◎ អនិច្ចាវេទនាជានិរន្តរ៍
រូបគង់អស់ជន្មគ្មានខានខាំង
នឹងរកទីណាពួនកំបាំង
អនិច្ចំពុំទៀងទាំងត្រៃភព ។

◎ អនិច្ចំមុខគួរឲ្យវេទនា
ខ្ទះរងវេកទុក្ខទាន់គ្រប់
ល្អុះល្អោចផ្សាខ្លោចដៃផ្សាយផ្សព្វ
ងងឹតឈឹងឈ្ងប់អប់អាប់អួរ ។

៙ អនិច្ចា មុខគួរឲ្យវេទនា
មនុស្សខ្លៅថាជាប្រាជ្ញតាប់គួរ
លោ គោ ទោ សោ មោហ៍ ម៉ៅមួ
តាំងតួតណ្ហាថាសប្បាយ ។

៙ សេចក្តីតណ្ហាសាបសូន្យទេ
ពុំគួរភប់ភេល់រូបកាយ
រឿងរូបដូចភ្លើងឆេះព្រានព្រាយ
រឿងកាយភេលភលរូបអាត្មា ។

៙ គួរគិតកុំភ្លើនឲ្យភ្លេចភ្លាំង
ទឹងកេអនិច្ចំតាំងអនត្តា
ធម្មតារូបរស់ក្នុងសង្ខារ
ធម៌ថាគង់ជារលាយបាត់ ។

៙ ខំនឹករឭកផល់មគ្គផល
ព្រះអង្គដំកល់ជាបរមត្ថ
ប្រឹងបុឹងក្នុងវង្សព្រះអរហត្ត
កាត់កម្មកិលេសប្រាសពីទុក្ខ ។

៙ មនោះអើយគួរមានះកាត់ឲ្យបាន
កុំឲ្យរំខានតទៅមុខ

ជាតិនេះជាតិនាយទឹងបានសុខ
ចៀសចាកទុក្ខមុខជាស្បើយ ។
៙ ខំគិតមានះទើបកាត់បាន
ជ្រះថ្លាសន្ដានបានយល់ត្រើយ
និរទេសទៀយណាយនិរទុក្ខហើយ
កាយអើយកាយគិតឲ្យជ្រះជ្រៅ ។
៙ និត្យទៅក្នុងលាកជាធម្មតា
លំបាកច្រើនគ្រាមិនដែលហៅ
បានស្បើយល្ហែល្ហើយសោបក្ដីក្ដៅ
នៅនេះនៅនឹងរឹងថែមទុក្ខ ។
៙ ត្រែកពាំងបីនេះល្ងង់
លន្ងោបឆុតផុងរឹងទរក
ខំទឹករៀករកទិសុខ
កុំមិកពនៃរកទុក្ខសែនសល់ ។
៙ ប្រាជ្ញខ្វះសង្សារថាបងជាប់
ពុំគួរបើកប់ឲ្យរលប់
ប្រាណបោលស្រឡះកុំឲ្យផល់
កុំខ្វល់កុំខ្វាយកុំស្ដាយថ្មី ។

៙ សង្សារនៅតែងទឹងល្ងងលោម
មិនឲ្យរំលងរួចទុក្ខភ័យ
ប្រាជ្ញប្រុះធ្លុះសព្វទាំងកពាក្រៃ
ម្តេចបាញ់កលស្រីមកសោយទុក្ខ ។

៙ ខំគិតខំកាត់កុំអាល័យ
សង្សារចៅដ្រៃក្របានសុខ
ហ្នឹងហើយជាដើមកូមិនរក
នាំបង្កើតទុក្ខពល់រូបា ។

៙ សិនធ្វើឲ្យខ្វល់សល់សែនខ្នាត
សិនធ្វើឲ្យខាតផ្លូវមេត្តា
សិនឲ្យកែកាយដួងចិត្តា
សិនឲ្យក្តៅផ្សាគ្មានល្ហែល្ហើយ ។

៙ សន្តានអ្នកទៅឥតប្រាជ្ញា
បាញ់កលតណ្ហាកើតឯក្រោយ
ឲ្យរាំធ្វើទុក្ខព្រមបណ្តោយ
នឹងផ្តោយគំនិតពិតសូន្យសោះ ។

៙ នោះពេញជាថយថោកប្រាជ្ញា
បាញ់កលតណ្ហាគ្មានចន្លោះ

កិលេសត្រាំសឹកសន្តានអស់
ម្ល៉េះម្ល៉ោះកាលណា នឹងស្វាងទុក្ខ ៗ.
៙ បើអ្នកឯណា មានទស្សនា
ប្រកបប្រាជ្ញាស្វែងរកសុខ
មានពិចារណា សេចក្តីទុក្ខ
នឹងបានរៀនត្រេកធម៌អាថ៌
៙ ព្រះពុទ្ធព្រះធម៌សង្ឃសេដ្ឋ
ប្រោសជាកំពាំងមានប្រាជ្ញ
ដឹងមគ្គផលដឹងធម៌អាថ៌
ក្នុងដួងចិន្តាជ្រះថ្លាឈ្វេង ៗ
៙ លុះយប់ស្ងាត់ស្ងាត់កាត់សង្ស័យ
រំពឹងព្រះត្រៃបិដកស្តែង
តាំងក្នុងតាំងក្រៅនៅខ្លួនឯង
កុំឲ្យវង្វេងទៅសោយទុក្ខ ៗ
៙ គន់គិតតាមដានព្រះអរហន្ត
អរហន្តលោកកាត់ហេលផុតភក់
ឆ្លងត្រើយល្ហែល្ហើយស្បើយពីទុក្ខ
សម្រេចដល់ស្រុកព្រះនិព្វាន ៗ

◎ នរណាសទ្ធាកាត់ឱ្យស្រួល
កុំឱ្យក្តៅក្តួលគិតរំខាន
កុំធ្វើឱ្យផល់ខ្វល់សន្តាន
ក្រែងខានសម្រេចក្តីប្រាថ្នា ។

◎ អស់យើងទាំងឡាយដែលកើតមក
គួរគិតរិះរកផ្លូវបញ្ញា
គួរគិតគួរគន់ពិចារណា
ឱ្យភ្លឺជ្រះថ្លាក្នុងសន្តាន

◎ ភ្លឺក្នុងទីងងឹតរបស់ក្រៅខ្លួន
នឹងមួននឹងមុជផ្លូវកម្មដ្ឋាន
នឹងជ្រះកិលេសក្នុងសន្តាន
នឹងបានសម្រេចដោយប្រាជ្ញា ។

◎ ឃើញបានបុណ្យដែលដំកល់ទុក
ស្វែងរកទីសុខដ្បិតជ្រះថ្លា
ដឹងខ្លះយល់ច្បាស់ដោយប្រាជ្ញា
បុះផ្លូវឯកគ្គតាភ្លឺសុះសាយ ។

◎ ឃើញច្បាស់ព្រះធម៌នេះសែនក្រ
ដំកល់ទុកឱ្យល្អទើបបានភាយ

តែឲ្យកំពប់ជ្រុះខ្ទាត់ខ្ចាយ
ល្អិតណាស់មិនងាយនឹងកើបបាន ។
៙ បើអ្នកឯណាប្រាស់ធម៌ពិត
ទើបគិតស្រឡាញ់ព្រះនិព្វាន
ផ្សិតកើតឡើយណាយក្នុងសន្តាន
វេទនារំខានឃើញអនត្តា ។
៙ ឃើញកើតហើយស្លាប់មុខគួរធុញ
ខ្ពះស្វែងរកបុញ្ញយសសក្តា
ស្លាប់បាត់សូន្យស្ងាត់សោះអសារ
ពោលយសសក្តាទីភូមិស្ថាន ។
៙ នឹងឃាត់អង្វរថាកុំទៅ
ឈប់សិនឲ្យនៅរូបប្ដីដ៏ថ្កាន
មានបុណ្យយសសក្តិទ្រព្យធនធាន
បរិវារក៏មានប្រើត្រៀបត្រា ។
៙ សង្ខារនោះទៀតដ៏រឹងមានះ
ឃើញថាគ្មានម្ចាស់លើផ្ទា
គ្មានព្រមអាណិតយសសក្តា
មិនស្គាល់បរិក្ខារណាសោះ ។

៙ ក្នុងកាលជាតិភពកំណើត
ឃើញហើយទើបកើតទោញចំពោះ
ឃើញច្បាស់វេទនាគ្មានសង្គ្រោះ
ចំពោះគិតខុសខាតអន្តរាយ ។

៙ ខ្លួនទៅទ្រព្យនៅចោលអសារ
បុណ្យស័ក្តិបរិវារនៅឯអាយ
ដឹងហើយឃើញហើយមិនគិតស្តាយ
បានចោលនៅអាយទៅតែខ្លួន ។

៙ ប្រសិនបើជាមានប្រាជ្ញា
គិតរកបរិវាររៀបជាក្បួន
ហៃយើងឲ្យជាប់ទៅតាមខ្លួន
នោះឃើញសមសួនថាមានស័ក្តិ ។

៙ អ្នកនោះហៅពេញជាគិតត្រូវ
សំណាងអ្នកទៅឥតធុរៈ
ព្រោះបេះបាត់ចែងដោះអន្ទាក់
ឃើញជាក់ជាបានឆ្លងដល់ត្រើយ ។

៙ ដ្បិតព្រះពុទ្ធអង្គទ្រង់ប្រែបន្ទុក
សង្សារជាតិដក់ជាប់ឯក្រោយ

កែខៃខំគិតកុំឲ្យភ្លោយ

កុំតាមបណ្ដោយផ្លូវតណ្ហា ។

◎ ដំបូរនេះគាបចូលគ្រប់រូប

គួរដោះឲ្យរបូតកុំរក្សា

គិតកាត់ដើមវង្សឫសតណ្ហា

កុំឲ្យផ្លែផ្កាជាប់ជាពូជ ។

◎ រំពឹងធមិកាថជាប្រយោជន៍

តាំងចិត្តកុំឲ្យខូចផ្លូវមេត្តា

កាត់ផ្លូវតណ្ហា ទូវអវិជ្ជា

គន់ថយតាមគ្នាខានគ្រប់រូប ។

ឧកញ៉ានភក្សត្រ ( គង់ )

---

រឿងនេះមានតទៅទៀតតែច្បាប់ដើម

បាត់រកមិនឃើញ ចាំបានតែប៉ុណ្ណេះ ។

ហិតោបទេស ភាគទី ១

"ការចងមិត្រ"

# ឧកញ៉ា ទេព ពិទូរក្រសេម - គន្ធរជនបណ្ឌិត

# ប្រែនិងរៀបរៀង (ត)

ដល់វេលារសៀលទាបហើយ ប្រើសនិងចចកក៏នាំគ្នាមកកាន់ទីលំនៅរបស់ប្រើស ។ មានក្អែកឈ្មោះសុពុទ្ធិ ជាមិត្រចាស់របស់ប្រើសអាស្រ័យនៅលើដើមចម្បក បានឃើញសត្វទាំងពីរបណ្ដើរគ្នាមកក៏ស្រែកសួរមកថា សំឡាញ់ប្រើស អ្នកនាំនរណាមកហ្នឹង? ប្រើសតបថា "សុនខចចក, ត្រូវការចងជាមិត្រនឹងខ្ញុំ ។

ប្រើសរំលឹកថា "សំឡាញ់! ការដែលជឿទុកចិត្តគ្នាភ្លាមនឹងអ្នកដែលជាអាគន្តុកទើបមកថ្មីនោះមិនគួរ មិនជាសេចក្ដីប្រព្រឹត្តដ៏ត្រឹមត្រូវឡើយ ព្រោះលោកថា :

៥៧ "អ្នកឯណាក៏ដោយ ដែលមិនបានស្គាល់ជាតិត្រកូលនិងសេចក្ដីប្រព្រឹត្ត មិនគួរឲ្យអាស្រ័យរួមគេហស្ថាន ត្មាតឈ្មោះជរទ្គវៈត្រូវប្រហារស្លាប់ ក៏ព្រោះសេចក្ដីខុសដែលបានទទួលឆ្មាឲ្យនៅផង" ។

ប្រើសនិងចចកសួរថា "រឿងនោះដូចម្ដេច" ក្អែកនិទានរឿង

## រឿងទី ៤

នៅឆ្នេរទន្លេភាគីរថី(១) លើភ្នំគ្ឫធ្រកូដ(២) មានជ្រៃ ១ ដើមធំ ក្នុងដើមមានប្រហោងរហូតដើម ។ ត្មាតជរទ្គវៈ ដោយអំណាចកម្មអំណោយផលឲ្យត្រូវលំបាកក៏មានភ្នែកងងឹតងងល់ ក្រចកសណ្ដកអស់

---

១ ទន្លេគង្គា មួយកន្លែងនោះ ហៅភាគីរថី ។ ២ ភ្នំគិជ្ឈកូដ ។

អាស្រ័យនៅលើដើមជ្រៃនោះ ។ បណ្ដាបក្សីសត្វដែលធ្វើសំបុកពងនៅដើមឈើជាមួយគ្នានោះ មានសេចក្ដីករុណាបានបែងចែកអាហារឲ្យបរិភោគល្មមបន្ដជីវិតទៅមួយថ្ងៃៗ ។ គ្រានោះ នាថ្ងៃមួយ ឆ្មាឈ្មោះទីឃិកណិ មកកាន់ទីនោះ ដោយបំណងនឹងចាប់កូនសត្វអំបាលនោះស៊ី តែលុះចូលទៅជិត កូនសត្វអំបាលនោះឃើញក៏ស្រែកខ្ញៀវខ្ញារឡើងដោយសេចក្ដីខ្លាច ជរទ្គវៈបានឮក៏គម្រាមសួរទៅថា "អ្នកណាចូលមកនុ៎ះ ហ៎ះ?

ទីឃិកណិឃើញត្មាតក៏ភ័យស្លុតព្រលឹងគិតថា "ហើយអញម្ដងនេះ មុខជាស្លាប់ហើយអញ តែ —

៥៨ ដរាបណាដែលអន្ដរាយនៅឆ្ងាយ ក៏គួរជាខ្លាចដរាបនោះ តែកាលអន្ដរាយមកជិតផ្ទាល់ខ្លួនហើយ នរជាតិត្រូវចាត់ការកែខៃឲ្យគួរតាមហេតុ ។ ឥឡូវខ្លួនយើងចូលជិតអន្ដរាយហើយ នឹងគេចរត់ទៅក៏ឃើញជាមិនផុត ចូលហួសមកហើយក៏ត្រូវតែកៃខៃដោះទាល់តាមការ ហេតុនោះ គួរយើងចូលទៅរកត្មាតឲ្យដល់ផ្ទាល់ខ្លួន គិតឃើញដូច្នេះហើយក៏ទន្ទូលលបចូលទៅរកត្មាតនិយាយថា "បពិត្រលោកអាចារ្យ! ខ្ញុំសូមសំដែងសេចក្ដីគោរពដល់លោក" ។

ត្មាតសួរថា "នរណា ហ៎ះ ។

ទីឃិកណិឆ្លើយថា "ខ្ញុំជាឆ្មា ឈ្មោះទីឃិកណិ" ។

ត្មាតគំរាមថា "ឃើ! អាចោរខូច, ចូរប្រញាប់ចេញទៅឲ្យឆ្ងាយ មិនដូច្នោះ នឹងត្រូវអញប្រហារស្លាប់ឥឡូវនេះ" ។ ឆ្មាអង្វរថា មេត្តាប្រោសស្ដាប់ពាក្យខ្ញុំសិន កាលណាលោកបានស្ដាប់ហើយ បើនៅតែឃើញថា ខ្ញុំសមគួរនឹងស្លាប់សោត ខ្ញុំក៏សុខចិត្តទទួលទោសប្រហារតាមចំណង់ ព្រោះ —

៤៩ មាននរណាឯណាខ្លះ ដែលត្រូវធ្វើទោសឬត្រូវបានទទួលកិត្តិ-យសដោយជាតិត្រកូលប៉ុណ្ណោះ; មានតែគេធ្វើទោសឬឲ្យកិត្តិយសក្នុងកាលដែលបានត្រួតពិនិត្យសេចក្ដីប្រព្រឹត្តស្រេចហើយ ។

ត្មាតតាំងបញ្ហាសួរថា អ្នកឯងចូរប្រាប់ឲ្យដឹងថា "ខ្លួនអ្នកមានសេចក្ដីប្រព្រឹត្តដូចម្ដេច?" ។

ឆ្មាឲ្យការថា "ខ្ញុំអាស្រ័យនៅទៀបទន្លេគង្គា ធ្វើកិច្ចស្នានបាប[1] ជានិច្ចសីល វៀរបរិភោគមំសាហារ កាន់ព្រហ្មចរិយសមាទានសីលចន្ទ្រាយណៈ[2] ឥឡូវនេះ ខ្ញុំបានឮពួកបក្សីដែលជាទីស្រឡាញ់នឹងជាទីទុកចិត្តរបស់លោក សរសើរកិត្តិគុណរបស់លោកថា មានសេចក្ដីចេះដឹងជ្រៅជ្រះច្រើន ប្រព្រឹត្តក្នុងសម្មាបដិបត្តិ ព្រោះហេតុនោះ ខ្ញុំមកនេះ ដើម្បីស្ដាប់ច្បាប់វិន័យ នៃសាសនាក្នុងសំណាក់លោកដែលជាអ្នកមានអាយុចាស់ជាង នឹងចេះចប់សព្វគ្រប់ក្នុងក្បួនសិល្បវិទ្យាផ្សេង ៗ កាល

១ ងូតទឹកលាងបាប ។ ២ គឺសីលដែលត្រូវរក្សាក្នុងថ្ងៃព្រះចន្ទពេញបូណ៌មី ។

បើដូច្នេះទេតើ ហេតុម្ដេចលោកអ្នកទ្រង់ទ្រូវធម៌ទើបមកគិតចំណាយខ្ញុំដ៏ជាភ្ញៀវមករកនេះបង់ ព្រោះមុខងាររបស់អ្នកជាគហបតីលោកពោលថា

៦០ គួរសំដែងសេចក្ដីអើពើដល់អ្នកដ៏ជាភ្ញៀវចូលមកក្នុងផ្ទះ ទោះបីជាសត្រូវក៏ដោយ! ព្រឹក្សជាតិក៏នៅឲ្យម្លប់សំណាក់អាស្រ័យដល់អ្នកដែលមកកាប់ ។ ទោះបីគ្មានអាហារលៀងភ្ញៀវដែលមក យ៉ាងហោចទៅ ក៏គួរជាសំដែងពាក្យអើពើបដិសណ្ឋារៈដោយល្អ ព្រោះថា –

៦១ ចំបើង (សម្រាប់បង្កាត់ភ្លើង), ទីសំណាក់អាស្រ័យ ទឹក នឹងវា-ចាផ្អែមល្ហែម ៤ យ៉ាងនេះ រមែងមិនឥតមានក្នុងផ្ទះនៃសប្បុរសសព្វកាល ។

៦២ អ្នកមកកាន់គេហស្ថាន ទោះជាក្មេង កំលោះ ក្រមុំ ចាស់ទុំក៏ដោយ យើងត្រូវទទួលអ្នកនោះ (ភ្ញៀវ) ត្រូវកាន់ថា ភ្ញៀវដែលមករកជាអ្នកខ្ពស់ជាងអ្នកណាទាំងអស់ ។

៦៣ អ្នកដែលមានចរិយាល្អ តែងតែសំដែងសេចក្ដីមេត្តាករុណាសូម្បីក្នុងសត្វដែលថយថោក, ព្រះចន្ទ្រក៏ពុំគេចវៀរការបំភ្លឺពន្លឺទៅក្នុងផ្ទះមនុស្សចណ្ឌាលក៏ទេដែរ ។

៦៤ ផ្ទះអ្នកណាដែលត្រូវភ្ញៀវត្រឡប់ទៅវិញដោយសេចក្ដីទោមនស្ស ក៏ទុកដូចជាភ្ញៀវនោះទម្លាក់ចោលនូវសេចក្ដីអមង្គលទុកឲ្យអ្នកម្ចាស់ផ្ទះ ហើយនាំយកសេចក្ដីមង្គលចេញទៅផង ។

៦៥ ក្អែកនោះបីជាអ្នកថោកទាប មកដល់ផ្ទះអ្នកមានត្រកូលនោះ ជាអ្នកមានបញ្ញាស័ក្តិខ្ពស់ គួរអ្នកម្ចាស់ផ្ទះទទួលតាមគុណានុរូប ព្រោះក្អែកទាំងអស់មានទេវតាប្រចាំនៅក្នុងខ្លួន ។

ត្មាតតបថា "ឈ្មោះថា ឆ្មាហើយរមែងចូលចិត្តស៊ីមំសៈជាអាហារ, នៅលើដើមឈើនេះមានកូនសត្វជាច្រើន ព្រោះហេតុនោះ ទើបយើងនិយាយដំទាស់ផ្លូវច្នោះ" ។

ឆ្មាបានស្តាប់ហើយទើបឱនក្បាលចុះទល់ដី ពោលថា បំណែកខ្ញុំ (ខុសនឹងឆ្មាធម្មតា) ព្រោះបានសមាទានសីលចន្ទ្រាយណៈ ដោយសេចក្តីព្យាយាមដ៏ក្លា ទាល់តែជាវីតកគៈប្រាសចាកសេចក្តីដំរេកត្រេកអរ បានសិក្សាគម្ពីរព្រះធម្មសាស្ត្រចប់ ។ រីឯព្រះគម្ពីរនៃព្រះជាម្ចាស់នោះ ទោះនឹងមានសេចក្តីខុសប្លែកចំឡែកទទឹងទាស់គ្នាខ្លះ ក៏ត្រឹមតែបន្តិចបន្តួច តែត្រង់សេចក្តីសំខាន់ រមែងត្រង់គ្នាទាំងអស់ គឺ អហិង្សាបរមធម៌ ធម៌មានការមិនបៀតបៀនគ្នាជាកំពូល ព្រោះ-

៦៦ អ្នកណាវៀរចេញឲ្យអ្នកដទៃក្តៅក្រហាយ អ្នកណាបានសេចក្តីព្យាយាមអត់ធន់នឹងសភាវៈទាំងពួង និងជាទីពឹងពំនាក់នៃសត្វទាំងឡាយ, អ្នកនោះរមែងដំណើរចូលទៅកាន់ផ្លូវសួគ៌ ។

៦៧ សេចក្ដីល្អប៉ុណ្ណោះ ដែលជាមិត្រជិតដោយតាមខ្លួនទៅបាន ដោយពិតក្នុងយាមដែលអស់ជីវិត, ចំណែកឯរបស់ដទៃ ៗ ក្រៅអំពីនោះ ក៏ដល់នូវសេចក្ដីទំលាយអន្តរាយព្រមជាមួយនឹងរាងកាយ ។

៦៨ អ្នកដែលទិញស៊ីគេ គួរជារលឹកឲ្យបានថា យើងនឹងអ្នកដែល យើងស៊ីនោះខុសគ្នា អ្នកស៊ីបានឆ្អែតពោះតែមួយរំពេច, តែអ្នកដែលត្រូវ បង់សាច់ រមែងបានទុក្ខវេទនាដល់ក្ស័យជីវិត ។

៦៩ ទុក្ខអំបាលណា កើតប្រាកដដល់មនុស្សដែលឃើញថា សូម្បី ខ្លួនក៏គោងស្លាប់ដែរ កាលអនុមានទុក្ខអំបាលនោះមកធៀបនឹងខ្លួនហើយ ទោះបីជាសត្រូវនឹងគ្នាក៏អាចជួយការពារអន្តរាយឲ្យគ្នាបាន ។

៧០ អ្នកណាឡើយនឹងសុខចិត្តកការអកុសល ព្រោះឃើញផល ពោះដែលស្រេកឃ្លាន ប្រសិនជាឃ្លាន លតាស្មៅព្រៃដែលដុះឯងក្នុង ព្រៃជរជាសក៏អាចនឹងចំអែតពោះឲ្យឆ្អែតបានដែរ ។

លុះវិឡារនិយាយសម្រួលឲ្យត្មាតបាត់សន្ទុះហើយ ក៏ចូលទៅអាស្រ័យនៅក្នុងរូងឈើ ។ ថ្ងៃតមក ឆ្មាក៏លបចាប់កូនសត្វអំបាលនោះមក ស៊ីរាល់ ៗ ថ្ងៃ ។ ចំណែកសត្វទាំងឡាយ ក៏សោយសោកក្ដៅក្រហាយ ដោយហេតុកូនរបស់ខ្លួនរលោះបាត់ទៅរាល់ថ្ងៃ ទើបនាំគ្នាស្រាវជ្រាវរក

ហេតុឯណោះឯណេះ ៗ ឆ្មាកាលដឹងទេម្រោយក៏លបគេចចេញចាកទីនោះ ក្រោយនោះពួកបក្សីទាំងឡាយស្រាវជ្រាវទៅស្រាវជ្រាវមក ក៏ប្រទះឃើញឆ្អឹងកូនខ្លួននៅក្នុងព្រង់ឈើ ក៏សម្រេចសន្និដ្ឋានថា ត្មាតចាស់នេះឯងជាអ្នកស៊ីកូនរបស់ខ្លួន ទើបនាំគ្នាចោមរោមប្រហារត្មាតនោះស្លាប់, ព្រោះហេតុនោះខ្ញុំ (ក្អែកសុពុទ្ធិ) ទើបថា អ្នកណាក៏ដោយ ដែលយើងមិនបានស្គាល់ជាតិត្រកូលនឹងនិស្ស័យ ។ល។ កុំគប្បីគប់ (៤៨) ។

(មានតទៀត)

# រឿងព្រេង-បុរសផ្កាប់ត្រឡោក

និយាយរឿងមួយមានសេដ្ឋីប្តីប្រពន្ធមានកូនក្រមុំមួយនាក់មានរូបឆោមល្អណាស់ បណ្តាជនកំឡោះប៉ុន្មានៗជាច្រើនឈ្មោះស្ម័គ្រស្រឡាញ់បានជំកបមាតាបិតាឲ្យទៅដណ្តឹងកូនក្រមុំមហាសេដ្ឋីៗ នោះក៏ឥតប្រកែកព្រមឲ្យ តែមានខសន្យាថា បើកំឡោះឈ្មោះណាចង់បានឲ្យសង់ផ្ទះ៥ល្វែងតែមួយថ្ងៃឲ្យហើយ បើធ្វើមិនហើយ សេដ្ឋីនោះផ្តាច់មិនឲ្យកូនក្រមុំ ៗ កំឡោះដទៃប៉ុន្មានៗខូចខាតជំនូនជាច្រើននាក់ ដោយធ្វើផ្ទះមួយថ្ងៃមិនហើយ សេដ្ឋីក៏ផ្តាច់មិនឲ្យកូនក្រមុំ ខណៈនោះមានកំឡោះម្នាក់ជាអ្នកមានគំនិតគិតឧបាយកលប្រាជ្ញ ឈ្មោះហៅថា អាផ្កាប់ត្រឡោក ជាកូនអ្នកមានគ្រាន់បើ បានសុំប្រាក់មាតាបិតាយកទៅទិញឈើលបធ្វើប្រុងប្រៀបគ្រប់ប្រដាប់ផ្ទះហើយស្រេច រួចកោសរូសខាត់ត្រឡោកស្អាតហើយជំកបមាតាបិតាឲ្យទៅដណ្តឹងកូនក្រមុំមហាសេដ្ឋីនោះ ឯមាតាបិតាក៏ទិញផ្លែឈើមើមឈើបានច្រើនគុ ហើយពឹងញាតិសន្តានឲ្យជួយកាន់ជំនូននោះទៅដល់ផ្ទះមហាសេដ្ឋីប្រណម្យសំពះជំកបថា ខ្ញុំបាទមកសូមដណ្តឹងកូនក្រមុំលោកផ្សំផ្គុំនឹងកូនប្រុសកំឡោះខ្ញុំបាទនាងខ្ញុំ ទោះបីខុសត្រូវសូមលោកសេដ្ឋីអភ័យទោស សូមឲ្យបានជាសាច់សន្តានតរៀងទៅ ៗ

សេដ្ឋីទាំងប្តីប្រពន្ធស្តាប់ហើយឆ្លើយថា យើងឥតប្រកែកថាអ្វីទេអ្នក តែថាថ្ងៃស្អែកនេះអ្នកធ្វើផ្ទះ៥ល្វែងឲ្យហើយស្រេច បើធ្វើមិនហើយយើង

កុំផ្តាច់មិនឲ្យកូនក្រមុំ ។ ឯមាតាបិតាអាផ្កាប់ត្រឡោកឮហើយជំរាបថា បើកូនខ្ញុំធ្វើផ្ទះថ្ងៃស្អែកនេះមិនហើយស្រេចទេ សូមលោកសេដ្ឋីផ្តាច់កុំឲ្យកូនក្រមុំលោកចុះ ជំនូនប៉ុន្មានតុនេះខ្ញុំបាទនាងខ្ញុំក៏សុខចិត្តជូនលោកទាំងអស់ឥតគិតយកថ្លៃពីលោកឡើយ ហើយជូនជំនូនទាំងអស់ទៅសេដ្ឋី ។ ក៏ឲ្យខ្ញុំកំដរលើកទៅផ្ទុំទុកពេញមួយល្វែងផ្ទះ ក៏យកសម្បកតុជាសមកឲ្យនោះមាតាបិតាអាផ្កាប់ត្រឡោកទទួលតុជាសគ្រប់ចំនួនហើយ ក៏សំពះលាមហាសេដ្ឋីនាំគ្នាត្រឡប់មកផ្ទះវិញ ។

ក្រោយនោះមហាសេដ្ឋីនិងភរិយា នាំគ្នាទៅមើលជំនូននៅលើផ្ទះនោះសុទ្ធតែផ្លែឈើមានដំឡៃប្លែក ៗ ពីប្រទេសឆ្ងាយខ្លះ នៅស្រុកអាយខ្លះ សេដ្ឋីក៏ញញឹមញញាក់មុខនឹងប្រពន្ធថា ជំនូននេះយើងមុខជាបានស៊ីទទេទៀតហើយ ។

ចំណែកមាតាបិតាអាផ្កាប់ត្រឡោកទៅដល់ផ្ទះក៏និយាយប្រាប់កូនថា សេដ្ឋីព្រមឲ្យហើយ ។ សេដ្ឋីថា ឲ្យកូនធ្វើផ្ទះតែក្នុងថ្ងៃស្អែកនេះឲ្យហើយស្រេច អាផ្កាប់ត្រឡោកឮមាតាបិតានិយាយប្រាប់ដូច្នោះមានចិត្តត្រេកអរណាស់ជំរាបមាតាបិតាថា លោកម៉ែលោកឪកុំព្រួយបារម្ភមុខជាបានដូចគំនិតដែលកូនគិតទុកពីថ្ងៃមុននោះ ហើយអាផ្កាប់ត្រឡោកក៏ទៅនិយាយពឹងបងប្អូនអ្នកដែលចេះការធ្វើផ្ទះបានគ្នាច្រើន ឲ្យគេជួយសង់ផ្ទះតែក្នុងថ្ងៃស្អែកនេះឲ្យហើយ បងប្អូនគេទទួលជួយទាំងអស់គ្នា អាផ្កាប់ត្រឡោក

ត្រឡប់មកផ្ទះវិញក៏ស្លៀកពាក់តែងខ្លួនស្អាតបាត ពឹងកំលោះផងគ្នាឲ្យជូនទៅផ្ទះសេដ្ឋីនោះ លុះដល់ឡើងទៅលើផ្ទះសេដ្ឋីៗសួរថា ចៅឯងមកមានការអ្វី ៗ នោះអាផ្កាប់ត្រឡោកលុតជង្គង់ប្រណម្យជំរាបសេដ្ឋីថា លោកម៉ែលោកឪខ្ញុំប្របាទ បើខ្ញុំប្របាទជាកូនឲ្យមកសូមក្រាបប្រណិប័តន៍លោកឪពុកម្តាយសូមមានប្រាប់ទីកន្លែងត្រង់ណាឲ្យបានខ្ញុំប្របាទសង់ផ្ទះ ខ្ញុំប្រ-បាទនឹងអាលទៅចាប់ការធ្វើក្រែងមិនហើយជូនលោកម្តាយឪពុកក្នុងវេលាថ្ងៃស្អែកនេះ ៗ

នោះសេដ្ឋីទាំងប្តីប្រពន្ធគន់មើលរូបឫកអាផ្កាប់ត្រឡោកនឹកក្នុងចិត្តសរសើរថា កូនប្រសាអញគ្រាន់បើដែរ តែថាមុខជាខូចខាតជំនួនដូចអាមុន ៗ ទៀតហើយ ៗ សេដ្ឋីប្រាប់ទីកន្លែងឲ្យសង់នៅទិសខាងជើងឲ្យឆ្ងាយពីផ្ទះធំចំនួន ៥ ម៉ែត្រ ៗ

ឯអាផ្កាប់ត្រឡោកបានឮសេដ្ឋីប្រាប់ជាក់ហើយក្រាបសំពះលានាំគ្នាត្រឡប់ទៅផ្ទះវិញ លុះដល់ប្រមូលបងប្អូនជួបជុំព្រម គ្រឿងផ្ទះណាដែលធ្ងន់ៗផ្ទុកដាក់រទេះឲ្យស្រេចពីយប់ របស់ណាល្មមគួរលីសែងក៏ចាត់ចែងផ្គរផ្គង់ដាក់មុខគ្នាស្រេច ៗ

លុះព្រឹកឡើងខ្លះដឹករទេះខ្លះលី-សែងទៅដល់ផ្ទះសេដ្ឋី ខ្លះកាប់ដីខ្លះជីករណ្តៅសសរតាមខ្នាតទំហំផ្ទះ ៥ ល្វែង ខំធ្វើស្រុះស្រួលគ្នាមិនឈប់ ៗ តែពេលបរិភោគបាយ បរិភោគបាយរួចនាំគ្នាធ្វើទៀត លុះតែ

ហើយស្រេចក្នុងវេលាថ្ងៃនោះ រួចអាផ្កាប់ត្រឡោកឡើងទៅលុតជង្គង់សំពះជូនផ្ទះមហាសេដ្ឋីជាមាតាបិតាក្មេក ហើយនាំគ្នាត្រឡប់ទៅផ្ទះវិញ ។

លុះដល់ថ្ងៃខែបាន់ឫក្សល្អ មាតាបិតាទាំងសងខាងក៏រៀបវិវាហមង្គលការកូនរួចស្រេច ឯអាផ្កាប់ត្រឡោកលាក់តែត្រឡោកមិនឲ្យឈ្មោះណាឃើញសោះ ដល់ពេលយប់រៀបសែនផ្សំដំណេករួចហើយក៏ដេកនៅក្នុងផ្ទះជាមួយគ្នា អាផ្កាប់ត្រឡោកយកត្រឡោកនោះទៅផ្កាប់គ្របពីលើស្វាស រួចស្មៀកសំពត់ចងក្បិនប្រយ័ត្នមិនឲ្យត្រឡោកធ្លាក់បាន ហើយដេកឃ្លាតពីភរិយា ធ្វើភរិយាសំងំមិនបានពាល់ដល់ចុងដៃ-ជើងភរិយានោះឡើយ ប្រើឧបាយយ៉ាងនេះ អត់ធន់បាន ៣-យប់ ។ ក្រោយទៀតនាងភរិយានោះសោប់សល់ខ្វល់ចិត្តគិតសង្ស័យថា ប្ដីអញនេះដេកនៅជាមួយគ្នាបួយប់ហើយ គាត់ធ្វើព្រងើយកន្តើយហាក់ដូចជាគ្មានដំរេកត្រេកត្រង់នឹងអញសោះ ជាគាត់ខ្ទើយឬក្សយលិង្គ គិតក្នុងចិត្តដូច្នោះហើយក៏ប្រថុយចង់ដឹងលបលូកស្ទាបឲ្យច្បាស់ ។

ឯអាផ្កាប់ត្រឡោកដេកពុំលក់ធ្វើជាស្រមុកខ្វិល ៗ នាងប្រពន្ធនោះលូកដៃស្ទាបត្រង់កន្ទៃងស្វាស នោះពានទៅលើត្រឡោកផ្កាប់លើងណាំលដកដៃមកវិញគិតថា ប្ដីអញនេះនឹងជាខ្ទើយឬក្សយលិង្គក៏មិនមែនសណ្ឋានហាក់ដូចជាកើតស្រី តែជាទាស់គ្មានប្រឡាយមុខគួរឲ្យឆ្ងល់ ។

លុះព្រឹកឡើងខ្សឹបនិយាយប្រាប់ម្ដាយ តាមដំណើរដែលលបស្ដាប់ប្ដីសព្វគ្រប់ ម្ដាយក៏ហើយដកដង្ហើមធំថា ឱកូនអញអើយ ប៉ុនប្ដីអឹក មិនដូចបុរសទាំងពួង ហើយនឹកបន្ទោសកូនប្រសាប្រុសនោះថា បើឯងគ្មានប្រាជ្ញាដូចប្រុសទាំងពួងទេ ហេតុម្ដេចក៏ស្រឡាញ់កូនអញអម្ល៉េះ គិតហើយក៏ជំរាបសេដ្ឋីជាប្ដីតាមដំណើរកូនស្រីប្រាប់សព្វគ្រប់ សេដ្ឋីស្ដាប់ហើយគិតថា បើអញនិយាយខ្លាំងខ្មាសគេផ្ទះជិតខាង ហើយក៏និយាយខ្សឹបខ្សៀវប្ដីប្រពន្ធថា កូនប្រសាយើងនេះវាគ្រាន់បើដែរ ណ្ហើយគេហ៍ យើងអាណិតវា ឲ្យប្រាក់ថ្លៃពស្ដុការបណ្ណាការ ទិញថ្លៃផ្ទះមួយពាន់ប្រាំរយណែនឲ្យទៅវា ហើយប្រាប់ឲ្យទៅនៅម៉ែឪវាវិញចុះ គិតព្រមគ្នាហើយហៅកូនប្រសាថា ដីឯងមកឯណេះ អាផ្កាប់ត្រឡោកក៏សេដ្ឋីឪពុកក្មេកម្ដាយក្មេកហៅខ្ញុំហើយ ក៏ទៅអង្គុយជិតសំពះសេដ្ឋីៗថា ឯងកិរិយាហាក់ដូចជាមិនស្រឡាញ់កូនអញ ណ្ហើយចុះអញឲ្យប្រាក់មួយពាន់ប្រាំរយណែន ឯងយកទៅនៅផ្ទះឪពុកម្ដាយឯងវិញចុះ រួចកប់ប្រាក់ប្រគល់ឲ្យគ្រប់ចំនួន អាផ្កាប់ត្រឡោកទទួលយកប្រាក់ហើយជំរាបថា លោកឪពុកខ្ញុំបាទសុំហឹបធំ ១ ដាក់ប្រាក់ដែលឲ្យខ្ញុំបាទ ហើយសូមទានឲ្យបាវប្រុស ១ ជួយសែងយកប្រាក់ទៅផ្ទះខ្ញុំបាទផង សេដ្ឋីក៏ឲ្យហឹបដាក់ប្រាក់ចាត់បាវឲ្យសែងតាមអាផ្កាប់ត្រឡោកទៅដល់ផ្ទះ ហើយជូនប្រាក់មួយពាន់ប្រាំរយណែន ដែលនៅក្នុងហឹបទៅមាតាបិតាជំរាប

រឿងសព្វគ្រប់ ក៏ត្រឡប់មកផ្ទះសេដ្ឋីវិញ លុះដល់អាផ្កាប់ត្រឡោកធ្វើឫកកិរិយាសញ្ជប់សញ្ជឹងហាក់ដូចជារលឹកអាល័យសេដ្ឋីនិងកិរិយានោះពន់ពេក ។

សេដ្ឋីឃើញហើយសួរថា ឯងអញឲ្យប្រាក់ទៅនៅផ្ទះម៉ែឪឯងវិញ ហេតុម្ដេចក៏មិនទៅ ។

ឯអាផ្កាប់ត្រឡោកឆ្លើយជំរាបសេដ្ឋីថា ខ្ញុំបាទរលឹកអាល័យលោកម៉ែលោកឪនឹងនាងជាកិរិយាខ្លាំងណាស់ សុំនៅទទួលដំណេកតែមួយយប់នេះទៀត ព្រឹកឡើងខ្ញុំបាទសូមប្រណិប័តន៍លាទៅផ្ទះវិញ ។

សេដ្ឋីប្ដីប្រពន្ធនិយាយគ្នាថា យើងឲ្យវាដេកមួយយប់ទៀតចុះ វាមិនទាន់ជាអ្វីទេ ដូចជាដេកជាមួយនឹងប្រុសដងគ្នា លុះដល់ពេលយប់បរិភោគបាយរួច អាផ្កាប់ត្រឡោកក៏ចូលទៅដេកជាមួយនឹងកិរិយា ត្រឡោកក៏ផ្កាប់ដដែល នោះនាងកិរិយាដល់យប់ជ្រៅគិតថា យប់ស្អែកនេះប្ដីអញទៅនៅផ្ទះគាត់វិញហើយ អញចង់ស្ទាបសង្កេតឲ្យច្បាស់ ៗ ឯអាផ្កាប់ត្រឡោកដេកផ្ការពុំលក់កើតមានសេចក្ដីដំរេកជាខ្លាំង ប៉ះដូចជាគេទូលត្រឡោក នាងកិរិយានោះលូកដៃទៅបះលើត្រឡោក ៗ ធ្លាក់ព្រួសរ្វាតខូស អាផ្កាប់ត្រឡោកឆាកផាងខិតចូលទៅរួមសេនឹងនាងកិរិយានោះ ដោយកំឡោះកំឡាំងក្លា កិរិយាក៏ក្រមុំរើរិតប្រតិព័ទ្ធគ្នាទៅវិញទៅមកពន់ប្រមាណ ។

លុះព្រឹកឡើងនាងនោះនិយាយជំរាបមាតាថា ម៉ែបើប្ដីខ្ញុំលាទៅផ្ទះវិញ សូមម៉ែអាណិតកូនឃាត់កុំឲ្យទៅ មាតាសង្ស័យណាស់សួរកូន ៗ និយាយខ្សឹបជំរាបមាតាថា ម៉ែប្ដីខ្ញុំគាត់មានប្រដាប់ដូចប្រុសទាំងពួងមិនមែនជាខ្ទើយឡើយ ។

ឯម្ដាយនោះដឹងចិត្តកូនហើយ ក៏ខ្សឹបនិយាយជំរាបសេដ្ឋីជាប្ដីដោយស្ងាត់ថា កូនយើងទាំងពីរត្រូវចិត្តគ្នាហើយ ។

សេដ្ឋីពុករិយានិយាយប្រាប់ពីរឿងក្ដីសព្វគ្រប់ក៏តបថា កាលមុនគេហ៍ឯងនិយាយប្រាប់អញ ៗ ក៏ជឿថា ពិតមែន អញបានសង់ថ្លៃពស្ដុការបណ្ណាការទឹងថ្លៃផ្ទះមួយពាន់ប្រាំរយណែនឲ្យទៅវា ឥឡូវថា កូនប្រសាយើងមានប្រដាប់ដូចប្រុសទាំងពួង ណ្ហើយចុះគេហ៍ បើវាត្រូវចិត្តគ្នាហើយប្រាក់ដែលយើងឲ្យទៅកូនប្រសានោះដូចជាឲ្យទៅកូនយើងទេ ប្ដីប្រពន្ធវាមានក្រជាមួយគ្នា សេដ្ឋីក៏ស្ងៀមស្ងាត់រាប់អានជាកូនតរៀងទៅ ។

លុះដល់សេដ្ឋីប្ដីនឹងភរិយាចាស់ជរាមរណភាពទៅវេលាណា ស្ដេចក្រុងព្រះនគរនោះទ្រង់ព្រះមេត្តាប្រោសតាំងអាផ្កាប់ត្រឡោកនឹងភរិយាឲ្យធ្វើជាសេដ្ឋីតាងបិតាលុះអស់ជីវិត ។

« រឿងអាផ្កាប់ត្រឡោកចប់តែប៉ុណ្ណេះ »

ឧកញ៉ាអក្ខរលេខា (ណុប) តែង ។

# ពិធីសូត្រមន្តរំដោះគ្រោះ

ឧកញ៉ាទេពពិទូរ ក្រសេម គន្ធរបនបណ្ឌិត

រៀបរៀង

# ទំនៀមសូត្រមន្តរំដោះគ្រោះ

អ្នកដែលមានជម្ងឺឈឺមកយូរថ្ងៃហើយ រកព្យាបាលដូរច្នេះហើយ ដូរច្នោះហើយមិនជា គេរមែងរកគ្រូហោរ គន់គូរមើលហេតុដែលបណ្ដាលឲ្យឈឺនោះ បើមើលទៅត្រូវថា មានគ្រោះថ្នាក់ នោះគេរមែងនិមន្តលោកមកសូត្រមន្តរំដោះគ្រោះនោះឲ្យបានសះជាស្បើយស្រើយទៅ ។

កម្មកិច្ចនេះត្រូវរៀបរណ្ដាប់ផ្សេងៗ តាមទម្លាប់របស់គ្រូ-អាចារ្យដែលធ្លាប់ធ្វើរៀងមក ក៏ទម្លាប់របស់គ្រូ-អាចារ្យនោះមិនដូចគ្នា, ខ្លះមានគ្រឿងប្រដាប់ច្រើន ខ្លះមានគ្រឿងប្រដាប់តិចសមគួរ ។ ក្នុងទីនេះនឹងរៀបរៀងតាមបែបមធ្យម ល្មមឲ្យអ្នកទីទាល់ក្រធ្វើបានផងដូចមានតទៅនេះ -

ឲ្យរៀបគ្រឿងពុទ្ធបូជា គឺបាយសីប៉ាក់ឆាម ១ គូ ស្លាធម៌ ១ គូ ទឹកអប់ ១ គូ ទៀន ៥ ធូប ៥ លាជ ៥ ផ្កា ៥ ។

នឹងរៀបគ្រឿងបូជាទេវតា គឺស្លាធម៌ ៨ ទឹកអប់ ៨ ឲ្យរៀបដាក់ខាងខ្នងអ្នកជម្ងឺម្ខាង ៤ ។

នឹងធ្វើតែ ៣ ហៅថា "តែមឈូស" បណ្ដោយប្រវែង ១ ហត្ថអ្នកជម្ងឺ ទទឹងប្រវែង ៣ ចំអាមអ្នកជម្ងឺ ឲ្យរៀបដាក់បាយ សំឡ ញាំ ភ្លា នំ ចំណីក្នុងតែនោះតាមទំនៀម នឹងសូនរូប ១ ដោយម្សៅ គឺជារូបស្នងខ្លួនអ្នកជម្ងឺឲ្យរៀបដាក់ក្នុងតែ, នឹងមានប្រឫស្សីស្រួចប្រមាណ ៣ ក្ដាប់ទុកនឹងដុតរូបនោះ ។ សំពត់សប្រវែង ៥ ហត្ថអ្នកជម្ងឺ ។ នឹងមានអង្ករពល់ដោយនាឡិ

ឬដោយតានតូច ៗ ចំនួនស្មើនឹងអាយុអ្នកជម្ងឺ បើមានសេសខែថ្ងៃប៉ុន្មាន ឲ្យកល់ប៉ុណ្ណោះដាក់ទៅទៀត ៗ នឹងកល់ទឹកអប់សំបួរចំនួនដូចគ្នានេះដាក់ក្នុងផ្តិលធំ ១ នឹងមានពូនកុំខ្សាច់ ១ ដាក់នៅថាស ៗ

របស់អំបាលនេះឲ្យយកទៅរៀបដាក់នៅមុខកន្ទេលលោកសូត្រមន្ត ៗ ដល់វេលានិមន្តលោកមកសូត្រមន្តមុននឹងសូត្រមន្តអាចារ្យរៀបសែនប្រ-បេះគ្រោះថ្នាក់នោះឲ្យស្បើយល្ហើយ ហើយយកភ្លើងអុចប្រឹប្ដស្បូវដុតរូបម្សៅនោះជាបតិច្ចថា បានដុតរូបអ្នកជម្ងឺនោះហើយ ហើយជូនពែនោះទៅតាមទិសដែលអាចារ្យបង្គាប់ ៗ

## ពាក្យសែន

អញខ្ញុំសូមអញ្ជើញទេវតា នូវព្រះបរមេស្វរ ព្រះពិស្ណុការ ព្រះម្រឹត្យូវ, ព្រះកាលៈ, ទើបអញ្ជើញព្រះអាទិត្យ ព្រះចន្ទ្រ, ព្រះអង្គារ, ព្រះពុធ, ព្រះព្រហស្បតិ៍, ព្រះសុក្រ, ព្រះសៅរ៍, ព្រះរាហូ, ព្រះកេតុ ៗ ទើបអញ្ជើញនូវបូព៌-ព្រះរាម អគ្នេយ៍-ខរ, ទក្សិណ-ព្រះលក្សណ៍, និរតី-ពតណ៍, បស្ចិម-សិតា, ពាយព្យ សិតាយុ ឧត្តរ-ហាណុមាន, ឥសាណ-ពិភេក, ទើបអញ្ជើញអ្នកមកយកក្រយាបូជា អញខ្ញុំសូមស្មាហោទោសអ្នកហោង ៗ ទោះឈើក្បាលក្បូរ ឈើក ឈើទ្រូង សាច់ស្អូតហឫទ័យ

តោះឈើជើងដៃ សរសៃពេគា សូមស្មាលាទោសកុំអ្នកប្រកួត តោះឈើថ្កាត់ចុះ រមួតរមួល ចង្អោរក្អែរក្អួត តោះឈើជោតចាក់ ឈឺច្រាក់សាច់ស្លួត បំពង់កស្ងួតខាន់ខះទឹកមាត់ ទើបអញ្ជើញអ្នក លំដោះគ្រោះដម្កាត់ពេគាឲ្យបាត់វិនាសទៅហោង បពិត្រវឹងថ្វាត់ ទៅដោយស្ពានទីទៃហោង ឱម នមោ ពុទ្ធស្ស នមោ ធម្មស្ស នមោ សង្ឃស្ស ហុលោ ហុលោ ស្វាហាយ ចរណាយចេញទៅ ។

លំដាប់នោះគេរៀបសូត្រមន្ត គឺសូត្រធម៌យោងគ្រោះ តាមទម្លាប់ដែលសូត្ររៀនមកហោង ។